# ព្រះ
# ត្រៃបិដកបាលី
នឹង
សេចក្តីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
ខុទ្ទកនិកាយ ខុទ្ទកបាឋ,ធម្មបទគាថា
ឧទាន,បឋមភាគ
# ៥២

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ
ព.ស ២៥០០

សុត្តន្តបិដក ខុទ្ទកនិកាយ

ខុទ្ទកបាឋ ធម្មបទគាថា ឧទាន

បឋមភាគ

៥២

ព. ស. ២.៥០០

# សុត្តន្តបិដកេ

## ខុទ្ទកនិកាយស្ស ខុទ្ទកបាឋោ

## បឋមោ ភាគោ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## ខុទ្ទកបាឋេ សរណគមនំ[១]

(១) ពុទ្ធំ សរណំ គច្ឆាមិ ធម្មំ សរណំ គច្ឆាមិ សង្ឃំ សរណំ គច្ឆាមិ ។ ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ ។ តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ តតិយម្បិ ធម្មំ សរណំ គច្ឆាមិ តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ ។

សរណគមនំ[២] និដ្ឋិតំ ។

## ខុទ្ទកបាឋេ ទសសិក្ខាបទំ

(២) បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ ។ អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ ។

---

១ ម.យ. សរណត្តយំ ។ ២ ម.យ. សរណត្តយំ ។

# សុត្តន្តបិដក

## ខុទ្ទកនិកាយ ខុទ្ទកបាឋ

## ភាគទី១

សូមនមស្ការព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។

## ខុទ្ទកបាឋ សរណគមន៍

[១] ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹង ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីពឹង ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹង ។ ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹង ជាគំរប់ពីរដងផង ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីពឹង ជាគំរប់ពីរដងផង ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹង ជាគំរប់ពីរដងផង ។ ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹង ជាគំរប់បីដងផង ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីពឹង ជាគំរប់បីដងផង ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹង ជាគំរប់បីដងផង ។

ចប់ សរណគមន៍ ។

## ខុទ្ទកបាឋ សិក្ខាបទ ១០

[២] ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកការសម្លាប់សត្វ ។ ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកការកាន់យក នូវវត្ថុដែលគេមិនបានឲ្យ ។

អព្រហ្មចរិយា វេរមណីសិក្ខាបទំ សមាទិយាមិ ។ មុសាវាទា វេរមណីសិក្ខាបទំ សមាទិយាមិ ។ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ សមាទិយាមិ ។ វិកាលភោជនា វេរមណីសិក្ខាបទំ សមាទិយាមិ ។ នច្ចគីតវាទិតវិសូកទស្សនា វេរមណីសិក្ខាបទំ សមាទិយាមិ ។ មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណីសិក្ខាបទំ សមាទិយាមិ ។ ឧច្ចាសយនមហាសយនា វេរមណីសិក្ខាបទំ សមាទិយាមិ ។ ជាតរូបរជតប្បដិគ្គហណា វេរមណីសិក្ខាបទំ សមាទិយាមិ ។

ទសសិក្ខាបទំ និដ្ឋិតំ ។

## ខុទ្ទកបាឋេ ទ្វត្តឹសាការោ

[៣] អត្ថិ ឥមស្មឹ កាយេ កេសា លោមា នខា



ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកការប្រព្រឹត្តនូវធម៌មិនប្រសើរ ។ ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកការពោលនូវពាក្យកុហក ។ ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ។ ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកការបរិភោគនូវភោជនាហារក្នុងកាលខុស ។ ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកការ រាំ ច្រៀង ប្រគំនិងការមើលល្បែងផ្សេងៗ ដែលជាសត្រូវដល់កុសលធម៌ ។ ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកការទ្រទ្រង់ការប្រដាប់និងការតាក់តែងស្អិតស្អាងនូវកាយ ដោយផ្កាកម្រង គ្រឿងក្រអូបនិងគ្រឿងលាបផ្សេងៗ ។ ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកសេនាសនៈដ៏ខ្ពស់ (ហួសប្រមាណ) និងសេនាសនៈដ៏ប្រសើរ ។ ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកការកាន់យក នូវមាសនិងប្រាក់ ។

ចប់ សិក្ខាបទ ១០ ។

## ខុទ្ទកបាឋ អាការៈ ៣២

(៣) ក្នុងកាយនេះ មានសក់ រោម ក្រចក

ទន្តា តចោ មំសំ ន្ហារុ[១] អដ្ឋិ[២] អដ្ឋិមិញ្ជំ វក្កំ ហទយំ យកនំ កិលោមកំ បិហកំ បប្ផាសំ អន្តំ អន្តគុណំ ឧទរិយំ ករីសំ បិត្តំ សេម្ហំ បុព្វោ លោហិតំ សេទោ មេទោ អស្សុ វសា ខេឡោ សិង្ឃាណិកា លសិកា មុត្តំ[៣] មត្ថកេ មត្ថលុង្គន្តិ[៤] ។

ទ្វត្តឹសាការោ និដ្ឋិតោ ។

## ខុទ្ទកបាឋេ សាមណេរបញ្ហា

(៤) ឯកំ នាម កឹ ។ សព្វេ សត្តា អាហារដ្ឋិតិកា ។ ទ្វេ នាម កឹ[៥] នាមញ្ច រូបញ្ច ។ តីណិ នាម កឹ[៦] តិស្សោ វេទនា ។ ចត្តារិ នាម កឹ ចត្តារិ អរិយសច្ចានិ ។ បញ្ច នាម កឹ បញ្ចុបាទានក្ខន្ធា ។ ឆ នាម កឹ ឆ អជ្ឈត្តិកានិ អាយតនានិ ។ សត្ត នាម កឹ សត្ត ពោជ្ឈង្គា ។ អដ្ឋ នាម កឹ អរិយោ អដ្ឋង្គិកោ មគ្គោ ។ នវ នាម កឹ នវ សត្តាវាសា ។ ទស នាម កឹ ទសហង្គេហិ សមន្នាគតោ អរហាតិ វុច្ចតីតិ ។

សាមណេរបញ្ហា និដ្ឋិតា ។

---

១ ឧ. ម. ន្ហារូ ។ ២ ឧ. ម. អដ្ឋី ។ ៣ ឧ. ម. មុត្តំ ។ មត្ថកេ មត្ថលុង្គន្តិ បាឋោ ឧ. ម. ... ។ ៤ ឧ. មត្ថលុង្គំ ។ ៥ ឧ. ទ្វេ នាម កឹ ... ។ ៦ ឧ. តីណិ-នាម កឹ ... ។



ឈ្មោះ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងនោម បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសំបោរ ទឹករំអិល ទឹកមូត្រ ខួរក្នុងក្បាល ។

ចប់ អាការៈ ៣២ ។

## ខុទ្ទកបាឋ សាមណេរបញ្ហា

(៤) ធម្មជាតឈ្មោះថា ១ គឺអ្វី គឺសត្វទាំងអស់ តាំងនៅដោយអាហារ ។ ធម្មជាតឈ្មោះថាពីរគឺអ្វី គឺនាមនិងរូប ។ ធម្មជាតឈ្មោះថា ៣ គឺអ្វី គឺវេទនា ៣ ។ ធម្មជាតឈ្មោះថា ៤ គឺអ្វី គឺអរិយសច្ច ៤ ។ ធម្មជាតឈ្មោះថា ៥ គឺអ្វី គឺឧបាទានក្ខន្ធ ៥ ។ ធម្មជាតឈ្មោះថា ៦ គឺអ្វី គឺអាយតនៈខាងក្នុង ៦ ។ ធម្មជាតឈ្មោះថា ៧ គឺអ្វី គឺពោជ្ឈង្គ ៧ ។ ធម្មជាតឈ្មោះថា ៨ គឺអ្វី គឺអរិយមគ្គប្រកបដោយអង្គ ៨ ។ ធម្មជាតឈ្មោះថា ៩ គឺអ្វី គឺសត្តាវាស ៩ ។ ធម្មជាតឈ្មោះថា ១០ គឺអ្វី គឺបុគ្គលដែលគេហៅថា ព្រះអរហន្ត ប្រកបដោយអង្គ ១០ ។

ចប់ សាមណេរបញ្ហា ។

(៥) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ គាថាយ អជ្ឈភាសិ ។

(៦) ពហូ ទេវា មនុស្សា ច មង្គលានិ អចិន្តយុំ
អាកង្ខមានា សោត្ថានំ ព្រូហិ មង្គលមុត្តមំ ។
អសេវនា ច ពាលានំ បណ្ឌិតានញ្ច សេវនា
បូជា ច បូជនីយានំ[1] ឯតម្មង្គលមុត្តមំ ។
បដិរូបទេសវាសោ[2] ច បុព្វេ ច កតបុញ្ញតា
អត្តសម្មាបណិធិ ច ឯតម្មង្គលមុត្តមំ ។
ពាហុសច្ចញ្ច សិប្បញ្ច វិនយោ ច សុសិក្ខិតោ
សុភាសិតា ច យា វាចា ឯតម្មង្គលមុត្តមំ ។

១ ម.ម. បូជនេយ្យានំ ។ ២ ម.ម. បតិរូបទេសវាសោ ។



(៥) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ទេវតា ១ អង្គ កាលបើបឋមយាម កន្លងទៅហើយ មានរស្មីដ៏ល្អ ញុំាងវត្តជេតពនទាំងមូលឲ្យភ្លឺស្វាង ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះមានព្រះភាគហើយ ឋិតនៅក្នុងទីសមគួរ ។ លុះទេវតានោះ ឋិតនៅ ក្នុងទីសមគួរហើយ ទើបក្រាបទូលព្រះមានព្រះភាគ ដោយគាថា ។

(៦) ទេវតានិងមនុស្សទាំងឡាយជាច្រើន ប្រាថ្នានូវសួស្តី បានគិតរកមង្គលទាំងឡាយ សូមព្រះអង្គសំដែងប្រាប់នូវមង្គលដ៏ឧត្តម ។ ( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ) ការមិនសេពគប់ពាលជនទាំងឡាយ ១ ការសេពគប់បណ្ឌិតជនទាំងឡាយ ១ ការបូជាចំពោះបុគ្គលដែលគួរបូជាទាំងឡាយ ១ នេះជាមង្គល ដ៏ឧត្តម ។ ការនៅក្នុងប្រទេស ដ៏សមគួរ ១ ភាពនៃបុគ្គលបានធ្វើបុណ្យទុកហើយក្នុងកាលមុន ១ ការដំកល់ខ្លួនប្រពៃ ១ នេះជាមង្គលដ៏ឧត្តម ។ ភាពនៃបុគ្គលបានស្តាប់ បានរៀនច្រើន ១ សិល្បៈគឺសេចក្តីឈ្លាសក្នុងហត្ថកម្ម របស់អ្នកបួសនិងគ្រហស្ថ ១ វិន័យដែលបុគ្គលសិក្សាប្រពៃ ១ វាចាដែលបុគ្គលពោលល្អ ១ នេះជាមង្គល ដ៏ឧត្តម ។

មាតាបិតុ ឧបដ្ឋានំ បុត្តទារស្ស សង្គហោ
អនាកុលា ច កម្មន្តា ឯតម្មង្គលមុត្តមំ ។
ទានញ្ច ធម្មចរិយា ច ញាតកានញ្ច សង្គហោ
អនវជ្ជានិ កម្មានិ ឯតម្មង្គលមុត្តមំ ។
អារតី វិរតី[១] បាបា មជ្ជបានា ច សញ្ញមោ
អប្បមាទោ ច ធម្មេសុ ឯតម្មង្គលមុត្តមំ ។
គារវោ ច និវាតោ ច សន្តុដ្ឋី ច កតញ្ញុតា
កាលេន ធម្មស្សវនំ ឯតម្មង្គលមុត្តមំ ។
ខន្តី ច សោវចស្សតា សមណានញ្ច ទស្សនំ
កាលេន ធម្មសាកច្ឆា ឯតម្មង្គលមុត្តមំ ។
តបោ ច ព្រហ្មចរិយញ្ច អរិយសច្ចានទស្សនំ
និព្វានសច្ឆិកិរិយា ច ឯតម្មង្គលមុត្តមំ ។

១. ម. អារតិ វិរតិ ។



ការបំរើមាតាបិតា ១ សេចក្ដីសង្គ្រោះដល់បុត្រនិងភរិយា ១ ការងារទាំងឡាយ ដែលមិនច្របូកច្របល់ ១ នេះជាមង្គល ដ៏ឧត្ដម ។

ការឲ្យទាន ១ ការប្រព្រឹត្តិធម៌ ១ សេចក្ដីសង្គ្រោះញាតិទាំងឡាយ ១ ការងារទាំងឡាយ ដែលមិនមានទោស ១ នេះជាមង្គល ដ៏ឧត្ដម ។

ការមិនត្រេកអរក្នុងបាបនិងការវៀរចាកបាប ១ សេចក្ដីសង្រួមចាកការផឹកនូវទឹកស្រវឹង ១ សេចក្ដីមិនប្រមាទ ក្នុងធម៌ទាំងឡាយ ១ នេះជាមង្គល ដ៏ឧត្ដម ។

សេចក្ដីគោរព ១ សេចក្ដីទន់ទាន ១ សេចក្ដីត្រេកអរតាមមាន តាមបាន ១ ការដឹងនូវឧបការៈ ដែលអ្នកដទៃធ្វើហើយ ១ ការស្ដាប់នូវធម៌តាមកាល ១ នេះជាមង្គល ដ៏ឧត្ដម ។

សេចក្ដីអត់ធន់ ១ ភាវៈនៃបុគ្គលដែលគេប្រដៅបានដោយងាយ ១ ការជួបប្រទះនូវសមណៈទាំងឡាយ ១ ការសន្ទនាទៅវិញទៅមកនូវធម៌តាមកាល ១ នេះជាមង្គល ដ៏ឧត្ដម ។

សេចក្ដីព្យាយាមដុតនូវបាបធម៌ ១ ការប្រព្រឹត្តិនូវធម៌ដ៏ប្រសើរ ១ ការឃើញនូវអរិយសច្ចទាំងឡាយ ១ ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ១ នេះជាមង្គល ដ៏ឧត្ដម ។

ផុដ្ឋស្ស លោកធម្មេហិ ចិត្តំ យស្ស ន កម្បតិ
អសោកំ វិរជំ ខេមំ ឯតម្មង្គលមុត្តមំ ។
ឯតាទិសានិ កត្វាន សព្វត្ថមបរាជិតា
សព្វត្ថ សោត្ថឹ គច្ឆន្តិ តន្តេសំ មង្គលមុត្តមន្តិ[១]។

មង្គលសុត្តំ និដ្ឋិតំ ។

## ខុទ្ទកបាឋេ រតនសុត្តំ

(៧) យានីធ ភូតានិ សមាគតានិ
ភុម្មានិ វា យានិ វ អន្តលិក្ខេ
សព្វេវ ភូតា សុមនា ភវន្តុ
អថោបិ សក្កច្ច សុណន្តុ ភាសិតំ
តស្មា ហិ ភូតា និសាមេថ សព្វេ
មេត្តំ ករោថ មានុសិយា បជាយ
ទិវា ច រត្តោ ច ហរន្តិ យេ ពលឹ
តស្មា ហិ នេ រក្ខថ អប្បមត្តា ។

១ ម.ឆ. មង្គលមុត្តមំ ។



ចិត្តនៃបុគ្គលណា ដែលលោកធម៌ទាំងឡាយ ពាល់ត្រូវហើយ មិនកម្រើកញាប់ញ័រ ១ ការមិនមានសេចក្តីសោក ១ ធូលីគឺរាគៈទៅប្រាសហើយ ១ ចិត្តក្សេមក្សាន្ត ១ នេះជាមង្គល ដ៏ឧត្តម ។ ទេវតានិងមនុស្សទាំងឡាយ ធ្វើនូវមង្គលទាំងឡាយ ប្រាកដដូច្នេះហើយ ជាអ្នកមិនចាញ់ក្នុងទីទាំងពួង រមែងដល់នូវសួស្តីក្នុងទីទាំងពួង នេះជាមង្គល ដ៏ឧត្តម របស់ទេវតានិងមនុស្សទាំងឡាយនោះ ។

ចប់ មង្គលសូត្រ ។

## ខុទ្ទកបាឋ រតនសូត្រ

[ ៧ ] ពួកភូតណា ឋិតនៅលើផែនដីក្តី ពួកភូតណា ឋិតនៅក្នុងអាកាសក្តី ដែលមកជួបជុំ ក្នុងទីនេះ ពួកភូតទាំងអស់នោះចូរមានចិត្តល្អ មួយទៀត ចូរស្តាប់នូវភាសិតដោយគោរព ព្រោះហេតុនោះ អ្នកទាំងឡាយ ជាភូតទាំងអស់ ចូរស្តាប់ (នូវព្រះបរិត្ត) ចូរធ្វើនូវមេត្តាចិត្តដល់ពពួកសត្វជាមនុស្សជាតិ មនុស្សទាំងឡាយណា តែងនាំមកនូវពលី ក្នុងវេលាថ្ងៃ និងវេលាយប់ ព្រោះហេតុនោះ សូមអ្នកទាំងឡាយ កុំប្រមាទសោះ រក្សានូវមនុស្សទាំងនោះ ។

យំ កិញ្ចិ វិត្តំ ឥធ វា ហុរំ វា
សគ្គេសុ វា យំ រតនំ បណីតំ
ន នោ សមំ អត្ថិ តថាគតេន
ឥទម្បិ ពុទ្ធេ រតនំ បណីតំ
ឯតេន សច្ចេន សុវត្ថិ ហោតុ ។
ខយំ វិរាគំ អមតំ បណីតំ
យទជ្ឈគា សក្យមុនី សមាហិតោ
ន តេន ធម្មេន សមត្ថិ កិញ្ចិ
ឥទម្បិ ធម្មេ រតនំ បណីតំ
ឯតេន សច្ចេន សុវត្ថិ ហោតុ ។
យំ ពុទ្ធសេដ្ឋោ បរិវណ្ណយី សុចឹ
សមាធិមានន្តរិកញ្ញមាហុ
សមាធិនា តេន សមោ ន វិជ្ជតិ
ឥទម្បិ ធម្មេ រតនំ បណីតំ
ឯតេន សច្ចេន សុវត្ថិ ហោតុ ។
យេ បុគ្គលា អដ្ឋ សតំ បសត្ថា





ទ្រព្យណាមួយ ក្នុងលោកនេះក្តី ក្នុងលោកដទៃក្តី រតនៈដ៏ឧត្តមណា ក្នុងឋានសួគ៌ក្តី ទ្រព្យនឹងរតនៈទាំងនោះឯង ស្មើដោយព្រះតថាគត មិនមានឡើយ រតនៈគឺព្រះពុទ្ធនេះឯង ជារតនៈដ៏ឧត្តម ដោយសច្ចៈនេះ សូមមានសិរីសួស្តី ។

ព្រះសក្យមុនី ទ្រង់មានព្រះទ័យដ៏តម្កល់មាំ បានត្រាស់ដឹងហើយនូវព្រះធម៌ណា ជាទីក្ស័យទៅនៃកិលេស ជាទីប្រាសចាកតម្រេក ជាធម៌មិនស្លាប់ ជាធម៌ឧត្តម រតនៈដទៃមួយស្មើដោយព្រះធម៌នោះមិនមាន រតនៈគឺព្រះធម៌នេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។

ព្រះពុទ្ធជាបុគ្គលប្រសើរ ទ្រង់សរសើរនូវសមាធិណា ថាជាធម៌ដ៏ស្អាត បណ្ឌិតទាំងឡាយ តែងហៅហើយនូវសមាធិណា ថាជាធម៌ឲ្យផល ដោយលំដាប់ សមាធិដទៃស្មើដោយសមាធិនោះមិនមានឡើយ រតនៈគឺព្រះធម៌នេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។

បុគ្គលទាំងឡាយណា ៨ពួក ដែលគួរសប្បុរស សរសើរហើយ

ចត្តារិ ឯតានិ យុគានិ ហោន្តិ
តេ ទក្ខិណេយ្យា សុគតស្ស សាវកា
ឯតេសុ ទិន្នានិ មហប្ផលានិ
ឥទម្បិ សង្ឃេ រតនំ បណីតំ
ឯតេន សច្ចេន សុវត្ថិ ហោតុ ។
យេ សុប្បយុត្តា មនសា ទឡ្ហេន
និក្កាមិនោ គោតមសាសនម្ហិ
តេ បត្តិបត្តា អមតំ វិគយ្ហ
លទ្ធា មុធា និព្វុតិំ ភុញ្ជមានា
ឥទម្បិ សង្ឃេ រតនំ បណីតំ
ឯតេន សច្ចេន សុវត្ថិ ហោតុ ។
យថិន្ទខីលោ បឋវឹ សិតោ សិយា
ចតុព្ភិ វាតេភិ[១] អសម្បកម្បិយោ
តថូបមំ សប្បុរិសំ វទាមិ
យោ អរិយសច្ចានិ អវេច្ច បស្សតិ

១ ម. ឆ. វាតេហិ ។



គប់ជាគូបាន ៤ គូ បុគ្គលទាំងឡាយនោះ ជាសាវ័ករបស់ព្រះសុគត លោកគួរដល់ទក្ខិណាទាន ទានទាំងឡាយ ដែលបុគ្គលឲ្យហើយ ចំពោះទក្ខិណេយ្យបុគ្គលទាំងឡាយនោះ ជាទានមានផលច្រើន រតនៈគឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។

អរិយបុគ្គលទាំងឡាយណា ក្នុងសាសនា នៃព្រះសម្ពុទ្ធព្រះនាមគោតម ប្រកបព្រមល្អហើយ មានចិត្តខ្ជាប់ខ្ជួន ឥតមានសេចក្តីប្រាថ្នាឡើយ អរិយបុគ្គលទាំងឡាយនោះ ដល់ហើយនូវអរហត្តផល សម្រេចហើយនូវព្រះនិព្វានបាននូវការរលត់កិលេសដោយទទេ ( ឥតមានទិញដូរឡើយ ) ហើយទទួលនូវផល រតនៈគឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម. ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។

សសរគោល ដែលគេបោះភ្ជាប់នឹងផែនដី ជាប់រឹងមាំមិនកក្រើកញាប់ញ័រដោយខ្យល់ព្យុះ ដែលបក់មកអំពីទិសទាំង ៤ យ៉ាងណាមិញ អ្នកណាពិចារណាឃើញ នូវអរិយសច្ចៈទាំងឡាយ

ឥទម្បិ សង្ឃេ រតនំ បណីតំ
ឯតេន សច្ចេន សុវត្ថិ ហោតុ ។
យេ អរិយសច្ចានិ វិភាវយន្តិ
គម្ភីរបញ្ញេន សុទេសិតានិ
កិញ្ចាបិ តេ ហោន្តិ ភុសប្បមត្តា(១)
ន តេ ភវំ អដ្ឋមមាទិយន្តិ(២)
ឥទម្បិ សង្ឃេ រតនំ បណីតំ
ឯតេន សច្ចេន សុវត្ថិ ហោតុ ។
សហាវស្ស ទស្សនសម្បទាយ
តយស្សុ ធម្មា ជហិតា ភវន្តិ
សក្កាយទិដ្ឋិ វិចិកិច្ឆិតញ្ច
សីលព្វតំ វាបិ យទត្ថិ កិញ្ចិ
ចតូហបាយេហិ ច វិប្បមុត្តោ

---

(១) ម. ភុសប្បមត្តា ។ (២) ឧ. ម. អដ្ឋមំ អាទិយន្តិ ។



តថាគតហៅអ្នកនោះ ថាជាសប្បុរស (មិនញាប់ញ័រដោយលោក-ធម៌ទាំងឡាយ) ដូចសសរគោលដ៏ធ្ងន់ឯង រតនៈគឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។ អរិយបុគ្គលទាំងឡាយណា ធ្វើឲ្យជាក់ច្បាស់ នូវអរិយសច្ចទាំងឡាយ ដែលព្រះតថាគត ព្រះអង្គមានប្រាជ្ញាដ៏ជ្រាលជ្រៅ សំដែងប្រៀបហើយ អរិយបុគ្គលទាំងនោះ ទុកជាប្រមាទដ៏លើសលប់ក៏ដោយ អរិយបុគ្គលទាំងនោះ គង់មិនកាន់យកភពជាគំរប់ ៨ គឺមិនកើតទៀតក្នុងភពទី ៨ ជាដាច់ឡើយ រតនៈគឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។ (សំយោជនក្តីលេស ៣ យ៉ាងគឺ) សក្កាយទិដ្ឋិ វិចិកិច្ឆា និងសីលព្វត-បរាមាសៈណាមួយ ធម៌ទាំងឡាយ ៣ នោះ សោតាបន្នបុគ្គលនោះ បានលះបង់ហើយ ជាមួយនឹងទស្សនសម្បទា គឺសោតាបត្តិមគ្គ មួយទៀត សោតាបន្នបុគ្គល រួចស្រឡះចាកអបាយទាំង ៤ ផង

ឆ ចាភិឋានានិ អភព្វោ កាតុំ(១)
ឥទម្បិ សង្ឃេ រតនំ បណីតំ
ឯតេន សច្ចេន សុវត្ថិ ហោតុ ។
កិញ្ចាបិ សោ កម្មំ ករោតិ(២) បាបកំ
កាយេន វាចាយុទ(៣) ចេតសា វា
អភព្វោ សោ តស្ស បដិច្ឆាទាយ(៤)
អភព្វតា ទិដ្ឋបទស្ស វុត្តា
ឥទម្បិ សង្ឃេ រតនំ បណីតំ
ឯតេន សច្ចេន សុវត្ថិ ហោតុ ។
វនប្បគុម្ពេ យថា ផុស្សិតគ្គេ
គិម្ហានមាសេ បឋមស្មឹ គិម្ហេ
តថូបមំ ធម្មវរំ អទេសយិ
និព្វានគាមឹ បរមំ ហិតាយ
ឥទម្បិ ពុទ្ធេ រតនំ បណីតំ
ឯតេន សច្ចេន សុវត្ថិ ហោតុ ។

១ ម. អភព្វកាតុំ ។ ២ ម. កម្មករោតិ ៣ ឱ.ម. វាចាឧទ ។ ៤ ម. បដិច្ឆាទាយ ។



មិនគួរបើធ្វើនូវអភិដ្ឋាន(១) ទាំងឡាយ ៦ ផង រតនៈគឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសួស្តី ។ ប្រសិនបើ សោតាបន្នបុគ្គលនោះ ធ្វើនូវបាបកម្មដោយកាយក៏ដោយ ឬដោយចិត្តក៏ដោយ (ព្រោះសេចក្តីភ្លាំងភ្លាត់) សោតាបន្នបុគ្គលនោះ មិនដែលបិទបាំងនូវបាបកម្មនោះឡើយ ភាវៈនៃបុគ្គលមានផ្លូវនៃព្រះនិព្វានឃើញហើយ ជាបុគ្គលមិនដែលបិទបាំងបាបកម្ម ព្រះពុទ្ធទាំងឡាយ បានត្រាស់សំដែងហើយ រតនៈគឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសួស្តី ។

គុម្ពឈើក្នុងព្រៃ មានត្រួយលូតលាស់ ក្នុងខែដើមគិម្ហរដូវនៃក្តៅ យ៉ាងណាមិញ ព្រះពុទ្ធ បានត្រាស់សំដែងហើយនូវធម៌ដ៏ប្រសើរ ជាធម៌ញ៉ាំងសត្វទាំងឡាយ ឲ្យដល់នូវព្រះនិព្វាន ដើម្បីប្រយោជន៍ដ៏ឧត្តម ដូចជាគុម្ពឈើ មានក្នុងព្រៃ ដូច្នោះឯង រតនៈគឺព្រះពុទ្ធនេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសួស្តី ។

១. សំដៅយកអនន្តរិយកម្ម ៥ និងការកាន់យកសាស្តាដទៃ ។

វរោ វរញ្ញូ វរទោ វរាហរោ
អនុត្តរោ ធម្មវរំ អទេសយិ
ឥទម្បិ ពុទ្ធេ រតនំ បណីតំ
ឯតេន សច្ចេន សុវត្ថិ ហោតុ ។
ខីណំ បុរាណំ នវំ [១] នត្ថិ សម្ភវំ
វិរត្តចិត្តាយតិកេ [២] ភវស្មិំ
តេ ខីណពីជា អវិរូឡ្ហិឆន្ទា
និព្វន្តិ ធីរា យថាយម្បទីបោ
ឥទម្បិ សង្ឃេ រតនំ បណីតំ
ឯតេន សច្ចេន សុវត្ថិ ហោតុ ។
យានីធ ភូតានិ សមាគតានិ
ភុម្មានិ វា យានិ វ អន្តលិក្ខេ
តថាគតំ ទេវមនុស្សបូជិតំ
ពុទ្ធំ នមស្សាម សុវត្ថិ ហោតុ ។

១ ម. នវំ ។ ២ ម. វិរត្តចិត្តា អាយតិកេ ។



ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរ ទ្រង់ជ្រាបនូវធម៌ប្រសើរ ទ្រង់ប្រទាននូវធម៌ប្រសើរ ទ្រង់នាំមកនូវធម៌ប្រសើរ ព្រះអង្គប្រសើរ ឥតមានអ្នកណាមួយស្មើ ទ្រង់ត្រាស់សំដែងហើយនូវធម៌ប្រសើរ តេជះនៃព្រះពុទ្ធនេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។

កម្មចាស់ ( របស់ពួកបុគ្គលណា ) អស់ហើយ កម្មថ្មី ដែលនឹងមិនកើតប្រាកដ ពួកបុគ្គលទាំងឡាយណាមានចិត្តនឿយណាយ ហើយក្នុងភពតទៅ ពួកបុគ្គលទាំងឡាយនោះ មានពូជអស់ហើយ មានឆន្ទៈគឺសេចក្តីប្រាថ្នាក្នុងចិត្ត មិនដុះលូតលាស់ឡើង ជាអ្នកមានប្រាជ្ញា រមែងរលត់ទៅ ដូចប្រទីប ដែលរលត់ទៅនេះ តេជះនៃព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។

ពួកភូតណា ដែលនៅលើផែនដីក្តី ពួកភូតណា ដែលនៅក្នុងអាកាសក្តី ដែលមកប្រជុំគ្នា ក្នុងទីនេះ យើងទាំងឡាយសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់ ទ្រង់បានត្រាស់មកហើយដូចគ្នាដែលទេវតានិងមនុស្សតែងបូជា សូមមានសិរីសួស្តី ។

យានីធ ភូតានិ សមាគតានិ
ភុម្មានិ វា យានិ វ អន្តលិក្ខេ
តថាគតំ ទេវមនុស្សបូជិតំ
ធម្មំ នមស្សាម សុវត្ថិ ហោតុ ។
យានីធ ភូតានិ សមាគតានិ
ភុម្មានិ វា យានិ វ អន្តលិក្ខេ
តថាគតំ ទេវមនុស្សបូជិតំ
សង្ឃំ នមស្សាម សុវត្ថិ ហោតុ ។

រតនសុត្តំ និដ្ឋិតំ ។

## ខុទ្ទកបាឋេ តិរោកុឌ្ឌកណ្ឌំ

[៨] មត្តាសុខបរិច្ចាគា បស្សេ ចេ វិបុលំ សុខំ
ចជេ មត្តាសុខំ ធីរោ សម្បស្សំ វិបុលំ សុខំ ។
តិរោកុឌ្ឌេសុ តិដ្ឋន្តិ សន្ធិសិង្ឃាដកេសុ ច
ទ្វារពាហាសុ តិដ្ឋន្តិ អាគន្ត្វាន សកំ ឃរំ ។



ពួកភូតណា បើកនៅលើផែនដីក្តី ពួកភូតណា បើកនៅក្នុងអាកាសក្តី ដែលមកប្រជុំគ្នា ក្នុងទីនេះ យើងទាំងឡាយសូមនមស្ការនូវព្រះធម៌ដែលមានមកហើយដូចគ្នា ដែលមនុស្សនឹងទេវតាតែងបូជា សូមមានសេរីសួស្តី ។

ពួកភូតណា បើកនៅលើផែនដីក្តី ពួកភូតណា បើកនៅ ក្នុងអាកាសក្តី ដែលមកប្រជុំគ្នា ក្នុងទីនេះ យើងទាំងឡាយ សូមនមស្ការ នូវព្រះសង្ឃ ដែលមានមកហើយដូចគ្នា ដែលទេវតានឹងមនុស្សតែងបូជា សូមមានសេរីសួស្តី ។

ចប់ រតនសូត្រ ។

## ខុទ្ទកបាឋ តិរោកុឌ្ឌកណ្ឌ

[៨] បើបុគ្គលឃើញសុខដ៏ទូលាយ ព្រោះលះសុខមានប្រមាណតិចចេញ អ្នកមានប្រាជ្ញា កាលឃើញច្បាស់សុខដ៏ទូលាយ គប្បីលះសុខមានប្រមាណតិចចេញ ។

ប្រេតទាំងឡាយ មកកាន់ផ្ទះនៃញាតិ ដោយគិតថា ផ្ទះរបស់ខ្លួន ហើយឈរនៅខាងក្រៅជញ្ជាំងទាំងឡាយខ្លះ តាមផ្លូវបែកជា ៤ នឹងផ្លូវបែកជា ៣ ទាំងឡាយខ្លះ ជិតក្លាក្រុងនឹងក្លាផ្ទះទាំងឡាយខ្លះ ។

បហុតេ[១] អន្នបានម្ហិ ខជ្ជភោជ្ជេ ឧបដ្ឋិតេ

ន តេសំ កោចិ សរតិ សត្តានំ កម្មបច្ចយា ។

ឯវំ ទទន្តិ ញាតីនំ យេ ហោន្តិ អនុកម្បកា

សុចឹ បណីតំ កាលេន កប្បិយំ បានភោជនំ

ឥទំ វោ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ ។

តេ ច តត្ថ សមាគន្ត្វា ញាតិបេតា សមាគតា

បហុតេ អន្នបានម្ហិ សក្កច្ចំ អនុមោទរេ

ចិរំ ជីវន្តុ នោ ញាតី យេសំ ហេតុ លភាមសេ

អម្ហាកញ្ច កតា បូជា ទាយកា ច អនិប្ផលា

ន ហិ តត្ថ កសី អត្ថិ គោរក្ខេត្ថ ន វិជ្ជតិ

វណិជ្ជា តាទិសី នត្ថិ ហិរញ្ញេន កយោកយំ[២]

---

១ ម. បហូតេ ។ ២ ម. កយក្កយំ ។ យ. កយោកយំ ។



កាលបើបាយទឹក បង្អែមនិងចំណាបមានគ្រប់គ្រាន់ ដែលគួរញាតិតាក់តែងទុកហើយ មិនមានញាតិណាមួយ នឹកដល់ប្រេតទាំងឡាយនោះ ព្រោះកម្មរបស់សត្វទាំងឡាយ ជាបច្ច័យ ។ ញាតិទាំងឡាយណា ជាអ្នកអនុគ្រោះ ញាតិទាំងឡាយនោះ រមែងឧទ្ទិសឲ្យនូវទឹកនឹងភោជនដ៏ស្អាតដ៏ប្រសើរ ជារបស់គួរតាមកាលដល់ញាតិទាំងឡាយ យ៉ាងនេះថា ទាននេះ ចូរមានដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយ បានដល់នូវសេចក្តីសុខ ។ ចំណែក ប្រេតជាញាតិ ជាអ្នកបណ្តុំគ្នាទាំងនោះ មកជួបជុំគ្នាហើយ ក្នុងមន្ទីរប្រេតនោះ កាលបើបាយនិងទឹក មានល្មមគ្រាន់ ក៏អនុមោទនា ដោយគោរពថា យើងទាំងឡាយ បានសម្បត្តិនេះព្រោះហេតុនៃញាតិទាំងឡាយណា សូមពួកញាតិរបស់យើងទាំងឡាយនោះ រស់នៅយឺនយូរ ការបូជាដែលញាតិទាំងឡាយធ្វើហើយដល់យើងទាំងឡាយក្តី ញាតិទាំងឡាយ ជាអ្នកឲ្យទានក្តី មិនមែនជាអឥតផលឡើយ កសិកម្មក៏មិនមានក្នុងភូមិនៃប្រេតនោះ គោរក្ខកម្មក៏មិនមានក្នុងភូមិនៃប្រេតនោះ ពាណិជ្ជកម្មដែលជាហេតុបានសម្បត្តិដែលដូច្នោះក៏មិនមាន ការលក់ទិញវត្ថុ ដោយប្រាក់ក៏មិនមាន

ឥតោ ទិន្នេន យាបេន្តិ បេតា កាលកតា តហិំ ។

ឧន្នតេ[1] ឧទកំ វុឌ្ឋំ[2] យថា និន្នំ បវត្តតិ

ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ ។

យថា វារិវហា បូរា បរិបូរេន្តិ សាគរំ

ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ ។

អទាសិ មេ អកាសិ មេ ញាតិមិត្តា សខា ច មេ

បេតានំ ទក្ខិណំ ទជ្ជា បុព្វេ កតមនុស្សរំ ។

ន ហិ រុណ្ណំ វា សោកោ វា យាវញ្ញា[3] បរិទេវនា

ន តំ បេតានមត្ថាយ ឯវំ តិដ្ឋន្តិ ញាតយោ ។

---

១ ម.ឧ. ឧន្នមេ ។ ២ ម. វុដ្ឋំ ។ ៣ ម.ឧ. យាចញ្ញា ។



បុគ្គលទាំងឡាយ ធ្វើកាលកិរិយា លះលោកនេះទៅហើយ រមែងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងប្រេតវិស័យនោះ ដោយផលទានដែលញាតិទាំងឡាយឧទ្ទិសឲ្យហើយអំពីលោកនេះ ។ ទឹកធ្លាក់ចុះលើទីទួល រមែងហូរទៅកាន់ទីទាបដូចម្តេចមិញ ទានដែលបុគ្គលឲ្យហើយអំពីលោកនេះ រមែងសម្រេចផល ដល់ប្រេតទាំងឡាយ ដូច្នោះដែរ ។ ផ្លូវទឹកមានទន្លេនិងស្ទឹងជាដើម ដ៏ពេញ រមែងញុំាងសាគរឲ្យពេញប្រៀបដូចម្តេចមិញ ទានដែលបុគ្គលឲ្យហើយអំពីលោកនេះ រមែងសម្រេចផល ដល់ប្រេតទាំងឡាយ ដូច្នោះដែរ ។ បុគ្គលកាលរឭកឃើញនូវឧបការគុណ ដែលលោកធ្វើហើយដល់ខ្លួន ក្នុងកាលមុនថាអ្នកនេះបានឲ្យរបស់នេះដល់អញ អ្នកនេះបានធ្វើកិច្ចនេះ ដល់អញជនទាំងឡាយនោះ ជាញាតិមិត្ត ជាសំឡាញ់របស់អញដូច្នេះហើយគួរឲ្យទក្ខិណាទាន ចំពោះប្រេតទាំងឡាយ ។ ការយំសោកសៅឬការខ្សឹកខ្សួលដទៃណា មិនមានប្រយោជន៍ឡើយ ការយំជាដើមនោះ មិនសម្រេចប្រយោជន៍ ដល់ប្រេតទាំងឡាយទេ ញាតិទាំងឡាយ រមែងឋិតនៅយ៉ាងនោះដដែល ផលជាដើមមិនបានឡើយ ។

អយញ្ច ខោ ទក្ខិណា ទិន្នា សង្ឃម្ហិ សុប្បតិដ្ឋិតា
ទីឃរត្តំ ហិតាយស្ស ឋានសោ ឧបកប្បតិ ។
សោ ញាតិធម្មោ ច អយំ និទស្សិតោ
បេតានបូជា(១) ច កតា ឧឡារា
ពលញ្ច ភិក្ខូនមនុប្បទិន្នំ
តុម្ហេហិ បុញ្ញំ បសុតំ អនប្បកន្តិ(២) ។

តិរោកុឌ្ឌកណ្ឌំ និដ្ឋិតំ ។

## ខុទ្ទកបាឋេ និធិកណ្ឌំ

(៨) និធឹ និធេតិ បុរិសោ គម្ភីរេ ឱទកន្តិកេ(៣)
អត្ថេ កិច្ចេ សមុប្បន្នេ អត្ថាយ មេ ភវិស្សតិ
រាជតោ វា ទុរុត្តស្ស ចោរតោ បីឡិតស្ស វា
ឥណស្ស វា បមោក្ខាយ ទុព្ភិក្ខេ អាបទាសុ វា

១ ឱ. បេតានំ បូជា ។ ២ ឱ. អនប្បកំ ។ ៣ ឱ. ឧទកន្តិកេ ។ អដ្ឋកថាយំ ឱទកន្តិកេ បាឋោ ។



លុះតែទក្ខិណាទាននេះ ដែលបុគ្គលបានឲ្យហើយ ដំកល់ទុកប្រពៃហើយ ក្នុងសង្ឃ ទើបសម្រេចផលដោយស្រួល ដើម្បីប្រយោជន៍ដល់ប្រេតនោះ អស់កាលជាអង្វែង ។ ញាតិធម៌នោះឈ្មោះថា មហាបពិត្រ បានសំដែងជាបែបយ៉ាងហើយ ការបូជាដ៏ថ្លៃថ្លា ដល់ពួកប្រេតទាំងឡាយ ឈ្មោះថា បានធ្វើហើយផង កំលាំងកាយនៃភិក្ខុទាំងឡាយ ឈ្មោះថា បានចំរើនឲ្យហើយផង បុណ្យក៏ឈ្មោះថា បានសន្សំទុក មិនមែនតិចទៀតផង ។

ចប់ តិរោកុឌ្ឌកណ្ឌ ។

## ខុទ្ទកបាឋ និធិកណ្ឌ

(៨) បុរសកប់កំណប់ទ្រព្យទុកក្នុងទីជ្រៅ ជាទីជិតនៃទឹក ដោយគិតថា កាលបើកិច្ច ដែលត្រូវការកើតឡើងហើយ ទ្រព្យនេះនឹងបានជាប្រយោជន៍ ដល់អាត្មាអញ ដែលត្រូវពួកបច្ចាមិត្រពាលបង្កាច់ពីដើមបានដោះខ្លួនចេញពីស្ដេច ឬ ត្រូវពួកចោរបៀតបៀនដើម្បីបានដោះខ្លួនចេញពីចោរនឹង បានដោះបំណុល ឬ ក្នុងវេលាទុរ្ភិក្ស ឬ ក្នុងកាលអន្តរាយទាំងឡាយ

ឯតទត្ថាយ លោកស្មឹ និធិ នាម និធិយ្យតិ ។
តាវស្សុ និហិតោ សន្តោ គម្ភីរេ ឱទកន្តិកេ
ន សព្វោ សព្វទាយេវ[១] តស្ស តំ ឧបកប្បតិ
និធិ វា ឋានា ចវតិ សញ្ញា វាស្ស វិមុយ្ហតិ
នាគា វា អបនាមេន្តិ យក្ខា វាបិ ហរន្តិ នំ
អប្បិយា វាបិ ទាយាទា ឧទ្ធរន្តិ អបស្សតោ
យទា បុញ្ញក្ខយោ ហោតិ សព្វមេតំ វិនស្សតិ ។
យស្ស ទានេន សីលេន សញ្ញមេន[២] ទមេន ច
និធិ សុនិហិតោ ហោតិ ឥត្ថិយា បុរិសស្ស វា
ចេតិយម្ហិ ច[៣] សង្ឃេ វា បុគ្គលេ អតិថីសុ វា
មាតរិ បិតរិ វាបិ[៤] អថោ ជេដ្ឋម្ហិ ភាតរិ
ឯសោ និធិ សុនិហិតោ អជេយ្យោ អនុគាមិកោ
បហាយ គមនីយេសុ ឯតំ អាទាយ គច្ឆតិ

១ ម.ម. អ ។ ២ ម.ម. សំយមេន ។ ៣ ម. វ ។ ៤ ម. ចាបិ ។



ធម្មតាកំណប់ដែលគេកប់ទុកក្នុងលោក ដើម្បីប្រយោជន៍នេះឯង ។ កំណប់ដែលបុគ្គលកប់ ក្នុងទីជ្រៅ មានទីបំផុតត្រឹមទឹក ដល់ទាំង កំណប់ទ្រព្យទាំងអស់នោះ ក៏មិនសម្រេចដល់បុគ្គលនោះសព្វកាលទេ ព្រោះថា កំណប់ទ្រព្យ រមែងឃ្លាតទៅចាកទីនោះ សេចក្តីចំណាំរបស់បុគ្គលនោះ រមែងវង្វេងទៅវិញ នាគទាំងឡាយ រមែងនាំផ្លាស់ទៅវិញ ពុំនោះសោត ពួកយក្សនាំយកទ្រព្យនោះទៅវិញ ពួកទាយាទដែលមិនជាទីស្រឡាញ់ រមែងគាស់យកនូវកំណប់ទ្រព្យនោះ កាលខ្លួនមិនបានឃើញវិញ ខ្លួនអស់បុណ្យទៅវេលាណា កំណប់ទ្រព្យទាំងអស់នោះ រមែងវិនាសបាត់បង់ទៅក្នុងវេលានោះ ។ កំណប់ទ្រព្យដែលស្ត្រី ឬ បុរសណា បានកប់ទុកល្អហើយ ដោយទាន សីល ដោយការសង្រួម និងដោយការទូន្មានខ្លួន ក្នុងចេតិយ ក្នុងសង្ឃ ក្នុងបុគ្គល ក្នុងភ្ញៀវ ក្នុងមាតា ក្នុងបិតា ឬថា ក្នុងបងប្រុសស្រីដែលជាច្បង កំណប់ទ្រព្យនុ៎ះ ទាក់ជាកំណប់ទ្រព្យដែលកប់ទុកប្រពៃហើយ នរណា ៗ មិនអាចផ្ចាញ់បានជា កំណប់ទ្រព្យ ដែលជាប់តាមខ្លួនទៅ កាលលះបង់ទាំងឡាយដែលខ្លួនត្រូវលះបង់ហើយទៅ ខ្លួនរមែងកាន់នាំយកកំណប់ទ្រព្យគឺបុណ្យនុ៎ះទៅ

អសាធារណមញ្ញេសំ អចោរាហរណោ[១] និធិ ។
កយិរាថ ធីរោ បុញ្ញានិ យោ និធិ អនុគាមិកោ
ឯស ទេវមនុស្សានំ សព្វកាមទទោ និធិ
យំ យំ ទេវាភិបត្ថេន្តិ សព្វមេតេន លព្ភតិ ។
សុវណ្ណតា សុស្សរតា សុសណ្ឋានំ សុរូបតា
អាធិបច្ចំ[២]បរិវារោ សព្វមេតេន លព្ភតិ ។
បទេសរជ្ជំ ឥស្សរិយំ ចក្កវត្តិសុខំ បិយំ
ទេវរជ្ជម្បិ ទិព្វេសុ សព្វមេតេន លព្ភតិ ។
មានុស្សិកា ច សម្បត្តិ ទេវលោកេ ច យា រតិ
យា ច និព្វានសម្បត្តិ សព្វមេតេន លព្ភតិ ។
មិត្តសម្បទមាគម្ម យោនិសោ វេ បយុញ្ជតោ
វិជ្ជាវិមុត្តិវសីភាវោ សព្វមេតេន លព្ភតិ ។

១ ម.ម. អចោរហរណោ ។ ២ ម.ម. អធិបច្ចំ ។



កំណប់ទ្រព្យគឺបុណ្យ មិនទូទៅ ដល់ពួកជនដទៃ ជារបស់ដែលចោរលួចនាំទៅមិនបាន ។ កំណប់ទ្រព្យ គឺបុណ្យណា ជាប់តាមខ្លួនទៅបាន អ្នកប្រាជ្ញ គួរធ្វើនូវកំណប់ទ្រព្យគឺបុណ្យនោះ កំណប់ទ្រព្យ គឺបុណ្យនុ៎ះ ឲ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាង ដល់ទេវតានិងមនុស្សទាំងឡាយ ពួកទេវតានិងមនុស្សទាំងឡាយ ប្រាថ្នាណាស់នូវផលណា ៗ ផលទាំងពួងនោះ ៗ រមែងបានដោយកំណប់ទ្រព្យគឺបុណ្យនុ៎ះ ។ ភាពជាអ្នកមានសម្បុរល្អផង មានសំឡេងពីរោះ ទ្រង់ទ្រាយល្អ រូបល្អ ជាអធិបតី មានបរិវារ ផលទាំងអស់ រមែងបានដោយកំណប់ទ្រព្យគឺបុណ្យនុ៎ះ ។ ភាពជាស្តេចប្រទេសរាជ ឥស្សរិយយស សេចក្តីសុខរបស់ស្តេចចក្រពត្តិជាទីស្រឡាញ់ ភាពជាស្តេចនៃទេវតា ក្នុងទេវនិកាយទាំងឡាយ ផលទាំងអស់ រមែងបានដោយកំណប់ទ្រព្យគឺបុណ្យនុ៎ះ ។ សម្បត្តិជារបស់មនុស្សណាផង សេចក្តីត្រេកអរ ក្នុងទេវលោកណាផង សម្បត្តិគឺព្រះនិព្វានណាផង សម្បត្តិទាំងអស់ រមែងបានដោយកំណប់ទ្រព្យគឺបុណ្យនុ៎ះ ។ ភាពនៃបុគ្គលកាលអាស្រ័យមិត្តសម្បទា ហើយប្រកបសេចក្តីព្យាយាម ដោយឧបាយដែលត្រូវ ជាអ្នកស្ទាត់ក្នុងវិជ្ជានិងវិមុត្តិ ផ្លែផលទាំងអស់ បានដោយកំណប់ទ្រព្យគឺបុណ្យនោះ ។

បដិសម្ភិទា វិមោក្ខា[១] ច យា ច សាវកបារមី

បច្ចេកពោធិ ពុទ្ធភូមិ សព្វមេតេន លព្ភតិ ។

ឯវំ មហិទ្ធិកា[២] ឯសា យទិទំ បុញ្ញសម្បទា

តស្មា ធីរា បសំសន្តិ បណ្ឌិតា កតបុញ្ញតំ ។

និធិកណ្ឌំ[៣] និដ្ឋិតំ ។

## ខុទ្ទកបាឋេ ករណីយមេត្តសុត្តំ

(១០) ករណីយមត្ថកុសលេន យន្តំ សន្តំ បទំ អភិសមេច្ច

សក្កោ ឧជូ ច សុហុជូ ច សុវចោ ចស្ស មុទុ អនតិមានី

សន្តុស្សកោ ច សុភរោ ច អប្បកិច្ចោ ច សល្លហុកវុត្តិ

សន្តិន្ទ្រិយោ ច និបកោ ច អប្បគព្ភោ កុលេសុ អននុគិទ្ធោ

ន ច ខុទ្ទំ សមាចរេ[៤] កិញ្ចិ យេន វិញ្ញូ បរេ ឧបវទេយ្យុំ

១ ម. វិមោក្ខោ ។ ២ ម. មហិទ្ធិកា ។ ៣ ម.ម. និធិកណ្ឌសុត្តំ ។ ៤ ម.ម. ខុទ្ទមាចរេ ។



បដិសម្ភិទា វិមោក្ខ សាវកបារមីញាណ បច្ចេកពោធិញាណ និងពុទ្ធ-ភូមិណា ៗ វត្ថុទាំងអស់ រមែងបានដោយកំណប់ទ្រព្យគឺបុណ្យនុ៎ះ ។ បុញ្ញសម្បទានេះ ឲ្យសំរេចប្រយោជន៍ធំ ដោយប្រការដូច្នោះ ព្រោះហេតុនោះ អ្នកប្រាជ្ញទាំងឡាយ ជាធីរជន ទើបសរសើរនូវភាពនៃបុគ្គលជាអ្នកមានបុណ្យធ្វើទុកហើយ ។

ចប់ និធិកណ្ឌសូត្រ ។

## ខុទ្ទកបាឋ ករណីយមេត្តសូត្រ

(១០) កិច្ចណា (ដែលត្រូវធ្វើ) បានត្រាស់ដឹងនូវបទដ៏ស្ងប់រម្ងាប់ គឺព្រះនិព្វាន (បានធ្វើហើយ) កិច្ចនោះ កុលបុត្រអ្នកឈ្លាសក្នុងប្រយោជន៍នូវអ្វី (កុលបុត្រនោះ) ជាអ្នកអាចហានផង ត្រង់ដោយកាយនិងវាចាផង ត្រង់ល្អដោយចិត្តផង គេប្រដៅងាយផង មានសុភាពទន់ភ្លន់ផង មិនមានមានះលើសក្រៃលែងផង សន្តោសផង គេចិញ្ចឹមងាយផង មានកិច្ចធុរៈតិចផង ប្រព្រឹត្តស្រាលព្រម (មានបរិក្ខារតិច) ផង មានឥន្ទ្រិយស្រគត់ស្រគំផង មានប្រាជ្ញាចាស់ផង មិនឃ្នើសឃ្នងផង មិនជាប់ជំពាក់ក្នុងត្រកូលទាំងឡាយផង វិញ្ញូជនទាំងឡាយ គួរតិះដៀលជនទាំងឡាយដទៃ ដោយកម្មណា មិនគួរប្រព្រឹត្តអ្វី នូវកម្មនោះ ដែលជាកម្មលាមក សូម្បីតិចតួច

សុខិនោ វា ខេមិនោ ហោន្តុ សព្វេ សត្តា ភវន្តុ សុខិតត្តា

យេ កេចិ បាណភូតត្ថិ តសា វា ថាវរា វា(១) អនវសេសា

ទីឃា វា យេ មហន្តា វា(២) មជ្ឈិមា រស្សកា អណុកថូលា

ទិដ្ឋា វា យេ ច អទិដ្ឋា យេ ច ទូរេ វសន្តិ អវិទូរេ

ភូតា វា សម្ភវេសី វា សព្វេ សត្តា ភវន្តុ សុខិតត្តា ។

ន បរោ បរំ និកុព្វេថ នាតិមញ្ញេថ កត្ថចិ(៣) នំ កញ្ចិ(៤)

ព្យារោសនា បដិឃសញ្ញា នាញ្ញមញ្ញស្ស ទុក្ខមិច្ឆេយ្យ ។

មាតា យថា និយំ បុត្តំ អាយុសា ឯកបុត្តមនុរក្ខេ

ឯវម្បិ សព្វភូតេសុ មានសម្ភាវយេ អបរិមាណំ ។

---

១ ម. [illegible] ២ [illegible] ៣ [illegible] ៤ [illegible]



(ហើយគប្បីផ្សាយមេត្តាចិត្ត ចំពោះពពួកសត្វថា) សត្វទាំងឡាយទាំងពួង សូមឲ្យមានសេចក្តីសុខ ឲ្យមានសេចក្តីក្សេម ឲ្យមានខ្លួនដល់នូវសេចក្តីសុខចុះ សត្វមានជីវិតទាំងឡាយណាមួយដែលមានសេសសល់ ទោះសត្វមានសេចក្តីតក់ស្លុត គឺនៅមានតណ្ហាក្តី ទាំមួនគឺផុតចាកតណ្ហាក្តី សត្វទាំងឡាយណា មានកាយវែងក្តី ធំក្តី មានកាយយ៉ាងកណ្តាលក្តី ខ្លីក្តី មានកាយល្អិត ឬ ធាត់ក្តី សត្វទាំងឡាយណា ដែលយើងឃើញហើយក្តី មិនឃើញហើយក្តី សត្វទាំងឡាយណា នៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី ដែលកើតរួចមកហើយក្តី ដែលកំពុងស្វែងរកទីកើតក្តី សត្វទាំងអស់ (នោះ) ចូរមានខ្លួនជាសុខចុះ ។ សត្វដទៃមិនគប្បីកំហែងបៀតបៀនសត្វដទៃឡើយ មិនគប្បីមើលងាយនឹងគេក្នុងទីណាមួយឡើយ មិនគប្បីប្រាថ្នានូវសេចក្តីទុក្ខដល់គ្នានឹងគ្នា ព្រោះសេចក្តីក្រេវក្រោធនិងសេចក្តីចង្អៀតចង្អល់ ក្នុងចិត្តឡើយ ។ មាតាថ្នមរក្សាបុត្រដែលកើតអំពីខ្លួន ជាកូនតែមួយដោយអាយុ (ស្មើដោយជីវិត) យ៉ាងណាមិញ បុគ្គលគប្បីចំរើនមេត្តាចិត្តមិនមានប្រមាណ ចំពោះសត្វទាំងឡាយទាំងពួង យ៉ាងនោះដែរ ។

មេត្តញ្ច សព្វលោកស្មឹ មានសម្ភាវយេ អបរិមាណំ

ឧទ្ធំ អធោ ច តិរិយញ្ច អសម្ពាធំ អវេរំ អសបត្តំ[១] ។

តិដ្ឋញ្ចរំ និសិន្នោ វា សយានោ វា យាវតស្ស វិគតមិទ្ធោ

ឯតំ សតិំ អធិដ្ឋេយ្យ ព្រហ្មមេតំ វិហារំ ឥធមាហុ[២] ។

ទិដ្ឋិញ្ច អនុបគម្ម សីលវា ទស្សនេន សម្បន្នោ

កាមេសុ វិនេយ្យ[៣] គេធំ ន ហិ ជាតុ គព្ភសេយ្យំ បុនរេតីតិ ។

មេត្តសុត្តំ និដ្ឋិតំ ។

ខុទ្ទកបាឋោ សមត្តោ[៤] ។

---

១ ម. អវេរមសបត្តំ ។ ២ ម. វិហារមិធមាហុ ។ ៣ ម. វិនេយ្យ ។ ៤ ឱ.ម. ខុទ្ទកបាឋប្បករណំ និដ្ឋិតំ ។



បុគ្គលគប្បីចំរើនមេត្តាចិត្ត មិនមានប្រមាណ ជាគុណមិនចង្អៀត មិនមានពៀរ មិនមានសត្រូវ ទៅក្នុងលោកទាំងអស់ គឺក្នុងទិសខាងលើផង ខាងក្រោមផង ខាងទទឹងគឺត្រង់កណ្តាលផង ។ ( បុគ្គលអ្នកចំរើនមេត្តាចិត្តនោះ ) ទោះឈរក្តី ដើរក្តី អង្គុយក្តី ដេកក្តី ជាអ្នកមានសេចក្តីងោកងុក ទៅប្រាសហើយ គឺជាអ្នកមិនដេកលក់ អស់កាលត្រឹមណា គួរដំកល់នូវសតិនោះ អស់កាលត្រឹមនោះ បណ្ឌិតទាំងឡាយ ពោលនូវកិរិយានុ៎ះថាជាព្រហ្មវិហារ ក្នុងសាសនានេះ ។ (បុគ្គលដែលមានមេត្តាព្រហ្មវិហារ) មិនចូលទៅកាន់ទិដ្ឋិ ជាអ្នកមានសីល ប្រកបដោយទស្សនសម្បត្តិ គឺសោតាបត្តិមគ្គ ( តទៅទៀត ) បន្ទោបង់នូវសេចក្តីជាប់ចំពាក់ ក្នុងកាមទាំងឡាយហើយ រមែងមិនមកកាន់គព្ភសេយ្យាទៀតឡើយ ។

ចប់ មេត្តសូត្រ ។

ចប់ ខុទ្ទកបាឋ ។

# សុត្តន្តបិដកេ
## ខុទ្ទកនិកាយស្ស ធម្មបទគាថា

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

(១១) មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា
មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា
តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ ។
មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា
មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា
តតោ នំ សុខមន្វេតិ ឆាយាវ អនុបាយិនី ។
អក្កោច្ឆិ មំ អវធិ មំ អជិនិ[១] មំ អហាសិ មេ
យេ ច[២] តំ ឧបនយ្ហន្តិ វេរំ តេសំ ន សម្មតិ ។
អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ

១ ម. អជិនី ។ ២ ម. [illegible] ។

# សុត្តន្តបិដក
## ខុទ្ទកនិកាយ ធម្មបទគាថា

សូមនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។

(១១) ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត (មានចិត្តជាធំ) សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តខ្រាលទោស(១) ប្រទូស្តហើយ ពោលក្តី ធ្វើក្តី (នូវទុច្ចរិត) ព្រោះទុច្ចរិតទាំងនោះ ទុក្ខ រមែងជាប់តាមបុគ្គលនោះទៅ ដូចកង់រទេះវិលតាមជាន់ជើងគោដែលកំពុងអូសទៅ ។

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តជ្រះថ្លា(២)ហើយ ពោលក្តី ធ្វើក្តី (នូវសុចរិត) ព្រោះសុចរិតទាំងនោះ សុខរមែងជាប់តាមបុគ្គលនោះទៅ ដូចស្រមោលអន្ទោលតាមប្រាណ ។

អ្នកឯណានុះ បានជេរអញ អ្នកឯណានុះ បានវាយអញ អ្នកឯណានុះ បានឈ្នះអញ អ្នកឯណានុះ បានលួចយកទ្រព្យរបស់អញទៅហើយ បើអ្នកណា ចងសេចក្តីក្រោធថែបានទុក (ដូច្នេះ) ពៀររបស់អ្នកនោះ មិនរម្ងាប់ឡើយ ។

អ្នកឯណានុះ បានជេរអញ អ្នកឯណានុះ បានវាយអញ អ្នកឯណានុះ បានឈ្នះអញ អ្នកឯណានុះ បានលួចយកទ្រព្យរបស់អញទៅហើយ

១ ពាក្យថា ទោស គឺសេចក្តីសៅហ្មងនៃចិត្តមានលោភជាដើម ដែលចូលទៅកប់ក្នុងចិត្តឲ្យកំរើក ។
២ ជ្រះថ្លាដោយគុណមានអលោភជាដើម ។ អដ្ឋកថា ។

យេ ច តំ នុបនយ្ហន្តិ[១] វេរំ តេសូបសម្មតិ ។

ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ

អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ ។

បរេ ច ន[២] វិជានន្តិ មយមេត្ថ យមាមសេ[៣]

យេ ច តត្ថ វិជានន្តិ តតោ សម្មន្តិ មេធគា ។

សុភានុបស្សឹ វិហរន្តំ ឥន្ទ្រិយេសុ អសំវុតំ

ភោជនម្ហិ អមត្តញ្ញុំ កុសីតំ ហីនវីរិយំ

តំ វេ បសហតិ មារោ វាតោ រុក្ខំវ ទុព្វលំ ។

អសុភានុបស្សឹ វិហរន្តំ ឥន្ទ្រិយេសុ សុសំវុតំ

ភោជនម្ហិ ច មត្តញ្ញុំ សទ្ធំ អារទ្ធវីរិយំ

តំ វេ នប្បសហតិ[៤] មារោ វាតោ សេលំវ បព្វតំ ។

១ ម.ឧ ឧបនយ្ហន្តិ ។ [illegible] ៤ [illegible]



បើអ្នកណា មិនចងសេចក្តីក្រោធថែមនោះទុក (ដូច្នេះ)ពៀររបស់អ្នកនោះនឹងរម្ងាប់បាន ។ ពិតមែន តាំងពីកាលណាមក ក្នុងលោកនេះ ពៀរទាំងឡាយ មិនរម្ងាប់ ដោយការចងពៀរឡើយ ពៀរទាំងឡាយតែងរម្ងាប់ ដោយមិនចងពៀរ នេះជាបវេណីចាស់ ។ ជនទាំងឡាយដទៃ ( ក្រៅអំពីបណ្ឌិត ) តែងមិនដឹងខ្លួនថា យើងទាំងឡាយនឹងវិនាសក្នុងកណ្តាលនៃពួកនេះ ដូច្នេះឡើយ ចំណែកជនទាំងឡាយណា ក្នុងពួកនេះ ដឹងខ្លួនថា យើងទាំងឡាយ នឹងវិនាសក្នុងកណ្តាលនៃពួកនេះ ដូច្នេះ ការឈ្លោះប្រកែកទាំងឡាយ រមែងរម្ងាប់អំពីជនទាំងឡាយនោះ ។

បុគ្គលដែលយល់ឃើញនូវអារម្មណ៍ថាល្អ មិនសង្រួមក្នុងឥន្ទ្រិយទាំងឡាយ មិនដឹងប្រមាណក្នុងភោជន ខ្ជិលច្រអូស មានព្យាយាមថយ កិលេសមារ រមែងគ្របសង្កត់បុគ្គលនោះឯង ដូចខ្យល់ដែលគ្របសង្កត់ដើមឈើទុព្វលដូច្នោះ ។ ឯបុគ្គល ដែលយល់ឃើញនូវអារម្មណ៍ថាមិនល្អ សង្រួមប្រពៃក្នុងឥន្ទ្រិយទាំងឡាយ ដឹងប្រមាណក្នុងភោជន មានសទ្ធា ប្រារព្ធព្យាយាម កិលេសមារតែងគ្របសង្កត់បុគ្គលនោះមិនបាន ដូចខ្យល់គ្របសង្កត់ភ្នំថ្មដាន់មិនបានដូច្នោះ ។

អនិក្កសាវោ កាសាវំ យោ វត្ថំ បរិទហេស្សតិ

អបេតោ ទមសច្ចេន ន សោ កាសាវមរហតិ ។

យោ ច វន្តកសាវស្ស សីលេសុ សុសមាហិតោ

ឧបេតោ ទមសច្ចេន ស វេ កាសាវមរហតិ ។

អសារេ សារមតិនោ សារេ ចាសារទស្សិនោ

តេ សារំ នាធិគច្ឆន្តិ មិច្ឆាសង្កប្បគោចរា ។

សារញ្ច សារតោ ញត្វា អសារញ្ច អសារតោ

តេ សារំ អធិគច្ឆន្តិ សម្មាសង្កប្បគោចរា ។

យថា អគារំ ទុច្ឆន្នំ វុដ្ឋី(១) សមតិវិជ្ឈតិ

ឯវំ អភាវិតំ ចិត្តំ រាគោ សមតិវិជ្ឈតិ ។

---

១ ម. វុដ្ឋិ ។



អ្នកណា នៅមានទឹកចត់ទឹកគឺកិលេស (គឺសក្តាន) ជាអ្នកព្រាត់ចាកការទូន្មាន នូវឥន្ទ្រិយនិងសច្ចៈ ហើយស្លៀកដណ្តប់សំពត់កាសាវៈ អ្នកនោះមិនគួរនឹងស្លៀកដណ្តប់សំពត់កាសាវៈឡើយ ។ លុះតែអ្នកណា ខាននូវទឹកចត់ទឹកគឺកិលេស ខ្ជាក់ចោលអស់ហើយ ជាអ្នកមានចិត្តដម្កល់ទាំ ក្នុងចតុប្បារិសុទ្ធិសីល ប្រកបដោយការទូន្មាននូវឥន្ទ្រិយនិងសច្ចៈ អ្នកនោះឯង ទើបគួរនឹងស្លៀកដណ្តប់សំពត់កាសាវៈបាន ។

ជនទាំងឡាយ ដែលយល់ឃើញ ក្នុងធម៌មិនមានខ្លឹម ថាជាធម៌មានខ្លឹមផង ជាអ្នកមានតម្រិះខុសជាអារម្មណ៍ រមែងមិនបាននូវធម៌ដែលមានខ្លឹមឡើយ ។ ជនទាំងឡាយ ដែលយល់ឃើញ នូវធម៌មានខ្លឹម ថាជាធម៌មានខ្លឹមផង យល់ឃើញ នូវធម៌គ្មានខ្លឹម ថាជាធម៌គ្មានខ្លឹមផង ជាអ្នកមានតម្រិះត្រូវ ជាអារម្មណ៍ រមែងបាននូវធម៌ដែលមានខ្លឹម ។

ផ្ទះដែលប្រក់ខ្ជីខ្ជាហើយ ដំណក់ទឹកភ្លៀង រមែងលេចធ្លាយយ៉ាងណាមិញ ចិត្តដែលបុគ្គលមិនបានអប់រំហើយ រាគៈរមែងចាក់ធ្លុះយ៉ាងនោះឯង ។

យថា អគារំ សុឆន្នំ វុដ្ឋី ន សមតិវិជ្ឈតិ

ឯវំ សុភាវិតំ ចិត្តំ រាគោ ន សមតិវិជ្ឈតិ ។

ឥធ សោចតិ បេច្ច សោចតិ បាបការី ឧភយត្ថ សោចតិ

សោ សោចតិ សោ វិហញ្ញតិ ទិស្វា កម្មកិលិដ្ឋមត្តនោ ។

ឥធ មោទតិ បេច្ច មោទតិ កតបុញ្ញោ ឧភយត្ថ មោទតិ

សោ មោទតិ សោ បមោទតិ ទិស្វា កម្មវិសុទ្ធិមត្តនោ ។

ឥធ តប្បតិ បេច្ច តប្បតិ បាបការី ឧភយត្ថ តប្បតិ

បាបំ មេ កតន្តិ តប្បតិ ភិយ្យោ តប្បតិ ទុគ្គតឹ គតោ ។

ឥធ នន្ទតិ បេច្ច នន្ទតិ កតបុញ្ញោ ឧភយត្ថ នន្ទតិ

បុញ្ញំ មេ កតន្តិ នន្ទតិ ភិយ្យោ នន្ទតិ សុគតឹ គតោ ។



ផ្ទះដែលប្រក់ល្អហើយ ដំណក់ទឹកភ្លៀង រមែងមិនលេចធ្លុះ យ៉ាងណាមិញ ចិត្តដែលបុគ្គលបានអប់រំទុកល្អហើយ រាគៈរមែងមិនចាក់ធ្លុះបាន យ៉ាងនោះឯង ។ បុគ្គលអ្នកធ្វើបាប តែងសោកស្ដាយក្នុងលោកទាំងពីរ គឺសោកស្ដាយ ក្នុងលោកនេះ ១ ក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងសោកស្ដាយ ក្ដៅក្រហាយ ព្រោះឃើញអំពើសៅហ្មងរបស់ខ្លួន ។

បុគ្គលអ្នកធ្វើបុណ្យទុក រមែងរីករាយ ក្នុងលោកទាំងពីរ គឺរីករាយក្នុងលោកនេះ ១ រីករាយក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងរីករាយស្រស់ស្រាយ ព្រោះឃើញអំពើបរិសុទ្ធរបស់ខ្លួន ។ បុគ្គលអ្នកធ្វើអំពើបាប តែងក្ដៅក្រហាយ ក្នុងលោកទាំងពីរ គឺក្ដៅក្រហាយក្នុងលោកនេះ ១ ក្ដៅក្រហាយក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងក្ដៅក្រហាយដោយគិតឃើញថា បាបអញបានធ្វើហើយ លុះធ្វើមរណកាលទៅកាន់ទុគ្គតិ គឺរឹតតែក្ដៅក្រហាយពេកក្រៃលែង ។

បុគ្គលអ្នកធ្វើបុណ្យទុក រមែងត្រេកអរ ក្នុងលោកទាំងពីរគឺត្រេកអរក្នុងលោកនេះ ១ ត្រេកអរក្នុងលោកខាងមុខ ១ បុគ្គលនោះរមែងត្រេកអរដោយគិតឃើញថា បុណ្យអញបានធ្វើហើយ លុះធ្វើមរណកាលទៅកាន់សុគតិ គឺរឹតតែត្រេកអរពេកក្រៃលែង ។

ពហុម្បិ ចេ សហិតំ ភាសមានោ
ន តក្ករោ ហោតិ នរោ បមត្តោ
គោបោវ គាវោ គណយំ បរេសំ
ន ភាគវា សាមញ្ញស្ស ហោតិ ។
អប្បម្បិ ចេ សហិតំ ភាសមានោ
ធម្មស្ស ហោតិ អនុធម្មចារី
រាគញ្ច ទោសញ្ច បហាយ មោហំ
សម្មប្បជានោ សុវិមុត្តចិត្តោ
អនុបាទិយានោ ឥធ វា ហុរំ វា
ស ភាគវា សាមញ្ញស្ស ហោតិ ។

យមកវគ្គោ បឋមោ ។

## ធម្មបទគាថាយ ទុតិយោ អប្បមាទវគ្គោ

[១២] អប្បមាទោ អមតំបទំ បមាទោ មច្ចុនោ បទំ
អប្បមត្តា ន មីយន្តិ យេ បមត្តា យថា មតា
ឯតំ[១] វិសេសតោ ញត្វា អប្បមាទម្ហិ បណ្ឌិតា

១ ម. ឯវំ ។



បើជនពោលពាក្យប្រកបដោយប្រយោជន៍សូម្បីច្រើន តែជាអ្នកប្រមាទ មិនធ្វើតាមពាក្យនោះ រមែងជាអ្នកមិនមានចំណែកសាមញ្ញផលឡើយ ដូចអ្នកគង្វាលគោ កាលរាប់គោប្រគល់ឲ្យម្ចាស់វិញហើយ (ជាអ្នកមិនបានបរិភោគនូវបញ្ចគោរស) ដូច្នោះឯង ។ បើជនពោលពាក្យប្រកបដោយប្រយោជន៍សូម្បីបន្តិចបន្តួច តែជាអ្នកប្រព្រឹត្តនូវធម៌សមគួរដល់ធម៌ លះបង់រាគៈ ទោសៈនិងមោហៈ ជាអ្នកដឹងនូវធម៌ ដែលគួរកំណត់តាមហេតុ មានចិត្តផុតស្រឡះអំពីសេចក្ដីសៅហ្មង មិនមានសេចក្ដីប្រកាន់មាំ ក្នុងលោកនេះនិងលោកខាងមុខ ជននោះ រមែងជាអ្នកបានចំណែកសាមញ្ញផល ។

ចប់ យមកវគ្គ ទី១ ។

## ធម្មបទគាថា អប្បមាទវគ្គទី២

[១២] សេចក្ដីមិនប្រមាទ[១] ជាផ្លូវនៃសេចក្ដីមិនស្លាប់[២] សេចក្ដីប្រមាទ
ជាផ្លូវនៃសេចក្ដីស្លាប់ ជនទាំងឡាយ ដែលមិនប្រមាទហើយ[៣]
ឈ្មោះថា មិនស្លាប់ ជនទាំងឡាយ ដែលប្រមាទហើយ ទុកដូច
ជាមនុស្សស្លាប់ទៅហើយ ។ អ្នកបណ្ឌិត បានជ្រាបនូវដំណើរ
នេះ ដោយវែកញែក ( ទើបមិន[illegible] ) ក្នុងសេចក្ដីមិនប្រមាទ

១ បានដល់ការប្រុងប្រយ័ត្ន ពាក្យនេះជាឈ្មោះស្មារតី ដែលតាំងប្រុងជានិច្ច ។
២ ពាក្យថា មិនស្លាប់នេះ ជាឈ្មោះព្រះនិព្វាន ព្រោះព្រះនិព្វានមិនមានកើត មិនមានស្លាប់ ។
៣ បានដល់ការមិនប្រុងប្រយ័ត្ន ពាក្យនេះជាឈ្មោះនៃការលះបង់ស្មារតី ។

អប្បមាទេ បមោទន្តិ អរិយានំ គោចរេ រតា

តេ ឈាយិនោ សាតតិកា និច្ចំ ទឡ្ហបរក្កមា

ផុសន្តិ ធីរា និព្វានំ យោគក្ខេមំ អនុត្តរំ ។

ឧដ្ឋានវតោ សតីមតោ សុចិកម្មស្ស និសម្មការិនោ

សញ្ញតស្ស(១) ច ធម្មជីវិនោ អប្បមត្តស្ស យសោភិវឌ្ឍតិ ។

ឧដ្ឋានេនប្បមាទេន សញ្ញមេន(២) ទមេន ច(៣)

ទីបំ កយិរាថ មេធាវី យំ ឱឃោ នាភិកីរតិ ។

បមាទមនុយុញ្ជន្តិ ពាលា ទុម្មេធិនោ ជនា

អប្បមាទញ្ច មេធាវី ធនំ សេដ្ឋំវ រក្ខតិ ។

មា បមាទមនុយុញ្ជេថ មា កាមរតិសន្ថវំ

អប្បមត្តោ ហិ ឈាយន្តោ បប្បោតិ វិបុលំ សុខំ ។

១ ម. សំយតស្ស ។ ២ ម. សំយមេន ។ ៣ ឱ. ក ។



វិសេស ក្នុងសេចក្តីមិនប្រមាទ បណ្ឌិតទាំងនោះ ជាអ្នកត្រេកអរ ក្នុងធម៌ ជាគោចរ(១) នៃអរិយបុគ្គលទាំងឡាយ មានការពិនិត្យ ជាប្រក្រតី មានព្យាយាមជាប់តគ្នា មានសេចក្តីប្រឹងប្រែងមាំមួនជានិច្ច ជាអ្នកមានប្រាជ្ញា តែងប៉ះពាល់នូវព្រះនិព្វានជាទីក្សេមក្សាន្តចាកយោគៈ ជាគុណជាតដ៏ប្រសើរបំផុត ។ យស(២) តែងចំរើនទូទៅ ដល់បុគ្គលអ្នកមានសេចក្តីប្រឹងប្រែង មានស្មារតី មានការងារស្អាត (ឥតទោស) ជាអ្នកពិចារណា រួចហើយទើបធ្វើ ជាអ្នកសង្រួម រស់នៅដោយធម៌ មិនមានសេចក្តីប្រមាទ ។ អ្នកប្រាជ្ញ គប្បីសាងកោះ គឺអរហត្តផល ជាការដែលជំនន់គឺកិលេស ផ្តួលរំលំមិនបាន ដោយសេចក្តីប្រឹងប្រែងផង ដោយសេចក្តីមិនប្រមាទផង ដោយការសង្រួមក្នុងបាតិមោក្ខសីលផង ដោយការទូន្មានឥន្ទ្រិយផង ។ ពួកជនពាលអប្បឥតប្រាជ្ញា តែងប្រកបរឿយៗ នូវសេចក្តីប្រមាទ ចំណែកអ្នកប្រាជ្ញ តែងរក្សានូវសេចក្តីមិនប្រមាទ ដូចទ្រព្យយ៉ាងប្រសើរ ។ អ្នកទាំងឡាយ កុំប្រកបរឿយៗនូវសេចក្តីប្រមាទ កុំប្រកបរឿយៗ នូវសេចក្តីរាប់អាន ត្រេកអរក្នុងកាមឡើយ ព្រោះថា បុគ្គលអ្នកមិនប្រមាទ រំពឹងពិនិត្យ តែងបាននូវសេចក្តីសុខដ៏ទូលាយ ។

១ គោចរក្នុងទីនេះ សំដៅយកសតិប្បដ្ឋាននិងលោកុត្តរធម៌ ។ ២ យសមានបីយ៉ាងៈ ១ ភោគសម្បត្តិ, សេចក្តីកម្រើក, កិត្តិសព្ទ ហៅថា យស ។

បមាទំ អប្បមាទេន យទា[១] នុទតិ បណ្ឌិតោ
បញ្ញាបាសាទមារុយ្ហ អសោកោ សោកិនឹ បជំ
បព្វតដ្ឋោវ ភុម្មដ្ឋេ ធីរោ ពាលេ អវេក្ខតិ ។
អប្បមត្តោ បមត្តេសុ សុត្តេសុ ពហុជាគរោ
អពលស្សំវ សីឃស្សោ ហិត្វា យាតិ សុមេធសោ ។
អប្បមាទេន មឃវា ទេវានំ សេដ្ឋតំ គតោ
អប្បមាទំ បសំសន្តិ បមាទោ គរហិតោ សទា ។
អប្បមាទរតោ ភិក្ខុ បមាទេ ភយទស្សិ វា
សញ្ញោជនំ អណុំ ថូលំ ឌហំ អគ្គីវ គច្ឆតិ ។

១ ម. នុទតិ ។



កាលណា បណ្ឌិត បន្ទាបង់នូវសេចក្ដីប្រមាទ ដោយសេចក្ដីមិនប្រមាទ កាលណោះ លោកនឹងឡើងកាន់ប្រាសាទគឺបញ្ញាជាបុគ្គលមិនសោក រមែងឃើញពួកសត្វដែលមានសោក ធីរជនតែងឃើញពួកជនពាល ដូចបុគ្គលដែលឈរលើកំពូលភ្នំ ហើយក្រឡេកមើលពួកជនដែលឋិតនៅលើផែនដី ដូច្នោះឯង ។

បណ្ឌិតមានប្រាជ្ញាបុគ្គល កាលពួកបុគ្គលកំពុងប្រមាទ លោកមិនប្រមាទ កាលពួកបុគ្គលកំពុងដេកលក់ លោកភ្ញាក់រឭកច្រើន លោករមែងលះបង់ចោលនូវបុគ្គលបែបនោះ ដូចសេះលឿន ដែលទៅចោលនូវសេះ មានកំឡាំងខ្សោយ ដូច្នោះឯង ។

មឃមាណព ដល់នូវភាពជាបុគ្គលប្រសើរបំផុត ជាងទេវតាទាំងឡាយ ព្រោះតែសេចក្ដីមិនប្រមាទ អ្នកប្រាជ្ញទាំងឡាយ តែងសរសើរនូវសេចក្ដីមិនប្រមាទ គេតិះដៀលនូវសេចក្ដីប្រមាទ សព្វៗកាល ។

ភិក្ខុអ្នកត្រេកអរ ក្នុងសេចក្ដីមិនប្រមាទ ឬឃើញភ័យ ក្នុងសេចក្ដីប្រមាទ តែងដុតនូវសំយោជនៈ ទាំងតូច ទាំងធំ ដូចភ្លើងឆេះ (កាលដុតគ្រឿងដុតទាំងតូចទាំងធំ) ដូច្នោះឯង ។

អប្បមាទរតោ ភិក្ខុ    បមាទេ ភយទស្សិ វា
អភព្វោ បរិហានាយ    និព្វានស្សេវ សន្តិកេ ។

អប្បមាទវគ្គោ ទុតិយោ ។

## ធម្មបទគាថាយ តតិយោ ចិត្តវគ្គោ

[៣៣] ផន្ទនំ ចបលំ ចិត្តំ ទុរក្ខំ ទុន្និវារយំ
ឧជុំ ករោតិ មេធាវី    ឧសុការោវ(១) តេជនំ ។
វារិជោវ ថលេ ខិត្តោ    ឱកមោកតឧព្ភតោ
បរិផន្ទតិទំ ចិត្តំ    មារធេយ្យំ បហាតវេ ។
ទុន្និគ្គហស្ស លហុនោ    យត្ថ កាមនិបាតិនោ
ចិត្តស្ស ទមថោ សាធុ    ចិត្តំ ទន្តំ សុខាវហំ ។

១. ឧសុការោ ។



ភិក្ខុអ្នកត្រេកអរ ក្នុងសេចក្ដីមិនប្រមាទ ឬឃើញភ័យ ក្នុងសេចក្ដីប្រមាទ ជាអ្នកមិនគួរនឹងសាបសូន្យចាកគុណធម៌ ឈ្មោះថា ជិត នៅក្នុងទីជិតនៃព្រះនិព្វាន ។

ចប់ អប្បមាទវគ្គ ទី២ ។

## ធម្មបទគាថា ចិត្តវគ្គ ទី៣

(៣៣) អ្នកប្រាជ្ញ តែងធ្វើចិត្តដែលញាប់ញ័រ ឃ្លេងឃ្លោង រក្សាបាន ដោយកម្រ ហាមឃាត់បានដោយលំបាក ឲ្យជាចិត្តត្រង់បាន ដូចអ្នកធ្វើព្រួញ ពត់ព្រួញឲ្យត្រង់ ។ ចិត្តនេះដែលបុគ្គលលើកឡើងចាកអាល័យគឺកាមគុណ ៥ បោះទៅក្នុងវិបស្សនាកម្មដ្ឋាន ដើម្បីលះបង់វដ្ដៈជាទីនៅនៃមារ រមែងញាប់ញ័រ ដូចត្រីដែលគេលើកឡើងចាកទីនៅគឺទឹក បោះទៅលើគោក ដូច្នោះឯង ។

ការទូន្មានចិត្ត ដែលសង្កត់សង្កិន បានដោយលំបាក ជាធម្មជាតរហ័ស មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្ដីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ រមែងជាគុណញុំាងប្រយោជន៍ឲ្យសម្រេច ( ព្រោះថា ) ចិត្តដែលបុគ្គលទូន្មានបានហើយ រមែងនាំមកនូវសេចក្ដីសុខ ។

សុទុទ្ទសំ សុនិបុណំ យត្ថ កាមនិបាតិនំ
ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ ។
ទូរង្គមំ ឯកចរំ(១) អសរីរំ គុហាសយំ
យេ ចិត្តំ សញ្ញមេស្សន្តិ មោក្ខន្តិ មារពន្ធនា ។
អនវដ្ឋិតចិត្តស្ស សទ្ធម្មំ អវិជានតោ
បរិប្លវបសាទស្ស បញ្ញា ន បរិបូរតិ ។
អនវស្សុតចិត្តស្ស អនន្វាហតចេតសោ
បុញ្ញបាបបហីនស្ស នត្ថិ ជាគរតោ ភយំ ។

កុម្ភូបមំ កាយមិមំ វិទិត្វា
នគរូបមំ ចិត្តមិទំ ឋបេត្វា
យោធេថ មារំ បញ្ញាវុធេន
ជិតញ្ច រក្ខេ អនិវេសនោ សិយា ។

១ ម. ឯកចារំ ។



អ្នកមានប្រាជ្ញា គួររក្សាចិត្តដែលឃើញដោយកម្រក្រៃពេក ដែលល្អិតពេកណាស់ មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្ដីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ (ព្រោះថា) ចិត្តដែលគេរក្សាបានហើយ រមែងនាំមកនូវសេចក្ដីសុខ ។

អ្នកទាំងឡាយណា នឹងសង្រួមចិត្តដែលទៅឆ្ងាយ ជាចិត្តត្រាច់ទៅតែឯង មិនមានសរីរៈ មានគូហាគឺមហាភូតរូប ៤ ជាទីអាស្រ័យនៅ អ្នកទាំងនោះឯង រមែងរួចចាកចំណងនៃមារ ។

ប្រាជ្ញា រមែងមិនបរិបូណ៌ដល់បុគ្គលដែលមានចិត្តមិនខ្ជាប់ខ្ជួន មិនដឹងច្បាស់នូវព្រះសទ្ធម្ម មានសេចក្ដីជ្រះថ្លាអណ្ដែតទៅ ។ ភ័យរមែងមិនមាន ដល់បុគ្គលអ្នកមានចិត្តមិនទទឹកដោយតម្រេក មានចិត្តដែលទោសទាំងខ្ទប់មិនបាន មានបុណ្យនិងបាបលះបង់ហើយភ្ញាក់រឭកជានិច្ច ។ បុគ្គលគប្បីដឹងច្បាស់នូវកាយនេះថា ដូចជាក្អម គប្បីបិទនូវចិត្តនេះឲ្យដូចជាបិទទ្វារនគរ គប្បីច្បាំងនឹងមារដោយអាវុធ គឺបញ្ញា គប្បីរក្សាគុណដែលខ្លួនឈ្នះហើយ មិនគប្បីជាអ្នកជំពាក់នៅ (ក្នុងគុណនោះ) ឡើយ ។

អចិរំ វតយំ កាយោ បឋវឹ អធិសេស្សតិ
ឆុឌ្ឌោ អបេតវិញ្ញាណោ និរត្ថំវ កលិង្គរំ ។

ទិសោ ទិសំ យន្តំ កយិរា វេរី វា បន វេរិនំ
មិច្ឆាបណិហិតំ ចិត្តំ បាបិយោ នំ តតោ ករេ ។

ន តំ មាតា បិតា កយិរា អញ្ញេ វាបិ ច ញាតកា
សម្មាបណិហិតំ ចិត្តំ សេយ្យសោ នំ តតោ ករេ ។

ចិត្តវគ្គោ តតិយោ ។

## ធម្មបទគាថាយ បុប្ផវគ្គោ

(៤៤) កោ ឥមំ បឋវឹ វិជេស្សតិ យមលោកញ្ច ឥមំ សទេវកំ (*)
កោ ធម្មបទំ សុទេសិតំ កុសលោ បុប្ផមិវ បចេស្សតិ ។

* ម. បុប្ផមិវប្បចេស្សតិ ។



ឱហ្ន៎ មិនយូរប៉ុន្មានទេតើ កាយនេះ មានវិញ្ញាណទៅប្រាស រមែងដេក ទៅចោលផុតហើយ មុខជានឹងដេកស្កកស្កឹងលើផែនដី ដូចជាអង្កត់ ទុស ឥតប្រយោជន៍ឥតខ្លឹម ។

ចោរក្រឡេកឃើញចោរដទៃ ឬក៏ បុគ្គលមានពៀរ ក្រឡេកឃើញ បុគ្គលមានពៀរដទៃ គប្បីធ្វើនូវសេចក្តីវិនាសណាមួយ ដល់គ្នា ចិត្តដែលបុគ្គលតាំងទុកខុសហើយ រមែងធ្វើបុគ្គលនោះ ឲ្យអាក្រក់ ក្រៃលែងជាងសេចក្តីវិនាសនោះទៅទៀត ។

មាតាបិតា មិនគប្បីធ្វើហេតុនោះបាន ឬជនទាំងឡាយដទៃជាញាតិ មិនគប្បីធ្វើនូវហេតុនោះបាន ចំណែកខាងចិត្ត ដែលបុគ្គលតាំងទុក ត្រូវហើយ រមែងធ្វើបុគ្គលនោះ ឲ្យប្រសើរជាងហេតុនោះបាន ។

ចប់ ចិត្តវគ្គទី៣ ។

## ធម្មបទគាថា បុប្ផវគ្គទី៤

(៤៤) អ្នកណានឹងដឹងច្បាស់នូវផែនដី គឺអត្តភាពនេះ នឹងយមលោកគឺ អបាយភូមិ ៤ នឹងមនុស្សលោកនេះព្រមទាំងទេវលោកបាន អ្នកណា នឹងជ្រើសរើសនូវចំណែកនៃធម៌ ដែលព្រះអង្គ សំដែងប្រពៃ ហើយ ដូចជាមាលាការដែលឈ្លាសវៃ ជ្រើសរើសនូវផ្កាផ្សេងៗបានដែរ ។

សេក្ខោ បឋវឹ វិចេស្សតិ យមលោកញ្ច ឥមំ សទេវកំ
សេក្ខោ ធម្មបទំ សុទេសិតំ កុសលោ បុប្ផមិវ បចេស្សតិ ។

ផេណូបមំ កាយមិមំ វិទិត្វា
មរីចិធម្មំ អភិសម្ពុធានោ
ឆេត្វាន មារស្ស បបុប្ផកានិ(១)
អទស្សនំ មច្ចុរាជស្ស គច្ឆេ ។

បុប្ផានិ ហេវ បចិនន្តំ(២) ព្យាសត្តមនសំ(៣) នរំ
សុត្តំ គាមំ មហោឃោវ មច្ចុ អាទាយ គច្ឆតិ ។

បុប្ផានិ ហេវ បចិនន្តំ ព្យាសត្តមនសំ នរំ
អតិត្តញ្ញេវ កាមេសុ អន្តកោ កុរុតេ វសំ ។

យថាបិ ភមរោ បុប្ផំ វណ្ណគន្ធំ អហេឋយំ(៤)
បលេតិ រសមាទាយ ឯវំ គាមេ មុនី ចរេ ។

---

១ ម. សបុប្ផកានិ ។ ២ ម. បចិនំ ។ ៣ ម. ព្យាសត្តមានសំ ។
៤ ម. វណ្ណគន្ធមហេឋយំ ។



ព្រះសេក្ខបុគ្គល នឹងពិចារណានូវផែនដីគឺអត្តភាពនេះ និងយម-
លោកគឺអបាយភូមិ ៤ និងមនុស្សលោកនេះព្រមទាំងទេវលោកផង
ព្រះសេក្ខបុគ្គល នឹងជ្រើសរើសនូវបទនៃធម៌ ដែលព្រះតថាគត
សំដែងប្រពៃហើយ ដូចមាលាការ ដែលឈ្លាសវៃ ជ្រើសរើស
នូវផ្កាដូច្នោះ ។

ភិក្ខុ កាលដឹងច្បាស់នូវកាយនេះថា ដូចជាពពុះទឹក ដឹងច្បាស់នូវ
កាយនេះថា មានសភាពដូចព្រៀងថ្ងៃ គប្បីកាត់នូវផ្កាជាប្រធាននៃ
មារទាំង ៣ ទៅកាន់ស្ថានជាទីមិនឃើញនៃមច្ចុរាជ ។

មច្ចុតែងកៀរយកទៅនូវនរជន អ្នកមានចិត្តជាប់ជំពាក់
ក្នុងកាមគុណផ្សេងៗ កំពុងជ្រើសរើសនូវផ្កា គឺកាមគុណ ៥ ដូចជា
ទឹកជំនន់ធំ ដែលកួចយកអ្នកស្រុកកំពុងដេកលក់ទៅ ដូច្នោះឯង ។
អ្នកធ្វើទីបំផុតគឺមរណៈ តែងធ្វើនូវនរជន ដែលមានចិត្តជាប់ជំពាក់
ក្នុងកាមគុណផ្សេងៗ កំពុងជ្រើសរើសនូវផ្កា គឺកាមគុណ ៥ មិនទាន់
ឆ្អែតក្នុងកាមទាំងឡាយនុ៎ះឯង ឱ្យនៅក្នុងអំណាចរបស់ខ្លួន ។
ភមរជាតិ មិនធ្វើផ្កាឈើដែលមានពណ៌និងក្លិនឱ្យវិនាសទេ ក្រេប
យកតែរស ហើយទៅ យ៉ាងណាមិញ អ្នកប្រាជ្ញ គប្បីត្រាច់ទៅ
ក្នុងស្រុក ក៏យ៉ាងនោះឯង ។

ន បរេសំ វិលោមានិ ន បរេសំ កតាកតំ

អត្តនោវ អវេក្ខេយ្យ កតានិ អកតានិ ច ។

យថាបិ រុចិរំ បុប្ផំ វណ្ណវន្តំ អគន្ធកំ

ឯវំ សុភាសិតា វាចា អផលា ហោតិ អកុព្វតោ ។

យថាបិ រុចិរំ បុប្ផំ វណ្ណវន្តំ សគន្ធកំ[១]

ឯវំ សុភាសិតា វាចា សផលា ហោតិ សុកុព្វតោ ។

យថាបិ បុប្ផរាសិម្ហា កយិរា មាលាគុណេ ពហូ

ឯវំ ជាតេន មច្ចេន កត្តព្វំ កុសលំ ពហុំ ។

ន បុប្ផគន្ធោ បដិវាតមេតិ

ន ចន្ទនំ តគរមល្លិកា[២]វា

---

១ ម. សុគន្ធំ ។ ២ ម. តគរំ មល្លិកា ។



ពាក្យពាក់ដោតទាំងឡាយរបស់ជនដទៃ បុគ្គលមិនគួរធ្វើទុកក្នុងចិត្តទេ កិច្ចដែលធ្វើហើយនិងមិនទាន់ធ្វើហើយរបស់ជនដទៃ (ដែលមិនមែនជាធុរការរបស់ខ្លួន) បុគ្គលមិនគួរគិតរិះរកមើលទេ បុគ្គលគួរគិតរិះពិចារណា តែកិច្ចការទាំងឡាយ ដែលធ្វើហើយ និងមិនទាន់ធ្វើហើយ របស់ខ្លួនតែម្យ៉ាង ។

ផ្កាឈើមានទ្រង់ទ្រាយល្អ មានពណ៌ (ល្អ) តែគ្មានក្លិន (ក្រអូប) ( រមែងមិនក្រអូបដល់អ្នកដែលទ្រទ្រង់ ) យ៉ាងណាមិញ ពាក្យសុភាសិត រមែងគ្មានផលដល់អ្នកដែលមិនធ្វើតាមយ៉ាងនោះ ផ្កាឈើដែលមានទ្រង់ទ្រាយល្អ មានពណ៌ មានក្លិន (រមែងក្រអូបដល់អ្នកដែលទ្រទ្រង់) យ៉ាងណាមិញ ពាក្យសុភាសិត រមែងមានផលដល់អ្នកដែលធ្វើតាមដោយគោរព យ៉ាងនោះដែរ ។

មាលាការ រមែងធ្វើសំណុំនៃកម្រងផ្កា អំពីគំនរនៃផ្កា (ផ្សេងៗ) ឲ្យច្រើនបាន យ៉ាងណាមិញ កុសលដែលសត្វកើតមកហើយ គួរធ្វើឲ្យច្រើន យ៉ាងនោះ ។

ក្លិនផ្កាឈើ ផ្សាយទៅច្រាសខ្យល់ មិនបាន ក្លិនខ្លឹមច័ន្ទន៍ក្តី ក្លិនខ្ទឹមក្រស្នាក្តី ក្លិនផ្កាម្លិះក្តី ក៏ផ្សាយទៅច្រាសខ្យល់ មិនបាន

សតញ្ច គន្ធោ បដិវាតមេតិ
សព្វា ទិសា សប្បុរិសោ បវាយតិ[១] ។
ចន្ទនំ តគរំ វាបិ ឧប្បលំ អថ វស្សិកី
ឯតេសំ គន្ធជាតានំ សីលគន្ធោ អនុត្តរោ ។
អប្បមត្តោ អយំ គន្ធោ យ្វាយំ តគរចន្ទនី[២]
យោ ច សីលវតំ គន្ធោ វាតិ ទេវេសុ ឧត្តមោ ។
តេសំ សម្បន្នសីលានំ អប្បមាទវិហារិនំ
សម្មទញ្ញា វិមុត្តានំ មារោ មគ្គំ ន វិន្ទតិ ។
យថា សង្ការធានស្មឹ[៣] ឧជ្ឈិតស្មឹ មហាបថេ
បទុមំ តត្ថ ជាយេថ សុចិគន្ធំ មនោរមំ
ឯវំ សង្ការភូតេសុ អន្ធភូតេ[៤] បុថុជ្ជនេ
អតិរោចតិ បញ្ញាយ សម្មាសម្ពុទ្ធសាវកោ ។

បុប្ផវគ្គោ ចតុត្ថោ ។

---

១ ម. វាតិ ។ ២ ម. តគរចន្ទនំ ។ ៣ ម. សង្ការដ្ឋានស្មឹំ ចាហ ។
៤ ម. អន្ធីភូតេ ។



ចំណែកក្លិនរបស់សប្បុរសទាំងឡាយ រមែងផ្សាយទៅច្រាសខ្យល់បាន ព្រោះសប្បុរស រមែងផ្សាយទៅបានគ្រប់ទិស ។ ក្លិននៃសីល ជាគុណជាតប្រសើរបំផុតជាងក្លិនជាតទាំងនេះគឺ ខ្លឹមចន្ទន៍ ខ្លឹមក្រស្នា ផ្កាឧប្បល ផ្កាម្លិះ ។

ក្លិនក្រស្នា នឹងក្លិនចន្ទន៍ណា ក្លិននេះ ក្រអូបមានប្រមាណតិចទេ ចំណែកក្លិននៃបុគ្គលមានសីលទាំងឡាយណា ក្លិននោះ ទើបក្រអូបលើសលប់ ផ្សាយទៅក្នុងទេវលោកនឹងមនុស្សលោកបាន ។

មារមិនដឹង (ទីកន្លែងទៅកើត) ក៏មិនជួបផ្លូវរបស់លោក អ្នកមានសីលបរិបូណ៌ អ្នកនៅដោយសេចក្ដីមិនប្រមាទ អ្នករួចស្រឡះ (ចាកធម៌ជាគ្រឿងសៅហ្មង) ព្រោះដឹងច្បាស់តាមហេតុ ។

ផ្កាឈូក ទុកជាកើតក្នុងគំនរសម្រាម ដែលគេចាក់ចោលក្បែរផ្លូវធំនោះ ក៏គង់មានក្លិនក្រអូប ជាទីពេញចិត្តបាន ដូចម្ដេចមិញ បណ្ដាជន ដែលដូចជាគំនរសម្រាម សាវ័ករបស់ព្រះសម្មាសម្ពុទ្ធ រមែងរុងរឿងកន្លងផុតបុថុជ្ជនទាំងឡាយ ដែលល្ងិតល្ងង់ ដោយប្រាជ្ញា (របស់ខ្លួន) ដូច្នោះឯង ។

ចប់ ពួកទី ៤ ។

# ធម្មបទគាថាយ បញ្ចមោ ពាលវគ្គោ

[១៥] ទីឃា ជាគរតោ រត្តិ ទីឃំ សន្តស្ស យោជនំ
ទីឃោ ពាលាន សំសារោ សទ្ធម្មំ អវិជានតំ ។
ចរញ្ចេ នាធិគច្ឆេយ្យ សេយ្យំ សទិសមត្តនោ
ឯកចរិយំ ទឡ្ហំ កយិរា នត្ថិ ពាលេ សហាយតា ។
បុត្តា(១) មត្ថិ ធនម្មត្ថិ(២) ឥតិ ពាលោ វិហញ្ញតិ
អត្តា ហិ អត្តនោ នត្ថិ កុតោ បុត្តា(៣) កុតោ ធនំ ។
យោ ពាលោ មញ្ញតី(៤) ពាល្យំ បណ្ឌិតោ វាបិ តេន សោ
ពាលោ ច បណ្ឌិតមានី ស វេ ពាលោតិ វុច្ចតិ ។

---

១ ម. បុត្ត ។ ២ ម. ធនមត្ថិ ។ ៣ ម. បុត្តោ ។ ៤ ម. មញ្ញតិ ។



# ធម្មបទគាថា ពាលវគ្គទី ៥

(១៥) រាត្រីវែង ចំពោះតែអ្នកភ្ញាក់ឮក (អ្នកដេកមិនលក់) យោជន៍វែង ចំពោះតែអ្នកនឿយហត់ សង្សារវដ្តវែង ចំពោះតែបុគ្គលពាល មិនដឹងច្បាស់នូវព្រះសទ្ធម្ម ។

បុគ្គលពាលស្វះស្វែងរកកល្យាណមិត្ត បើមិនបានមិត្តដ៏ប្រសើរជាងខ្លួន ឬមិត្តដែលស្មើនឹងខ្លួនទេ គប្បីប្រព្រឹត្តនៅតែម្នាក់ឯង ឲ្យខ្ជាប់ខ្ជួនវិញ ព្រោះថាសហាយតាគុណ(១)មិនមានក្នុងបុគ្គលពាលឡើយ ។

ជនពាលតែងក្រួយលំបាក ដោយសេចក្តីសំគាល់ថា កូនទាំងឡាយរបស់អញមាន ទ្រព្យរបស់អញមាន តាមដែលពិត សូម្បីខ្លួនរបស់ខ្លួនក៏មិនមាន (២) ចំណង់បើកូនទាំងឡាយ នឹងរាប់ជាមានអំពីណាបាន ទ្រព្យនឹងរាប់ជា មានអំពីណាបាន ។

អ្នកណា ជាមនុស្សពាល ហើយដឹងនូវភាពនៃខ្លួនថាជាពាល អ្នកនោះនឹងទៅជាបណ្ឌិតបានខ្លះ ដោយហេតុដែលដឹងខ្លួន ថាជាពាលនោះ ម្យ៉ាងទៀត អ្នកណា ជាមនុស្សពាល មានសេចក្តីប្រកាន់ថាខ្លួនជាបណ្ឌិត អ្នកនោះ ឈ្មោះថាជាមនុស្សពាល ដោយពិត ។

---

១ ចូឡសីល, មជ្ឈិមសីល, មហាសីល, កថាវត្ថុ១០, ធុតង្គគុណ១៣, វិបស្សនាញាណ, មគ្គ៤, ផល៤, វិជ្ជា៣ អភិញ្ញា៦, ហៅថា សហាយតាគុណ ។ ២ ព្រោះមិនអាចនឹងឃាត់ឃាំងខ្លួនបាន ។ អដ្ឋកថា ។

យាវជីវម្បិ ចេ ពាលោ បណ្ឌិតំ បយិរុបាសតិ
ន សោ ធម្មំ វិជានាតិ ទព្វី សូបរសំ យថា ។
មុហុត្តមបិ ចេ វិញ្ញូ បណ្ឌិតំ បយិរុបាសតិ
ខិប្បំ ធម្មំ វិជានាតិ ជិវ្ហា សូបរសំ យថា ។
ចរន្តិ ពាលា ទុម្មេធា អមិត្តេនេវ អត្តនា
ករោន្តា[១] បាបកំ កម្មំ យំ ហោតិ កដុកប្ផលំ[២] ។
ន តំ កម្មំ កតំ សាធុ យំ កត្វា អនុតប្បតិ
យស្ស អស្សុមុខោ រោទំ វិបាកំ បដិសេវតិ ។
តញ្ច កម្មំ កតំ សាធុ យំ កត្វា នានុតប្បតិ
យស្ស បតីតោ សុមនោ វិបាកំ បដិសេវតិ ។
មធុវា មញ្ញតី ពាលោ យាវ បាបំ ន បច្ចតិ
យទា ច បច្ចតី បាបំ អថ[៣] [ពាលោ] ទុក្ខំ និគច្ឆតិ ។

---

១ ម. ករោន្តិ ។ ២ ម. កដុកំ ផលំ ។ ៣ ម. អថពាលោ ទុក្ខំ ។



មនុស្សពាល បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីអស់មួយជីវិត ក៏ឥតមានដឹងសេចក្ដីអ្វី ឲ្យច្បាស់លាស់ឡើយ ដូចវែក ដែលមិនដឹងរសសម្ល ។

វិញ្ញូជន បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីតែមួយរំពេច រមែងយល់សេចក្ដី ដោយឆាប់រហ័ស ដូចអណ្ដាត ដឹងនូវរសសម្ល ។

ពួកជនពាលមិនមានប្រាជ្ញា មានខ្លួនដូចជាសត្រូវ តែងធ្វើកម្មលាមក ដែលជាទីកើតមានផលក្ដៅក្រហាយ ។

បុគ្គលធ្វើកម្មណាហើយ រមែងក្ដៅក្រហាយ ទាំងមានមុខប្រឡាក់ ដោយទឹកភ្នែក ស្រែកយំ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះ ឈ្មោះថាជាកម្មមិនល្អឡើយ ។

បុគ្គលធ្វើកម្មណាហើយ រមែងមិនក្ដៅក្រហាយ ទទួលនូវសេចក្ដីពេញចិត្ត មានចិត្តល្អ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះឯង ឈ្មោះថាជាកម្មល្អ ។

បាបមិនទាន់ឲ្យផលត្រឹមណា ជនពាល តែងសំគាល់នូវបាបនោះថា ដូចទឹកឃ្មុំ លុះតែកាលណាបាបឲ្យផល ជនពាលទើបប្រទះនូវសេចក្ដីទុក្ខ ក្នុងកាលនោះ ។

មាសេ មាសេ កុសគ្គេន ពាលោ ភុញ្ជេថ ភោជនំ

ន សោ សង្ខាតធម្មានំ កលំ អគ្ឃតិ សោឡសឹ ។

ន ហិ បាបំ កតំ កម្មំ សជ្ជុខីរំ មុច្ចតិ

ឌហន្តំ ពាលមន្វេតិ ភស្មាច្ឆន្នោ[1]វ បាវកោ ។

យាវទេវ អនត្ថាយ ញត្តំ ពាលស្ស ជាយតិ

ហន្តិ ពាលស្ស សុក្កំសំ មុទ្ធំ អស្ស[2]វិបាតយំ ។

អសន្តំ ភាវនមិច្ឆេយ្យ បុរេក្ខារញ្ច ភិក្ខុសុ

អាវាសេសុ ច ឥស្សរិយំ បូជា បរកុលេសុ ច ។

១ ម. ភស្មច្ឆន្នោ ។ ២ ម. មុទ្ធមស្ស ។



ជនពាលគប្បីបរិភោគភោជនដោយចុង(១)ស្បូវ គ្រប់ៗខែ ជនពាល នោះក៏មិនដល់មួយចំណិតនៃចំណែកទី ១៦ ។ លើក របស់បុគ្គលទាំងឡាយ ដែលមានធម៌បានដឹង ឬបានពិចារណាហើយឡើយ ។ កម្មលាមក ដែលជនពាលធ្វើហើយ មិនទាន់ឲ្យផលនោះក៏មាន ដូចទឹកដោះស្រស់ ដែលមិនទាន់ប្រែក្លាយ ( ក្នុង ១ ពេល ) ដូច្នោះ បាបកម្មនោះ រមែងតាមបុគ្គលពាល ដូចរងើកភ្លើងដែលបិទបាំងទុកដោយផេះដូច្នោះ ។

ការចេះដឹង កើតឡើងដល់បុគ្គលពាល គ្រាន់តែដើម្បីសេចក្តីវិនាសប៉ុណ្ណោះ រមែងញ៉ាំងបញ្ញាឲ្យធ្លាក់ចុះ បំផ្លិចបំផ្លាញចំណែកធម៌សគឺកុសលរបស់បុគ្គលពាលនោះ ។ ភិក្ខុពាល រមែងប្រាថ្នានូវសេចក្តីសរសើរ ដែលមិនមាន(ក្នុងខ្លួន)ផង នូវការធ្វើក្នុងទីមុខគឺជាប្រមុខ ក្នុងពួកភិក្ខុផង នូវភាពជាឥស្សរៈ ក្នុងអាវាសទាំងឡាយផង នូវការបូជាទាំងឡាយ ក្នុងត្រកូលនៃជនទាំងឡាយ ដទៃ ផង

១ បានសេចក្តីថា យកចុងស្បូវទៅចាក់ភោជន ហើយយកមកដាក់លើចុងអណ្តាត ចំពោះតែម្តងនេះ ព្រោះមនុស្សប្រុសនិងស្រីនៃប្រាថ្នាចង់ធ្វើខ្លួនជាអ្នក ដែលជាអ្នកប្រព្រឹត្តបរិភោគ តិចតួចតែប៉ុណ្ណោះ ក្នុងពេលដែលមានតែមួយលើក ។

មមេវ កត មញ្ញន្តុ គិហិបព្វជិតា ឧភោ
មមេវ អតិវសា[១] អស្សុ កិច្ចាកិច្ចេសុ កិស្មិចិ[២]
ឥតិ ពាលស្ស សង្កប្បោ ឥស្សា[៣] មានោ ច វឌ្ឍតិ ។
អញ្ញា ហិ លាភូបនិសា អញ្ញា និព្វានគាមិនី
ឯវមេតំ អភិញ្ញាយ ភិក្ខុ ពុទ្ធស្ស សាវកោ
សក្ការំ នាភិនន្ទេយ្យ វិវេកមនុព្រូហយេ ។

ពាលវគ្គោ បញ្ចមោ ។

## ធម្មបទគាថាយ ឆដ្ឋោ បណ្ឌិតវគ្គោ

(៧៦) និធីនំវ បវត្តារំ យំ បស្សេ វជ្ជទស្សិនំ
និគ្គយ្ហវាទឹ មេធាវឹ តាទិសំ បណ្ឌិតំ ភជេ
តាទិសំ ភជមានស្ស សេយ្យោ ហោតិ ន បាបិយោ ។

១ ឆ, ម, មមេវាតិវសា ។ ២ ម; កិស្មិញ្ចិ ។ ៣ ឆ, ម, ឥច្ឆា ។



ភិក្ខុពាល តែងមានសេចក្ដីត្រិះរិះថា គ្រហស្ថនឹងបព្វជិត ទាំង ២ ពួក ចូរសំគាល់នូវកិច្ចដែលមនុស្សដទៃធ្វើហើយថាជាកិច្ចរបស់អញវិញ អំណាចដ៏ក្រៃលែងរបស់អញ ចូរមាននូវកិច្ច តូច ធំ ណា ១ មួយ (កាលបើយ៉ាងនេះ) ឫស្យា នឹងមានះ រមែងចំរើន ។ បដិបទា អាស្រ័យនូវលាភផ្សេង បដិបទា ជាដំណើរទៅកាន់ព្រះនិព្វានផ្សេង ភិក្ខុជាសាវ័ករបស់ព្រះពុទ្ធ ដឹងច្បាស់នូវហេតុទាំងពីរយ៉ាងនេះហើយ មិនត្រូវត្រេកអរចំពោះសក្ការៈឡើយ គប្បីញ៉ាំងវិវេកឲ្យចំរើនដោយលំដាប់ ។

ចប់ ពាលវគ្គទី ៥ ។

## ធម្មបទគាថា បណ្ឌិតវគ្គទី ៦

(៧៦) បុគ្គលគប្បីឃើញនូវអ្នកប្រាជ្ញណា ដែលជាអ្នកពោលសង្កត់សង្កិន ចង្អុលប្រាប់ទោស ដូចជាបុគ្គលអ្នកប្រាប់កំណប់ទ្រព្យឲ្យ ដូច្នោះ គួរគប់អ្នកប្រាជ្ញបែបនោះ ( ព្រោះថា ) កាលបុគ្គលគប់អ្នកប្រាជ្ញបែបនោះហើយ រមែងមានសេចក្ដីល្អប្រសើរ ឥតមានទោសដ៏លាមកឡើយ ។

ឱវាទេយ្យានុសាសេយ្យ អសព្ភា ច និវារយេ
សតំ ហិ សោ បិយោ ហោតិ អសតំ ហោតិ អប្បិយោ ។
ន ភជេ បាបកេ មិត្តេ ន ភជេ បុរិសាធមេ
ភជេថ មិត្តេ កល្យាណេ ភជេថ បុរិសុត្តមេ ។
ធម្មបីតិ សុខំ សេតិ វិប្បសន្នេន ចេតសា
អរិយប្បវេទិតេ ធម្មេ សទា រមតិ បណ្ឌិតោ ។

ឧទកញ្ហិ នយន្តិ នេត្តិកា
ឧសុការា នមយន្តិ(១) តេជនំ
ទារុំ នមយន្តិ(១) តច្ឆកា
អត្តានំ ទមយន្តិ បណ្ឌិតា ។

សេលោ យថា ឯកឃនោ វាតេន ន សមីរតិ
ឯវំ និន្ទាបសំសាសុ ន សមិញ្ជន្តិ បណ្ឌិតា ។
យថាបិ រហទោ គម្ភីរោ វិប្បសន្នោ អនាវិលោ
ឯវំ ធម្មានិ សុត្វាន វិប្បសីទន្តិ បណ្ឌិតា ។

(១) ម. នមេន្តិ ។



បណ្ឌិតគួរទូន្មានប្រៀនប្រដៅ គួរហាមឃាត់នូវជនទាំងឡាយចាក អំពើអសប្បុរស បណ្ឌិតនោះ រមែងជាទីស្រឡាញ់របស់សប្បុរស តែម្យ៉ាង មិនជាទីស្រឡាញ់នៃអសប្បុរសឡើយ ។

បុគ្គល មិនគួរគប់មិត្តអាក្រក់ មិនគួរគប់បុរសថោកទាប គួរគប់តែមិត្តដែលល្អ គួរគប់តែបុរសជាន់ខ្ពស់ ។

បណ្ឌិត ដែលមានសេចក្ដីឆ្អែតក្នុងធម៌ មានចិត្តជ្រះថ្លាហើយ រមែងដេកជាសុខ រមែងត្រេកអរ ក្នុងធម៌ដែលព្រះអរិយៈ ប្រកាសទុកហើយ គ្រប់កាល ។

ធម្មតាអ្នកបង្ហូរទឹក តែងបង្ហូរទឹកទៅ អ្នកធ្វើព្រួញ តែងពត់ព្រួញ (ឲ្យត្រង់) អ្នកចាំងឈើ តែងចាំងឈើ ឯបណ្ឌិតទាំងឡាយ តែងទូន្មានខ្លួន(ដូច្នោះដែរ) ។

ភ្នំថ្មតាន់ មិនរំភើប ព្រោះខ្យល់ ដូចម្ដេចមិញ បណ្ឌិតទាំងឡាយ ក៏មិនរំភើប ព្រោះពាក្យតិះដៀល និងពាក្យសរសើរ (ជាដើម) ដូច្នោះឯង ។

អន្លង់ទឹកដែលជ្រៅ រមែងថ្លាមិនល្អក់យ៉ាងណា បណ្ឌិតទាំងឡាយ បើបានស្ដាប់ធម៌ទេសនាហើយ រមែងជ្រះថ្លាស៊ប់ស្ងួន យ៉ាងនោះ ។

សព្វត្ថ វេ សប្បុរិសា ចជន្តិ[១]
ន កាមកាមា លបយន្តិ សន្តោ
សុខេន ផុដ្ឋា អថ វា ទុខេន
ន ឧច្ចាវចំ បណ្ឌិតា ទស្សយន្តិ ។
ន អត្តហេតុ ន បរស្ស ហេតុ
ន បុត្តមិច្ឆេ ន ធនំ ន រដ្ឋំ
ន ឥច្ឆេយ្យ អធម្មេន សមិទ្ធិមត្តនោ
ស សីលវា បញ្ញវា ធម្មិកោ សិយា ។

អប្បកា តេ មនុស្សេសុ យេ ជនា បារគាមិនោ
អថាយំ ឥតរា បជា តីរមេវានុធាវតិ ។
យេ ច ខោ សម្មទក្ខាតេ ធម្មេ ធម្មានុវត្តិនោ
តេ ជនា បារមេស្សន្តិ មច្ចុធេយ្យំ សុទុត្តរំ ។
កណ្ហំ ធម្មំ វិប្បហាយ សុក្កំ ភាវេថ បណ្ឌិតោ

១. វជន្តិ ។ ម. វជ្ជន្តិ ។



ពួកសប្បុរស តែងលះ (ឆន្ទរាគ) ក្នុងធម៌ទាំងពួង ពួកលោកអ្នកស្ងប់ រមែងមិនរអែរអួ ព្រោះសេចក្តីប្រាថ្នាក្នុងកាម ពួកបណ្ឌិតប៉ះសេចក្តីសុខឬទុក្ខពាល់ត្រូវហើយ រមែងមិនសំដែងអាការឡើងចុះឡើយ ។

បណ្ឌិតមិនគួរធ្វើអាក្រក់ ព្រោះហេតុនៃខ្លួន មិនគួរធ្វើអាក្រក់ ព្រោះហេតុនៃអ្នកដទៃ មិនគួរប្រាថ្នាកូន មិនគួរប្រាថ្នាទ្រព្យ មិនគួរប្រាថ្នាដែន មិនគួរប្រាថ្នាសិទ្ធិ ដើម្បីខ្លួន ដោយហេតុមិនមែនជាធម៌ឡើយ លោកគួរជាអ្នកមានសីល មានប្រាជ្ញាប្រកបដោយធម៌ ។

បណ្ដាមនុស្សទាំងឡាយ ពួកជនណា ដែលឆ្លងដល់ត្រើយគឺព្រះនិព្វាន ពួកជននោះ មានប្រមាណតិច ចំណែកពួកសត្វក្រៅនេះ រមែងស្ទុះទៅកាន់ត្រើយ (គឺសក្កាយទិដ្ឋិ) ។

ជនទាំងឡាយណា ប្រព្រឹត្តតាមធម៌ក្នុងធម៌ ដែលព្រះតថាគតទ្រង់សំដែងទុកហើយដោយប្រពៃ ជនទាំងនោះនឹងឆ្លងផុតលំនៅនៃមច្ចុ ដែលមិនងាយឆ្លងបាន ហើយដល់នូវព្រះនិព្វាន ។

បណ្ឌិតគួរលះបង់ធម៌ខ្មៅ[១]ចេញ ញុំាងធម៌[២]ស ឲ្យចំរើនឡើង

១ អកុសលធម៌ មានកាយទុច្ចរិតជាដើម ។ ២ កុសលធម៌មានកាយសុចរិតជាដើម ។ អដ្ឋកថា ។

ឱកា អនោកមាគម្ម វិវេកេ យត្ថ ទូរមំ

តត្រាភិរតិមិច្ឆេយ្យ ហិត្វា កាមេ អកិញ្ចនោ

បរិយោទបេយ្យ អត្តានំ ចិត្តក្លេសេហិ បណ្ឌិតោ ។

យេសំ សម្ពោធិយង្គេសុ សម្មា ចិត្តំ សុភាវិតំ

អាទានបដិនិស្សគ្គេ អនុបាទាយ យេ រតា

ខីណាសវា ជុតិមន្តោ តេ លោកេ បរិនិព្វុតា ។

បណ្ឌិតវគ្គោ ឆដ្ឋោ ។

## ធម្មបទគាថាយ សត្តមោ អរហន្តវគ្គោ

(៩០) គតទ្ធិនោ វិសោកស្ស វិប្បមុត្តស្ស សព្វធិ

សព្វគន្ថប្បហីនស្ស បរិឡាហោ ន វិជ្ជតិ ។



(ដោយវិធី)ចេញចាកអាល័យគឺកាមគុណ ហើយឈប់នៅក្នុងព្រះនិព្វាន ជាធម្មជាតមិនមានអាល័យ គប្បីលះបង់កាមទាំងឡាយចេញ ជាអ្នកមិនមានកង្វល់ ប្រាថ្នានូវសេចក្ដីត្រេកអរ ក្នុងវិវេកដែលពួកសត្វត្រេកអរបានដោយក្រនោះ បណ្ឌិតគប្បីញ៉ាំងខ្លួនឲ្យផូរផង់ចាកគ្រឿងសៅហ្មងចិត្ត ។ ចិត្តដែលបណ្ឌិតទាំងឡាយណា ចំរើនល្អហើយ ក្នុងអង្គនៃធម៌ ជាគ្រឿងត្រាស់ដឹងទាំងឡាយ ។ បណ្ឌិតទាំងឡាយណា មិនប្រកាន់មាំ ត្រេកអរក្នុងការលះនូវសេចក្ដីប្រកាន់មាំ បណ្ឌិតទាំងឡាយនោះ ។ ដែលជាអ្នកអស់អាសវៈ មានសេចក្ដីរុងរឿង បរិនិព្វាន ក្នុងលោក ។

ចប់ បណ្ឌិតវគ្គទី ៦ ។

## ធម្មបទគាថា អរហន្តវគ្គទី ៧

(៩០) សេចក្ដីក្ដៅក្រហាយ(១) រមែងមិនមានដល់លោកអ្នក មានផ្លូវឆ្ងាយដើរដល់(២)ហើយ មិនមានសេចក្ដីសោក រួចស្រឡះចាកធម៌ទាំងពួង (មានខន្ធជាដើម)មានកិលេសជាគ្រឿងចាក់ស្រេះទាំងពួងលះបង់ហើយ ។

---

១ សេចក្ដីក្ដៅក្រហាយមានពីរយ៉ាង គឺក្ដៅក្រហាយកាយ ១ ក្ដៅក្រហាយចិត្ត ១ ព្រះខីណាស្រព នៅមានសេចក្ដីក្ដៅក្រហាយកាយ ព្រោះគំលាយរំងាប់ក្ដៅឬត្រជាក់ជាដើមនៃក្ដៅក្រហាយក្នុងចិត្ត មិនមាន ក្នុងទីនេះសំដៅសេចក្ដីក្ដៅក្រហាយក្នុងចិត្ត ។ ២ ផ្លូវឆ្ងាយក្នុងទីនេះ សំដៅយកវដ្ដៈដែលហៅថាវដ្ដៈ ។ ពួកសត្វដែលជាប់ក្នុងវដ្ដៈ នៅក្នុងវដ្ដៈដរាបណា ឈ្មោះថាជាអ្នកដើរផ្លូវឆ្ងាយដរាបនោះ ព្រះអរហន្តបុគ្គលទាំងនោះ កំពុងដើរក្នុងផ្លូវឆ្ងាយដែរ ព្រោះមិនទាន់អស់វដ្ដៈ តែព្រះខីណាស្រពលោកផុតវដ្ដៈរួចស្រេចហើយ ទើបឈ្មោះថាជាអ្នកដើរផុតផ្លូវឆ្ងាយដើរដល់ហើយ ។

ឧយ្យុញ្ជន្តិ សតីមន្តោ ន និកេតេ រមន្តិ តេ
ហំសាវ បល្លលំ ហិត្វា ឱកមោកំ ជហន្តិ តេ ។

យេសំ សន្និចយោ នត្ថិ យេ បរិញ្ញាតភោជនា
សុញ្ញតោ អនិមិត្តោ ច វិមោក្ខោ យេស គោចរោ
អាកាសេវ សកុន្តានំ[១] គតិ តេសំ ទុរន្នយា ។

យស្សាសវា បរិក្ខីណា អាហារេ ច អនិស្សិតោ
សុញ្ញតោ អនិមិត្តោ ច វិមោក្ខោ យស្ស គោចរោ
អាកាសេវ សកុន្តានំ[១] បទំ តស្ស ទុរន្នយំ ។

យស្សិន្ទ្រិយានិ សមថង្គតានិ
អស្សា យថា សារថិនា សុទន្តា
បហីនមានស្ស អនាសវស្ស
ទេវាបិ តស្ស បិហយន្តិ តាទិនោ ។

១ ម. សកុណានំ ។





ព្រះខីណាស្រពទាំងឡាយ មានស្មារតី រមែងខ្វល់ខ្វាយ[១] រមែងមិនត្រេកអរ ក្នុងទីនៅអាស្រ័យ លោកលះបង់ចោលស្រឡះ នូវអាល័យទាំងអស់ ដូចហង្សលះបង់ភក់ហើយទៅ ដូច្នោះ ។ ពួកជនណា មិនមានសេចក្ដីសន្សំ ពួកជនណា កំណត់ដឹងភោជន ហើយ ជនណា មានសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ និងអប្បណិហិត-វិមោក្ខ ជាគោចរ គតិដំណើរ របស់ពួកជននោះៗ គេត្រូវដឹងបាន ដូចដំណើរនៃពួកសត្វស្លាបក្នុងអាកាស ដូច្នោះ ។ ជនណា អស់អាសវៈហើយ ទាំងមិនអាស្រ័យ (តណ្ហានិងទិដ្ឋិ) ក្នុងអាហារ ជនណា មានសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ និងអប្បណិហិតវិមោក្ខ ជាគោចរ ដំណើររបស់ជននោះ គេត្រូវដឹងបាន ដូចដំណើរនៃពួកសត្វស្លាបក្នុងអាកាស ដូច្នោះ ។ ឥន្ទ្រិយទាំងឡាយ របស់អ្នកណា ដល់នូវការស្ងប់ស្ងាប់ ដូចសេះ ដែលនាយសារថី ទូន្មានល្អហើយ សូម្បីទេវតានិងមនុស្ស ទាំងឡាយ ក៏ស្រឡាញ់អ្នកនោះផង ដែលមានមានៈលះបង់ហើយ មិនមានអាសវៈ ជាបុគ្គលមានចិត្តនឹងនឹងមិនញាប់ញ័រ ។

១ ខ្វល់ខ្វាយក្នុងគុណដែលខ្លួនបានហើយ ឬក្នុងឈាននិងវិបស្សនា ដោយកិច្ចគឺ ចូលទៅ ចេញ អធិដ្ឋាន ឬពិចារណាមិនមានសេចក្ដីប្រមាទ ។ អដ្ឋកថា ។

បឋវីសមោ នោ វិរុជ្ឈតិ
ឥន្ទខីលុបមោ តាទិ សុព្វតោ
រហទោវ អបេតកទ្ទមោ
សំសារា ន ភវន្តិ តាទិនោ ។
សន្តំ តស្ស មនំ ហោតិ
សន្តា វាចា ច កម្ម ច
សម្មទញ្ញា វិមុត្តស្ស
ឧបសន្តស្ស តាទិនោ ។
អស្សទ្ធោ អកតញ្ញូ ច
សន្ធិច្ឆេទោ ច យោ នរោ
ហតាវកាសោ វន្តាសោ
ស វេ ឧត្តមបោរិសោ ។
គាមេ វា យទិ វារញ្ញេ
និន្នេ វា យទិ វា ថលេ
យត្ថ អរហន្តោ វិហរន្តិ
តំ ភូមិរាមណេយ្យកំ(១) ។

១. ភូមិំ រាមណេយ្យកំ ។



ភិក្ខុមានចិត្តដូចផែនដី មិនក្រោធ មានវត្តល្អ មានចិត្តនឹងធឹងដូចសសរគោល មានចិត្តថ្លា ដូចអន្លង់ប្រាសចាកភក់ សង្សារទាំងឡាយរបស់ភិក្ខុបែបនោះ រមែងមិនមាន ។

ចិត្តស្ងប់ វាចាស្ងប់ នឹងកាយកម្មស្ងប់ រមែងមាន ដល់លោកដែលដឹងដោយប្រពៃ ផុតស្រឡះ (ចាកកាមកិលេស) ជាអ្នកស្ងប់រម្ងាប់ ដូច្នោះ ។

នរជនណា មិនជឿតាមអ្នកដទៃផង ស្គាល់ព្រះនិព្វានផង កាត់ខ្សែស្រឡៀតនៃភពផង មានឱកាសកាត់ផ្តាច់ហើយផង មានសេចក្តីប្រាថ្នាខ្ជាក់ចោលហើយផង នរជននោះ ជាឧត្តមបុរស ។

ព្រះអរហន្តទាំងឡាយ នៅក្នុងទីណា ទោះជាស្រុកក្តី ព្រៃក្តី ទីទាបក្តី ទីទួលក្តី ទីនោះឯង ជាភូមិ គួរត្រេកអរ ។

រមណីយានិ អរញ្ញានិ
យត្ថ ន រមតី ជនោ
វីតរាគា រមិស្សន្តិ
ន តេ កាមគវេសិនោ ។

អរហន្តវគ្គោ សត្តមោ ។

## ធម្មបទគាថាយ អដ្ឋមោ សហស្សវគ្គោ

(១៩) សហស្សមបិ ចេ វាចា អនត្ថបទសញ្ហិតា
ឯកំ អត្ថបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។
សហស្សមបិ ចេ គាថា អនត្ថបទសញ្ហិតា
ឯកំ គាថាបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។
យោ ច គាថា សតំ ភាសេ អនត្ថបទសញ្ហិតា[១]
ឯកំ ធម្មបទំ[២] សេយ្យោ យំ សុត្វា ឧបសម្មតិ ។

១ ម· អនត្ថបទសញ្ហិតំ ។ ២ ម· គាថាបទំ ។





ជន (អ្នកស្វែងរកកាម) រមែងមិនត្រេកអរ ក្នុងព្រៃដែលគួររីករាយទេ ព្រះអរិយណាស្រកដែលមានរាគៈទៅប្រាសហើយ រមែងត្រេកអរក្នុងព្រៃនោះ ព្រោះពួកលោកជាអ្នក មិនស្វែងរកកាម ។

ចប់ អរហន្តវគ្គទី ៧ ។

## ធម្មបទគាថា សហស្សវគ្គ ទី ៨

(១៨) បើវាចា សូម្បីមួយពាន់ ជាវាចាប្រកបដោយបទឥតប្រយោជន៍ វាចានោះ ក៏មិនប្រសើរឡើយ អ្នកណា ស្ដាប់បទមានប្រយោជន៍ណា ហើយ រមែងស្ងប់រម្ងាប់បាន បទមានប្រយោជន៍នោះ សូម្បីតែ១ បទ ក៏ឈ្មោះថា ប្រសើរជាង ។

បើគាថា សូម្បីមួយពាន់ ជាគាថា ប្រកបដោយបទឥតប្រយោជន៍ គាថានោះ ក៏មិនប្រសើរឡើយ អ្នកណាស្ដាប់បទនៃគាថាណាហើយ រមែងស្ងប់រម្ងាប់បាន បទនៃគាថានោះ សូម្បីតែ១បទ ក៏ឈ្មោះថា ប្រសើរជាង ។

អ្នកណា សូម្បីពោលគាថាមួយរយ ជាគាថា ប្រកបដោយបទឥតប្រយោជន៍ គាថាដែលអ្នកនោះពោលហើយនោះ ក៏មិនប្រសើរឡើយ អ្នកណាស្ដាប់បទនៃធម៌ហើយ រមែងស្ងប់រម្ងាប់បាន បទនៃធម៌នោះ សូម្បីតែមួយបទ ក៏ឈ្មោះថា ប្រសើរជាង ។

យោ សហស្សំ សហស្សេន សង្គាមេ មានុសេ ជិនេ
ឯកញ្ច ជេយ្យមត្តានំ ស វេ សង្គាមជុត្តមោ ។
អត្តា ហវេ ជិតំ សេយ្យោ យា ចាយំ ឥតរា បជា
អត្តទន្តស្ស បោសស្ស និច្ចំ សញ្ញតចារិនោ[១]
នេវ ទេវោ ន គន្ធព្វោ ន មារោ សហ ព្រហ្មុនា
ជិតំ អបជិតំ កយិរា តថារូបស្ស ជន្តុនោ ។
មាសេ មាសេ សហស្សេន យោ យជេថ សតំ សមំ
ឯកញ្ច ភាវិតត្តានំ មុហុត្តមបិ បូជយេ
សាយេវ បូជនា សេយ្យោ យញ្ចេ[២] វស្សសតំ ហុតំ ។
យោ ច វស្សសតំ ជន្តុ អគ្គឹ បរិចរេ វនេ
ឯកញ្ច ភាវិតត្តានំ មុហុត្តមបិ បូជយេ
សាយេវ បូជនា សេយ្យោ យញ្ចេ[៣] វស្សសតំ ហុតំ ។

---

១ ឱ· សំយតចារិនោ ។ ឱ· សត្តភាវិត ។ ២·៣ ឱ. យញ្ញ ។



អ្នកណា គប្បីឈ្នះពួកមនុស្សក្នុងសង្គ្រាមអស់មួយពាន់ដង គុណមួយលាន ចំណែកអ្នកណា ឈ្នះខ្លួនឯងតែម្នាក់ឯងបាន អ្នកនោះឈ្មោះជាជាងមនុស្សខ្ពង់ខ្ពស់ ជាអ្នកដែលឈ្នះ ក្នុងសង្គ្រាមនោះ ។

ខ្លួនឯងដែលឈ្នះហើយ ប្រសើរជាង ចំណែកពួកសត្វក្រៅពីនេះដែលគេឈ្នះហើយ មិនប្រសើរឡើយ កាលបើបុរសមានខ្លួនទូន្មានហើយ ជាអ្នកប្រព្រឹត្តសង្រួមជានិច្ច ទេវតា គន្ធព្វ មារ ព្រមទាំងព្រហ្ម មិនគប្បីធ្វើនូវជ័យ របស់សត្វមានសភាពដូច្នោះ ឲ្យត្រឡប់ជាចាញ់វិញបានឡើយ ។

អ្នកណា បូជា(លោកិយមហាជន) ដោយទ្រព្យមួយពាន់រាល់ខែ ៗ អស់ ១ រយឆ្នាំគត់ ចំណែកអ្នកណា គប្បីបូជាចំពោះបុគ្គលដែលមានខ្លួនអប់រំហើយ តែ ១ នាក់ សូម្បីតែមួយភ្លែត ការបូជានោះឯង ប្រសើរជាងការបូជារបស់អ្នកដែលបូជាអស់ ១ រយឆ្នាំនោះ ការបូជាអស់ ១០០ ឆ្នាំ មិនប្រសើរឡើយ ។

ជនណា បម្រើភ្លើងក្នុងព្រៃអស់ ១០០ឆ្នាំ ចំណែកអ្នកណាបូជាលោកដែលមានខ្លួនអប់រំហើយ តែ ១ នាក់ សូម្បីមួយភ្លែត ការបូជានោះឯង ប្រសើរជាងការបូជារបស់ជននោះ ការបូជាអស់ ១០០ ឆ្នាំ មិនប្រសើរឡើយ ។

យង្កិញ្ចិ យិដ្ឋំ វ ហុតំ(១) វ លោកេ
សំវច្ឆរំ យជេថ បុញ្ញបេក្ខោ(២)
សព្វម្បិ តំ ន ចតុភាគមេតិ
អភិវាទនា ឧជ្ជុគតេសុ សេយ្យោ ។

អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ
ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ ។

យោ ច វស្សសតំ ជីវេ ទុស្សីលោ អសមាហិតោ
ឯកាហំ ជីវិតំ សេយ្យោ សីលវន្តស្ស ឈាយិនោ ។

យោ ច វស្សសតំ ជីវេ ទុប្បញ្ញោ អសមាហិតោ
ឯកាហំ ជីវិតំ សេយ្យោ បញ្ញវន្តស្ស ឈាយិនោ ។

យោ ច វស្សសតំ ជីវេ កុសីតោ ហីនវីរិយោ
ឯកាហំ ជីវិតំ សេយ្យោ វីរិយំ អារភតោ ទឡ្ហំ ។

១ ម. យិដ្ឋញ្ចហុតញ្ច ។ ២ ម. បុញ្ញបេក្ខោ ។



បុគ្គលអ្នកប្រាថ្នាបុណ្យ គប្បីបូជាគ្រឿងសក្ការបូជា ដ៏តូចណាមួយ ក្នុងលោកអស់មួយឆ្នាំ ការបូជាទាំងអស់នោះឯង រមែងមិនដល់ នូវចំណែកទី ៤ នៃការអភិវាទន៍ ចំពោះលោកទាំងឡាយ ដែលប្រតិបត្តិត្រង់ហើយ ប្រសើរជាង ។

ធម៌ ៤ ប្រការគឺ អាយុ ១ វណ្ណៈ ១ សុខៈ ១ ពលៈ ១ រមែងចំរើនដល់ អ្នកដែលមានសេចក្ដីគោរពថ្វាយបង្គំជាប្រក្រតី មានសេចក្ដីកោតក្រែង ដល់បុគ្គលដែលចំរើនជាងខ្លួន អស់កាលជានិច្ច ។

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សទ្រុស្តសីល មានចិត្ត មិនតាំងតម្កល់ខ្ជាប់ ការរស់នៅតែមួយថ្ងៃ របស់លោកដែលមាន សីលមានការពិនិត្យពិចារណា ជាប្រក្រតី ប្រសើរជាង ។

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សមិនមានប្រាជ្ញា មានចិត្ត មិនតាំងតម្កល់ខ្ជាប់ ការរស់នៅតែមួយថ្ងៃ របស់លោកដែលមាន ប្រាជ្ញា មានការពិនិត្យពិចារណា ជាប្រក្រតី ប្រសើរជាង ។

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សមានចិត្តធ្លាក់ចុះ ក្នុង អកុសលវិតក្កៈ មានព្យាយាមថោកថយ ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកដែលប្រារព្ធសេចក្ដីព្យាយាមមាំមួន ប្រសើរជាង ។

យោ ច វស្សសតំ ជីវេ អបស្សំ ឧទយព្វយំ[១]
ឯកាហំ ជីវិតំ សេយ្យោ បស្សតោ ឧទយព្វយំ ។
យោ ច វស្សសតំ ជីវេ អបស្សំ អមតំ បទំ
ឯកាហំ ជីវិតំ សេយ្យោ បស្សតោ អមតំ បទំ ។
យោ ច វស្សសតំ ជីវេ អបស្សំ ធម្មមុត្តមំ
ឯកាហំ ជីវិតំ សេយ្យោ បស្សតោ ធម្មមុត្តមំ ។

សហស្សវគ្គោ អដ្ឋមោ ។

## ធម្មបទគាថាយ នវមោ បាបវគ្គោ

(១៩) អភិត្ថរេថ កល្យាណេ បាបា ចិត្តំ និវារយេ[២]
ទន្ធំ ហិ ករោតោ បុញ្ញំ បាបស្មឹ រមតី មនោ ។
បាបញ្ចេ បុរិសោ កយិរា ន នំ កយិរា បុនប្បុនំ
ន តម្ហិ ឆន្ទំ កយិរាថ ទុក្ខោ បាបស្ស ឧច្ចយោ ។

---
១ ឧទយព្វយំ ។ ២ ម. ឆ. ម. តុរិត ។



បុគ្គលណា រស់នៅមួយរយឆ្នាំ មើលឃើញការកើតឡើងនិងការវិនាសទៅ ការរស់នៅ សូម្បីតែមួយថ្ងៃ របស់លោកដែលឃើញការកើតឡើង និងការវិនាសទៅ ប្រសើរជាង ។

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនឃើញផ្លូវព្រះនិព្វាន ការរស់នៅ សូម្បីតែមួយថ្ងៃ របស់លោកអ្នកឃើញផ្លូវព្រះនិព្វាន ប្រសើរជាង ។

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនឃើញធម៌ដ៏ខ្ពង់ខ្ពស់ ការរស់នៅ សូម្បីតែមួយថ្ងៃ របស់លោកអ្នកឃើញធម៌ដ៏ខ្ពង់ខ្ពស់ ប្រសើរជាង ។

ចប់ សហស្សវគ្គទី ៨ ។

## ធម្មបទគាថា បាបវគ្គទី ៩

(១៩) បុគ្គលគួរប្រញាប់ប្រញាល់ធ្វើអំពើល្អ គួរឃាត់ចិត្តពីអំពើបាប ព្រោះថា កាលបើបុគ្គលធ្វើបុណ្យយឺតយូរ ចិត្តរមែងត្រេកអរក្នុងអំពើបាប ។ បើបុរសធ្វើបាប កុំធ្វើបាបនោះរឿយៗ ឡើយ កុំគប្បីធ្វើសេចក្ដីពេញចិត្ត ក្នុងបាបនោះ ( ព្រោះថា ) ការសន្សំបាប តែងនាំសេចក្ដីទុក្ខមកឱ្យ ។

ពុញ្ញញ្ចេ បុរិសោ កយិរា  កយិរាថេនំ បុនប្បុនំ
តម្ហិ ឆន្ទំ កយិរាថ  សុខោ បុញ្ញស្ស ឧច្ចយោ ។

បាបោបិ បស្សតិ ភទ្រំ  យាវ បាបំ ន បច្ចតិ
យទា ច បច្ចតិ បាបំ  អថ(បាបោ)បាបានិ បស្សតិ ។

ភទ្រោបិ បស្សតិ បាបំ  យាវ ភទ្រំ ន បច្ចតិ
យទា ច បច្ចតិ ភទ្រំ  អថ(ភទ្រោ)ភទ្រានិ បស្សតិ ។

មាវមញ្ញេថ[១]បាបស្ស  ន មត្តំ[២]អាគមិស្សតិ
ឧទពិន្ទុនិបាតេន  ឧទកុម្ភោបិ បូរតិ
អាបូរតិ ពាលោ បាបស្ស[៣]  ថោកំ ថោកម្បិ អាចិនំ ។

មាវមញ្ញេថ បុញ្ញស្ស  ន មត្តំ អាគមិស្សតិ
ឧទពិន្ទុនិបាតេន  ឧទកុម្ភោបិ បូរតិ
អាបូរតិ ធីរោ បុញ្ញស្ស  ថោកំ ថោកម្បិ អាចិនំ ។

---

១ ឧ· អប្បមញ្ញេថ ។ ២ ឧ· មន្តំ ។ ម· មន្តំ ។ ៣ ឧ· ពាលោ បូរតិ បាបស្ស ។ ពន្ធី សោភ្ជាក បូរតិ ពាលោ ឈបប្បូរំ បាប ចិស្សតិ ។



បើបុរសធ្វើបុណ្យ គួរធ្វើបុណ្យនោះរឿយៗ គួរធ្វើសេចក្ដីពេញចិត្ត ក្នុងបុណ្យនោះ (ព្រោះថា) ការសន្សំបុណ្យ តែងនាំសេចក្ដីសុខមកឲ្យ ។

បាប មិនទាន់ឲ្យផលត្រឹមណា មនុស្សបាប ក៏នៅឃើញតែសេចក្ដីចំរើនត្រឹមណោះ លុះកាលណា បាបឲ្យផល មនុស្សបាប ទើបឃើញបាប ក្នុងកាលនោះ ។

អំពើល្អ មិនទាន់ឲ្យផលត្រឹមណា មនុស្សល្អ នៅឃើញតែបាបត្រឹមណោះ លុះកាលណា អំពើល្អឲ្យផល មនុស្សល្អ ទើបឃើញល្អក្នុងកាលនោះ ។

បុគ្គល មិនគួរមើលងាយបាបថា មានប្រមាណប៉ុណ្ណឹង នឹងមិនឲ្យផលដល់ខ្លួនឡើយ ប្រៀបដូចក្អមទឹក រមែងពេញបានដោយដំណក់ទឹកដែលធ្លាក់ចុះ យ៉ាងណា បុគ្គលពាល កាលសន្សំបាប សូម្បីបន្តិចម្ដងៗ គង់ពេញបានដោយបាប យ៉ាងនោះដែរ ។

បុគ្គល មិនគួរមើលងាយបុណ្យថា មានប្រមាណប៉ុណ្ណឹង នឹងមិនឲ្យផលដល់ខ្លួនឡើយ ប្រៀបដូចក្អមទឹក រមែងពេញបានដោយដំណក់ទឹកដែលធ្លាក់ចុះ យ៉ាងណា អ្នកមានប្រាជ្ញា កាលសន្សំបុណ្យបន្តិចម្ដងៗ គង់ពេញបានដោយបុណ្យ យ៉ាងនោះ ។

វាណិជោវ ភយំ មគ្គំ អប្បសត្ថោ មហទ្ធនោ
វិសំ ជីវិតុកាមោវ បាបានិ បរិវជ្ជយេ ។

បាណិម្ហិ ចេ វណោ នាស្ស ហរេយ្យ បាណិនា វិសំ
នាព្វណំ(១) វិសមន្វេតិ នត្ថិ បាបំ អកុព្វតោ ។

យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ
សុទ្ធស្ស បោសស្ស អនង្គណស្ស
តមេវ ពាលំ បច្ចេតិ បាបំ
សុខុមោ រជោ បដិវាតំ ខិត្តោ ។

គព្ភមេកេ ឧប្បជ្ជន្តិ និរយំ បាបកម្មិនោ
សគ្គំ សុគតិនោ យន្តិ បរិនិព្វន្តិ អនាសវា ។

ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ
ន បព្វតានំ វិវរំ បវិសំ(២)
ន វិជ្ជតិ(៣) សោ ជគតិប្បទេសោ
យត្រដ្ឋិតោ(៤) មុច្ចេយ្យ(៥) បាបកម្មា ។

១ ម. នាពណោ ។ ២ ឱ. ម. បវិស្ស ។ ៣ ម. វិជ្ជតិ ។ វិជ្ជតេ[illegible] ។ ៤ ម. យត្ថដ្ឋិតោ ។ ៥ ម. មុច្ចេយ្យ ។



បុគ្គលអ្នកចៀសវាងនូវបាបទាំងឡាយ ឲ្យដូចពាណិជៈ ដែលមានទ្រព្យច្រើន តែមានគ្នាតិច ចៀសវាងផ្លូវគួរខ្លាច ឬដូចជាបុរសប្រាថ្នារស់នៅ ចៀសវាងថ្នាំពិសដូច្នោះដែរ ។

បើដៃពុំមានដំបៅទេ បុគ្គលគប្បីកាន់យកថ្នាំពិសដោយបាតដៃ ថ្នាំពិស តែងមិនជ្រាបចូលទៅកាន់បាតដៃដែលគ្មានដំបៅ យ៉ាងណា បាប តែងមិនមានដល់បុគ្គលអ្នកមិនធ្វើ យ៉ាងនោះដែរ ។

បុគ្គលណា ប្រទូស្តចំពោះអ្នកមិនប្រទូស្តតប ជាសត្វស្អាត មិនមានកិលេសដូចជាទីទួល បាប តែងត្រឡប់មកកាន់បុគ្គលពាលនោះវិញ ដូចធូលីល្អិត ដែលបុគ្គលបាចសាចទៅកាន់ទីច្រាសខ្យល់ ។

ជនពួកខ្លះ កើតក្នុងផ្ទៃនៃមនុស្ស ពួកអ្នកមានអំពើអាក្រក់ ទៅកាន់នរក ពួកអ្នកមានគតិល្អ ទៅកាន់ឋានសួគ៌ ពួកអ្នកមិនមានអាសវៈ បរិនិព្វាន ។

បុគ្គលអ្នកធ្វើបាបកម្មហើយ ទោះបីចូលទៅក្នុងអាកាស ក្នុងកណ្ដាលសមុទ្រ កាន់ចន្លោះភ្នំទាំងឡាយ ក៏មិនគប្បីរួចចាកបាបកម្ម ព្រោះប្រទេសលើផែនដី ដែលបុគ្គលឋិតនៅហើយ គប្បីរួចចាកបាបកម្មបាន នោះមិនដែលមានឡើយ ។

ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ
ន បព្វតានំ វិវរំ បវិស្ស
ន វិជ្ជតី សោ ជគតិប្បទេសោ
យត្ថដ្ឋិតំ នប្បសហេយ្យ(១) មច្ចុ ។

បាបវគ្គោ នវមោ ។

## ធម្មបទគាថាយ ទសមោ វគ្គោ

(២០) សព្វេ តសន្តិ ទណ្ឌស្ស សព្វេ ភាយន្តិ មច្ចុនោ
អត្តានំ ឧបមំ កត្វា ន ហនេយ្យ ន ឃាតយេ ។
សព្វេ តសន្តិ ទណ្ឌស្ស សព្វេសំ ជីវិតំ បិយំ
អត្តានំ ឧបមំ កត្វា ន ហនេយ្យ ន ឃាតយេ ។
សុខកាមានិ ភូតានិ យោ ទណ្ឌេន វិហឹសតិ
អត្តនោ សុខមេសានោ បេច្ច សោ ន លភតេ សុខំ ។

១ ម.- នប្បសហេថ ។



បុគ្គលទៅ ក្នុងអាកាស ក្នុងកណ្ដាលសមុទ្រ កាន់ចន្លោះនៃភ្នំ ទាំងឡាយ ក៏មិនរួចចាកសេចក្ដីស្លាប់បាន ព្រោះប្រទេសលើផែនដី ដែលបុគ្គលឋិតនៅហើយ សេចក្ដីស្លាប់គ្របសង្កត់មិនបាននោះ មិន ដែលមានឡើយ ។

ចប់ វគ្គទី ៩ ។

## ធម្មបទគាថា វគ្គទី ១០

(៦០) សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា សត្វទាំងឡាយ តែងខ្លាចចំពោះសេចក្ដីស្លាប់គ្រប់ៗរូប បុគ្គលគួរធ្វើខ្លួនឲ្យជាឧបមា ហើយមិនគួរប្រហារ ដោយខ្លួនឯង មិនគួរប្រើគេឲ្យប្រហារឡើយ ។

សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា (ព្រោះថា) ជីវិតជាទីស្រឡាញ់របស់សត្វទាំងពួង បុគ្គលគួរធ្វើខ្លួនឲ្យជាឧបមា ហើយ មិនគួរប្រហារ ដោយខ្លួនឯង មិនគួរប្រើគេឲ្យប្រហារឡើយ ។

ជនណា ស្វែងរកសេចក្ដីសុខ ដើម្បីខ្លួន តែបៀតបៀនសត្វទាំងឡាយ ដែលប្រាថ្នាសេចក្ដីសុខ ដោយអាជ្ញា ជននោះលះលោកនេះទៅហើយ នឹងមិនបានសេចក្ដីសុខឡើយ ។

សុខកាមានិ ភូតានិ  យោ ទណ្ឌេន ន ហឹសតិ
អត្តនោ សុខមេសានោ  បេច្ច សោ លភតេ សុខំ ។
មាវោច ផរុសំ កញ្ចិ[១]  វុត្តា បដិវទេយ្យុ[២] តំ
ទុក្ខា ហិ សារម្ភកថា  បដិទណ្ឌា ផុសេយ្យុ[៣] តំ ។
សចេ នេរេសិ អត្តានំ  កំសោ ឧបហតោ យថា
ឯស បត្តោសិ និព្វានំ  សារម្ភោ[៤] តេ ន វិជ្ជតិ ។
យថា ទណ្ឌេន គោបាលោ  គាវោ បាចេតិ[៥] គោចរំ
ឯវំ ជរា ច មច្ចុ ច  អាយុំ បាចេន្តិ បាណិនំ ។
អថ បាបានិ កម្មានិ  ករំ ពាលោ ន ពុជ្ឈតិ
សេហិ កម្មេហិ ទុម្មេធោ  អគ្គិទឌ្ឍោវ តប្បតិ ។

---

១ ម. កិញ្ចិ ។ ២ ម. បដិវទេយ្យុំ ។ ៣ ម. ផុសេយ្យុំ ។ ៤ ម. សារម្ភា ។ ៥ ម. បាជេតិ ។



ជនណា ស្វែងរកសេចក្តីសុខ ដើម្បីខ្លួន តែមិនបៀតបៀនសត្វទាំងឡាយ អ្នកដែលប្រាថ្នាសេចក្តីសុខ ដោយអាជ្ញា ជននោះលុះលោកនេះទៅហើយ រមែងបានសេចក្តីសុខ ។

អ្នកកុំនិយាយពាក្យអាក្រក់នឹងអ្នកណាមួយឡើយ ជនទាំងឡាយដែលអ្នកស្តីដាក់ហើយ គេគប្បីស្តីតបមកអ្នកវិញ ព្រោះថា ការពោលពាក្យប្រណាំងប្រជែង ជាហេតុនាំឲ្យកើតទុក្ខ ការតស៊ូទាំងឡាយគប្បីប៉ះពាល់នូវអ្នក ។ បើអ្នកធ្វើខ្លួនមិនឲ្យញាប់ញ័រ ដូចកាំងដែលបៀរបាក់បែកហើយ (រមែងមិនលាន់ឮសូរ) ដូច្នោះ អ្នកនុ៎ះជាបុគ្គលដល់នូវព្រះនិព្វាន ការប្រណាំងប្រជែង មិនមានដល់អ្នក ។

គង្វាលគោ រមែងកៀងគោទៅកាន់ទីគោចរដោយអាជ្ញា ដូចម្តេចមិញ ជរានឹងមច្ចុ តែងកៀងអាយុរបស់សត្វទាំងឡាយ ដូច្នោះឯង ។

បុគ្គលមិនមានប្រាជ្ញា កាលធ្វើអំពើអាក្រក់ រមែងមិនភ្ញាក់ខ្លួន លុះកាលជាខាងក្រោយ ទើបក្តៅក្រហាយ ដោយសារកម្មរបស់ខ្លួន ដូចត្រូវភ្លើងឆេះ ។

យោ ទណ្ឌេន អទណ្ឌេសុ អប្បទុដ្ឋេសុ ទុស្សតិ
ទសន្នមញ្ញតរំ ឋានំ ខិប្បមេវ និគច្ឆតិ
វេទនំ ផរុសំ ជានឹ សរីរស្ស ច ភេទនំ
គរុកំ វាបិ អាពាធំ ចិត្តក្ខេបំ[1] ច បាបុណេ
រាជតោ វា ឧបសគ្គំ អព្ភក្ខានំ ច ទារុណំ
បរិក្ខយំ[2] ច ញាតីនំ ភោគានំ[3] ច បភង្គុណំ[4]
អថវាស្ស អគារានិ អគ្គិ ឌហតិ[5] បាវកោ
កាយស្ស ភេទា ទុប្បញ្ញោ និរយំ សោ ឧបបជ្ជតិ[6] ។

ន នគ្គចរិយា ន ជដា ន បង្កា
នានាសកា ថណ្ឌិលសាយិកា វា
រជោជល្លំ ឧក្កុដិកប្បធានំ
សោធេន្តិ មច្ចំ អវិតិណ្ណកង្ខំ ។
អលង្កតោ ចេបិ សមំ ចរេយ្យ
សន្តោ ទន្តោ និយតោ ព្រហ្មចារី
សព្វេសុ ភូតេសុ និធាយ ទណ្ឌំ
សោ ព្រាហ្មណោ សោ សមណោ ស ភិក្ខុ ។

---

១ ម. ចិត្តក្ខេបញ្ច ។ ២ ម. បរិក្ខយញ្ច ។ ៣ ម. ភោគានញ្ច ។ ៤ ម. បភង្គុរំ ។ ៥ ម. ឌយ្ហតិ ។ ៦ ម. បបជ្ជតិ ។



បុគ្គលណា ប្រទូស្តដោយអាជ្ញា ចំពោះបុគ្គលទាំងឡាយ ដែលមិនមានអាជ្ញា មិនប្រទូស្ត បុគ្គលនោះ រមែងដល់នូវហេតុនៃសេចក្តីទុក្ខណាមួយ ក្នុងហេតុ ១០ យ៉ាង ដោយឆាប់ពិត គឺរមែងដល់នូវវេទនាដ៏អាក្រក់ ១ សេចក្តីវិនាសទ្រព្យ ១ បែកធ្លាយសរីរៈ ១ អាពាធដ៏ធ្ងន់ ១ ក្រឡាប់ចិត្ត (ឆ្កួត) ១ ភ័យអំពីស្តេច ១ ពោលពាក្យបង្កាច់ដ៏អាក្រក់ ១ អស់ពួកញាតិវង្ស ១ ក្តីវិនាសនៃភោគសម្បត្តិទាំងឡាយ ១ ទាំងភ្លើងឆេះផ្ទះសំបែង របស់បុគ្គលនោះ ១ បុគ្គលមិនមានប្រាជ្ញានោះ លុះបែកធ្លាយរាងកាយ រមែងទៅកើត ក្នុងនរក ។

ការប្រព្រឹត្តអាក្រាតកាយ ទុកសក់ ផាត់លើភក់ មិនបរិភោគបាយ ដេកលើផែនដី ប្រឡាក់ខ្លួនដោយធូលី ព្យាយាមអង្គុយច្រហោង មិនជម្រះសត្វដែលមិនទាន់ឆ្លងផុតសេចក្តីសង្ស័យបានទេ ។

បើបុគ្គលណាមានខ្លួនប្រដាប់ស្អិតស្អាងហើយ (ដោយគ្រឿងអលង្ការ) តែងប្រព្រឹត្តស្មើ ស្ងប់រម្ងាប់ ទូន្មាន (ឥន្ទ្រិយ) ជាបុគ្គលទៀង (ចំពោះមគ្គផល) អ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ទម្លាក់ចោលនូវអាជ្ញាក្នុងសត្វទាំងពួងចេញហើយ បុគ្គលនោះ ហៅថា ព្រាហ្មណ៍ក៏បាន ថា សមណៈក៏បាន ថាភិក្ខុក៏បាន ។

ហិរីនិសេធោ[១] បុរិសោ កោចិ លោកស្មិំ[២] វិជ្ជតិ
យោ និទ្ទំ អបពោធេតិ[៣] អស្សោ ភទ្រោ កសាមិវ ។
អស្សោ យថា ភទ្រោ កសានិវិដ្ឋោ
អាតាបិនោ សំវេគិនោ ភវាថ[៤]
សទ្ធាយ សីលេន ច វីរិយេន ច
សមាធិនា ធម្មវិនិច្ឆយេន ច
សម្បន្នវិជ្ជាចរណា បតិស្សតា
បហស្សថ[៥] ទុក្ខមិទំ អនប្បកំ ។

ឧទកំ ហិ នយន្តិ[៦] នេត្តិកា ឧសុការា នមយន្តិ[៧] តេជនំ
ទារុំ នមយន្តិ[៨] តច្ឆកា អត្តានំ ទមយន្តិ សុព្វតា ។

ទណ្ឌវគ្គោ ទសមោ ។

## ធម្មបទគាថាយ ឯកាទសមោ ជរាវគ្គោ

(២៧) កោ នុ ហាសោ កិមានន្ទោ និច្ចំ បជ្ជលិតេ សតិ
អន្ធការេន ឱនទ្ធា បទីបំ ន គវេសថ[៩] ។

១ ម.ប. ហិរីនិសេធោ ។ ២ ម. លោកស្មឹ ។ ៣ ម. ឱ. យោ និទ្ទំ អប្ប- ពោធតិ ។ ម. យោ និទ្ទំ អប្បពោធេសិ ។ ៤ ម. ភវថ ។ ៥ ម. បហិស្សថ ។ ៦ ម. អនប្បកំ ។ ៧-៨ ម. ទមយន្តិ ។ ៩ ម. គវេស្សថ ។



បុរសអ្នកកំចាត់បង់នូវអកុសលវិតក្កៈ ដោយសេចក្តីខ្មាសបាប មានតិចក្នុងលោក បុគ្គលណាបន្ទោបង់នូវការដេកលក់ ដូចសេះល្អខ្លាចព្រោះរំពាត់ បុរសនោះ រកបានដោយក្រ ក្នុងលោក ។

សេះល្អ ដែលគេវាយសារថីខ្ចួន ដោយរំពាត់ តក់ស្លុតយ៉ាងណា អ្នកទាំងឡាយ ចូរជាបុគ្គលមានព្យាយាម មានសេចក្តីតក់ស្លុតយ៉ាងនោះឯង ហើយអ្នកទាំងឡាយ ប្រកបព្រមដោយសទ្ធាផង សីលផង ព្យាយាមផង សមាធិផង ធម្មវិនិច្ឆ័យផង ជាអ្នកមានវិជ្ជានិងចរណៈដ៏បរិបូណ៌ មានស្មារតីដំកល់មាំ រំលងបង់នូវទុក្ខ មានប្រមាណច្រើននេះ មិនខាន ។

ធម្មតាអ្នកបង្ហូរ តែងបង្ហូរទឹក ជាងធ្វើព្រួញ តែងពត់ព្រួញ ( ឱ្យត្រង់ ) អ្នកចាំង តែងចាំងនូវឈើ អ្នកមានវត្តល្អ តែងទូន្មានខ្លួន ។

ចប់ ទណ្ឌវគ្គ ទី ១០ ។

## ធម្មបទគាថា ជរាវគ្គទី ១១

(៦១) កាលបើលោកសព្វកាល ត្រូវភ្លើងមានរាគៈជាដើម ឆេះរោលរាល ជានិច្ច សេចក្តីសើចអ្វី សេចក្តីត្រេកត្រអាលអ្វី អ្នកទាំងឡាយត្រូវងងឹតគឺអវិជ្ជារួបរឹតហើយ (ព្រោះហេតុអ្វី) ក៏មិនស្វែងរកប្រទីបគឺប្រាជ្ញា ។

បស្ស ចិត្តកតំ ពិម្ពំ    អរុកាយំ សមុស្សិតំ
អាតុរំ ពហុសង្កប្បំ    យស្ស នត្ថិ ធុវំ ឋិតិ(១) ។
បរិជិណ្ណមិទំ រូបំ    រោគនិឌ្ឌំ បភង្គុរំ
ភិជ្ជតិ បូតិ សន្ទេហោ    មរណន្តំ ហិ ជីវិតំ ។
យានិមានិ អបត្ថានិ    អលាពូនេវ សារទេ
កាបោតកានិ អដ្ឋីនិ    តានិ ទិស្វាន កា រតិ ។
អដ្ឋីនំ នគរំ កតំ    មំសលោហិតលេបនំ
យត្ថ ជរា ច មច្ចុ ច    មានោ មក្ខោ ច ឱហិតោ ។

ជីរន្តិ វេ រាជរថា សុចិត្តា
អថោ សរីរម្បិ ជរំ ឧបេតិ
សតញ្ច ធម្មោ ន ជរំ ឧបេតិ
សន្តោ ហវេ សព្ភិ បវេទយន្តិ ។



អត្តភាពណា មិនទៀងទាត់ ឋិតថេរ អ្នកចូរមើលអត្តភាព (នោះ) ដែលកុសលាកុសលកម្ម ធ្វើវិចិត្រហើយ ជាកាយពាសពេញ ដោយដំបៅ ដែលឆ្អឹងបីរយកំណាត់ ផ្គុំគ្នាហើយ ជាអត្តភាពក្ដៅក្រហាយជានិច្ច ជាទីតាំងនៃគំនិតរបស់ជនច្រើនគ្នា ។

រូបនេះគ្រាំគ្រាតស់ហើយ ជាទីសំណាក់នៃរោគ ជារបស់ពុកផុយ កន្ទកាយជារបស់ស្អុយ (នេះ) តែងបែកធ្លាយទៅវិញ ព្រោះជាជីវិតមានសេចក្ដីស្លាប់ជាទីបំផុត ។

ឆ្អឹងទាំងឡាយណា មានសម្បុរដូចសង្កុព្រាប ដែលគេចោលហើយ ដូចផ្លែឃ្លោកក្នុងសរទកាល សេចក្ដីត្រេកអរអ្វីនឹង (របស់អ្នកទាំងឡាយ) ព្រោះតែឃើញឆ្អឹងទាំងឡាយនោះ ។

សេចក្ដីគ្រាំគ្រា សេចក្ដីស្លាប់ សេចក្ដីប្រកាន់ខ្លួន នឹងសេចក្ដីលុបគុណ ប្រជុំចុះក្នុងសរីរៈណា (សរីរៈនោះ) ដែលកុសលាកុសលកម្មធ្វើហើយឱ្យជានគររបស់ឆ្អឹងទាំងឡាយ ជាគ្រឿងប្រឡាក់ដោយសាច់នឹងឈាម ។

រាជរថទាំងឡាយ ដ៏វិចិត្រល្អ រមែងគ្រាំគ្រា សូម្បីសរីរៈក៏ដល់នូវសេចក្ដីគ្រាំគ្រាដូចគ្នា ចំណែកធម៌ របស់សប្បុរសទាំងឡាយ មិនដល់នូវសេចក្ដីគ្រាំគ្រា (ដូច្នោះ) ទេ សប្បុរសទាំងឡាយ តែងនិយាយឱ្យពួកសប្បុរសដទៃគ្នាដឹងច្បាស់ ។

អប្បស្សុតាយំ បុរិសោ ពលិពទ្ទោវ ជីរតិ
មំសានិ តស្ស វឌ្ឍន្តិ បញ្ញា តស្ស ន វឌ្ឍតិ ។
អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ
គហការំ[១] គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ ។
គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ
សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ
វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា ។
អចរិត្វា ព្រហ្មចរិយំ អលទ្ធា យោព្វនេ ធនំ
ជិណ្ណកោញ្ចាវ ឈាយន្តិ ខីណមច្ឆេវ បល្លលេ ។
អចរិត្វា ព្រហ្មចរិយំ អលទ្ធា យោព្វនេ ធនំ
សេន្តិ ចាបាតិខីណាវ បុរាណានិ អនុត្ថុនំ ។

ជរាវគ្គោ ឯកាទសមោ ។

១ ម. គហការកំ ។



បុរសអ្នកមិនមានការចេះដឹងនេះ តែងចាស់ (ទៅតែ) ដូចគោបរិវ សាច់របស់វា តែងចំរើនឡើង តែប្រាជ្ញារបស់វាមិនចំរើនឡើយ ។ កាលតថាគតមិនទាន់បានជួបប្រទះ (ពោធិញ្ញាណ) ស្វះស្វែងរកជាងផ្ទះគឺតណ្ហា អ្នកធ្វើផ្ទះគឺអត្តភាព ក៏អន្ទោលទៅកាន់សង្សារវដ្ដ មានជាតិដ៏ច្រើន សេចក្ដីកើត ជាទុក្ខរឿយ ៗ ។

នែជាងផ្ទះ អ្នកឯងធ្វើផ្ទះគឺអត្តភាព តថាគតឃើញហើយ អ្នកនឹងធ្វើផ្ទះ(របស់តថាគត) ទៀត មិនបានឡើយ ឆ្អឹងជំនីគឺកិលេសរបស់អ្នកទាំងអស់តថាគតកាច់បំបាក់អស់ហើយ ដំបូលផ្ទះគឺអវិជ្ជា តថាគតក៏កំចាត់ចោលហើយ ចិត្តរបស់តថាគត ដល់ព្រះនិព្វានដែលមានសង្ខារប្រាសហើយ តថាគត បានដល់នូវធម៌ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ។

ជនពាលទាំងឡាយ មិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យ ក្នុងកាលខ្លួននៅជាកំលោះក្រមុំ រមែងសញ្ជប់សញ្ជឹង ដូចសត្វក្រៀលចាស់ សំកុកនៅ ក្នុងភក់ដែលអស់ត្រីហើយ ។

ជនពាលទាំងឡាយ មិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យក្នុងកាលខ្លួននៅកំលោះក្រមុំ រមែងដេកថ្ងូរ សោកស្ដាយទ្រព្យចាស់ទាំងឡាយ ដូចព្រួញដែលផុតចាកខ្សែធ្នូដូច្នោះ ។

ចប់ ជរាវគ្គ ទី ១១ ។

# ធម្មបទគាថាយ ទ្វាទសមោ អត្តវគ្គោ

(១៥៧) អត្តានញ្ចេ បិយំ ជញ្ញា រក្ខេយ្យ នំ សុរក្ខិតំ
តិណ្ណំ អញ្ញតរំ យាមំ បដិជគ្គេយ្យ បណ្ឌិតោ ។
អត្តានមេវ បឋមំ បតិរូបេ និវេសយេ
អថញ្ញមនុសាសេយ្យ ន កិលិស្សេយ្យ បណ្ឌិតោ ។
អត្តានញ្ចេ តថា កយិរា យថញ្ញមនុសាសតិ
សុទន្តោ វត ទមេថ អត្តា ហិ កិរ ទុទ្ទមោ ។
អត្តា ហិ អត្តនោ នាថោ កោ ហិ នាថោ បរោ សិយា
អត្តនា ហិ សុទន្តេន នាថំ លភតិ ទុល្លភំ ។
អត្តនា វ កតំ បាបំ អត្តជំ(១) អត្តសម្ភវំ
អភិមត្ថតិ ទុម្មេធំ វជិរំ វម្ហមយំ(២) មណឹ ។

១ អត្រជន្តិ បាឋោ ។ ២ ម. វជិរំវម្ហមយំ ។ ប. អម្ហមយំ ។



# ធម្មបទគាថា អត្តវគ្គទី ១២

(១៥៧) បើបណ្ឌិតដឹងថា ខ្លួនជាទីស្រឡាញ់ គួររក្សាខ្លួនដោយល្អ គួរស្ងួនគ្រងខ្លួនក្នុងវ័យទាំង៣ វ័យណាមួយ ។
បណ្ឌិត គួរតម្កល់ខ្លួន ក្នុងគុណដ៏សមគួរជាមុនសិន ហើយ សឹមប្រៀនប្រដៅអ្នកដទៃ ជាខាងក្រោយ (ធ្វើយ៉ាងនេះ) ទើបមិនលំបាកឡើយ ។
បុគ្គលប្រៀនប្រដៅអ្នកដទៃ យ៉ាងណា គួរធ្វើខ្លួនឲ្យបាន យ៉ាងនោះដែរ អ្នកដែលទូន្មានខ្លួនល្អហើយ ទើបគួរទូន្មានអ្នកដទៃបាន ព្រោះថា ខ្លួនគេទូន្មានបានដោយក្រណាស់ ។
ខ្លួនជាទីពឹងរបស់ខ្លួន អ្នកដទៃជាទីពឹងដូចម្ដេចបាន ព្រោះបុគ្គលអ្នកមានខ្លួនទូន្មានល្អហើយ រមែងបានទីពឹង ដែលគេបានដោយកម្រ ។
បាប កើតអំពីខ្លួន មានខ្លួនជាដែនកើត ដែលខ្លួនធ្វើហើយ តែងញាំញីមនុស្សឥតប្រាជ្ញា ដូចពេជ្រសម្រាប់កាត់កែវមណី ដែលកើតអំពីថ្ម ដូច្នោះឯង ។

យស្ស អច្ចន្តទុស្សីល្យំ មាលុវា សាលមិវោត្ថតំ
ករោតិ សោ តថត្តានំ(១) យថា នំ ឥច្ឆតី ទិសោ ។
សុករានិ អសាធូនិ អត្តនោ អហិតានិ ច
យំ វេ(២) ហិតញ្ច សាធុញ្ច តំ វេ បរមទុក្ករំ ។
យោ សាសនំ អរហតំ អរិយានំ ធម្មជីវិនំ
បដិក្កោសតិ ទុម្មេធោ ទិដ្ឋឹ និស្សាយ បាបិកំ
ផលានិ កណ្ដកស្សេវ(៣) អត្តឃញ្ញាយ(៤) ផល្លតិ ។
អត្តនា វ កតំ បាបំ អត្តនា សង្កិលិស្សតិ
អត្តនា អកតំ បាបំ អត្តនា វ វិសុជ្ឈតិ
សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ ។

១ ម. តថត្តានំ ។ ២ ម. វេ ។ ៣ ម. កដ្ឋកស្សេវ ។
៤ ម. អត្តឃាតាយ ។



ភាពជាអ្នកទ្រុស្តសីលហួសហេតុ (១) គ្របសង្កត់ (ខ្លួនអ្នកកាន់) របស់បុគ្គលណា ដូចវល្លិ៍ដែលរួបរឹតដើមឈើ បុគ្គលនោះឈ្មោះថា ធ្វើខ្លួនឯងឱ្យវិនាស ដូចជាពួកសត្រូវប្រាថ្នាធ្វើបុគ្គលនោះ ឱ្យវិនាស ដូច្នោះ ។

កម្មទាំងឡាយណា មិនល្អផង មិនជាប្រយោជន៍ដល់ខ្លួនផង កម្មទាំងនោះដែលជនពាលធ្វើបានដោយងាយ កម្មណាជាប្រយោជន៍ផង ល្អផង កម្មនោះឯង ដែលជនពាលធ្វើបាន ដោយលំបាក ។

បុគ្គលណាអប្បប្រាជ្ញ អាស្រ័យទិដ្ឋិដ៏លាមក ហាមឃាត់សាសនា របស់ព្រះអរហន្តទាំងឡាយដ៏ប្រសើរ រស់នៅដោយធម៌ ការហាមឃាត់របស់បុគ្គលនោះ រមែងចេញផល ដើម្បីសម្លាប់ខ្លួន ដូចផ្លែឫស្សីដូច្នោះ ។

អ្នកធ្វើបាបខ្លួនឯង នឹងសៅហ្មងខ្លួនឯង អ្នកមិនធ្វើបាបខ្លួនឯង តែងបរិសុទ្ធខ្លួនឯង សេចក្ដីបរិសុទ្ធិនឹងមិនបរិសុទ្ធិ ជាចំពោះខ្លួន អ្នកដទៃនឹងធ្វើអ្នកដទៃ ឱ្យបរិសុទ្ធពុំបានទេ ។

១ បើប្រែតាមសព្ទ [illegible] ។

អត្តទត្ថំ បរត្ថេន ពហុនាបិ ន ហាបយេ
អត្តទត្ថមភិញ្ញាយ សទត្ថបសុតោ សិយា ។

អត្តវគ្គោ ទ្វាទសមោ ។

# ធម្មបទគាថាយ តេរសមោ លោកវគ្គោ

(៦៧) ហីនំ ធម្មំ ន សេវេយ្យ បមាទេន ន សំវសេ
មិច្ឆាទិដ្ឋឹ ន សេវេយ្យ ន សិយា លោកវឌ្ឍនោ ។
ឧត្តិដ្ឋេ នប្បមជ្ជេយ្យ ធម្មំ សុចរិតំ ចរេ
ធម្មចារី សុខំ សេតិ អស្មឹ លោកេ បរម្ហិ ច ។
ធម្មំ ចរេ សុចរិតំ ន តំ ទុច្ចរិតំ ចរេ
ធម្មចារី សុខំ សេតិ អស្មឹ លោកេ បរម្ហិ ច ។



បុគ្គល កុំគប្បីធ្វើប្រយោជន៍ខ្លួនឲ្យវិនាស ព្រោះប្រយោជន៍របស់អ្នកដទៃ សូម្បីច្រើន លើដឹងច្បាស់នូវប្រយោជន៍របស់ខ្លួនហើយ គប្បីខ្វល់ខ្វាយក្នុងប្រយោជន៍របស់ខ្លួន (តែ) ។

ចប់ អត្តវគ្គ ទី ១២ ។

# ធម្មបទគាថា លោកវគ្គទី ១៣

(៦៧) បុគ្គល មិនគួរសេពនូវហីនធម៌[១] មិនគួរនៅដោយសេចក្តីប្រមាទ មិនគួរសេពមិច្ឆាទិដ្ឋិ មិនគួរជាមនុស្សចម្រើនលោក ។ បុគ្គលមិនគួរប្រមាទ ក្នុងដុំបាយ ដែលខ្លួនគប្បីក្រោកឡើងទទួល គប្បីប្រព្រឹត្តធម៌[២]ឲ្យសុចរិត បុគ្គលអ្នកប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។ បុគ្គលគួរប្រព្រឹត្តធម៌ឲ្យសុចរិត មិនគួរប្រព្រឹត្តធម៌នោះឲ្យទុច្ចរិតឡើយ បុគ្គលប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

---

១ កាមគុណ ៥ ឈ្មោះថា ធម៌ថោកទាប ព្រោះជា ធម៌សម្រាប់ជនថោកទាប រាប់តាំងអំពីកិច្ចនិងគោតើម [illegible] ។ ២ សំដៅយកកិច្ចចរិយាធម៌ [illegible] ។

យថា ពុព្វុឡកំ បស្សេ យថា បស្សេ មរីចិកំ
ឯវំ លោកំ អវេក្ខន្តំ មច្ចុរាជា ន បស្សតិ ។
ឯថ បស្សថិមំ លោកំ ចិត្តំ រាជរថូបមំ
យត្ថ ពាលា វិសីទន្តិ នត្ថិ សង្គោ វិជានតំ ។
យោ ច បុព្វេ បមជ្ជិត្វា បច្ឆា សោ នប្បមជ្ជតិ
សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។
យស្ស បាបំ កតំ កម្មំ កុសលេន បិធីយតិ
សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។
អន្ធភូតោ អយំ លោកោ តនុកេត្ថ វិបស្សតិ
សកុន្តោ(១) ជាលមុត្តោវ អប្បោ សគ្គាយ គច្ឆតិ ។

១ ម. សកុណោ ។



បុគ្គលឃើញពពុះទឹកយ៉ាងណា ឃើញព្រញាថ្ងៃយ៉ាងណា ស្តេចមច្ចុ មិនឃើញអ្នកពិចារណាខន្ធលោកជាដើម យ៉ាងនោះទេ ។

អ្នកទាំងឡាយ ចូរមកមើលលោកនេះ ដ៏ប្រពៃ ដូចរាជរថ ដែលពាលទាំងឡាយ តែងលិចលង់ ក្នុងលោកណា សេចក្តីជាប់ជំពាក់ ក្នុងលោកនោះ តែងមិនមាន ដល់ជនជាបណ្ឌិតទាំងឡាយដែលដឹងច្បាស់ទេ ។

បុគ្គលណាមួយ កាលពីមុនប្រមាទហើយ លុះកាលជាខាងក្រោយ លែងប្រមាទវិញ បុគ្គលនោះ ឈ្មោះថា ញ៉ាំងខន្ធាទិលោកនេះឲ្យភ្លឺច្បាស់ ដូចព្រះចន្ទ្រផុតចាកពពក ។

បុគ្គលណា ធ្វើអំពើបាបហើយ បិទបាំងអំពើបាបនោះដោយកុសល គឺអរហត្តមគ្គបាន បុគ្គលនោះឈ្មោះថា ញ៉ាំងខន្ធាទិលោកនេះ ឲ្យភ្លឺច្បាស់ ដូចព្រះចន្ទ្រផុតចាកពពក ។

លោកិយមហាជននេះ ជាមនុស្សងងឹត បណ្តាជនទាំងនេះ ជនតិចណាស់ដែលឃើញច្បាស់ (នូវខន្ធាទិលោកនេះដោយអំណាចអនិច្ចលក្ខណៈជាដើម) ជនតិចណាស់ ដែលទៅកាន់ឋានសួគ៌ ដូចសត្វស្លាប (ដែលជាប់សំណាញ់របស់ព្រានហើយ) តិចណាស់ ដែលរួចអំពីសំណាញ់ ដូច្នោះ ។

ហំសាទិច្ចបថេ យន្តិ  អាកាសេ យន្តិ ឥទ្ធិយា
នីយន្តិ ធីរា លោកម្ហា  ជេត្វា មារំ សវាហនំ ។
ឯកំ ធម្មំ អតីតស្ស  មុសាវាទិស្ស ជន្តុនោ
វិតិណ្ណបរលោកស្ស  នត្ថិ បាបំ អការិយំ ។

ន វេ កទរិយា ទេវលោកំ វជន្តិ
ពាលា ហវេ នប្បសំសន្តិ ទានំ
ធីរោ ច ទានំ អនុមោទមានោ
តេនេវ សោ ហោតិ សុខី បរត្ថ ។

បថព្យា ឯករជ្ជេន  សគ្គស្ស គមនេន វា
សព្វលោកាធិបច្ចេន  សោតាបត្តិផលំ វរំ ។

លោកវគ្គោ តេរសមោ ។

## ធម្មបទគាថាយ ចុទ្ទសមោ ពុទ្ធវគ្គោ

(២៤) យស្ស ជិតំ នាវជីយតិ
ជិតមស្ស នោ យាតិ កោចិ លោកេ
តំ ពុទ្ធំ អនន្តគោចរំ
អបទំ កេន បទេន នេស្សថ ។



ហ្វូងហង្ស ដែលហើរទៅក្នុងគន្លងនៃព្រះអាទិត្យ អ្នកមានឫទ្ធិ ដែលហោះទៅក្នុងអាកាស ដោយឫទ្ធិ អ្នកប្រាជ្ញ ផ្ចាញ់កិលេសមារ ព្រមទាំងពលពាហនៈនឹងតណ្ហាបានហើយ រមែងរលាស់ខ្លួនចេញ ចាកលោកបាន ។

បុគ្គលប្រព្រឹត្តកន្លងធម៌ (ពាក្យសច្ចៈ) ដែលជាធម៌ឯក និយាយតែពាក្យកុហក មានបរលោក លះបង់ហើយ ឈ្មោះថា មិនធ្វើអំពើបាប មិនមែនឡើយ ។

បុគ្គល កំណាញ់ស្វិតស្វាញ មិនបានទៅកាន់ទេវលោកទេ ជនពាលទាំងឡាយ មិនសរសើរទានឡើយ ចំណែកអ្នកប្រាជ្ញ តែងអនុមោទនាទាន ព្រោះហេតុនោះ លោកតែងបានសេចក្តីសុខ ក្នុងលោកខាងមុខ ។ សោតាបត្តិផល ជាគុណជាតដ៏ប្រសើរ ជាងភាពនៃឯកច្ឆត្រលើផែនដីផង ជាងដំណើរទៅកាន់ឋានសួគ៌ផង ជាងភាពជាធំ ក្នុងលោកទាំងមូលផង ។

ចប់ លោកវគ្គ ទី ១៣ ។

## ធម្មបទគាថា ពុទ្ធវគ្គ ទី ១៤

(៦៤) ជ័យជំនះរបស់ព្រះពុទ្ធអង្គណា មិនត្រឡប់ចាញ់វិញ កិលេសណាមួយក្នុងលោក រមែងមិនជាប់តាមជ័យជំនះ របស់ព្រះពុទ្ធអង្គនោះ អ្នកទាំងឡាយនឹងប្រលោមព្រះពុទ្ធអង្គនោះ ដែលមានគោចរ រកទីបំផុតគ្មាន មិនមានកិលេសដូចស្នាមជើង ដោយកិលេសដូចស្នាមជើង ដូចម្តេចកើត ។

យស្ស ជាលិនី វិសត្តិកា
តណ្ហា នត្ថិ កុហិញ្ចិ នេតវេ
តំ ពុទ្ធំ អនន្តគោចរំ
អបទំ កេន បទេន នេស្សថ ។

យេ ឈានបសុតា ធីរា នេក្ខម្មូបសមេ រតា
ទេវាបិ តេសំ បិហយន្តិ សម្ពុទ្ធានំ សតីមតំ ។

កិច្ឆោ មនុស្សបដិលាភោ កិច្ឆំ មច្ចាន ជីវិតំ
កិច្ឆំ សទ្ធម្មស្សវនំ កិច្ឆោ ពុទ្ធានមុប្បាទោ ។

សព្វបាបស្ស អករណំ កុសលស្សូបសម្បទា
សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំ ។



តណ្ហាដែលមានបណ្ដាញផ្សាយទៅ ក្នុងអារម្មណ៍ផ្សេង ៗ មិនមានដល់ព្រះពុទ្ធអង្គណា ដើម្បីនឹងនាំទៅ ក្នុងភពណាមួយ នាង ទាំងឡាយ នឹងប្រលោមព្រះពុទ្ធអង្គនោះ ដែលមានគោចរ រកទីបំផុតគ្មាន មិនមានកិលេសដូចស្នាមជើង ដោយកិលេសដូចស្នាមជើង ដូចម្ដេចកើត ។

អ្នកប្រាជ្ញទាំងឡាយណា ជាអ្នកខ្វល់ខ្វាយក្នុងឈាន ត្រេកអរក្នុងនេក្ខម្មៈ ជាទីនស្ងប់រម្ងាប់កិលេស សូម្បីទេវតានិងមនុស្សទាំងឡាយ តែងប៉ង ចំពោះអ្នកប្រាជ្ញទាំងឡាយនោះ ដែលជាអ្នកត្រាស់ដឹងខ្លួនឯង ទាំងមានស្មារតី ។

ការត្រឡប់បានអត្តភាពជាមនុស្ស បានដោយកម្រ ការរស់របស់សត្វទាំងឡាយ បានដោយកម្រ ការស្ដាប់ធម៌របស់សប្បុរស បានដោយកម្រ ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ បានដោយកម្រ ។

ការមិនធ្វើបាបទាំងពួង ការញុំាងកុសលឲ្យកើតឡើង ការធ្វើចិត្តរបស់ខ្លួនឲ្យផូរផង់ នេះជាពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។

ខន្តិ បរមំ តបោ តិតិក្ខា
និព្វានំ បរមំ វទន្តិ ពុទ្ធា
ន ហិ បព្វជិតោ បរូបឃាតី
សមណោ ហោតិ បរំ វិហេឋយន្តោ ។

អនូបវាទោ អនូបឃាតោ បាតិមោក្ខេ ច សំវរោ
មត្តញ្ញុតា ច ភត្តស្មឹ បន្តញ្ច សយនាសនំ
អធិចិត្តេ ច អាយោគោ ឯតំ ពុទ្ធាន សាសនំ ។

ន កហាបណវស្សេន តិត្តិ កាមេសុ វិជ្ជតិ
អប្បស្សាទា ទុខា កាមា ឥតិ វិញ្ញាយ បណ្ឌិតោ
អបិ ទិព្វេសុ កាមេសុ រតឹ សោ នាធិគច្ឆតិ
តណ្ហក្ខយរតោ ហោតិ សម្មាសម្ពុទ្ធសាវកោ ។

ពហុំ វេ សរណំ យន្តិ បព្វតានិ វនានិ ច
អារាមរុក្ខចេត្យានិ មនុស្សា ភយតជ្ជិតា
នេតំ ខោ សរណំ ខេមំ នេតំ សរណមុត្តមំ
នេតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ ។



ខន្តិ គឺសេចក្ដីអត់ធន់ ជាតបធម៌(*)ដ៏ឧត្ដម ព្រះពុទ្ធទាំងឡាយ តែងពោលថា ព្រះនិព្វាន ជាធម្មជាតដ៏ឧត្ដម បុគ្គលដែលសម្លាប់សត្វដទៃ មិនឈ្មោះថា បព្វជិតទេ បុគ្គលដែលបៀតបៀនសត្វដទៃ ក៏មិនឈ្មោះថា សមណឡើយ ។

ការមិនតិះដៀល ១ ការមិនបៀតបៀន ១ ការសង្រួមក្នុងបាតិមោក្ខ ១ ភាពជាអ្នកដឹងប្រមាណក្នុងភត្ត ១ ការដេកនិងអង្គុយក្នុងទីស្ងាត់ ១ ការព្យាយាមក្នុងអធិចិត្ត ១ នុ៎ះជាពាក្យប្រដៅ របស់ព្រះពុទ្ធទាំងឡាយ ។

ការស្កប់ស្កល់ ក្នុងកាមទាំងឡាយ រមែងមិនមាន ព្រោះភ្លៀងកហាបណៈ (ដែលធ្លាក់ចុះ) ដូចទឹកភ្លៀងទេ កាមទាំងឡាយ មានសុខតិច មានទុក្ខច្រើន អ្នកប្រាជ្ញដឹងច្បាស់ យ៉ាងនេះហើយ រមែងមិនដល់សេចក្ដីត្រេកអរ ក្នុងកាមទាំងឡាយ សូម្បីជាទិព្វឡើយ សាវ័ករបស់ព្រះសម្មាសម្ពុទ្ធ រមែងជាអ្នកត្រេកអរ ក្នុងធម៌ ជាគ្រឿងអស់តណ្ហា ។

មនុស្សទាំងឡាយ ច្រើននាក់ ត្រូវភ័យគម្រាមហើយ តែងយកភ្នំ អារាមនិងរុក្ខចេតិយ ជាទីពឹង ទីពឹងនោះ មិនមែនជាទីពឹងដ៏ក្សេមទេ ទីពឹងនោះ មិនមែនជាទីពឹងដ៏ឧត្ដមទេ បុគ្គលអាស្រ័យនូវទីពឹងនោះហើយ រមែងមិនរួចស្រឡះចាកទុក្ខទាំងពួងឡើយ ។

* ធម្មជាតដុតនូវកិលេសបាប ។

យោ ច ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ
ចត្តារិ អរិយសច្ចានិ សម្មប្បញ្ញាយ បស្សតិ
ទុក្ខំ ទុក្ខសមុប្បាទំ ទុក្ខស្ស ច អតិក្កមំ
អរិយញ្ចដ្ឋង្គិកំ មគ្គំ ទុក្ខូបសមគាមិនំ
ឯតំ ខោ សរណំ ខេមំ ឯតំ សរណមុត្តមំ
ឯតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ ។
ទុល្លភោ បុរិសាជញ្ញោ ន សោ សព្វត្ថ ជាយតិ
យត្ថ សោ ជាយតី ធីរោ តំ កុលំ សុខមេធតិ ។
សុខោ ពុទ្ធានុប្បាទោ សុខា សទ្ធម្មទេសនា
សុខា សង្ឃស្ស សាមគ្គី សមគ្គានំ តបោ សុខោ ។
បូជារហេ បូជយតោ ពុទ្ធេ យទិ ច សាវកេ
បបញ្ចសមតិក្កន្តេ តិណ្ណសោកបរិទ្ទវេ
តេ តាទិសេ បូជយតោ និព្វុតេ អកុតោភយេ
ន សក្កា បុញ្ញំ សង្ខាតុំ ឥមេត្តមបិ កេនចិ ។

ពុទ្ធវគ្គោ ចុទ្ទសមោ ។

បឋមភាណវារំ ។



លុះតែបុគ្គលណា យកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹង ឃើញច្បាស់នូវអរិយសច្ចទាំង ៤ គឺ ទុក្ខសច្ច ១ ទុក្ខសមុទយសច្ច ១ និរោធសច្ច កន្លងទុក្ខ ១ អរិយមគ្គប្រកបដោយអង្គ ៨ ជាដំណើរទៅកាន់ព្រះនិព្វានដែលជាទីរម្ងាប់ទុក្ខ ១ ដោយប្រាជ្ញាដ៏ប្រពៃ នេះឯងជាទីពឹងដ៏ក្សេម នេះឯង ជាទីពឹងដ៏ឧត្តម បុគ្គលអាស្រ័យទីពឹងនេះ .រមែង រួចស្រឡះចាកទុក្ខទាំងពួងបាន ។

បុរសអាជានេយ្យ គេបានដោយកម្រ លោកមិនកើតក្នុងសព្វឋានឡើយ លោកជាអ្នកមានប្រាជ្ញាកើតក្នុងត្រកូលណា ត្រកូលនោះ តែងដល់នូវសេចក្តីសុខ ។

ការកើតឡើងនៃព្រះពុទ្ធ ជាសុខ ការសំដែងព្រះសទ្ធម្ម ជាសុខ សេចក្តីព្រមព្រៀងគ្នានៃពួក ជាសុខ តបធម៌ របស់បុគ្គលអ្នកព្រមព្រៀងគ្នាទាំងឡាយ ជាសុខ ។

កាលបុគ្គលបូជា ដល់បូជារហបុគ្គលគឺព្រះពុទ្ធ ឬសាវ័ករបស់ព្រះពុទ្ធ ដែលកន្លងផុតបបញ្ចធម៌ ដែលកន្លងផុតសេចក្តីសោកនិងខ្សឹកខ្សួល ឬ កាលបូជាដល់បូជារហបុគ្គលទាំងនោះ ដែលប្រកប ដោយតាទិគុណ លោកមិនមានភ័យអំពីទីណា ស្ងប់រម្ងាប់ទៅហើយ បុគ្គលណាមួយ មិនអាចរាប់បុណ្យថាបុណ្យនេះមានប្រមាណប៉ុណ្ណេះ បានឡើយ ។

ចប់ ពុទ្ធវគ្គ ទី ១៤ ។

ចប់ បឋមភាណវារៈ ។

# ធម្មបទគាថាយ បណ្ណរសមោ សុខវគ្គោ

(២៨) សុសុខំ វត ជីវាម វេរិនេសុ អវេរិនោ
វេរិនេសុ មនុស្សេសុ វិហរាម អវេរិនោ ។
សុសុខំ វត ជីវាម អាតុរេសុ អនាតុរា
អាតុរេសុ មនុស្សេសុ វិហរាម អនាតុរា ។
សុសុខំ វត ជីវាម ឧស្សុកេសុ អនុស្សុកា
ឧស្សុកេសុ មនុស្សេសុ វិហរាម អនុស្សុកា ។
សុសុខំ វត ជីវាម យេសន្នោ នត្ថិ កិញ្ចនំ
បីតិភក្ខា ភវិស្សាម ទេវា អាភស្សរា យថា ។
ជយំ វេរំ បសវតិ ទុក្ខំ សេតិ បរាជិតោ
ឧបសន្តោ សុខំ សេតិ ហិត្វា ជយបរាជយំ ។
នត្ថិ រាគសមោ អគ្គិ នត្ថិ ទោសសមោ កលិ
នត្ថិ ខន្ធសមា ទុក្ខា នត្ថិ សន្តិបរំ សុខំ ។



# ធម្មបទគាថា សុខវគ្គទី ១៥

(២៨) យើងជាអ្នកមិនមានពៀរ រស់នៅជាសុខពិត ក្នុងពួកមនុស្សមានពៀរ កាលពួកមនុស្សមានពៀរ យើងជាអ្នកមិនមានពៀរ ។ យើងជាអ្នកមិនមានសេចក្តីក្តៅក្រហាយ (ដោយកិលេស) រស់នៅជាសុខពិត ក្នុងពួកមនុស្សមានសេចក្តីក្តៅក្រហាយ កាលពួកមនុស្សមានសេចក្តីក្តៅក្រហាយ យើងជាអ្នកមិនមានសេចក្តីក្តៅក្រហាយ ។ យើងជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ក្នុងការស្វែងរក រស់នៅជាសុខពិត ក្នុងពួកមនុស្សមានសេចក្តីខ្វល់ខ្វាយ កាលពួកមនុស្សមានសេចក្តីខ្វល់ខ្វាយ យើងជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ។ យើងមិនមានកង្វល់ តែងរស់នៅជាសុខពិត (ព្រោះ) យើងមានបីតិជាអាហារ ដូចពួកទេវតាជាន់អាភស្សរៈ ។

បុគ្គលអ្នកឈ្នះ តែងកើតពៀរ បុគ្គលអ្នកចាញ់ តែងដេកជាទុក្ខ ចំណែកបុគ្គល លះបង់ការឈ្នះនិងការចាញ់ចេញហើយ ជាអ្នកស្ងប់រម្ងាប់ ទើបដេកជាសុខ ។

ភ្លើងស្មើដោយរាគៈ មិនមាន ទោសកំហុសស្មើដោយទោសៈ មិនមាន ទុក្ខដទៃស្មើដោយខន្ធ មិនមាន សុខក្រៅពីសេចក្តីស្ងប់ មិនមាន ។

ជិឃច្ឆា បរមា រោគា សង្ខារា បរមា ទុក្ខា

ឯតំ ញត្វា យថាភូតំ និព្វានំ បរមំ សុខំ ។

អារោគ្យបរមា លាភា សន្តុដ្ឋីបរមំ ធនំ

វិស្សាសបរមា ញាតិ និព្វានំ បរមំ សុខំ ។

បវិវេករសំ បិត្វា រសំ ឧបសមស្ស ច

និទ្ទរោ ហោតិ និប្បាបោ ធម្មបីតិរសំ បិវំ ។

សាធុ ទស្សនមរិយានំ សន្និវាសោ សទា សុខោ

អទស្សនេន ពាលានំ និច្ចមេវ សុខី សិយា ។

ពាលសង្គតចារី ហិ ទីឃមទ្ធាន សោចតិ

ទុក្ខោ ពាលេហិ សំវាសោ អមិត្តេនេវ សព្វទា ។



សេចក្ដីស្រេកឃ្លាន ជារោគយ៉ាងក្រៃលែង សង្ខារទាំងឡាយ ជាទុក្ខយ៉ាងក្រៃលែង (អ្នកប្រាជ្ញ) ដឹងច្បាស់សេចក្ដីនុ៎ះ តាមពិតហើយ (រមែងធ្វើឲ្យច្បាស់) នូវព្រះនិព្វាន ជាសុខយ៉ាងក្រៃលែង ។

លាភមានការមិនមានរោគ ជាយ៉ាងក្រៃលែង ទ្រព្យមានសេចក្ដីសន្ដោស ជាយ៉ាងក្រៃលែង ញាតិមានសេចក្ដីស្និទ្ធស្នាល ជាយ៉ាងក្រៃលែង ព្រះនិព្វាន ជាសុខយ៉ាងក្រៃលែង ។

ភិក្ខុផឹករស (*) វិវេកផង រសព្រះនិព្វាន ជាទីរម្ងាប់កិលេសផង ផឹករសបីតិដែលកើតអំពីធម៌ផង រមែងជាអ្នកមិនមានសេចក្ដីក្រវល់ក្រវាយ មិនមានសេចក្ដីសៅហ្មងឡើយ ។

ការជួបប្រទះព្រះអរិយបុគ្គលទាំងឡាយ ជាការល្អ ការនៅរួមជាមួយព្រះអរិយបុគ្គលទាំងឡាយ ជាហេតុឲ្យកើតសេចក្ដីសុខ សព្វកាល បុគ្គលគប្បីមានសេចក្ដីសុខអស់កាលជានិច្ចបាន ព្រោះមិនជួបប្រទះបុគ្គលពាលទាំងឡាយ ។

បុគ្គលអ្នកប្រព្រឹត្តសមគប់ដោយជនពាល រមែងសោកស្ដាយអស់កាលយូរអង្វែង ការនៅរួមជាមួយនឹងជនពាល រមែងជាទុក្ខសព្វកាល ។

---

* រស ក្នុងទីនេះសំដៅយកសេចក្ដីសុខដ៏ប្រសើរ ។

ធីរោ ច សុខសំវាសោ ញាតីនំវ សមាគមោ

តស្មា ហិ

ធីរញ្ច បញ្ញញ្ច ពហុស្សុតញ្ច

ធោរយ្ហសីលំ វតវន្តមរិយំ

តំ តាទិសំ សប្បុរិសំ សុមេធំ

ភជេថ នក្ខត្តបថំវ ចន្ទិមា ។

សុខវគ្គោ បន្នរសមោ ។

## ធម្មបទគាថាយ សោឡសមោ បិយវគ្គោ

(៦៦) អយោគេ យុញ្ជមត្តានំ យោគស្មិញ្ច អយោជយំ

អត្ថំ ហិត្វា បិយគ្គាហី បិហេតត្តានុយោគិនំ ។

មា បិយេហិ សមាគញ្ឆិ អប្បិយេហិ កុទាចនំ

បិយានំ អទស្សនំ ទុក្ខំ អប្បិយានញ្ច ទស្សនំ ។



ដូចការនៅរួមជាមួយ នឹងសត្រូវ ចំណែកខាងការនៅរួមនឹងធីរជន រមែងជាសុខ ដូចការជួបជុំនៃញាតិទាំងឡាយ ព្រោះហេតុនោះឯង បុគ្គលគួរសេពគប់សប្បុរស ជាអ្នកនាំមុខផង មានបញ្ញាផង មានសេចក្ដីចេះដឹងច្រើនផង មានការព្យាយាមនាំទៅនូវធុរៈជាប្រក្រតីផង មានសីលនិងវត្តប្រតិបត្តិផង ជាអ្នកឆ្ងាយចាកកិលេសផង មានបញ្ញាល្អផង ប្រាកដដូច្នោះ ៗ ឲ្យដូចព្រះចន្ទគប់នូវផ្លូវនៃនក្ខត្តឫក្ស ។

ចប់ សុខវគ្គ ទី ១៥ ។

## ធម្មបទគាថា បិយវគ្គ ទី ១៦

(៦៦) បុគ្គលកាលប្រកបខ្លួនទុក ក្នុងអំពើដែលមិនគួរប្រកប មិនប្រកបខ្លួន ក្នុងអំពើដែលគួរប្រកប លះបង់ប្រយោជន៍ចេញហើយ កាន់យកតាមតែចិត្ត រមែងស្រឡាញ់ បុគ្គលអ្នកប្រកបតាមខ្លួន ។ កុំគប់គេសត្វនិងសង្ខារទាំងឡាយ ដែលជាទីស្រឡាញ់ និងមិនជាទីស្រឡាញ់ ក្នុងកាលណា ៗ ឡើយ ព្រោះថា ការមិនបានឃើញសត្វ សត្វនិងសង្ខារជាទីស្រឡាញ់ក្ដី ការបានឃើញសត្វនិងសង្ខារមិនជាទីស្រឡាញ់ក្ដី ជាហេតុនាំមកនូវទុក្ខ ។

តស្មា បិយំ ន កយិរាថ បិយាបាយោ ហិ បាបកោ
គន្ថា តេសំ ន វិជ្ជន្តិ យេសំ នត្ថិ បិយាប្បិយំ ។

បិយតោ ជាយតី(១) សោកោ បិយតោ ជាយតី ភយំ
បិយតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។

បេមតោ ជាយតី សោកោ បេមតោ ជាយតី ភយំ
បេមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។

រតិយា ជាយតី សោកោ រតិយា ជាយតី ភយំ
រតិយា វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។

កាមតោ ជាយតី សោកោ កាមតោ ជាយតី ភយំ
កាមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។

តណ្ហាយ ជាយតី សោកោ តណ្ហាយ ជាយតី ភយំ
តណ្ហាយ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។

១ ពិយាករណ៍ ជាយតេ ។



ព្រោះហេតុនោះ បុគ្គលមិនគួរធ្វើសត្វនឹងសង្ខារ ឲ្យជាទីស្រឡាញ់ ព្រោះការព្រាត់ប្រាសចាកសត្វនឹងសង្ខារ ជាទីស្រឡាញ់ ជាសភាពអាក្រក់ ការស្រឡាញ់នឹងការស្អប់ មិនមានដល់ពួកជនណា កិលេសគ្រឿងចាក់ស្រែះទាំងឡាយ រមែងមិនមាន ដល់ពួកជននោះ ។

សេចក្ដីសោកកើតអំពីសេចក្ដីស្រឡាញ់ ភ័យកើតអំពីសេចក្ដីស្រឡាញ់ កាលបើរួចស្រឡះចាកសេចក្ដីស្រឡាញ់ហើយ សេចក្ដីសោក ក៏លែងមាន ភ័យនឹងមានមកពីណា ។

សេចក្ដីសោកកើតអំពីសេចក្ដីស្រឡាញ់ ភ័យកើតអំពីសេចក្ដីស្រឡាញ់ កាលបើរួចស្រឡះចាកសេចក្ដីស្រឡាញ់ហើយ សេចក្ដីសោក ក៏លែងមាន ភ័យនឹងមានមកពីណា ។

សេចក្ដីសោកកើតអំពីតម្រេក ភ័យកើតអំពីតម្រេក កាលបើរួចស្រឡះចាកតម្រេកហើយ សេចក្ដីសោកក៏លែងមាន ភ័យនឹងមានមកពីណា ។

សេចក្ដីសោកកើតអំពីកាម ភ័យកើតអំពីកាម កាលបើរួចស្រឡះចាកកាមហើយ សេចក្ដីសោក ក៏លែងមាន ភ័យនឹងមានមកពីណា ។

សេចក្ដីសោកកើតអំពីតណ្ហា ភ័យកើតអំពីតណ្ហា កាលបើរួចស្រឡះចាកតណ្ហាហើយ សេចក្ដីសោក ក៏លែងមាន ភ័យនឹងមានមកពីណា ។

សីលទស្សនសម្បន្នំ ធម្មដ្ឋំ សច្ចវាទិនំ

អត្តនោ កម្មកុព្វានំ តញ្ជនោ កុរុតេ បិយំ ។

ឆន្ទជាតោ អនក្ខាតេ មនសា ច ផុដោ(១) សិយា

កាមេ(២) ច អប្បដិពទ្ធចិត្តោ(៣) ឧទ្ធំសោតោតិ វុច្ចតិ ។

ចិរប្បវាសឹ បុរិសំ ទូរតោ សោត្ថិមាគតំ

ញាតី មិត្តា សុហជ្ជា ច អភិនន្ទន្តិ អាគតំ

តថេវ កតបុញ្ញម្បិ អស្មា លោកា បរំ គតំ

បុញ្ញានិ បដិគណ្ហន្តិ បិយំ ញាតីវ អាគតំ ។

បិយវគ្គោ សោឡសមោ ។

## ធម្មបទគាថាយ សត្តរសមោ កោដ្ឋាសោ

(៦៧) កោធំ ជហេ វិប្បជហេយ្យ មានំ

១ ម. ផុដោ ។ ផុដ្ឋោសិ យា ។ ២ កាមេ ... កាមេសុ ចសព្វធិ ។
៣ ម. អប្បដិពទ្ធចិត្តោ ។



ជនតែងធ្វើបុគ្គលដែលបរិបូណ៌ ដោយសីលនិងការឃើញត្រូវ ឋិតនៅក្នុងធម៌ ពោលសច្ចធម៌(១)ជាប្រក្រតី ធ្វើកម្ម(២)ជារបស់ខ្លួននោះ ឲ្យជាទីស្រឡាញ់ ។

បុគ្គល អ្នកមានសេចក្ដីប្រាថ្នា ចំពោះព្រះនិព្វាន ដែលគេនិយាយប្រាប់ភ្លាមមិនបានផង ជាអ្នកមានមគ្គចិត្តនិងផលចិត្ត (ខាងក្រោម) ប៉ះពាល់ហើយផង មានចិត្តមិនប្រតិព័ទ្ធក្នុងកាមផង គេហៅអ្នកនោះថា ជាអ្នកមានខ្សែមគ្គប្រព្រឹត្តទៅ ក្នុងខាងលើ ។

ពួកញាតិក្ដី មិត្រក្ដី សំឡាញ់ក្ដី រមែងត្រេកអរនឹងបុរសដែលឃ្លាតឆ្ងាយ អស់កាលយូរ មកអំពីចម្ងាយដោយសួស្ដី មកដល់ហើយ យ៉ាងណាមិញ បុណ្យទាំងឡាយ តែងទទួលបុគ្គល ដែលបានធ្វើបុណ្យ ច្រើនអំពីមនុស្សលោកនេះ ទៅកាន់លោកខាងមុខ ដូចញាតិទាំងឡាយ ទទួលបុរសជាទីស្រឡាញ់ដែលមកដល់ ដូច្នោះឯង ។

ចប់ បិយវគ្គ ទី ១៦ ។

## ធម្មបទគាថា កោដ្ឋាសទី ១៧

( ៦៧ ) បុគ្គលគប្បីលះបង់សេចក្ដីក្រោធចេញ គប្បីលះបង់មានះចេញ

១ សំដៅយកអរិយសច្ច ៤ ។ ២ បានដល់ត្រៃសិក្ខា ។ អដ្ឋកថា ។

សញ្ញោជនំ សព្វមតិក្កមេយ្យ
តញ្ចាមរូបស្មិំ អសជ្ជមានំ
អកិញ្ចនំ នានុបតន្តិ ទុក្ខា ។

យោ វេ ឧប្បតិតំ កោធំ រថំ ភន្តំវ ធារយេ (១)
តមហំ សារថឹ ព្រូមិ រស្មិគ្គាហោ ឥតរោ ជនោ ។

អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ
ជិនេ កទរិយំ ទានេន សច្ចេនាលិកវាទិនំ ។

សច្ចំ ភណេ ន កុជ្ឈេយ្យ ទជ្ជា អប្បស្មិំ យាចិតោ
ឯតេហិ តីហិ ឋានេហិ គច្ឆេ ទេវាន សន្តិកេ ។

អហឹសកា យេ មុនយោ និច្ចំ កាយេន សំវុតា
តេ យន្តិ អច្ចុតំ ឋានំ យត្ថ គន្ត្វា ន សោចរេ ។

---
១. ម. ធារយំ ។



រួតនូវសញ្ញោជនៈទាំងអស់ចោលចេញ ទុក្ខទាំងឡាយ តែងមិនជាប់តាមបុគ្គល ដែលមិនជំពាក់ ក្នុងនាមនិងរូប មិនមានកិលេស គ្រឿងកង្វល់នោះឡើយ ។

បុគ្គលណា ឃាត់សេចក្តីក្រោធ ដែលកើតឡើងហើយ ដូចសារថី ទប់រថដែលកំពុងលឿនបាន តថាគតហៅបុគ្គលនោះថាជាសារថី ជនក្រៅពីនេះ គ្រាន់តែជាអ្នកកាន់ខ្សែ (មិនមែនសារថីឡើយ) ។

បុគ្គលគប្បីឈ្នះមនុស្សក្រោធ ដោយសេចក្តីមិនក្រោធ គប្បីឈ្នះមនុស្សអសប្បុរស ដោយសប្បុរស គប្បីឈ្នះមនុស្សកំណាញ់ដោយការឲ្យ គប្បីឈ្នះមនុស្សនិយាយពាក្យមិនពិត ដោយពាក្យពិត ។

បុគ្គលគួរពោលពាក្យពិត ១ មិនគួរក្រោធ ១ កាលគេសូមវត្ថុសូម្បីមានតិច ក៏គួរឲ្យ (តាមតិច) ១ បុគ្គលគប្បីទៅកើត ក្នុងសំណាក់ទេវតាទាំងឡាយបាន ដោយហេតុទាំង ៣ នេះឯង ។

ជនទាំងឡាយណា ជាអ្នកប្រាជ្ញ(១) មិនបៀតបៀនសត្វដទៃ សង្រួមហើយដោយកាយទ្វារ (ជាដើម) ជានិច្ច ជនទាំងឡាយនោះ រមែងទៅកាន់ស្ថានដ៏មិនប្រែប្រួល ជាស្ថានដែលគេទៅដល់ហើយ តែងមិនសោកស្តាយ ។

---
១ សំដៅយកអរហន្តមុនី ដែលសម្រេចមោនធម្មផល ដោយមោនេយ្យប្បដិបទា ។ អដ្ឋកថា ។

សទា ជាគរមានានំ អហោរត្តានុសិក្ខិនំ
និព្វានំ អធិមុត្តានំ អត្ថំ គច្ឆន្តិ អាសវា ។
ពោរាណមេតំ អតុល នេតំ អជ្ជតនាមិវ
និន្ទន្តិ តុណ្ហិមាសីនំ និន្ទន្តិ ពហុភាណិនំ
មិតភាណិម្បិ និន្ទន្តិ នត្ថិ លោកេ អនិន្ទិតោ ។
ន ចាហុ ន ច ភវិស្សតិ ន ចេតរហិ វិជ្ជតិ
ឯកន្តំ និន្ទិតោ បោសោ ឯកន្តំ វា បសំសិតោ ។
យញ្ចេ វិញ្ញូ បសំសន្តិ អនុវិច្ច សុវេ សុវេ
អច្ឆិទ្ទវុត្តឹ[១] មេធាវឹ បញ្ញាសីលសមាហិតំ
នេក្ខំ ជម្ពោនទស្សេវ កោ តំ និន្ទិតុមរហតិ
ទេវាបិ នំ បសំសន្តិ ព្រហ្មុនាបិ បសំសិតោ ។

១ ម. អច្ឆិន្នវុត្តឹ ។



អាសវៈទាំងឡាយរបស់បុគ្គល អ្នកភ្ញាក់រឭកសព្វកាល ជាអ្នកសិក្សាត្រៃសិក្ខា ទាំងថ្ងៃទាំងយប់ មានចិត្តចុះស៊ប់ចំពោះព្រះនិព្វាន តែងដល់នូវការវិនាសទៅមិនខានឡើយ ។

ម្នាលអតុលៈ ការនិន្ទារៀលនិងការសរសើរនេះ ជារបស់ចាស់ណាស់ ការនិន្ទារៀលនិងការសរសើរនេះ មិនមែនទើបនឹងកើតឡើង ក្នុងថ្ងៃនេះ (ក្រោយៗ) ជនទាំងឡាយ តែងនិន្ទាបុគ្គលអ្នកអង្គុយស្ងៀម ក៏មាន និន្ទាបុគ្គលអ្នកនិយាយច្រើន ក៏មាន និន្ទាបុគ្គលអ្នកនិយាយល្មមប្រមាណ ក៏មាន (អ្នកណាៗ ក៏ដោយ) ក្នុងលោក ដែលមិនត្រូវគេនិន្ទា គ្មានឡើយ បុគ្គលដែលត្រូវគេនិន្ទាតែម្យ៉ាង ឬត្រូវគេសរសើរតែម្យ៉ាង មិនមែនមានមកហើយក្នុងកាលកន្លងទេ នឹងមានទៅក្នុងអនាគត ក៏ទេ មានក្នុងបច្ចុប្បន្ននេះក៏ទេ ។

បើអ្នកប្រាជ្ញទាំងឡាយសង្កេតមើលរាល់ៗថ្ងៃ ហើយសរសើរបុគ្គលណា ដែលជាអ្នកប្រព្រឹត្តមិនដាច់ មានប្រាជ្ញា មានចិត្តតម្កល់ខ្ជាប់ក្នុងបញ្ញានិងសីល អ្នកណាគួរនឹងនិន្ទាបុគ្គល ដែលដូចជាដុំនៃមាសជម្ពូនទនោះបាន សូម្បីទេវតានឹងមនុស្សទាំងឡាយ ក៏សរសើរបុគ្គលនោះ ទាំងព្រហ្មក៏សរសើរ (ដូចគ្នា) ។

កាយប្បកោបំ រក្ខេយ្យ កាយេន សំវុតោ សិយា
កាយទុច្ចរិតំ ហិត្វា កាយេន សុចរិតំ ចរេ
វចីបកោបំ រក្ខេយ្យ វាចាយ សំវុតោ សិយា
វចីទុច្ចរិតំ ហិត្វា វាចាយ សុចរិតំ ចរេ
មនោបកោបំ រក្ខេយ្យ មនសា សំវុតោ សិយា
មនោទុច្ចរិតំ ហិត្វា មនសា សុចរិតំ ចរេ
កាយេន សំវុតា ធីរា អថោ វាចាយ សំវុតា
មនសា សំវុតា ធីរា តេ វេ សុបរិសំវុតា ។

កោធវគ្គោ សត្តរសមោ ។

## ធម្មបទគាថាយ អដ្ឋារសមោ មលវគ្គោ

(៦៨) បណ្ឌុបលាសោវ ទានិសិ
យមបុរិសាបិ ច តេ ឧបដ្ឋិតា
ឧយ្យោគមុខេ ច តិដ្ឋសិ
បាថេយ្យម្បិ ច តេ ន វិជ្ជតិ ។



បុគ្គលគប្បីរក្សានូវការក្រេវក្រោធកាយ គប្បីសង្រួមកាយ គប្បីលះបង់កាយទុច្ចរិត គប្បីប្រព្រឹត្តកាយសុចរិត គប្បីរក្សានូវការក្រេវក្រោធវាចា គប្បីសង្រួមវាចា គប្បីលះបង់វចីទុច្ចរិត គប្បីប្រព្រឹត្តវចីសុចរិត គប្បីរក្សានូវការក្រេវក្រោធចិត្ត គប្បីសង្រួមចិត្ត គប្បីលះបង់មនោទុច្ចរិត គប្បីប្រព្រឹត្តមនោសុចរិត អ្នកប្រាជ្ញទាំងឡាយ បានសង្រួមកាយ សង្រួមវាចា អ្នកប្រាជ្ញទាំងឡាយ បានសង្រួមចិត្តហើយ លោកទាំងនោះឯង ឈ្មោះថា សង្រួមហើយដោយប្រពៃ ។

ចប់ កោធវគ្គទី ១៧ ។

## ធម្មបទគាថា មលវគ្គទី ១៨

(៦៨) ឥឡូវនេះ ខ្លួនអ្នកដូចស្លឹកឈើទុំហើយ ទាំងពួកបុរសរបស់យមរាជ(១) ប្រាកដ ដល់អ្នកហើយ ខ្លួនអ្នកតាំងនៅក្នុងមាត់សេចក្តីវិនាស សូម្បីស្បៀងគឺកុសលរបស់អ្នក ក៏មិនមានឡើយ ។

១ ពួកបម្រើរបស់យមៈ ឬពាក្យនេះសំដៅយកសេចក្តីស្លាប់ ។ អដ្ឋកថា ។

សោ ករោហិ ទីបមត្តនោ
ខិប្បំ វាយម បណ្ឌិតោ ភវ
និទ្ធន្តមលោ អនង្គណោ
ទិព្វំ អរិយភូមិមេហិសិ[១] ។
ឧបនីតវយោ ច ទានិសិ
សម្បយាតោសិ[២] យមស្ស សន្តិកំ[៣]
វាសោបិ ច តេ នត្ថិ អន្តរា
បាថេយ្យម្បិ ច តេ ន វិជ្ជតិ ។
សោ ករោហិ ទីបមត្តនោ
ខិប្បំ វាយម បណ្ឌិតោ ភវ
និទ្ធន្តមលោ អនង្គណោ
ន បុន ជាតិជរំ ឧបេហិសិ ។
អនុបុព្វេន មេធាវី ថោកំ ថោកំ ខណេ ខណេ
កម្មារោ រជតស្សេវ និទ្ធមេ មលមត្តនោ ។

១ ម. អរិយភូមឹ ឧបេហិសិ ។ ២. សម្បយាតោ ច ។ ៣ ឱ.ម. សន្តិកេ ។



អ្នកចូរធ្វើកុសលជាទីពឹងសម្រាប់ខ្លួនទៅ ចូរព្យាយាមឲ្យឆាប់ទៅ ចូរជាអ្នកប្រាជ្ញទៅ បើអ្នក (ធ្វើយ៉ាងនេះហើយ) នឹងទៅជាអ្នកកំចាត់បង់មន្ទិលបាន មិនមានទីចូលគឺកិលេស នឹងដល់នូវភូមិរបស់ព្រះអរិយៈ ដូចជាទិព្វបាន ។

ឥឡូវនេះ ខ្លួនអ្នកត្រូវជរាចូលដល់ហើយ ជាអ្នករៀបដំណើរទៅកាន់សំណាក់យមរាជ មួយទៀត ទីសំចតក្នុងចន្លោះ មិនមានដល់អ្នកទេ សម្ភារស្បៀង ក៏មិនមានដល់អ្នក ។

អ្នកចូរធ្វើទីពឹងសម្រាប់ខ្លួនទៅ ចូរព្យាយាមឲ្យឆាប់ទៅ ចូរជាអ្នកប្រាជ្ញទៅ បើអ្នក (ធ្វើយ៉ាងនេះហើយ) នឹងទៅជាអ្នកកំចាត់បង់មន្ទិលបាន មិនមានទីចូលគឺកិលេស នឹងមិនត្រូវចូលទៅកាន់ជាតិ ជរា ព្យាធិ មរណៈ ទៀតឡើយ ។

អ្នកមានប្រាជ្ញ គួរកំចាត់បង់មន្ទិលរបស់ខ្លួនបន្តិចម្តងៗ រាល់ៗ ខណៈ ដោយលំដាប់ ដូចជាងមាស ដកស្នឹមច្រែះរបស់មាសដូច្នោះ ។

អយសា វ មលំ សមុដ្ឋិតំ(១)
តទុដ្ឋាយ តមេវ ខាទតិ
ឯវំ អតិធោនចារិនំ
សានិ កម្មានិ នយន្តិ ទុគ្គតឹ ។

អសជ្ឈាយមលា មន្តា   អនុដ្ឋានមលា ឃរា
មលំ វណ្ណស្ស កោសជ្ជំ   បមាទោ រក្ខតោ មលំ ។
មលិត្ថិយា ទុច្ចរិតំ   មច្ឆេរំ ទទតោ មលំ
មលា វេ បាបកា ធម្មា   អស្មឹ លោកេ បរម្ហិ ច
តតោ មលា មលតរំ   អវិជ្ជា បរមំ មលំ
ឯតំ មលំ បហន្ត្វាន   និម្មលា ហោថ ភិក្ខវោ ។
សុជីវំ អហិរិកេន   កាកសូរេន ធំសិនា
បក្ខន្ទិនា បគព្ភេន   សង្កិលិដ្ឋេន ជីវិតំ ។
ហិរីមតា ច ទុជ្ជីវំ   និច្ចំ សុចិគវេសិនា
អលីនេនាបគព្ភេន   សុទ្ធាជីវេន បស្សតា ។

១ ឆដ្ឋំ បោត្ថកេ សមុដ្ឋាយំ ទិស្សតិ ។



ច្រែះកើតអំពីដែក លុះកើតអំពីដែកនោះហើយ តែងស៊ីដែកនោះវិញ យ៉ាងណាមិញ កម្មទាំងឡាយរបស់ខ្លួន តែងនាំបុគ្គលអ្នកប្រព្រឹត្តកន្លងបញ្ញាជាគ្រឿងពិចារណា ឲ្យទៅកាន់ទុគ្គតិ ក៏យ៉ាងនោះឯង ។

មន្តទាំងឡាយមានការមិនស្វាធ្យាយ ជាមន្ទិល ផ្ទះទាំងឡាយមានការមិនថែទាំ ជាមន្ទិល សេចក្តីខ្ជិល ជាមន្ទិលរបស់ពណ៌សម្បុរ សេចក្តីប្រមាទ ជាមន្ទិលរបស់បុគ្គលអ្នករក្សា ។

ការប្រព្រឹត្តអាក្រក់(១) ជាមន្ទិលរបស់ស្ត្រី សេចក្តីកំណាញ់ ជាមន្ទិលរបស់អ្នកឲ្យ ធម៌អាក្រក់ទាំងឡាយ ជាមន្ទិល ក្នុងលោកនេះនិងលោកខាងមុខ ធម្មជាត ជាមន្ទិលដ៏លើសលុប ជាងមន្ទិលទាំងនោះ គឺអវិជ្ជា ជាមន្ទិលដ៏ក្រៃលែង ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះមន្ទិលទាំងនេះចេញ ចូរកុំជាអ្នកមានមន្ទិលឡើយ ។

បុគ្គលអ្នកមិនមានសេចក្តីខ្មាស ក្លៀវក្លាដូចសត្វក្អែក កំចាត់បង់គុណរបស់អ្នកដទៃ ជាអ្នកល្មោភពាន (យកមុខ) ជាអ្នកឃ្លើសឃ្លង់ ជាមនុស្សសៅហ្មង រស់នៅដោយងាយ ។ ចំណែកបុគ្គលអ្នកមានសេចក្តីខ្មាស ស្វែងរកតែកិរិយាស្អាតជានិច្ច មិនរួញរា មិនឃ្លើសឃ្លង់ រស់នៅដោយកម្មដ៏បរិសុទ្ធ អ្នកឃើញច្បាស់ រស់នៅដោយលំបាក

១ សំដៅយកការប្រព្រឹត្តកន្លងស្វាមី ។ អដ្ឋកថា ។

យោ បាណមតិបាតេតិ[១] មុសាវាទញ្ច ភាសតិ
លោកេ អទិន្នំ អាទិយតិ បរទារញ្ច គច្ឆតិ
សុរាមេរយបានញ្ច យោ នរោ អនុយុញ្ជតិ
ឥធេវមេសោ លោកស្មឹ មូលំ ខណតិ អត្តនោ ។
ឯវំ ភោ បុរិស ជានាហិ បាបធម្មា អសញ្ញតា
មា តំ[២] លោភោ អធម្មោ ច ចិរំ ទុក្ខាយ រន្ធយុំ[៣] ។
ទទាតិ[៤] វេ យថាសទ្ធំ យថាបសាទនំ ជនោ
តត្ថ យោ មង្កុតោ ហោតិ បរេសំ បានភោជនេ
ន សោ ទិវា វា រត្តឹ វា សមាធឹ អធិគច្ឆតិ ។
យស្ស ចេតំ សមុច្ឆិន្នំ មូលឃច្ចំ[៥] សមូហតំ
ស វេ ទិវា វា រត្តឹ វា សមាធឹ អធិគច្ឆតិ ។
នត្ថិ រាគសមោ អគ្គិ នត្ថិ ទោសសមោ គហោ
នត្ថិ មោហសមំ ជាលំ នត្ថិ តណ្ហាសមា នទី ។

---

១ យុត្តិ សោធកោ យោ បាណមតិបាតេតិ ទិស្សតិ ។ ២ [illegible] ។ ៣ ម. រន្ធយុំ ។ ៤ យុត្តិ សោធកោ ទទន្តិ ទិស្សតិ ។ ៥ មូលឃច្ចំ [illegible] ។



ជនណា សម្លាប់សត្វផង និយាយពាក្យកុហកផង កាន់យកនូវវត្ថុដែលគេមិនបានឲ្យ ក្នុងលោកផង សេពប្រពន្ធរបស់អ្នកដទៃផង ជនណា ផឹកទឹកស្រវឹងគឺសុរានិងមេរ័យផង ជននោះឈ្មោះថា គាស់រំលើងឫសគល់របស់ខ្លួន ក្នុងលោកនេះ ដោយពិត ។

ម្នាលបុរសដ៏ចំរើន អ្នកចូរដឹងយ៉ាងនេះថា ជនទាំងឡាយមានធម៌ដ៏លាមក រមែងមិនជាអ្នកសង្រួមដូច្នេះ លោភៈនិងសភាពមិនមែនធម៌ ទោសៈ ចូរកុំបៀតបៀនអ្នក ឲ្យបានសេចក្តីទុក្ខអស់កាលយូរឡើយ ។

ជន រមែងឲ្យតាមសទ្ធា តាមសេចក្តីជ្រះថ្លា បុគ្គលណា ជាអ្នកអៀនខ្មាសក្នុងទឹកនិងភោជនរបស់ជនទាំងឡាយដទៃ ជននោះ រមែងមិនបានសមាធិចិត្ត ក្នុងវេលាថ្ងៃ ក្នុងវេលាយប់ឡើយ ។

សេចក្តីអៀនខ្មាសនោះ បុគ្គលណា បានផ្តាច់ផ្តិលដកឡើង ធ្វើឲ្យមានឫសគល់ដាច់ហើយ បុគ្គលនោះឯង ទើបបានសមាធិចិត្ត ក្នុងវេលាថ្ងៃ ក្នុងវេលាយប់ ។

ភ្លើងស្មើដោយរាគៈ មិនមាន ការចាប់ស្មើដោយទោសៈ មិនមាន បណ្តាញស្មើដោយមោហៈ មិនមាន ស្ទឹងស្មើដោយតណ្ហា មិនមាន ។

សុទស្សំ វជ្ជមញ្ញេសំ អត្តនោ បន ទុទ្ទសំ
បរេសំ ហិ សោ វជ្ជានិ ឱបុណាតិ យថាភុសំ
អត្តនោ បន ឆាទេតិ កលឹវ កិតវា សឋោ ។

បរវជ្ជានុបស្សិស្ស និច្ចំ ឧជ្ឈានសញ្ញិនោ
អាសវា តស្ស វឌ្ឍន្តិ អារា សោ អាសវក្ខយា ។

អាកាសេវ បទំ នត្ថិ សមណោ នត្ថិ ពាហិរេ[១]
បបញ្ចាភិរតា បជា និប្បបញ្ចា តថាគតា ។

អាកាសេវ បទំ នត្ថិ សមណោ នត្ថិ ពាហិរេ[២]
សង្ខារា សស្សតា នត្ថិ នត្ថិ ពុទ្ធានមិញ្ជិតំ ។

មលវគ្គោ អដ្ឋារសមោ ។

---
១-២ ឱ. ម. ពាហិរោ ។



ទោសរបស់អ្នកដទៃ ឃើញបានដោយងាយ ចំណែកទោសរបស់ខ្លួន ឃើញបានដោយលំបាក ព្រោះថា បុគ្គលនោះ រោយទោសទាំងឡាយ ចំពោះអ្នកដទៃ ដូចបុគ្គលរោយអង្កាមដូច្នោះ តែថា រមែងបិទបាំងនូវទោសរបស់ខ្លួនទុក ដូចព្រានបក្សីបិទបាំងនូវអត្តភាពដោយវត្ថុសម្រាប់បិទបាំង (មានមែកឈើជាដើម) ដូច្នោះ ។

កាលបុគ្គលតាមឃ្លាំមើលទោស របស់បុគ្គលដទៃ ជាប្រក្រតី មានការសំគាល់ទោសក្នុងការពាលទោស (អ្នកដទៃ) ជានិច្ចជាប្រក្រតី អាសវៈ ទាំងឡាយ របស់បុគ្គលនោះ រមែងចំរើន បុគ្គលនោះ ឈ្មោះថា ឋិតនៅឆ្ងាយអំពីធម៌ជាគ្រឿងអស់អាសវៈ ។

ស្នាមជើង ក្នុងអាកាស មិនមាន សមណៈខាងក្រៅ មិនមាន ពួកសត្វត្រេកអរហើយ ក្នុងធម៌ជាគ្រឿងយឺតយូរ ព្រះតថាគតទាំងឡាយ មិនមានធម៌ជាគ្រឿងយឺតយូរឡើយ ។

ស្នាមជើង ក្នុងអាកាស មិនមាន សមណៈខាងក្រៅ មិនមាន សង្ខារទាំងឡាយជារបស់ទៀង មិនមាន ព្រះពុទ្ធទាំងឡាយ មិនមានកិលេសជាគ្រឿងញាប់ញ័រទេ ។

ចប់ មលវគ្គ ទី ១៨ ។

## ធម្មបទគាថាយ ឯកូនវីសតិមោ ធម្មដ្ឋវគ្គោ

(៦៨) ន តេន ហោតិ ធម្មដ្ឋោ យេនត្ថំ សហសា នយេ

យោ ច អត្ថំ អនត្ថញ្ច ឧភោ និច្ឆេយ្យ បណ្ឌិតោ ។

អសាហសេន ធម្មេន សមេន នយតី បរេ

ធម្មស្ស គុត្តោ មេធាវី ធម្មដ្ឋោតិ បវុច្ចតិ ។

ន តេន បណ្ឌិតោ ហោតិ យាវតា ពហុ ភាសតិ

ខេមី អវេរី អភយោ បណ្ឌិតោតិ បវុច្ចតិ ។

ន តាវតា ធម្មធរោ យាវតា ពហុ ភាសតិ

យោ ច អប្បម្បិ សុត្វាន ធម្មំ កាយេន បស្សតិ

ស វេ ធម្មធរោ ហោតិ យោ ធម្មំ នប្បមជ្ជតិ ។





## ធម្មបទគាថា ធម្មដ្ឋវគ្គ ទី ១៩

(៦៨) បុគ្គលកាត់សេចក្តីដោយតក្រក់ ដោយសារហេតុណា ឈ្មោះថាជាអ្នកតាំងនៅក្នុងធម៌ ដោយហេតុនោះ មិនបានឡើយ លុះត្រាតែបុគ្គលណា ជាបណ្ឌិតកាត់សេចក្តីទាំងពីរ គឺសេចក្តីពិត និងសេចក្តីមិនពិត វែកញែកចាក់ឡូយផ្សេង ដោយមិនតក្រក់ ដោយសារធម៌តាមសមគួរ ( ដល់ទោស ) បុគ្គលនោះ ឈ្មោះថាជាអ្នកមានប្រាជ្ញត្រូវធម៌ ទើបហៅថា អ្នកតាំងនៅក្នុងធម៌ ។

បុគ្គលនិយាយច្រើន ដោយហេតុមានប្រមាណប៉ុណ្ណា ឈ្មោះថាជាបណ្ឌិត ដោយហេតុមានប្រមាណប៉ុណ្ណោះ មិនបានឡើយ លុះត្រាតែបុគ្គលដែលមានសេចក្តីក្សេម មិនមានពៀរ មិនមានភ័យ ទើបហៅថា បណ្ឌិតបាន ។

បុគ្គលនិយាយច្រើន ដោយហេតុមានប្រមាណប៉ុណ្ណា ឈ្មោះថាជាអ្នកទ្រទ្រង់ធម៌ ដោយហេតុមានប្រមាណប៉ុណ្ណោះ មិនបានឡើយ លុះត្រាតែបុគ្គលណា ស្តាប់ព្រះវចនៈ សូម្បីមានប្រមាណតិចហើយឃើញធម៌ដោយតាមកាយនិងចិត្តបាន បុគ្គលនោះទើបឈ្មោះថាជាអ្នកទ្រទ្រង់ធម៌ បុគ្គលណា មិនភ្លេចភ្លាំងធម៌ បុគ្គលនោះក៏ឈ្មោះថាជាអ្នកទ្រទ្រង់ធម៌ ។

ន តេន ថេរោ ហោតិ យេនស្ស បលិតំ សិរោ
បរិបក្កោ វយោ តស្ស មោឃជិណ្ណោតិ វុច្ចតិ ។
យម្ហិ សច្ចញ្ច ធម្មោ ច អហឹសា សញ្ញមោ (១) ទមោ
ស វេ វន្តមលោ ធីរោ សោ ថេរោតិ បវុច្ចតិ ។
ន វាក្ករណមត្តេន វណ្ណបោក្ខរតាយ វា
សាធុរូបោ នរោ ហោតិ ឥស្សុកី មច្ឆរី សឋោ ។
យស្ស ចេតំ សមុច្ឆិន្នំ មូលឃច្ចំ សមូហតំ
ស វន្តទោសោ មេធាវី សាធុរូបោតិ វុច្ចតិ ។
ន មុណ្ឌកេន សមណោ អព្វតោ អលិកំ ភណំ
ឥច្ឆាលោភសមាបន្នោ សមណោ កឹ ភវិស្សតិ ។
យោ ច សមេតិ បាបានិ អណុំថូលានិ សព្វសោ
សមិតត្តា ហិ បាបានំ សមណោតិ បវុច្ចតិ ។

១ ម. សំយមោ ។



បុគ្គលមានក្បាលស្កូវហើយ ដោយហេតុណា ឈ្មោះថាជាថេរៈ ដោយហេតុនោះមិនទាន់បានទេ វ័យរបស់បុគ្គលនោះចាស់ស្រុលហើយ ហៅថាចាស់ជាមោឃៈ ។ លុះត្រាតែ សច្ចៈផង ធម៌ផង ការមិនបៀតបៀនផង ការសង្រួមផង ការទូន្មានខ្លួនផង មានក្នុងបុគ្គលណា បុគ្គលនោះឯងជាអ្នកមានមន្ទិលខ្ជាក់ចោលហើយ ជាអ្នកមានប្រាជ្ញា ទើបហៅថា ថេរៈ ។ បុគ្គលមានសេចក្តីច្រណែន មានសេចក្តីកំណាញ់ ជាអ្នកអួតអាង ឈ្មោះថាជាមនុស្សល្អ ដោយហេតុត្រឹមតែធ្វើការនិយាយពាក្យ ( ល្អ ) ឬដោយភាពជាអ្នកមានសម្បុរជាទីគាប់ចិត្ត ក៏មិនបានទេ ។ លុះត្រាតែទោសជាតិ មានឫស្យាជាដើមនេះ បុគ្គលណាបានផ្តាច់ផ្តិលផងឡើង ធ្វើឲ្យមានឫសគល់ដាច់ហើយ បុគ្គលនោះជាអ្នកមានទោសខ្ជាក់ចោលហើយ ជាអ្នកមានប្រាជ្ញា ទើបហៅថាជាមនុស្សល្អបាន ។ បុគ្គល មិនបានឈ្មោះថាជាសមណៈ ដោយភាពជាអ្នកមានក្បាលត្រងោលទេ បុគ្គលអ្នកមិនមានសីលនិងធុតង្គវត្ត ពោលតែពាក្យឡេះឡោះ ប្រកបដោយសេចក្តីប្រាថ្នានិងលោភៈ ឈ្មោះថាជាសមណៈដូចម្តេចបាន ។ លុះត្រាតែបុគ្គលណា រម្ងាប់បាបទាំងឡាយទាំងតូចទាំងធំ ដោយប្រការទាំងពួងបាន ទើបហៅថា សមណៈ ព្រោះបាបទាំងឡាយ ដែលបុគ្គលនោះរម្ងាប់បានហើយ ។

ន តេន ភិក្ខុ សោ ហោតិ  យាវតា ភិក្ខតេ បរេ
វិស្សំ ធម្មំ សមាទាយ  ភិក្ខុ ហោតិ ន តាវតា ។
យោធ បុញ្ញញ្ច បាបញ្ច  ពាហេត្វា ព្រហ្មចរិយវា (១)
សង្ខាយ លោកេ ចរតិ  ស វេ ភិក្ខូតិ វុច្ចតិ ។
ន មោនេន មុនិ ហោតិ  មូឡ្ហរូបោ អវិទ្ទសុ
យោ ច តុលំវ បគ្គយ្ហ  វរមាទាយ បណ្ឌិតោ
បាបានិ បរិវជ្ជេតិ  ស មុនិ (២) តេន សោ មុនិ
យោ មុនាតិ ឧភោ លោកេ  មុនិ តេន បវុច្ចតិ ។
ន តេន អរិយោ ហោតិ  យេន បាណានិ ហឹសតិ
អហឹសា សព្វបាណានំ  អរិយោតិ បវុច្ចតិ ។

១ ម. វាហិត្វា ព្រហ្មចរិយវា ។ ២ ឧ. ម. មុនី ។



បុគ្គលណា ដើរសូមផលតាំងទុកយកទៅ ដោយហេតុត្រឹមណា បុគ្គលនោះ មិនបានឈ្មោះថាជាភិក្ខុ ដោយហេតុត្រឹមណោះទេ បុគ្គលសមាទានធម៌ជាពិស ឈ្មោះថាជាភិក្ខុ ដោយហេតុត្រឹមតែការដើរសូមប៉ុណ្ណោះ មិនបានទេ ។ លុះត្រាតែបុគ្គលណា ក្នុងលោកនេះ បន្សាត់បុណ្យនិងបាបចេញហើយ ជាអ្នកមានការប្រព្រឹត្តដ៏ប្រសើរត្រាច់ទៅក្នុងលោកដោយសេចក្ដីចេះដឹង បុគ្គលនោះឯង ទើបហៅថាជាភិក្ខុ ។ បុគ្គលមានសេចក្ដីល្ងង់ ជាខ្លៅ មិនមានការចេះដឹង មិនបានឈ្មោះថាជាមុនី ដោយភាពជាអ្នកស្ងៀមទេ លុះត្រាតែបុគ្គលណា ជាបណ្ឌិតកាន់យកធម៌ដ៏ប្រសើរ វៀរចាកបាបទាំងឡាយ ដូចបុគ្គលកាន់ជញ្ជីងហើយថ្លឹងថ្លា បុគ្គលនោះទើបឈ្មោះថាជាមុនី ដោយភាពជាអ្នកស្ងៀមនោះបាន បុគ្គលណា ដឹងប្រយោជន៍ទាំងពីរ ក្នុងលោក បុគ្គលនោះហៅថា មុនី ដោយហេតុនោះ ។ បុគ្គលបៀតបៀនសត្វទាំងឡាយ ដោយហេតុណា មិនបានឈ្មោះថាជាអរិយៈ ដោយហេតុនោះទេ បុគ្គលដែលគេហៅថា អរិយៈ ព្រោះមិនបៀតបៀនសត្វទាំងពួង ។

ន សីលព្វតមត្តេន ពាហុសច្ចេន វា បន
អថ វា សមាធិលាភេន វិវិត្តសយនេន[១] វា
ផុសាមិ នេក្ខម្មសុខំ អបុថុជ្ជនសេវិតំ
ភិក្ខុ វិស្សាសមាបាទិ អប្បត្តោ អាសវក្ខយំ ។

ធម្មដ្ឋវគ្គោ ឯកូនវីសតិមោ ។

# ធម្មបទគាថាយ វីសតិមោ មគ្គវគ្គោ

(៣០) មគ្គានដ្ឋង្គិកោ សេដ្ឋោ សច្ចានំ ចតុរោ បទា
វិរាគោ សេដ្ឋោ ធម្មានំ ទ្វិបទានញ្ច ចក្ខុមា
ឯសេវ[២] មគ្គោ នត្ថញ្ញោ ទស្សនស្ស វិសុទ្ធិយា ។
ឯតញ្ហិ តុម្ហេ បដិបជ្ជថ មារស្សេតំ បមោហនំ
ឯតញ្ហិ តុម្ហេ បដិបន្នា ទុក្ខស្សន្តំ ករិស្សថ ។
អក្ខាតោ វោ មយា មគ្គោ អញ្ញាយ សល្លសន្ថនំ[៣]
តុម្ហេហិ កិច្ចំ អាតប្បំ អក្ខាតារោ តថាគតា

១ ម. វិវិត្តសេនេន ។ ២ ម. ឯសោវ ។ ៣ ម. សល្លសន្ថនំ ។
ម. សល្លកន្តនំ ។



ម្នាលភិក្ខុ ភិក្ខុមិនទាន់ដល់នូវការអស់អាសវៈទេ កុំទាន់ទុកចិត្ត ដោយគុណត្រឹមតែសីលនិងវត្ត ឬដោយភាពជាអ្នកចេះដឹងច្រើនឡើយ មួយទៀត ដោយការបានសមាធិ ឬដោយការដេកក្នុងទីស្ងាត់ ឬក៏ដោយគុណមានប្រមាណប៉ុណ្ណោះថា អាត្មាអញ ពាល់ត្រូវនេក្ខម្មសុខ ដែលបុថុជ្ជនមិនដែលសេពប្រសព្វ ដូច្នេះឡើយ ។

ចប់ ធម្មដ្ឋវគ្គ ទី ១៩ ។

# ធម្មបទគាថា មគ្គវគ្គ ទី ២០

(៣០) ផ្លូវមានអង្គ ៨ ប្រសើរជាងផ្លូវទាំងឡាយ បទ ៤ គឺអរិយសច្ច ប្រសើរជាងសច្ចៈទាំងឡាយ វិរាគធម៌ប្រសើរជាងធម៌ទាំងឡាយ មួយទៀត ព្រះតថាគតមានចក្ខុ ប្រសើរជាងសត្វទ្វិបាទទាំងឡាយ ផ្លូវនេះឯង ប្រព្រឹត្តទៅដើម្បីសេចក្ដីបរិសុទ្ធិនៃទស្សនៈ ផ្លូវដទៃមិនមានទេ ។ ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរដើរទៅកាន់ផ្លូវនោះ ផ្លូវនោះជាផ្លូវញុំាងមារឲ្យវង្វេង អ្នកទាំងឡាយដើរទៅកាន់ផ្លូវនេះហើយ នឹងធ្វើនូវទីបំផុតទុក្ខបាន ។ ផ្លូវនេះហើយ ដែលតថាគតដឹងជាផ្លូវកំចាត់បង់កូនសរព្រួញដល់អ្នកទាំងឡាយ សេចក្ដីព្យាយាម ញុំាងកិលេសឲ្យក្ដៅសព្វ អ្នកទាំងឡាយគប្បីធ្វើ ព្រះតថាគតទាំងឡាយ គ្រាន់តែជាអ្នកប្រាប់

បដិបន្នា បមោក្ខន្តិ ឈាយិនោ មារពន្ធនា ។

សព្វេ សង្ខារា អនិច្ចាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ[១] ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។
សព្វេ សង្ខារា ទុក្ខាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។
សព្វេ ធម្មា អនត្តាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។

ឧដ្ឋានកាលម្ហិ អនុដ្ឋហានោ
យុវា ពលី អាលសិយំ ឧបេតោ
សំសន្នសង្កប្បមនោ[២] កុសីតោ
បញ្ញាយ មគ្គំ អលសោ ន វិន្ទតិ ។

វាចានុរក្ខី មនសា សុសំវុតោ
កាយេន ច អកុសលំ ន កយិរា
ឯតេ តយោ កម្មបថេ វិសោធយេ
អារាធយេ មគ្គមិសិប្បវេទិតំ ។

---

១ ឧ. និព្វិន្ទតី ។ ២ ម. សំសប្បសង្កប្បមនោ ។



ផងទាំងឡាយមានការពិនិត្យ ដើបានដើរទៅហើយ នឹងរួចចាកចំណង របស់មារបាន ។

កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួងមិនទៀង ដូច្នេះ កាលណោះ រមែងនឿយណាយ ក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធិ ។

កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួង នាំមកនូវសេចក្តីទុក្ខដូច្នេះ កាលណោះ រមែងនឿយណាយ ក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធិ ។ កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួង មិនមែនជារបស់ខ្លួនដូច្នេះ កាលណោះ រមែងនឿយណាយ ក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធិ ។

បុគ្គលនៅកំលោះមានកំឡាំង តាស់តែប្រកបដោយសេចក្តីខ្ជិលច្រអូស មិនប្រឹងប្រែង ក្នុងកាលដែលគួរប្រឹងប្រែង មានសេចក្តីត្រិះរិះក្នុងចិត្តលិចចុះ គឺអកុសលវិតក្កៈ ជាមនុស្សខ្ជិល បុគ្គលខ្ជិល ( នោះ ) រមែងមិនបានផ្លូវបញ្ញាឡើយ ។

បុគ្គលគប្បីជាអ្នករក្សាវាចា សង្រួមល្អ ដោយចិត្ត ទាំងមិនគប្បីធ្វើអកុសលដោយកាយ បុគ្គលគប្បីជំរះកម្មបថទាំង ៣ នេះ នឹងគប្បីត្រេកអរចំពោះមគ្គ ដែលលោកអ្នកស្វែងរកគុណបំពេញ សំដែងទុកហើយ ។

យោគា វេ ជាយតី ភូរិ[១] អយោគា ភូរិសង្ខយោ
ឯតំ ទ្វេធាបថំ ញត្វា ភវាយ វិភវាយ ច
តថត្តានំ និវេសេយ្យ យថា ភូរិ បវឌ្ឍតិ ។
វនំ ឆិន្ទថ មា រុក្ខំ វនតោ ជាយតី[២] ភយំ
ឆេត្វា វនំ វនថញ្ច និព្វនា ហោថ ភិក្ខវោ ។

យាវញ្ហិ វនថោ ន ឆិជ្ជតិ
អណុមត្តោបិ នរស្ស នារិសុ
បដិពទ្ធមនោ វ តាវ សោ
វច្ឆោ ខីរបកោវ[៣] មាតរិ ។
ឧច្ឆិន្ទ សិនេហមត្តនោ
កុមុទំ សារទិកំវ បាណិនា
សន្តិមគ្គមេវ ព្រូហយ
និព្វានំ សុគតេន ទេសិតំ ។

ឥធ វស្សំ វសិស្សាមិ ឥធ ហេមន្តគិម្ហិសុ
ឥតិ ពាលោ វិចិន្តេតិ អន្តរាយំ ន ពុជ្ឈតិ ។

---

១ ម. ភូរី ។ ២ ម. ជាយតេ ។ ៣ ម. ខីរបានោ ។ ម. ទុម្មេធោ ។



ប្រាជ្ញា រមែងកើតអំពីការប្រកប សេចក្តីវិនាសប្រាជ្ញា រមែងកើតអំពីការមិនប្រកប អ្នកមានប្រាជ្ញា ដឹងការប្រកប និងការមិនប្រកប ទាំងពីរនេះ ជាគន្លងនៃសេចក្តីចំរើននឹងសេចក្តីវិនាសហើយ ប្រាជ្ញាចំរើនឡើងដោយប្រការណា គួរដំកល់ខ្លួនទុក ដោយប្រការនោះ ។

អ្នកទាំងឡាយ ចូរកាត់កិលេសដូចជាព្រៃចេញ ចូរកុំកាត់ដើមឈើ(ព្រោះ) ភ័យកើតអំពីកិលេសដូចជាព្រៃ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរកាត់កិលេសដូចជាព្រៃផង កិលេសដូចជាដើមឈើដុះក្នុងព្រៃផង ហើយ ចូរជាអ្នកគ្មានកិលេស ដូចជាព្រៃឡើយ ព្រោះថាកិលេសដូចជាដើមឈើដុះក្នុងព្រៃរបស់នរជន សូម្បីមានប្រមាណតិចតួចដោយ បើកាត់មិនដាច់ក្នុងពួកនារីណា នរជននោះឯង រមែងមានចិត្តជាប់ជំពាក់ក្នុងពួកនារី ដូចកូនគោនៅកំពុងបៅដោះ ដែលមានចិត្តជាប់នៅនឹងមេ ដូច្នោះ ។

អ្នកចូរផ្តាច់សេចក្តីស្រឡាញ់របស់ខ្លួនចេញ ដូចបុគ្គល ដកផ្កាកុមុទ ដែលកើតក្នុងសរទកាលដោយដៃ អ្នកចូរបណ្តុះផ្លូវសន្តិភាពតែម្យ៉ាង ព្រះនិព្វាន ព្រះសុគតសំដែងទុកហើយ ។

អញនឹងនៅក្នុងទីនេះអស់វស្សារដូវ អញនឹងនៅក្នុងទីនេះក្នុងហេមន្តរដូវ និងគិម្ហរដូវ ជនពាល រមែងគិតខ្វល់ខ្វាយដូច្នេះ តែមិនដឹងច្បាស់សេចក្តីអន្តរាយឡើយ ។

តំ បុត្តបសុសម្មត្តំ ព្យាសត្តមនសំ(១) នរំ
សុត្តំ គាមំ មហោឃោវ មច្ចុ អាទាយ គច្ឆតិ ។
ន សន្តិ បុត្តា តាណាយ ន បិតា នបិ ពន្ធវា
អន្តកេនាធិបន្នស្ស នត្ថិ ញាតីសុ តាណតា
ឯតមត្ថវសំ ញត្វា បណ្ឌិតោ សីលសំវុតោ
និព្វានគមនំ មគ្គំ ខិប្បមេវ វិសោធយេ ។

មគ្គវគ្គោ វីសតិមោ ។

## ធម្មបទគាថាយ ឯកវីសតិមោ បកិណ្ណកវគ្គោ

(៣១) មត្តាសុខបរិច្ចាគា បស្សេ ចេ វិបុលំ សុខំ
ចជេ មត្តាសុខំ ធីរោ សម្បស្សំ វិបុលំ សុខំ ។
បរទុក្ខូបធានេន យោ អត្តនោ សុខមិច្ឆតិ
វេរសំសគ្គសំសដ្ឋោ វេរា សោ ន បរិមុច្ចតិ ។

១ . ម. ព្យាសត្តមានសំ ។



មច្ចុ គឺសេចក្តីស្លាប់ តែងនាំយកនរជន អ្នកស្រវឹងស្រវ៉ាក្នុងកូននិងសត្វចិញ្ចឹម មានចិត្តជាប់ជំពាក់ ក្នុងកាមគុណផ្សេងៗនោះ ដូចជំនន់ទឹកធំ នាំយកអ្នកស្រុកកំពុងដេកលក់ ។

កាលបុគ្គល ត្រូវមច្ចុគ្របសង្កត់ហើយ កូនទាំងឡាយ មិនមាន ដើម្បីជាទីពឹង បិតា ក៏មិនមាន ពួកផៅពង្ស ក៏មិនមាន ដើម្បីជាទីពឹងឡើយ សេចក្តីទីពឹងក្នុងញាតិទាំងឡាយ ក៏មិនមាន បណ្ឌិតដឹងអំណាចប្រយោជន៍នេះហើយ គួរជាអ្នកសង្រួមក្នុងសីល គួរប្រញាប់ប្រញាល់ជម្រះផ្លូវ ជាទីទៅកាន់ព្រះនិព្វានឲ្យបាន ។

ចប់ មគ្គវគ្គ ទី ២០ ។

## ធម្មបទគាថា បកិណ្ណកវគ្គ ទី ២១

(៣១) បើឃើញសេចក្តីសុខដ៏ធំទូលាយ ព្រោះលះបង់សុខល្មមប្រមាណ អ្នកមានប្រាជ្ញា កាលឃើញសុខដ៏ទូលាយ គប្បីលះសុខល្មមប្រមាណចេញ ។

ជនប្រាថ្នាសេចក្តីសុខ ដើម្បីខ្លួន ដោយបង្កទុក្ខឲ្យអ្នកដទៃ ជននោះឈ្មោះថា ច្រឡូកច្រឡំហើយ ដោយការជាប់ជំពាក់ គឺពៀរ រមែងមិនរួចចាកពៀរទេ ។

យញ្ហិ កិច្ចំ អបវិទ្ធំ អកិច្ចំ បន កយិរតិ(១)

ឧន្នឡានំ បមត្តានំ តេសំ វឌ្ឍន្តិ អាសវា ។

យេសញ្ច សុសមារទ្ធា និច្ចំ កាយគតា សតិ

អកិច្ចន្តេ ន សេវន្តិ កិច្ចេ សាតច្ចការិនោ

សតានំ សម្បជានានំ អត្ថំ គច្ឆន្តិ អាសវា ។

មាតរំ បិតរំ ហន្ត្វា រាជានោ ទ្វេ ច ខត្តិយេ

រដ្ឋំ សានុចរំ ហន្ត្វា អនីឃោ យាតិ ព្រាហ្មណោ ។

មាតរំ បិតរំ ហន្ត្វា រាជានោ ទ្វេ ច សោត្ថិយេ

វេយ្យគ្ឃបញ្ចមំ ហន្ត្វា អនីឃោ យាតិ ព្រាហ្មណោ ។

១ ម. ករីយតិ ។



របស់ណាដែលខ្លួនគួរធ្វើ របស់នោះពួកភិក្ខុណា លះបង់ចោលហើយ តែរបស់ដែលមិនគួរធ្វើ គេឡប់ជាធ្វើវិញ អាសវៈទាំងឡាយ តែងចំរើនឡើងដល់ពួកភិក្ខុនោះ ជាអ្នកមានសេចក្តីប្រមាទ មានមានះដូចជាដើមបបុសលើកឡើងហើយ ។

លុះតែសតិប្រព្រឹត្តទៅ ក្នុងកាយជានិច្ច ដែលពួកភិក្ខុណាបានប្រារព្ធប្រពៃហើយ ភិក្ខុទាំងនោះ រមែងជាអ្នកធ្វើការដែលគួរធ្វើរឿយ ៗ មិនធ្វើការដែលមិនគួរធ្វើ អាសវៈទាំងឡាយ របស់ពួកភិក្ខុនោះ ដែលជាអ្នកមានសតិ មានសម្បជញ្ញៈ រមែងដល់នូវការអស់ទៅ ។

បុគ្គលសម្លាប់តណ្ហាដូចមាតាផង សម្លាប់អស្មិមានះដូចបិតាផង សម្លាប់សស្សតទិដ្ឋិនិងឧច្ឆេទទិដ្ឋិ ដូចជាស្តេចជាក្សត្រិយ៍ព្រះអង្គផង សម្លាប់អាយតនៈដូចជាដែន ប្រព្រឹត្តទៅមួយអន្លើ ដោយបុរសអ្នកដើរតាមគឺស្បៀងផង រមែងបានទៅជាខីណាស្រពព្រាហ្មណ៍ ជាអ្នកមិនមានទុក្ខ ។

បុគ្គលសម្លាប់តណ្ហាដូចមាតាផង សម្លាប់អស្មិមានះដូចបិតាផង សម្លាប់សស្សតទិដ្ឋិនិងឧច្ឆេទទិដ្ឋិ ដូចជាស្តេច ជាព្រាហ្មណ៍ទាំងពីរផង សម្លាប់វិចិកិច្ឆា ដូចជាខ្លាធំជាគំរប់ ៥ ផង ( ដែលនៅស្កាត់ផ្លូវ ) បានហើយ រមែងបានទៅជាខីណាស្រពព្រាហ្មណ៍ ជាអ្នកមិនមានទុក្ខ ។

ធម្មបទគាថាយ ឯកវីសតិមោ បកិណ្ណកវគ្គោ

សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ ពុទ្ធគតា សតិ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ ធម្មគតា សតិ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ សង្ឃគតា សតិ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ កាយគតា សតិ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច អហឹសាយ រតោ មនោ ។
សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច ភាវនាយ រតោ មនោ ។



ធម្មបទគាថា បកិណ្ណកវគ្គ ទី ២១

សតិរបស់ជនពួកណា ដែលឋិតនៅ ក្នុងព្រះពុទ្ធគុណ អស់កាលជានិច្ច ទាំងថ្ងៃទាំងយប់ ជនពួកនោះឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់ឭក ៗ ដោយប្រពៃ សព្វកាល ។

សតិរបស់ជនពួកណា ដែលឋិតនៅ ក្នុងព្រះធម្មគុណ អស់កាលជានិច្ច ទាំងថ្ងៃ ទាំងយប់ ជនពួកនោះឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់ឭក ៗ ដោយប្រពៃ សព្វកាល ។

សតិរបស់ជនពួកណា ដែលឋិតនៅ ក្នុងព្រះសង្ឃគុណ អស់កាលជានិច្ច ទាំងថ្ងៃ ទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់ឭក ៗ ដោយប្រពៃ សព្វកាល ។

សតិរបស់ជនពួកណា ដែលឋិតនៅក្នុងកាយ អស់កាលជានិច្ច ទាំងថ្ងៃ ទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់ឭក ៗ ដោយប្រពៃ សព្វកាល ។

ចិត្តរបស់ជនពួកណា ត្រេកអរហើយ ក្នុងការមិនបៀតបៀនគេ ទាំងថ្ងៃ ទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់ឭក ៗ ដោយប្រពៃ សព្វកាល ។

ចិត្តរបស់ជនពួកណា ត្រេកអរហើយ ក្នុងភាវនា ទាំងថ្ងៃទាំងយប់ ជនពួកនោះឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់ឭក ៗ ដោយប្រពៃ សព្វកាល ។

ទុប្បព្វជ្ជំ ទុរភិរមំ   ទុរាវាសា ឃរា ទុខា
ទុក្ខោសមានសំវាសោ   ទុក្ខានុបតិតទ្ធគូ
តស្មា ន ចទ្ធគូ សិយា   ន ច ទុក្ខានុបតិតោ សិយា ។
សទ្ធោ សីលេន សម្បន្នោ   យសោភោគសមប្បិតោ
យំ យំ បទេសំ ភជតិ   តត្ថ តត្ថេវ បូជិតោ ។
ទូរេ សន្តោ បកាសេន្តិ   ហិមវន្តោវ បព្វតោ
អសន្តេត្ថ ន ទិស្សន្តិ   រត្តឹ ខិត្តា យថា សរា ។
ឯកាសនំ ឯកសេយ្យំ   ឯកោ ចរមតន្ទិតោ
ឯកោ ទមយមត្តានំ   វនន្តេ រមិតោ សិយា ។

បកិណ្ណកវគ្គោ ឯកវីសតិមោ ។



ការបួសបានដោយក្រ ការត្រេកអរក្រៃពេកបានដោយក្រ ផ្ទះទាំងឡាយមានការនៅគ្រប់គ្រងដោយលំបាក ជាការក្រ ការនៅរួមដោយជនស្មើគ្នា(១) (ដែលមិនមានសេចក្ដីគាប់ចិត្ត) ជាការក្រ ជនអ្នកដើរផ្លូវឆ្ងាយគឺវដ្ដៈ តែងត្រូវសេចក្ដីទុក្ខធ្លាក់ដាប់តាម ព្រោះហេតុនោះ បុគ្គលមិនគប្បីជាអ្នកដើរផ្លូវឆ្ងាយផង មិនគប្បីជាអ្នកត្រូវសេចក្ដីទុក្ខធ្លាក់ដាប់តាមផង ។

បុគ្គលអ្នកមានសទ្ធា បរិបូណ៌ដោយសីល ស្កប់ស្កល់ដោយយសនឹងភោគសម្បត្តិ គប់ទៅប្រទេសណា ៗ រមែងបានបូជា ក្នុងប្រទេសនោះ ៗ ។

ពួកសប្បុរស រមែងប្រាកដ ក្នុងទីឆ្ងាយ ដូចភ្នំហិមពាន្តដូច្នោះ ពួកអសប្បុរស (ទុកជាបិតនៅ) ក្នុងទីជិត ក៏រមែងមិនប្រាកដ ដូចព្រួញដែលបុគ្គលបាញ់ ក្នុងវេលាយប់ ។

បុគ្គល អ្នកអង្គុយតែម្នាក់ឯង ដេកម្នាក់ឯង ជាអ្នកត្រាច់ទៅម្នាក់ឯង មិនជាអ្នកខ្ជិលច្រអូស ជាអ្នកទូន្មានម្នាក់ឯងនូវខ្លួន គួរជាអ្នកត្រេកអរក្នុងព្រៃស្ងាត់ ។

ចប់ បកិណ្ណកវគ្គ ទី ២១ ។

---

* ពាក្យខាងលើ ប្រែថា ការនៅរួមដោយជនមិនស្មើគ្នា ព្រោះបទថា ទុក្ខោសមានសំវាសោ អាចកាត់បទជា ទុក្ខោ + អសមានសំវាសោ ដូច្នេះបាន ។ អដ្ឋកថា ក៏មានពន្យល់តែពីសេចក្ដី ដែលនៅរួមគ្នាទាំង ២ យ៉ាង គឺការមិនរួមនឹងមនុស្សស្មើគ្នា ក៏ជាការក្រ នៅរួមនឹងមនុស្សមិនស្មើគ្នា ក៏ជាការក្រ ។

## ធម្មបទគាថាយ ទ្វាវីសតិមោ និរយវគ្គោ

[៣២] អភូតវាទី និរយំ ឧបេតិ

យោ វាបិ[១] កត្វា ន ករោមិ[២] ចាហ

ឧភោបិ តេ បេច្ច សមា ភវន្តិ

និហីនកម្មា មនុជា បរត្ថ ។

កាសាវកណ្ឋា ពហវោ   បាបធម្មា អសញ្ញតា

បាបា បាបេហិ កម្មេហិ   និរយន្តេ ឧបបជ្ជរេ ។

សេយ្យោ អយោគុឡោ ភុត្តោ   តត្តោ អគ្គិសិខូបមោ

យញ្ចេ ភុញ្ជេយ្យ ទុស្សីលោ   រដ្ឋបិណ្ឌំ អសញ្ញតោ ។

ចត្តារិ ឋានានិ នរោ បមត្តោ

អាបជ្ជតិ បរទារូបសេវី

អបុញ្ញលាភំ ន និកាមសេយ្យំ

និន្ទំ តតិយំ និរយំ ចតុត្ថំ ។

១ ឱ. វាបិ ។ ២ ម. ឱ. ករោមិ ។ ករោមិ ចាហន្តិ បាឋោ ។





## ធម្មបទគាថា និរយវគ្គ ទី ២២

(៣៦) អ្នកពោលពាក្យមិនពិត ឬបុគ្គលណាធ្វើ (អំពើអាក្រក់) ហើយ និយាយថា អញមិនធ្វើទេ (បុគ្គលនោះ) រមែងទៅកាន់នរក ជនទាំងពីរនាក់ ដែលមានអំពើថោកទាប (ស្មើគ្នា) នោះ លុះលះលោកនេះទៅហើយ រមែងជាអ្នកស្មើគ្នា (ដោយគតិ) ក្នុងលោកខាងមុខទៀត ។

ក្នុងជនច្រើននាក់ ដែលមានកព័ទ្ធក្ដុំ ដោយសំពត់កាសាវៈ តែ (ប្រព្រឹត្ត) អធម៌លាមក មិនបានសង្រួម ក្នុងជនលាមកទាំងនោះ រមែងទៅកើតក្នុងនរក ដោយសារកម្មទាំងឡាយ ដ៏លាមកនោះ ។

បព្វជិតទ្រុស្តសីល ស៊ូលេបគ្រាប់ដែក ដែលកំពុងក្តៅ មានពណ៌ដូចអណ្តាតភ្លើង ប្រសើរជាង បព្វជិតទ្រុស្តសីល មិនសង្រួម បរិភោគដុំបាយអ្នកដែន ពិតប្រសើរ ដូចម្ដេចបាន ។

នរជន អ្នកប្រមាទហើយ សេពប្រពន្ធរបស់បុគ្គលដទៃ រមែងដល់នូវហេតុនៃសេចក្តីទុក្ខ ៤ យ៉ាង គឺ ទី ១ បានរបស់មិនមែនជាបុណ្យ ទី ២ ដេកមិនបានតាមប្រាថ្នា ទី ៣ ការតិះដៀល ទី ៤ ការធ្លាក់នរក ។

អបុញ្ញលាភោ ច គតី ច បាបិកា
ភីតស្ស ភីតាយ រតី ច ថោកិកា
រាជា ច ទណ្ឌំ គរុកំ បណេតិ
តស្មា នរោ បរទារំ ន សេវេ ។

កុសោ យថា ទុគ្គហិតោ ហត្ថមេវានុកន្តតិ
សាមញ្ញំ ទុប្បរាមដ្ឋំ និរយាយុបកឌ្ឍតិ ។

យំ កិញ្ចិ សិថិលំ កម្មំ សង្កិលិដ្ឋញ្ច យំ វតំ
សង្កស្សរំ ព្រហ្មចរិយំ ន តំ ហោតិ មហប្ផលំ ។

កយិរា ចេ កយិរាថេនំ ទឡ្ហមេនំ បរក្កមេ
សិថិលោ ហិ បរិព្វាជោ(*) ភិយ្យោ អាកិរតេ រជំ ។

អកតំ ទុក្កតំ សេយ្យោ បច្ឆា តបតិ ទុក្កតំ
កតញ្ច សុកតំ សេយ្យោ យំ កត្វា នានុតប្បតិ ។

---

* ម. បរិព្វជោ ។



(ហេតុនៃសេចក្តីទុក្ខ ៤ យ៉ាងនេះផ្សេងទៀត) គឺ បានរបស់មិនជាបុណ្យ ១ មានគតិអាក្រក់ ១ តម្រេករបស់បុរសអ្នកខ្លាច ជាមួយនឹងស្ត្រីដែលខ្លាចវិញ មានប្រមាណតិច ១ ព្រះរាជានឹងដាក់អាជ្ញាយ៉ាងធ្ងន់ ១ ព្រោះហេតុនោះ បុរសមិនគួរសេពប្រពន្ធ របស់បុគ្គលដទៃឡើយ ។

ស្បូវភ្លាំង ដែលបុគ្គលកាន់មិនចំណាប់ រមែងលះដៃ យ៉ាងណាមិញ ភាពជាសមណៈដែលបព្វជិតកាន់មិនស៊ប់ស្ងួនហើយ រមែងទាញបព្វជិតនោះទៅនរក យ៉ាងនោះឯង ។

កម្មណាមួយ ដែលធូរថយក្តី វត្តណាមួយដែលសៅហ្មងក្តី ព្រហ្មចរិយៈ ដែលបុគ្គលរឭកដោយសេចក្តីរង្កៀសក្តី កម្មទាំង ៣ នោះ ជារបស់មិនមានផលច្រើនឡើយ ។

បើបុគ្គលធ្វើ គប្បីធ្វើកម្មនោះឲ្យមែនទែន គប្បីប្រឹងប្រែងធ្វើកម្មនោះឲ្យមាំមួន ព្រោះថា សមណធម៌ជាគ្រឿងវៀរចាកកិលេសធូរថយ រមែងរោយធូលីគឺរាគាទិក្កិលេសដល់បុគ្គល ដោយក្រៃលែង ។

អំពើអាក្រក់ ដែលបុគ្គលមិនធ្វើ ប្រសើរជាង ( ព្រោះថា ) អំពើអាក្រក់ រមែងធ្វើឲ្យក្តៅក្រហាយ ក្នុងកាលខាងក្រោយ បុគ្គលធ្វើអំពើណាហើយ រមែងមិនក្តៅក្រហាយក្រោយ អំពើនោះ ជាអំពើល្អ បើបុគ្គលធ្វើហើយ ឈ្មោះថា ល្អប្រសើរ ។

នគរំ យថា បច្ចន្តំ គុត្តំ សន្តរពាហិរំ

ឯវំ គោបេថ អត្តានំ ខណោ វោ មា ឧបច្ចគា

ខណាតីតា ហិ សោចន្តិ និរយម្ហិ សមប្បិតា ។

អលជ្ជិតាយេ លជ្ជន្តិ លជ្ជិតាយេ ន លជ្ជរេ

មិច្ឆាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ ទុគ្គតឹ ។

អភយេ[១] ភយទស្សិនោ ភយេ ច អភយទស្សិនោ[២]

មិច្ឆាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ ទុគ្គតឹ ។

អវជ្ជេ វជ្ជមតិនោ វជ្ជេ ច អវជ្ជទស្សិនោ

មិច្ឆាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ ទុគ្គតឹ ។

១ ម. [illegible] ។ ២ ម. [illegible] ។



នគរនៅទីបំផុតដែន ដែលគេគ្រប់គ្រងហើយ ទាំងខាងក្នុង ទាំងខាងក្រៅយ៉ាងណា អ្នកទាំងឡាយ គួររក្សាខ្លួនយ៉ាងនោះ កុំឲ្យខណៈ[១] កន្លងអ្នកទាំងឡាយបានឡើយ ព្រោះថាជនទាំងឡាយ ដែលឲ្យខណៈកន្លងហើយ រមែងសោកស្តាយ ក្នុងនរក ម៉ាផេផាស ។

សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងខ្មាស ក្នុងហេតុដែលគេមិនគួរខ្មាស រមែងមិនខ្មាស ក្នុងហេតុដែលគេគួរខ្មាស សត្វទាំងនោះ រមែងទៅកាន់ទុគ្គតិ ។

សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងយល់ឃើញ ក្នុងហេតុដែលគេមិនគួរខ្លាច ថាជាហេតុដែលគេគួរខ្លាចផង យល់ឃើញ ក្នុងហេតុដែលគេគួរខ្លាច ថាជាហេតុដែលគេមិនគួរខ្លាចផង សត្វទាំងនោះ រមែងទៅកាន់ទុគ្គតិ ។

សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ រមែងយល់ឃើញ ក្នុងហេតុដែលឥតទោស ថាជាហេតុមានទោសផង យល់ឃើញ ក្នុងហេតុដែលមានទោស ថាជាហេតុឥតទោសផង សត្វទាំងនោះរមែងទៅកាន់ទុគ្គតិ ។

១ ខណៈ-សព្ទនេះ ប្រែថា " វេលា " សំដៅយកខណៈ ៤ គឺ ពុទ្ធុប្បាទក្ខណោ កាលដែលព្រះពុទ្ធត្រាស់ ១ មជ្ឈិមប្បទេសេ ឧប្បត្តិក្ខណោ កាលដែលកើតក្នុងមជ្ឈិមប្បទេស ១ សម្មាទិដ្ឋិយា បដិលទ្ធក្ខណោ កាលដែលបានសម្មាទិដ្ឋិ ១ ឆន្នំ អាយតនានំ អវេកល្លក្ខណោ កាលដែលអាយតនៈមិនខ្វះ ១ ។ អដ្ឋកថា ។

វជ្ជញ្ច វជ្ជតោ ញត្វា អវជ្ជញ្ច អវជ្ជតោ
សម្មាទិដ្ឋិសមាទានា សត្តា គច្ឆន្តិ សុគ្គតឹ ។

និរយវគ្គោ ទ្វាវីសតិមោ ។

## ធម្មបទគាថាយ តេវីសតិមោ នាគវគ្គោ

(៣៣) អហំ នាគោវ សង្គាមេ ចាបាតោ បតិតំ សរំ
អតិវាក្យំ តិតិក្ខិស្សំ ទុស្សីលោ ហិ ពហុជ្ជនោ ។
ទន្តំ នយន្តិ សមិតឹ ទន្តំ រាជាភិរូហតិ
ទន្តោ សេដ្ឋោ មនុស្សេសុ យោតិវាក្យំ តិតិក្ខតិ ។
វរមស្សតរា ទន្តា អាជានីយា ច[១] សិន្ធវា
កុញ្ជរា ច មហានាគា អត្តទន្តោ តតោ វរំ ។

[១] ម. ឆ. ច ។



សត្វទាំងឡាយ ដែលប្រកាន់សម្មាទិដ្ឋិ ដឹងរបស់មានទោស ថាជារបស់មានទោសផង ដឹងរបស់មិនមានទោស ថាជារបស់មិនមានទោសផង សត្វទាំងនោះ តែងទៅកាន់សុគតិ ។

ចប់ និរយវគ្គ ទី ២២ ។

## ធម្មបទគាថា នាគវគ្គ ទី ២៣

(៣៣) តថាគតនឹងអត់ទ្រាំពាក្យល្មើស ដូចដំរីកាលអត់ទ្រាំចំពោះព្រួញ ដែលធ្លាក់ចេញអំពីធ្នូ ក្នុងសង្គ្រាមដូច្នោះ ព្រោះថា ជនទ្រុស្តសីលមានច្រើនណាស់ ។ ពួកជនតែងនាំពាហនៈ ដែលទូន្មានហើយទៅកាន់ទីប្រជុំ ព្រះរាជាតែងស្ដេចឡើងកាន់ពាហនៈ ដែលទូន្មានហើយ បណ្ដាមនុស្សទាំងឡាយ មនុស្សណា អត់សង្កត់នូវពាក្យល្មើសបាន មនុស្សនោះ ជាអ្នកមានខ្លួនទូន្មានហើយ ឈ្មោះថា បុគ្គលប្រសើរបំផុត ។ ពួកសេះអស្សតរក្តី សេះអាជានេយ្យក្តី សេះសិន្ធពក្តី ដំរីកុញ្ជរធំប្រសើរក្តី ដែលបុគ្គលប្រៀនប្រដៅទូន្មានហើយ រមែងជាសត្វប្រសើរ បុគ្គលដែលមានខ្លួនទូន្មានបានហើយ ប្រសើរជាងសត្វទាំងអស់នោះ ។

ន ហិ ឯតេហិ យានេហិ គច្ឆេយ្យ អគតំ ទិសំ

យថាត្តនា[*] សុទន្តេន ទន្តោ ទន្តេន គច្ឆតិ ។

ធនបាលកោ នាម កុញ្ជរោ

កដុកប្បភេទនោ ទុន្និវារយោ

ពទ្ធោ[២] កពឡំ ន ភុញ្ជតិ

សុមរតិ នាគវនស្ស កុញ្ជរោ ។

មិទ្ធី យទា ហោតិ មហគ្ឃសោ ច

និទ្ទាយិតា សម្បរិវត្តសាយី

មហាវរាហោវ និវាបបុដ្ឋោ

បុនប្បុនំ គព្ភមុបេតិ មន្ទោ ។

ឥទំ បុរេ ចិត្តមចារិ ចារិកំ

យេនិច្ឆកំ យត្ថកាមំ យថាសុខំ

តទជ្ជហំ និគ្គហេស្សាមិ យោនិសោ

ហត្ថិប្បភិន្នំ វិយ អង្កុសគ្គហោ ។

---

* យថត្តនាតិបិ បាឋោ ។ ២ ម. ពទ្ធោ ។



បុគ្គលខ្លួនឯងទូន្មានបានហើយ ទូន្មានខ្លួនល្អហើយ ឈ្មោះថាទូន្មានហើយ រមែងទៅកាន់ទិសដែលខ្លួនមិនធ្លាប់ទៅគឺព្រះនិព្វានបាន ពុំមែនដូចបុគ្គលទៅកាន់ទិស ដែលខ្លួនមិនធ្លាប់ទៅ ដោយសារយានទាំងឡាយនោះឡើយ ។

ដំរីឈ្មោះធនបាល ជាសត្វចុះប្រេង ក្លៀវក្លា នាយហត្ថាចារ្យឃាត់បានដោយលំបាក បើនាយហត្ថាចារ្យ ចងភ្ជាប់ មិនស៊ីស្មៅទេ ព្រោះរឭកដល់ព្រៃខ្ទឹង ដែលដំរីនោះធ្លាប់នៅ ។

កាលណា បុគ្គលអ្នកមានសេចក្តីងោកងុយផង អ្នកបរិភោគភោជនមានប្រមាណច្រើនផង អ្នកដេកលក់ផង អ្នកដេកបម្រះខ្លួនវៀលផង ដូចជ្រូកស្រុក ដែលបុគ្គលចិញ្ចឹម ដោយស្លូកកាក កាលនោះបុគ្គលនោះ ជាមនុស្សខ្លៅ រមែងចូលទៅកាន់គភ៌រឿយ ៗ ។

ក្នុងកាលមុនអំពីកាលនេះ ចិត្តនេះបានត្រាច់ទៅកាន់ចារិក តាមការដែលខ្លួនប្រាថ្នា តាមអារម្មណ៍ដែលខ្លួនប្រាថ្នា តាមសេចក្តីសប្បាយក្នុងចិត្ត ថ្ងៃនេះ អាត្មានឹងសង្កត់សង្កិនចិត្តនោះ ដោយឧបាយ ដូចហ្មដំរីកាន់កង្វេរសង្កត់សង្កិនដំរីចុះប្រេង ដូច្នោះដែរ ។

អប្បមាទរតា ហោថ សចិត្តមនុរក្ខថ
ទុគ្គា ឧទ្ធរថត្តានំ[១] បង្កេ សន្នោវ កុញ្ជរោ ។

សចេ លភេថ និបកំ សហាយំ
សទ្ធឹ ចរំ សាធុវិហារិ ធីរំ
អភិភុយ្យ សព្វានិ បរិស្សយានិ
ចរេយ្យ តេនត្តមនោ សតីមា ។

នោ ចេ លភេថ និបកំ សហាយំ
សទ្ធឹ ចរំ សាធុវិហារិំ ធីរំ
រាជាវ រដ្ឋំ វិជិតំ បហាយ
ឯកោ ចរេ មាតង្គរញ្ញេវ នាគោ ។

ឯកស្ស ចរិតំ សេយ្យោ នត្ថិ ពាលេ សហាយតា
ឯកោ ចរេ ន ច បាបានិ កយិរា
អប្បោស្សុក្កោ មាតង្គរញ្ញេវ នាគោ ។

១ ម. ឧទ្ធរេត្តានំ ។



អ្នកទាំងឡាយ ចូរត្រេកអរ ក្នុងសេចក្តីមិនប្រមាទ ចូររក្សាចិត្តរបស់ខ្លួន ចូរស្រង់ខ្លួនចេញចាកភក់គឺកិលេស ដែលធ្វើបានដោយកម្រ ដូចដំរីដែលជាប់នៅក្នុងភក់ ស្រង់ខ្លួនឡើងបាន ។

បើបុគ្គលបានសំឡាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានប្រាជ្ញាចាស់ មានគុណធម៌ជាគ្រឿងនៅញ៉ាំងប្រយោជន៍ឲ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយ គួរជាអ្នកមានចិត្តត្រេកអរ មានស្មារតី គ្របសង្កត់សេចក្តីអន្តរាយទាំងពួង ហើយត្រាច់ទៅជាមួយនឹងសំឡាញ់នោះចុះ ។ បើស្វែងរកមិនបានសំឡាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានប្រាជ្ញាចាស់ មានគុណធម៌ជាគ្រឿងញ៉ាំងប្រយោជន៍ឲ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយទេ គួរត្រាច់ទៅតែឯកឯងវិញ ដូចព្រះរាជាលះបង់រដ្ឋ ដែលទ្រង់ឈ្នះហើយស្តេចទៅតែឯកឯង ក៏នោះសោត ដូចដំរីឈ្មោះមាតង្គៈ ដែលលះហ្វូងត្រាច់ទៅតែឯកឯងក្នុងព្រៃ ដូច្នោះដែរ ។

ការត្រាច់ទៅ របស់បុគ្គលឯកឯង ជាគុណជាតប្រសើរបំផុត (ព្រោះថា) សហាយតាគុណ រមែងមិនមាន ក្នុងជនពាលឡើយ បុគ្គលនោះគប្បីជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ត្រាច់ទៅតែម្នាក់ឯងផង មិនគប្បីធ្វើនូវអំពើបាបទាំងឡាយផង ដូចដំរីឈ្មោះមាតង្គៈ ជាសត្វមិនមានសេចក្តីខ្វល់ខ្វាយ លះបង់ហ្វូង ត្រាច់ទៅតែឯកឯងក្នុងព្រៃ ដូច្នោះដែរ ។

អត្ថម្ហិ ជាតម្ហិ សុខា សហាយា
តុដ្ឋី សុខា យា ឥតរីតរេន
បុញ្ញំ សុខំ ជីវិតសង្ខយម្ហិ
សព្វស្ស ទុក្ខស្ស សុខំ បហានំ ។

សុខា មត្តេយ្យតា(១) លោកេ អថោ បេត្តេយ្យតា សុខា
សុខា សាមញ្ញតា លោកេ អថោ ព្រហ្មញ្ញតា សុខា
សុខំ យាវ ជរា សីលំ សុខា សទ្ធា បតិដ្ឋិតា
សុខោ បញ្ញាបដិលាភោ បាបានំ អករណំ សុខំ ។

នាគវគ្គោ តេវីសតិមោ ។

## ធម្មបទគាថាយ ចតុវីសតិមោ តណ្ហាវគ្គោ

(៣៤) មនុជស្ស បមត្តចារិនោ
តណ្ហា វឌ្ឍតិ មាលុវា វិយ
សោ បលវតី(២) ហុរាហុរំ
ផលមិច្ឆំវ វនស្មិ(៣) វានរោ ។

---

១ ក្នុងចប់ ឃោនូក មេត្តេយ្យតាតិ ទំព្យរម៌ ។ ២ ប្លវតីតិបិ បាឋោ ។ ៣. វនេតិ ។



កាលបើសេចក្តីត្រូវការ កើតឡើងហើយ សំឡាញ់ទាំងឡាយនាំសេចក្តីសុខមកឲ្យ សេចក្តីត្រេកអរដោយបច្ច័យ តាមមានតាមបាន ជាហេតុនាំសេចក្តីសុខមកឲ្យ បុណ្យនាំសេចក្តីសុខមកឲ្យ ក្នុងកាលទៀបក្ស័យជីវិត ការលះបង់ទុក្ខទាំងអស់បាន ជាហេតុនាំសេចក្តីសុខមកឲ្យ ។ សេចក្តីប្រតិបត្តិល្អក្នុងមាតា នាំសេចក្តីសុខមកឲ្យក្នុងលោក មួយទៀត សេចក្តីប្រតិបត្តិល្អក្នុងបិតា នាំសេចក្តីសុខមកឲ្យ សេចក្តីប្រតិបត្តិល្អក្នុងសមណៈ នាំសេចក្តីសុខមកឲ្យក្នុងលោក មួយទៀត សេចក្តីប្រតិបត្តិល្អក្នុងព្រាហ្មណ៍ នាំសេចក្តីសុខមកឲ្យ សីលនាំសេចក្តីសុខមកឲ្យ ដរាបដល់ចាស់ សទ្ធាដែលបុគ្គលតម្កល់ស៊ប់ហើយ នាំសេចក្តីសុខមកឲ្យ ការបានប្រាជ្ញា នាំសេចក្តីសុខមកឲ្យ ការមិនធ្វើបាបទាំងឡាយ នាំសេចក្តីសុខមកឲ្យ ។

ចប់ វគ្គទី ២៣ ។

## ធម្មបទគាថា តណ្ហាវគ្គ ទី ២៤

(៣៤) តណ្ហា រមែងចំរើនដល់មនុស្សអ្នកមានការប្រព្រឹត្តិ ដោយសេចក្តីប្រមាទជាប្រក្រតី ដូចវល្លិ៍ រួតរឹតដើមឈើហើយ ចំរើនឡើង បុគ្គលនោះ រមែងស្ទុះទៅ កាន់ភពតូចភពធំ ដូចស្វា កាលប្រាថ្នាផ្លែឈើលោតទៅក្នុងព្រៃ ដូច្នោះដែរ ។

យំ ឯសា សហតី[១] ជម្មី តណ្ហា លោកេ វិសត្តិកា
សោកា តស្ស បវឌ្ឍន្តិ អភិវដ្ឋំវ[២] ពីរណំ ។
យោ ចេ[៣]តំ សហតី ជម្មឹ តណ្ហំ លោកេ ទុរច្ចយំ[៤]
សោកា តម្ហា បបតន្តិ[៥] ឧទពិន្ទុវ បោក្ខរា ។
តំ វោ វទាមិ ភទ្ទំ វោ យាវន្តេត្ថ សមាគតា
តណ្ហាយ មូលំ ខណថ ឧសីរត្ថោវ ពីរណំ ។
មា វោ នឡំវ សោតោវ មារោ ភញ្ជិ បុនប្បុនំ ។

យថាបិ មូលេ អនុបទ្ទវេ ទឡ្ហេ
ឆិន្នោបិ រុក្ខោ បុនរេវ[៦] រូហតិ
ឯវម្បិ តណ្ហានុសយេ អនូហតេ
និព្វត្តតី ទុក្ខមិទំ បុនប្បុនំ ។

---

១ សហតេតិបិ បាឋោ ។ ២ ឧ. អភិវដ្ឋំ ។ ម. អភិវុដ្ឋំ ។ អភិវុឌ្ឍន្តិបិ បាឋោ ។ ៣ ឧ. ម. យោ ចេ ។ ៤ ទុរច្ចយន្តិបិ បាឋោ ។ ៥ បបតន្តីតិបិ បាឋោ ។ ៦ បុនរេវាតិបិ បាឋោ ។



តណ្ហានុ៎ះ ជាទោសជាតិដ៏លាមក ផ្សាយទៅក្នុងអារម្មណ៍ផ្សេងៗ ក្នុងលោក គ្របសង្កត់បុគ្គលណា សេចក្តីសោកស្តាយ រមែងចំរើនឡើង ដល់បុគ្គលនោះ ដូចស្មៅពិណ្ណាស ដែលត្រូវភ្លៀងធ្លាក់ចុះស្រោចហើយតែង លូតលាស់ឡើង ដូច្នោះដែរ ។

ចំណែកជនណា គ្របសង្កត់តណ្ហាដ៏លាមក ក្នុងលោក ដែលគេឆ្លងបានដោយកម្រនោះ សេចក្តីសោកស្តាយ រមែងធ្លាក់ចេញចាកជននោះឯង ដូចដំណក់ទឹកដែលធ្លាក់ចុះពីលើស្លឹកឈូក ដូច្នោះដែរ ។

ព្រោះហេតុនោះ បានជាតថាគត ប្រាប់អ្នកទាំងឡាយ អ្នកទាំងឡាយមានចំនួនប៉ុន្មាន ដែលមកប្រជុំក្នុងទីនេះ សេចក្តីចំរើនចូរមានដល់អ្នកទាំងឡាយទាំងប៉ុណ្ណោះចុះ អ្នកទាំងឡាយ ចូរជីកឫសតណ្ហាចោលចេញ ដូចបុគ្គលត្រូវការដោយស្មៅក្រាំង ជីកស្មៅពិណ្ណាសចោលចេញ ដូច្នោះ មារកុំគ្របសង្កត់អ្នកទាំងឡាយរឿយៗ ដូចខ្សែទឹក កាច់បំបាក់ដើមបបុស ដូច្នោះឡើយ ។

កាលបើឫសឈើ មិនមានសេចក្តីអន្តរាយ នៅមាំមួនទេ ដើមឈើទុកជាកាប់ចោលហើយ ក៏រមែងដុះឡើងវិញទៀតបាន មានឧបមាដូចម្តេចមិញ កាលបើតណ្ហានុស័យ បុគ្គលកំចាត់មិនទាន់បានហើយ ទុក្ខ (មានជាតិទុក្ខជាដើម) នេះ ក៏រមែងកើតរឿយៗ មានឧបមេយ្យដូច្នោះឯង ។

យស្ស ឆត្តឹសតី សោតា មនាបសវនា ភុសា

មាហា[១] វហន្តិ ទុទ្ទិដ្ឋឹ សង្កប្បា រាគនិស្សិតា ។

សវន្តិ សព្វធី សោតា លតា ឧព្ភិជ្ជ[២] តិដ្ឋតិ

តញ្ច ទិស្វា លតំ ជាតំ មូលំ[៣] បញ្ញាយ ឆិន្ទថ ។

សរិតានិ សិនេហិតានិ ច

សោមនស្សានិ ភវន្តិ ជន្តុនោ

តេ សាតសិតា សុខេសិនោ

តេ វេ ជាតិជរូបគា នរា ។

តសិណាយ[៤] បុរក្ខតា[៥] បជា

បរិសប្បន្តិ សសោវ ពាធិតោ

សញ្ញោជនសង្គសត្តា[៦]

ទុក្ខមុបេន្តិ បុនប្បុនំ ចិរាយ ។

---

១ ឱ. ភវហា ។ ២ ឧប្បជ្ជាតិបិ បាឋោ ។ ៣ ឱ. មូលេ ។ ៤ តសិណាយាតិបិ បាឋោ ។ ៥ ឱ. បុរក្ខិតា ។ បុរក្ខតាតិបិ បាឋោ ។ ៦ ឱ. សំយោជនសង្គសត្តា ។



ខ្សែតណ្ហា ៣៦ ជាធម្មជាតិហូរទៅ ក្នុងអារម្មណ៍ ជាទីគាប់ចិត្ត ជាធម្មជាតិក្លៀវក្លា នាំដល់បុគ្គលណា តម្រិះទាំងឡាយដ៏ធំ ដែលអាស្រ័យនូវរាគៈ រមែងនាំនូវទិដ្ឋិអាក្រក់ របស់បុគ្គលនោះ ។

ខ្សែតណ្ហាទាំងឡាយ រមែងហូរទៅ ក្នុងអារម្មណ៍ទាំងពួង ដូចជាវល្លិ ដែលបែកខ្នែងឡើង តាំងនៅដូច្នោះ លោកអ្នកទាំងឡាយ ឃើញតណ្ហា ដូចជាវល្លិនោះ កើតឡើងហើយ ចូរកាត់ឫសចោលចេញ ដោយកាំបិតគឺបញ្ញា ។

សោមនស្សទាំងឡាយ ដែលផ្សាយទៅហើយផង ដែលប្រព្រឹត្តទៅដោយសេចក្តីស្រឡាញ់ផង រមែងមានដល់សត្វ ពួកសត្វនោះ ជាអ្នកអាស្រ័យនូវសេចក្តីរីករាយ អ្នកស្វែងរកសេចក្តីសុខ នរជនទាំងឡាយនោះឯង រមែងលុះទៅរកជាតិនិងជរា ។

ពួកសត្វដែលតណ្ហា ជាទីញុំាងសត្វឲ្យតក់ស្លុត ក្រុងហ៊ុមហើយ រមែងខ្វល់ខ្វាយដូចទន្សាយដែលព្រានទាក់បានហើយដូច្នោះ ពួកសត្វ ដែលជាប់ក្នុងសំយោជនៈនិងសង្គធម៌ ( ធម៌ជាគ្រឿងជំពាក់ ) រមែងដល់នូវសេចក្តីទុក្ខរឿយ ៗ អស់កាលអង្វែង ។

តសិណាយ បុរក្ខតា បជា
បរិសប្បន្តិ សសោវ ពាធិតោ
តស្មា តសិណំ វិនោទយេ
ភិក្ខុ អាកង្ខី[១] វិរាគមត្តនោ ។
យោ និព្វនថោ វនាធិមុត្តោ
វនមុត្តោ វនមេវ ធាវតិ
តំ បុគ្គលមេថ បស្សថ
មុត្តោ ពន្ធនមេវ ធាវតិ ។
ន តំ ទឡ្ហំ ពន្ធនមាហុ ធីរា
យទាយសំ ទារុជំ បព្វជញ្ច ។
សារត្តរត្តា មណិកុណ្ឌលេសុ
បុត្តេសុ ទារេសុ ច យា អបេក្ខា
ឯតំ ទឡ្ហំ ពន្ធនមាហុ ធីរា
ឱហារិនំ សិថិលំ ទុប្បមុញ្ចំ
ឯតម្បិ ឆេត្វាន បរិព្វជន្តិ
អនបេក្ខិនោ[២] កាមសុខំ បហាយ ។

---

១ ម. អាកន្ទ ។ ឱ. អាកង្ខី ។ ២ ម. អនបេក្ខិនោ ។



ពួកសត្វដែលតណ្ហា ជាទីញុាំងសត្វឲ្យតក់ស្លុត ក្រសិទុកហើយ តែងរន្ធត់ដូចទន្សាយ ដែលនាយព្រានទាក់ជាប់ហើយដូច្នោះ ព្រោះហេតុនោះ ភិក្ខុកាលប្រាថ្នាធម៌ ជាគ្រឿងប្រាសចាករាគៈ ដើម្បីខ្លួន គប្បីបន្ទោបង់តណ្ហា ដែលជាគ្រឿងតក់ស្លុត ចោលចេញ ។

បុគ្គលណា មិនមានអាល័យ ក្នុងគិហិភាព ដូចដើមឈើតាំងនៅក្នុងព្រៃ មានចិត្តចុះស៊ប់ក្នុងព្រៃគឺតបធម៌ ជាអ្នកផុតស្រឡះចាកព្រៃគឺតណ្ហា ហើយស្ទុះទៅរកព្រៃគឺតណ្ហាវិញ អ្នកទាំងឡាយចូរមើលបុគ្គលនោះឯង បុគ្គលនោះរួចចាកចំណងគឺយកសហើយ ស្ទុះទៅរកចំណងគឺយកសវិញ ។

ចំណងណា ដែលកើតអំពីដែកក្តី កើតអំពីឈើក្តី កើតអំពីស្មៅបាប្ជូសក្តី អ្នកប្រាជ្ញមិនហៅចំណងនោះ ថាជាចំណងមាំមួនឡើយ ។

ពួកជនណា ត្រេកអរក្រៃពេក ក្នុងកែវមណី និងកុណ្ឌលទាំងឡាយក្តី សេចក្តីអាឡោះអាល័យក្នុងកូននិងប្រពន្ធទាំងឡាយក្តី អ្នកប្រាជ្ញទាំងឡាយ ហៅសេចក្តីត្រេកអរនិងសេចក្តីអាឡោះអាល័យនោះ ថាជាចំណងមាំមួន ជាចំណងនាំចុះ ( ទាញសត្វទំលាក់ទៅក្នុងអបាយ ) ជាចំណងធូរ ប៉ុន្តែសត្វស្រាយបានដោយកម្រ អ្នកប្រាជ្ញទាំងឡាយកាត់ចំណងនោះចេញ ជាអ្នកមិនមានសេចក្តីអាឡោះអាល័យ លះបង់កាម-សុខ ហើយចេញបួស ។

យេ រាគរត្តានុបតន្តិ សោតំ
សយំ កតំ មក្កដកោវ ជាលំ
ឯតម្បិ ឆេត្វាន(១) វជន្តិ ធីរា
អនបេក្ខិនោ សព្វទុក្ខំ បហាយ ។
មុញ្ច បុរេ មុញ្ច បច្ឆតោ
មជ្ឈេ មុញ្ច ភវស្ស បារគូ
សព្វត្ថ វិមុត្តមានសោ
ន បុន ជាតិជរំ ឧបេហិសិ ។
វិតក្កមថិតស្ស ជន្តុនោ
តិព្វរាគស្ស សុភានុបស្សិនោ
ភិយ្យោ តណ្ហា បវឌ្ឍតិ
ឯស ខោ ទឡ្ហំ(២) ករោតិ ពន្ធនំ ។
វិតក្កូបសមេ ច(៣) យោ រតោ
អសុភំ ភាវយតី(៤) សទា សតោ
ឯស ខោ វ្យន្តិកាហតិ
ឯសច្ឆេច្ឆតិ(៥) មារពន្ធនំ ។

---

១ ម. ឆិន្ទិត្វាន ។ ២ ម. ឯស គាឡ្ហំ ។ ៣ ម. ៖ ។ ៤ ម. ភាវយតិ ។ ៥ ម. ឯស ឆេជ្ជតិ ។



ពួកជនណា ត្រេកអរដោយតំណាចរាគៈ ពួកជននោះ តែងធ្លាក់ចុះកាន់ខ្សែតណ្ហា ដូចពីងពាងធ្លាក់ចុះកាន់សំណាញ់ ដែលធ្វើហើយដោយខ្លួនឯង អ្នកប្រាជ្ញកាត់ផ្ដាច់ តែងកាត់ខ្សែតណ្ហានោះ ជាអ្នកមិនមានសេចក្តីអាឡោះអាល័យ លះទុក្ខទាំងពួងចេញទៅ ។

អ្នកចូរដោះ ( សេចក្តីអាល័យ ) ក្នុងកាលមុនចេញ ចូរដោះ ( សេចក្តីអាល័យ ) ក្នុងកាលក្រោយចេញ ចូរដោះ (សេចក្តីអាល័យ) ក្នុងកាលជាកណ្តាលចេញ (កាលបើធ្វើយ៉ាងនេះ ) អ្នកនឹងដល់ត្រើយនៃភព នឹងមានចិត្តរួចស្រឡះ ចាកសង្ខារទាំងពួង មិនត្រឡប់ទៅកាន់ជាតិនិងជរាទៀតឡើយ ។

តណ្ហា រមែងចំរើនក្រៃលែង ដល់ជនដែលវិតក្កៈញាំញី មានតម្រេកក្លៀវក្លា យល់ឃើញការល្អថាល្អ បុគ្គលនោះឯងរមែងធ្វើចំណងឲ្យមាំមួន ។ លុះតែបុគ្គលណា ត្រេកអរក្នុងអសុភជ្ឈាន ដែលជាហេតុឲ្យស្ងប់រម្ងាប់វិតក្កៈ មានស្មារតីសព្វកាល តែងចំរើនអសុភជ្ឈាន បុគ្គលនោះឯង នឹងធ្វើតណ្ហាឲ្យអស់ទៅបាន បុគ្គលនោះឯង ទើបផ្ដាច់ កាត់ចំណងនៃមារបាន ។

និដ្ឋង្គតោ អសន្តាសី វីតតណ្ហោ អនង្គណោ

អច្ឆិន្ទិ ភវសល្លានិ អន្តិមោយំ សមុស្សយោ ។

វីតតណ្ហោ អនាទានោ និរុត្តិបទកោវិទោ

អក្ខរានំ សន្និបាតំ ជញ្ញា បុព្វាបរានិ ច

ស វេ អន្តិមសារីរោ មហាបញ្ញោ មហាបុរិសោតិ វុច្ចតិ ។

សព្វាភិភូ សព្វវិទូហមស្មិ

សព្វេសុ ធម្មេសុ អនូបលិត្តោ

សព្វញ្ជហោ តណ្ហក្ខយេ វិមុត្តោ

សយំ អភិញ្ញាយ កមុទ្ទិសេយ្យំ ។

សព្វទានំ ធម្មទានំ ជិនាតិ

សព្វរសំ ធម្មរសោ ជិនាតិ

សព្វរតឹ ធម្មរតិ ជិនាតិ

តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ ។



បុគ្គលណា ដល់សេចក្តីសម្រេចគឺអរហត្ត ជាអ្នកមិនតក់ស្លុត មិនមានតណ្ហា មិនមានកិលេសដូចទីទួល បានកាត់ផ្តាច់សរគឺកិលេស ជាហេតុនាំសត្វឲ្យទៅកាន់ភពបានហើយ កាយដែលខ្ពុំ លេខ០ កំណាត់ផ្តុំ ហើយនេះ របស់បុគ្គលនោះ ឈ្មោះជាកាយនៅក្នុងទីបំផុត ។

បុគ្គលណា មិនមានតណ្ហា មិនមានសេចក្តីប្រកាន់មាំ ជាអ្នកឈ្លាស ក្នុងនិរុត្តិ (គឺពាក្យគន្លឹងសំដែងចេញ) និងបទដ៏សេស ដឹងច្បាស់ នូវប្រជុំនៃអក្ខរៈទាំងឡាយផង នូវខាងដើមនិងខាងចុង នៃអក្ខរៈទាំងឡាយផង បុគ្គលនោះឯង តថាគតហៅថា អ្នកមានសរីរៈឋិតនៅក្នុងទីបំផុត មានបញ្ញាច្រើន ជាមហាបុរស ។

តថាគតជាអ្នកគ្របសង្កត់នូវពួកធម៌ទាំងអស់ ដឹងច្បាស់នូវពួកធម៌ទាំងអស់ មានចិត្តមិនបានជាប់នៅ ក្នុងពួកធម៌ទាំងអស់ លះបង់នូវពួកធម៌ទាំងអស់ មានចិត្តរួចស្រឡះ ព្រោះអស់តណ្ហា បើតថាគតត្រាស់ដឹងឯង ដោយខ្លួនឯងហើយ ចាំបាច់យកអ្នកណាជាគ្រូពាក្យទៀត ។

ធម្មទានឈ្នះការឲ្យទានទាំងពួង ធម្មរសឈ្នះរសទាំងពួង សេចក្តីត្រេកអរក្នុងធម៌ ឈ្នះសេចក្តីត្រេកអរទាំងពួង ការអស់តណ្ហាឈ្នះទុក្ខទាំងពួង ។

ហនន្តិ ភោគា ទុម្មេធំ នោ ច បារគវេសិនោ
ភោគតណ្ហាយ ទុម្មេធោ ហន្តិ អញ្ញេវ អត្តនំ ។
តិណទោសានិ ខេត្តានិ រាគទោសា អយំ បជា
តស្មា ហិ វីតរាគេសុ ទិន្នំ ហោតិ មហប្ផលំ ។
តិណទោសានិ ខេត្តានិ ទោសទោសា អយំ បជា
តស្មា ហិ វីតទោសេសុ ទិន្នំ ហោតិ មហប្ផលំ ។
តិណទោសានិ ខេត្តានិ មោហទោសា អយំ បជា
តស្មា ហិ វីតមោហេសុ ទិន្នំ ហោតិ មហប្ផលំ ។
តិណទោសានិ ខេត្តានិ ឥច្ឆាទោសា អយំ បជា
តស្មា ហិ វិគតិច្ឆេសុ ទិន្នំ ហោតិ មហប្ផលំ ។

តណ្ហាវគ្គោ ចតុវីសតិមោ ។



ភោគៈទាំងឡាយ រមែងសម្លាប់បុគ្គលអប្បប្រាជ្ញ ប៉ុន្តែមិនសម្លាប់បុគ្គលអ្នកស្វែងរកត្រើយគឺព្រះនិព្វានទេ ឯបុគ្គលអប្បប្រាជ្ញ រមែងសម្លាប់ខ្លួនឯង ដូចជាសម្លាប់បុគ្គលដទៃ ព្រោះចំណង់ក្នុងភោគៈ ។ ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វលោកនេះមានរាគៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានរាគៈអស់ហើយ រមែងជាទានមានផលច្រើន ។ ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វលោកនេះ មានទោសៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយដល់អ្នកមានទោសៈអស់ហើយ រមែងជាទានមានផលច្រើន ។ ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វលោកនេះ មានមោហៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានមោហៈអស់ហើយ រមែងជាទានមានផលច្រើន ។ ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វលោកនេះ មានសេចក្តីប្រាថ្នា ជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់អ្នកមានសេចក្តីប្រាថ្នាអស់ហើយ រមែងជាទានមានផលច្រើន ។

ចប់ តណ្ហាវគ្គ ទី ២៤ ។

# ធម្មបទគាថាយ បញ្ចវីសតិមោ ភិក្ខុវគ្គោ

(៣៩) ចក្ខុនា សំវរោ សាធុ សាធុ សោតេន សំវរោ
ឃានេន សំវរោ សាធុ សាធុ ជិវ្ហាយ សំវរោ
កាយេន សំវរោ សាធុ សាធុ វាចាយ សំវរោ
មនសា សំវរោ សាធុ សាធុ សព្វត្ថ សំវរោ
សព្វត្ថ សំវុតោ ភិក្ខុ សព្វទុក្ខា បមុច្ចតិ ។

ហត្ថសញ្ញតោ[១] បាទសញ្ញតោ
វាចាយ សញ្ញតោ[២] សញ្ញតុត្តមោ[៣]
អជ្ឈត្តរតោ សមាហិតោ
ឯកោ សន្តុសិតោ តមាហុ ភិក្ខុំ ។

យោ មុខសញ្ញតោ ភិក្ខុ មន្តភាណី អនុទ្ធតោ
អត្ថំ ធម្មញ្ច ទីបេតិ មធុរំ តស្ស ភាសិតំ ។
ធម្មារាមោ ធម្មរតោ ធម្មំ អនុវិចិន្តយំ
ធម្មំ អនុស្សរំ ភិក្ខុ សទ្ធម្មា ន បរិហាយតិ ។

---

១ ម. ហត្ថសំយតោ ។ ២ ម. វាចាសំយតោ ។ ៣ ម. សញ្ញតុត្តមោ ។ ឬ. សំយតុត្តមោ ។





# ធម្មបទគាថា ភិក្ខុវគ្គ ទី ២៥

(៣៩) ការសង្រួមភ្នែកប្រពៃ ការសង្រួមត្រចៀកប្រពៃ ការសង្រួមច្រមុះប្រពៃ ការសង្រួមអណ្តាតប្រពៃ ការសង្រួមកាយប្រពៃ ការសង្រួមវាចាប្រពៃ ការសង្រួមចិត្តប្រពៃ ការសង្រួមទាំងអស់ប្រពៃ ភិក្ខុសង្រួមហើយក្នុងទ្វារទាំងអស់ តែងរួចស្រឡះចាកទុក្ខទាំងពួងបាន ។ ជនណា សង្រួមដៃ សង្រួមជើង សង្រួមវាចា សង្រួមអត្តភាព ជាអ្នកត្រេកអរក្នុងការចំរើនកម្មដ្ឋានដែលមានក្នុងខ្លួន ជាអ្នកមានចិត្តតម្កល់មាំ ជាអ្នកនៅឯកឯង តែងមានចិត្តត្រេកអរក្នុងធម៌ បណ្ឌិតទាំងឡាយហៅជននោះថា ភិក្ខុ ។

ភិក្ខុណា សង្រួមមាត់ ជាអ្នកពោលដោយបញ្ញា មានចិត្តមិនរាយមាយ សំដែងអត្ថផងធម៌ផង ភាសិតរបស់ភិក្ខុនោះទើបឈ្មោះថាពីរោះ ។ ភិក្ខុមានធម៌ជាទីត្រេកអរ ត្រេកអរហើយក្នុងធម៌ ពិចារណាធម៌ រឭកធម៌រឿយ ៗ តែងមិនសាបសូន្យចាកព្រះសទ្ធម្មឡើយ ។

សលាភំ នាតិមញ្ញេយ្យ នាញ្ញេសំ បិហយំ ចរេ
អញ្ញេសំ បិហយំ ភិក្ខុ សមាធឹ នាធិគច្ឆតិ ។
អប្បលាភោបិ ចេ ភិក្ខុ សលាភំ នាតិមញ្ញតិ
តំ វេ ទេវា បសំសន្តិ សុទ្ធាជីវឹ អតន្ទិតំ ។
សព្វសោ នាមរូបស្មឹ យស្ស នត្ថិ មមាយិតំ
អសតា ច ន សោចតិ ស វេ ភិក្ខូតិ វុច្ចតិ ។
មេត្តាវិហារី យោ ភិក្ខុ បសន្នោ ពុទ្ធសាសនេ
អធិគច្ឆេ បទំ សន្តំ សង្ខារូបសមំ សុខំ ។
សិញ្ច ភិក្ខុ ឥមំ នាវំ សិត្តា តេ លហុមេស្សតិ
ឆេត្វា រាគញ្ច ទោសញ្ច តតោ និព្វានមេហិសិ ។
បញ្ច ឆិន្ទេ បញ្ច ជហេ បញ្ច ឧត្តរិ(១) ភាវយេ
បញ្ចសង្គាតិគោ ភិក្ខុ ឱឃតិណ្ណោតិ វុច្ចតិ ។

១ ម. បញ្ចុត្តរិ ។





ភិក្ខុមិនគប្បីមើលងាយលាភរបស់ខ្លួន (ដែលកើតឡើងដោយធម៌) មិនគប្បីប្រព្រឹត្តចង់បានលាភរបស់ភិក្ខុដទៃ ដ្បិតចង់បានលាភរបស់ភិក្ខុដទៃ រមែងមិនបានសមាធិឡើយ ។ បើភិក្ខុសូម្បីមានលាភតិច មិនមើលងាយលាភរបស់ខ្លួន ទេវតានិងមនុស្សទាំងឡាយ តែងសរសើរភិក្ខុនោះឯង ដែលជាអ្នកមានព្យាយាមជាគ្រឿងអាស្រ័យរស់នៅ ដោយបរិសុទ្ធ ជាអ្នកមិនខ្ជិលច្រអូស ។

បុគ្គលណា មិនមានសេចក្តីប្រកាន់ក្នុងនាមនិងរូបថាជារបស់អញ ដោយប្រការទាំងពួង មួយទៀត បុគ្គលណា មិនសោកស្តាយ ព្រោះនាមនិងរូបដែលមិនមាន បុគ្គលនោះឯងគេហៅថា ភិក្ខុ ។

ភិក្ខុណា នៅដោយកំណាចមេត្តា ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះរមែងបានបទដ៏ស្ងប់ ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្តីសុខ ។

ម្នាលភិក្ខុ ចូរអ្នកស្តារទូកអត្តភាពនេះ ទូកដែលអ្នកស្តារហើយ នឹងដល់ត្រើយឆាប់ អ្នកកាត់រាគៈនិងទោសៈបានហើយ អំពីនោះនឹងកាន់ដល់នូវព្រះនិព្វាន ។

ភិក្ខុគប្បីកាត់ ឱរម្ភាគិយសំយោជនៈ ៥ ផង គប្បីលះបង់ឧទ្ធម្ភាគិយសំ-យោជនៈ ៥ ផង គប្បីចំរើនឥន្ទ្រិយ ៥ តទៅ ភិក្ខុអ្នកកន្លងនូវកិលេសជាគ្រឿងជំពាក់ ៥ (រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ) បានហើយ ទើបគេហៅថា អ្នកឆ្លងឱឃបាន ។

ឈាយ ភិក្ខុ មា ច បមាទោ
មា តេ កាមគុណេ ភមស្សុ ចិត្តំ
មា លោហគុឡំ គិលី បមត្តោ
មា កន្ទិ ទុក្ខមិទន្តិ ឌយ្ហមានោ[១] ។

នត្ថិ ឈានំ អបញ្ញស្ស   នត្ថិ បញ្ញា អឈាយតោ
យម្ហិ ឈានញ្ច បញ្ញា ច   ស វេ និព្វានសន្តិកេ ។
សុញ្ញាគារំ បវិដ្ឋស្ស   សន្តចិត្តស្ស ភិក្ខុនោ
អមានុសី រតី ហោតិ   សម្មា ធម្មំ វិបស្សតោ ។
យតោ យតោ សម្មសតិ   ខន្ធានំ ឧទយព្វយំ
លភតិ បីតិបាមោជ្ជំ   អមតំ តំ វិជានតំ ។
តត្រាយមាទិ ភវតិ   ឥធ បញ្ញស្ស ភិក្ខុនោ
ឥន្ទ្រិយគុត្តិ សន្តុដ្ឋិ   បាតិមោក្ខេ ច សំវរោ
មិត្តេ ភជស្សុ កល្យាណេ   សុទ្ធាជីវេ អតន្ទិតេ ។
បដិសន្ថារវុត្យស្ស   អាចារកុសលោ សិយា
តតោ បាមោជ្ជពហុលោ   ទុក្ខស្សន្តំ ករិស្សតិ ។

១ ឌ្ឍហតោតិបិ បាឋោ ។



ម្នាលភិក្ខុ ចូរអ្នកពិនិត្យផង ចូរកុំជាអ្នកប្រមាទផង ចិត្តរបស់អ្នក ចូរកុំវិលទៅក្នុងកាមគុណឡើយ អ្នកចូរកុំប្រមាទ ទំពាស៊ីដុំលោហៈ កុំឲ្យជាអ្នកកាលភ្លើងឆេះហើយ កន្ទក់កន្ទេញថា នេះទុក្ខ ដូច្នេះឡើយ ។

ការពិនិត្យមិនមានដល់បុគ្គលអ្នកមិនមានប្រាជ្ញា ប្រាជ្ញាមិនមានដល់បុគ្គលអ្នកមិនពិនិត្យ ការពិនិត្យនិងប្រាជ្ញា មានក្នុងបុគ្គលណា បុគ្គលនោះឯង ឈ្មោះថា ឋិតនៅក្នុងទីជិតនៃព្រះនិព្វាន ។

សេចក្តីត្រេកអរ ដែលមិនមែនជារបស់មនុស្ស រមែងមានដល់ភិក្ខុអ្នកចូលទៅកាន់ផ្ទះស្ងាត់ អ្នកមានចិត្តស្ងប់ អ្នកឃើញធម៌ដោយប្រពៃ ។

ភិក្ខុពិចារណាការកើតឡើងនិងការវិនាសនៃខន្ធទាំងឡាយ ក្នុងកាលណា ក្នុងកាលនោះ ភិក្ខុនោះរមែងបាននូវបីតិនិងបាមោជ្ជៈ បីតិនិងបាមោជ្ជៈនោះ ឈ្មោះថា ជាអមតធម៌ របស់បណ្ឌិតអ្នកដឹងធម៌ទាំងឡាយ ។

គុណធម៌ប្រការនេះ គឺការគ្រប់គ្រងឥន្ទ្រិយ ១ សេចក្តីសន្តោស ១ ការសង្រួមក្នុងបាតិមោក្ខ ១ ជាធម៌ដើមនៃព្រះនិព្វាននោះ តែងមានដល់ភិក្ខុអ្នកមានបញ្ញាក្នុងសាសនានេះ (ម្នាលភិក្ខុ) អ្នកចូរគប់កល្យាណមិត្ត អ្នកមានព្យាយាមជាគ្រឿងរស់ដោយបរិសុទ្ធិ ជាអ្នកមិនខ្ជិលច្រអូស ។

ភិក្ខុគប្បីជាអ្នកប្រព្រឹត្តទទួលបដិសន្ថារៈ គប្បីជាអ្នកឈ្លាសក្នុងអាចារៈ ព្រោះហេតុទាំងពីរនោះ អ្នកនឹងមានបាមោជ្ជៈច្រើន នឹងធ្វើទីបំផុតទុក្ខបាន ។

វស្សិកា វិយ បុប្ផានិ មទ្ទវានិ(១) បមុញ្ចតិ
ឯវំ រាគញ្ច ទោសញ្ច វិប្បមុញ្ចេថ ភិក្ខវោ ។
សន្តកាយោ សន្តវាចោ សន្តមនោ សុសមាហិតោ(២)
វន្តលោកាមិសោ ភិក្ខុ ឧបសន្តោតិ វុច្ចតិ ។
អត្តនា ចោទយត្តានំ បដិមំសេតមត្តនា(៣)
សោ អត្តគុត្តោ សតិមា សុខំ ភិក្ខុ វិហាហិសិ ។
អត្តា ហិ អត្តនោ នាថោ អត្តា ហិ អត្តនោ គតិ
តស្មា សញ្ញម អត្តានំ(៤) អស្សំ ភទ្រំវ វាណិជោ ។
បាមោជ្ជពហុលោ ភិក្ខុ បសន្នោ ពុទ្ធសាសនេ
អធិគច្ឆេ បទំ សន្តំ សង្ខារូបសមំ សុខំ ។
យោ ហវេ ទហរោ ភិក្ខុ យុញ្ជតិ ពុទ្ធសាសនេ
សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។

ភិក្ខុវគ្គោ បញ្ចវីសតិមោ ។

---

១ ម. មទ្ទវានិ ។ ២ ម. សមាហិតោ ។ ៣ ម. បដិមាសេ អត្តមត្តនា ។ ម. បដិមាសេថ អត្តនា ។ ៤ ម. សញ្ញម អត្តានំ ។ ម. សំយមមត្តានំ ។



ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីជំរុះរាគៈនឹងទោសៈចេញ ដូចម្លិះជំរុះផ្កាម្លិះទាំងឡាយ ដែលស្វិតហើយ ដូច្នោះ ។

ភិក្ខុអ្នកមានកាយស្ងប់ហើយ មានវាចាស្ងប់ហើយ មានចិត្តស្ងប់ហើយ មានចិត្តតម្កល់មាំហើយ មានអាមិសៈក្នុងលោក ខ្ជាក់ចោលហើយ ទើបអ្នកប្រាជ្ញហៅថា អ្នកស្ងប់រម្ងាប់ ។

អ្នកចូរដាស់តឿនខ្លួនដោយខ្លួនឯង ចូរពិចារណាខ្លួនដោយខ្លួនឯង ម្នាលភិក្ខុ អ្នកនោះបើមានស្មារតី រក្សាខ្លួនបានហើយ នឹងនៅជាសុខ ។

មែនពិត ខ្លួនជាទីពឹងរបស់ខ្លួន ខ្លួនឯងជាគតិរបស់ខ្លួន ព្រោះហេតុនោះ អ្នកចូររាំងខ្លួន ដូចពាណិជរាំងសេះល្អ ។

ភិក្ខុអ្នកច្រើនដោយសេចក្តីរីករាយ ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា រមែងបាននូវបទដ៏ស្ងប់ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្តីសុខ ។

ភិក្ខុណានៅក្មេង ប្រឹងប្រែង ក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះរមែងញុំាងលោកនេះឲ្យភ្លឺស្វាង ដូចព្រះចន្ទដែលផុតអំពីពពក ។

ចប់ភិក្ខុវគ្គ ទី ២៥ ។

## ធម្មបទគាថាយ ឆព្វីសតិមោ ព្រាហ្មណវគ្គោ

(៣៦) ឆិន្ទ សោតំ បរក្កម្ម កាមេ បនុទ(១) ព្រាហ្មណ
សង្ខារានំ ខយំ ញត្វា អកតញ្ញូសិ ព្រាហ្មណ ។
យទា ទ្វយេសុ ធម្មេសុ បារគូ ហោតិ ព្រាហ្មណោ
អថស្ស សព្វេ សំយោគា អត្ថំ គច្ឆន្តិ ជានតោ ។
យស្ស បារំ អបារំ វា បារាបារំ ន វិជ្ជតិ
វីតទ្ទរំ វិសញ្ញុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។
ឈាយឹ វិរជមាសីនំ កតកិច្ចំ អនាសវំ
ឧត្តមត្ថំ អនុប្បត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

(១) ម.ម. បនុទ ។





## ធម្មបទគាថា ព្រាហ្មណវគ្គ ទី ២៦

(៣៦) ម្នាលព្រាហ្មណ៍ អ្នកចូរប្រឹងកាត់កណ្ដាលខ្សែទឹក ចូរបន្ទោបង់កាមទាំងឡាយចេញ ម្នាលព្រាហ្មណ៍ អ្នកស្គាល់ច្បាស់នូវការអស់សង្ខារទាំងឡាយហើយ ឈ្មោះថាជាអ្នកដឹងព្រះនិព្វានដែលបច្ច័យតាក់តែងមិនបាន ។

កាលណា ព្រាហ្មណ៍អ្នកដល់ត្រើយ ក្នុងធម៌ពីរប្រការគឺសមថៈនិងវិបស្សនាធម៌ ក្នុងកាលណោះ កិលេស គ្រឿងប្រកបសព្វគ្រប់ទាំងអស់របស់ព្រាហ្មណ៍ អ្នកដឹងនោះ រមែងដល់នូវការតាំងនៅមិនបាន ។

ត្រើយក្ដី ទីមិនមែនត្រើយក្ដី ត្រើយនិងទីមិនមែនត្រើយក្ដី មិនមានដល់បុគ្គលណា ( សេចក្ដីប្រកាន់ថាយើងរបស់យើងមិនមានដល់បុគ្គលណា ) តថា-គតហៅបុគ្គលនោះ ដែលជាអ្នកមានសេចក្ដីក្រវល់ក្រវាយអស់ហើយ ជាអ្នកប្រាសចាកកិលេស ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គលអ្នកចំរើនឈាន មានធូលីគឺកាមអស់ហើយ អ្នកអង្គុយនៅឯកឯង អ្នកមានការងារគួរធ្វើធ្វើស្រេចហើយ មិនមានអាសវៈ ដល់នូវប្រយោជន៍ដ៏ខ្ពង់ខ្ពស់បំផុតហើយនោះ ថាជាព្រាហ្មណ៍ ។

ទិវា តបតិ អាទិច្ចោ រត្តិមាភាតិ ចន្ទិមា

សន្នទ្ធោ ខត្តិយោ តបតិ ឈាយី តបតិ ព្រាហ្មណោ

អថ សព្ពមហោរត្តឹ ពុទ្ធោ តបតិ តេជសា ។

ពាហិតបាបោ ហិ(២) ព្រាហ្មណោ

សមចរិយា សមណោតិ វុច្ចតិ

បព្វាជយមត្តនោ មលំ

តស្មា បព្វជិតោតិ វុច្ចតិ ។

ន ព្រាហ្មណស្ស បហរេយ្យ នាស្ស មុញ្ចេថ ព្រាហ្មណោ

ធិ(១) ព្រាហ្មណស្ស ហន្តារំ តតោ ធិ(២) យស្ស មុញ្ចតិ ។

ន ព្រាហ្មណស្សេតទកិញ្ចិ សេយ្យោ

យទានិសេធោ មនសោ បិយេហិ

យតោ យតោ ហឹសមនោ និវត្តតិ

តតោ តតោ សម្មតិមេវ ទុក្ខំ ។

១ ម.ម. ធី ។ ២ ទុទ្ធិ ពាហេ ។



ព្រះអាទិត្យរុងរឿង ក្នុងវេលាថ្ងៃ ព្រះចន្ទរុងរឿង ក្នុងវេលាយប់ ក្សត្រទ្រង់ប្រដាប់ពេញយសហើយ ក៏រុងរឿង សមណព្រាហ្មណ៍អ្នកមានឈាន ក៏រុងរឿង ចំណែកព្រះសម្ពុទ្ធ ក៏រុងរឿងដោយតេជះអស់ថ្ងៃនិងយប់ទាំងអស់ ។

អ្នកដែលមានបាបបន្សាត់ហើយ ឈ្មោះថា ព្រាហ្មណ៍ អ្នកដែលគេថាគត ហៅថាសមណៈ ព្រោះការប្រព្រឹត្តិស្ងប់ អ្នកដែលបណ្ដេញមន្ទិលនៃខ្លួន ហេតុនោះទើបគេថាគេហៅថា បព្វជិត ។

ព្រាហ្មណ៍ មិនគប្បីប្រហារព្រាហ្មណ៍ទេ (ចំណែក)ព្រាហ្មណ៍ (ដែលត្រូវគេប្រហារហើយ) មិនគប្បីចងពៀរចំពោះព្រាហ្មណ៍នោះ គេថាគគតិះដៀលព្រាហ្មណ៍ ដែលប្រហារព្រាហ្មណ៍ ព្រាហ្មណ៍ណា ចងពៀរចំពោះព្រាហ្មណ៍នោះ គេថាគគតិះដៀលព្រាហ្មណ៍នោះ ក្រៃលែងជាងនោះទៅទៀត ។

ការហាមឃាត់ចិត្ត ចាកអារម្មណ៍ជាទីស្រឡាញ់ របស់ព្រាហ្មណ៍នោះ មិនមែនប្រសើរបន្តិចបន្តួចទេ ចិត្តដែលគិតបៀតបៀនគេ នឹងងាកចេញ ចាកវត្ថុណា ៗ សេចក្ដីទុក្ខព្រោះវត្ថុនោះ ៗ ក៏រម្ងាប់ទៅម្ដង ។

យស្ស កាយេន វាចាយ មនសា នត្ថិ ទុក្កដំ
សំវុតំ តីហិ ឋានេហិ តមហំ ព្រូមិ ព្រាហ្មណំ ។

យម្ហា ធម្មំ វិជានេយ្យ សម្មាសម្ពុទ្ធទេសិតំ
សក្កច្ចំ តំ នមស្សេយ្យ អគ្គិហុត្តំវ ព្រាហ្មណោ ។

ន ជដាហិ ន គោត្តេន ន ជច្ចា ហោតិ ព្រាហ្មណោ
យម្ហិ សច្ចញ្ច ធម្មោ ច សោ សុចី សោ ច ព្រាហ្មណោ ។

កិន្តេ ជដាហិ ទុម្មេធ កិន្តេ អជិនសាដិយា
អព្ភន្តរំ តេ គហនំ ពាហិរំ បរិមជ្ជសិ ។

បំសុកូលធរំ ជន្តុំ កិសំ ធមនិសន្ថតំ
ឯកំ វនស្មឹ ឈាយន្តំ តមហំ ព្រូមិ ព្រាហ្មណំ ។



អំពើអាក្រក់ ដោយផ្លូវកាយ ផ្លូវវាចា ផ្លូវចិត្ត របស់បុគ្គលណា មិនមានទេ តថាគតហៅបុគ្គល ដែលបានសង្រួមដោយឋានទាំង៣នោះ ថាជាព្រាហ្មណ៍ ។

បុគ្គលបានធម៌ពិត ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សំដែងហើយ អំពីសំណាក់បុគ្គលណា គប្បីនមស្ការបុគ្គលនោះ ដោយគោរព ដូចព្រាហ្មណ៍ដែលនមស្ការបូជាភ្លើងដូច្នោះដែរ ។

បុគ្គលដែលឈ្មោះជាព្រាហ្មណ៍ ព្រោះផ្នួងសក់ ក៏មិនមែន ព្រោះគោត្រ ក៏មិនមែន ព្រោះជាតិ ក៏មិនមែន សច្ចៈផង ធម៌ផង មានក្នុងបុគ្គលណា បុគ្គលនោះឈ្មោះថា អ្នកស្អាតផង បុគ្គលនោះឈ្មោះថា ព្រាហ្មណ៍ផង ។

នែអ្នកអប្បប្រាជ្ញាអើយ អ្នកបានប្រយោជន៍អ្វី ដោយការទុកផ្នួងសក់ អ្នកបានប្រយោជន៍អ្វី ដោយការទ្រទ្រង់សំពត់ស្បែកខ្លា ព្រោះសន្ដានខាងក្នុងរបស់អ្នក សឹងសាំញ៉ាំ ដោយរាគាទិក្កិលេស អ្នកឈ្មោះថាដុសខាត់តែកាយខាងក្រៅ ។

តថាគតហៅ បុគ្គលអ្នកទ្រទ្រង់សំពត់បង្សុកូល មានកាយស្គម មានខ្សែសរសៃផុសឡើងសព្វកាយ ជាបុគ្គលឯកឯង ចំរើនឈានក្នុងព្រៃនោះ ថាជាព្រាហ្មណ៍ ។

ន ចាហំ ព្រាហ្មណំ ព្រូមិ យោនិជំ មត្តិសម្ភវំ[១]
ភោវាទី នាម សោ ហោតិ ស វេ[២] ហោតិ សកិញ្ចនោ
អកិញ្ចនំ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។
សព្វសំយោជនំ ឆេត្វា យោ វេ ន បរិតស្សតិ
សង្គាតិគំ វិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។
ឆេត្វា នទ្ធឹ[៣] វរត្តញ្ច សន្ទានំ[៤] សហនុក្កមំ
ឧក្ខិត្តបលិឃំ[៥] ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។
អក្កោសំ វធពន្ធញ្ច អទុដ្ឋោ យោ តិតិក្ខតិ
ខន្តីពលំ ពលានីកំ[៦] តមហំ ព្រូមិ ព្រាហ្មណំ ។

---

១ ម. បេត្តិសម្ភវំ ។ ២ ឱ. សចេ ។ ៣ ម. នន្ធឹ ។ ៤ ម. សន្ទានំ ។ ៥ ឱ. ឧក្ខិត្តបលិឃំ ។ ៦ ម. ពលនីកំ ។





តថាគតមិនហៅអ្នកកើត អំពីកំណើត អ្នកកើតក្នុងផ្ទៃនៃព្រាហ្មណីជាមាតា ថាជាព្រាហ្មណ៍ គឺថា បុគ្គលនោះគ្រាន់តែបានឈ្មោះថា ភោវាទី (អ្នកពោលថាចំរើន) ព្រោះបុគ្គលនោះឯង ជាអ្នកមានកិលេសជាគ្រឿងកង្វល់នៅឡើយ តថាគតហៅបុគ្គលអ្នកមិនមានកិលេសជាគ្រឿងកង្វល់ អ្នកមិនមានសេចក្តីប្រកាន់មាំនោះឯង ថាជាព្រាហ្មណ៍ ។

បុគ្គលណា កាត់សញ្ញោជនៈទាំងអស់បាន មិនតក់ស្លុត តថាគតហៅបុគ្គលនោះ ដែលឆ្លងកិលេសជាគ្រឿងជំពាក់ អ្នកប្រាសចាកកិលេស ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គលដែលកាត់សេចក្តីក្រោធ ដូចខ្សែផង កាត់តណ្ហា ដូចព្រ័ត្រផង កាត់ទិដ្ឋិ ៦២ ដូចទឹក ព្រមទាំងអនុស័យ ដូចអ្នកដើរតាមផង អ្នកមានអវិជ្ជា ដូចសសរទ្វារដែលលើកចោលហើយ អ្នកត្រាស់ដឹងសច្ចៈ ៤ នោះឯង ថាជាព្រាហ្មណ៍ ។

បុគ្គលណា មិនប្រទូស្ត អត់សង្កត់ពាក្យជេរផង ការបៀតបៀនផង ការចងផងបាន ទើបតថាគតហៅបុគ្គលដែលមានខន្តិជាពលៈ មានខន្តិជាសេនាពលនោះឯង ថាជាព្រាហ្មណ៍ ។

អក្កោធនំ វតវន្តំ សីលវន្តំ អនុស្សទំ(១)
ទន្តំ អន្តិមសារីរំ តមហំ ព្រូមិ ព្រាហ្មណំ ។
វារិ បោក្ខរបត្តេវ អារគ្គេរិវ សាសបោ
យោ ន លិម្បតិ(២) កាមេសុ តមហំ ព្រូមិ ព្រាហ្មណំ ។
យោ ទុក្ខស្ស បជានាតិ ឥធេវ ខយមត្តនោ
បន្នភារំ វិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។
គម្ភីរបញ្ញំ មេធាវឹ មគ្គាមគ្គស្ស កោវិទំ
ឧត្តមត្ថំ អនុប្បត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។
អសំសដ្ឋំ គហដ្ឋេហិ អនាគារេហិ ចូភយំ
អនោកសារឹ អប្បិច្ឆំ តមហំ ព្រូមិ ព្រាហ្មណំ ។

១ ម· អនុស្សុតំ ។ ២ ម· លិប្បតិ ។



តថាគតហៅបុគ្គល ដែលមិនមានសេចក្តីក្រោធ មានធុតង្គវត្ត មានចតុប្បារិសុទ្ធិសីល មិនមានតណ្ហាគ្រឿងដុះដាលចិត្ត មានឥន្ទ្រិយទូន្មានហើយ មានសរីរៈឋិតនៅ ក្នុងទីបំផុតនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា មានចិត្តមិនបានជាប់នៅ ក្នុងកាមទាំងឡាយ ដូចទឹកលើស្លឹកឈូក ឬដូចគ្រាប់ស្ពៃលើចុងដែកស្រួច តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា ក្នុងសាសនានេះឯង ដឹងច្បាស់នូវការអស់ទុក្ខរបស់ខ្លួន តថាគតហៅបុគ្គលនោះ ដែលមានខន្ធភារៈ ដាក់ចុះហើយ ដែលរួចស្រឡះចាកកិលេសទាំងឡាយ ថាជាព្រាហ្មណ៍ ។

តថាគតហៅ បុគ្គលអ្នកមានប្រាជ្ញាជ្រៅ មានប្រាជ្ញាជាគ្រឿងកំចាត់កិលេស អ្នកឈ្លាស ក្នុងផ្លូវនិងមិនមែនផ្លូវ បានសម្រេចប្រយោជន៍ដ៏ខ្ពង់ខ្ពស់នោះ ថាជាព្រាហ្មណ៍ ។

តថាគតហៅ បុគ្គលដែលមិនច្រឡំ ដោយជនទាំងឡាយ គឺពួក គឺគ្រហស្ថ ១ បព្វជិត ១ ជាអ្នកត្រាច់ទៅដោយមិនមានសេចក្តីអាល័យ មានសេចក្តីប្រាថ្នាតិចនោះ ថាជាព្រាហ្មណ៍ ។

និធាយ ទណ្ឌំ ភូតេសុ តសេសុ ថាវរេសុ ច

យោ ន ហន្តិ ន ឃាតេតិ តមហំ ព្រូមិ ព្រាហ្មណំ ។

អវិរុទ្ធំ វិរុទ្ធេសុ អត្តទណ្ឌេសុ និព្វុតំ

សាទានេសុ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។

យស្ស រាគោ ច ទោសោ ច មានោ មក្ខោ ច បាតិតោ

សាសបោរិវ អារគ្គា តមហំ ព្រូមិ ព្រាហ្មណំ ។

អក្កកសំ វិញ្ញាបនឹ[១] គិរំ សច្ចំ ឧទីរយេ

យាយ នាភិសជេ កញ្ចិ តមហំ ព្រូមិ ព្រាហ្មណំ ។

យោធ ទីឃំ វ រស្សំ វា អណុំ ថូលំ សុភាសុភំ

លោកេ អទិន្នំ នាទិយតិ តមហំ ព្រូមិ ព្រាហ្មណំ ។

អាសា យស្ស ន វិជ្ជន្តិ អស្មឹ លោកេ បរម្ហិ ច

និរាសយំ វិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

១ ម. វិញ្ញាបណឹ ។ ម. វិញ្ញាបនំ ។



បុគ្គលណា ដាក់ចុះនូវអាជ្ញា ក្នុងសត្វទាំងឡាយ ដែលនៅតក់ស្លុតក្តី ដែលមាំមួន គឺមិនមានតក់ស្លុតក្តី មិនបៀតបៀនដោយខ្លួនឯង មិនប្រើគេឲ្យបៀតបៀន តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គលអ្នកដែលមិនទទឹង ចំពោះពួកជនដែលទទឹងហើយ អ្នករលត់ចំពោះពួកជនដែលមានអាជ្ញាក្នុងខ្លួន អ្នកមិនមានសេចក្តីប្រកាន់ ចំពោះពួកជនដែលមានសេចក្តីប្រកាន់នោះ ថាជាព្រាហ្មណ៍ ។

រាគៈ ទោសៈ មានៈ និងមក្ខៈ ដែលបុគ្គលណា ធ្លាក់ចុះចេញហើយ ដូចគ្រាប់ស្ពៃដែលធ្លាក់ចុះ អំពីចុងដែកស្រួច តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា ពោលពាក្យមិនគគ្រើម ពាក្យជាហេតុឲ្យដឹងសេចក្តីបាន ជាពាក្យពិត ជាពាក្យដែលមិនធ្វើអ្នកណា ឲ្យទាស់ចិត្ត តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា មិនកាន់យករបស់ដែលវែងខ្លី តូចធំ ល្អអាក្រក់ ដែលគេមិនបានឲ្យហើយក្នុងលោកនេះ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

អ្នកណា មិនមានសេចក្តីប្រាថ្នាក្នុងលោកនេះផង ក្នុងលោកខាងមុខផង តថាគតហៅបុគ្គលនោះ ដែលមិនមានសេចក្តីប្រាថ្នា ដែលផុតស្រឡះ ចាកកិលេស ថាជាព្រាហ្មណ៍ ។

យស្សាលយា ន វិជ្ជន្តិ អញ្ញាយ អកថង្កថី
អមតោគធំ អនុប្បត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។
យោធ បុញ្ញញ្ច បាបញ្ច ឧភោ សង្គំ ឧបច្ចគា
អសោកំ វិរជំ សុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។
ចន្ទំវ វិមលំ សុទ្ធំ វិប្បសន្នមនាវិលំ
នន្ទិភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ ។
យោមំ បលិបថំ ទុគ្គំ សំសារំ មោហមច្ចគា
តិណ្ណោ បារគតោ ឈាយី អនេជោ អកថង្កថី
អនុបាទាយ និព្វុតោ តមហំ ព្រូមិ ព្រាហ្មណំ ។



អ្នកណា មិនមានសេចក្តីអាល័យគឺតណ្ហា មិនមានសេចក្តីសង្ស័យក្នុងអ្វីៗ ព្រោះដឹងច្បាស់ធម៌ តថាគតហៅបុគ្គលនោះ ដែលមានចិត្តចុះស៊ប់កាន់ព្រះនិព្វាន ដែលមានព្រះអរហត្តផលដល់ហើយ ដោយលំដាប់ ថាជាព្រាហ្មណ៍ ។

បុគ្គលណា ក្នុងលោកនេះ លះបង់បុណ្យនិងបាបទាំង ២ និងកិលេសជាគ្រឿងជំពាក់(មានរាគៈជាដើម)ចេញហើយ តថាគតហៅបុគ្គលនោះ ដែលជាអ្នកមិនមានសេចក្តីសោក មានធូលីគឺកិលេសអស់ហើយ ជាអ្នកបរិសុទ្ធ ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គល ដែលមិនមានសេចក្តីសៅហ្មង ដូចព្រះចន្ទ្រប្រាសចាកមន្ទិល ជាអ្នកបរិសុទ្ធ មានចិត្តជ្រះថ្លា មិនកករល្អក់ អស់សេចក្តីត្រេកអរក្នុងភពហើយនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា កន្លងផុតភក់គឺរាគៈ និងភក់ដែលគេឆ្លងបានដោយក្រ គឺកិលេស និងសង្សារវដ្ត និងមោហៈទាំងនេះបាន ជាអ្នកឆ្លងផុតទាំងនេះ បានដល់ត្រើយគឺព្រះនិព្វាន ជាអ្នកមានឈាន មិនញាប់ញ័រដោយតណ្ហា មិនមានសេចក្តីសង្ស័យ មិនប្រកាន់មាំ ជាអ្នករលត់កិលេសហើយ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

យោធ កាមេ បហន្តាន(១) អនាគារោ បរិព្វជេ

កាមភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ ។

យោធ តណ្ហំ បហន្តាន(១) អនាគារោ បរិព្វជេ

តណ្ហាភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ(២) ។

ហិត្វា មានុសកំ យោគំ ទិព្វំ យោគំ ឧបច្ចគា

សព្វយោគវិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

ហិត្វា រតឹ អរតិញ្ច សីតិភូតំ និរូបធឹ

សព្វលោកាភិភុំ វីរំ តមហំ ព្រូមិ ព្រាហ្មណំ ។

ចុតឹ យោ វេទិ សត្តានំ ឧបបត្តិញ្ច សព្វសោ

អសត្តំ សុគតំ ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។

---

១ ១. បហត្វាន ។ ២ [illegible] ។



បុគ្គលណា ក្នុងលោកនេះ បានលះបង់កាមទាំងឡាយ ជាអ្នកមិនមានផ្ទះ គេចចេញចាកកាមបាន តថាគតហៅបុគ្គលនោះ ដែលអស់កាមភពហើយ ថាជាព្រាហ្មណ៍ ។

បុគ្គលណា ក្នុងលោកនេះ បានលះបង់តណ្ហាហើយ ជាអ្នកមិនមានផ្ទះ គេចចេញចាកតណ្ហាបាន តថាគតហៅបុគ្គល ដែលអស់តណ្ហានឹងភពហើយនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា លះកិលេសជាគ្រឿងប្រកប ដែលជារបស់មនុស្ស កន្លងកិលេសជាគ្រឿងប្រកប ដែលជារបស់ទិព្វផងហើយ តថាគតហៅបុគ្គល ដែលផុតស្រឡះ ចាកកិលេសជាគ្រឿងប្រកបទាំងពួងនោះ ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គល ដែលលះបង់សេចក្ដីត្រេកអរ ក្នុងកាមគុណនឹងមិនត្រេកអរក្នុងកិរិយានៅក្នុងព្រៃ ជាអ្នកមានចិត្តត្រជាក់មិនមានឧបក្កិលេស គ្របសង្កត់លោកទាំងពួង មានសេចក្ដីព្យាយាមនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា ដឹងច្បាស់ចុតិនឹងបដិសន្ធិរបស់ពួកសត្វ ដោយអាការទាំងពួងបាន តថាគតហៅបុគ្គលដែលជាអ្នកមិនជាប់នៅក្នុងកាម អ្នកមានដំណើរល្អ ដោយសេចក្ដីប្រតិបត្តិ ត្រាស់ដឹងនូវសច្ចៈ ៤ នោះ ថាជាព្រាហ្មណ៍ ។

យស្ស គតឹ ន ជានន្តិ ទេវា គន្ធព្វមានុសា
ខីណាសវំ អរហន្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

យស្ស បុរេ ច បច្ឆា ច មជ្ឈេ ច នត្ថិ កិញ្ចនំ
អកិញ្ចនំ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។

ឧសភំ បវរំ វីរំ មហេសឹ វិជិតាវិនំ
អនេជំ ន្ហាតកំ[១] ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។

បុព្វេនិវាសំ យោ វេទិ[២] សគ្គាបាយញ្ច បស្សតិ
អថោ ជាតិក្ខយំ បត្តោ អភិញ្ញាវោសិតោ មុនិ
សព្វវោសិតវោសានំ តមហំ ព្រូមិ ព្រាហ្មណំ ។

ព្រាហ្មណវគ្គោ ឆព្វីសតិមោ ។

១ ម. ន្ហាតកំ ។ ២ ម. វេទី ។



ទេវតា គន្ធព្វ នឹងពួកមនុស្សទាំងឡាយ មិនដឹងគតិ របស់បុគ្គលណា តថាគតហៅបុគ្គល ដែលជាអ្នកមានអាសវៈអស់ហើយ ជាព្រះអរហន្ត នោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា មិនមានសេចក្តីកង្វល់ ក្នុងកាលមុនផង ក្នុងកាលជាខាងក្រោយផង ក្នុងកាលជាកណ្តាលផង តថាគតហៅបុគ្គល ដែលជាអ្នកមិនមានកង្វល់ មិនមានសេចក្តីប្រកាន់នោះ ថាជាព្រាហ្មណ៍ ។

តថាគតហៅវីរបុរស អ្នកអង់អាច អ្នកប្រសើរ អ្នកស្វែងរកគុណដ៏ធំ ឈ្នះមារ មិនមានកិលេសជាគ្រឿងញាប់ញ័រ ជ្រះលាងកិលេស ត្រាស់ដឹងសច្ចៈនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា ដឹងច្បាស់នូវបុព្វេនិវាសៈ ដែលខ្លួនធ្លាប់នៅអាស្រ័យ ក្នុងកាលមុនផង ឃើញច្បាស់នូវឋានសួគ៌ នឹងអបាយភូមិផង មួយទៀត បានសម្រេចធម៌ជាគ្រឿងអស់ជាតិ ជាអ្នកប្រាជ្ញ ស្រេចកិច្ចហើយ ព្រោះអភិញ្ញា តថាគតហៅបុគ្គល ដែលជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ចប់សព្វគ្រប់ហើយនោះ ថាជាព្រាហ្មណ៍ ។

ចប់ ព្រាហ្មណវគ្គ ទី ២៦ ។

## ធម្មបទគាថាយ ឧទ្ទានំ

(១)

(៣៧) យមកំ អប្បមទំ ចិត្តំ បុប្ផំ ពាលេន បណ្ឌិតំ
អរហន្តំ សហស្សេន បាបំ ទណ្ឌេន តេ ទស ។
ជរា អត្តា ច លោកោ ច ពុទ្ធំ សុខំ បិយេន ច
កោធំ មលញ(២) ធម្មដ្ឋំ មគ្គវគ្គេន វីសតិ ។
បកិណ្ណំ(៣) និរយំ នាគំ តណ្ហា ភិក្ខុ ច ព្រាហ្មណោ
ឯតេ ឆព្វីសតិ វគ្គា ទេសិតាទិច្ចពន្ធុនា ។
យមកេ វីសតិ គាថា អប្បមាទម្ហិ ទ្វាទស
ឯកាទស ចិត្តវគ្គេ បុប្ផវគ្គម្ហិ សោឡស
ពាលេ សត្តរស គាថា បណ្ឌិតម្ហិ ចតុទ្ទស
អរហន្តេ ទស គាថា សហស្សេ ហោន្តិ សោឡស
តេរស បាបវគ្គម្ហិ ទណ្ឌម្ហិ ទស សត្ត ច
ឯកាទស ជរាវគ្គេ អត្តវគ្គម្ហិ ទ្វាទស
ទ្វាទស លោកវគ្គម្ហិ ពុទ្ធវគ្គម្ហិ សោឡស
សុខេ ច បិយវគ្គេ ច គាថាយោ ហោន្តិ ទ្វាទស
ចុទ្ទស កោធវគ្គម្ហិ មលវគ្គេកវីសតិ
សត្តរស ច ធម្មដ្ឋេ មគ្គវគ្គម្ហិ សោឡស

១ ឱ. អប្បមាទំ ។ ២ ឱ. មលញ្ច ។ ៣ បកិណ្ណកំ ។

## ឧទ្ទាន នៃធម្មបទគាថា គឺ

(៣៧) សំដែងពីយមកវគ្គ ១ អប្បមាទវគ្គ ១ ចិត្តវគ្គ ១ បុប្ផវគ្គ ១ ពាលវគ្គ ១ បណ្ឌិតវគ្គ ១ អរហន្តវគ្គ ១ សហស្សវគ្គ ១ បាបវគ្គ ១ ទណ្ឌវគ្គ ១ ត្រូវជា ១០ វគ្គ ។

ជរាវគ្គ ១ អត្តវគ្គ ១ លោកវគ្គ ១ ពុទ្ធវគ្គ ១ សុខវគ្គ ១ បិយវគ្គ ១ កោធវគ្គ ១ មលវគ្គ ១ ធម្មដ្ឋវគ្គ ១ មគ្គវគ្គ ១ រួមនឹងវគ្គខាងដើមត្រូវជា ២០ វគ្គ ។

បកិណ្ណកវគ្គ ១ និរយវគ្គ ១ នាគវគ្គ ១ តណ្ហាវគ្គ ១ ភិក្ខុវគ្គ ១ ព្រាហ្មណវគ្គ ១ បូករួមត្រូវជា ២៦ វគ្គ ដែលព្រះអាទិច្ចពន្ធុទ្រង់សំដែងទុកហើយ ។

ក្នុងយមកវគ្គ មាន ២០ គាថា ក្នុងអប្បមាទវគ្គ មាន ១២ គាថា ក្នុងចិត្តវគ្គ មាន ១១ គាថា ក្នុងបុប្ផវគ្គ មាន ១៦ គាថា ក្នុងពាលវគ្គ មាន ១៧ គាថា ក្នុងបណ្ឌិតវគ្គ មាន ១៤ គាថា ក្នុងអរហន្តវគ្គ មាន ១០ គាថា ក្នុងសហស្សវគ្គ មាន ១៦ គាថា ក្នុងបាបវគ្គ មាន ១៣ គាថា ក្នុងទណ្ឌវគ្គ មាន ១៧ គាថា ក្នុងជរាវគ្គ មាន ១១ គាថា ក្នុងអត្តវគ្គ មាន ១២ គាថា ក្នុងលោកវគ្គ មាន ១២ គាថា ក្នុងពុទ្ធវគ្គ មាន ១៦ គាថា ក្នុងសុខវគ្គនឹងបិយវគ្គ មាន ១២ គាថា ស្មើគ្នា ក្នុងកោធវគ្គ មាន ១៤ គាថា ក្នុងមលវគ្គ មាន ២១ គាថា ក្នុងធម្មដ្ឋវគ្គ មាន ១៧ គាថា ក្នុងមគ្គវគ្គ មាន ១៦ គាថា

បកិណ្ណេ សោឡស គាថា និរយេ នាគេ ចុទ្ទស
ទ្វាវីស តណ្ហាវគ្គម្ហិ តេវីសា ភិក្ខុវគ្គកា
ចត្តាឡីស ច គាថាយោ ព្រាហ្មណេ វគ្គមុត្តមេ ។
គាថាសតានិ ចត្តារិ តេវីសា ច បុនាបរេ
ធម្មបទេ និបាតម្ហិ ទេសិតាទិច្ចពន្ធុនា[១] ។

ធម្មបទំ និដ្ឋិតំ ។

---

១ ធម្មបទស្ស វគ្គយុត្តំ

យមកំ បមាទំ ចិត្តំ បុប្ផំ ពាលញ្ច បណ្ឌិតំ
អរហន្តំ សហស្សំ បាបំ ទណ្ឌំ ជរា អត្តលោកំ ។
ពុទ្ធំ សុខំ បិយំ កោធំ មលំ ធម្មដ្ឋញ្ច មគ្គំ
បកិណ្ណំ និរយំ នាគំ តណ្ហា ភិក្ខុ ច ព្រាហ្មណោ ។

គាថាយុត្តំ

យមកេ វីស គាថាយោ អប្បមាទម្ហិ ច
បិយេ ទ្វាទស គាថាយោ ចិត្តេ ឯកាទសា ភវេ ។
បុប្ផពាលសហស្សម្ហិ ពុទ្ធមគ្គបកិណ្ណកេ
សោឡស បណ្ឌិតេ តេរេ និរយេ នាគេ ចុទ្ទស ។
អរហន្តេ ទសគាថា ជរាសុខម្ហិ តេរស
សត្តរស ទណ្ឌធម្មដ្ឋេ មលម្ហិ ឯកវីសតិ ។
តណ្ហាវគ្គេ សត្តវីស តេវីស ភិក្ខុវគ្គម្ហិ
ព្រាហ្មណេ ឯកតាឡីស ចតុស្សតា សតេវីសេ ។

ធម្មបទំ សមត្តំ មរម្មបោត្ថកេ ទិស្សន្តិ ។

គាថាយុត្តំ បន ខេមរបោត្ថកេ នត្ថិ ។



ក្នុងបកិណ្ណកវគ្គ មាន ១៦ គាថា ក្នុងនិរយវគ្គនិងនាគវគ្គ មាន ១៤ គាថា ផ្សេងគ្នា ក្នុងតណ្ហាវគ្គ មាន ២៦ គាថា ក្នុងភិក្ខុវគ្គ មាន ២៣ គាថា ក្នុងព្រាហ្មណវគ្គដ៏ឧត្តម មាន ៤០ គាថា ។ ៤២៣ គាថានៅទៀត ព្រះអាទិច្ចពន្ធុទ្រង់សំដែងទុកហើយ ក្នុងធម្មបទនិបាត ។

ចប់ ធម្មបទ ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស

# ឧទានំ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## បឋមោ ពោធិវគ្គោ

[៣៨] ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា ឧរុវេលាយំ វិហរតិ នជ្ជា នេរញ្ជរាយ តីរេ ពោធិរុក្ខមូលេ បឋមាភិសម្ពុទ្ធោ ។

តេន ខោ បន សមយេន ភគវា សត្តាហំ ឯកបល្លង្កេន និសិន្នោ ហោតិ វិមុត្តិសុខំ បដិសំវេទី ។ អថខោ ភគវា តស្ស សត្តាហស្ស អច្ចយេន តម្ហា សមាធិម្ហា វុដ្ឋហិត្វា រត្តិយា បឋមំ យាមំ បដិច្ចសមុប្បាទំ អនុលោមំ សាធុកំ មនសាកាសិ ឥតិ ឥមស្មឹ សតិ ឥទំ ហោតិ ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ យទិទំ អវិជ្ជាបច្ចយា សង្ខារា សង្ខារបច្ចយា វិញ្ញាណំ វិញ្ញាណបច្ចយា នាមរូបំ នាមរូបបច្ចយា សឡាយតនំ សឡាយតនបច្ចយា ផស្សោ ផស្សបច្ចយា វេទនា

សុត្តន្តបិដក ខុទ្ទកនិកាយ

# ឧទាន

សូមនមស្ការ ចំពោះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។

## ពោធិវគ្គ ទី ១

[៣៨] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ បានត្រាស់ដឹងជាដំបូង ទ្រង់គង់នៅក្បែរគល់ពោធិព្រឹក្ស ទៀបឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេស ។

សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់ដោយបល្ល័ង្កតែមួយ សោយវិមុត្តិសុខអស់ ១ សប្តាហ៍ ( ៧ ថ្ងៃ ) ។ លុះកន្លងសប្តាហ៍នោះហើយ ព្រះមានព្រះភាគ ទ្រង់ចេញអំពីសមាធិនោះ ទ្រង់ធ្វើទុកក្នុងព្រះទ័យចំពោះបដិច្ចសមុប្បាទធម៌ ជាអនុលោមដ៏ពិតៗណាមួយ អស់ក្នុងបឋមយាម ដោយប្រៀបថា កាលបើបច្ច័យ (*) នេះមាន ផលនេះក៏មាន ផលនេះ រមែងកើតឡើង ព្រោះការកើតឡើងនៃបច្ច័យនេះ គឺសង្ខារទាំងឡាយ កើតមាន ព្រោះអវិជ្ជា ជាបច្ច័យ វិញ្ញាណកើតមាន ព្រោះសង្ខារ ជាបច្ច័យ នាមរូប កើតមាន ព្រោះវិញ្ញាណ ជាបច្ច័យ សឡាយតនៈ កើតមាន ព្រោះនាមរូប ជាបច្ច័យ ផស្សៈ កើតមាន ព្រោះសឡាយតនៈ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈ ជាបច្ច័យ

* ពាក្យថា បច្ច័យគឺពាក្យប្រើជំនួសពាក្យថា ហេតុ ។

វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានបច្ចយា ភវោ ភវបច្ចយា ជាតិ ជាតិបច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ឯវមេតស្ស កេវលស្ស[១] ទុក្ខក្ខន្ធស្ស សមុទយោ ហោតីតិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

យទា ហវេ បាតុភវន្តិ ធម្មា
អាតាបិនោ ឈាយតោ ព្រាហ្មណស្ស
អថស្ស កង្ខា វបយន្តិ សព្វា
យតោ បជានាតិ សហេតុធម្មន្តិ ។ សុត្តំ បឋមំ[២] ។

(៣៩) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ឧរុវេលាយំ វិហរតិ នជ្ជា នេរញ្ជរាយ តីរេ ពោធិរុក្ខមូលេ បឋមាភិសម្ពុទ្ធោ ។ តេន ខោ បន សមយេន ភគវា សត្តាហំ ឯកបល្លង្កេន និសិន្នោ ហោតិ វិមុត្តិសុខំ បដិសំវេទី ។ អថខោ ភគវា តស្ស សត្តាហស្ស អច្ចយេន តម្ហា សមាធិម្ហា វុដ្ឋហិត្វា រត្តិយា មជ្ឈិមំ យាមំ បដិច្ចសមុប្បាទំ បដិលោមំ សាធុកំ មនសាកាសិ ឥតិ

១. ឥទំ បទំ នត្ថិ ។ ២ ឱ.ម. សុត្តំ បឋមំ នត្ថិ ។



តណ្ហាកើតមាន ព្រោះវេទនា ជាបច្ច័យ ឧបាទានកើតមាន ព្រោះតណ្ហា ជាបច្ច័យ ភពកើតមាន ព្រោះឧបាទាន ជាបច្ច័យ ជាតិកើតមាន ព្រោះភពជាបច្ច័យ ជរាមរណៈកើតមាន ព្រោះជាតិជាបច្ច័យ សោកៈ បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ ក៏កើតព្រម ការកើតឡើងនៃគំនរទុក្ខទាំងអស់នោះ រមែងមានយ៉ាងនេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

ធម៌ទាំងឡាយ រមែងប្រាកដដល់ព្រាហ្មណ៍ អ្នកមានព្យាយាមញ៉ាំង
កិលេសឲ្យក្តៅ អ្នកដុតបំផ្លាញកិលេស ក្នុងកាលណា សេចក្តីសង្ស័យ
ទាំងឡាយទាំងពួងរបស់ព្រាហ្មណ៍នោះ រមែងអស់ទៅ ក្នុងកាលនោះ
ព្រោះដឹងច្បាស់នូវធម៌ព្រមទាំងហេតុ ។ សូត្រទី ១ ។

( ៣៩ ) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ត្រាស់ដឹងជាដំបូង ទ្រង់គង់នៅក្បែរគល់ពោធិព្រឹក្ស ទៀបឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេស ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់ដោយបល្ល័ង្កតែមួយ សោយវិមុត្តិសុខ អស់ ៧ សប្តាហ៍ ។ លុះអំណើះ សប្តាហ៍នោះហើយ ទើបព្រះមានព្រះភាគ ទ្រង់ចេញអំពីសមាធិនោះ ហើយទ្រង់ធ្វើទុកក្នុងព្រះហឫទ័យ បំពោះបដិច្ចសមុប្បាទធម៌ ជាបដិលោម គឺជាលំដាប់ច្រាសឡើងអស់មជ្ឈិមយាមនៃរាត្រី ដោយប្រពៃថា

ឥមស្មិំ អសតិ ឥទំ ន ហោតិ ឥមស្ស និរោធា ឥទំ និរុជ្ឈតិ យទិទំ អវិជ្ជានិរោធា សង្ខារនិរោធោ សង្ខារនិរោធា វិញ្ញាណនិរោធោ វិញ្ញាណនិរោធា នាមរូបនិរោធោ នាមរូបនិរោធា សឡាយតននិរោធោ សឡាយតននិរោធា ផស្សនិរោធោ ផស្សនិរោធា វេទនានិរោធោ វេទនានិរោធា តណ្ហានិរោធោ តណ្ហានិរោធា ឧបាទាននិរោធោ ឧបាទាននិរោធា ភវនិរោធោ ភវនិរោធា ជាតិនិរោធោ ជាតិនិរោធា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ ឯវមេតស្ស កេវលស្ស[១] ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។

អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

យទា ហវេ បាតុភវន្តិ ធម្មា
អាតាបិនោ ឈាយតោ ព្រាហ្មណស្ស
អថស្ស កង្ខា វបយន្តិ សព្វា
យតោ ខយំ បច្ចយានំ អវេទិ ។ ទុតិយំ[២] ។

១ ម. សព្វត្ថ ។ ២ ម. ម. ទុតិយំ សុត្តំ ។



កាលបើបច្ច័យនេះមិនមាន ផលនេះ ក៏មិនមាន ផលនេះ រមែងរលត់ទៅ ព្រោះរលត់ទៅនៃបច្ច័យនេះ គឺការរលត់ទៅនៃសង្ខារ ព្រោះរលត់អវិជ្ជា ការរលត់ទៅនៃវិញ្ញាណ ព្រោះរលត់សង្ខារ ការរលត់ទៅនៃនាមរូប ព្រោះរលត់វិញ្ញាណ ការរលត់ទៅនៃសឡាយតនៈ ព្រោះរលត់នាមរូប ការរលត់ទៅនៃផស្សៈ ព្រោះរលត់សឡាយតនៈ ការរលត់ទៅនៃវេទនា ព្រោះរលត់ផស្សៈ ការរលត់ទៅនៃតណ្ហា ព្រោះរលត់វេទនា ការរលត់ទៅនៃឧបាទាន ព្រោះរលត់តណ្ហា ការរលត់ទៅនៃភព ព្រោះរលត់ឧបាទាន ការរលត់ទៅនៃជាតិ ព្រោះរលត់ភព ជរាមរណៈរលត់ទៅព្រម ព្រោះរលត់ជាតិ សោកៈ បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ ក៏រមែងរលត់ សេចក្តីរលត់នៃគំនរទុក្ខទាំងអស់នុ៎ះ តែងមានយ៉ាងនេះ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺនូវឧទាននេះ ក្នុងវេលានោះថា

ធម៌ទាំងឡាយ រមែងប្រាកដដល់ព្រាហ្មណ៍ អ្នកមានព្យាយាមញ៉ាំងកិលេសឲ្យក្តៅ អ្នកដុតបង់កិលេស ក្នុងកាលណា សេចក្តីសង្ស័យទាំងឡាយ ទាំងពួងរបស់ព្រាហ្មណ៍នោះ រមែងអស់ទៅក្នុងកាលនោះ ព្រោះបានដឹងច្បាស់នូវព្រះនិព្វាន ជាទីអស់ទៅនៃបច្ច័យទាំងឡាយ ។

សូត្រ ទី ២ ។

(៦០) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ឧរុវេលាយំ វិហរតិ នជ្ជា នេរញ្ជរាយ តីរេ ពោធិរុក្ខមូលេ បឋមាភិសម្ពុទ្ធោ ។ អថ ខោ ភគវា សត្តាហំ ឯកបល្លង្កេន និសិន្នោ ហោតិ វិមុត្តិសុខំ បដិសំវេទី ។ អថខោ ភគវា តស្ស សត្តាហស្ស អច្ចយេន តម្ហា សមាធិម្ហា វុដ្ឋហិត្វា រត្តិយា បឋមំ យាមំ បដិច្ចសមុប្បាទំ អនុលោមប្បដិលោមំ សាធុកំ មនសាកាសិ ឥតិ ឥមស្មឹ សតិ ឥទំ ហោតិ ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ ឥមស្មឹ អសតិ ឥទំ ន ហោតិ ឥមស្ស និរោធា ឥទំ និរុជ្ឈតិ យទិទំ អវិជ្ជាបច្ចយា សង្ខារា សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា នាមរូបំ នាមរូបប្បច្ចយា សឡាយតនំ សឡាយតនប្បច្ចយា ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ។



(៦០) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ បានត្រាស់ដឹង ជាដំបូង ទ្រង់គង់នៅក្បែរគល់ពោធិព្រឹក្ស ទៀបឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេស ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់នៅដោយបល្ល័ង្កតែមួយ សោយវិមុត្តិសុខអស់ ៧ សប្តាហ៍ ។ លុះផុតអំណើះ សប្តាហ៍នោះហើយ ទើបព្រះមានព្រះភាគ ទ្រង់ចេញអំពីសមាធិនោះ ហើយទ្រង់ធ្វើទុកក្នុងព្រះហឫទ័យចំពោះបដិច្ចសមុប្បាទធម៌ ជាអនុលោមនិងបដិលោមអស់បឋមយាម ដោយប្រពៃថា កាលបើបច្ច័យនេះមាន ផលនេះក៏មាន ផលនេះ រមែងកើតឡើង ព្រោះកើតឡើងនៃបច្ច័យនេះ កាលបើបច្ច័យនេះមិនមាន ផលនេះក៏មិនមាន ផលនេះរលត់ទៅ ព្រោះរលត់ទៅនៃបច្ច័យនេះ គឺសង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះសង្ខារ ជាបច្ច័យ នាមរូបកើតមាន ព្រោះវិញ្ញាណ ជាបច្ច័យ សឡាយតនៈកើតមាន ព្រោះនាមរូប ជាបច្ច័យ ផស្សៈ កើតមាន ព្រោះសឡាយតនៈជាបច្ច័យ វេទនាកើតមាន ព្រោះផស្សៈ ជាបច្ច័យ តណ្ហាកើតមាន ព្រោះវេទនា ជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហា ជាបច្ច័យ ភពៈកើតមាន ព្រោះឧបាទាន ជាបច្ច័យ ជាតិកើតមាន ព្រោះភព ជាបច្ច័យ ជរាមរណៈ កើតមានព្រម ព្រោះជាតិ ជាបច្ច័យ សោកៈ បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ ក៏រមែងកើតមាន ។

ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។ អវិជ្ជាយត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ សង្ខារនិរោធា វិញ្ញាណនិរោធោ វិញ្ញាណនិរោធា នាមរូបនិរោធោ នាមរូបនិរោធា សឡាយតននិរោធោ សឡាយតននិរោធា ផស្សនិរោធោ ផស្សនិរោធា វេទនានិរោធោ វេទនានិរោធា តណ្ហានិរោធោ តណ្ហានិរោធា ឧបាទាននិរោធោ ឧបាទាននិរោធា ភវនិរោធោ ភវនិរោធា ជាតិនិរោធោ ជាតិនិរោធា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។

អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

យទា ហវេ បាតុភវន្តិ ធម្មា
អាតាបិនោ ឈាយតោ ព្រាហ្មណស្ស
វិធូបយំ តិដ្ឋតិ មារសេនំ
សុរិយោវ ឱភាសយមន្តលិក្ខន្តិ ។ តតិយំ[១] ។

១ វ. ម. តតិយវគ្គ ៥ បណ្ណាសកំ ។



ការកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះឯង ។ ការរលត់ទៅនៃសង្ខារ ព្រោះរលត់ទៅនៃអវិជ្ជាមិនមានសេសសល់ ការរលត់ទៅនៃវិញ្ញាណ ព្រោះរលត់សង្ខារ ការរលត់ទៅនៃនាមរូប ព្រោះរលត់វិញ្ញាណ ការរលត់ទៅនៃសឡាយតនៈ ព្រោះរលត់នាមរូប ការរលត់ទៅនៃផស្សៈ ព្រោះរលត់សឡាយតនៈ ការរលត់ទៅនៃវេទនា ព្រោះរលត់ផស្សៈ ការរលត់ទៅនៃតណ្ហា ព្រោះរលត់វេទនា ការរលត់ទៅនៃឧបាទាន ព្រោះរលត់តណ្ហា ការរលត់ទៅនៃភព ព្រោះរលត់ឧបាទាន ការរលត់ទៅនៃជាតិ ព្រោះរលត់ភព ជរាមរណៈរលត់ព្រម ព្រោះរលត់ជាតិ សោកៈ បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ ក៏រមែងរលត់ទៅ ។ សេចក្តីរលត់នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះឯង ។ លុះព្រះមានព្រះភាគជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបបន្លឺនូវឧទាននេះ ក្នុងវេលានោះថា

ធម៌ទាំងឡាយ រមែងប្រាកដដល់ព្រាហ្មណ៍ អ្នកមានព្យាយាមញុំាងកិលេសឲ្យក្តៅ អ្នកដុតបង់នូវកិលេស ក្នុងកាលណា ព្រាហ្មណ៍នោះ រមែងកំចាត់បង់នូវមារ ព្រមទាំងសេនាមារ ឋិតនៅ ក្នុងកាលនោះ ដូចព្រះអាទិត្យរះឡើង ធ្វើអាកាសឲ្យភ្លឺរុងរឿង ដោយរស្មីរបស់ខ្លួន កំចាត់បង់នូវងងឹត ឋិតនៅ ដូច្នោះឯង ។ សូត្រទី ៣ ។

[៤] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ឧរុវេលាយំ វិហរតិ នជ្ជា នេរញ្ជរាយ តីរេ អជបាលនិគ្រោធេ បឋមាភិសម្ពុទ្ធោ ។ តេន ខោ បន សមយេន ភគវា សត្តាហំ ឯកបល្លង្កេន និសិន្នោ ហោតិ វិមុត្តិសុខំ បដិសំវេទី ។ អថខោ ភគវា តស្ស សត្តាហស្ស អច្ចយេន តម្ហា សមាធិម្ហា វុដ្ឋាសិ ។ អថខោ អញ្ញតរោ ហុំហុំកជាតិកោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ សោ ព្រាហ្មណោ ភគវន្តំ ឯតទវោច កិត្តាវតា នុ ខោ ភោ គោតម ព្រាហ្មណោ ហោតិ កតមេ ច បន ព្រាហ្មណករណា[១] ធម្មាតិ ។

អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

យោ ព្រាហ្មណោ ពាហិតបាបធម្មោ
និហុំហុំកោ[២] និក្កសាវោ យតត្តោ

១ ម. ព្រាហ្មណការកា ។ ២ ម. និហុហុំកោ ។ ឱ. និហុំហុំកោ ។



[៤] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ត្រាស់ដឹងជាដំបូង ទ្រង់គង់នៅក្រោមដើមអជបាលនិគ្រោធ ក្បែរឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេស ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់នៅដោយបល្ល័ង្កតែមួយ សោយវិមុត្តិសុខអស់ ១ សប្តាហ៍ ។ លុះកន្លងសប្តាហ៍នោះហើយ ទើបព្រះមានព្រះភាគ ទ្រង់ចេញអំពីសមាធិនោះ ។ គ្រានោះ ព្រាហ្មណ៍ម្នាក់ ជាហុំហុំកជាតិកៈ (មានជាតិជាអ្នកធ្វើសំឡេងគ្រោមថាហុំហុំ) ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏ឋិតនៅក្នុងទីសមគួរ ។ លុះព្រាហ្មណ៍នោះ ឋិតនៅក្នុងទីសមគួរហើយ ក៏ទូលសួរព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចំរើន បុគ្គលដែលហៅថាព្រាហ្មណ៍ ដោយហេតុដូចម្តេច មួយទៀត ធម៌អ្វីខ្លះ សម្រាប់ធ្វើបុគ្គល ឲ្យជាព្រាហ្មណ៍ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទើបបន្លឺនូវឧទាននេះ ក្នុងវេលានោះថា

ព្រាហ្មណ៍ណា មានបាបធម៌ បណ្តេញចោលហើយ មាន
សំឡេងគ្រោមថា ហុំហុំ លះចោលហើយ មានទឹកចត់
គឺកាមទិក្កិលេស លះចោលហើយ មានចិត្តសង្រួមហើយ

វេទន្តគូ វុសិតព្រហ្មចរិយោ

ធម្មេន សោ [ព្រាហ្មណោ] ព្រហ្មវាទំ វទេយ្យ (១)

យស្សុស្សទា នត្ថិ កុហិញ្ចិ លោកេតិ ។ ចតុត្ថំ ។

(៦៦) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា ច សារីបុត្តោ អាយស្មា ច មហាមោគ្គល្លានោ អាយស្មា ច មហាកស្សបោ អាយស្មា ច មហាកច្ចានោ(២) អាយស្មា ច មហាកោដ្ឋិតោ(៣) អាយស្មា ច មហាកប្បិនោ អាយស្មា ច មហាចុន្ទោ អាយស្មា ច អនុរុទ្ធោ អាយស្មា ច រេវតោ(៤) អាយស្មា ច នន្ទោ(៥) យេន ភគវា តេនុបសង្កមឹសុ ។ អទ្ទសា ខោ ភគវា តេ អាយស្មន្តេ ទូរតោ វ អាគច្ឆន្តេ ទិស្វាន ភិក្ខូ អាមន្តេសិ ឯតេ ភិក្ខវេ ព្រាហ្មណា អាគច្ឆន្តិ ឯតេ ភិក្ខវេ ព្រាហ្មណា អាគច្ឆន្តីតិ ។

១ ឱ. ម. ឧត្តានំ នត្ថិ ។ ២ ឱ. ម. មហាកច្ចាយនោ ។ ៣ ឱ. មហាកោដ្ឋិកោ ។
៤ ឱ. ឧត្តាន អាយស្មា ច រេវតោតិ នត្ថិ ។ ៥ ឱ. អានន្ទោ ។



ដល់នូវវេទ គឺមគ្គញ្ញាណ ទាំង ៤ មានមគ្គព្រហ្មចរិយធម៌ អប់រំហើយ មួយទៀត ព្រាហ្មណ៍ណា មិនមានឧស្សទៈ គឺរាគាទិកិលេស ក្នុងអារម្មណ៍បន្តិចបន្តួច ក្នុងលោក-សន្និវាស ព្រាហ្មណ៍នោះ ទើបគួរនិយាយនូវពាក្យថា ព្រាហ្មណ៍ ដោយធម៌ពិត ។ សូត្រទី ៤ ។

(៦៦) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះសារីបុត្តដ៏មានអាយុ ព្រះមហាមោគ្គល្លានដ៏មានអាយុ ព្រះមហាកស្សបដ៏មានអាយុ ព្រះមហាកច្ចានៈដ៏មានអាយុ ព្រះមហាកោដ្ឋិតៈដ៏មានអាយុ ព្រះមហាកប្បិនៈដ៏មានអាយុ ព្រះមហាចុន្ទៈដ៏មានអាយុ ព្រះអនុរុទ្ធដ៏មានអាយុ ព្រះរេវតៈដ៏មានអាយុ ព្រះនន្ទៈដ៏មានអាយុ ចូលទៅគាល់ ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ក៏បានទតឃើញពួកលោក ដ៏មានអាយុ អម្បាលនោះ ដែលកំពុងដើរមក អំពីចម្ងាយ លុះឃើញហើយ ទ្រង់ត្រាស់ប្រាប់ពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ពួកព្រាហ្មណ៍ទាំងនុ៎ះ កំពុងដើរមក ម្នាលភិក្ខុទាំងឡាយ ពួកព្រាហ្មណ៍ទាំងនុ៎ះ កំពុងដើរមក ។

ឯវំ វុត្តេ អញ្ញតរោ ព្រាហ្មណជាតិកោ ភិក្ខុ ភគវន្តំ ឯតទវោច កិត្តាវតា នុ ខោ ភន្តេ ព្រាហ្មណោ ហោតិ កតមេ ច បន ព្រាហ្មណករណា ធម្មាតិ ។

អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

ពាហិត្វា បាបកេ ធម្មេ យេ ចរន្តិ សទា សតា
ខីណសញ្ញោជនា ពុទ្ធា តេ វេ លោកស្មិ ព្រាហ្មណាតិ ។

បញ្ចមំ[១] ។

(៦៣) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អាយស្មា មហាកស្សបោ បិប្ផលិគុហាយំ វិហរតិ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ ។ អថខោ អាយស្មា មហាកស្សបោ អបរេន សមយេន តម្ហា អាពាធា វុដ្ឋាសិ ។ អថខោ អាយស្មតោ មហា-កស្សបស្ស តម្ហា អាពាធា វុដ្ឋិតស្ស ឯតទហោសិ យន្នូនាហំ រាជគហំ បិណ្ឌាយ បវិសេយ្យន្តិ ។

១. ម. បញ្ចមន្តិ ន ទិស្សតិ ។



កាលបើព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ ភិក្ខុមួយរូបមានជាតិជាព្រាហ្មណ៍ បានទូលសួរព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន បុគ្គលដែលឈ្មោះថា ព្រាហ្មណ៍ ដោយហេតុដូចម្តេច មួយទៀត ធម៌ដូចម្តេចខ្លះ ដែលធ្វើបុគ្គលឲ្យ ជាព្រាហ្មណ៍ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវបញ្ហានុ៎ះហើយ ទើបទ្រង់បន្លឺនូវឧទាននេះក្នុងវេលានោះថា

បុគ្គលណា បានបណ្តាត់បង់នូវធម៌ដ៏លាមក មានស្មារតីប្រព្រឹត្ត
ទៅគ្រប់កាល ជាអ្នកអស់សញ្ញោជនៈ (ត្រាស់ដឹងនូវសច្ចធម៌)
បុគ្គលនោះឯង ឈ្មោះថា ព្រាហ្មណ៍ ក្នុងលោក ។ សូត្រទី៥ ។

(៦៣) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន កលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះមហាកស្សបមានអាយុ គង់នៅក្នុងបិប្ផលិគុហា ជាអ្នកមានអាពាធ ប្រកបដោយទុក្ខឈឺធ្ងន់ ។ លុះក្នុងសម័យជាន់ក្រោយមក ព្រះមហាកស្សបមានអាយុ [illegible]ស្បើយចាកអាពាធនោះ ។ លុះព្រះមហា-កស្សបជាសះស្បើយចាកអាពាធនោះហើយ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ មានតែអាត្មាអញ ចូលទៅបិណ្ឌបាត ក្នុងក្រុងរាជគ្រឹះចុះ ។

តេន ខោ បន សមយេន បញ្ចមត្តានិ ទេវតាសតានិ ឧស្សុក្កំ អាបន្នានិ ហោន្តិ អាយស្មតោ មហាកស្សបស្ស បិណ្ឌបាតបដិលាភាយ ។ អថខោ អាយស្មា មហាកស្សបោ តានិ បញ្ចមត្តានិ ទេវតាសតានិ បដិក្ខិបិត្វា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ រាជគហំ បិណ្ឌាយ បាវិសិ យេន ទលិទ្ទវិសិខា កបណវិសិខា បេសការវិសិខា ។ អទ្ទសា ខោ ភគវា អាយស្មន្តំ មហាកស្សបំ រាជគហេ បិណ្ឌាយ ចរន្តំ យេន ទលិទ្ទវិសិខា កបណវិសិខា បេសការវិសិខា ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

អនញ្ញបោសិមញ្ញាតំ(១) ទន្តំ សារេ បតិដ្ឋិតំ
ខីណាសវំ វន្តទោសំ តមហំ ព្រូមិ ព្រាហ្មណន្តិ ។
ឆដ្ឋំ(២) ។

១ ម. អនញ្ញបោសិំ អញ្ញាតំ ។ ឧ. អនញ្ញបោសិំ អញ្ញាតំ ។ ២-ម. ឆដ្ឋំ ឆដ្ឋំ ។





សម័យនោះឯង ពួកទេវតាចំនួន ៥០០ ប្រឹងខ្នះខ្នែង ដើម្បីឲ្យព្រះមហាកស្សបដ៏មានអាយុ បានបិណ្ឌបាត ។ លំដាប់នោះ ព្រះមហាកស្សបៈដ៏មានអាយុ បានហាមឃាត់ពួកទេវតាទាំង ៥០០ នោះ ហើយស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ចូលទៅបិណ្ឌបាត ក្នុងក្រុងរាជគ្រឹះ តាមច្រកល្ហករបស់មនុស្សកំសត់ មនុស្សកំព្រា និងជាងតម្បាញ ក្នុងបុព្វណ្ហសម័យ ។ ព្រះមានព្រះភាគ បានឃើញព្រះមហាកស្សបដ៏មានអាយុ កំពុងដើរបិណ្ឌបាត ក្នុងក្រុងរាជគ្រឹះ តាមច្រក របស់មនុស្សកំសត់ មនុស្សកំព្រា និងជាងតម្បាញ ។ លុះព្រះមានព្រះភាគ បានជ្រាបច្បាស់ នូវសេចក្តីនុ៎ះហើយ ទើបបន្លឺនូវឧទាននេះ ក្នុងវេលានោះថា

បុគ្គលដែលជាអ្នកមិនចិញ្ចឹមអ្នកដទៃ អ្នកដែលគេស្គាល់ច្បាស់ អ្នកទូន្មានខ្លួន
តាំងនៅ ក្នុងធម៌ជាខ្លឹម អ្នកអស់អាសវៈ អ្នកមានទោសៈខ្ជាក់ចោល
តថាគតហៅ បុគ្គលនោះ ថាជាព្រាហ្មណ៍ ។ សូត្រទី៦ ។

[៦៦] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា បាវាយំ[១] វិហរតិ អជកលាបកេ ចេតិយេ អជកលាបកស្ស យក្ខស្ស ភវនេ ។ តេន ខោ បន សមយេន ភគវា រត្តន្ធការតិមិសាយំ អព្ភោកាសេ និសិន្នោ ហោតិ ទេវោ ច ឯកមេកំ ផុសាយតិ ។ អថខោ អជកលាបកោ យក្ខោ ភគវតោ ភយំ ឆម្ភិតត្តំ លោមហំសំ ឧប្បាទេតុកាមោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតោ អវិទូរេ តិក្ខត្តុំ អក្កុលោ បក្កុលោ[២] អក្កុលបក្កុលិកំ អកាសិ ឯសោ តេ សមណ បិសាចោតិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

យទា សកេសុ ធម្មេសុ បារគូ ហោតិ ព្រាហ្មណោ
អថ ឯតំ[៣] បិសាចញ្ច បក្កុលញ្ចាតិ វត្តតីតិ ។

សត្តមំ[៤] ។

១ ឱ. បាដលិយំ ។ ២ ឱ ម. បក្កុលកន្តិ បាឋោ ទិស្សតិ ។ ៣ ឱ.ម. ឯតំ ។ ៤ ឱ.ម. សត្តមន្តិ នត្ថិ ។



(៦៦) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ ក្នុងអជកលាបកចេតិយ ជាលំនៅនៃអជកលាបកយក្ស ជិតក្រុងបាវា ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងទីវាល នៅវេលាយប់ដែលងងឹតស្លុង ទាំងភ្លៀង ក៏កំពុងធ្លាក់រលឹមស្រិច ១ ៗ ។ លំដាប់នោះ អជកលាបកយក្ស មានបំណងនឹងធ្វើព្រះមានព្រះភាគឲ្យខ្លាច តក់ស្លុតព្រឺព្រោមរោម បានចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏បានសំដែងការបន្លាច ធ្វើសំឡេងសន្ធាប់ខ្លាំង ១ គស់ក៏ៈ ៣ ដង ជិតព្រះមានព្រះភាគថា នែព្រះសមណៈ ខ្មោចបិសាច ( ឈរតាទីមុខ ) ចំពោះលោកហើយ ។ លុះព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់សេចក្តីនុះហើយ ទើបទ្រង់បន្លឺឧទាននេះក្នុងវេលានោះថា

កាលណា បុគ្គលណាដល់ត្រើយក្នុងសភាវធម៌[១]ជាគ្រឿងខ្លួន ក្នុងកាល
នោះ បុគ្គលនោះឈ្មោះថា ព្រាហ្មណ៍ រមែងប្រសើរកន្លងបិសាច
ផង នូវសំឡេងសន្ធាប់ដ៏យ៉ាងនេះ ក្នុងកាលនោះ ។ សូត្រទី ៧ ។

១ កុសលធម៌ ជាគ្រឿងយកឹង មានសីល សមាធិ បញ្ញា ជាដើម ដែលជាធម៌ប្រយោជន៍ដល់ខ្លួនប្រតិបត្តិ ហៅថា សកធម្ម (ធម៌របស់ខ្លួន) ។ អកុសលធម៌ មានរាគៈ ទោសៈ មោហៈ ជាដើម ដែលជាគ្រឿងប្រយោជន៍ឲ្យវិនាស ហៅថា បរធម្ម (ធម៌ដទៃ) ។ អដ្ឋកថា ។

(៤៨) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា សង្គាមជិ សាវត្ថឹ អនុប្បត្តោ ហោតិ ភគវន្តំ ទស្សនាយ ។ អស្សោសិ ខោ អាយស្មតោ សង្គាមជិស្ស បុរាណទុតិយិកា អយ្យោ កិរ សង្គាមជិ សាវត្ថឹ អនុប្បត្តោតិ ។ សា ទារកំ អាទាយ ជេតវនំ អគមាសិ ។ តេន ខោ បន សមយេន អាយស្មា សង្គាមជិ អញ្ញតរស្មឹ រុក្ខមូលេ ទិវាវិហារេ[១] និសិន្នោ ហោតិ ។ អថខោ អាយស្មតោ សង្គាមជិស្ស បុរាណទុតិយិកា យេនាយស្មា សង្គាមជិ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ សង្គាមជឹ ឯតទវោច ខុទ្ទបុត្តំ ហិ សមណ បោស មន្តិ ។ ឯវំ វុត្តេ អាយស្មា សង្គាមជិ តុណ្ហី អហោសិ ។ ទុតិយម្បិ ខោ អាយស្មតោ សង្គាមជិស្ស បុរាណទុតិយិកា អាយស្មន្តំ សង្គាមជឹ ឯតទវោច ខុទ្ទបុត្តំ ហិ សមណ បោស មន្តិ ។

១ ម, ឧ. ទិវាវិហារំ ។



( ៤៨ ) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះ ព្រះសង្គាមជិដ៏មានអាយុ បានមកនគរសាវត្ថី ដើម្បីជួប ព្រះមានព្រះភាគ ។ ឯបុរាណទុតិយិកា របស់ព្រះសង្គាមជិដ៏មានអាយុ បានឮដំណឹងថា ឮថា ព្រះសង្គាមជិ មកដល់នគរសាវត្ថីហើយ ។ នាងនោះបាននាំទារកទៅឯវត្តព្រៃជេតពន ។ សម័យនោះ ព្រះសង្គាម-ជិដ៏មានអាយុ កំពុងអង្គុយនៅ ក្នុងវេលាថ្ងៃ ក្បែរគល់ឈើមួយដើម ។ លំដាប់នោះ បុរាណទុតិយិកា របស់ព្រះសង្គាមជិដ៏មានអាយុ បានចូលទៅរកព្រះសង្គាមជិដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏និយាយនឹងព្រះសង្គាមជិ ដ៏មានអាយុថា បពិត្រសមណៈ សូមលោកចិញ្ចឹមខ្ញុំ ទាំងកូនតូចផង ។ កាលបើបុរាណទុតិយិកានោះ ពោលយ៉ាងនេះហើយ ព្រះសង្គាមជិដ៏មានអាយុនៅស្ងៀម ។ បុរាណទុតិយិកា របស់ព្រះសង្គាមជិដ៏មានអាយុ បានពោលនឹងព្រះសង្គាមជិដ៏មានអាយុ ជាគំរប់ពីរដង យ៉ាងនេះទៀតថា បពិត្រសមណៈ សូមលោកចិញ្ចឹមខ្ញុំ ទាំងកូនតូចផង ។

ទុតិយម្បិ ខោ អាយស្មា សត្តុមជិ តុណ្ហី អហោសិ ។ តតិយម្បិ ខោ អាយស្មតោ សត្តុមជិស្ស បុណ្ណទុតិយិកា អាយស្មន្តំ សត្តុមជឹ ឯតទវោច ខុទ្ទបុត្តំ ហិ សមណ បោស មន្តិ ។ តតិយម្បិ ខោ អាយស្មា សត្តុមជិ តុណ្ហី អហោសិ ។ អថខោ អាយស្មតោ សត្តុមជិស្ស បុណ្ណទុតិយិកា តំ ធារកំ អាទាយ អាយស្មតោ សត្តុមជិស្ស បុរតោ និក្ខិបិត្វា បក្កាមិ ឯសោ តេ សមណ បុត្តោ បោស នន្តិ ។ អថខោ អាយស្មា សត្តុមជិ តំ ធារកំ នេវ អភិលោកេសិ នាបិ អាលបិ ។ អថខោ អាយស្មតោ សត្តុមជិស្ស បុណ្ណទុតិយិកា អវិទូរេ[១] គន្ត្វា អបលោកេន្តី អទ្ទសាយស្មន្តំ សត្តុមជឹ តំ ធារកំ នេវ អភិលោកេន្តំ នាបិ អាលបន្តំ ទិស្វានស្សា ឯតទហោសិ ន ចាយំ សមណោ បុត្តេនបិ អត្ថិកោតិ ។ តតោ បដិនិវត្តិត្វា ធារកំ អាទាយ បក្កាមិ ។ អទ្ទសា ខោ ភគវា ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន អាយស្មតោ សត្តុមជិស្ស បុណ្ណទុតិយិកាយ ឯវរូបំ វិប្បការំ ។

១ ម. អវិទូរំ ។



ព្រះសត្តុមជិដ៏មានអាយុ នៅស្ងៀមអស់វារៈពីរដង ។ បុណ្ណទុតិយិកា របស់សត្តុមជិដ៏មានអាយុ ក៏ទទូចនិយាយនឹងព្រះសត្តុមជិដ៏មានអាយុ ជាគំរប់បីដងថា បពិត្រសមណៈ សូមលោកចិញ្ចឹមខ្ញុំនិងកូនតូចផង ។ ព្រះសត្តុមជិដ៏មានអាយុ ក៏នៅស្ងៀមអស់វារៈបីដង ។ លំដាប់នោះ បុណ្ណទុតិយិកា របស់ព្រះសត្តុមជិដ៏មានអាយុ ទើបយកទារកតូចនោះ ទៅដាក់អំពីមុខព្រះសត្តុមជិដ៏មានអាយុ រួចនិយាយថា បពិត្រសមណៈ នេះជាកូនប្រុសរបស់លោក លោកចិញ្ចឹមវាផងចុះ រួចហើយក៏ដើរចេញទៅ ។ តែព្រះសត្តុមជិដ៏មានអាយុមិនមើលមើល មិនហៅគេឡើយកូនតូចនោះសោះ ។ លំដាប់នោះ បុណ្ណទុតិយិកា របស់ព្រះសត្តុមជិដ៏មានអាយុ កាលដើរចេញទៅមិនឆ្ងាយប៉ុន្មាន ក៏ងាកមើលមកឃើញព្រះសត្តុមជិដ៏មានអាយុ ដែលមិនមើលមើល មិនហៅកូនតូចនោះសោះ ស្រីនោះលុះឃើញហើយ ក៏មានសេចក្ដីត្រិះរិះយ៉ាងនេះថា សមណៈនេះមិនត្រូវការដោយកូនប្រុសទេតើ ។ បុណ្ណទុតិយិកានោះ ក៏ត្រឡប់អំពីនោះ មកយកកូនតូចនោះហើយដើរចេញទៅ ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញនូវការចំឡែក បែបយ៉ាងនេះ នៃបុណ្ណទុតិយិកា របស់ព្រះសត្តុមជិដ៏មានអាយុ ដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងចក្ខុរបស់មនុស្សធម្មតា ។

អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

អាយន្តឹ នាភិនន្ទតិ បក្កមន្តឹ(១) ន សោចតិ
សង្គា សង្គាមជឹ មុត្តំ តមហំ ព្រូមិ ព្រាហ្មណន្តិ
អដ្ឋមំ(២) ។

(៤៦) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា គយាយំ វិហរតិ គយាសីសេ ។ តេន ខោ បន សមយេន សម្ពហុលា ជដិលា សីតាសុ ហេមន្តិកាសុ រត្តីសុ អន្តរដ្ឋកេ ហិមបាតសមយេ គយាយំ ឧម្មុជ្ជន្តិបិ និម្មុជ្ជន្តិបិ ឧម្មុជ្ជនិម្មុជ្ជម្បិ ករោន្តិ ឱសិញ្ចន្តិបិ អគ្គឹបិ ជុហន្តិ ឥមិនា សុទ្ធីតិ ។ អទ្ទសា ខោ ភគវា តេ សម្ពហុលេ ជដិលេ សីតាសុ ហេមន្តិកាសុ រត្តីសុ អន្តរដ្ឋកេ ហិមបាតសមយេ គយាយំ ឧម្មុជ្ជន្តេបិ និម្មុជ្ជន្តេបិ ឧម្មុជ្ជនិម្មុជ្ជម្បិ ករោន្តេ ឱសិញ្ចន្តេបិ អគ្គឹបិ ជុហន្តេ ឥមិនា សុទ្ធីតិ ។

១ ម. បក្កមន្តំ ។ ២ ឱ. ម. អដ្ឋមំ [illegible] ។



លុះព្រះមានព្រះភាគ ជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទើបបន្លឺនូវឧទាននេះ ក្នុងវេលានោះថា

ភិក្ខុណា មិនត្រេកត្រអាលនឹងស្រ្តីដែលមករក មិនស្តាយស្រ្តីដែលចេញចេញទៅ តថាគតហៅបុគ្គលនោះថាជាព្រាហ្មណ៍ ដូចជាភិក្ខុឈ្មោះសង្គាមជិ ដែលរួចស្រឡះហើយចាកគ្រឿងជាប់ គឺកិលេស ។

សូត្រទី៨ ។

(៤៦) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងគយាសីសៈប្រទេស ទៀបទន្លេគយា ។ សម័យនោះឯង ពួកជដិលច្រើនរូប នាំគ្នាងើបខ្លះ មុជខ្លះ ងើបមុជ ៗ ខ្លះ ស្រោចទឹកខ្លះ បូជាភ្លើងខ្លះ ទៀបកំពង់ឈ្មោះគយា ក្នុងសម័យជាទីធ្លាក់ចុះនៃទឹកសន្សើម រវាង៨ថ្ងៃ(១) ក្នុងវេលាយប់ដ៏ត្រជាក់ នៃហេមន្តរដូវ ដោយសេចក្តីគិតឃើញថា សេចក្តីបរិសុទ្ធិ ដោយការធ្វើនេះ ។ ព្រះមានព្រះភាគ ក៏បានឃើញពួកជដិល ជាច្រើនទាំងនោះ ដែលកំពុងងើបខ្លះ មុជខ្លះ ងើបមុជ ៗ ខ្លះ ស្រោចទឹកខ្លះ បូជាភ្លើងខ្លះ ទៀបកំពង់ឈ្មោះគយា ក្នុងសម័យជាទីធ្លាក់ចុះនៃទឹកសន្សើម រវាង៨ថ្ងៃ ក្នុងវេលាយប់ ដ៏ត្រជាក់នៃហេមន្តរដូវ ដោយសេចក្តីគិតឃើញថា សេចក្តីបរិសុទ្ធិ ដោយការធ្វើនេះ ។

១ ពីថ្ងៃខាងចុងខែមាឃ ៤ ថ្ងៃ ខាងដើមខែផល្គុន ៤ ថ្ងៃ រួមជា ៨ ថ្ងៃ ។

អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

ន ឧទកេន សុចី ហោតិ ពហ្វេត្ថ ន្ហាយតី ជនោ យម្ហិ សច្ចញ្ច ធម្មោ ច សោ សុចី សោ ច ព្រាហ្មណោតិ ។ នវមំ[១] ។

(៦៧) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ពាហិយោ ទារុចីរិយោ សុប្បារកេ[២] បដិវសតិ សមុទ្ទតីរេ សក្កតោ ហោតិ គរុកតោ មានិតោ បូជិតោ អបចិតោ លាភី ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ។ អថខោ ពាហិយស្ស ទារុចីរិយស្ស រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ យេ ខោ កេចិ លោកេ អរហន្តោ វា អរហត្តមគ្គំ វា សមាបន្នា អហំ តេសំ អញ្ញតរោ ។

១ ឱ. ម. នវមំ ។ ២ ម. សុប្បារកេ ។



លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបបន្លឺឧទាននេះ ក្នុងវេលានោះថា

បុគ្គលមិនមែនស្អាត ព្រោះទឹកទេ អ្នកផងច្រើនគ្នាមែនងូតទឹកក្នុងទីនេះ សច្ចៈ[១] ១ ធម្មៈ[២] ១ (មាននៅ) ក្នុងបុគ្គលណា បុគ្គលនោះទើបឈ្មោះថាជាអ្នកស្អាតផង ឈ្មោះថាជាព្រាហ្មណ៍ផង ។ សូត្រទី ៩ ។

(៦៧) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ។ សម័យនោះឯង ពាហិយទារុចីរិយបុរស (អ្នកស្លៀកដណ្តប់សំពត់សំបកឈើ ឈ្មោះពាហិយៈ) អាស្រ័យនៅទៀបឆ្នេរសមុទ្រ ឈ្មោះសុប្បារកៈ ជាអ្នកដែលគេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង បាននូវចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ។ កាលពាហិយទារុចីរិយបុរស ចូលសម្ងំក្នុងទីស្ងាត់ ស្រាប់តែមានសេចក្តីត្រិះរិះគិតឡើងក្នុងចិត្តយ៉ាងនេះថា ពួកជនណាមួយក្នុងលោកជាព្រះអរហន្ត ឬសម្រេចអរហត្តមគ្គ បណ្តាអរហន្តទាំងនោះ ខ្លួនអញជាអរហន្តមួយដែរ ។

១ បានដល់វចីសច្ចៈ និងវិរតិសច្ចៈ ឬញាណសច្ចៈ និងបរមត្ថសច្ចៈ ។
២ បានដល់អរិយមគ្គធម៌ និងអរិយផលធម៌ ។ អដ្ឋកថា ។

អថខោ ពាហិយស្ស ទារុចីរិយស្ស បុរាណសាលោហិតា ទេវតា អនុកម្បិកា អត្ថកាមា ពាហិយស្ស ទារុចីរិយស្ស ចេតសា ចេតោបរិវិតក្កមញ្ញាយ យេន ពាហិយោ ទារុចីរិយោ តេនុបសង្កមិ ឧបសង្កមិត្វា ពាហិយំ ទារុចីរិយំ ឯតទវោច នេវ ខោ ត្វំ ពាហិយ អរហា នាបិ អរហត្តមគ្គំ វា សមាបន្នោ សាបិ តេ បដិបទា នត្ថិ យាយ ត្វំ អរហា វា អស្សសិ អរហត្តមគ្គំ វា សមាបន្នោតិ ។ អថ[១] កេ ចរហិ សទេវកេ លោកេ អរហន្តោ វា អរហត្តមគ្គំ វា សមាបន្នាតិ ។ អត្ថិ ពាហិយ ឧត្តរេសុ ជនបទេសុ សាវត្ថី នាម នគរំ តត្ថ សោ ភគវា ឯតរហិ វិហរតិ អរហំ សម្មាសម្ពុទ្ធោ ។ សោ ហិ ពាហិយ ភគវា អរហា ចេវ អរហត្តាយ ច ធម្មំ ទេសេតីតិ ។ អថខោ ពាហិយោ ទារុចីរិយោ តាយ ទេវតាយ សំវេជិតោ តាវទេវ សុប្បារកម្ហា[២] បក្កាមិ សព្វត្ថ ឯករត្តិបរិវាសេន យេន ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ[៣] តេនុបសង្កមិ ។

១ ម. អថ កោ ចរហិ ។ ២ ឱ. សុប្បារកម្ហា ។ ម. សុប្បារកម្ហា ។ ៣ ម. យេន សាវត្ថិ ជេតវនំ អនាថបិណ្ឌិកស្សារាមោ [illegible] ។





លំដាប់នោះ ទេវតាដែលជាសាលោហិតក្នុងកាលមុន របស់ពាហិយទារុចីរិយបុគ្គល ជាអ្នកអនុគ្រោះ ប្រាថ្នាប្រយោជន៍ បានដឹងច្បាស់នូវសេចក្តីត្រិះរិះក្នុងចិត្ត ដោយចិត្តរបស់ពាហិយទារុចីរិយបុគ្គល ក៏ចូលទៅរកពាហិយទារុចីរិយបុគ្គល លុះចូលទៅដល់ហើយ ក៏និយាយនឹងពាហិយទារុចីរិយបុគ្គលយ៉ាងនេះថា នែពាហិយៈ អ្នកមិនមែនជាព្រះអរហន្តទេ ទាំងមិនទាន់សម្រេចអរហត្តមគ្គទេ ទាំងអ្នកមិនមានបដិបទាដែលនាំឲ្យបានជាព្រះអរហន្ត ឬសម្រេចអរហត្តមគ្គទេ ។ ពាហិយទារុចីរិយៈ សួរថា បើដូច្នោះ ក្នុងកាលឥឡូវនេះ ក្នុងលោកព្រមទាំងទេវលោក តើជនណា ជាអរហន្ត ឬបានសម្រេចអរហត្តមគ្គ បានដែរ ។ ទេវតាឆ្លើយថា ម្នាលពាហិយៈ មាន ក្នុងជនបទខាងជើង មានក្រុងមួយឈ្មោះសាវត្ថី ឥឡូវនេះព្រះមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់គង់នៅក្នុងក្រុងសាវត្ថីនោះ ។ ម្នាលពាហិយៈ ព្រះមានព្រះភាគអង្គនោះឯង ជាព្រះអរហន្តផង ទ្រង់សំដែងធម៌ ដើម្បីអរហត្តផង ។ លំដាប់នោះ ពាហិយទារុចីរិយបុគ្គល ដែលទេវតានោះធ្វើឲ្យតក់ស្លុត ក៏ស្រេចតែចេញអំពីកំពង់សមុទ្រឈ្មោះ សុប្បារកៈក្នុងខណៈនោះភ្លាម ដោយការនៅតែក្នុងទីផ្ទុំក្នុងអស់ ១ យប់ ក៏បានទៅដល់ព្រះមានព្រះភាគ ដែលកំពុងគង់ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។

(៤៨) តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ អព្ភោកាសេ ចង្កមន្តិ ។ អថខោ ពាហិយោ ទារុចីរិយោ យេន ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា តេ ភិក្ខូ ឯតទវោច កហំ នុ ខោ ភន្តេ ឯតរហិ ភគវា វិហរតិ អរហំ សម្មាសម្ពុទ្ធោ ទស្សនកាមម្ហា មយំ តំ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធន្តិ ។ អន្តរឃរំ បវិដ្ឋោ ខោ ពាហិយ ភគវា បិណ្ឌាយាតិ ។ អថខោ ពាហិយោ ទារុចីរិយោ តរមានរូបោ ជេតវនា និក្ខមិត្វា សាវត្ថឹ បវិសិត្វា អទ្ទស ភគវន្តំ សាវត្ថិយំ បិណ្ឌាយ ចរន្តំ បាសាទិកំ បសាទនីយំ[១] សន្តិន្ទ្រិយំ សន្តមានសំ ឧត្តមទមថសមថំ អនុប្បត្តំ ទន្តំ គុត្តំ យតិន្ទ្រិយំ[២] នាគំ ទិស្វាន យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតោ បាទេ សិរសា និបតិត្វា ភគវន្តំ ឯតទវោច ទេសេតុ មេ ភន្តេ ភគវា ធម្មំ ទេសេតុ សុគតោ ធម្មំ យំ មមស្ស ទីឃរត្តំ ហិតាយ សុខាយាតិ ។

---

១ ឱ. បសាទិយំ ។ ២ ឱ. សន្តិន្ទ្រិយំ ។



[៤៨] សម័យនោះ ពួកភិក្ខុច្រើនរូប កំពុងដើរចង្ក្រម ក្នុងទីវាល ។ លំដាប់នោះ ពាហិយទារុចីរិយបុរស ក៏ចូលទៅរកពួកភិក្ខុ លុះចូលទៅដល់ហើយ ក៏បានសួរភិក្ខុទាំងនោះដូច្នេះថា បពិត្រលោកដ៏ចំរើនទាំងឡាយ ឥឡូវនេះព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ គង់នៅទីណា យើងមានបំណងនឹងចូលទៅ ដើម្បីជួបព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។ ពួកភិក្ខុតបថា ម្នាលពាហិយៈ ព្រះមានព្រះភាគចូលកាន់ចន្លោះស្រុក ដើម្បីបិណ្ឌបាតទៅហើយ ។ លំដាប់នោះ ពាហិយទារុចីរិយបុរស ក៏មានដំណើរប្រញាប់ចេញពីវត្តជេតពន ចូលទៅកាន់សាវត្ថី បានឃើញព្រះមានព្រះភាគ កំពុងដើរបិណ្ឌបាត ក្នុងក្រុងសាវត្ថី ជាទីតាំងនៃសេចក្តីជ្រះថ្លា គួរជ្រះថ្លា មានឥន្ទ្រិយស្ងប់ មានព្រះទ័យស្ងប់ ទ្រង់បានដល់នូវការហាត់ពត់ គឺការស្ងប់រម្ងាប់ដ៏ឧត្តម ទ្រង់បានទូន្មាន គ្រប់គ្រង សង្រួមឥន្ទ្រិយ ជាកុញ្ជរៈ គឺជាព្រះពុទ្ធដ៏ប្រសើរ លុះឃើញហើយ ក៏ចូលទៅរកព្រះមានព្រះភាគ ឱនសិរ្សៈចុះក្រាប ព្រះបាទ នៃព្រះមានព្រះភាគ ហើយក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ សំដែងធម៌ប្រោសខ្ញុំព្រះអង្គ សូមព្រះសុគតសំដែងធម៌ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលដ៏វែង ដល់ខ្ញុំព្រះអង្គផង ។

(៦៨) ឯវំ វុត្តេ ភគវា ពាហិយំ ទារុចីរិយំ ឯតទវោច អកាលោ ខោ តាវ ពាហិយ អន្តរឃរំ បវិដ្ឋម្ហា បិណ្ឌាយាតិ ។ ទុតិយម្បិ ខោ ពាហិយោ ទារុចីរិយោ ភគវន្តំ ឯតទវោច ទុជ្ជានំ ខោ បនេតំ ភន្តេ ភគវតោ វា ជីវិតន្តរាយានំ មយ្ហំ វា ជីវិតន្តរាយានំ ទេសេតុ មេ ភន្តេ ភគវា ធម្មំ ទេសេតុ សុគតោ ធម្មំ យំ មមស្ស ទីឃរត្តំ ហិតាយ សុខាយាតិ ។ ទុតិយម្បិ ខោ ភគវា ពាហិយំ ទារុចីរិយំ ឯតទវោច អកាលោ ខោ តាវ ពាហិយ អន្តរឃរំ បវិដ្ឋម្ហា បិណ្ឌាយាតិ ។ តតិយម្បិ ខោ ពាហិយោ ទារុចីរិយោ ភគវន្តំ ឯតទវោច ទុជ្ជានំ ខោ បនេតំ ភន្តេ ភគវតោ វា ជីវិតន្តរាយានំ មយ្ហំ វា ជីវិតន្តរាយានំ ទេសេតុ មេ ភន្តេ ភគវា ធម្មំ ទេសេតុ សុគតោ ធម្មំ យំ មមស្ស ទីឃរត្តំ ហិតាយ សុខាយាតិ ។



(៦៨) កាលពាហិយទារុចីរិយបុរស អាគតជា យ៉ាងនេះហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងពាហិយទារុចីរិយបុរសដូច្នេះថា ម្នាលពាហិយៈ ឈប់សិន កាលនេះជាកាលមិនគួរ ព្រោះតថាគតចូលទៅកាន់ចន្លោះផ្ទះដើម្បីបិណ្ឌបាត ។ ពាហិយទារុចីរិយបុរស ទូលព្រះមានព្រះភាគជាគំរប់ពីរដងយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ដំណើរប្រព្រឹត្តទៅនៃជីវិតន្តរាយ របស់ព្រះមានព្រះភាគ ឬជីវិតន្តរាយ របស់ខ្ញុំព្រះអង្គ ដឹងបានដោយក្រណាស់ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគសំដែងធម៌ប្រោសខ្ញុំព្រះអង្គ សូមព្រះសុគតសំដែងធម៌ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលដ៏វែង ដល់ខ្ញុំព្រះអង្គឲ្យបាន ។ ព្រះមានព្រះភាគបានត្រាស់នឹងទារុចីរិយបុរស អស់វារៈគំរប់ពីរដង យ៉ាងនេះថា ម្នាលពាហិយៈ ឈប់សិន កាលនេះជាកាលមិនគួរ ព្រោះតថាគតចូលទៅកាន់ចន្លោះផ្ទះ បិណ្ឌបាតសិន ។ ពាហិយទារុចីរិយបុរស ទូលព្រះមានព្រះភាគ អស់វារៈបីដង យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ដំណើរប្រព្រឹត្តទៅនៃជីវិតន្តរាយ របស់ព្រះមានព្រះភាគ ឬជីវិតន្តរាយ របស់ខ្ញុំព្រះអង្គ ដឹងបានដោយក្រណាស់ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ សំដែងធម៌ប្រោសខ្ញុំព្រះអង្គ សូមព្រះសុគតសំដែងធម៌ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលដ៏វែង ដល់ខ្ញុំព្រះអង្គឲ្យបាន ។

តស្មាតិហ តេ ពាហិយ ឯវំ សិក្ខិតព្វំ ទិដ្ឋេ ទិដ្ឋមត្តំ ភវិស្សតិ សុតេ សុតមត្តំ ភវិស្សតិ មុតេ មុតមត្តំ ភវិស្សតិ វិញ្ញាតេ វិញ្ញាតមត្តំ ភវិស្សតីតិ ឯវញ្ហិ តេ ពាហិយ សិក្ខិតព្វំ ។ យតោ ខោ តេ ពាហិយ ទិដ្ឋេ ទិដ្ឋមត្តំ ភវិស្សតិ សុតេ សុតមត្តំ ភវិស្សតិ មុតេ មុតមត្តំ ភវិស្សតិ វិញ្ញាតេ វិញ្ញាតមត្តំ ភវិស្សតិ តតោ ត្វំ ពាហិយ នត្ថិ យតោ ត្វំ ពាហិយ នេត្ថិ (១) តតោ ត្វំ ពាហិយ នេវិធ ន ហុរំ ន ឧភយមន្តរេ (២) ឯសេវន្តោ ទុក្ខស្សាតិ ។ អថខោ ពាហិយស្ស ទារុចីរិយស្ស ភគវតោ ឥមាយ សង្ខិត្តាយ ធម្មទេសនាយ តាវទេវ អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចិ ។

១. តតោ ត្វំ ពាហិយ ន តត្ថ យតោ ត្វំ ពាហិយ នេវត្ថាតិ ទិស្សន្តិ ។ ម. តតោ ត្វំ ពាហិយ ន តេន យតោ ត្វំ ពាហិយ ន តេន តតោ ត្វំ ពាហិយ ន តត្ថ យតោ ត្វំ ពាហិយ ន តត្ថាតិ អធិ ទិស្សន្តិ ។ ២ ឥ. ម. ឧភយមន្តរេន ។



ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលពាហិយៈ ព្រោះហេតុនោះ អ្នកគួរសិក្សា យ៉ាងនេះថា រូបារម្មណ៍ ដែលអ្នកឃើញហើយ គ្រាន់តែជារូបារម្មណ៍ដែលឃើញហើយ សទ្ទារម្មណ៍ ដែលអ្នកឮហើយ គ្រាន់តែជាសទ្ទារម្មណ៍ដែលឮហើយ គន្ធៈរសៈផោដ្ឋព្វារម្មណ៍ ដែលប៉ះពាល់ហើយ គ្រាន់តែជាអារម្មណ៍ ដែលប៉ះពាល់ហើយ ធម្មារម្មណ៍ដែលអ្នកដឹងហើយ គ្រាន់តែ ជាធម្មារម្មណ៍ ដែលដឹងហើយ ម្នាលពាហិយៈ អ្នកគប្បីសិក្សា យ៉ាងនេះឯង ។ ម្នាលពាហិយៈ រូបារម្មណ៍ដែលអ្នកឃើញហើយ គ្រាន់តែ ជារូបារម្មណ៍ ដែលឃើញហើយ សទ្ទារម្មណ៍ ដែលអ្នកឮហើយ គ្រាន់តែ ជាសទ្ទារម្មណ៍ ដែលឮហើយ គន្ធៈរសៈផោដ្ឋព្វារម្មណ៍ ដែលអ្នកប៉ះពាល់ហើយ គ្រាន់តែជាអារម្មណ៍ដែលប៉ះពាល់ហើយ ធម្មារម្មណ៍ ដែលអ្នកដឹងហើយ គ្រាន់តែជាធម្មារម្មណ៍ ដែលដឹងហើយ ព្រោះហេតុណា ម្នាលពាហិយៈ ព្រោះហេតុនោះ អ្នកនឹងមិនមាន ម្នាលពាហិយៈ អ្នកនឹងមិនមាន ព្រោះហេតុណា ម្នាលពាហិយៈ ព្រោះហេតុនោះ អ្នកនឹងមិនមានក្នុងលោកនេះ នឹងកពុង នឹងមិនមានក្នុងចន្លោះ នៃលោកទាំងពីរ នេះឯងជាទីបំផុតនៃទុក្ខ ។ គ្រានោះ ចិត្តនៃពាហិយទារុចីរិយបុរស ផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនមានប្រកាន់ ក្នុងខណៈនោះឯង ដោយធម្មទេសនាសង្ខេប របស់ព្រះមានព្រះភាគនេះ ។

អថខោ ភគវា ពាហិយំ ទារុចីរិយំ ឥមិនា សង្ខិត្តេន ធម្មេន ឱវទិត្វា បក្កាមិ ។

(៨០) អថខោ អចិរបក្កន្តស្ស ភគវតោ ពាហិយំ ទារុចីរិយំ គាវី តរុណវច្ឆា អធិបតិត្វា ជីវិតា វោរោបេសិ ។ អថខោ ភគវា សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ នគរម្ហា និក្ខមិត្វា អទ្ទស ពាហិយំ ទារុចីរិយំ កាលកតំ ទិស្វាន ភិក្ខូ អាមន្តេសិ គណ្ហថ ភិក្ខវេ ពាហិយស្ស ទារុចីរិយស្ស សរីរកំ មញ្ចកំ អារោបេត្វា នីហរិត្វា ឈាបេថ ថូបញ្ចស្ស ករោថ សព្រហ្មចារី វោ ភិក្ខវេ កាលកតោតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បដិស្សុត្វា ពាហិយស្ស ទារុចីរិយស្ស សរីរកំ មញ្ចកំ អារោបេត្វា នីហរិត្វា ឈាបេត្វា ថូបញ្ចស្ស ករិត្វា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា[1] ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ ទឌ្ឍំ ភន្តេ ពាហិយស្ស ទារុចីរិយស្ស សរីរំ ថូបោ ចស្ស កតោ តស្ស កា គតិ កោ អភិសម្បរាយោតិ ។

១ ម. ឆ. ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ ។



លុះព្រះមានព្រះភាគ ទ្រង់ទូន្មាន ពាហិយទារុចីរិយបុរស ដោយធម៌សង្ខេបនេះហើយ ស្ដេចចៀសចេញទៅ ។

(៨០) កាលដែលព្រះមានព្រះភាគ ស្ដេចចេញផុតទៅមិនយូរប៉ុន្មាន មេគោមានកូនខ្ចី ប៉ះផ្ដួលពាហិយទារុចីរិយបុរស ឲ្យដាច់ជីវិតទៅ ។ លំដាប់នោះ ព្រះមានព្រះភាគ ត្រាច់បិណ្ឌបាតក្នុងនគរសាវត្ថី រួចត្រឡប់អំពីបិណ្ឌបាត វេលាខាងក្រោយភត្ត ចេញអំពីនគរជាមួយនឹងភិក្ខុច្រើនរូប បានទតឃើញពាហិយទារុចីរិយបុរសធ្វើមរណកាល លុះទតឃើញហើយ ទើបត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរយកសរីរៈពាហិយទារុចីរិយបុរស លើកដាក់លើគ្រែនាំទៅដុតផង ធ្វើស្តូបដល់សរីរៈនោះផង ម្នាលភិក្ខុទាំងឡាយ (ព្រោះថា) សព្រហ្មចារីរបស់អ្នកទាំងឡាយ ធ្វើមរណកាលហើយ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយលើកសរីរៈពាហិយទារុចីរិយបុរស ដាក់លើគ្រែ នាំទៅដុតហើយ ទាំងធ្វើស្តូបដល់សរីរៈនោះ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សមគួរ ហើយបានទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សរីរៈពាហិយទារុចីរិយបុរស រលាយហើយ ទាំងស្តូបសម្រាប់បញ្ចុះសរីរៈនោះក៏ធ្វើហើយ គតិរបស់គាត់ តើដូចម្ដេច ដំណើរក្នុងលោកខាងមុខ តើដូចម្ដេច ។

បណ្ឌិតោ កិច្ចានិ ការិយោ ធាតុទ្ធរិយោ បច្ចាគតំ ចន្ទ-ស្សាគុណកំ ច ច[១] ចេត្តាធិការណំ វិហេសេតិ បរិឆិន្ទតោ កិច្ចានិ ការិយោ ធាតុទ្ធរិយោតិ ។ អជេតោ កតកំ ឯកមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

យត្ថ អាទោ ច បរិ ខោជា ភាយោ ច តាធតិ
ន តត្ថ សុញ្ញា ជោតន្តិ អាតិប្បា ចយ្យកាសតិ
ន តត្ថ ឆន្ទិមា ភាតិ តមោ តត្ថ ន វិជ្ជតិ ។
យទា ច អត្តនាវេទិ[២] មុនិ មោនេន ព្រាហ្មណោ
អថ រូបា អរូបា ច សុខទុក្ខា បមុច្ចតីតិ ។ ទសមំ ។
(៣)

ពោធិវគ្គោ បឋមោ ។

## ពស្សោត្តជំ

តយោ ច កោជិ មិត្តោ តោ តេ វេក តស្សាបេន ច តាភយ[៤] សត្តាមជិ ផជិលា ការិយេន តេនសកតិ ។

១ ម. ម. ចន្ទេន្ត មទ្ធំ ទ័ស្សនំ ។ ២ ម. អត្តនាវេទិ ។ ៣ ម. ម. ទសមំ ឥតិ ។ ៤ ម. ម. ឧទ្ទាន អាយំ ខុទ្ទកោ ព្រហ្ម កម្មោ តតិ ចេ សុត្តន្តិ បាឋោ ទ័ស្សន្តំ ។ ៨ ម. បាឋស្សំ ។ ម. បាត ។



ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការហ៊ានការច្រើន បុរស ជាបណ្ឌិត បានប្រកបក្នុងមិត្តរបស់ព្រះនិព្វានហើយ មិនរៀន រៀនតថាគត ព្រោះយកកុសលផលធម៌ ម្នាលភិក្ខុទាំងឡាយ ការហ៊ាន-ការច្រើនបុរស បរិនិព្វានហើយ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាប ច្បាស់នូវសេចក្ដីនុះហើយ ទើបទ្រង់បន្លឺឧទាននុះ ក្នុងវេលានោះថា

ទឹក ដី ភ្លើង ខ្យល់ រមែងមិនតាំងនៅក្នុងនិព្វានណាក្ដុ ក្នុងព្រះអាទិត្យ ព្រះចន្ទ ពេលដែលមិនភ្លឺ ពីព្រះអាទិត្យក៏មិនរុងរឿង ក្នុងនិព្វានណានោះ ព្រះចន្ទ ក៏មិនមានពន្លឺក្នុងនិព្វានណានោះ ងងឹត ក៏មិនមាន ក្នុងនិព្វានណានោះទេ ។ ព្រាហ្មណ៍មានឈ្មោះថាមុនី ព្រោះ មានញាណធម៌ ដឹងច្បាស់នូវព្រះនិព្វានដោយខ្លួនឯង ក្នុងកាលណា រមែង រួចចាកអរូបផង រូបផង សុខទុក្ខផង ក្នុងកាលនោះ ។ សូត្រទី ១០ ។

ចប់ ពោធិវគ្គ ទី ១ ។

## ខុទ្ទកនិកាយ ឧទានតោះតិ

និយាយអំពីព្រះមានព្រះភាគ គង់ក្រោមពោធិព្រឹក្ស ៣ លើក ព្រះមាន ព្រះភាគគង់ក្រោមដើមអជបាលនិគ្រោធ ១ ព្រះពុទ្ធនៈប្រើប្រាស់ ១ ព្រះ មហាកស្សប ១ ព្រះមានព្រះភាគគង់នៅពិតក្រុងប៉ាវា ១ ព្រះសង្គាមជិ ភ្នេរ ១ ក្នុងពហិយ ១ ការហ៊ានការច្រើនបុរស ១ រួមទាំងអស់ជា ១០ រឿង

# ឧទានេ ទុតិយោ មុចលិន្ទវគ្គោ

[៥១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ឧរុវេលាយំ វិហរតិ នជ្ជា នេរញ្ជរាយ តីរេ មុចលិន្ទមូលេ បឋមាភិសម្ពុទ្ធោ ។ តេន ខោ បន សមយេន ភគវា សត្តាហំ ឯកបល្លង្កេន និសិន្នោ ហោតិ វិមុត្តិសុខំ បដិសំវេទី ។ តេន ខោ បន សមយេន មហាអកាលមេឃោ ឧទបាទិ ។ សត្តាហវទ្ទលិកា សីតវាតា ទុទ្ទិនី ។ អថខោ មុចលិន្ទោ នាគរាជា សកាភវនា និក្ខមិត្វា ភគវតោ កាយំ សត្តក្ខត្តុំ ភោគេហិ បរិក្ខិបិត្វា ឧបរិមុទ្ធនិ មហន្តំ ផណំ វិហច្ច អដ្ឋាសិ មា ភគវន្តំ សីតំ មា ភគវន្តំ ឧណ្ហំ មា ភគវន្តំ ឌំសមកសវាតាតបសិរីសបសម្ផស្សោតិ[១] ។ អថខោ ភគវា តស្ស សត្តាហស្ស អច្ចយេន តម្ហា សមាធិម្ហា វុដ្ឋាសិ ។ អថខោ មុចលិន្ទោ នាគរាជា វិទ្ធំ វិគតវលាហកំ ទេវំ វិទិត្វា ភគវតោ កាយំ

១ ម. ឱ. — សរីសបេតិ ។



# ឧទាន មុចលិន្ទវគ្គ ទី ២

[៥១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទើបបានត្រាស់ដឹងជាដំបូង ទ្រង់គង់នៅទៀបមុចលិន្ទ (ពីងអន្ទក់) ក្បែរឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេស ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់ដោយបល្ល័ង្កតែមួយ សោយវិមុត្តិសុខ អស់ ៧ សប្តាហ៍ ។ សម័យនោះ បណ្តាលជាភ្លៀងធំ ពុំគួរកាលកើតឡើង ។ ភ្លៀងរលឹម ៧ សប្តាហ៍ មានមេឃត្រជាក់ក្នុងថ្ងៃស្រពាប់ ។ លំដាប់នោះ មុចលិន្ទនាគរាជ ចេញពីលំនៅរបស់ខ្លួនហើយ ពេនព័ទ្ធព្រះកាយ នៃព្រះមានព្រះភាគដោយខ្លួន ៧ ជុំ ហើយបើកពពារដ៏ធំបាំងពីខាងលើព្រះសិរ្សព្រះមានព្រះភាគ ដោយគិតថា ត្រជាក់កុំបីពាល់ព្រះមានព្រះភាគ ក្តៅកុំបីពាល់ព្រះមានព្រះភាគ សម្ផស្ស របោម មូស ខ្យល់ ក្តៅថ្ងៃ ពស់តូច ពស់ធំ ក៏កុំបីបៀតបៀនព្រះមានព្រះភាគឡើយ ។ លុះកន្លងសប្តាហ៍នោះហើយ ព្រះមានព្រះភាគ ទ្រង់ចេញអំពីសមាធិនោះ ។ លំដាប់នោះ មុចលិន្ទនាគរាជ ដឹងថា ភ្លៀងរាំងហើយ មានពពកស្រឡះហើយ ក៏ស្រាយខ្លួន ចាកព្រះកាយ នៃព្រះមានព្រះភាគ

ភោគេហិ និវេឋេត្វា សកវណ្ណំ អភិនិម្មិត្វា[១] ភគវតោ បុរតោ អដ្ឋាសិ បញ្ជលិកោ ភគវន្តំ នមស្សមានោ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

សុខោ វិវេកោ តុដ្ឋស្ស សុតធម្មស្ស បស្សតោ
អព្យាបជ្ជំ សុខំ លោកេ បាណភូតេសុ សញ្ញមោ[២]
សុខា វិរាគតា លោកេ កាមានំ សមតិក្កមោ
អស្មិមានស្ស វិនយោ ឯតំ វេ បរមំ សុខន្តិ ។
បឋមំ[៣] ។

(៥៦) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សម្ពហុលានំ ភិក្ខូនំ បច្ឆាភត្តំ បិណ្ឌបាតបដិក្កន្តានំ ឧបដ្ឋានសាលាយំ សន្និសិន្នានំ សន្និបតិតានំ អយមន្តរា កថា ឧទបាទិ

---

១ ឱ. ម. ភោគេ ភោគេហិ និវេឋេត្វា សកវណ្ណំ បដិសំហរិត្វា មាណវកវណ្ណំ អភិនិម្មិត្វាន ។ ឥម បាឋោ យុត្តតរោ ន ហិ និ ឧបមានត្ថេ ។ ២ ម. សំយមោ ។ ៣ ឱ. ម. បឋមំ សុត្តំ ។



និម្មិតភេទរបស់ខ្លួន (ជាភេទមាណព) ឈរប្រណម្យអញ្ជលី នមស្ការព្រះមានព្រះភាគ ពីខាងមុខព្រះភក្ត្រព្រះអង្គ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុះហើយ ទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

វិវេក[១]របស់បុគ្គល អ្នកត្រេកអរ (ដោយមគ្គញាណ) មានធម៌ស្តាប់ហើយ បានឃើញច្បាស់ (ដោយញាណចក្ខុ) ជាសេចក្តីសុខ ការមិនបៀតបៀនគ្នា និងការសង្រួម ក្នុងសត្វទាំងឡាយ ជាសុខក្នុងលោក ការប្រាសចាកតម្រេក ការប្រព្រឹត្តកន្លងកាមទាំងឡាយ ជាសុខក្នុងលោក ការកំចាត់បង់នូវអស្មិមានះ ដ៏ណានុះ ឈ្មោះថាជាសុខយ៉ាងក្រៃលែង ។ សូត្រទី១ ។

(៥៦) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ពួកភិក្ខុច្រើនរូបត្រឡប់អំពីបិណ្ឌបាត ក្នុងវេលាក្រោយភត្ត អង្គុយប្រជុំគ្នា ក្នុងឧបដ្ឋានសាលា អន្តរកថា[២]នេះកើតឡើងថា

---

១ បណ្តាវិវេក ៣ យ៉ាង វិវេកក្នុងទីនេះ សំដៅយកឧបធិវិវេក គឺព្រះនិព្វាន ។ អដ្ឋកថា ។ ២ ពាក្យនិយាយខ្សែក គឺពាក្យតំណាលយកចិត្តទុកដាក់ ក្នុងកម្មដ្ឋាន រៀនធម៌ និង អដ្ឋកថា គឺមិន មែនជា អន្តរកថា ។ អដ្ឋកថា ។

កោ នុ ខោ អាវុសោ ឥមេសំ ទ្វិន្នំ រាជូនំ មហទ្ធនតរោ វា មហាភោគតរោ វា មហាកោសតរោ វា មហាវិជិតតរោ វា មហាវាហនតរោ វា មហព្ពលតរោ វា មហិទ្ធិកតរោ វា មហានុភាវតរោ វា រាជា វា មាគធោ សេនិយោ ពិម្ពិសារោ រាជា វា បសេនទិ កោសលោតិ ។ អយញ្ចរហិ តេសំ ភិក្ខូនំ អន្តរកថា វិប្បកតា ។ អថខោ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន ឧបដ្ឋានសាលា តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា ភិក្ខូ អាមន្តេសិ កាយ នុត្ថ ភិក្ខវេ ឯតរហិ កថាយ សន្និសិន្នា សន្និបតិតា កា ច បន វោ អន្តរកថា វិប្បកតាតិ ។ ឥធ ភន្តេ អម្ហាកំ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តានំ ឧបដ្ឋានសាលាយំ សន្និសិន្នានំ សន្និបតិតានំ អយមន្តរកថា ឧទបាទិ



ម្នាលអាវុសោទាំងឡាយ បណ្តាព្រះរាជាទាំងពីរព្រះអង្គនេះ គឺព្រះរាជា ព្រះនាមមាគធសេនិយពិម្ពិសារ ១ នឹងព្រះរាជា ព្រះនាមបសេនទិកោសល ព្រះរាជាអង្គណាហ្ន៎ ដែលមានទ្រព្យច្រើន មានភោគៈច្រើន មានឃ្លាំងច្រើន មានដែនធំល្វឹងច្រើន មានពាហនៈច្រើន មានពលច្រើន មានឫទ្ធិច្រើន មានអានុភាពច្រើនជាង ។ សំណួរនេះ អន្តរកថា របស់ភិក្ខុទាំងនោះ កំពុងតែឈប់នៅ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ចេញអំពីទីសម្ងំ ក្នុងសាយណ្ហសម័យ ក៏យាងចូលទៅកាន់ឧបដ្ឋានសាលា លុះទ្រង់ចូលទៅដល់ហើយ ក៏គង់លើអាសនៈ ដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគទ្រង់គង់ហើយ ទើបត្រាស់សួរពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ អង្គុយប្រជុំគ្នា ដោយការនិយាយអ្វី ក្នុងកាលឥឡូវនេះ មួយទៀត អន្តរកថាដូចម្តេច ដែលអ្នកទាំងឡាយផ្អាកទុក ។ ពួកភិក្ខុទាំងនោះ ទូលថា បពិត្រព្រះអង្គដ៏ចំរើន កាលដែលពួកយើងខ្ញុំទាំងឡាយត្រឡប់មកពីបិណ្ឌបាត វេលាខាងក្រោយភត្ត ក្នុងក្រោយភត្តនេះ ហើយអង្គុយប្រជុំគ្នា ក្នុងឧបដ្ឋានសាលា មានអន្តរកថានេះ កើតឡើងថា

កោ នុ ខោ អាវុសោ ឥមេសំ ទ្វិន្នំ រាជូនំ មហទ្ធនតរោ វា មហាភោគតរោ វា មហាកោសតរោ វា មហាវិជិតតរោ វា មហាវាហនតរោ វា មហព្ពលតរោ វា មហិទ្ធិកតរោ វា មហានុភាវតរោ វា រាជា វា មាគធោ សេនិយោ ពិម្ពិសារោ រាជា វា បសេនទិ កោសលោតិ ។ អយំ ខោ នោ ភន្តេ អន្តរាកថា វិប្បកតា អថ ភគវា អនុប្បត្តោតិ ។ ន ខ្វេតំ ភិក្ខវេ តុម្ហាកំ បតិរូបំ កុលបុត្តានំ សទ្ធា អគារស្មា អនគារិយំ បព្វជិតានំ យំ តុម្ហេ ឯវរូបិំ កថំ កថេយ្យាថ សន្និបតិតានំ វោ ភិក្ខវេ ទ្វយំ ករណីយំ ធម្មី វា កថា អរិយោ វា តុណ្ហីភាវោតិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

យញ្ច កាមសុខំ លោកេ យញ្ចិទំ ទិវិយំ សុខំ
តណ្ហក្ខយសុខស្សេតេ កលំ នាគ្ឃន្តិ សោឡសិន្តិ ។

ទុតិយំ(១) ។

១ ម. ម. រាជសុត្តំ ។



ម្នាលអាវុសោទាំងឡាយ បណ្តាព្រះរាជាពីរព្រះអង្គនេះ គឺព្រះរាជាព្រះនាមមាគធសេនិយពិម្ពិសារ នឹងព្រះរាជាព្រះនាមបសេនទិកោសល ព្រះរាជាអង្គណាហ្ន៎ ដែលមានទ្រព្យច្រើន មានភោគៈច្រើន មានឃ្លាំងច្រើន មានដែនដំណាក់ច្រើន មានពាហនៈច្រើន មានពលច្រើន មានឫទ្ធិច្រើន មានអានុភាពច្រើនជាង ។ បពិត្រព្រះអង្គដ៏ចំរើន អន្តរកថានេះឯង ដែលយើងខ្ញុំទាំងឡាយផ្អាកទុក ក៏ស្រាប់តែព្រះមានព្រះភាគ ស្តេចយាងមកដល់ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ត្រង់ដែលអ្នកទាំងឡាយនិយាយពាក្យបែបនេះ ជាការមិនគួរ មិនមែនជាគំរូដ៏គួរដល់អ្នកទាំងឡាយ ដែលជាកុលបុត្ត ចេញចាកផ្ទះ ចូលកាន់ផ្នួសដោយសទ្ធាទេ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កាលដែលប្រជុំគ្នា គប្បីធ្វើកិច្ចពីរយ៉ាង គឺការនិយាយធម៌ ១ ការស្ងប់ស្ងៀមដ៏ប្រសើរ(១) ១ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនុះហើយ ទ្រង់បន្លឺនូវឧទាននេះ ក្នុងវេលានោះថា

កាមសុខណា ក្នុងលោកក្តី ទិព្វសុខ(២)ណាក្តី សេចក្តីសុខទាំង
នោះ មិនដល់នូវចំណែក ១ ក្នុងចំណែក ១៦ នៃសេចក្តីសុខ(៣)
ព្រោះការអស់តណ្ហាទេ ។ សូត្រទី២ ។

១ សំដៅយកការស្ងប់ស្ងៀមស្រួលដោយឈានសមាបត្តិ ។ ២ សំដៅយកសេចក្តីសុខ ក្នុងរូបព្រហ្ម អរូបព្រហ្ម និងទេវលោកទាំង ៦ ។ ៣ សំដៅយកសេចក្តីសុខ ក្នុងផលសមាបត្តិ ។ អដ្ឋកថា ។

(៥៣) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សម្ពហុលា កុមារកា អន្តរា ច សាវត្ថឹ អន្តរា ច ជេតវនំ អហឹ ទណ្ឌេន ហនន្តិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បាវិសិ ។ អទ្ទសា ខោ ភគវា តេ សម្ពហុលេ កុមារកេ អន្តរា ច សាវត្ថឹ អន្តរា ច ជេតវនំ អហឹ ទណ្ឌេន ហនន្តេ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

សុខកាមានិ ភូតានិ យោ ទណ្ឌេន វិហឹសតិ
អត្តនោ សុខមេសានោ បេច្ច សោ ន លភតេ សុខំ ។
សុខកាមានិ ភូតានិ យោ ទណ្ឌេន ន ហឹសតិ
អត្តនោ សុខមេសានោ បេច្ច សោ លភតេ សុខន្តិ ។
តតិយំ[១] ។

(៥៤) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា

១ ឱ.ម. តតិយំ សុត្តំ ។



(៥៣) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ពួកកុមារច្រើននាក់ នាំគ្នាបៀតបៀនពស់ដោយដំបង ក្នុងចន្លោះនៃក្រុងសាវត្ថី និងវត្តជេតពន ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ ប្រដាប់បាត្រនិងចីវរ ចូលទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថី ក្នុងបុព្វណ្ហសម័យ ។ ព្រះមានព្រះភាគ បានទតឃើញពួកកុមារច្រើននាក់ទាំងនោះ កំពុងវាយបៀតបៀនពស់ដោយដំបង ក្នុងចន្លោះនៃក្រុងសាវត្ថី និងវត្តជេតពន ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺនូវឧទាននេះ ក្នុងវេលានោះថា

បុគ្គលណា កាលស្វែងរកសេចក្តីសុខ ដើម្បីខ្លួន ហើយបៀតបៀន
ពួកសត្វអ្នកប្រាថ្នាសេចក្តីសុខ ដោយដំបង បុគ្គលនោះ លុះលះ
លោកនេះទៅ រមែងមិនបានសេចក្តីសុខឡើយ ។
បុគ្គលណា កាលស្វែងរកសេចក្តីសុខ ដើម្បីខ្លួន មិនបៀតបៀន
ពួកសត្វ អ្នកប្រាថ្នាសេចក្តីសុខ ដោយដំបង បុគ្គលនោះ លុះ
លះលោកនេះទៅ រមែងបានសេចក្តីសុខ ។ សូត្រ ទី ៣ ។

(៥៤) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ

សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភគវា សក្កតោ ហោតិ គរុកតោ មានិតោ បូជិតោ អបចិតោ លាភី ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ។ ភិក្ខុសង្ឃោបិ សក្កតោ ហោតិ គរុកតោ មានិតោ បូជិតោ អបចិតោ លាភី ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ។ អញ្ញតិត្ថិយា បន បរិព្វាជកា អសក្កតា ហោន្តិ អគរុកតា អមានិតា អបូជិតា ន អបចិតា ន លាភិនោ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ។ អថ ខោ[១] អញ្ញតិត្ថិយា បរិព្វាជកា ភគវតោ សក្ការំ អសហមានា ភិក្ខុសង្ឃស្ស ច គាមេ ច អរញ្ញេ ច ភិក្ខូ ទិស្វា អសព្ភាហិ ផរុសាហិ វាចាហិ អក្កោសន្តិ បរិភាសន្តិ រោសេន្តិ វិហេសេន្តិ[២] ។ អថ ខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ ឯតរហិ ភន្តេ ភគវា

១ ឱ. ម. អថខោ តេ ។ ២ ឱ. ហេសន្តិ វិហេសេន្តិ ។



ទ្រង់គង់នៅ ក្នុងវត្តព្រះជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគ គេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង បានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ជាប្រក្រតី ។ សូម្បីភិក្ខុសង្ឃ ក៏គេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង បានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារផង ។ ចំណែកពួកបរិព្វាជក អន្យតិរ្ថិយ គេមិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជា មិនកោតក្រែង មិនបានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ជាប្រក្រតីឡើយ ។ គ្រានោះឯង ពួកបរិព្វាជក អន្យតិរ្ថិយ កាលទ្រាំមិនបានសក្ការៈ ចំពោះព្រះមានព្រះភាគ និងភិក្ខុសង្ឃ មិនបាន លុះឃើញពួកភិក្ខុ ក្នុងស្រុកក្តី ក្នុងព្រៃក្តី ក៏ជេរប្រទេច ទឹងទាស់ក្រេ ដោយសំដីទ្រគោះ ជារបស់អសប្បុរស ។ លំដាប់នោះឯង ពួកភិក្ខុច្រើនរូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ក៏ទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ព្រះមានព្រះភាគ

សក្កតោ ហោតិ គរុកតោ មានិតោ បូជិតោ អបចិតោ លាភី ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ។ ភិក្ខុសង្ឃោបិ សក្កតោ ហោតិ គរុកតោ មានិតោ បូជិតោ អបចិតោ លាភី ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ។ អញ្ញតិត្ថិយា បន បរិព្វាជកា អសក្កតា ហោន្តិ អគរុកតា អមានិតា អបូជិតា អនបចិតា ន លាភិនោ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ។ អថខោ តេ តាន្ត អញ្ញតិត្ថិយា បរិព្វាជកា ភគវតោ សក្ការំ អសហមានា ភិក្ខុសង្ឃស្ស ច គាមេ ច អរញ្ញេ ច ភិក្ខូ ទិស្វា[1] អសព្ភាហិ ផរុសាហិ គិរាហិ អក្កោសន្តិ បរិភាសន្តិ រោសេន្តិ វិហេសេន្តិ[2] ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

គាមេ អរញ្ញេ សុខទុក្ខផុដ្ឋោ[3]

នេវត្តតោ នោ បរតោ ទហេថ

១ ឱ. ម. ភិក្ខូ ទិស្វា ។ ២ ឱ. វិហេសន្តិ ។ ម. វិហេសេន្តិ ។ ៣ ឱ. ម. សុខទុក្ខផុដ្ឋោ ។



មានគេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង បានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ។ ចំណែកភិក្ខុសង្ឃ ក៏គេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង បានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ជាប្រក្រតីដែរ ។ ចំណែកខាងពួកបរិព្វាជក អន្យតិរ្ថិយ គេមិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជា មិនកោតក្រែង មិនបានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ជាប្រក្រតី ។ [illegible] លំដាប់នោះឯង ពួកបរិព្វាជក អន្យតិរ្ថិយទាំងនោះ កាលអត់ទ្រាំមិនបានសក្ការៈ ចំពោះព្រះមានព្រះភាគនឹងភិក្ខុសង្ឃ មិនបាន លុះបានឃើញពួកភិក្ខុសង្ឃ ក្នុងស្រុកក្តី ក្នុងព្រៃក្តី ក៏ជេរប្រទេច ទីងទាល់ ដោយពាក្យទ្រគោះ ជារបស់អសប្បុរស ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាន ក្នុងវេលានោះថា

អ្នកទាំងឡាយ ដែលសុខនឹងទុក្ខ ប៉ះពាល់ហើយ ទោះនៅក្នុង

ស្រុកឬព្រៃ មិនគ្រោតគ្រាតត្រហាយ អំពីខ្លួន ឬអំពីអ្នកដទៃឡើយ

ផុសន្តិ ផស្សា ឧបធឹ បដិច្ច

និរូបធឹ កេន ផុសេយ្យុំ(១) ផស្សាតិ ។ ចតុត្ថំ(២) ។

(៥៥) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរោ ឥច្ឆានង្គលកោ ឧបាសកោ សាវត្ថឹ អនុប្បត្តោ ហោតិ កេនចិទេវ ករណីយេន ។ អថ ខោ សោ ឧបាសកោ សាវត្ថិយំ តំ ករណីយំ តីរេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ តំ ឧបាសកំ ភគវា ឯតទវោច ចិរស្សំ ខោ ត្វំ ឧបាសក ឥមំ បរិយាយមកាសិ យទិទំ ឥធាគមនាយាតិ ។ ចិរប្បដិកាហំ ភន្តេ ភគវន្តំ ទស្សនាយ ឧបសង្កមិតុកាមោ អបិចាហំ កេហិចិ កិច្ចករណីយេហិ ព្យាវដោ ឯវាហំ នាសក្ខឹ ភគវន្តំ ទស្សនាយ ឧបសង្កមិតុន្តិ ។ អថ ខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

១ ម. ផុសេយ្យុំ ។ ឱ. ផុសេយ្យុ ។ ២ ម.ឱ. ចតុត្ថំ [illegible] ។



ផស្សធម៌ទាំងឡាយ ប៉ះពាល់ត្រូវបាន ព្រោះអាស្រ័យ ឧបធិ កាលបើឧបធិ មិនមាន ផស្សធម៌ទាំងឡាយ ប៉ះពាល់ ត្រូវដូចម្តេចបាន ។ សូត្រ ទី ៤ ។

(៥៥) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុង សាវត្ថី ។ សម័យនោះឯង ឧបាសកម្នាក់ នៅក្នុងស្រុកឥច្ឆានង្គលៈ បានទៅដល់នគរសាវត្ថី ដោយកិច្ចនីមួយ ។ លុះឧបាសកនោះ បានសំរេចកិច្ចនោះស្រេច ក្នុងនគរសាវត្ថីហើយ ក៏ចូលទៅ គាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមាន ព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះឧបាសកនោះ អង្គុយក្នុង ទីសមគួរហើយ ព្រះមានព្រះភាគ ត្រាស់យ៉ាងនេះថា ម្នាលឧបា-សក ឧបាសកធ្វើហេតុជាទំនង ដើម្បីមកទីនេះដោយយូរអង្វែងហើយ ។ ឧបាសកនោះទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គប្រុងនឹងចូល មកគាល់ព្រះមានព្រះភាគ ជាយូរហើយ ប៉ុន្តែខ្ញុំព្រះអង្គជាអ្នកខ្វល់ ខ្វាយមិនដាច់ ដោយកិច្ចការនីមួយ ទើបមិនអាចនឹងចូលមកគាល់ ព្រះមានព្រះភាគបានសោះ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាប ច្បាស់នូវសេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

សុខំ វត តស្ស ន ហោតិ កិញ្ចិ
សង្ខាតធម្មស្ស[១] ពហុស្សុតស្ស
សកិញ្ចនំ បស្ស វិហញ្ញមានំ
ជនោ ជនស្មឹ[២] បដិពន្ធរូបោតិ ។ បញ្ចមំ[៣] ។

(៥៦) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរស្ស បរិព្វាជកស្ស ទហរា មាណវិកា បជាបតិ ហោតិ គព្ភិនី ឧបវិជញ្ញា ។ អថ ខោ សា បរិព្វាជិកា តំ បរិព្វាជកំ ឯតទវោច គច្ឆ ត្វំ ព្រាហ្មណ តេលំ អាហរ យំ មេ វិជាតាយ ភវិស្សតីតិ ។ ឯវំ វុត្តេ សោ បរិព្វាជកោ តំ បរិព្វាជិកំ ឯតទវោច កុតោ បនាហំ ភោតិយា តេលំ អាហរាមីតិ ។ ទុតិយម្បិ ខោ សា បរិព្វាជិកា តំ បរិព្វាជកំ ឯតទវោច គច្ឆ ត្វំ ព្រាហ្មណ តេលំ អាហរ យំ មេ វិជាតាយ ភវិស្សតីតិ ។ ទុតិយម្បិ ខោ សោ បរិព្វាជកោ តំ បរិព្វាជិកំ ឯតទវោច កុតោ បនាហំ ភោតិយា តេលំ អាហរាមីតិ ។

១ ម. សង្ខាតធម្មស្ស ។ ២ ម. ជនស្មឹ ។ ៣ ឱ. ម. បញ្ចមំ [illegible] ។





កិលេសគ្រឿងកង្វល់ណាមួយ មិនមានដល់បុគ្គលអ្នកមានធម៌ពិចារណាហើយ ជាពហុស្សូត នុ៎ះឯងជាសុខ អ្នកចូរមើលបុគ្គលអ្នកប្រកបដោយកង្វល់ កំពុងតែលំបាកចំពោះអ្នកដទៃ ព្រោះតែជាជនសកាងជាប់ចំពាក់ចំពោះអ្នកដទៃ ។ សូត្រ ទី ៥ ។

(៥៦) ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគគង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង នាងមាណវិកាក្មេងខ្ចី ជាប្រពន្ធបរិព្វាជកម្នាក់ ជាស្ត្រីមានគភ៌ ជិតសម្រាលកូន ។ លំដាប់នោះ នាងបរិព្វាជិកានោះ បាននិយាយនឹងបរិព្វាជកនោះយ៉ាងនេះថា នែព្រាហ្មណ៍ អ្នកចូរទៅនាំយកនូវប្រេងដែលជាប្រយោជន៍ដល់ខ្ញុំ សម្រាប់សម្រាលកូន ។ កាលបើនាងបរិព្វាជិកានិយាយយ៉ាងនេះហើយ បរិព្វាជកនោះ ក៏និយាយនឹងនាងបរិព្វាជិកាវិញថា ចុះអញនាំយកប្រេងពីណាមកឲ្យនាង ។ នាងបរិព្វាជិកានោះ បាននិយាយនឹងបរិព្វាជកនោះ ជាគំរប់ ២ ដងយ៉ាងនេះថា ម្នាលព្រាហ្មណ៍ អ្នកចូរទៅនាំប្រេង ដែលជាប្រយោជន៍ដល់ខ្ញុំសម្រាប់សម្រាលកូន ។ បរិព្វាជកនោះបាននិយាយនឹងនាងបរិព្វាជិកានោះជាគំរប់ ២ ដងយ៉ាងនេះថា ចុះអញនាំយកប្រេងពីណា មកឲ្យនាង ។

តតិយម្បិ ខោ សា បរិព្វាជិកា តំ បរិព្វាជកំ ឯតទវោច គច្ឆ តុំ ព្រាហ្មណ តេលំ អាហរ យំ មេ វិជាតាយ ភវិស្សតីតិ ។

(៨៧) តេន ខោ បន សមយេន រញ្ញោ បសេនទិស្ស កោសលស្ស កោដ្ឋាគារេ សមណស្ស វា ព្រាហ្មណស្ស វា សប្បិស្ស វា តេលស្ស វា យាវទត្ថំ បាតុំ ទីយតិ នោ នីហរិតុំ ។ អថខោ តស្ស បរិព្វាជកស្ស ឯតទហោសិ រញ្ញោ ខោ បន បសេនទិស្ស កោសលស្ស កោដ្ឋាគារេ សមណស្ស វា ព្រាហ្មណស្ស វា សប្បិស្ស វា តេលស្ស វា យាវទត្ថំ បាតុំ ទីយតិ នោ នីហរិតុំ យន្នូនាហំ រញ្ញោ បសេនទិស្ស កោសលស្ស កោដ្ឋាគារំ គន្ត្វា តេលស្ស យាវទត្ថំ បិវិត្វា ឃរំ អាគន្ត្វា ឧច្ឆទ្ទេត្វា ទទេយ្យំ យំ ឥមិស្សា វិជាតាយ ភវិស្សតីតិ ។ អថខោ សោ បរិព្វាជកោ រញ្ញោ បសេនទិស្ស កោសលស្ស កោដ្ឋាគារំ គន្ត្វា តេលស្ស យាវទត្ថំ បិវិត្វា ឃរំ អាគន្ត្វា[១] នេវ សក្កោតិ ឧទ្ធំ កាតុំ ន បន អធោ ។

១ ម. គន្ត្វា ។



នាងបរិព្វាជិកានោះ ក៏និយាយនឹងបរិព្វាជកនោះជាគំរប់ ៣ ដងថា ម្នាលព្រាហ្មណ៍ អ្នកចូរទៅនាំយកប្រេង ដែលជាប្រយោជន៍ដល់ខ្ញុំ សម្រាប់សម្រាលកូន ។

(៨៧) សម័យនោះឯង ព្រះរាជាបសេនទិកោសល ទ្រង់ប្រទានឲ្យសមណៈ ឬព្រាហ្មណ៍ ផឹកសប្បិ ឬ ប្រេង ក្នុងឃ្លាំងត្រឹម ។ ឆ្អែត មិនទ្រង់ប្រទាន ឲ្យនាំចេញទៅទេ ។ គ្រានោះឯង បរិព្វាជកនោះ មានសេចក្តីត្រិះរិះថា ចំណាំតែព្រះរាជាព្រះនាមបសេនទិកោសល ទ្រង់ប្រទានឲ្យសមណៈ ឬព្រាហ្មណ៍ផឹកសប្បិ ឬប្រេង ក្នុងឃ្លាំង ត្រឹម ។ ឆ្អែត មិនទ្រង់ប្រទាន ឲ្យនាំចេញទៅទេ បើដូច្នោះ មានតែ អាត្មាអញគប្បីទៅឯឃ្លាំង ព្រះរាជាព្រះនាមបសេនទិកោសល ក្រេបផឹកប្រេងដោយដល់ឆ្អែត ហើយមកផ្ទះវិញ សឹមក្អួតឲ្យ ដើម្បីជាប្រយោជន៍ដល់ប្រពន្ធនេះ សម្រាប់សម្រាលកូន ។ លំដាប់នោះ បរិព្វាជកនោះ ទៅឯឃ្លាំងព្រះរាជា ព្រះនាមបសេនទិកោសលហើយ ក្រេបផឹកនូវប្រេង ដោយដល់ឆ្អែតមកផ្ទះវិញ ក៏មិនអាចនឹងធ្វើប្រេងឲ្យចេញមកខាងលើ ទាំងមិនអាចធ្វើឲ្យធ្លាក់ចុះទៅខាងក្រោមបាន ។

(១)

សោ ទុក្ខាហិ តិព្វាហិ កដុកាហិ វេទនាហិ ផុដ្ឋោ អាវដ្ដតិ បរិវដ្ដតិ ។ អថ ខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បាវិសិ ។ អទ្ទសា ខោ ភគវា តំ បរិព្វាជកំ ទុក្ខាហិ តិព្វាហិ[២] កដុកាហិ វេទនាហិ ផុដ្ឋំ អាវដ្ដមានំ បរិវដ្ដមានំ ។ អថ ខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

សុខិនោ វត យេ អកិញ្ចនា
វេទគុនោ ហិ ជនា អកិញ្ចនា
សកិញ្ចនំ បស្ស វិហញ្ញមានំ
ជនោ ជនស្មឹ បដិពទ្ធចិត្តោតិ ។ ឆដ្ឋំ[៣] ។

(៩៩) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរស្ស ឧបាសកស្ស ឯកបុត្តកោ បិយោ មនាបោ កាលកតោ ហោតិ ។ អថ ខោ សម្ពហុលា ឧបាសកា អល្លវត្ថា អល្លកេសា ទិវាទិវស្ស យេន ភគវា តេនុបសង្កមឹសុ

១-២ ឱ. ម. ឯត្ថន្តរេ ខរាហិ ទិស្សតិ ។ ៣ ឱ. ម. ឆដ្ឋំ សុត្តំ ។



បរិព្វាជកនោះ ត្រូវទុក្ខវេទនា ដ៏ក្លៀវក្លា ក្តៅក្រហាយ ពាល់ត្រូវ ក៏ប្រែះនឹងរៀលទៅមក ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ សព្វស្តេចចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ក្នុងបុព្វណ្ហសម័យ ។ ព្រះមានព្រះភាគ បានទតឃើញបរិព្វាជកនោះ កំពុងត្រូវទុក្ខវេទនា ដ៏ក្លៀវក្លា ក្តៅក្រហាយ ពាល់ត្រូវ កំពុងប្រែះនឹងរៀលទៅមក ។ លុះព្រះមានព្រះភាគ ទ្រង់បានជ្រាបច្បាស់ នូវសេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

ឱហ្ន៎ ជនទាំងឡាយណា មិនមានកិលេសជាគ្រឿងកង្វល់ ជនទាំងនោះ
រមែងមានសេចក្តីសុខ មួយទៀត ជនទាំងឡាយណា មិនមាន
កង្វល់ ជនទាំងនោះ ឈ្មោះថាដល់នូវវេទ ដោយហេតុមានញាណ អ្នក
ចូរមើលពួកជន ដែលប្រកបដោយកង្វល់កំពុងលំបាក (ដោយទុក្ខ)
ព្រោះជន (ច្រើនទៀត) មានចិត្តចំពាក់ចំពោះអ្នកដទៃ ។ សូត្រទី ៦ ។

(៨៨) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ឧបាសកម្នាក់ មានកូនប្រុសតូចមួយ ជាទីស្រឡាញ់ ជាទីគាប់ចិត្ត ធ្វើមរណកាល ។ គ្រានោះឯង ពួកឧបាសកច្រើននាក់មានសំពត់ទទឹក មានសក់ទទឹក ចូលទៅគាល់ព្រះមានព្រះភាគ ក្នុងថ្ងៃ

ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ តំ ឧបាសកំ ភគវា ឯតទវោច កិន្នុ តុម្ហេ ឧបាសកា អល្លវត្ថា អល្លកេសា ឥធូបសង្កមិត្ថ[១] ទិវាទិវស្សាតិ ។ ឯវំ វុត្តេ សោ ឧបាសកោ ភគវន្តំ ឯតទវោច ឥធ មេ ភន្តេ[២] ឯកបុត្តកោ បិយោ មនាបោ កាលកតោ[៣] តេន មយំ អល្លវត្ថា អល្លកេសា ឥធូបសង្កមន្តា ទិវាទិវស្សាតិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

បិយរូបស្សាទគធិតា សេ[៤]
ទេវកាយា បុថុមនុស្សា ច
អឃាវិនោ បរិជុណ្ណា
មច្ចុរាជស្ស វសំ គច្ឆន្តិ ។
យេ វេ ទិវា ច រត្តោ ច
អប្បមត្តា ជហន្តិ បិយរូបំ
តេ វេ ខណន្តិ អឃមូលំ
មច្ចុនោ អាមិសំ ទុរតិវត្តន្តិ ។ សត្តមំ[៥] ។

---

១ ឱ. ម. ឧបសង្កមត្ថា ។ ២ ឱ. ម. ភន្តេ ។ ៣ ឱ. ម. [illegible] ទិវស្សន្តិ ។ ៤ ឱ. ម. បិយរូបសាតគធិតាសេ ។ ៥ ឱ. ម. សត្តមំ ៦ បញ្ចមំ ។



ហើយថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះឧបាសកទាំងនោះ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគត្រាស់សួរយ៉ាងនេះថា ម្នាលឧបាសកទាំងឡាយ ដូចម្តេចហ្ន៎ បានជាអ្នកទាំងឡាយ មានសំពត់ទទឹក មានសក់ទទឹក ចូលមកក្នុងទីនេះទាំងថ្ងៃ ។ កាលបើព្រះមានព្រះភាគ ត្រាស់សួរយ៉ាងនេះហើយ ឧបាសកនោះ បានទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះមានព្រះភាគ កូនប្រុសតែមួយរបស់ខ្ញុំព្រះអង្គ ជាទីស្រឡាញ់ ជាទីគាប់ចិត្ត ធ្វើមរណកាលទៅ បានជាពួកខ្ញុំព្រះអង្គ មានសំពត់ទទឹក មានសក់ទទឹក ចូលមកក្នុងទីនេះទាំងថ្ងៃ ។ លុះព្រះមានព្រះភាគ ទ្រង់បានជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

ពួកទេវតានិងពួកមនុស្ស ជាច្រើន ជាប់ចំពាក់ដោយការត្រេកត្រអាលក្នុងរូប ជាទីស្រឡាញ់ ជាអ្នកមានសេចក្តីទុក្ខ និងសេចក្តីសាបសូន្យ លុះក្នុងអំណាចមច្ចុរាជ ។ ពួកជនណា មិនធ្វេសប្រហែសទាំងថ្ងៃទាំងយប់លះបង់រូប ជាទីស្រឡាញ់ ពួកជនទាំងនោះឯង រមែងជីកគាស់ហើយនូវឫសគល់នៃទុក្ខជានុយនៃមច្ចុ ដែលកន្លងបានដោយក្រ ។ សូត្រទី ៧ ។

(៥៩) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កុណ្ឌិយាយំ វិហរតិ កុណ្ឌិដ្ឋានវនេ[១] ។ តេន ខោ បន សមយេន សុប្បវាសា កោលិយធីតា សត្ត វស្សានិ គព្ភំ ធារេតិ សត្តាហំ មូឡ្ហគព្ភា ។ សា ទុក្ខាហិ តិព្វាហិ កដុកាហិ វេទនាហិ ផុដ្ឋា តីហិ វិតក្កេហិ អធិវាសេតិ សម្មាសម្ពុទ្ធោ វត សោ ភគវា យោ ឥមស្ស ឯវរូបស្ស ទុក្ខស្ស បហានាយ ធម្មំ ទេសេតិ សុប្បដិបន្នោ វត តស្ស ភគវតោ សាវកសង្ឃោ យោ ឥមស្ស ឯវរូបស្ស ទុក្ខស្ស បហានាយ បដិបន្នោ សុសុខំ វត និព្វានំ យត្ថិទំ[២] ឯវរូបំ ទុក្ខំ ន សំវិជ្ជតីតិ ។

(៦០) អថខោ សុប្បវាសា កោលិយធីតា សាមិកំ អាមន្តេសិ ឯហិ ត្វំ អយ្យបុត្ត យេន ភគវា តេនុបសង្កម ឧបសង្កមិត្វា មម វចនេន ភគវតោ បាទេ សិរសា វន្ទាហិ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆ សុប្បវាសា ភន្តេ កោលិយធីតា ភគវតោ បាទេ សិរសា វន្ទតិ

១ ម. ឧ. កុណ្ឌធានវនេ ។ ២ ម.ឧ. យត្ថិទំ ។



(៥៩) ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគគង់នៅក្នុងកុណ្ឌិដ្ឋានវ័ន ទៀបក្រុងកុណ្ឌិយា ។ សម័យនោះឯង កោលិយធីតាឈ្មោះសុប្បវាសា ទ្រទ្រង់គភ៌អស់ ៧ ឆ្នាំ មានគភ៌ល្ងង់អស់ ៧ ថ្ងៃ ។ កោលិយធីតានោះ ត្រូវទុក្ខវេទនា ក្លាខ្លាំង ក្ដៅក្រហាយ ប៉ះពាល់ហើយ ត្រាំត្រែងដោយតម្រិះ ៣ យ៉ាងថា ឱហ្ន៎ ព្រះមានព្រះភាគ ព្រះអង្គនោះ ត្រាស់ដឹងញេយ្យធម៌ចំពោះព្រះអង្គឯង ដោយប្រពៃពេក ព្រោះទ្រង់សំដែងធម៌ ដើម្បីលះបង់ទុក្ខបែបនេះ ១ ឱហ្ន៎ ព្រះសង្ឃសាវ័ករបស់ព្រះមានព្រះភាគព្រះអង្គនោះ លោកប្រតិបត្តិប្រពៃ ព្រោះលោកប្រតិបត្តិហើយ ដើម្បីលះបង់ទុក្ខបែបនេះ ១ ឱហ្ន៎ ព្រះនិព្វាន ជាសុខយ៉ាងក្រៃលែង ព្រោះមិនមានទុក្ខបែបនេះឡើយ ១ ។

(៦០) គ្រានោះ កោលិយធីតា ឈ្មោះសុប្បវាសា បានហៅស្វាមីមកប្រាប់ថា បពិត្រព្រះអយ្យបុត្ត សូមព្រះអង្គមក សូមព្រះអង្គចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ សូមថ្វាយបង្គំព្រះបាទានៃព្រះមានព្រះភាគ ដោយសិរ្សៈ សូមព្រះអង្គ ទូលសួរនូវការមិនមានអាពាធ មិនមានទុក្ខ មានកំឡាំងក្រោកឡើងរហ័ស និងការនៅសប្បាយ តាមពាក្យរបស់ខ្ញុំម្ចាស់ថា បពិត្រព្រះអង្គដ៏ចំរើន កោលិយធីតា ឈ្មោះសុប្បវាសា ថ្វាយបង្គំព្រះបាទានៃព្រះមានព្រះភាគ ដោយសិរ្សៈ

អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆតីតិ ឯវញ្ច វទេហិ សុប្បវាសា ភន្តេ កោលិយធីតា សត្ត វស្សានិ គព្ភំ ធារេតិ សត្តាហំ មូឡ្ហគព្ភា សា ទុក្ខាហិ តិព្វាហិ ខរាហិ កដុកាហិ វេទនាហិ ផុដ្ឋា តីហិ វិតក្កេហិ អធិវាសេតិ សម្មាសម្ពុទ្ធោ វត សោ ភគវា យោ ឥមស្ស ឯវរូបស្ស ទុក្ខស្ស បហានាយ ធម្មំ ទេសេតិ សុប្បដិបន្នោ វត តស្ស ភគវតោ សាវកសង្ឃោ យោ ឥមស្ស ឯវរូបស្ស ទុក្ខស្ស បហានាយ បដិបន្នោ សុសុខំ វត និព្វានំ យត្ថិទំ ឯវរូបំ ទុក្ខំ ន សំវិជ្ជតីតិ ។ បរមន្តិ ខោ សោ កោលិយបុត្តោ សុប្បវាសាយ កោលិយធីតាយ បដិស្សុត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ កោលិយបុត្តោ ភគវន្តំ ឯតទវោច សុប្បវាសា ភន្តេ កោលិយធីតា ភគវតោ បាទេ សិរសា វន្ទតិ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆតិ ឯវញ្ច វទេតិ



ទូលសួរនូវការមិនមានអាពាធ មិនមានទុក្ខ ងាកើបឡើង ក្រោកឡើងរហ័ស នឹងការនៅសប្បាយ មួយទៀត សូមព្រះអង្គទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន កោលិយធីតា នាមសុប្បវាសា ទ្រទ្រង់គភ៌អស់៧ឆ្នាំ មានគភ៌វង្វេង អស់ ៧ថ្ងៃ ព្រោះនាងត្រូវទុក្ខវេទនាដ៏ក្លាខ្លាំង ខ្លោចផ្សា ពាល់ត្រូវហើយ អត់ទ្រាំដោយការត្រិះរិះ ៣ យ៉ាងថា ហ្ន៎ ព្រះមានព្រះភាគព្រះអង្គនោះ ទ្រង់ត្រាស់ដឹងនូវធម៌ចំពោះព្រះអង្គឯង ដោយប្រពៃ ព្រោះទ្រង់សំដែងធម៌ ដើម្បីឲ្យលះបង់ទុក្ខបែបនេះ ហ្ន៎ ព្រះសង្ឃសាវ័ករបស់ព្រះមានព្រះភាគព្រះអង្គនោះ ប្រតិបត្តិប្រពៃ ព្រោះលោកប្រតិបត្តិហើយ ដើម្បីលះបង់ទុក្ខបែបនេះ ហ្ន៎ ព្រះនិព្វាន ជាសុខយ៉ាងក្រៃលែង ព្រោះមិនមានទុក្ខបែបនេះឡើយ ។ ។ កោលិយបុត្រ (ជាស្វាមី) បានទទួលស្ដាប់ពាក្យកោលិយធីតា នាមសុប្បវាសាថា ប្រពៃហើយ រួចចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះកោលិយបុត្រ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន កោលិយធីតា នាមសុប្បវាសា ថ្វាយបង្គំព្រះបាទា នៃព្រះមានព្រះភាគដោយសិរ្សៈ ទូលសួរការមិនមានអាពាធ មិនមានទុក្ខ ងាកើបឡើងក្រោកឡើងរហ័ស នឹងការនៅជាសុខសប្បាយ រួចនិយាយផ្ដាំ យ៉ាងនេះថា

សុប្បវាសា កោលិយធីតា សត្ត វស្សានិ គព្ភំ ធារេតិ សត្តាហំ មូឡ្ហគព្ភា សា ទុក្ខាហិ តិព្វាហិ ខរាហិ កដុកាហិ វេទនាហិ ផុដ្ឋា តីហិ វិតក្កេហិ អធិវាសេតិ សម្មាសម្ពុទ្ធោ វត សោ ភគវា យោ ឥមស្ស ឯវរូបស្ស ទុក្ខស្ស បហានាយ ធម្មំ ទេសេតិ សុប្បដិបន្នោ វត តស្ស ភគវតោ សាវកសង្ឃោ យោ ឥមស្ស ឯវរូបស្ស ទុក្ខស្ស បហានាយ បដិបន្នោ សុសុខំ វត និព្វានំ យត្ថិទំ ឯវរូបំ ទុក្ខំ ន សំវិជ្ជតីតិ ។ សុខិនី ហោតុ សុប្បវាសា កោលិយធីតា អរោគា អរោគំ បុត្តំ វិជាយតូតិ ។ សហ វចនា ច បន ភគវតោ សុប្បវាសា កោលិយធីតា សុខិនី អរោគា អរោគំ បុត្តំ វិជាយិ ។ ឯវំ ភន្តេតិ ខោ សោ កោលិយបុត្តោ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា យេន សកំ ឃរំ តេន បច្ចយាសិ[១] ។ អទ្ទសា ខោ សោ កោលិយបុត្តោ សុប្បវាសំ កោលិយធីតរំ

១ ម. ឱ. បក្កាមិ ។



កោលិយធីតា ឈ្មោះសុប្បវាសា ទ្រទ្រង់គភ៌ អស់ ៧ ឆ្នាំ មានគភ៌លំបាក អស់ ៧ ថ្ងៃ នាងត្រូវទុក្ខវេទនា ដ៏ក្លាខ្លាំង ខ្លោចផ្សា អត់ទ្រាំ ដោយការត្រិះរិះ ៣ យ៉ាងថា ឱហ្ន៎ ព្រះមានព្រះភាគព្រះអង្គនោះ ទ្រង់ត្រាស់ដឹងញេយ្យធម៌ទាំងពួងព្រះអង្គឯង ដោយប្រពៃ ព្រោះព្រះអង្គទ្រង់សំដែងធម៌ ដើម្បីលះបង់ទុក្ខបែបនេះ ១ ឱហ្ន៎ ព្រះសង្ឃសាវ័ករបស់ព្រះមានព្រះភាគព្រះអង្គនោះប្រតិបត្តិប្រពៃ ព្រោះលោកប្រតិបត្តិហើយ ដើម្បីលះបង់នូវទុក្ខបែបនេះ ១ ឱហ្ន៎ ព្រះនិព្វានជាសុខយ៉ាងក្រៃលែង ព្រោះមិនមានទុក្ខបែបនេះឡើយ ១ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា សូមឲ្យកោលិយធីតា ឈ្មោះសុប្បវាសា ចូរមានសេចក្តីសុខ សូមកុំឲ្យមានរោគប្រសូតបុត្រកុំឲ្យមានរោគ ។ ឯកោលិយធីតា ឈ្មោះសុប្បវាសា ក៏ចូរមានសេចក្តីសុខ ឥតមានរោគ ប្រសូតបុត្រក៏ឥតមានរោគ ដំណាលគ្នានឹងព្រះពុទ្ធដីកាព្រះមានព្រះភាគ ។ កោលិយកុលបុត្រនោះ ត្រេកអរអនុមោទនា ភាសិតរបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក្រោកចាកអាសនៈ ថ្វាយបង្គំលាព្រះមានព្រះភាគរួច ធ្វើប្រទក្សិណហើយ យាងសំដៅមកកាន់គេហដ្ឋានព្រះអង្គវិញ ។ កោលិយកុលបុត្រនោះបានឃើញ កោលិយធីតា ឈ្មោះសុប្បវាសា

សុខិនឹ អរោគំ អរោគំ បុត្តំ វិជាតំ ទិស្វានស្ស ឯតទហោសិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ តថាគតស្ស មហិទ្ធិ-កតា មហានុភាវតា យត្រ ហិ នាមាយំ សុប្បវាសា កោលិយធីតា សហ វចនា ច បន ភគវតោ សុខិនី អរោគា អរោគំ បុត្តំ វិជាយិស្សតីតិ អត្តមនោ បមុទិតោ បីតិសោមនស្សជាតោ អហោសិ ។

[៦១] អថ ខោ សុប្បវាសា កោលិយធីតា សាមិកំ អាមន្តេសិ ឯហិ ត្វំ អយ្យបុត្ត យេន ភគវា តេនុបសង្កម ឧបសង្កមិត្វា មម វចនេន ភគវតោ បាទេ សិរសា វន្ទាហិ សុប្បវាសា ភន្តេ កោលិយធីតា ភគវតោ បាទេ សិរសា វន្ទតីតិ ឯវញ្ច វទេហិ សុប្បវាសា ភន្តេ កោលិយធីតា សត្ត វស្សានិ គព្ភំ ធារេសិ សត្តាហំ មូឡ្ហគព្ភា សា ឯតរហិ សុខិនី អរោគា អរោគំ បុត្តំ វិជាតា សា សត្តាហំ ពុទ្ធប្បមុខំ (១) ភិក្ខុសង្ឃំ ភត្តេន និមន្តេតិ

១ ម. ឥទំ សទ្ទោ នត្ថិ ។



បានសេចក្តីសុខ មិនមានរោគ ប្រសូតបុត្ត មិនមានរោគ លុះកោលិយ-បុត្តនោះ បានឃើញហើយ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ អស្ចារ្យណាស់ ឱហ្ន៎ ចំឡែកណាស់អើ ព្រះតថាគតមានឫទ្ធិច្រើន មានអានុភាពច្រើនមែន មិនគួរបើកោលិយធីតា នាមសុប្បវាសានេះ បានសេចក្តីសុខ មិនមានរោគ ប្រសូតបុត្តមិនមានរោគ អំណាចគ្រាន់តែព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគនោះសោះ កោលិយបុត្ត មានចិត្តត្រេកអរ រីករាយ កើតបីតិសោមនស្ស ។

(៦១) គ្រានោះ កោលិយធីតា នាមសុប្បវាសា ហៅស្វាមីមកថា បពិត្រព្រះអយ្យបុត្ត សូមព្រះអង្គមក សូមព្រះអង្គចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ចូរថ្វាយបង្គំព្រះបាទានៃព្រះមានព្រះភាគដោយសិរ្សៈ តាមពាក្យរបស់ខ្ញុំម្ចាស់ថា បពិត្រព្រះអង្គដ៏ចំរើន កោលិ-យធីតា នាមសុប្បវាសា ថ្វាយបង្គំព្រះបាទានៃព្រះមានព្រះភាគ ដោយសិរ្សៈ រួចសូមព្រះអង្គក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន កោ-លិយធីតា នាមសុប្បវាសា ទ្រទ្រង់គភ៌អស់ ៧ឆ្នាំ មានគភ៌ល្ងង់ អស់៧ថ្ងៃ ឥឡូវនេះ នាងបានសេចក្តីសុខ មិនមានរោគ ប្រសូតបុត្តមិនមានរោគ នាងនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយភត្តអស់ ៧ ថ្ងៃ

អធិវាសេតុ កិរ ភន្តេ ភគវា សុប្បវាសាយ កោលិយធីតាយ សត្ត ភត្តានិ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ បរមន្តិ ខោ[១] សោ កោលិយបុត្តោ សុប្បវាសាយ កោលិយធីតាយ បដិស្សុត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ កោលិយបុត្តោ ភគវន្តំ ឯតទវោច សុប្បវាសា ភន្តេ កោលិយធីតា ភគវតោ បាទេ សិរសា វន្ទតិ ឯវញ្ច វទតិ សុប្បវាសា ភន្តេ កោលិយធីតា សត្ត វស្សានិ គព្ភំ ធារេសិ[២] សត្តាហំ មូឡ្ហគព្ភា សា ឯតរហិ សុខិនី អរោគា អរោគំ បុត្តំ វិជាតា សា សត្តាហំ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ ភត្តេន និមន្តេតិ អធិវាសេតុ កិរ ភន្តេ ភគវា សុប្បវាសាយ កោលិយធីតាយ សត្ត ភត្តានិ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។

(៦៦) តេន ខោ បន សមយេន អញ្ញតរេន ឧបាសកេន ពុទ្ធប្បមុខោ ភិក្ខុសង្ឃោ ស្វាតនាយ ភត្តេន និមន្តិតោ ហោតិ ។ សោ ច ឧបាសកោ អាយស្មតោ មហាមោគ្គល្លានស្ស ឧបដ្ឋាកោ ហោតិ ។ អថខោ ភគវា

១ ម. ឯវំ ភទ្ទេតិ ខោ [illegible] ។ ២ ម. ធារេតិ ។



បពិត្រព្រះអង្គដ៏ចំរើន បើដូច្នោះ សូមព្រះមានព្រះភាគព្រមទាំងភិក្ខុសង្ឃ ទទួលភត្ត ៧ ថ្ងៃ របស់កោលិយធីតា នាមសុប្បវាសា ។ កោលិយបុត្តនោះ ទទួលស្ដាប់ពាក្យកោលិយធីតា នាមសុប្បវាសាថា ប្រសើរហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះកោលិយបុត្តនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន កោលិយធីតា នាមសុប្បវាសា ថ្វាយបង្គំព្រះបាទនៃព្រះមានព្រះភាគ ដោយសិរ្សៈ មួយទៀត នាងក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន កោលិយធីតា នាមសុប្បវាសា ទ្រទ្រង់គភ៌អស់ ៧ ឆ្នាំ មានគភ៌លំបាកអស់ ៧ ថ្ងៃ ឥឡូវនេះនាងមានសេចក្ដីសុខ មិនមានរោគ ប្រសូតបុត្រមិនមានរោគ នាងនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយភត្តអស់ ៧ ថ្ងៃ បពិត្រព្រះអង្គដ៏ចំរើន បើដូច្នោះ សូមព្រះមានព្រះភាគ ព្រមទាំងភិក្ខុសង្ឃ ទទួលភត្ត ៧ ថ្ងៃ របស់កោលិយធីតា នាមសុប្បវាសាផង ។

(៦៦) សម័យនោះឯង ឧបាសកម្នាក់ និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយភត្តក្នុងថ្ងៃស្អែក ។ ឧបាសកនោះ ជាឧបដ្ឋាករបស់ព្រះមហាមោគ្គល្លានដ៏មានអាយុ ។ គ្រានោះ ព្រះមានព្រះភាគ

អាយស្មន្តំ មហាមោគ្គល្លានំ អាមន្តេសិ ឯហិ ត្វំ មោគ្គល្លាន យេន សោ ឧបាសកោ តេនុបសង្កម ឧបសង្កមិត្វា តំ ឧបាសកំ ឯវំ វទេហិ សុប្បវាសា អាវុសោ កោលិយធីតា សត្ត វស្សានិ គព្ភំ ធារេសិ សត្តាហំ មូឡ្ហគព្ភា សា ឯតរហិ សុខិនី អរោគា អរោគំ បុត្តំ វិជាតា សា សត្តាហំ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ ភត្តេន និមន្តេតិ[១] ករោតុ សុប្បវាសា កោលិយធីតា សត្ត ភត្តានិ បច្ឆា សោ ការិស្សតិ[២] តុយ្ហំ សោ[៣] ឧបាសកោតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា មហាមោគ្គល្លានោ ភគវតោ បដិស្សុត្វា យេន សោ ឧបាសកោ តេនុបសង្កមិ ឧបសង្កមិត្វា តំ ឧបាសកំ ឯតទវោច សុប្បវាសា អាវុសោ កោលិយធីតា សត្ត វស្សានិ គព្ភំ ធារេសិ សត្តាហំ មូឡ្ហគព្ភា សា ឯតរហិ សុខិនី អរោគា អរោគំ បុត្តំ វិជាតា សា សត្តាហំ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ ភត្តេន និមន្តេតិ ករោតុ សុប្បវាសា កោលិយធីតា សត្ត ភត្តានិ

១ ឱ. និមន្តេសីតិ ។ ២ ម. បច្ឆា ត្វំ ការិស្សសីតិ សព្វត្ថ ។ ៣ ឱ. ម. ទុល្លភោ ។



ទ្រង់ត្រាស់ហៅព្រះមហាមោគ្គល្លានដ៏មានអាយុថា ម្នាលមោគ្គល្លាន អ្នកចូរមក អ្នកចូលទៅរកឧបាសកនោះ លុះចូលទៅដល់ហើយ ចូរនិយាយនឹងឧបាសកនោះយ៉ាងនេះថា ម្នាលអាវុសោ កោលិយធីតា នាមសុប្បវាសា ទ្រទ្រង់គភ៌អស់៧ឆ្នាំ មានគភ៌ជាប់អស់៧ថ្ងៃ ឥឡូវនេះ នាងមានសេចក្ដីសុខ មិនមានរោគ ប្រសូតបុត្រឥតមានរោគ នាងនិមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ដោយភត្តអស់៧ថ្ងៃ សូមឲ្យកោលិយធីតា នាមសុប្បវាសា ធ្វើភត្ត៧ថ្ងៃសិនចុះ ខ្លួនអ្នកចាំធ្វើក្រោយ ព្រោះឧបាសកនោះជាឧបដ្ឋាករបស់លោកស្រាប់ហើយ ។ ព្រះមហាមោគ្គល្លានដ៏មានអាយុទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ រួចចូលទៅរកឧបាសកនោះ លុះចូលទៅដល់ហើយ ក៏និយាយនឹងឧបាសកនោះយ៉ាងនេះថា ម្នាលអាវុសោ កោលិយធីតា នាមសុប្បវាសា ទ្រទ្រង់គភ៌អស់៧ឆ្នាំ មានគភ៌ជាប់អស់៧ថ្ងៃ ឥឡូវនេះ នាងមានសេចក្ដីសុខ មិនមានរោគ ប្រសូតបុត្រឥតមានរោគ នាងនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយភត្តអស់ ៧ ថ្ងៃ សូមឲ្យកោលិយធីតា នាមសុប្បវាសា ធ្វើភត្ត ៧ ថ្ងៃសិនចុះ ខ្លួនអ្នកនឹងធ្វើក្រោយ ។

បច្ឆា ត្វំ ករិស្សសីតិ ។ សចេ មេ ភន្តេ អយ្យោ មហាមោគ្គល្លានោ តិណ្ណំ ធម្មានំ បាដិភោគោ ភោគានញ្ច ជីវិតស្ស ច សទ្ធាយ ច ករោតុ សុប្បវាសា កោលិយធីតា សត្ត ភត្តានិ បច្ឆា(១) ករិស្សាមីតិ ។ ទ្វិន្នំ ខោ អហំ តេ អាវុសោ ធម្មានំ បាដិភោគោ ភោគានញ្ច ជីវិតស្ស ច សទ្ធាយ បន ត្វំយេវ បាដិភោគោតិ ។ សចេ(២) ភន្តេ អយ្យោ មហាមោគ្គល្លានោ ទ្វិន្នំ ធម្មានំ បាដិភោគោ ភោគានញ្ច ជីវិតស្ស ច ករោតុ សុប្បវាសា កោលិយធីតា សត្ត ភត្តានិ បច្ឆា ករិស្សាមីតិ ។ អថខោ អាយស្មា មហាមោគ្គល្លានោ តំ ឧបាសកំ សញ្ញាបេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ ឯតទវោច សញ្ញត្តោ(៣) ភន្តេ សោ ឧបាសកោ មយា ករោតុ សុប្បវាសា កោលិយធីតា សត្ត ភត្តានិ បច្ឆា សោ ករិស្សតីតិ ។ អថខោ សុប្បវាសា កោលិយធីតា សត្តាហំ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេសិ សម្បវារេសិ

១ ម. ម. បច្ឆាហំ ។ ២ ម. ម. សចេ មេ ។ ៣ ម. ម. សញ្ញត្តោ ។



ឧបាសកនោះ និយាយថា បពិត្រលោកដ៏ចំរើន បើព្រះមហាមោគ្គល្លានមានខ្លួនជាធានា ចំពោះធម៌ ៣ យ៉ាងគឺ ភោគៈ ១ ជីវិត ១ សទ្ធា ១ សូមឲ្យកោលិយធីតា ឈ្មោះសុប្បវាសា ធ្វើភត្ត ៧ ថ្ងៃសិនចុះ ខ្ញុំនឹងធ្វើក្រោយ ។ ព្រះមហាមោគ្គល្លានពោលថា ម្នាលអាវុសោ ខ្ញុំអាចធានានូវធម៌ ២ យ៉ាង គឺភោគៈ ១ ជីវិត ១ ចំណែកខាងសទ្ធា ត្រូវតែអ្នកធានាខ្លួនឯងចុះ ។ ឧបាសកនោះនិយាយថា បពិត្រលោកដ៏ចំរើន បើព្រះមហាមោគ្គល្លានដ៏មានអាយុ អាចធានានូវធម៌ ២ យ៉ាងគឺភោគៈ ១ ជីវិត ១ សូមឲ្យកោលិយធីតា ឈ្មោះសុប្បវាសា ធ្វើភត្ត ៧ ថ្ងៃសិនចុះ ខ្ញុំនឹងធ្វើក្រោយ ។ លំដាប់នោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ បានពន្យល់ឧបាសកនោះហើយ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ បានពន្យល់ឧបាសកនោះហើយ សូមឲ្យកោលិយធីតា ឈ្មោះសុប្បវាសា ធ្វើភត្ត ៧ ថ្ងៃសិនចុះ ឧបាសកនោះ នឹងធ្វើខាងក្រោយ ។ លំដាប់នោះ កោលិយធីតា ឈ្មោះសុប្បវាសា អង្គាសភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន អស់ ៧ ថ្ងៃ ឲ្យឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនីយាហារ ដ៏ឧត្តម ដោយដៃខ្លួនឯង ទាល់តែហាមឃាត់

តញ្ច ទារកំ ភគវន្តំ វន្ទាបេសិ ភិក្ខុសង្ឃំ ។ អថខោ អាយស្មា សារីបុត្តោ តំ ទារកំ ឯតទវោច កច្ចិ តេ[1] ទារក ខមនីយំ កច្ចិ យាបនីយំ កច្ចិ ន កិញ្ចិ ទុក្ខន្តិ ។ កុតោ មេ ភន្តេ សារីបុត្ត ខមនីយំ កុតោ យាបនីយំ សត្ត មេ វស្សានិ លោហិតកុម្ភិយា វុត្ថានីតិ ។ អថខោ សុប្បវាសា កោលិយធីតា បុត្តោ មេ ធម្មសេនា-បតិនា សទ្ធិំ មន្តេតីតិ អត្តមនា បមុទិតា បីតិសោម-នស្សជាតា អហោសិ ។ អថខោ ភគវា សុប្បវាសំ កោលិយធីតរំ អត្តមនំ បមុទិតំ បីតិសោមនស្ស-ជាតំ វិទិត្វា សុប្បវាសំ កោលិយធីតរំ ឯតទវោច ឥច្ឆេយ្យាសិ ត្វំ សុប្បវាសេ អញ្ញម្បិ ឯវរូបំ បុត្តន្តិ ។ ឥច្ឆេយ្យាហំ ភន្តេ ភគវា អញ្ញានិបិ ឯវរូបានិ សត្ត បុត្តានីតិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ



រួចហើយ ឲ្យទារកនោះ ថ្វាយបង្គំព្រះមានព្រះភាគនិងភិក្ខុសង្ឃ ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ បានសួរទារកនោះ យ៉ាងនេះថា ម្នាលទារក កាលអ្នកនៅក្នុងគភ៌ ល្មមអត់ទ្រាំបានដែរឬ ល្មមប្រព្រឹត្តទៅបានដែរឬ មិនមានទុក្ខតិចតួចទេឬ ។ ទារកនោះទូលតបថា បពិត្រព្រះសារីបុត្តដ៏ចំរើន ខ្ញុំព្រះករុណា ល្មមអត់ទ្រាំបាន មកពីណា ល្មមប្រព្រឹត្តទៅបាន មកពីណា (ព្រោះ) ខ្ញុំនៅក្នុងផ្ទៃ ប្រឡាក់ដោយឈាម អស់ ៧ ឆ្នាំមកហើយ ។ លំដាប់នោះ កោលិយធីតា នាមសុប្បវាសា មានចិត្តត្រេកអរ រីករាយ កើតបីតិសោមនស្ស ដោយសេចក្ដីគិតថា បុត្តរបស់អញ ចេះប្រឹក្សាជាមួយព្រះធម្មសេនាបតីបាន ។ លំដាប់នោះ ព្រះមានព្រះភាគ បានជ្រាបថា កោលិយធីតា នាមសុប្បវាសា មានចិត្តត្រេកអរ រីករាយ កើតបីតិសោមនស្សហើយ ទើបត្រាស់នឹងកោលិ-យធីតា នាមសុប្បវាសា យ៉ាងនេះថា ម្នាលនាងសុប្បវាសា នាងចង់បានបុត្តដទៃបែបនេះ តទៅទៀតដែរឬ ។ កោលិយធីតា នាមសុប្ប-វាសា ទូលថា បពិត្រព្រះមានព្រះភាគ ដ៏ចំរើន ខ្ញុំម្ចាស់ចង់បានបុត្តដទៃ បែបនេះ ៧ នាក់ទៀត ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្ដីនុ៎ះហើយ ទើបបន្លឺនូវឧទាននេះ ក្នុងវេលានោះថា

អសាតំ សាតរូបេន បិយរូបេន អប្បិយំ ទុក្ខំ សុខស្ស រូបេន បមត្តមតិវត្តតីតិ ។ អដ្ឋមំ[១] ។

[៦៣] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ បុព្វារាមេ មិគារមាតុបាសាទេ ។ តេន ខោ បន សមយេន វិសាខាយ មិគារមាតុយា កោចិទេវ អត្ថោ រញ្ញេ បសេនទិម្ហិ កោសលេ បដិពទ្ធោ[២] ហោតិ ។ តំ រាជា បសេនទិ កោសលោ ន យថាធិប្បាយំ តីរេតិ ។ អថខោ វិសាខា មិគារមាតា ទិវា ទិវស្ស យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ វិសាខំ មិគារមាតរំ ភគវា ឯតទវោច ហន្ទ កុតោ នុ ត្វំ វិសាខេ អាគច្ឆសិ ទិវា ទិវស្សាតិ ។ ឥធ មេ ភន្តេ កោចិទេវ អត្ថោ រញ្ញេ បសេនទិម្ហិ កោសលេ បដិពទ្ធោ ហោតិ តំ រាជា បសេនទិ កោសលោ ន យថាធិប្បាយំ តីរេតីតិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

១ ម. ឧ. អដ្ឋមំ សុត្តំ ។ ២ ម. ឧ. បដិពទ្ធោ ។



អារម្មណ៍ មិនជាទីត្រេកអរ មិនជាទីស្រឡាញ់ អារម្មណ៍ ជាទុក្ខ រមែងគ្របសង្កត់នូវបុគ្គលអ្នកប្រមាទ ដោយសភាពជាទីត្រេកអរ ដោយសភាពជាទីស្រឡាញ់ ដោយសភាពនៃសេចក្ដីសុខ ។ សូត្រទី ៨ ។

[៦៣] ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅ ក្នុងប្រាសាទនៃមិគារមាតា ក្នុងវត្តបុព្វារាម ជិតក្រុងសាវត្ថី ។ សម័យនោះឯង ប្រយោជន៍ណាមួយ របស់នាងវិសាខាមិគារមាតា ជាប្រយោជន៍ជាប់ទាក់ទងនឹងព្រះបាទបសេនទិកោសល ។ ព្រះបាទបសេនទិកោសល ទ្រង់មិនពិចារណាប្រយោជន៍នោះ តាមបំណងឡើយ ។ គ្រានោះ នាងវិសាខាមិគារមាតា ចូលទៅគាល់ព្រះមានព្រះភាគ ទាំងថ្ងៃក្ដៅ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះនាងវិសាខាមិគារមាតា អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលនាងវិសាខា នាងមកអំពីណា ទាំងថ្ងៃក្ដៅម៉្លេះ ។ នាងវិសាខាទូលថា បពិត្រព្រះអង្គដ៏ចំរើន ប្រយោជន៍មួយ របស់ខ្ញុំព្រះអង្គក្នុងទីនេះ ជាប្រយោជន៍ជាប់ទាក់ទង នឹងព្រះបាទបសេនទិកោសល ព្រះបាទបសេនទិកោសល ទ្រង់មិនពិចារណាប្រយោជន៍នោះតាមបំណងឡើយ ។ លុះព្រះមានព្រះភាគ ទ្រង់បានជ្រាបច្បាស់នូវសេចក្ដីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

សព្វំ បរវសំ ទុក្ខំ សព្វំ ឥស្សរិយំ សុខំ
សាធារណេ វិហញ្ញន្តិ យោគា ហិ ទុរតិក្កមាតិ ។
នវមំ(១) ។

(២៦) ឯវមេ សុតំ ។ ឯកំ សមយំ ភគវា អនុបិយាយំ វិហរតិ អម្ពវនេ ។ តេន ខោ បន សមយេន អាយស្មា ភទ្ទិយោ កាឡីគោធាយ បុត្តោ អរញ្ញគតោបិ រុក្ខមូលគតោបិ សុញ្ញាគារគតោបិ អភិក្ខណំ ឧទានំ ឧទានេសិ អហោ សុខំ អហោ សុខន្តិ ។ អស្សោសុំ ខោ សម្ពហុលា ភិក្ខូ អាយស្មតោ ភទ្ទិយស្ស កាឡីគោធាយ បុត្តស្ស អរញ្ញគតស្សបិ រុក្ខមូលគតស្សបិ សុញ្ញាគារគតស្សបិ អភិក្ខណំ ឧទានំ ឧទានេន្តស្ស(២) អហោ សុខំ អហោ សុខន្តិ ។ សុត្វាន តេសំ ឯតទហោសិ និស្សំសយំ ខោ អាវុសោ អាយស្មា ភទ្ទិយោ កាឡីគោធាយ បុត្តោ អនភិរតោ ព្រហ្មចរិយំ ចរតិ យំស បុព្វេ អគារិកភូតស្ស រជ្ជសុខំ សោ តមនុស្សរមានោ អរញ្ញគតោបិ រុក្ខមូលគតោបិ សុញ្ញាគារគតោបិ អភិក្ខណំ

១ ឱ. ម. នវមំ ។ ២ ម. ឧទានេន្តិ ។



(ប្រយោជន៍ណាមួយ) ដែលនៅក្នុងអំណាចនៃជនដទៃទាំងអស់ នាំមកនូវទុក្ខ ឥស្សរភាពទាំងអស់ នាំមកនូវសុខ សត្វទាំងឡាយដែលប្រមូលទៅ ក្នុងហេតុនៃទុក្ខនោះ តែងតែរឿយព្រួយ ព្រោះកិលេសជាគ្រឿងប្រកបទាំងឡាយ សត្វកន្លងបានដោយក្រ ។ សូត្រ ទី ៩ ។

(២៦) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងអម្ពវ័ន ទៀបក្រុងអនុបិយា ។ សម័យនោះ ព្រះភទ្ទិយៈដ៏មានអាយុ ជាបុត្តនាងសាកិយានី ឈ្មោះកាឡិគោធា ទោះនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងបន្លឺឧទានរឿយៗថា ឱ! សុខណាស់ ឱ! សុខណាស់ ។ ពួកភិក្ខុជាច្រើនរូបបានឮថា ព្រះភទ្ទិយៈដ៏មានអាយុ ជាបុត្តនៃនាងសាកិយានី ឈ្មោះកាឡិគោធា ទោះនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងបន្លឺឧទានរឿយៗថា ឱ! សុខណាស់ ឱ! សុខណាស់ ដូច្នេះ ។ លុះភិក្ខុទាំងនោះបានឮហើយ ក៏មានសេចក្តីត្រិះរិះដូច្នេះថា ព្រះភទ្ទិយៈដ៏មានអាយុ ជាបុត្តនាងសាកិយានី ឈ្មោះកាឡិគោធា ប្រាកដជា មិនត្រេកអរប្រព្រឹត្តព្រហ្មចរិយៈជាមិនខាន ព្រះភទ្ទិយៈដ៏មានអាយុនោះ នឹករលឹកសេចក្តីសុខក្នុងរាជ្យរបស់លោក កាលនៅជាគ្រហស្ថកំពីដើម ទោះនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងបន្លឺឧទានរឿយៗថា

ឧទានំ ឧទានេសិ អហោ សុខំ អហោ សុខន្តិ ។ អថខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ អាយស្មា ភន្តេ ភទ្ទិយោ កាឡិគោធាយ បុត្តោ អរញ្ញគតោបិ រុក្ខមូលគតោបិ សុញ្ញាគារគតោបិ អភិក្ខណំ ឧទានំ ឧទានេសិ អហោ សុខំ អហោ សុខន្តិ និស្សំសយំ ខោ ភទ្ទិយោ កាឡិគោធាយ បុត្តោ អនភិរតោ ។បេ។ អហោ សុខន្តិ ។

(៦៨) អថខោ ភគវា អញ្ញតរំ ភិក្ខុំ អាមន្តេសិ ឯហិ ត្វំ ភិក្ខុ មម វចនេន ភទ្ទិយំ ភិក្ខុំ អាមន្តេហិ សត្ថា តំ អាវុសោ ភទ្ទិយ អាមន្តេតីតិ ។ ឯវំ ភន្តេតិ ខោ សោ ភិក្ខុ ភគវតោ បដិស្សុត្វា យេនាយស្មា ភទ្ទិយោ កាឡិគោធាយ បុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ភទ្ទិយំ កាឡិគោធាយ បុត្តំ ឯតទវោច សត្ថា តំ អាវុសោ ភទ្ទិយ អាមន្តេតីតិ ។



ឱហ្ន៎ សុខ អ៊ីយ៉ូះ ឱហ្ន៎ សុខ អ៊ីយ៉ូះ ។ លំដាប់នោះ ពួកភិក្ខុច្រើនរូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ព្រះភទ្ទិយៈដ៏មានអាយុ ជាបុត្តនាងសាកិយានីឈ្មោះកាឡិគោធា ទោះនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងបន្លឺឧទានរឿយ ៗ ថា ឱហ្ន៎ សុខ អ៊ីយ៉ូះ ឱហ្ន៎ សុខ អ៊ីយ៉ូះ ព្រះភទ្ទិយៈជាបុត្តនាងសាកិយានីឈ្មោះកាឡិគោធា ប្រាកដជា អផ្សុកនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ដោយពិត ។ បេ ។ ឱហ្ន៎ សុខ អ៊ីយ៉ូះ ។

(៦៨) គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុមួយរូបហើយ បង្គាប់ថា ម្នាលភិក្ខុ អ្នកចូរមក ចូរហៅភទ្ទិយភិក្ខុ តាមពាក្យតថាគតថា នែអាវុសោភទ្ទិយៈ ព្រះសាស្តាទ្រង់ឲ្យហៅអ្នក ។ ភិក្ខុនោះ ទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ រួចចូលទៅរកព្រះភទ្ទិយៈដ៏មានអាយុ ជាបុត្តនាងសាកិយានីឈ្មោះកាឡិគោធា លុះចូលទៅដល់ហើយ ក៏និយាយនឹងព្រះភទ្ទិយៈដ៏មានអាយុ ជាបុត្តនាងសាកិយានីឈ្មោះកាឡិគោធាថា នែអាវុសោ ភទ្ទិយៈ ព្រះសាស្តាត្រាស់ហៅអ្នក

ឯវមាវុសោតិ ខោ អាយស្មា ភទ្ទិយោ កាឡិគោធាយ បុត្តោ តស្ស ភិក្ខុនោ បដិស្សុត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ ភទ្ទិយំ កាឡិគោធាយ បុត្តំ ភគវា ឯតទវោច សច្ចំ កិរ ត្វំ ភទ្ទិយ អរញ្ញគតោបិ រុក្ខមូលគតោបិ សុញ្ញាគារគតោបិ អភិក្ខណំ ឧទានំ ឧទានេសិ អហោ សុខំ អហោ សុខន្តិ ។ ឯវំ ភន្តេតិ ។ កិំ បន ត្វំ ភទ្ទិយ អត្ថវសំ សម្បស្សមានោ អរញ្ញគតោបិ រុក្ខមូលគតោបិ សុញ្ញាគារគតោបិ អភិក្ខណំ ឧទានំ ឧទានេសិ អហោ សុខំ អហោ សុខន្តិ ។ បុព្វេ មេ ភន្តេ អគារិកភូតស្ស រជ្ជំ ការេន្តស្ស អន្តោបិ អន្តេបុរេ រក្ខា សុសំវិហិតា(១) អហោសិ ពហិបិ អន្តេបុរេ រក្ខា សុសំវិហិតា អហោសិ អន្តោបិ នគរេ រក្ខា សុសំវិហិតា អហោសិ ពហិបិ នគរេ រក្ខា សុសំវិហិតា អហោសិ អន្តោបិ ជនបទេ រក្ខា សុសំវិហិតា អហោសិ ពហិបិ ជនបទេ រក្ខា សុសំវិហិតា អហោសិ ។

១ ឱ. ម. សុសំវិហិតា ។



ព្រះភទ្ទិយៈដ៏មានអាយុជាបុត្តនាងសាកិយានីឈ្មោះកាឡិគោធា ក៏ទទួលពាក្យភិក្ខុនោះថា អើអាវុសោ ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះភទ្ទិយៈដ៏មានអាយុ ជាបុត្តនាងសាកិយានីឈ្មោះកាឡិគោធា អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភទ្ទិយៈ ពិតឬថា អ្នកទោះនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងបន្លឺនូវឧទានរឿយៗថា ឱហ្ន៎ សុខ អ្វីម្ល៉េះ ឱហ្ន៎ សុខ អ្វីម្ល៉េះ ដូច្នេះមែនឬ ។ ព្រះភទ្ទិយៈក្រាបទូលថា ព្រះករុណាព្រះអង្គ ។ ម្នាលភទ្ទិយៈ អ្នកឃើញអំណាចប្រយោជន៍ដូចម្តេច បានជាចូលទៅនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងបន្លឺនូវឧទានរឿយៗថា ឱហ្ន៎ សុខ អ្វីម្ល៉េះ ឱហ្ន៎ សុខ អ្វីម្ល៉េះ ដូច្នេះ ។ បពិត្រព្រះអង្គដ៏ចំរើន កាលពីដើមខ្ញុំព្រះអង្គនៅជាគ្រហស្ថសោយសុខក្នុងរាជ្យ ការរក្សាខាងក្នុងព្រះរាជវាំង គេបានចាត់ចែងល្អហើយ ការរក្សាខាងក្រៅព្រះរាជវាំង គេក៏ចាត់ចែងល្អហើយ ការរក្សាខាងក្នុងនគរ គេចាត់ចែងល្អហើយ ការរក្សាខាងក្រៅនគរ គេចាត់ចែងល្អហើយ ការរក្សាក្នុងជនបទ គេចាត់ចែងល្អហើយ ការរក្សាខាងក្រៅជនបទ គេចាត់ចែងល្អហើយ ។

សេន ទោ អហំ កន្ត ឯវំ វុត្តោ តោបិតោ[១] សត្ថា

ភិតោ ទុរុត្តោ ទុស្សុត្តិ ទុក្រោសី[២] វិហាសី ឯកវហំ ទោ

បជហំ កន្ត អញ្ញតោបិ ព្រហ្មចរិយតោបិ សុញ្ញាគារ-

គតោបិ ឯកគោ អភិតោ អនុត្តរ្ពា អនុស្សតិ អនុ-

ក្រោសី អបេក្ខសន្ធោ បទ្ធាលោ បរជិវុត្តោ[៣] មិតក្ខ-

តេន ចេតសា វិហារាមិ ។ នំ[៤] ទោ អហំ កន្ត

អត្ថាយំ សម្បស្សមានោ អញ្ញតោបិ ព្រហ្មចរិយ-

តោបិ សុញ្ញាគារតោបិ អភិក្កមាំ ទុតាន់ ទុតានេសិ

អហោ សុខំ អហោ សុខន្តិ ។ អជទោ កតក

ឯកមន្តំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

យស្សន្តរតោ ន សន្តិ កោបា

ឥតិ ភវាភវតញ្ច វីតិវត្តោ

តំ វិគតភយំ សុខី អសោកំ

ទេវា នានុភវន្តិ ទស្សនាយាតិ ។ ទសមំ[៥] ។

ពុទ្ធសិក្ខា ទុតិយោ ។

---

១. ម. ឆ. ហត្ថិបាសិកោ ។ ២. ម. ម. ឆ. ឆ. ទុក្កុសោ ។ ៣. ឆ. បរាដ្ឋកេ ។ ៤. ឆ. អត្ថវសំ ។ ៥. ឆ. ឆ. ម. ទសមំ ។





បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនោះឯង ដែលគេរក្សាគ្រប់គ្រងយ៉ាងនេះ

ហើយ ក៏នៅតែភ័យខ្លាចតក់ស្លុតរន្ធត់ព្រឺរោមក្បាល បពិត្រព្រះអង្គដ៏ចំរើន ចំណែក

ខ្ញុំព្រះអង្គឥឡូវនេះឯង ទោះនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុង

ផ្ទះស្ងាត់ក្តី ក៏លែងភ័យ លែងតក់ស្លុត លែងតក់ស្លុតហើយ ជាអ្នកមាន

ការខ្វល់ខ្វាយតិច ជាមនុស្សស្ងប់រម្ងាប់ ចិញ្ចឹមជីវិតដោយបច្ច័យដែលអ្នកដទៃ

ឲ្យ នៅដោយមានចិត្តដូចជាម្រឹគ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ

ពិចារណា ឃើញអំណាចប្រយោជន៍នេះហើយ ទោះនៅក្នុងព្រៃក្តី នៅ

ទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងបន្លឺឧទានរឿយ ៗ ថា សុខ្ញុំ សុខ

ណាស់ហ្ន៎ សុខ ណាស់ហ្ន៎ ដូច្នេះ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់

ជ្រាបច្បាស់សេចក្តីនេះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

សេចក្តីក្រោធ មិនមានក្នុងចិត្តរបស់បុគ្គលណា បុគ្គលនោះឈ្មោះ

ថា កន្លងផុតនូវសេចក្តីចំរើន និងសេចក្តីវិនាស ទេវតាទាំងឡាយ

កម្រនឹងបានឃើញបុគ្គលដែលប្រាសចាកភ័យ បានប្រកបដោយ

សេចក្តីសុខ ឥតសោកនោះឡើយ ។ សូត្រទី ១០ ។

ចប់ ពុទ្ធសិក្ខា ទី ២ ។

## ឧទ្ទានំ

មុចលិន្ទោ រាជា ទណ្ឌេន សក្ការោ ឧបាសកេន ច

គព្ភិនី ឯកបុត្តោ ច សុប្បវាសា វិសាខា ច

កាឡិគោធាយ ភទ្ទិយោតិ ។



## ឧទ្ទាននៃមុចលិន្ទវគ្គនោះគឺ

និយាយអំពីព្រះមានព្រះភាគគង់ទៀបគល់ចិក ១

អំពីព្រះរាជា ១ អំពីការវាយពស់ដោយដំបង ១

អំពីគ្រឿងសក្ការៈ ១ អំពីបុគ្គលម្នាក់ជាឧបាសក ១

អំពីប្រពន្ធព្រាហ្មណ៍មានគភ៌ ១ អំពីកូនតូច ១

អំពីកាលដែលនាងឈ្មោះសុប្បវាសា ១ អំពីនាង

វិសាខា ១ អំពីព្រះភទ្ទិយត្ថេរ ( ជាបុត្ត ) នាង

សាកិយានី ឈ្មោះកាឡិគោធា ១ ។

## ឧទានេ តតិយោ នន្ទវគ្គោ

(៦៦) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ភគវតោ អវិទូរេ និសិន្នោ ហោតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បុរាណកម្មវិបាកជំ ទុក្ខំ តិព្វំ[១] ខរំ កដុកំ វេទនំ អធិវាសេន្តោ សតោ សម្បជានោ អវិហញ្ញមានោ ។ អទ្ទសា ខោ ភគវា តំ ភិក្ខុំ អវិទូរេ និសិន្នំ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បុរាណកម្មវិបាកជំ ទុក្ខំ តិព្វំ[១] ខរំ កដុកំ វេទនំ អធិវាសេន្តំ សតំ សម្បជានំ អវិហញ្ញមានំ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

សព្វកម្មជហស្ស ភិក្ខុនោ
ធុនមានស្ស[៣] បុរេ កតំ រជំ
អមមស្ស ឋិតស្ស តាទិនោ
អត្ថោ នត្ថិ ជនំ លបេតវេតិ ។ សុត្តំ បឋមំ[២] ។

---

១ ឱ.ម. តិព្វំ ខរំ កដុកំ ។ អដ្ឋកថាយំ ទុក្ខំ តិព្វំ បាឋោ ។ ២ ឱ.ម.-សុត្តំ បឋមំ សុត្តំ ។





## ឧទាន នន្ទវគ្គ ទី ៣

(៦៦) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ភិក្ខុមួយរូប អង្គុយពែនភ្នែនក្នុងទីជិតនៃព្រះមានព្រះភាគ ហើយតាំងកាយត្រង់ អត់ទ្រាំទុក្ខវេទនា ដ៏ក្លាខ្លាំង ក្តៅចុករោយ ដែលកើតអំពីផលនៃកម្មចាស់ មានស្មារតី មានសេចក្តីដឹងខ្លួន មិនលំបាក ។ ព្រះមានព្រះភាគ បានទតឃើញភិក្ខុនោះ អង្គុយពែនភ្នែនក្នុងទីជិតនៃព្រះអង្គ តាំងកាយត្រង់ អត់ទ្រាំទុក្ខវេទនា ដ៏ក្លាខ្លាំង ក្តៅចុករោយ ដែលកើតអំពីផលនៃកម្មចាស់ មានស្មារតី មានសេចក្តីដឹងខ្លួន មិនលំបាក ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

ភិក្ខុអ្នកលះបង់កម្មទាំងពួង កំចាត់បង់នូវធូលីគឺកិលេស ដែលខ្លួនធ្លាប់ធ្វើក្នុងកាលមុន មិនមានសេចក្តីប្រកាន់ថាអាត្មាអញ ឋិតនៅនឹងនឹង សេចក្តីត្រូវការដើម្បីរាប់រក[១] ជនដទៃដើម្បីជួយមិនមានឡើយ ។ ចប់ សូត្រទី១ ។

---

១ ប្រយោជន៍ដើម្បីរាប់រកជនដទៃ ឲ្យគេជួយ ... មិនមានឡើយ ព្រោះលោកលែងមានសេចក្តីត្រូវការអាស្រ័យក្នុងសរីរៈ ។ អដ្ឋកថា ។

(៦៧) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា នន្ទោ ភគវតោ ភាតា មាតុច្ឆាបុត្តោ សម្ពហុលានំ ភិក្ខូនំ ឯវំ អារោចេសិ អនភិរតោ អហំ អាវុសោ ព្រហ្មចរិយំ ចរាមិ ន សក្កោមិ ព្រហ្មចរិយំ សន្ធារេតុំ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តិស្សាមីតិ ។ អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច អាយស្មា ភន្តេ នន្ទោ ភគវតោ ភាតា មាតុច្ឆាបុត្តោ សម្ពហុលានំ ភិក្ខូនំ ឯវំ អារោចេសិ អនភិរតោ អហំ អាវុសោ ព្រហ្មចរិយំ ចរាមិ ន សក្កោមិ ព្រហ្មចរិយំ សន្ធារេតុំ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តិស្សាមីតិ ។ អថខោ ភគវា អញ្ញតរំ ភិក្ខុំ អាមន្តេសិ ឯហិ ត្វំ ភិក្ខុ មម វចនេន នន្ទំ ភិក្ខុំ អាមន្តេហិ សត្ថា តំ អាវុសោ នន្ទ អាមន្តេតីតិ ។



(៦៧) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះនន្ទដ៏មានអាយុ ជាព្រះអនុជ ជាបុត្រព្រះមាតុច្ឆា នៃព្រះមានព្រះភាគ និយាយប្រាប់ពួកភិក្ខុច្រើនរូបយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំមិនត្រេកអរនឹងប្រព្រឹត្តព្រហ្មចរិយៈទេ ខ្ញុំមិនអាចនឹងទ្រទ្រង់ព្រហ្មចរិយៈបានទេ ខ្ញុំមុខជានឹងលាលែងសិក្ខា ត្រឡប់ទៅកាន់ភេទជាគ្រហស្ថវិញ ។ លំដាប់នោះ ភិក្ខុមួយរូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនោះ អង្គុយក្នុងទីសមគួរហើយ ក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ព្រះនន្ទដ៏មានអាយុ ជាព្រះអនុជនឹងជាបុត្រព្រះមាតុច្ឆា នៃព្រះមានព្រះភាគ បាននិយាយប្រាប់ពួកភិក្ខុច្រើនរូបយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំមិនត្រេកអរនឹងប្រព្រឹត្តព្រហ្មចរិយធម៌ទេ ខ្ញុំមិនអាចទ្រទ្រង់ព្រហ្មចរិយធម៌បានទេ ខ្ញុំមុខជានឹងលាលែងសិក្ខា ត្រឡប់ទៅកាន់ភេទជាគ្រហស្ថវិញ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុ ១ រូបមកថា ម្នាលភិក្ខុ អ្នកចូរមក ចូរហៅនន្ទភិក្ខុ តាមពាក្យតថាគតថា ម្នាលអាវុសោ នន្ទ ព្រះសាស្តា ទ្រង់ត្រាស់ហៅអ្នក ។

ឯវំ ភន្តេតិ ខោ សោ ភិក្ខុ ភគវតោ បដិស្សុត្វា យេនា-
យស្មា នន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ
នន្ទំ ឯតទវោច សត្ថា តំ អាវុសោ នន្ទ អាមន្តេតីតិ ។
ឯវមាវុសោតិ ខោ អាយស្មា នន្ទោ តស្ស ភិក្ខុនោ
បដិស្សុត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា
ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ។ ឯកមន្តំ និសិន្នំ
ខោ អាយស្មន្តំ នន្ទំ ភគវា ឯតទវោច សច្ចំ កិរ ត្វំ
នន្ទ សម្ពហុលានំ ភិក្ខូនំ ឯវំ អារោចេសិ អនភិរតោ
អហំ អាវុសោ ។បេ។ ហីនាយាវត្តិស្សាមីតិ ។ ឯវំ
ភន្តេតិ ។ កិស្ស បន ត្វំ នន្ទ អនភិរតោ ព្រហ្មចរិយំ
ចរសិ ន សក្កោសិ ព្រហ្មចរិយំ សន្ធារេតុំ សិក្ខំ
បច្ចក្ខាយ ហីនាយាវត្តិស្សសីតិ ។ សាកិយានី
មំ[១] ភន្តេ ជនបទកល្យាណី ឃរា និក្ខមន្តស្ស[២]
ឧបឌ្ឍុល្លិខិតេហិ កេសេហិ អបលោកេត្វា មំ
ឯតទវោច តុវដំ ខោ អយ្យបុត្ត អាគច្ឆេយ្យាសីតិ ។

១ ឱ. ម. មំ ។ ២ ម. និក្ខមន្តំ ។



ភិក្ខុនោះ ទទួលស្តាប់ព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ
ហើយចូលទៅរកព្រះនន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ បាននិយាយ
នឹងព្រះនន្ទ ដ៏មានអាយុ ដូច្នេះថា ម្នាលអាវុសោនន្ទ ព្រះសាស្តាទ្រង់
ត្រាស់ហៅអ្នក ។ ព្រះនន្ទដ៏មានអាយុ ទទួលពាក្យភិក្ខុនោះថា អើអា-
វុសោ ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាប
ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះនន្ទដ៏
មានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា
ម្នាលនន្ទ បានឮថា អ្នកបាននិយាយប្រាប់ពួកភិក្ខុច្រើនរូប យ៉ាងនេះថា
ម្នាលអាវុសោទាំងឡាយ ខ្ញុំមិនត្រេកអរ ។បេ។ ខ្ញុំមុខជានឹងត្រឡប់ទៅ
កាន់ភេទដ៏ថោកទាបវិញដូច្នេះ ពិតមែនឬ ។ ព្រះនន្ទក្រាបទូលថា ព្រះ
ករុណាព្រះអង្គ ពិតមែន ។ ម្នាលនន្ទ ព្រោះហេតុអ្វី បានជាអ្នកមិនត្រេក
អរនឹងប្រព្រឹត្តព្រហ្មចរិយៈ មិនអាចទ្រទ្រង់ព្រហ្មចរិយៈ នឹងពោលលា
សិក្ខា ត្រឡប់ទៅកាន់ភេទដ៏ថោកទាបវិញ ។ បពិត្រព្រះអង្គដ៏ចំរើន កាល
ដែលខ្ញុំព្រះអង្គចេញមកអំពីផ្ទះ នាងសាកិយានី ជនបទកល្យាណី កំពុងតែ
ស្អិតស្អាងសក់បានតែកន្លះ បានក្រឡេកមើលខ្ញុំព្រះអង្គដូច្នេះថា បពិត្រ
ព្រះអយ្យបុត្ត សូមទ្រង់ត្រឡប់មកវិញឆាប់ៗ ណា៎ ។

សោ ខោ អហំ ភន្តំ តំ អនុស្សរមានោ អនភិរតោ ព្រហ្មចរិយំ ចរាមិ ន សក្កោមិ ព្រហ្មចរិយំ សន្ធារេតុំ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តិស្សាមីតិ ។ អថខោ ភគវា អាយស្មន្តំ នន្ទំ ពាហាយ គហេត្វា សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវំ ជេតវនេ អន្តរហិតោ ទេវេសុ តាវតិំសេសុ បាតុរហោសិ ។

(៦៨) តេន ខោ បន សមយេន បញ្ចមត្តានិ អច្ឆរាសតានិ សក្កស្ស ទេវានមិន្ទស្ស ឧបដ្ឋានំ អាគតានិ ហោន្តិ កកុដបាទានិ[១] ។ អថខោ[២] ភគវា អាយស្មន្តំ នន្ទំ អាមន្តេសិ បស្សសិ នោ ត្វំ នន្ទ ឥមានិ បញ្ច អច្ឆរាសតានិ កកុដបាទានីតិ ។ ឯវំ ភន្តេតិ ។ តំ កិំ មញ្ញសិ នន្ទ កតមា នុ ខោ អភិរូបតរា វា ទស្សនីយតរា វា បាសាទិកតរា វា សាកិយានី វា ជនបទកល្យាណី ឥមានិ វា បញ្ច អច្ឆរាសតានិ កកុដបាទានីតិ ។

១ ម. កកុដបាទិនិ ។ ឧ. កកុដបាទិនី ។ ២ ម. អថ ខោ ។



បតិស្រ្តព្រះអង្គមិនបាន ខ្ញុំព្រះអង្គនោះ រលឹកឃើញពាក្យនោះ បានជាមិនត្រេកអរនឹងប្រព្រឹត្តព្រហ្មចរិយៈ មិនអាចទ្រទ្រង់ព្រហ្មចរិយៈបាន នឹងលាលាសិក្ខា ត្រឡប់ទៅកាន់ភេទថោកទាបវិញ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ចាប់ព្រះនន្ទដ៏មានអាយុ ត្រង់ដើមដៃ ហើយបាត់អំពីវត្តជេតពន ទៅប្រាកដឯស្ថានតាវត្តិង្សទេវលោក ដូចជាបុរសមានកំឡាំង លាដៃដែលបត់ ឬបត់ដៃដែលលាដូច្នោះ ។

(៦៨) សម័យនោះឯង ពួកស្រ្តីទេពអប្សរ ចំនួន ៥០០រូប មានសម្បុរជើងដូចសម្បុរជើងព្រាប បានមកគាល់បំរើព្រះឥន្ទ្រ ជាស្តេចទេវតា ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅព្រះនន្ទដ៏មានអាយុថា ម្នាលនន្ទ អ្នកឃើញពួកស្រ្តីទេពអប្សរចំនួន ៥០០រូប ដែលមានសម្បុរជើងដូចជាសម្បុរជើងព្រាបនេះដែរឬ ។ ព្រះនន្ទក្រាបទូលថា ព្រះករុណាព្រះអង្គ ។ ម្នាលនន្ទ អ្នកសំគាល់ហេតុនោះដូចម្តេច នាងសាកិយានីជនបទកល្យាណី នឹងពួកស្រ្តីទេពអប្សរ ចំនួន ៥០០រូប ដែលមានសម្បុរជើងដូចជាសម្បុរជើងព្រាបនេះ តើស្រ្តីណាមានរូបល្អជាង គួរមើលជាង គួរជ្រះថ្លាជាង ។

សេយ្យថាបិ ភន្តេ បលុដ្ឋមក្កដី កណ្ណនាសច្ឆិន្នា ឯវមេវ ខោ ភន្តេ សាកិយានី ជនបទកល្យាណី ឥមេសំ បញ្ចន្នំ អច្ឆរាសតានំ ឧបនិធាយ សង្ខម្បិ ន ឧបេតិ[១] កលភាគម្បិ ន ឧបេតិ ឧបនិធិម្បិ ន ឧបេតិ អថខោ ឥមានិ បញ្ច អច្ឆរាសតានិ អភិរូបតរានិ ចេវ ទស្សនីយតរានិ ច បាសាទិកតរានិ ចាតិ ។ អភិរម នន្ទ អភិរម នន្ទ អហន្តេ បាដិភោគោ បញ្ចន្នំ អច្ឆរាសតានំ បដិលាភាយ កកុដបាទានន្តិ ។ សចេ មេ ភន្តេ ភគវា បាដិភោគោ បញ្ចន្នំ អច្ឆរាសតានំ បដិលាភាយ កកុដបាទានំ[២] អភិរមិស្សាមហំ ភន្តេ ភគវតិ ព្រហ្មចរិយេតិ ។ អថខោ ភគវា អាយស្មន្តំ នន្ទំ ពាហាយ គហេត្វា សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវំ ទេវេសុ តាវតឹសេសុ អន្តរហិតោ ជេតវនេ បាតុរហោសិ ។ អស្សោសុំ ខោ ភិក្ខូ អាយស្មា កិរ នន្ទោ ភគវតោ ភាតា មាតុច្ឆាបុត្តោ អច្ឆរានំ ហេតុ ព្រហ្មចរិយំ ចរតិ

១ ម. ឧបេតិ ។ ២ ម. កកុដបាទិនំ ។



បពិត្រព្រះអង្គដ៏ចំរើន មេស្វាមានរោមរបេច ដែលគេកាត់ត្រចៀកនិងច្រមុះ យ៉ាងណា បពិត្រព្រះអង្គដ៏ចំរើន នាងសាកិយានីជនបទកល្យាណី បើប្រៀបធៀបនឹងពួកស្រីទេពអប្សរទាំង ៥០០ រូបនេះ មិនដល់នូវការរាប់ មិនបានមួយចំណិត ទាំងមិនគួរនឹងប្រៀបផ្ទឹមទេ ប្រៀបដូចគ្នានឹងមេស្វា នោះក៏យ៉ាងនោះដែរ កាលបើយ៉ាងនេះ ពួកស្រីទេពអប្សរទាំង ៥០០ រូបនេះ មានរូបល្អជាងផង គួរមើលជាងផង គួរជ្រះថ្លាជាងផង ។ ម្នាលនន្ទ អ្នកចូរត្រេកអរចុះ ម្នាលនន្ទ អ្នកចូរត្រេកអរចុះ តថាគតជាអ្នកធានាឲ្យអ្នកបាននូវពួកស្រីទេពអប្សរទាំង ៥០០ រូប ដែលមានសម្បុរដូចជាសម្បុរជើងព្រាប ។ បពិត្រព្រះអង្គដ៏ចំរើន បើព្រះមានព្រះភាគ ធានាខ្ញុំព្រះអង្គ បាននូវពួកស្រីទេពអប្សរ ៥០០ រូប ដែលមានសម្បុរដូចសម្បុរជើងព្រាប បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនឹងត្រេកអរក្នុងព្រហ្មចរិយធម៌ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ចាប់នូវព្រះនន្ទដ៏មានអាយុ ត្រង់ដើមដៃ ហើយបាត់អំពីពួកទេវតាជាន់តាវត្តឹង្ស មកប្រាកដនៅវត្តជេតពន ដូចជាបុរសមានកំឡាំង លាដៃដែលបត់ ឬបត់ដៃដែលលាដូច្នោះឯង ។ ពួកភិក្ខុបានឮថា ព្រះនន្ទដ៏មានអាយុ ជាព្រះអនុជ ជាបុត្រព្រះមាតុច្ឆានៃព្រះមានព្រះភាគ ប្រព្រឹត្តព្រហ្មចរិយៈ ព្រោះហេតុ ( បានដល់ ) នូវពួកស្រីទេពអប្សរ

ភគវា កិរស្ស បាដិភោគោ បញ្ចន្នំ អច្ឆរាសតានំ បដិលាភាយ កកុដបាទានន្តិ ។

[៦៥] អថខោ អាយស្មតោ នន្ទស្ស សហាយកា ភិក្ខូ អាយស្មន្តំ នន្ទំ ភតកវាទេន ច ឧបក្កិតកវាទេន ច សមុទាចរន្តិ ភតកោ កិរាយស្មា នន្ទោ ឧបក្កិតកោ កិរាយស្មា នន្ទោ អច្ឆរានំ ហេតុ ព្រហ្មចរិយំ ចរតិ ភគវា កិរស្ស បាដិភោគោ បញ្ចន្នំ អច្ឆរាសតានំ បដិលាភាយ កកុដបាទានន្តិ ។ អថខោ អាយស្មា នន្ទោ សហាយកានំ ភិក្ខូនំ ភតកវាទេន ច ឧបក្កិតកវាទេន ច អដ្ដិយមានោ ហរាយមានោ ជិគុច្ឆមានោ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ ន ចិរស្សេវ យស្សត្ថាយ កុលបុត្តា[១] សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ[២] តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ

១ ម. កុលបុត្តា ។ ២ ម. បព្វជតិ ។



បានឮថា ព្រះមានព្រះភាគ ជាអ្នកធានា ឲ្យលោកបាននូវស្រីទេពអប្សរចំនួន ៥០០ រូប ដែលមានសម្បុរ ដូចជាសម្បុរជើងព្រាប ។

[ ៦៥ ] លំដាប់នោះ ពួកភិក្ខុជាសំឡាញ់ព្រះនន្ទដ៏មានអាយុ តែងហៅព្រះនន្ទដ៏មានអាយុ ដោយពាក្យថា ព្រះនន្ទជាអ្នកស៊ីឈ្នួលផង ដោយពាក្យថា ព្រះនន្ទគឺព្រះមានព្រះភាគជួលហើយផង បានឮថា ព្រះនន្ទដ៏មានអាយុ ជាអ្នកស៊ីឈ្នួល បានឮថា ព្រះនន្ទដ៏មានអាយុ ព្រះមានព្រះភាគជួលហើយ ប្រព្រឹត្តព្រហ្មចរិយធម៌ ព្រោះហេតុតែពួកស្រីទេពអប្សរ បានឮថា ព្រះមានព្រះភាគ ទ្រង់ធានាឲ្យលោកបាននូវពួកស្រីទេពអប្សរចំនួន ៥០០ រូប ដែលមានសម្បុរដូចជាសម្បុរជើងព្រាប ។ លំដាប់នោះ ព្រះនន្ទដ៏មានអាយុ នឿយណាយធុញទ្រាន់ ជិនឆ្អន់នឹងពាក្យរបស់ពួកភិក្ខុជាសំឡាញ់ ដែលនិយាយថា លោកជាអ្នកស៊ីឈ្នួលផង នឹងពាក្យថា លោកគឺព្រះមានព្រះភាគជួលហើយផង ក៏គេចចេញទៅនៅតែម្នាក់ឯង មិនមានសេចក្ដីប្រមាទ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ពួកកុលបុត្ត ដែលចេញចាកផ្ទះហើយ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីឧត្តមគុណណា មិនយូរប៉ុន្មាន លោកក៏បានធ្វើឲ្យជាក់ច្បាស់ សម្រេចឧត្តមគុណនោះ គឺព្រហ្មចរិយៈ ជាទីបំផុត ដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯង ក្នុងបច្ចុប្បន្ន

ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ច បនាយស្មា នន្ទោ អរហតំ អហោសិ ។

(៩០) អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ ឯតទវោច អាយស្មា ភន្តេ នន្ទោ ភគវតោ ភាតា មាតុច្ឆាបុត្តោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តិំ បញ្ញាវិមុត្តិំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។ ភគវតោបិ ញាណំ ឧទបាទិ នន្ទោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តិំ បញ្ញាវិមុត្តិំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។ អថខោ អាយស្មា នន្ទោ តស្សា រត្តិយា



ក៏បានដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចារ្យ តថាគតបាននៅប្រព្រឹត្តរួចហើយ សោឡសកិច្ច តថាគតបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ បណ្ដាព្រះអរហន្តទាំងឡាយ ព្រះនន្ទដ៏មានអាយុ ក៏ជាព្រះអរហន្តមួយរូបដែរ ។

(៩០) សម័យនោះឯង ទេវតាមួយអង្គ កាលរាត្រីបឋមយាមកន្លងទៅហើយ មានរស្មីរុងរឿងញុំាងវត្តជេតពនទាំងមូលឲ្យភ្លឺស្វាងហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតក្នុងទីសមគួរ ។ លុះទេវតានោះ ឋិតក្នុងទីសមគួរហើយ ក៏បានក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ព្រះនន្ទដ៏មានអាយុ ជាព្រះអនុជ ជាបុត្រព្រះមាតុច្ឆា នៃព្រះមានព្រះភាគ បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯង ក្នុងបច្ចុប្បន្នហើយ ។ ញាណក៏កើតដល់ព្រះមានព្រះភាគ ដូច្នោះថា នន្ទភិក្ខុ បានធ្វើឲ្យជាក់ច្បាស់សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯង ក្នុងបច្ចុប្បន្នមែន ។ លុះកន្លងរាត្រីនោះហើយ ព្រះនន្ទដ៏មានអាយុ

អច្ចយេន យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា នន្ទោ ភគវន្តំ ឯតទវោច យំ មេ ភន្តេ ភគវា បាដិភោគោ បញ្ចន្នំ អច្ឆរាសតានំ បដិលាភាយ កកុដបាទានំ មុញ្ចាមហំ ភន្តេ ភគវន្តំ ឯតស្មា បដិស្សវាតិ ។ មយាបិ ខោ ត្វំ នន្ទ ចេតសា ចេតោ បរិច្ច វិទិតោ នន្ទោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តិំ បញ្ញាវិមុត្តិំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ទេវតាបិ[១] មេ ឯតមត្ថំ អារោចេសិ អាយស្មា ភន្តេ នន្ទោ ភគវតោ ភាតា មាតុច្ឆាបុត្តោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តិំ បញ្ញាវិមុត្តិំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។ យទេវ ខោ តេ នន្ទ អនុបាទាយ អាសវេហិ ចិត្តំ វិមុត្តំ[២]

---

១ ម. ទេវតា ។ ២ ម. វិមុត្តំ ។



ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅគាល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយ ក្នុងទីសមគួរ ។ លុះព្រះនន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ទ្រង់ធានាឲ្យខ្ញុំព្រះអង្គបានពួកស្រីទេពអប្សរទាំង ៥០០ រូប មានសម្បុរដូចជាសម្បុរជើងព្រាប ដោយការធានាណា បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ខ្ញុំព្រះអង្គបានរួចចាកការធានានុ៎ះនឹងព្រះមានព្រះភាគហើយ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលនន្ទ តថាគតបានកំណត់ដឹងចិត្ត របស់អ្នកដោយចិត្តថា នន្ទភិក្ខុ បានធ្វើឲ្យជាក់ច្បាស់ សម្រេចចេតោវិមុត្តិ នឹងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯង ក្នុងបច្ចុប្បន្នដែរ ទាំងទេវតា ក៏បានប្រាប់សេចក្តីនុ៎ះដល់តថាគតថា បពិត្រព្រះអង្គដ៏ចំរើន ព្រះនន្ទជាព្រះអនុជ ជាបុត្រព្រះមាតុច្ឆានៃព្រះមានព្រះភាគ បានធ្វើឲ្យជាក់ច្បាស់សម្រេចចេតោវិមុត្តិនឹងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯង ក្នុងបច្ចុប្បន្ន ។ ម្នាលនន្ទ ចិត្តរបស់អ្នកផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនមានសេចក្តីប្រកាន់ ក្នុងកាលណា

អថាហំ មុត្តោ ឯតស្មា បដិស្សវាតិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

យស្ស និត្តិណ្ណោ បង្កោ[១] មទ្ទិតោ កាមកណ្ដកោ[២]
មោហក្ខយំ អនុប្បត្តោ សុខទុក្ខេសុ ន វេធតី
ស ភិក្ខូតិ ។ ទុតិយំ[៣] ។

(៧១) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន យសោជប្បមុខានិ បញ្ចមត្តានិ ភិក្ខុសតានិ សាវត្ថឹ អនុប្បត្តានិ ហោន្តិ ភគវន្តំ ទស្សនាយ ។ តេ ច[៤] អាគន្តុកា ភិក្ខូ នេវាសិកេហិ ភិក្ខូហិ សទ្ធឹ បដិសម្មោទមានា សេនាសនានិ បញ្ញាបយមានា បត្តចីវរានិ បដិសាមយមានា ឧច្ចាសទ្ទា មហាសទ្ទា អហេសុំ ។ អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ កេ បនេតេ អានន្ទ ឧច្ចាសទ្ទា មហាសទ្ទា កេវដ្ដា មញ្ញេ មច្ឆំ វិលោបេន្តីតិ ។

● ១. ឱ. យស្ស និត្តិណ្ណោ បង្កោ ។ ម. យស្ស និតិណ្ណោ បលិខោ ។ ២ ម. កាមកណ្ដកោ ។ ៣ ម. ឱ. ទុតិយំ សុត្តំ ។ ៤ ម. ច តេ ។



ឯតថាគត ក៏រួចស្រឡះ ចាកការប្ដេជ្ញានុ៎ះ ក្នុងកាលនោះដែរ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្ដីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

ភិក្ខុណា បានឆ្លងភក់គឺកាម បានញាំញីបន្លាគឺកាម ភិក្ខុនោះ បាន
ដល់នូវការអស់មោហៈ រមែងមិនញាប់ញ័រព្រោះសុខនឹងទុក្ខឡើយ ។

សូត្រ ទី ២ ។

(៧១) ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ពួកភិក្ខុចំនួន ៥០០ រូប មានព្រះយសោជៈជាប្រធាន បានមកដល់ក្រុងសាវត្ថី ដើម្បីគាល់ព្រះមានព្រះភាគ ។ ពួកអាគន្តុកភិក្ខុទាំងនោះ កាលនិយាយសំណេះសំណាលជាមួយនឹងពួកនេវាសិកភិក្ខុ ឬក្រាលសេនាសនៈ ទុកដាក់បាត្រចីវរ ក៏មានសំឡេងកងរំពង មានសំឡេងខ្លាំង ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមកថា ម្នាលអានន្ទ សូរសំឡេងកងរំពង សូរសំឡេងខ្លាំង ដំណងដូចព្រានសំណាញ់ក្នុងកាលចាប់ត្រី តើជាសំឡេងអ្វី ។

ឯតានិ ភន្តេ យសោជប្បមុខានិ បញ្ចមត្តានិ ភិក្ខុសតានិ សាវត្ថិំ អនុប្បត្តានិ ភគវន្តំ ទស្សនាយ តេ ច អាគន្តុកា ភិក្ខូ នេវាសិកេហិ ភិក្ខូហិ សទ្ធិំ បដិសម្មោទមានា សេនាសនានិ បញ្ញាបយមានា បត្តចីវរានិ បដិសាមយមានា ឧច្ចាសទ្ទា មហាសទ្ទាតិ ។ តេនហានន្ទ មម វចនេន តេ ភិក្ខូ អាមន្តេហិ សត្ថា អាយស្មន្តេ អាមន្តេតីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុត្វា យេន តេ ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា តេ ភិក្ខូ ឯតទវោច សត្ថា អាយស្មន្តេ អាមន្តេតីតិ ។ ឯវមាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ អានន្ទស្ស បដិស្សុត្វា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នេ ខោ តេ ភិក្ខូ ភគវា ឯតទវោច កិន្នុ តុម្ហេ ភិក្ខវេ ឧច្ចាសទ្ទា មហាសទ្ទា កេវដ្ដា មញ្ញេ មច្ឆំ វិលោបេន្តីតិ ។



ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ពួកភិក្ខុ ៥០០រូប មានព្រះយសោជៈជាប្រធាននុ៎ះ បានមកដល់នគរសាវត្ថី ដើម្បីគាល់ព្រះមានព្រះភាគ ពួកអាគន្តុកភិក្ខុទាំងនោះ កាលនិយាយសំណេះសំណាលជាមួយនឹងពួកនេវាសិកភិក្ខុ រៀបចំសេនាសនៈ ទុកដាក់បាត្រចីវរ ក៏មានសំឡេងកងរំពង មានសំឡេងខ្លាំង ។ ម្នាលអានន្ទ បើដូច្នោះ ចូរអ្នកទៅហៅពួកភិក្ខុទាំងនោះតាមពាក្យរបស់តថាគតថា ព្រះសាស្តាត្រាស់ហៅលោកដ៏មានអាយុទាំងឡាយ ។ ព្រះអានន្ទដ៏មានអាយុ បានទទួលស្តាប់ព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយចូលទៅរកពួកភិក្ខុទាំងនោះ លុះចូលទៅដល់ហើយនិយាយនឹងពួកភិក្ខុទាំងនោះថា ព្រះសាស្តាត្រាស់ហៅលោកដ៏មានអាយុទាំងឡាយ ។ ពួកភិក្ខុទាំងនោះ ទទួលពាក្យព្រះអានន្ទដ៏មានអាយុថា អើករុណា ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ដូចម្តេច បានជាអ្នកទាំងឡាយមានសំឡេងកងរំពង មានសំឡេងខ្លាំង ទំនងដូចជាពួកព្រានសំណាញ់ក្នុងកាលចាប់ត្រី ។

(៤២) ឯវំ វុត្តេ អាយស្មា យសោជោ ភគវន្តំ ឯតទវោច ឥមានិ ភន្តេ បញ្ចមត្តានិ ភិក្ខុសតានិ សាវត្ថឹ អនុប្បត្តានិ ភគវន្តំ ទស្សនាយ តេធ អាគន្តុកា ភិក្ខូ នេវាសិកេហិ ភិក្ខូហិ សទ្ធឹ បដិសម្មោទមានា សេនាសនានិ បញ្ញាបយមានា បត្តចីវរានិ បដិសាមយមានា ឧច្ចាសទ្ទា មហាសទ្ទាតិ ។ គច្ឆថ ភិក្ខវេ បណាមេមិ វោ ន វោ មម សន្តិកេ វត្ថព្វន្តិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បដិស្សុត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា សេនាសនំ បដិសាមេត្វា(១) បត្តចីវរមាទាយ យេន វជ្ជី តេន ចារិកំ បក្កមឹសុ វជ្ជីសុ អនុបុព្វេន ចារិកញ្ចរមានា យេន វគ្គុមុទានទី តេនុបសង្កមឹសុ ឧបសង្កមិត្វា វគ្គុមុទានទីតីរេ(២) បណ្ណកុដិយោ ករិត្វា វស្សំ ឧបគច្ឆឹសុ ។

(៤៣) អថខោ អាយស្មា យសោជោ វស្សូបគតោ(៣)

១ ម. សំសាមេត្វា ។ ២ ឱ. ម. វគ្គុមុទាយ នទិយា តីរេ ។ ៣ ម. វស្សូបគតេ ។



(៤២) កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះយសោជៈដ៏មានអាយុ ក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ពួកភិក្ខុ ៥០០ រូបនេះ មកកាន់នគរសាវត្ថី ដើម្បីគាល់ព្រះមានព្រះភាគ ពួកអាគន្តុកភិក្ខុទាំងនោះ កាលនិយាយសំណេះសំណាលជាមួយនឹងពួកនេវាសិកភិក្ខុ ឲ្យក្រាលសេនាសនៈ ទុកដាក់បាត្រចីវរ ក៏មានសំឡេងឧឹកឧរ៉ឹក មានសំឡេងខ្លាំង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរទៅ តថាគតបណ្តេញអ្នកទាំងឡាយ អ្នកទាំងឡាយ មិនត្រូវនៅក្នុងសំណាក់តថាគតទេ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក្រោកចាកអាសនៈថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ទុកដាក់សេនាសនៈ យកបាត្រចីវរ ហើយចៀសចេញទៅកាន់ចារិកក្នុងដែនវជ្ជី កាលត្រាច់ទៅកាន់ចារិកក្នុងដែនវជ្ជីតាមលំដាប់ បានចូលទៅឯស្ទឹងវគ្គុមុទា លុះចូលទៅដល់ហើយ ក៏ធ្វើខ្ទមស្លឹកនៅចាំវស្សា ទៀបមាត់ស្ទឹង ឈ្មោះវគ្គុមុទា ។

(៤៣) សម័យនោះ ព្រះយសោជៈដ៏មានអាយុ នៅចាំវស្សាហើយ

ភិក្ខូ អាមន្តេសិ ភគវតា មយំ អាវុសោ បណាមិតា អត្ថកាមេន ហិតេសិនា អនុកម្បកេន អនុកម្បំ ឧបាទាយ ហន្ទ មយំ អាវុសោ តថា វិហារំ កប្បេម យថា នោ វិហរតំ[១] អត្តមនោ[២] អស្សាតិ ។ ឯវមាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ យសោជស្ស បច្ចស្សោសុំ ។ អថខោ តេ ភិក្ខូ វូបកដ្ឋា អប្បមត្តា អាតាបិនោ បហិតត្តា វិហរន្តា តេនេវន្តរវស្សេន សព្វេវ តិស្សោ វិជ្ជា សច្ឆាកំសុ ។

(៧៦) អថខោ ភគវា សាវត្ថិយំ យថាភិរន្តំ វិហរិត្វា យេន វេសាលី តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកំ ចរមានោ យេន វេសាលី តទវសរិ ។ តត្រ សុទំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថខោ ភគវា វគ្គុមុទាតីរិយានំ ភិក្ខូនំ ចេតសា ចេតោ បរិច្ច មនសិការិត្វា អាយស្មន្តំ អានន្ទំ អាមន្តេសិ

១ ម. ភគវតោ ។ ២ ឱ. ម. អត្តមនោ ។



ក៏ហៅភិក្ខុទាំងនោះមកថា ម្នាលអាវុសោទាំងឡាយ យើងទាំងឡាយត្រូវព្រះមានព្រះភាគ ព្រះអង្គជាអ្នកប្រាថ្នាសេចក្ដីចំរើន ស្វែងរកប្រយោជន៍ ព្រះអង្គអនុគ្រោះ អាស្រ័យសេចក្ដីអនុគ្រោះ ទ្រង់បណ្ដេញហើយ ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគ គប្បីត្រេកអរប្រយោជន៍ ចំពោះពួកយើងកាលនៅដោយការប្រព្រឹត្តយ៉ាងណា ពួកយើង គួរសម្រេចការនៅដោយការប្រព្រឹត្តយ៉ាងនោះចុះ ។ ភិក្ខុទាំងនោះ ទទួលពាក្យព្រះយសោជៈដ៏មានអាយុថា អើអាវុសោ ។ លំដាប់នោះ ភិក្ខុទាំងនោះ ក៏ចៀសចេញទៅ មិនមានសេចក្ដីប្រមាទ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន លុះនៅចាំក្នុងវស្សានោះ ក៏បានធ្វើឲ្យជាក់ច្បាស់នូវវិជ្ជាបីទាំងអស់គ្នា ។

(៧៦) គ្រានោះ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងក្រុងសាវត្ថី តាមសមគួរដល់អធ្យាស្រ័យហើយ ស្ដេចចៀសចេញទៅកាន់ចារិក ក្នុងក្រុងវេសាលី កាលត្រាច់ទៅកាន់ចារិក តាមលំដាប់ ចូលទៅដល់ក្រុងវេសាលី ។ បានឮថា ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារ-សាលា ព្រៃមហាវ័ន ជិតក្រុងវេសាលីនោះ ។ លំដាប់នោះ ព្រះមានព្រះភាគ កំណត់ចិត្តពួកភិក្ខុ អ្នកនៅប្រចាំច្រាំងស្ទឹងវគ្គុមុទា ដោយព្រះទ័យ ហើយធ្វើទុកក្នុងព្រះទ័យ ត្រាស់ហៅ ព្រះអានន្ទដ៏មានអាយុមកថា

អាលោកជាតា វិយ មេ អានន្ទ ឯសា ទិសា ឱភាស-ជាតា វិយ មេ អានន្ទ ឯសា ទិសា យស្សំ ទិសាយំ វគ្គុមុទាតីរិយា ភិក្ខូ វិហរន្តិ គន្តុំ អប្បដិកូលាសិ មេ មនសិកាតុំ បហិណេយ្យាសិ ត្វំ អានន្ទ វគ្គុមុទាតី-រិយានំ ភិក្ខូនំ សន្តិកេ ទូតំ សត្ថា អាយស្មន្តេ អាម-ន្តេតិ សត្ថា អាយស្មន្តានំ ទស្សនកាមោតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុត្វា យេន អញ្ញតរោ ភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា តំ ភិក្ខុំ ឯតទវោច ឯហិ ត្វំ អាវុសោ យេន វគ្គុមុទាតី-រិយា ភិក្ខូ តេនុបសង្កម ឧបសង្កមិត្វា វគ្គុមុទាតីរិយេ ភិក្ខូ ឯវំ វទេហិ សត្ថា អាយស្មន្តេ អាមន្តេតិ សត្ថា អាយស្មន្តានំ ទស្សនកាមោតិ ។ ឯវមាវុសោតិ ខោ សោ ភិក្ខុ អាយស្មតោ អានន្ទស្ស បដិស្សុត្វា សេយ្យ-ថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសា-រេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវំ មហាវនេ កូដាគារសាលាយំ អន្តរហិតោ វគ្គុមុទាយ នទិយា តីរេ តេសំ ភិក្ខូនំ បុរតោ បាតុរហោសិ ។ អថខោ សោ ភិក្ខុ



ពួកភិក្ខុអ្នកនៅប្រមាត់ឆ្នេរស្ទឹងវគ្គុមុទា នៅក្នុងទិសណា ម្នាលអានន្ទ ទិសនុ៎ះឯង ដូចជាមានពន្លឺផ្លេកផ្លែក ម្នាលអានន្ទ ទិសនុ៎ះឯង ដូចជាមានរស្មីផ្លេកផ្លក ភិក្ខុទាំងនោះ តថាគតមិនមែនស្អប់ខ្ពើមដើម្បីនឹងទៅកាន់ទេ តថា-គតមិនមែនស្អប់ខ្ពើមដើម្បីនឹងធ្វើទុកក្នុងចិត្តទេ ម្នាលអានន្ទ អ្នកគប្បីបញ្ជូនទូតទៅក្នុងសំណាក់ពួកភិក្ខុអ្នកនៅប្រមាត់ឆ្នេរស្ទឹងវគ្គុមុទា ដោយពាក្យថា ព្រះសាស្តាត្រាស់ហៅលោកដ៏មានអាយុទាំងឡាយ ព្រះសាស្តាចង់ជួបលោកដ៏មានអាយុទាំងឡាយ ។ ព្រះអានន្ទដ៏មានអាយុ បានទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយចូលទៅរកភិក្ខុមួយរូប លុះចូលទៅដល់ហើយ ក៏បាននិយាយនឹងភិក្ខុនោះថា ម្នាលអាវុសោ អ្នកចូរមក អ្នកចូរទៅរកពួកភិក្ខុអ្នកនៅប្រមាត់ឆ្នេរស្ទឹងវគ្គុមុទា លុះចូលទៅដល់ហើយ ចូរនិយាយប្រាប់ពួកភិក្ខុអ្នកនៅប្រមាត់ឆ្នេរស្ទឹងវគ្គុមុទាយ៉ាងនេះថា ព្រះសាស្តា ទ្រង់ត្រាស់ហៅលោកដ៏មានអាយុទាំងឡាយ ព្រះសាស្តា ចង់ជួបនឹងលោកដ៏មានអាយុទាំងឡាយ ។ ភិក្ខុនោះ បានទទួលពាក្យព្រះអានន្ទដ៏មានអាយុថា អើអាវុសោ ហើយក៏ស្រាប់តែបាត់អំពីកូដាគារសាលា ក្នុងមហាវន ទៅប្រាកដ ក្នុងទីចំពោះមុខពួកភិក្ខុនោះ ប្រមាត់ឆ្នេរស្ទឹងវគ្គុមុទា ដូចជាបុរសមានកំឡាំងលាតដៃដែលបត់ ឬបត់ដៃដែលលាតដូច្នោះ ។ លំដាប់នោះ ភិក្ខុនោះ

វគ្គុមុទាតីរិយេ ភិក្ខូ ឯតទវោច សត្ថា អាយស្មន្តេ អាមន្តេតិ សត្ថា អាយស្មន្តានំ ទស្សនកាមោតិ ។ ឯវ-មាវុសោតិ ខោ តេ ភិក្ខូ តស្ស ភិក្ខុនោ បដិស្សុត្វា សេនាសនំ បដិសាមេត្វា បត្តចីវរមាទាយ សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវំ វគ្គុមុទាយ នទិយា តីរេ អន្តរហិតា មហាវនេ កូដាគារសាលាយំ ភគវតោ សម្មុខេ បាតុរហេសុំ ។

(៧៥) តេន ខោ បន សមយេន ភគវា អានេញ្ជេន សមាធិនា និសិន្នោ ហោតិ ។ អថខោ តេសំ ភិក្ខូនំ ឯតទហោសិ កតមេន នុ ខោ ភគវា វិហារេន ឯតរហិ វិហរតីតិ ។ អថខោ តេសំ ភិក្ខូនំ ឯតទហោសិ អានេញ្ជេន ខោ ភគវា វិហារេន ឯតរហិ វិហរតីតិ ។ សព្វេវ អានេញ្ជេន សមាធិនា និសីទឹសុ ។ អថខោ អាយស្មា អានន្ទោ អភិក្កន្តាយ រត្តិយា និក្ខន្តេ បឋមេ យាមេ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ[១] ករិត្វា យេន ភគវា តេនញ្ជលឹ បណាមេត្វា ភគវន្តំ ឯតទវោច

១ ម. ចីវរំ ករិត្វា ។



បាននិយាយប្រាប់ភិក្ខុ អ្នកនៅប្រចាំក្នុងស្ទឹងវគ្គុមុទាថា ព្រះសាស្ដាទ្រង់ត្រាស់ហៅលោកដ៏មានអាយុទាំងឡាយ ព្រះសាស្ដាចង់ជួបនឹងលោកដ៏មានអាយុទាំងឡាយ ។ ពួកភិក្ខុទាំងនោះ ទទួលពាក្យភិក្ខុនោះថា អើ ករុណា ហើយក៏ទុកដាក់សេនាសនៈ កាន់យកបាត្រនិងចីវរ រួចស្រាប់តែបាត់អំពីច្រាំងស្ទឹងវគ្គុមុទា មកប្រាកដ ក្នុងទីចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគក្នុងកូដាគារសាលា ក្នុងមហាវ័ន ដូចជាបុរសមានកំឡាំងលាដៃដែលបត់ ឬបត់ដៃដែលលាដូច្នោះ ។

(៧៥) សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់ដោយសមាធិ មិនកំរើក ។ លំដាប់នោះ ពួកភិក្ខុទាំងនោះមានសេចក្ដីត្រិះរិះថា ឥឡូវនេះ ព្រះមានព្រះភាគទ្រង់គង់នៅដោយវិហារធម៌ ដូចម្ដេចហ្ន៎ ។ លំដាប់នោះ ភិក្ខុទាំងនោះ មានសេចក្ដីត្រិះរិះថា ឥឡូវនេះ ព្រះមានព្រះភាគទ្រង់គង់នៅ ដោយវិហារធម៌ ដ៏មិនកំរើក ។ ភិក្ខុទាំងអស់ ក៏អង្គុយនៅដោយសមាធិ ដ៏មិនកំរើកដែរ ។ គ្រាកាលដែលរាត្រីកន្លងទៅ បឋមយាមកន្លងហើយ ព្រះអានន្ទដ៏មានអាយុ ក្រោកចាកអាសនៈ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះព្រះមានព្រះភាគ រួចក្រាបទូលព្រះមានព្រះភាគថា

អភិក្កន្តា ភន្តេ រត្តិ និក្ខន្តោ បឋមោ យាមោ ចិរនិសិន្នា អាគន្តុកា ភិក្ខូ បដិសម្មោទតុ ភន្តេ ភគវា អាគន្តុកេហិ ភិក្ខូហីតិ ។ ឯវំ វុត្តេ ភគវា តុណ្ហី អហោសិ ។ ទុតិយម្បិ ខោ អាយស្មា អានន្ទោ អភិក្កន្តាយ រត្តិយា និក្ខន្តេ មជ្ឈិមេ យាមេ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលិំ បណាមេត្វា ភគវន្តំ ឯតទវោច អភិក្កន្តា ភន្តេ រត្តិ និក្ខន្តោ មជ្ឈិមោ យាមោ ចិរនិសិន្នា អាគន្តុកា ភិក្ខូ បដិសម្មោទតុ ភន្តេ ភគវា អាគន្តុកេហិ ភិក្ខូហីតិ ។ ទុតិយម្បិ ខោ ភគវា តុណ្ហី អហោសិ ។ តតិយម្បិ ខោ អាយស្មា អានន្ទោ អភិក្កន្តាយ រត្តិយា និក្ខន្តេ បច្ឆិមេ យាមេ ឧទ្ធស្តេ(១) អរុណេ នន្ទិមុខិយា រត្តិយា ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលិំ បណាមេត្វា ភគវន្តំ ឯតទវោច អភិក្កន្តា ភន្តេ រត្តិ និក្ខន្តោ បច្ឆិមោ យាមោ ឧទ្ធស្តោ អរុណោ នន្ទិមុខី រត្តិ ចិរនិសិន្នា អាគន្តុកា ភិក្ខូ

១ ឱ. ម. ឧទ្ធេ ។



បពិត្រព្រះអង្គដ៏ចំរើន រាត្រីកន្លងហើយ បឋមយាម កន្លងហើយ ពួកអាគន្តុកភិក្ខុ អង្គុយយូរហើយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទ្រង់មានព្រះហឫទ័យ សំណេះសំណាលនឹងពួកអាគន្តុកភិក្ខុ ។ កាលដែលព្រះអានន្ទ ក្រាបទូលយ៉ាងនេះហើយ ព្រះមានព្រះភាគទ្រង់នៅស្ងៀម ។ លុះរាត្រីកន្លងទៅ មជ្ឈិមយាម កន្លងហើយ ព្រះអានន្ទដ៏មានអាយុ ក្រោកចាកអាសនៈ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះព្រះមានព្រះភាគ រួចក្រាបបង្គំទូលព្រះមានព្រះភាគ អស់វារៈជាគំរប់ពីរថា បពិត្រព្រះអង្គដ៏ចំរើន រាត្រីកន្លងទៅ មជ្ឈិមយាម កន្លងហើយ ពួកអាគន្តុកភិក្ខុ អង្គុយយូរហើយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទ្រង់មានព្រះហឫទ័យ សំណេះសំណាលនឹងពួកអាគន្តុកភិក្ខុ ។ ព្រះមានព្រះភាគទ្រង់នៅស្ងៀម អស់វារៈជាគំរប់ពីរ ។ កាលដែលរាត្រីកន្លងទៅ បច្ឆិមយាម កន្លងទៅ អរុណក៏រះឡើង រាត្រីក៏ប្រាកដដូចជាមានមុខស្រស់ ព្រះអានន្ទដ៏មានអាយុ ក៏ក្រោកចាកអាសនៈ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះព្រះមានព្រះភាគ រួចក្រាបបង្គំទូលព្រះមានព្រះភាគ អស់វារៈជាគំរប់បីថា បពិត្រព្រះអង្គដ៏ចំរើន រាត្រីកន្លងទៅ បច្ឆិមយាម កន្លងទៅ អរុណក៏រះហើយ រាត្រីក៏ប្រាកដដូចជាមានមុខស្រស់ ពួកអាគន្តុកភិក្ខុ អង្គុយយូរហើយ

បដិសម្មោទតុ ភន្តេ ភគវា អាគន្តុកេហិ ភិក្ខូហីតិ ។ អថខោ ភគវា តម្ហា សមាធិម្ហា វុដ្ឋហិត្វា អាយស្មន្តំ អានន្ទំ អាមន្តេសិ សចេ ខោ ត្វំ អានន្ទ ជានេយ្យាសិ ឯត្តកម្បិ តេ ន បដិភាសេយ្យ[១] អហញ្ចានន្ទ ឥមានិ ច បញ្ចភិក្ខុសតានិ សព្វេវ អានេញ្ជសមាធិនា និសិន្នាតិ[២] ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

យស្ស ជិតោ កាមកណ្ដកោ
អក្កោសោ ច វធោ ច ពន្ធនញ្ច
បព្វតោ វិយ សោ ឋិតោ អនេជោ
សុខទុក្ខេសុ ន វេធតី ស ភិក្ខូតិ ។ តតិយំ[៣] ។

(៧៦) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា សារីបុត្តោ ភគវតោ អវិទូរេ និសិន្នោ ហោតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។

១ ម. ឯត្តកម្បិ តេ នប្បដិភាសេយ្យ ។ ២ ឱ. និសិន្នម្ហាតិ ។ ៣ ម. ឱ. យសោជសុត្តំ ។



បតិក្រៃក្រៃពេកហើយ សូមព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលសំណេះសំណាលនឹងពួកអាគន្តុកភិក្ខុ ។ សំដាប់នោះ ព្រះមានព្រះភាគទ្រង់ចេញចាកសមាធិនោះហើយ ត្រាស់ហៅព្រះអានន្ទ ដ៏មានអាយុមកថា ម្នាលអានន្ទ ប្រសិនបើអ្នកដឹង អ្នកមិននិយាយពាក្យត្រឹមប៉ុណ្ណេះទេ ម្នាលអានន្ទ (ព្រោះថា) តថាគតផង ភិក្ខុ ៥០០ រូបនេះផង ទាំងអស់គ្នា សុទ្ធតែអង្គុយនៅដោយសមាធិមិនកំរើក ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្ដីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

បន្លាគឺកាម គឺការជេរ ការសម្លាប់ និងការចង ដែលបុគ្គលណា
ឈ្នះហើយ បុគ្គលនោះ ឈ្មោះថាមិនញាប់ញ័របីដូចជាភ្នំ បុគ្គល
នោះឈ្មោះថា ភិក្ខុ រមែងមិនញាប់ញ័រ ព្រោះសុខនិងទុក្ខឡើយ ។

សូត្រទី ៣ ។

(៧៦) ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះសារីបុត្តដ៏មានអាយុ អង្គុយពែនភ្នែន តម្រង់កាយឲ្យត្រង់ តម្កល់ស្មារតីឆ្ពោះទៅរកកម្មដ្ឋាន ក្នុងទីជិតនៃព្រះមានព្រះភាគ ។

អទ្ទសា ខោ ភគវា អាយស្មន្តំ សារីបុត្តំ អវិទូរេ និសិន្នំ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ អថ ខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

យថាបិ បព្វតោ សេលោ អចលោ សុប្បតិដ្ឋិតោ
ឯវំ មោហក្ខយា[១] ភិក្ខុ បព្វតោវ ន វេធតីតិ ។
ចតុត្ថំ[២] ។

(៤៥) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា មហាមោគ្គល្លានោ ភគវតោ អវិទូរេ និសិន្នោ ហោតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ កាយគតាយ សតិយា អជ្ឈត្តំ សូបដ្ឋិតាយ ។ អទ្ទសា ខោ ភគវា អាយស្មន្តំ មហាមោគ្គល្លានំ អវិទូរេ និសិន្នំ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ កាយគតាយ សតិយា អជ្ឈត្តំ សូបដ្ឋិតាយ ។ អថ ខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

---

១ ម. មោហក្ខយោ ។ ២ ឱ. ម. បឋមត្ថំ សុត្តំ ។



ព្រះមានព្រះភាគ ទ្រង់ទតឃើញព្រះសារីបុត្តដ៏មានអាយុ អង្គុយពែនភ្នែនតម្រង់កាយផ្ចង់ស្មារតី ឆ្ពោះមុខទៅរកកម្មដ្ឋាន ក្នុងទីជិតនៃព្រះអង្គ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

ភ្នំជាវិការៈនៃថ្ម មិនកំរើកញាប់ញ័រ តាំងនៅស៊ប់យ៉ាងណា ភិក្ខុ
ដែលអស់មោហៈហើយ រមែងមិនញាប់ញ័រ ដូចភ្នំយ៉ាងនោះដែរ ។
សូត្រ ទី ៤ ។

(៤៥) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមហាមោគ្គល្លានដ៏មានអាយុ អង្គុយពែនភ្នែនក្នុងទីជិតនៃព្រះមានព្រះភាគ ហើយតម្រង់កាយ មានកាយគតាសតិដំកល់ស៊ប់ក្នុងសន្តាន ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញព្រះមហាមោគ្គល្លានដ៏មានអាយុ អង្គុយពែនភ្នែនតម្រង់កាយ មានកាយគតាសតិដំកល់ស៊ប់ក្នុងសន្តាន ក្នុងទីជិតនៃព្រះអង្គ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

សតិ កាយគតា ឧបដ្ឋិតា
ឆសុ ផស្សាយតនេសុ សំវុតោ
សតតំ ភិក្ខុ សមាហិតោ
ជញ្ញា និព្ពានមត្តនោតិ ។ បញ្ចមំ [១] ។

(៧៨) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អាយស្មា បិលិន្ទវច្ឆោ ភិក្ខូ វសលវាទេន សមុទាចរតិ ។ អថ ខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ អាយស្មា ភន្តេ បិលិន្ទវច្ឆោ ភិក្ខូ វសលវាទេន សមុទាចរតីតិ ។ អថ ខោ ភគវា អញ្ញតរំ ភិក្ខុំ អាមន្តេសិ ឯហិ ត្វំ ភិក្ខុ មម វចនេន បិលិន្ទវច្ឆំ ភិក្ខុំ អាមន្តេហិ សត្ថា តំ អាវុសោ វច្ឆ[២] អាមន្តេតីតិ ។ ឯវំ ភន្តេតិ ខោ សោ ភិក្ខុ ភគវតោ បដិស្សុត្វា យេនាយស្មា បិលិន្ទវច្ឆោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ បិលិន្ទវច្ឆំ ឯតទវោច សត្ថា តំ អាវុសោ អាមន្តេតីតិ ។

១ ឱ. ម. បញ្ចមំ នត្ថិ ។



ភិក្ខុតាំងស៊ប់នូវកាយគតាសតិ ហើយបានសង្រួម ក្នុងទ្វារទាំង ៦ ដែលជាហេតុនៃផស្សៈ មានចិត្តតាំងមាំជានិច្ច គប្បីដឹងនូវព្រះនិព្វាន ចំពោះខ្លួន ។ សូត្រទី ៥ ។

(៧៨) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះបិលិន្ទវច្ឆៈដ៏មានអាយុ តែងហៅភិក្ខុទាំងឡាយ ដោយពាក្យអសុរេះ ។ គ្រានោះ ពួកភិក្ខុច្រើនរូប បានចូលទៅគាល់ ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ព្រះបិលិន្ទវច្ឆៈដ៏មានអាយុ ហៅពួកភិក្ខុ ដោយពាក្យអសុរេះ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុមួយរូបមកថា ម្នាលភិក្ខុ អ្នកចូរមក អ្នកចូរហៅបិលិន្ទវច្ឆភិក្ខុមក តាមពាក្យតថាគតថា នែអាវុសោ វច្ឆៈ ព្រះសាស្តាទ្រង់ត្រាស់ហៅលោក ។ ភិក្ខុនោះទទួលព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយចូលទៅរកបិលិន្ទវច្ឆភិក្ខុដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏និយាយប្រាប់បិលិន្ទវច្ឆៈដ៏មានអាយុដូច្នេះថា នែអាវុសោ ព្រះសាស្តា ទ្រង់ត្រាស់ហៅលោក ។

ឯវមាវុសោតិ ខោ អាយស្មា បិលិន្ទវច្ឆោ តស្ស ភិក្ខុនោ បដិស្សុត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ បិលិន្ទវច្ឆំ ភគវា ឯតទវោច សច្ចំ កិរ ត្វំ បិលិន្ទវច្ឆ ភិក្ខូ វសលវាទេន សមុទាចរសីតិ ។ ឯវំ ភន្តេតិ ។ អថខោ ភគវា អាយស្មតោ បិលិន្ទវច្ឆស្ស បុព្វេនិវាសំ មនសិការិត្វា ភិក្ខូ អាមន្តេសិ មា ខោ តុម្ហេ ភិក្ខវេ វច្ឆស្ស ភិក្ខុនោ ឧជ្ឈាយិត្ថ ន ភិក្ខវេ វច្ឆោ ទោសន្តរោ ភិក្ខូ វសលវាទេន សមុទាចរតិ វច្ឆស្ស ភិក្ខវេ ភិក្ខុនោ បញ្ច ជាតិសតានិ អព្វោកិណ្ណានិ ព្រាហ្មណកុលេ បច្ចាជាតានិ សោ តស្ស វសលវាទោ ទីឃរត្តំ សមុទាចិណ្ណោ តេនាយំ វច្ឆោ ភិក្ខូ វសលវាទេន សមុទាចរតីតិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ



បិលិន្ទវច្ឆៈដ៏មានអាយុ ទទួលពាក្យភិក្ខុនោះថា អើអាវុសោ ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះបិលិន្ទវច្ឆៈដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលបិលិន្ទវច្ឆៈ បានឮថា អ្នកហៅពួកភិក្ខុ ដោយពាក្យអស្សុរោះ ពិតមែនឬ ។ បិលិន្ទវច្ឆៈបានក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ពិតមែន ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ធ្វើទុកក្នុងព្រះទ័យនូវបុព្វេនិវាសៈ របស់បិលិន្ទវច្ឆៈដ៏មានអាយុ ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំពោលទោសវច្ឆភិក្ខុឡើយ ម្នាលភិក្ខុទាំងឡាយ វច្ឆភិក្ខុ មិនមែនជាអ្នកមានទោសចិត្ត ហើយហៅពួកភិក្ខុ ដោយពាក្យអស្សុរោះទេ ម្នាលភិក្ខុទាំងឡាយ វច្ឆភិក្ខុធ្លាប់កើត ក្នុងត្រកូលព្រាហ្មណ៍ ច្រឡំបល់គ្នាអស់ ៥០០ ជាតិមកហើយ វច្ឆភិក្ខុនោះ ធ្លាប់សន្សំពាក្យអស្សុរោះនោះអស់កាលជាអង្វែងមកហើយ ហេតុនោះបានជាវច្ឆភិក្ខុនេះ តែងហៅពួកភិក្ខុ ដោយពាក្យអស្សុរោះ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្ដីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

យម្ហិ ន មាយា វសតិ[១] ន មានោ
យោ វីតលោភោ អមមោ និរាសោ
បនុណ្ណកោធោ អភិនិព្វុតត្តោ
សោ ព្រាហ្មណោ សោ សមណោ ស ភិក្ខូតិ ។
ឆដ្ឋំ[២] ។

(៧៩) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អាយស្មា មហាកស្សបោ បិប្ផលិគុហាយំ វិហរតិ សត្តាហំ ឯកបល្លង្កេន និសិន្នោ[៣] អញ្ញតរំ សមាធឹ សមាបជ្ជិត្វា ។ អថខោ អាយស្មា មហាកស្សបោ តស្ស សត្តាហស្ស អច្ចយេន តម្ហា សមាធិម្ហា វុដ្ឋាសិ ។ អថខោ អាយស្មតោ មហាកស្សបស្ស តម្ហា សមាធិម្ហា វុដ្ឋិតស្ស ឯតទហោសិ យន្នូនាហំ រាជគហំ បិណ្ឌាយ បវិសេយ្យន្តិ ។ តេន ខោ បន សមយេន បញ្ចមត្តានិ ទេវតាសតានិ ឧស្សុក្កំ អាបន្នានិ ហោន្តិ អាយស្មតោ មហាកស្សបស្ស បិណ្ឌបាតបដិលាភាយ ។ អថខោ អាយស្មា មហាកស្សបោ

១ ម. វសតី ។ ២ ឧ. ម. ឆដ្ឋំ សុត្តំ ។ ៣ ម. និសិន្នោ ហោតិ អញ្ញតរំ ។



មាយា ( ការបិទបាំងទោសខ្លួន ) និងមានះ ( សេចក្ដីប្រកាន់ ) មិនប្រព្រឹត្តទៅ ក្នុងបុគ្គលណា ឬក៏បុគ្គលណា អស់សេចក្ដីលោភ មិនប្រកាន់ថា របស់អញ មិនមានសេចក្ដីប្រាថ្នា បន្ទោបង់សេចក្ដីក្រោធ មានចិត្តត្រជាក់ បុគ្គលនោះ ហៅថា ព្រាហ្មណ៍ ក៏បាន ថា សមណៈ ក៏បាន ថា ភិក្ខុ ក៏បាន ។ សូត្រ ទី ៦ ។

(៧៩) ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះមហាកស្សបដ៏មានអាយុ នៅក្នុងបិប្ផលិគុហា អង្គុយផ្គត់ផ្គែនតែមួយ ចូលសមាធិ (១) ណាមួយ អស់ ៧ ថ្ងៃ ។ លុះកន្លង ៧ ថ្ងៃនោះហើយ ព្រះមហាកស្សបដ៏មានអាយុ ក៏ចេញអំពីសមាធិនោះ ។ កាលដែលព្រះមហាកស្សបដ៏មានអាយុ ចេញអំពីសមាធិនោះហើយ មានសេចក្ដីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ ចូលទៅបិណ្ឌបាត ក្នុងក្រុងរាជគ្រឹះចុះ ។ សម័យនោះឯង ពួកទេវតាចំនួន ៥០០ អង្គ ដល់នូវការខ្វល់ខ្វាយ ដើម្បីប្រគេនបិណ្ឌបាតចំពោះព្រះមហាកស្សបដ៏មានអាយុ ។ លំដាប់នោះ ព្រះមហាកស្សបដ៏មានអាយុ

១ សំដៅយកអាលោកកសិណសមាធិ ។

តានិ បញ្ចមត្តានិ ទេវតាសតានិ បដិក្ខិបិត្វា បុព្វ-ណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ រាជគហំ បិណ្ឌាយ បាវិសិ ។

[៨០] តេន ខោ បន សមយេន សក្កោ ទេវានមិន្ទោ អាយស្មតោ មហាកស្សបស្ស បិណ្ឌបាតំ ទាតុកាមោ ហោតិ បេសការវណ្ណំ[១] អភិនិម្មិនិត្វា តន្តំ វិនាតិ ។ សុជា អសុរកញ្ញា តសរំ[២] បូរេតិ ។ អថ ខោ អាយស្មា មហាកស្សបោ រាជគហេ សបទានំ បិណ្ឌាយ ចរមានោ យេន សក្កស្ស ទេវានមិន្ទស្ស និវេសនំ តេនុបសង្កមិ ។ អទ្ទសា ខោ សក្កោ ទេវានមិន្ទោ អាយស្មន្តំ មហាកស្សបំ ទូរតោវ អាគច្ឆន្តំ ទិស្វាន ឃរា និក្ខមិត្វា បច្ចុគ្គន្ត្វា ហត្ថតោ បត្តំ គហេត្វា ឃរំ បវិសិត្វា ឃដិយា ឱទនំ ឧទ្ធរិត្វា បត្តំ បូរេត្វា អាយស្មតោ មហាកស្សបស្ស អទាសិ ។

១ ឱ. បេសការិវណ្ណំ ។ ម. បេសការវណ្ណំ ។ ២ ឱ. តសរំ ។ ម. តសំ ។



ហាមឃាត់ពួកទេវតាទាំង ៥០០ អង្គនោះហើយ ស្លៀកស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅបិណ្ឌបាត ឯក្រុងរាជគ្រឹះ ។

(៨០) សម័យនោះឯង សក្កៈ ជាធំជាងពួកទេវតា មានប្រាថ្នា ដើម្បីប្រគេនបិណ្ឌបាត ចំពោះព្រះមហាកស្សប ដ៏មានអាយុ បាននិម្មិតភេទខ្លួន ជាជាងតម្បាញ កំពុងត្បាញនូវតម្បាញ ។ នាងអសុរកញ្ញា ឈ្មោះសុជា កំពុងតម្រៀបពេញត្បារ ។ គ្រានោះ ព្រះមហាកស្សប ដ៏មានអាយុ កំពុងត្រាច់បិណ្ឌបាតតាមលំដាប់ត្រកូល ក្នុងក្រុងរាជគ្រឹះ បានចូលទៅកាន់លំនៅរបស់ទេវតាឈ្មោះសក្កៈ ជាធំជាងពួកទេវតា ។ សក្កៈជាធំជាងពួកទេវតា បានឃើញព្រះមហាកស្សបដ៏មានអាយុ កំពុងនិមន្តមកអំពីចម្ងាយ លុះបានឃើញហើយ ក៏ចេញអំពីផ្ទះទៅទទួលយកបាត្រអំពីព្រះហស្ត ចូលទៅកាន់ផ្ទះ ដួសបាយអំពីឆ្នាំង ដាក់ឲ្យពេញបាត្រ រួចប្រគេន ចំពោះព្រះមហាកស្សប ដ៏មានអាយុ ។

សោ អហោសិ បិណ្ឌបាតោ អនេកសូបោ អនេកព្យញ្ជនោ[១] ។ អថខោ អាយស្មតោ មហាកស្សបស្ស ឯតទហោសិ កោ នុ ខោ អយំ សត្តោ យស្សាយំ ឯវរូបោ ឥទ្ធានុភាវោតិ ។ អថខោ អាយស្មតោ មហាកស្សបស្ស ឯតទហោសិ សក្កោ ខោ អយំ ទេវានមិន្ទោតិ ។ ឥតិ វិទិត្វា សក្កំ ទេវានមិន្ទំ ឯតទវោច កតំ ខោ[២]តេ ឥទំ កោសិយ មា បុនបិ ឯវរូបមកាសីតិ ។ អម្ហាកម្បិ ភន្តេ កស្សប បុញ្ញេន អត្ថោ អម្ហាកម្បិ បុញ្ញេន ករណីយន្តិ ។ អថខោ សក្កោ ទេវានមិន្ទោ អាយស្មន្តំ មហាកស្សបំ អភិវាទេត្វា បទក្ខិណំ កត្វា វេហាសំ អព្ភុគ្គន្ត្វា អាកាសេ អន្តលិក្ខេ តិក្ខត្តុំ ឧទានំ ឧទានេសិ

អហោ ទានំ បរមទានំ កស្សបេ សុប្បតិដ្ឋិតំ
អហោ ទានំ បរមទានំ កស្សបេ សុប្បតិដ្ឋិតន្តិ ។

(៨០) អស្សោសិ ខោ ភគវា ទិព្វាយ សោតធាតុយា វិសុទ្ធាយ អតិក្កន្តមានុសិកាយ សក្កស្ស ទេវានមិន្ទស្ស

១ ឱ. ពិពា បា អនេកសូបអនេកព្យញ្ជនោតិ ទិស្សតិ ។ យុ. អនេកសូបព្យញ្ជនោតិ ទិស្សតិ ។ ២ ឱ. កតំ នុ ខោ ។



បិណ្ឌបាតនោះ មានសម្លច្រើនមុខ មានម្ហូបក្រៀមច្រើនមុខ ។ លំដាប់នោះ ព្រះមហាកស្សបដ៏មានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា សត្វនេះជា អ្វីហ្ន៎ ចុះជាមានឥទ្ធានុភាព មានសភាពយ៉ាងនេះ ។ លំដាប់នោះ ព្រះមហាកស្សបដ៏មានអាយុ មានសេចក្តីត្រិះរិះ ដូច្នេះទៀតថា ម្នាល៎ សក្កៈជាធំជាងទេវតា ទេតើ ។ លុះព្រះមហាកស្សបដ៏មានអាយុ បានដឹងច្បាស់ដូច្នេះហើយ និយាយនឹងសក្កៈជាធំជាងទេវតាថា បពិត្រកោសិយៈ ព្រះអង្គបានធ្វើអំពើនេះហើយ ក្រោយទៅ ព្រះអង្គកុំធ្វើអំពើយ៉ាងនេះទៀតឡើយ ។ បពិត្រព្រះកស្សបដ៏ចំរើន យើងខ្ញុំក៏មានសេចក្តីត្រូវការដោយបុណ្យដែរ យើងខ្ញុំគួរធ្វើបុណ្យបានដែរ ។ លំដាប់នោះ សក្កៈ ជាធំជាងទេវតា ថ្វាយបង្គំព្រះមហាកស្សបដ៏មានអាយុ ធ្វើប្រទក្សិណ ហើយហោះទៅឯអាកាស បន្លឺឧទាន ក្នុងអាកាសជាទីវាលអស់វារៈ ៣ ដងថា

ឱ្ហ៎ ទានដែលអាត្មាអញ បានដំកល់ទុកល្អហើយ ក្នុងព្រះមហា-
កស្សប ហៅពេញជាទានឧត្តម ឱ្ហ៎ ទានដែលអាត្មាអញ បាន
ដំកល់ទុកល្អហើយ ក្នុងព្រះមហាកស្សប ហៅពេញជាទានឧត្តម ។

(៨០) ព្រះមានព្រះភាគទ្រង់បានឮ ដោយទិព្វសោតធាតុដ៏បរិសុទ្ធ កន្លងបង់សោតធាតុរបស់មនុស្សធម្មតា ដែលសក្កៈ ជាធំជាងទេវតា

វេហាសំ អព្ភុគ្គន្ត្វា អាកាសេ អន្តលិក្ខេ តិក្ខត្តុំ ឧទានំ ឧទានេន្តស្ស

អហោ ទានំ បរមទានំ កស្សបេ សុប្បតិដ្ឋិតំ

អហោ ទានំ បរមទានំ កស្សបេ សុប្បតិដ្ឋិតន្តិ ។

អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

បិណ្ឌបាតិកស្ស ភិក្ខុនោ អត្តភរស្ស អនញ្ញបោសិនោ ទេវា បិហយន្តិ តាទិនោ ឧបសន្តស្ស សទា សតីមតោតិ ។ សត្តមំ[1] ។

(៨) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សម្ពហុលានំ ភិក្ខូនំ បិណ្ឌបាតបដិក្កន្តានំ បច្ឆាភត្តំ ករេរិមណ្ឌលមាឡេ សន្និសិន្នានំ សន្និបតិតានំ អយមន្តរាកថា ឧទបាទិ បិណ្ឌបាតិកោ អាវុសោ ភិក្ខុ បិណ្ឌាយ ចរន្តោ

១ ម. ឱ. សត្តមំ ។



កំពុងហោះហើរទៅនាអាកាស ហើយបន្លឺឧទានអស់ ៣ ដង ក្នុងអាកាសដូច្នេះថា

ឱហ្ន៎ ទានដែលអាត្មាអញ បានដំកល់ទុកល្អហើយ ក្នុងព្រះមហាកស្សប ទៅជាទានដ៏ឧត្តម ឱហ្ន៎ ទានដែលអាត្មាអញ បានដំកល់ទុកល្អហើយ ក្នុងព្រះមហាកស្សប ទៅជាទានដ៏ឧត្តម ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

ទេវតាទាំងឡាយ រមែងស្រឡាញ់ភិក្ខុ អ្នកប្រព្រឹត្តបិណ្ឌបាតជាវត្ត អ្នកចិញ្ចឹមតែខ្លួន មិនចិញ្ចឹមបុគ្គលដទៃ ជាអ្នកនឹងធឹង ស្ងប់រម្ងាប់ មានស្មារតី គ្រប់កាល ។ សូត្រ ទី ៧ ។

(៨) ខ្ញុំបានស្តាប់មកយ៉ាងនេះ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន នៃអនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ភិក្ខុច្រើនរូប ត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាជាខាងក្រោយភត្ត ហើយអង្គុយប្រជុំគ្នា ក្នុងរោងឈ្មោះករេរិមណ្ឌល[1] កាលគតអន្តរកថា[2] នេះឡើងថា ម្នាលអាវុសោទាំងឡាយ ភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាត កាលត្រាច់ទៅបិណ្ឌបាត

១ រោងសម្រាប់អង្គុយដែលគេធ្វើជិតដើមក្តិប ។ អដ្ឋកថា ។

២ ពាក្យដែលពោលក្នុងចន្លោះពាក្យ ហៅថា អន្តរកថា ។

លភតិ កាលេន កាលំ មនាបិកេ ចក្ខុនា រូបេ បស្សិតុំ លភតិ កាលេន កាលំ មនាបិកេ សោតេន សទ្ទេ សោតុំ លភតិ កាលេន កាលំ មនាបិកេ ឃានេន គន្ធេ ឃាយិតុំ លភតិ កាលេន កាលំ មនាបិកេ ជិវ្ហាយ រសេ សាយិតុំ លភតិ កាលេន កាលំ មនាបិកេ កាយេន ផោដ្ឋព្វេ ផុសិតុំ ។ បិណ្ឌបាតិកោ អាវុសោ ភិក្ខុ សក្កតោ គរុកតោ មានិតោ បូជិតោ អបចិតោ បិណ្ឌាយ ចរតិ ហន្ទ មយំ អាវុសោ បិណ្ឌបាតិកា ហោម មយម្បិ លច្ឆាម កាលេន កាលំ មនាបិកេ ចក្ខុនា រូបេ បស្សិតុំ មយម្បិ លច្ឆាម កាលេន កាលំ មនាបិកេ សោតេន សទ្ទេ សោតុំ មយម្បិ លច្ឆាម កាលេន កាលំ មនាបិកេ ឃានេន គន្ធេ ឃាយិតុំ មយម្បិ លច្ឆាម កាលេន កាលំ មនាបិកេ ជិវ្ហាយ រសេ សាយិតុំ មយម្បិ លច្ឆាម កាលេន កាលំ មនាបិកេ កាយេន ផោដ្ឋព្វេ ផុសិតុំ មយម្បិ សក្កតា គរុកតា មានិតា បូជិតា អបចិតា បិណ្ឌាយ ចរិស្សាមាតិ ។



តែងបានឃើញរូបទាំងឡាយ ដែលជាទីគាប់ចិត្ត ដោយភ្នែក មួយដង មួយកាល បានឮសម្លេងទាំងឡាយ ដែលជាទីគាប់ចិត្ត ដោយត្រចៀក មួយដង មួយកាល បានធុំក្លិនទាំងឡាយ ដែលជាទីគាប់ចិត្ត ដោយច្រមុះ មួយដង មួយកាល បានទទួលរសទាំងឡាយ ដែលជាទីគាប់ចិត្ត ដោយអណ្តាត មួយដង មួយកាល បានប៉ះពាល់វត្ថុទាំងឡាយ ដែលជាទីគាប់ចិត្ត ដោយកាយ មួយដង មួយកាល ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាត ជាអ្នកគេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ព្រោះនៅបិណ្ឌបាត ម្នាលអាវុសោទាំងឡាយ ណ្ហើយចុះពួកយើង ចូរជាអ្នកប្រព្រឹត្តបិណ្ឌបាត ពួកយើងនឹងបានឃើញរូបទាំងឡាយ ដែលជាទីគាប់ចិត្ត ដោយភ្នែក មួយដងមួយកាលផង ពួកយើងនឹងបានឮសំឡេងទាំងឡាយ ដែលជាទីគាប់ចិត្តដោយត្រចៀក មួយដង មួយកាលផង ពួកយើងនឹងបានធុំក្លិនទាំងឡាយ ដែលជាទីគាប់ចិត្តដោយច្រមុះ មួយដង មួយកាលផង ពួកយើងនឹងបានទទួលរសទាំងឡាយ ដែលជាទីគាប់ចិត្តដោយអណ្តាត មួយដងមួយកាលផង ពួកយើងនឹងបានប៉ះពាល់វត្ថុទាំងឡាយ ដែលជាទីគាប់ចិត្តដោយកាយ មួយដង មួយកាលផង ពួកយើងនឹងជាអ្នកគេធ្វើសក្ការៈគោរព រាប់អាន បូជា កោតក្រែង ព្រោះនៅបិណ្ឌបាតផង ។

អយញ្ចរហិ តេសំ ភិក្ខូនំ អន្តរាកថា ហោតិ វិប្បកតា ។ អថខោ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន ករេរិមណ្ឌលមាឡោ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា ភិក្ខូ អាមន្តេសិ កាយ នុត្ថ ភិក្ខវេ ឯតរហិ កថាយ សន្និសិន្នា កា ច បន វោ អន្តរាកថា វិប្បកតាតិ ។ ឥធ ភន្តេ អម្ហាកំ បច្ឆាភត្តំ បិណ្ឌបាតបដិក្កន្តានំ ករេរិមណ្ឌលមាឡេ សន្និសិន្នានំ សន្និបតិតានំ អយមន្តរាកថា ឧទបាទិ បិណ្ឌបាតិកោ អាវុសោ ភិក្ខុ បិណ្ឌាយ ចរន្តោ លភតិ កាលេន កាលំ មនាបិកេ ចក្ខុនា រូបេ បស្សិតុំ លភតិ កាលេន កាលំ មនាបិកេ សោតេន សទ្ទេ សោតុំ លភតិ កាលេន កាលំ មនាបិកេ ឃានេន គន្ធេ ឃាយិតុំ លភតិ កាលេន កាលំ មនាបិកេ ជិវ្ហាយ រសេ សាយិតុំ លភតិ កាលេន កាលំ មនាបិកេ កាយេន ផោដ្ឋព្វេ ផុសិតុំ



អន្តរកថានេះ ពួកភិក្ខុទាំងនោះ កំពុងតាំងធ្វើឲ្យរបស់ស្រេចនៅឡើយ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ចេញចាកការសម្ងំ ក្នុងវេលាសាយ័ន្ត ក្នុងសាយណ្ហសម័យ ហើយទ្រង់ចូលទៅកាន់រោង ឈ្មោះករេរិមណ្ឌល លុះទ្រង់ចូលទៅដល់ហើយ ក៏គង់លើអាសនៈ ដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគ ទ្រង់គង់ស្រេចហើយ ទើបត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ អ្នកទាំងឡាយ អង្គុយប្រជុំគ្នា ដោយកថាដូចម្ដេច អន្តរកថា ដូចម្ដេច ដែលអ្នកទាំងឡាយ ធ្វើមិនទាន់ចប់ ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន កាលពួកខ្ញុំព្រះអង្គ ត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្ត ហើយអង្គុយប្រជុំគ្នា ក្នុងរោងឈ្មោះករេរិមណ្ឌលនេះ អន្តរកថានេះ កើតឡើងថា ម្នាលអាវុសោទាំងឡាយ ភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាត កាលត្រាច់ទៅបិណ្ឌបាត តែងបានឃើញរូបទាំងឡាយ ដែលជាទីគាប់ចិត្តដោយភ្នែក មួយដង មួយកាល បានឮសំឡេងទាំងឡាយ ដែលជាទីគាប់ចិត្ត ដោយត្រចៀក មួយដង មួយកាល បានធុំក្លិនទាំងឡាយ ដែលជាទីគាប់ចិត្ត ដោយច្រមុះ មួយដង មួយកាល បានទទួលរសទាំងឡាយ ដែលជាទីគាប់ចិត្ត ដោយអណ្ដាត មួយដង មួយកាល បានប៉ះពាល់ផ្សព្វទាំងឡាយ ដែលជាទីគាប់ចិត្ត ដោយកាយ មួយដង មួយកាល

បិណ្ឌបាតិកោ អាវុសោ ភិក្ខុ សក្កតោ គរុកតោ
មានិតោ បូជិតោ អបចិតោ បិណ្ឌាយ ចរតិ ហន្ទ
អាវុសោ មយម្បិ បិណ្ឌបាតិកា ហោម មយម្បិ
លច្ឆាម កាលេន កាលំ មនាបិកេ ចក្ខុនា រូបេ
បស្សិតុំ មយម្បិ លច្ឆាម កាលេន កាលំ មនាបិកេ
សោតេន សទ្ទេ សោតុំ មយម្បិ លច្ឆាម កាលេន
កាលំ មនាបិកេ ឃានេន គន្ធេ ឃាយិតុំ មយម្បិ
លច្ឆាម កាលេន កាលំ មនាបិកេ ជិវ្ហាយ រសេ
សាយិតុំ មយម្បិ លច្ឆាម កាលេន កាលំ មនាបិកេ
កាយេន ផោដ្ឋព្វេ ផុសិតុំ មយម្បិ សក្កតា គរុកតា
មានិតា បូជិតា អបចិតា បិណ្ឌាយ ចរិស្សាមាតិ អយំ
ខោ នោ ភន្តេ អន្តរាកថា វិប្បកតា អថ ភគវា
អនុប្បត្តោតិ ។ ន ខោ បនេតំ ភិក្ខវេ តុម្ហាកំ បតិរូបំ កុលបុ-
ត្តានំ សទ្ធា(១) អគារស្មា អនគារិយំ បព្វជិតានំ យំ តុម្ហេ
ឯវរូបិំ កថំ កថេយ្យាថ(២) សន្និបតិតានំ វោ ភិក្ខវេ ទ្វយំ
ករណីយំ ធម្មី វា កថា អរិយោ វា តុណ្ហីភាវោ ។

---
១ ម. សទ្ធាយ ។



ម្នាលអាវុសោទាំងឡាយ ភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាត មានគេធ្វើសក្ការៈ
គោរព រាប់អាន បូជា កោតក្រែង ត្រាច់ទៅបិណ្ឌបាត ម្នាលអាវុសោភិក្ខុ
ទាំងឡាយ ល្អហើយចុះ ពួកយើងត្រូវជាអ្នកប្រព្រឹត្តបិណ្ឌបាតផង ពួកយើង
នឹងបានឃើញរូបទាំងឡាយ ដែលជាទីគាប់ចិត្តដោយភ្នែក មួយដងមួយ
កាលផង ពួកយើងនឹងបានឮសំឡេងទាំងឡាយ ដែលជាទីគាប់ចិត្តដោយ
ត្រចៀក មួយដងមួយកាលផង ពួកយើងនឹងបានធុំក្លិនទាំងឡាយ ដែលជា
ទីគាប់ចិត្ត ដោយច្រមុះ មួយដង មួយកាលផង ពួកយើងនឹងបានទទួល
រសទាំងឡាយ ដែលជាទីគាប់ចិត្ត ដោយអណ្តាត មួយដង មួយកាលផង
ពួកយើងនឹងបានប៉ះពាល់ផ្សព្វទាំងឡាយ ដែលជាទីគាប់ចិត្ត ដោយកាយ
មួយដង មួយកាលផង ពួកយើងនឹងមានគេធ្វើសក្ការៈ គោរព រាប់អាន
បូជា កោតក្រែង ត្រាច់ទៅបិណ្ឌបាតផង បពិត្រព្រះអង្គដ៏ចំរើន ពួកភិក្ខុ-
ទាំងនេះហើយ ដែលពួកខ្ញុំព្រះអង្គ ធ្វើមិនទាន់ចប់ស្រេចទៅឡើយ ស្រាប់
តែព្រះមានព្រះភាគ ទ្រង់ស្តេចមកដល់ ។ ម្នាលភិក្ខុទាំងឡាយ អ្នក
ទាំងឡាយ ពោលកថា មានសភាពយ៉ាងនេះ មិនសមគួរដល់កុលបុត្តទាំង
ឡាយ ដែលជាកុលបុត្តចេញចាកផ្ទះ ចូលទៅកាន់ផ្នួសៈ ដោយសទ្ធាឡើយ
ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កាលបើបានប្រជុំគ្នា គួរធ្វើអំពើ
២ យ៉ាង គឺធម្មីកថា ១ អរិយតុណ្ហីភាព ១ ។

អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

បិណ្ឌបាតិកស្ស ភិក្ខុនោ អត្តភរស្ស អនញ្ញបោសិនោ ទេវា បិហយន្តិ តាទិនោ ឧបសន្តស្ស សទា សតីមតោតិ ។ អដ្ឋមំ[១] ។

(៨៣) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សម្ពហុលានំ ភិក្ខូនំ បច្ឆាភត្តំ បិណ្ឌបាតបដិក្កន្តានំ ឧបដ្ឋានសាលាយំ សន្និសិន្នានំ សន្និបតិតានំ អយមន្តរាកថា ឧទបាទិ កោ នុ ខោ អាវុសោ សិប្បំ ជានាតិ កោ កឹ សិប្បំ សិក្ខិ កតរំ សិប្បំ សិប្បានំ អគ្គន្តិ ។ តត្ថេកច្ចេ ឯវមាហំសុ ហត្ថិសិប្បំ សិប្បានំ អគ្គន្តិ ។ ឯកច្ចេ ឯវមាហំសុ អស្សសិប្បំ សិប្បានំ អគ្គន្តិ ។ ឯកច្ចេ ឯវមាហំសុ រថសិប្បំ សិប្បានំ អគ្គន្តិ ។

១ ម.ឆ. អដ្ឋមំ ។



លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្ដីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

ទេវតាទាំងឡាយ តែងស្រឡាញ់ភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាត អ្នកចិញ្ចឹមតែខ្លួន មិនចិញ្ចឹមបុគ្គលដទៃ ជាអ្នកនឹងធឹង ប្រសិនបើ (ភិក្ខុនោះ) មិនត្រេកអរនឹងលាភសក្ការៈ ដ៏ស្ងប់ស្ងាត់ ( សេចក្ដីសោកសៅ ហើយនឹងមាន ក្នុងទីចំពោះមុខ ប្ដូរចិត្តមុខមិនខាន ) ។

សូត្រទី ៨ ។

(៨៣) ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ពួកភិក្ខុច្រើនរូប កាលត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្ត អង្គុយប្រជុំគ្នាក្នុងរោងសម្រាប់អង្គុយ អន្តរកថានេះកើតឡើងថា ម្នាលអាវុសោទាំងឡាយ អ្នកណាហ្ន៎ ដឹងនូវសិល្បៈ អ្នកណា ជាអ្នកសិក្សាសិល្បៈអ្វី បណ្ដាសិល្បៈទាំងឡាយ សិល្បៈណា ប្រសើរជាង ។ បណ្ដាភិក្ខុទាំងនោះ ភិក្ខុពួកខ្លះ និយាយយ៉ាងនេះថា បណ្ដាសិល្បៈទាំងឡាយ សិល្បៈខាងដំរីប្រសើរជាង ។ ភិក្ខុពួកខ្លះនិយាយយ៉ាងនេះថា បណ្ដាសិល្បៈទាំងឡាយ សិល្បៈខាងសេះប្រសើរជាង ។ ភិក្ខុពួកខ្លះនិយាយយ៉ាងនេះថា បណ្ដាសិល្បៈទាំងឡាយ សិល្បៈខាងរថប្រសើរជាង ។

ឯកច្ចេ ឯវមាហំសុ ធនុសិប្បំ សិប្បានំ អគ្គន្តិ ។ ឯកច្ចេ ឯវមាហំសុ ថរុសិប្បំ[១] សិប្បានំ អគ្គន្តិ ។ ឯកច្ចេ ឯវមាហំសុ មុទ្ទាសិប្បំ[២] សិប្បានំ អគ្គន្តិ ។ ឯកច្ចេ ឯវមាហំសុ គណនាសិប្បំ[៣] សិប្បានំ អគ្គន្តិ ។ ឯកច្ចេ ឯវមាហំសុ សង្ខានសិប្បំ សិប្បានំ អគ្គន្តិ ។ ឯកច្ចេ ឯវមាហំសុ លេខាសិប្បំ សិប្បានំ អគ្គន្តិ ។ ឯកច្ចេ ឯវមាហំសុ កាព្យសិប្បំ[៤] សិប្បានំ អគ្គន្តិ ។ ឯកច្ចេ ឯវមាហំសុ លោកាយតសិប្បំ[៥] សិប្បានំ អគ្គន្តិ ។ ឯកច្ចេ ឯវមាហំសុ ខេត្តវិជ្ជាសិប្បំ សិប្បានំ អគ្គន្តិ ។ អថខោ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន មណ្ឌលមាឡោ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។

១ ម. ថារុសិប្បំ ។ ២ ឱ.ម. មុទ្ទាសិប្បំ ។ ៣ ឱ.ម. គណនសិប្បំ ។ ៤ ឱ.ម. កាវេយ្យសិប្បំ ។ ៥ ឱ.ម. លោកាយតសិប្បំ ។



ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្ដាសិល្បៈទាំងឡាយ សិល្បៈគឺធ្នូ ប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្ដាសិល្បៈទាំងឡាយ សិល្ប គឺដាវប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្ដាសិល្បៈទាំងឡាយ សិល្បៈគឺមេដៃប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្ដាសិល្បៈទាំងឡាយ សិល្បៈគឺការរាប់ប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្ដាសិល្បៈទាំងឡាយ សិល្បៈគឺការគប់ចូកប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្ដាសិល្បៈទាំងឡាយ សិល្បៈគឺការសរសេរប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្ដាសិល្បៈទាំងឡាយ សិល្បៈគឺកាព្យប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្ដាសិល្បៈទាំងឡាយ សិល្បៈគឺគម្ពីរលោកាយតៈ(១) ប្រសើរជាង ។ ពួកភិក្ខុខ្លះ និយាយយ៉ាងនេះថា បណ្ដាសិល្បៈទាំងឡាយ សិល្បៈគឺវិជ្ជាខាងស្រែប្រសើរជាង ។ ឯអន្តរកថានេះពួកភិក្ខុទាំងនោះមិនទាន់ចប់ស្រេចនៅឡើយ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ចេញចាកការសម្ងំ ក្នុងសាយណ្ហសម័យ ហើយស្ដេចចូលទៅកាន់រោងជាទីអង្គុយ ទ្រង់គង់លើអាសនៈ ដែលគេក្រាលថ្វាយ ។

១ សំដៅយកគម្ពីរនៃពួកពាលជនដែលនិយាយប្រកាន់ខុស មានតក្កវិជ្ជា សត្ថប្បករណ៍ ព្រោះវិតណ្ឌ ស ... ។

និសជ្ជ ខោ ភគវា ភិក្ខូ អាមន្តេសិ កាយ នុត្ថ ភិក្ខវេ ឯតរហិ កថាយ សន្និសិន្នា កា ច បន វោ អន្តរាកថា វិប្បកតាតិ ។ ឥធ ភន្តេ អម្ហាកំ បច្ឆាភត្តំ បិណ្ឌបាតបដិក្កន្តានំ មណ្ឌលមាឡេ សន្និសិន្នានំ សន្និបតិតានំ អយមន្តរាកថា ឧទបាទិ កោ នុ ខោ អាវុសោ សិប្បំ ជានាតិ កោ កឹ សិប្បំ សិក្ខិ កតរំ សិប្បំ សិប្បានំ អគ្គន្តិ ។ តត្ថេកច្ចេ ឯវមាហំសុ ហត្ថិសិប្បំ សិប្បានំ អគ្គន្តិ ។ ឯកច្ចេ ឯវមាហំសុ អស្សសិប្បំ សិប្បានំ អគ្គន្តិ ។ ឯកច្ចេ ឯវមាហំសុ រថសិប្បំ សិប្បានំ អគ្គន្តិ ។ ឯកច្ចេ ឯវមាហំសុ ធនុសិប្បំ សិប្បានំ អគ្គន្តិ ។ ឯកច្ចេ ឯវមាហំសុ ថរុសិប្បំ សិប្បានំ អគ្គន្តិ ។ ឯកច្ចេ ឯវមាហំសុ មុទ្ទាសិប្បំ សិប្បានំ អគ្គន្តិ ។ ឯកច្ចេ ឯវមាហំសុ គណនាសិប្បំ សិប្បានំ អគ្គន្តិ ។



លុះព្រះមានព្រះភាគ ទ្រង់គង់ស្រេចហើយ ទើបត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ អ្នកទាំងឡាយ អង្គុយប្រជុំគ្នា ដោយកថាដូចម្តេច អន្តរកថាដូចម្តេច ដែលអ្នកទាំងឡាយធ្វើមិនទាន់ចប់ស្រេចនៅឡើយ ។ ពួកភិក្ខុទាំងនោះ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន កាលដែលពួកខ្ញុំព្រះអង្គត្រឡប់មក អំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្ត ហើយអង្គុយប្រជុំគ្នា ក្នុងរោងសម្រាប់អង្គុយនេះ អន្តរកថាកើតឡើងថា ម្នាលអាវុសោទាំងឡាយ អ្នកណាដឹង នូវសិល្បៈ អ្នកណាជាអ្នកសិក្សាសិល្បៈអ្វី បណ្តាសិល្បៈទាំងឡាយ សិល្បៈណា ប្រសើរជាង ។ បណ្តាភិក្ខុទាំងនោះ ពួកភិក្ខុខ្លះ និយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈដំរីប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈក្នុងសេះប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈក្នុងរថប្រសើរជាង ។ ពួកភិក្ខុខ្លះ និយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈក្នុងធ្នូប្រសើរជាង ។ ពួកភិក្ខុខ្លះ និយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈក្នុងដាវប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈក្នុងមេដៃប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្តាសិល្បៈទាំងឡាយ សិល្បៈក្នុងការរាប់តាមលំដាប់ប្រសើរជាង ។

ឯកច្ចេ ឯវមាហំសុ សង្ខានសិប្បំ សិប្បានំ អគ្គន្តិ ។ ឯកច្ចេ ឯវមាហំសុ លេខាសិប្បំ សិប្បានំ អគ្គន្តិ ។ ឯកច្ចេ ឯវមាហំសុ កាព្យសិប្បំ សិប្បានំ អគ្គន្តិ ។ ឯកច្ចេ ឯវមាហំសុ លោកាយតសិប្បំ សិប្បានំ អគ្គន្តិ ។ ឯកច្ចេ ឯវមាហំសុ ខេត្តវិជ្ជាសិប្បំ សិប្បានំ អគ្គន្តិ ។ អយំ ខោ នោ ភន្តេ អន្តរកថា វិប្បកតា អថ ភគវា អនុប្បត្តោតិ ។ ន ខ្វេតំ ភិក្ខវេ តុម្ហាកំ បតិរូបំ កុលបុត្តានំ សទ្ធា អគារស្មា អនគារិយំ បព្វជិតានំ យំ តុម្ហេ ឯវរូបិំ កថំ កថេយ្យាថ ។ សន្និបតិតានំ វោ ភិក្ខវេ ទ្វយំ ករណីយំ ធម្មី វា កថា អរិយោ វា តុណ្ហីភាវោតិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

អសិប្បជីវី លហុ អត្ថកាមោ
យតិន្ទ្រិយោ សព្វធិ វិប្បមុត្តោ



ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្ដាសិល្បៈទាំងឡាយ សិល្បៈគឺការរាប់បូកប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្ដាសិល្បៈទាំងឡាយ សិល្បៈគឺការសរសេរប្រសើរជាង ។ ពួកភិក្ខុខ្លះនិយាយយ៉ាងនេះថា បណ្ដាសិល្បៈទាំងឡាយ សិល្បៈគឺកាព្យប្រសើរជាង ។ ពួកភិក្ខុខ្លះ និយាយយ៉ាងនេះថា បណ្ដាសិល្បៈទាំងឡាយ សិល្បៈគឺគម្ពីរលោកាយតៈប្រសើរជាង ។ ពួកភិក្ខុខ្លះ និយាយយ៉ាងនេះថា បណ្ដាសិល្បៈទាំងឡាយ សិល្បៈគឺវិជ្ជាខាងស្រែ ប្រសើរជាង ។ បពិត្រព្រះអង្គដ៏ចំរើន អន្តរកថានេះហើយ ដែលពួកខ្ញុំព្រះអង្គ ធ្វើកុំទាន់ចប់ស្រេចនៅឡើយ ស្រាប់តែព្រះមានព្រះភាគ ទ្រង់ស្ដេចមកដល់ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ពោលកថាមានសភាពយ៉ាងនេះ មិនសមគួរដល់អ្នកទាំងឡាយ ដែលជាកុលបុត្តចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយសទ្ធាទេ ។ ម្នាលភិក្ខុទាំងឡាយ កាលអ្នកទាំងឡាយប្រជុំគ្នាគួរធ្វើអំពើ ២ យ៉ាង គឺ ធម្មីកថា ឬ អរិយតុណ្ហីភាព ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្ដីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

បុគ្គលណា ជាអ្នកមិនចិញ្ចឹមជីវិត ដោយសិល្បៈ ជាអ្នក
ប្រព្រឹត្តស្រាល ប្រាថ្នាប្រយោជន៍ ដល់ជនដទៃ ។ សង្រួម
ឥន្ទ្រិយ មានចិត្តផុតស្រឡះ ចាកអាសវៈទាំងពួង

អនោកសារី អមមោ និរាសោ
ហិត្វា មានំ(១) ឯកចរោ ស ភិក្ខូតិ ។ នវមំ(២) ។

[៨៦] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ឧរុវេលាយំ វិហរតិ នជ្ជា នេរញ្ជរាយ តីរេ ពោធិរុក្ខមូលេ បឋមាភិសម្ពុទ្ធោ ។ តេន ខោ បន សមយេន ភគវា សត្តាហំ ឯកបល្លង្កេន និសិន្នោ ហោតិ វិមុត្តិសុខំ បដិសំវេទី ។ អថខោ ភគវា តស្ស សត្តាហស្ស អច្ចយេន តម្ហា សមាធិម្ហា វុដ្ឋហិត្វា ពុទ្ធចក្ខុនា លោកំ វោលោកេសិ ។ អទ្ទសា ខោ ភគវា ពុទ្ធចក្ខុនា(៣) វោលោកេន្តោ សត្តេ អនេកេហិ សន្តាបេហិ សន្តប្បមានេ អនេកេហិ ច បរិឡាហេហិ បរិឌយ្ហមានេ រាគជេហិបិ ទោសជេហិបិ មោហជេហិបិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

អយំ លោកោ សន្តាបជាតោ ផស្សបរេតោ រោគំ វទតិ
អត្តតោ
យេន ហិ មញ្ញតិ តតោ តំ ហោតិ អញ្ញថា

---
១ ឱ. ហត្វា មានំ ។ ម. ហិត្វា មានំ ។ ២ ឱ. ម. សិប្បសុត្តំ ។ ៣ ឱ. ពុទ្ធចក្ខុ វោលោកេន្តិ អត្ថិ ។



មិនមានទីនៅនៃតណ្ហា មិនមានសេចក្ដីប្រកាន់ថា របស់អញ
មិនមានសេចក្ដីប្រាថ្នា បានលះបង់មានះហើយ បានទៅម្នាក់ឯង
បុគ្គលនោះឈ្មោះថា ភិក្ខុ ។ សូត្រ ទី ៩ ។

[៨៦] ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទើបនឹងត្រាស់ដឹងថ្មីៗ ទ្រង់គង់នៅ ទៀបគល់ពោធិព្រឹក្ស ប្រចាំស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេស ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់ដោយបល្ល័ង្កតែមួយ សោយវិមុត្តិសុខអស់ ៧ ថ្ងៃ ។ លុះកន្លង ៧ ថ្ងៃនោះទៅហើយ ព្រះមានព្រះភាគ ទ្រង់ចេញចាកសមាធិនោះហើយប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ។ កាលព្រះមានព្រះភាគ ទ្រង់ប្រមើលមើលដោយពុទ្ធចក្ខុ ទ្រង់បានឃើញពួកសត្វដែលកំពុងក្ដៅក្រហាយ ដោយគ្រឿងក្ដៅជាអនេកប្រការ កំពុងឆេះរោលរាល ដោយគ្រឿងឆេះរោលរាលជាអនេកប្រការ ដែលកើតអំពីរាគៈខ្លះ កើតអំពីទោសៈខ្លះ កើតអំពីមោហៈខ្លះ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្ដីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

សត្វលោកនេះមានសេចក្ដីក្ដៅក្រហាយ ត្រូវផស្សៈគ្របសង្កត់ហើយ
រមែងពោលនូវខន្ធបញ្ចកៈ ដែលមានរោគថាជាខ្លួន ព្រោះថាសំគាល់
ឃើញ ដោយអាការណា ខន្ធបញ្ចកៈនោះ រមែងប្រែប្រួលទៅ

អញ្ញថាភាវី ភវសត្តោ[១] លោកោ ភវបរេតោ ភវមេ-
វាភិនន្ទតិ ។
យទាភិនន្ទតិ[២] តំ ភយំ យស្ស ភាយតិ តំ ទុក្ខំ
ភវវិប្បហានាយ ខោ បនិទំ ព្រហ្មចរិយំ វុស្សតិ[៣] ។
យេ ហិ កេចិ សមណា វា ព្រាហ្មណា វា ភវេន ភវស្ស
វិប្បមោក្ខមាហំសុ
សព្វេតេ អវិប្បមុត្តា ភវស្មាតិ វទាមិ ។
យេ វា បន កេចិ សមណា វា ព្រាហ្មណា វា វិភវេន
ភវស្ស និស្សរណមាហំសុ
សព្វេតេ អនិស្សដា[៤] ភវស្មាតិ វទាមិ ។
សព្វុបធឹ ហិ[៥] បដិច្ច ទុក្ខមិទំ សម្ភោតិ
សព្វុបាទានក្ខយា នត្ថិ ទុក្ខស្ស សម្ភវោ ។
លោកមិមំ បស្ស បុថុ អវិជ្ជាយ បរេតា ភូតា ភូតរតា
ភវា អបរិមុត្តា ។

១ ម. ភវប្បត្តោ ។ ២ ម. យទភិនន្ទតិ ។ ៣ ម. វុសីតិ ។ ៤ ម. អនិស្ស-
ដា ។ ៥ ម. ឧបធឹ ហិ ។



តាមភាពនោះ សត្វលោក ជាប់ចំពាក់ក្នុងភព ត្រូវភពគ្របសង្កត់
មានភាពប្រែប្រួលជាធម្មតា រមែងត្រេកត្រអាលនឹងភព ។ សត្វត្រេកអរ
នឹងរបស់ណា របស់នោះជាភ័យ ខ្លាចចំពោះរបស់ណា របស់នោះជាទុក្ខ
តថាគតប្រព្រឹត្តព្រហ្មចរិយៈនេះ ដើម្បីលះបង់នូវភព ។ ពួក
សមណៈ ឬព្រាហ្មណ៍ណាមួយ ពោលនូវការរួចចាកភពដោយភព
(សស្សតទិដ្ឋិ) ពួកសមណៈឬព្រាហ្មណ៍ទាំងអស់នោះ តថាគតពោលថា-
មិនផុតស្រឡះចាកភពឡើយ ។ មួយទៀត ពួកសមណៈឬព្រាហ្មណ៍
ណាមួយ ពោលនូវការរលាស់ចាកភពដោយវិភព ( ឧច្ឆេទទិដ្ឋិ )
ពួកសមណៈ ឬព្រាហ្មណ៍ទាំងអស់នោះ តថាគតពោលថា មិនរលាស់
ចេញចាកភពបានឡើយ ។ ព្រោះថាទុក្ខនេះ កើតមានព្រោះអាស្រ័យ
ឧបធិទាំងពួង ការកើតនៃទុក្ខមិនមាន ព្រោះអស់ឧបាទានទាំងពួង ។ អ្នក
ចូរមើលលោកនេះចុះ ពួកសត្វ អ្នកត្រេកអរក្នុងពួកសត្វ ដែលអវិជ្ជា
គ្របសង្កត់ហើយ មិនរួចស្រឡះ ( ចាកទុក្ខ ) បានឡើយ ។

យេ ហិ កេចិ ភវា សព្វធិ សព្វត្ថតាយ
សព្វេ តេ ភវា អនិច្ចា ទុក្ខា វិបរិណាមធម្មា[១] ។
ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតោ
ភវតណ្ហា បហីយតិ វិភវតណ្ហាភិនន្ទតិ[២] ។
សព្វសោ[៣] តណ្ហានំ ខយា អសេសវិរាគនិរោធោ និព្វានំ
តស្ស និព្វុតស្ស ភិក្ខុនោ អនុបាទា បុនព្ភវោ ន ហោតិ ។
អភិភូតោ មារោ វិជិតសង្គាមោ ឧបច្ចគា សព្វភវានិ តា-
ទីតិ ។ ទសមំ[៤] ។

នន្ទវគ្គោ តតិយោ ។

## តស្សុទ្ទានំ

កម្មំ នន្ទោ យសោជោ ច សារីបុត្តោ ច កោលិតោ
បិលិន្ទោ កស្សបោ បិណ្ឌោ សិប្បំ លោកេន តេ ទសាតិ ។

---

១ ម. យ. ធម្មាតិ ។ ២ ម. វិភវំ នាភិនន្ទតិ ។ ៣ ម. សព្វតោ ។
៤ ម. យ. ទសមំ សុត្តំ ។



ព្រោះថា ភពណាមួយ ក្នុងទីទាំងពួង គ្រប់ទិសទាំងអស់ ភពទាំងអស់នោះ សុទ្ធតែមិនទៀង ជាទុក្ខ មានការប្រែប្រួលជាធម្មតា ។ កាលបើបុគ្គលឃើញហេតុនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃតាមពិត យ៉ាងនេះហើយ រមែងលះបង់ ភវតណ្ហា មិនត្រេកត្រអាលចំពោះវិភវតណ្ហាឡើយ ។ ការប្រាសចាកតម្រេក និងការរលត់មិនសល់ ព្រោះអស់តណ្ហាទាំងឡាយ ដោយសព្វគ្រប់ ឈ្មោះថា និព្វាន ភពថ្មី ក៏មិនមានដល់ភិក្ខុនោះ អ្នករលត់ហើយ ព្រោះមិនមានឧបាទាន ។ ភិក្ខុនោះបានគ្របសង្កត់មារ ទាំងឈ្នះសង្គ្រាម ជាអ្នកនឹងធឹង កន្លងភពទាំងអស់បាន ។ សូត្រទី ១០ ។

ចប់ នន្ទវគ្គ ទី ៣ ។

## ឧទ្ទាននៃនន្ទវគ្គនោះគឺ

និយាយអំពីផលនៃកម្មចាស់ ១ ព្រះនន្ទ ១ ព្រះយសោជៈ ១ ព្រះសារីបុត្ត ១ ព្រះកោលិត(មោគ្គល្លាន) ១ ព្រះបិលិន្ទវច្ឆៈ ១ ព្រះកស្សប ១ ភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាត ១ សិល្បៈ ១ សត្វលោក ១ រួមទាំងអស់ត្រូវជា ១០ ។

## ឧទានេ ចតុត្ថោ មេឃិយវគ្គោ

(៨៨) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ចាលិកាយំ វិហរតិ ចាលិកេ បព្វតេ ។ តេន ខោ បន សមយេន អាយស្មា មេឃិយោ ភគវតោ ឧបដ្ឋាកោ ហោតិ ។ អថខោ អាយស្មា មេឃិយោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ អាយស្មា មេឃិយោ ភគវន្តំ ឯតទវោច ឥច្ឆាមហំ ភន្តេ ជន្តុគាមេ[១] បិណ្ឌាយ បវិសិតុន្តិ ។ យស្សទានិ ត្វំ មេឃិយ កាលំ មញ្ញសីតិ ។ អថខោ អាយស្មា មេឃិយោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ ជន្តុគាមំ បិណ្ឌាយ បាវិសិ ។ ជន្តុគាមេ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ យេន កិមិកាឡាយ នទិយា តីរំ តេនុបសង្កមិ ឧបសង្កមិត្វា កិមិកាឡាយ នទិយា តីរេ ជង្ឃាវិហារំ អនុចង្កមមានោ អនុវិចរមានោ អទ្ទសា ខោ អម្ពវនំ បាសាទិកំ មនុញ្ញំ រមណីយំ

១ ម. ជន្តុគាមំ ។



## ឧទាន មេឃិយវគ្គ ទី ៤

(៨៨) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅទៀបចាលិកបព៌ត ជិតក្រុងចាលិកា ។ សម័យនោះឯង ព្រះមេឃិយៈដ៏មានអាយុ ជាអ្នកបំរើព្រះមានព្រះភាគ ។ គ្រានោះ ព្រះមេឃិយៈដ៏មានអាយុ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចឋិតនៅក្នុងទីសមគួរ ។ លុះព្រះមេឃិយៈដ៏មានអាយុ ឋិតនៅក្នុងទីសមគួរហើយ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គប្រាថ្នានឹងចូលទៅបិណ្ឌបាតក្នុងជន្តុគ្រាម ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលមេឃិយៈ អ្នកចូរសំគាល់នូវកាលដែលគួរនឹងទៅ ក្នុងកាលឥឡូវនេះចុះ ។ លំដាប់នោះ ព្រះមេឃិយៈដ៏មានអាយុ ស្លៀកស្បង់ប្រដាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅបិណ្ឌបាតឯជន្តុគ្រាម ។ លុះត្រាច់ទៅបិណ្ឌបាត ក្នុងជន្តុគ្រាម រួចត្រឡប់មកអំពីបិណ្ឌបាតក្នុងវេលាខាងក្រោយភត្តវិញ ហើយចូលទៅឯឆ្នេរស្ទឹងកិមិកាឡា លុះចូលទៅដល់ហើយ ក៏ដើរទៅដើរមក សម្រាកស្មង ប្រចាំឆ្នេរស្ទឹងកិមិកាឡា បានឃើញព្រៃស្វាយគួរជាទីជ្រះថ្លា គួររីករាយ

ទិស្វានស្ស ឯតទហោសិ បាសាទិកំ វតិទំ អម្ពវនំ
រមណីយំ អលំ វតិទំ កុលបុត្តស្ស បធានត្ថិកស្ស
បធានាយ សចេ មំ ភគវា អនុជានេយ្យ អាគច្ឆេយ្យា-
ហំ ឥមំ អម្ពវនំ បធានាយាតិ ។ អថខោ អាយស្មា-
មេឃិយោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា
ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ
និសិន្នោ ខោ អាយស្មា មេឃិយោ ភគវន្តំ ឯតទវោច
អហំ ភន្តេ បុព្ពណ្ហសមយំ និវាសេត្វា បត្តចីវរមា-
ទាយ ជន្តុគាមំ បិណ្ឌាយ បាវិសិំ ជន្តុគាមេ បិណ្ឌាយ
ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ យេន កិមិ-
កាឡាយ នទិយា តីរំ តេនុបសង្កមិំ ឧបសង្កមិត្វា
កិមិកាឡាយ នទិយា តីរេ ជង្ឃាវិហារំ អនុចង្ក-
មមានោ អនុវិចរមានោ អទ្ទសំ អម្ពវនំ បាសាទិកំ(១)
មនុញ្ញំ រមណីយំ ទិស្វាន មេ ឯតទហោសិ បាសាទិកំ
វតិទំ អម្ពវនំ រមណីយំ អលំ វតិទំ កុលបុត្តស្ស
បធានត្ថិកស្ស បធានាយ សចេ មំ ភគវា អនុជានេយ្យ

១ ម. អម្ពវនំ មនុញ្ញំ អត្ថិ ។



លុះព្រះមេឃិយៈមានអាយុ បានឃើញហើយ ក៏មានសេចក្ដីត្រិះរិះថា ឱហ្ន៎ ព្រៃស្វាយនេះ គួរជាទីជ្រះថ្លា គួរត្រេកអរ ឱហ្ន៎ ព្រៃស្វាយនេះ សមគួរដល់ការព្យាយាម របស់កុលបុត្តអ្នកត្រូវការដោយព្យាយាម ប្រសិនបើព្រះមានព្រះភាគ ទ្រង់អនុញ្ញាតដល់ខ្ញុំអញ គួរខ្ញុំអញមកកាន់ព្រៃស្វាយនេះ ដើម្បីប្រកបព្យាយាម ។ លំដាប់នោះ ព្រះមេឃិយៈមានអាយុ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះមានព្រះភាគហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះមេឃិយៈមានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គស្លៀកស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យហើយ ចូលទៅបិណ្ឌបាត ក្នុងជន្តុគ្រាម លុះត្រាច់ទៅបិណ្ឌបាតក្នុងជន្តុគ្រាម រួចត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្តវិញ ហើយចូលទៅ ឯច្រាំងស្ទឹងកិមិកាឡា លុះចូលទៅដល់ហើយ ក៏ដើរទៅដើរមក សញ្ចរកម្សាន្ត ក្បែរច្រាំងស្ទឹងកិមិកាឡា បានឃើញព្រៃស្វាយ គួរជាទីជ្រះថ្លា គួរត្រេកអរ លុះខ្ញុំព្រះអង្គបានឃើញហើយ ក៏មានសេចក្ដីត្រិះរិះថា ឱហ្ន៎ ព្រៃស្វាយនេះ គួរជាទីជ្រះថ្លា គួរជាទីត្រេកអរ ឱហ្ន៎ ព្រៃស្វាយនេះ សមគួរដល់ការព្យាយាម របស់កុលបុត្ត អ្នកត្រូវការដោយព្យាយាម ប្រសិនបើព្រះមានព្រះភាគ ទ្រង់អនុញ្ញាតដល់ខ្ញុំអញ

គច្ឆេយ្យាហំ ឥទំ(១) អម្ពវនំ បធានាយាតិ ។ សចេ មំ ភន្តេ ភគវា អនុជានាតិ គច្ឆេយ្យាហំ(២) អម្ពវនំ បធានាយាតិ ។

(៨៦) ឯវំ វុត្តេ ភគវា អាយស្មន្តំ មេឃិយំ ឯតទវោច អាគមេហិ តាវ មេឃិយ ឯកកោម្ហិ(៣) តាវ យាវ អញ្ញោបិ កោចិ ភិក្ខុ អាគច្ឆតីតិ ។ ទុតិយម្បិ ខោ អាយស្មា មេឃិយោ ភគវន្តំ ឯតទវោច ភគវតោ ភន្តេ នត្ថិ កិញ្ចិ ឧត្តរិ ករណីយំ នត្ថិ កតស្ស បដិចយោ មយ្ហំ ខោ បន ភន្តេ អត្ថិ ឧត្តរិ ករណីយំ អត្ថិ កតស្ស បដិចយោ សចេ មំ ភន្តេ ភគវា អនុជានាតិ គច្ឆេយ្យាហំ តំ អម្ពវនំ បធានាយាតិ ។ ទុតិយម្បិ ខោ ភគវា អាយស្មន្តំ មេឃិយំ ឯតទវោច អាគមេហិ តាវ មេឃិយ ឯកកោម្ហិ តាវ យាវ អញ្ញោបិ កោចិ ភិក្ខុ អាគច្ឆតីតិ ។

១ ម. ឥទំ ។ ២ ឱ.ម. គន្តុំ អត្ថុំ ។ ៣ ឱ. ឯកកម្ហា ។ ម. ឯកកម្ហិ ។



តាញ្ញអញ នូវមកព្រៃស្វាយនោះ ដើម្បីប្រកបព្យាយាម ។ បពិត្រព្រះអង្គដ៏ចំរើន បើព្រះមានព្រះភាគ ទ្រង់អនុញ្ញាតឲ្យខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គទៅឯព្រៃស្វាយ ដើម្បីប្រកបព្យាយាម ។

(៨៦) កាលព្រះមេឃិយៈដ៏មានអាយុ ក្រាបទូលយ៉ាងនេះហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះមេឃិយៈដ៏មានអាយុថា ម្នាលមេឃិយៈ អ្នកចូរនៅចាំសិន ក្នុងការនៅតែម្នាក់ឯងនេះ ចាំភិក្ខុឯទៀតណាមួយមកសិន ។ ព្រះមេឃិយៈដ៏មានអាយុ នៅតែក្រាបទូលព្រះមានព្រះភាគ ជាគំរប់ពីរដងទៀតថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគមិនមានកិច្ចតូចដែលត្រូវធ្វើតទៅទៀតឡើយ ទាំងមិនមានការសន្សំកិច្ចដែលទ្រង់ធ្វើស្រេច ហើយឲ្យចំរើនឡើងទៀតទេ បពិត្រព្រះអង្គដ៏ចំរើន ឯខ្ញុំព្រះអង្គនៅមានកិច្ច ដែលត្រូវធ្វើតទៅទៀត ទាំងនៅមានការសន្សំកិច្ច ដែលខ្ញុំព្រះអង្គធ្វើហើយឲ្យចំរើនឡើងទៀត បពិត្រព្រះអង្គដ៏ចំរើន បើព្រះមានព្រះភាគ ទ្រង់អនុញ្ញាតឲ្យខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គទៅឯព្រៃស្វាយនោះ ដើម្បីប្រកបព្យាយាម ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះមេឃិយៈដ៏មានអាយុ ជាគំរប់ពីរដងទៀតថា ម្នាលមេឃិយៈ អ្នកចូរនៅចាំបន្តិចសិន ក្នុងការនៅតែម្នាក់ឯងនេះ ចាំភិក្ខុឯទៀតណាមួយ មកសិន ។

តតិយម្បិ ខោ អាយស្មា មេឃិយោ ភគវន្តំ ឯតទវោច ភគវតោ ភន្តេ នត្ថិ កិញ្ចិ ឧត្តរឹ ករណីយំ នត្ថិ កតស្ស វា បដិចយោ មយ្ហំ ខោ បន ភន្តេ អត្ថិ ឧត្តរឹ ករណីយំ អត្ថិ កតស្ស វា បដិចយោ សចេ មំ ភគវា អនុជានាតិ គច្ឆេយ្យាហំ តំ អម្ពវនំ បធានាយាតិ ។ បធានន្តិ ខោ មេឃិយ វទមានំ កិន្តិ វទេយ្យាម យស្សទានិ ត្វំ មេឃិយ កាលំ មញ្ញសីតិ ។

[៨៧] អថខោ អាយស្មា មេឃិយោ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា យេន តំ អម្ពវនំ តេនុបសង្កមិ ឧបសង្កមិត្វា តំ អម្ពវនំ អជ្ឈោគាហេត្វា អញ្ញតរស្មឹ រុក្ខមូលេ ទិវាវិហារំ និសីទិ ។ អថខោ អាយស្មតោ មេឃិយស្ស តស្មឹ អម្ពវនេ វិហរន្តស្ស យេភុយ្យេន តយោ បាបកា អកុសលា វិតក្កា សមុទាចរន្តិ សេយ្យថីទំ កាមវិតក្កោ ព្យាបាទវិតក្កោ វិហឹសាវិតក្កោ ។ អថខោ



ព្រះមេឃិយៈដ៏មានអាយុ នៅតែក្រាបទូលព្រះមានព្រះភាគ ជាគំរប់បីដងទៀតថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគមិនមានកិច្ចកិច្ច ដែលត្រូវធ្វើតទៅទៀតឡើយ ទាំងមិនមានការសន្សំកិច្ច ដែលទ្រង់ធ្វើស្រេចហើយឲ្យចំរើនឡើងទៀត បពិត្រព្រះអង្គដ៏ចំរើន ឯខ្ញុំព្រះអង្គនៅមានកិច្ច ដែលត្រូវធ្វើតទៅទៀត ទាំងនៅមានការសន្សំកិច្ច ដែលខ្ញុំព្រះអង្គធ្វើហើយឲ្យច្រើនឡើងទៀត បពិត្រព្រះអង្គដ៏ចំរើន ប្រសិនបើព្រះមានព្រះភាគ ទ្រង់អនុញ្ញាតឲ្យខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គនឹងទៅកាន់ព្រៃស្វាយនោះ ដើម្បីប្រកបព្យាយាម ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលមេឃិយៈតថាគតនឹងនិយាយនឹងអ្នកកាលនិយាយថា ព្យាយាមដូច្នេះ ដូចម្តេចបាន ម្នាលមេឃិយៈ អ្នកចូរសំគាល់នូវកាលដែលគួរនឹងទៅ ក្នុងកាលឥឡូវនេះចុះ ។

(៨៧) លំដាប់នោះ ព្រះមេឃិយៈដ៏មានអាយុ ក្រោកចាកអាសនៈក្រាបថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយចូលទៅកាន់ព្រៃស្វាយនោះ លុះចូលទៅដល់ហើយ ក៏លុកចូលទៅក្នុងព្រៃស្វាយនោះ រួចអង្គុយសម្រាកនៅវេលាថ្ងៃ ត្រង់គល់ឈើមួយដើម ។ កាលដែលព្រះមេឃិយៈ ដ៏មានអាយុ នៅសម្រាក ក្នុងព្រៃស្វាយនោះ អកុសលវិតក្កៈដ៏លាមក ៣ យ៉ាង គឺកាមវិតក្កៈ ១ ព្យាបាទវិតក្កៈ ១ វិហឹសាវិតក្កៈ ១ ផុសផុលឡើងរឿយ ៗ ។ លំដាប់នោះ

អាយស្មតោ មេឃិយស្ស ឯតទហោសិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ សទ្ធា[១] ច វតម្ហិ អគារស្មា អនគារិយំ បព្វជិតោ អថ ច បនិមេហិ តីហិ បាបកេហិ អកុសលេហិ វិតក្កេហិ អន្វាសត្តោ[២] សេយ្យថីទំ កាមវិតក្កេន ព្យាបាទវិតក្កេន វិហឹសាវិតក្កេនាតិ ។ អថ ខោ អាយស្មា មេឃិយោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា មេឃិយោ ភគវន្តំ ឯតទវោច ឥធ[៣] ភន្តេ មយ្ហំ អម្ពវនេ វិហរន្តស្ស យេភុយ្យេន តយោ បាបកា អកុសលា វិតក្កា សមុទាចរន្តិ សេយ្យថីទំ កាមវិតក្កោ ព្យាបាទវិតក្កោ វិហឹសាវិតក្កោ ។ តស្ស មយ្ហំ ភន្តេ ឯតទហោសិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ សទ្ធា ច វតម្ហិ អគារស្មា អនគារិយំ បព្វជិតោ

---

១ ម.ម. សទ្ធាយ ។ ២ ឱ. អន្វាសត្តោ ។ ម. អន្វាសត្តា ។ ៣ ម.ម. ឥធ មយ្ហំ ភន្តេ ។



ព្រះមេឃិយៈដ៏មានអាយុ មានសេចក្តីត្រិះរិះថា ឱហ្ន៎ អស្ចារ្យណាស់ ឱហ្ន៎ ចំឡែកណាស់ អាត្មាអញ ជាអ្នកចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយសទ្ធា នៅតែមានអកុសលវិតក្កៈដ៏លាមកទាំង ៣ នេះ គឺកាមវិតក្កៈ ១ ព្យាបាទវិតក្កៈ ១ វិហឹសាវិតក្កៈ ១ គ្របសង្កត់បាន ។ លំដាប់នោះ ព្រះមេឃិយៈដ៏មានអាយុ ចេញចាកទីសម្ងំ ក្នុងសាយណ្ហសម័យ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះមេឃិយៈដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងទីឯណោះ កាលដែលខ្ញុំព្រះអង្គកំពុងនៅ ក្នុងព្រៃស្វាយនោះ អកុសលវិតក្កៈដ៏លាមក ៣ យ៉ាង គឺ កាមវិតក្កៈ ១ ព្យាបាទវិតក្កៈ ១ វិហឹសាវិតក្កៈ ១ ផុសផុលឡើងរឿយ ៗ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនោះ មានសេចក្តីត្រិះរិះថា ឱហ្ន៎ អស្ចារ្យណាស់ ឱហ្ន៎ ចំឡែកណាស់ អាត្មាអញ ជាអ្នកចេញចាកផ្ទះទៅកាន់ផ្នួសដោយសទ្ធា

អថ ច បនិមេហិ តីហិ បាបកេហិ អកុសលេហិ វិតក្កេហិ អន្វាសត្តោ សេយ្យថីទំ កាមវិតក្កេន ព្យាបាទវិតក្កេន វិហឹសាវិតក្កេនាតិ ។

[៨៨] អបរិបក្កាយ មេឃិយ ចេតោវិមុត្តិយា បញ្ច ធម្មា បរិបាកាយ សំវត្តន្តិ ។ កតមេ បញ្ច ។ ឥធ មេឃិយ ភិក្ខុ កល្យាណមិត្តោ ហោតិ កល្យាណសហាយោ កល្យាណសម្បវង្កោ ។ អបរិបក្កាយ មេឃិយ ចេតោវិមុត្តិយា អយំ បឋមោ ធម្មោ បរិបាកាយ សំវត្តតិ ។ បុន ចបរំ មេឃិយ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ អបរិបក្កាយ មេឃិយ ចេតោវិមុត្តិយា អយំ ទុតិយោ ធម្មោ បរិបាកាយ សំវត្តតិ ។ បុន ចបរំ មេឃិយ ភិក្ខុ យាយំ កថា អភិសល្លេខិកា ចេតោវិវរណសប្បាយា ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ សេយ្យថីទំ អប្បិច្ឆកថា សន្តុដ្ឋិកថា បវិវេកកថា



នៅតែមានអកុសលវិតក្កៈដ៏លាមកច្រើនយ៉ាង គឺកាមវិតក្កៈ១ ព្យាបាទវិតក្កៈ១ វិហឹសាវិតក្កៈ១ គ្របសង្កត់បាន ។

[៨៨] ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលមេឃិយៈ ធម៌ ៥ យ៉ាង ប្រព្រឹត្តទៅ ដើម្បីធ្វើចេតោវិមុត្តិ ដែលមិនទាន់ចាស់ក្លាឲ្យចាស់ក្លាបាន ។ ធម៌ ៥ យ៉ាងតើដូចម្ដេច ។ ម្នាលមេឃិយៈ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានមិត្តល្អ រាប់អានតែមិត្តល្អ ។ ម្នាលមេឃិយៈ នេះជាធម៌ទី ១ ប្រព្រឹត្តទៅ ដើម្បីធ្វើចេតោវិមុត្តិ ដែលមិនទាន់ចាស់ក្លាឲ្យចាស់ក្លាបាន ។ ម្នាលមេឃិយៈ មួយទៀត ភិក្ខុជាអ្នកមានសីល សង្រួមហើយដោយការសង្រួមក្នុងបាតិមោក្ខ បរិបូណ៌ដោយអាចារៈនិងគោចរៈ ជាអ្នកឃើញភ័យ ក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលមេឃិយៈ នេះជាធម៌ទីពីរ ប្រព្រឹត្តទៅ ដើម្បីធ្វើនូវចេតោវិមុត្តិ ដែលមិនទាន់ចាស់ក្លាឲ្យចាស់ក្លាបាន ។ ម្នាលមេឃិយៈ មួយទៀត ភិក្ខុជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយ នូវកថាមានសភាពយ៉ាងនេះ គឺអប្បិច្ឆកថា ១ សន្តុដ្ឋិកថា ១ បវិវេកកថា ១

អសំសគ្គកថា វីរិយារម្ភកថា សីលកថា សមាធិកថា បញ្ញាកថា វិមុត្តិកថា វិមុត្តិញ្ញាណទស្សនកថា ឯវរូបិយា កថាយ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី ។ អបរិបក្កាយ មេឃិយ ចេតោវិមុត្តិយា អយំ តតិយោ ធម្មោ បរិបាកាយ សំវត្តតិ ។ បុន ចបរំ មេឃិយ ភិក្ខុ អារទ្ធវីរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ ។ អបរិបក្កាយ មេឃិយ ចេតោវិមុត្តិយា អយំ ចតុត្ថោ ធម្មោ បរិបាកាយ សំវត្តតិ ។ បុន ចបរំ មេឃិយ ភិក្ខុ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា ។ អបរិបក្កាយ មេឃិយ ចេតោវិមុត្តិយា អយំ បញ្ចមោ ធម្មោ បរិបាកាយ សំវត្តតិ ។ អបរិបក្កាយ មេឃិយ ចេតោវិមុត្តិយា ឥមេ បញ្ច ធម្មា បរិបាកាយ សំវត្តន្តិ ។



អសំសគ្គកថា ១ វីរិយារម្ភកថា ១ សីលកថា ១ សមាធិកថា ១ បញ្ញាកថា ១ វិមុត្តិកថា ១ វិមុត្តិញ្ញាណទស្សនកថា ១ ដែលជាកថាផ្សាយនូវចិត្ត សប្បាយទូលាយចិត្តប្រព្រឹត្តទៅ ដើម្បីសេចក្ដីនឿយណាយតែម្យ៉ាង ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងចំពោះ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ។ ម្នាលមេឃិយៈ នេះជាធម៌ទី ៣ ប្រព្រឹត្តទៅ ដើម្បីធ្វើចេតោវិមុត្តិ ដែលមិនទាន់ចាស់ក្លាឲ្យចាស់ក្លាបាន ។ ម្នាលមេឃិយៈ មួយទៀត ភិក្ខុជាអ្នកប្រារព្ធព្យាយាម ដើម្បីលះអកុសលធម៌ទាំងឡាយ ដើម្បីញ៉ាំងកុសលធម៌ទាំងឡាយឲ្យកើតឡើង ជាអ្នកមានកំឡាំង មានសេចក្ដីប្រឹងប្រែងមាំមួន មិនដាក់ធុរៈ ក្នុងកុសលធម៌ទាំងឡាយ ។ ម្នាលមេឃិយៈ នេះជាធម៌ទី ៤ ប្រព្រឹត្តទៅ ដើម្បីធ្វើចេតោវិមុត្តិដែលមិនទាន់ចាស់ក្លាឲ្យចាស់ក្លាបាន ។ ម្នាលមេឃិយៈ មួយទៀត ភិក្ខុមានបញ្ញា ប្រកបដោយបញ្ញា ជាគ្រឿងដឹងនូវការកើតឡើង នឹងវិនាសទៅ ជាប្រាជ្ញាដ៏ប្រសើរ ជាគ្រឿងទំលុះទំលាយកិលេស ប្រព្រឹត្តទៅ ដើម្បីអស់ទុក្ខដោយប្រពៃ ។ ម្នាលមេឃិយៈ នេះជាធម៌ទី ៥ ប្រព្រឹត្តទៅ ដើម្បីធ្វើចេតោវិមុត្តិ ដែលមិនទាន់ចាស់ក្លាឲ្យចាស់ក្លាបាន ។ ម្នាលមេឃិយៈ ធម៌ ៥ យ៉ាងនេះ ប្រព្រឹត្តទៅ ដើម្បីធ្វើចេតោវិមុត្តិ ដែលមិនទាន់ចាស់ក្លាឲ្យចាស់ក្លាបាន ។

កល្យាណមិត្តស្សេតំ មេឃិយ ភិក្ខុនោ បាដិកង្ខំ កល្យាណសហាយស្ស កល្យាណសម្បវង្កស្ស យំ សីលវា ភវិស្សតិ បាតិមោក្ខសំវរសំវុតោ វិហរិស្សតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខិស្សតិ(១) សិក្ខាបទេសុ ។ កល្យាណមិត្តស្សេតំ មេឃិយ ភិក្ខុនោ បាដិកង្ខំ កល្យាណសហាយស្ស កល្យាណសម្បវង្កស្ស យាយំ កថា អភិសល្លេខិកា ចេតោវិវរណសប្បាយា ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តិស្សតិ(២) សេយ្យថីទំ អប្បិច្ឆកថា សន្តុដ្ឋិកថា បវិវេកកថា អសំសគ្គកថា វីរិយារម្ភកថា សីលកថា សមាធិកថា បញ្ញាកថា វិមុត្តិកថា វិមុត្តិញាណទស្សនកថា ឯវរូបិយា កថាយ និកាមលាភី ភវិស្សតិ(៣) អកិច្ឆលាភី អកសិរលាភី ។ កល្យាណមិត្តស្សេតំ មេឃិយ ភិក្ខុនោ

១ ឱ. សិក្ខតិ ។ ២ ឱ. សំវត្តតិ ។ ៣ ឱ. ហោតិ ។



ម្នាលមេឃិយៈ គុណជាតនុ៎ះ រមែងកើតប្រាកដ ដល់ភិក្ខុដែលមានមិត្តល្អ មានសំឡាញ់ល្អ ចូលទៅរកមិត្តល្អ ព្រោះភិក្ខុនោះជាអ្នកមានសីល សង្រួមហើយដោយការសង្រួម ក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរៈ ជាអ្នកឃើញភ័យ ក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលមេឃិយៈ គុណជាតនុ៎ះ រមែងកើតប្រាកដ ដល់ភិក្ខុដែលមានមិត្តល្អ មានសំឡាញ់ល្អ ចូលទៅរកមិត្តល្អ ព្រោះភិក្ខុនោះជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយ នូវកថាមានសភាពយ៉ាងនេះ គឺ អប្បិច្ឆកថា ១ សន្តុដ្ឋិកថា ១ បវិវេកកថា ១ អសំសគ្គកថា ១ វីរិយារម្ភកថា ១ សីលកថា ១ សមាធិកថា ១ បញ្ញាកថា ១ វិមុត្តិកថា ១ វិមុត្តិញាណទស្សនកថា ១ ដែលជាកថាជូតផង់ ជាទីសប្បាយខ្វាយចិត្ត ប្រព្រឹត្តទៅ ដើម្បីនឿយណាយតែម្យ៉ាងពិត ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងចំពោះ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ។ ម្នាលមេឃិយៈ គុណជាតនុ៎ះ រមែងកើតប្រាកដ ដល់ភិក្ខុដែលមានមិត្តល្អ

បាដិកង្ខំ កល្យាណសហាយស្ស កល្យាណសម្បវង្កស្ស យំ អារទ្ធវីរិយោ វិហរិស្សតិ[១] អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ ។ កល្យាណមិត្តស្សេតំ មេឃិយ ភិក្ខុនោ បាដិកង្ខំ កល្យាណសហាយស្ស កល្យាណសម្បវង្កស្ស យំ បញ្ញវា ភវិស្សតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា ។

(៨៤) តេន ច បន មេឃិយ ភិក្ខុនា ឥមេសុ បញ្ចសុ[២] បតិដ្ឋាយ ចត្តារោ ធម្មា ឧត្តរិ ភាវេតព្វា អសុភា ភាវេតព្វា រាគស្ស បហានាយ មេត្តា ភាវេតព្វា ព្យាបាទស្ស បហានាយ អានាបានស្សតិ ភាវេតព្វា វិតក្កុបច្ឆេទាយ អនិច្ចសញ្ញា ភាវេតព្វា អស្មិមានសមុគ្ឃាតាយ ។ អនិច្ចសញ្ញិនោ ហិ មេឃិយ អនត្តសញ្ញា សណ្ឋាតិ អនត្តសញ្ញី អស្មិមានសមុគ្ឃាតំ បាបុណាតិ ទិដ្ឋេវ ធម្មេ និព្វានន្តិ ។

១ ម. ភវិស្សតិ ។ ២ ម.ឱ. បញ្ចសុ ធម្មេសុ ឋត្វា ។



មានសំឡាញ់ល្អ បែរទៅរកមិត្តល្អ ព្រោះភិក្ខុនោះជាអ្នកប្រារព្ធព្យាយាម ដើម្បីលះបង់អកុសលធម៌ទាំងឡាយ ដើម្បីញុំាងកុសលធម៌ទាំងឡាយ ឲ្យកើតឡើង មានកំឡាំង មានសេចក្ដីប្រឹងប្រែងមាំមួន មិនដាក់ធុរៈក្នុងកុសលធម៌ទាំងឡាយ ។ ម្នាលមេឃិយៈ គុណជាតនុ៎ះ រមែងមានប្រាកដ ដល់ភិក្ខុ ដែលមានមិត្តល្អ មានសំឡាញ់ល្អ បែរទៅរកមិត្តល្អ ព្រោះភិក្ខុនោះជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញាជាគ្រឿងដឹងនូវការកើតឡើង និងសូន្យទៅ ជាប្រាជ្ញាដ៏ប្រសើរ អាចចាក់ទំលាយកិលេស ប្រព្រឹត្តទៅដើម្បីអស់ទុក្ខដោយប្រពៃ ។

(៨៤) ម្នាលមេឃិយៈ មួយទៀត ភិក្ខុនោះ គឺតាំងនៅក្នុងធម៌ ៥ យ៉ាងនេះហើយ ត្រូវចំរើនធម៌ ៤ យ៉ាងទៀត គឺចំរើនអសុភ ដើម្បីលះរាគៈ ១ ចំរើនមេត្តា ដើម្បីលះព្យាបាទ ១ ចំរើនអានាបានស្សតិ ដើម្បីផ្ដាច់បង់វិតក្កៈ ១ ចំរើនអនិច្ចសញ្ញា ដើម្បីដកអស្មិមានៈ ១ ។ ម្នាលមេឃិយៈ ព្រោះថា កាលភិក្ខុមានសេចក្ដីសំគាល់ថា មិនទៀងហើយ សេចក្ដីសំគាល់ថា មិនមែនខ្លួន រមែងតាំងនៅ (ក្នុងចិត្ត) ភិក្ខុដែលមានសេចក្ដីសំគាល់ថា មិនមែនខ្លួន រមែងដល់នូវការដកអស្មិមានៈ ឈ្មោះថាដល់និព្វានក្នុងបច្ចុប្បន្ន ។

អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

ខុទ្ទា វិតក្កា សុខុមា វិតក្កា
អនុគ្គតា មនសោ ឧព្ពិលាវា(១)
ឯតេ អវិទ្វា មនសោ វិតក្កេ
ហុរាហុរំ ធាវតិ ភន្តចិត្តោ ។
ឯតេ ច វិទ្វា មនសោ វិតក្កេ
អាតាបិយោ សំវរតិ សតិមា
អនុគ្គតេ មនសោ ឧព្ពិលាវេ(២)

(៣) (៤)
អសេសមេតេ បជហាតិ ពុទ្ធោតិ ។ សុត្តំ បឋមំ ។

[៩០] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កុសិនារាយំ វិហរតិ ឧបវត្តនេ មល្លានំ សាលវនេ ។ តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ ភគវតោ អវិទូរេ អរញ្ញកុដិកាយំ វិហរន្តិ ឧទ្ធតា(៥) ឧន្នឡា ចបលា មុខរា វិកិណ្ណវាចា មុដ្ឋស្សតិនោ អសម្បជានា អសមាហិតា វិព្ភន្តចិត្តា បាកតិន្ទ្រិយា ។

១ ម. ឧព្ពិលាវា ។ ២ ម. ឧព្ពិលាវេ ។ ៣ ម. អសេសមាហេ ។ ៤ ឱ. ម. សត៌ ពាហ្វ័ន្ត ឥត្ថិ ។ ៥ ឱ. ឯទ្ធតា បោត្ថកេ អត្ថិ ។



លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

វិតក្កៈទាំងឡាយ ដ៏ថោកទាប វិតក្កៈទាំងឡាយ ដ៏ល្អិត ដែលចិត្តប្រព្រឹត្តទៅតាមហើយ ធ្វើចិត្តឲ្យផ្ទឹកការត្រើង បុគ្គលមិនដឹងច្បាស់សេចក្តីត្រិះរិះនៃចិត្តទាំងនុ៎ះទេ ជាអ្នកមានចិត្តរាត់ផ្អើល ស្ទុះទៅស្ទុះមក កាន់អារម្មណ៍ផ្សេង ៗ ឯអ្នកប្រាជ្ញដឹងច្បាស់សេចក្តីត្រិះរិះ នៃចិត្តទាំងនុ៎ះហើយ ជាអ្នកមានព្យាយាម ជាគ្រឿងដុតបំផ្លាញកិលេស មានស្មារតី បិទខ្ទប់វិតក្កៈទាំងឡាយ ដែលចិត្តប្រព្រឹត្តទៅតាម ហើយធ្វើចិត្តឲ្យផ្ទឹកការត្រើង លះបង់វិតក្កៈទាំងនុ៎ះ មិនឲ្យសេសសល់ ។ សូត្រទី ១ ។

[៩០] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងសាលវ័នឧបវត្តន របស់មល្លក្សត្រិយ៍ ជាទីប្រព្រឹត្តចូលទៅជិតក្រុងកុសិនារា ។ សម័យនោះឯង ពួកភិក្ខុច្រើនរូប នៅ ក្នុងកុដិដែលនៅក្នុងព្រៃ ក្នុងទីជិតព្រះមានព្រះភាគ ជាអ្នកមានចិត្តអណ្តែតអណ្តូង លើកកំពស់ មានចិត្តឃ្លេងឃ្លោង មានមាត់រឹង មានសំដីផ្តេសផ្តាស ភ្លេចស្មារតី មិនដឹងខ្លួន មិនបានតាំងចិត្តមាំមួន មានចិត្តរាត់រាយ មានឥន្ទ្រិយដ៏ប្រាកដ ( មិនសង្រួមឥន្ទ្រិយ ) ។

អទ្ទសា ខោ ភគវា តេ សម្ពហុលេ ភិក្ខូ អវិទូរេ អរញ្ញ-កុដិកាយំ វិហរន្តេ ឧទ្ធតេ ឧន្នឡេ ចបលេ មុខរេ វិកិណ្ណវាចេ មុដ្ឋស្សតិនោ អសម្បជានេ អសមាហិតេ វិព្ភន្តចិត្តេ បាកតិន្ទ្រិយេ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

អរក្ខិតេន កាយេន មិច្ឆាទិដ្ឋិគតេន ច
ថីនមិទ្ធាភិភូតេន វសំ មារស្ស គច្ឆតិ ។
តស្មា រក្ខិតចិត្តស្ស សម្មាសង្កប្បគោចរោ
សម្មាទិដ្ឋិំ បុរេក្ខត្វា ញត្វាន ឧទយព្វយំ
ថីនមិទ្ធាភិភូ ភិក្ខុ សព្វា ទុគ្គតិយោ ជហេតិ ។

ទុតិយំ[1] ។

(៤០) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កោសលេសុ ចារិកំ ចរតិ មហតា ភិក្ខុសង្ឃេន សទ្ធឹ ។ អថខោ ភគវា មគ្គា ឱក្កម្ម យេន អញ្ញតរំ រុក្ខមូលំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ អញ្ញតរោ គោបាលកោ យេន ភគវា តេនុបសង្កមិ

១ ម. ឧ. ឧទ្ធតសុត្តំ ។



ព្រះមានព្រះភាគ ទ្រង់បានទតឃើញភិក្ខុច្រើនរូបនោះ នៅ ក្នុងខ្ទម ដែលនៅជិតនឹងព្រៃ ក្នុងទីជិតព្រះអង្គ មានចិត្តរវើរវាយ ជាអ្នកលើកកំពស់ មានចិត្តឃ្លេងឃ្លោង មានមាត់រឹង មានសំដីផ្តេសផ្តាស ភ្លេចស្មារតី មិនដឹងខ្លួន មិនបានតាំងចិត្តមាំមួន មានចិត្តភ្ញាក់ផ្អើល មានឥន្ទ្រិយដ៏ប្រាកដ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

បុគ្គលមានវិញ្ញាណកាយទាំង ៦ មិនរក្សាផង ជាមិច្ឆាទិដ្ឋិផង
ដែលថីនមិទ្ធៈ គ្របសង្កត់ផង រមែងដល់នូវអំណាចនៃមារ ។
ព្រោះហេតុនោះ ភិក្ខុជាអ្នកមានចិត្តរក្សាហើយ មានសេចក្តីត្រិះ
រិះត្រូវ ជាអារម្មណ៍ មានសម្មាទិដ្ឋិប្រព្រឹត្តទៅក្នុងខាងមុខ ដឹងការ
កើតឡើងនិងសូន្យទៅបាន គ្របសង្កត់នូវថីនៈនិងមិទ្ធៈហើយ
គប្បីលះបង់នូវពួកទុគ្គតិទាំងពួង ។ សូត្រទី ២ ។

(៤០) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ស្តេចទៅកាន់ចារិក ក្នុងកោសលជនបទ ជាមួយនឹងភិក្ខុសង្ឃ ច្រើនរូប ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ចេញចាកផ្លូវ ហើយចូលទៅកាន់ម្លប់ឈើមួយដើម លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈ ដែលគេក្រាលថ្វាយ ។ លំដាប់នោះ គោបាលម្នាក់ បានចូលទៅគាល់ ព្រះមានព្រះភាគ

ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ តំ គោបាលកំ ភគវា ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ សោ គោបាលកោ ភគវតា ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ សម្បហំសិតោ ភគវន្តំ ឯតទវោច អធិវាសេតុ មេ ភន្តេ ភគវា ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ សោ គោបាលកោ ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ សោ គោបាលកោ តស្សា រត្តិយា អច្ចយេន សកេ និវេសនេ បហូតំ អប្បោទកបាយាសំ បដិយាទាបេត្វា នវញ្ច សប្បឹ ភគវតោ កាលំ អារោចេសិ កាលោ ភន្តេ និដ្ឋិតំ ភត្តន្តិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សទ្ធឹ ភិក្ខុសង្ឃេន យេន តស្ស គោបាលកស្ស និវេសនំ តេនុបសង្កមិ



លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះនាយគោបាលនោះ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់សំដែងពន្យល់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ។ គ្រានោះ នាយគោបាលនោះ លុះព្រះមានព្រះភាគទ្រង់សំដែងពន្យល់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទ្រង់ទទួលភត្តរបស់ខ្ញុំព្រះអង្គ ក្នុងថ្ងៃស្អែក ជាមួយនឹងភិក្ខុសង្ឃ ។ ព្រះមានព្រះភាគ ទ្រង់ទទួលដោយតុណ្ហីភាព ។ លុះនាយគោបាលនោះ ដឹងនូវថា ព្រះមានព្រះភាគទ្រង់ទទួលហើយ ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ រួចចៀសចេញទៅ ។ លំដាប់នោះ នាយគោបាលនោះ លុះកន្លងរាត្រីនោះហើយ ក៏បានឲ្យមនុស្សតាក់តែង អប្បោទកបាយាស ( បាយាសមានទឹកតិច ) និងទឹកដោះថ្លាថ្មី ជាច្រើន ក្នុងលំនៅរបស់ខ្លួន ហើយឲ្យមនុស្សទៅក្រាបទូលភត្តកាល ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន កាលល្មមហើយ ចំណែកភត្តសោត ក៏ស្រេចហើយ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយយាងចូលទៅកាន់លំនៅ របស់នាយគោបាលនោះ ជាមួយនឹងភិក្ខុសង្ឃ

ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ សោ គោបាលកោ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ អប្បោទកបាយាសេន ច នវេន ច សប្បិនា សហត្ថា សន្តប្បេសិ សម្បវារេសិ ។ អថខោ សោ គោបាលកោ ភគវន្តំ ភុត្តាវឹ ឱនីតបត្តបាណឹ អញ្ញតរំ នីចំ អាសនំ គហេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ តំ គោបាលកំ ភគវា ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧដ្ឋាយាសនា បក្កាមិ ។

(៤៦) អថខោ អចិរបក្កន្តស្ស ភគវតោ តំ គោបាលកំ អញ្ញតរោ បុរិសោ សីមន្តរិកាយ ជីវិតា វោរោបេសិ ។ អថខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ យេន ភន្តេ គោបាលកេន អជ្ជ ពុទ្ធប្បមុខោ ភិក្ខុសង្ឃោ អប្បោទកបាយាសេន ច នវេន ច សប្បិនា សហត្ថា សន្តប្បិតោ សម្បវារិតោ



លុះយាងទៅដល់ហើយ ក៏គង់លើអាសនៈ ដែលគេក្រាលថ្វាយ ។ លំដាប់នោះ នាយគោបាលនោះ អង្គាសភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ដោយអប្បោទកបាយាសនឹងទឹកដោះថ្លាថ្មី ឲ្យឆ្អែតស្កប់ស្កល់ ព្រមទាំងហាមឃាត់ដោយដៃខ្លួនឯង ។ លំដាប់នោះ នាយគោបាលនោះ លុះព្រះមានព្រះភាគទ្រង់សោយស្រេចលែងលូកព្រះហស្តក្នុងបាត្រទៀតហើយ ក៏កាន់យកអាសនៈដ៏ទាបមួយ អង្គុយក្នុងទីសមគួរ ។ លុះនាយគោបាលនោះអង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់សំដែងធម្មីកថាឲ្យកាន់យក ឲ្យអាចហានឡើង ឲ្យរីករាយដោយធម្មីកថា ស្រេចទ្រង់ក្រោកចាកអាសនៈយាងចេញទៅ ។

(៤៦) គ្រាកាលដែលព្រះមានព្រះភាគ ស្ដេចចេញទៅមិនយូរប៉ុន្មាន ស្រាប់តែមានបុរសម្នាក់ ផ្ដាច់ជីវិតនាយគោបាលនោះ ត្រង់ចន្លោះព្រំប្រទល់ស្រុក ។ លំដាប់នោះ ពួកភិក្ខុច្រើនរូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូល ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន នាយគោបាលណា ដែលបានអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយអប្បោទកបាយាសនឹងទឹកដោះថ្លាដ៏ថ្មី ឲ្យឆ្អែតស្កប់ស្កល់ ព្រមទាំងហាមឃាត់ដោយដៃខ្លួនឯង ក្នុងថ្ងៃនេះ

សោ កិរ ភន្តេ គោបាលកោ អញ្ញតរេន បុរិសេន សីមន្តរិកាយ ជីវិតា វោរោបិតោតិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

ទិសោ ទិសំ យន្តំ កយិរា វេរី វា បន វេរិនំ

មិច្ឆាបណិហិតំ ចិត្តំ បាបិយោ នំ តតោ ករេតិ ។

តតិយំ[១] ។

(៨៣) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អាយស្មា ច សារីបុត្តោ អាយស្មា ច មហា-មោគ្គល្លានោ កបោតកន្ទរាយំ វិហរន្តិ ។ តេន ខោ បន សមយេន អាយស្មា សារីបុត្តោ ជុណ្ហាយ រត្តិយា នវោរោបិតេហិ កេសេហិ អព្ភោកាសេ និសិន្នោ ហោតិ អញ្ញតរំ សមាធិំ សមាបជ្ជិត្វា ។

(៨៤) តេន ខោ បន សមយេន ទ្វេ យក្ខា សហាយកា ឧត្តរាយ ទិសាយ ទក្ខិណំ ទិសំ គច្ឆន្តិ កេនចិទេវ ករណីយេន ។ អទ្ទសំសុ ខោ តេ យក្ខា

១ ឱ. ម. តតិយំ នត្ថិ ។



បពិត្រព្រះអង្គដ៏ចំរើន បានឮថា នាយគោបាលនោះ មានបុរសម្នាក់ផ្តាច់ជីវិត ត្រង់ចន្លោះព្រំប្រទល់ស្រុកទៅហើយ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

ចោរបានឃើញចោរដែលគ្នា ធ្វើ បុគ្គលមានពៀរ ឃើញបុគ្គល

មានពៀរដែលគ្នា គប្បីធ្វើសេចក្តីវិនាសណា ចិត្តដែលបុគ្គល

ដំកល់ខុសហើយ រមែងធ្វើបុគ្គលនោះ ឲ្យលាមកលើសជាង

សេចក្តីវិនាសនោះទៅទៀត ។ សូត្រ ទី ៣ ។

(៨៣) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះសារីបុត្តដ៏មានអាយុ និងព្រះមហាមោគ្គល្លានដ៏មានអាយុ នៅក្នុងវិហារកបោតកន្ទរ ។ សម័យនោះ ព្រះសារីបុត្តដ៏មានអាយុ មានសក់ទើបកោរថ្មី ៗ អង្គុយក្នុងទីវាល ចូលកាន់សមាធិណាមួយ ក្នុងរាត្រីមានខែភ្លឺ ។

(៨៤) សម័យនោះ មានយក្សពីរនាក់ជាសំឡាញ់នឹងគ្នា មកអំពីទិសខាងជើង ទៅទិសខាងត្បូង ដោយកិច្ចណាមួយ ។ យក្សទាំងនោះ បានឃើញ

អាយស្មន្តំ សារីបុត្តំ ជុណ្ហាយ រត្តិយា នវោរោបិតេហិ កេសេហិ អព្ភោកាសេ និសិន្នំ ទិស្វាន ឯកោ យក្ខោ ទុតិយំ យក្ខំ ឯតទវោច បដិភាតិ មំ សម្ម ឥមស្ស សមណស្ស សីសេ បហារំ ទាតុន្តិ ។ ឯវំ វុត្តេ សោ យក្ខោ តំ យក្ខំ ឯតទវោច អលំ សម្ម មា សមណំ អាសាទេសិ[១] ឧឡារោ សោ សម្ម សមណោ មហិទ្ធិកោ មហានុភាវោតិ ។ ទុតិយម្បិ ខោ សោ យក្ខោ តំ យក្ខំ ឯតទវោច បដិភាតិ មំ សម្ម ឥមស្ស សមណស្ស សីសេ បហារំ ទាតុន្តិ ។ ទុតិយម្បិ ខោ សោ យក្ខោ តំ យក្ខំ ឯតទវោច អលំ សម្ម មា សមណំ អាសាទេសិ ឧឡារោ សោ សម្ម សមណោ មហិទ្ធិកោ មហានុភាវោតិ ។ តតិយម្បិ ខោ សោ យក្ខោ តំ យក្ខំ ឯតទវោច បដិភាតិ មំ សម្ម ឥមស្ស សមណស្ស សីសេ បហារំ ទាតុន្តិ ។ តតិយម្បិ ខោ សោ យក្ខោ តំ យក្ខំ ឯតទវោច អលំ សម្ម មា សមណំ អាសាទេសិ ឧឡារោ សោ សម្ម សមណោ មហិទ្ធិកោ មហានុភាវោតិ ។

១ ម. អាសាទេសិ ។



ព្រះសារីបុត្តដ៏មានអាយុ មានសក់ទើបកោរថ្មីៗ អង្គុយក្នុងទីវាល ក្នុងរាត្រីមានខែភ្លឺ លុះយក្ខម្នាក់ បានឃើញហើយ និយាយប្រាប់យក្ខម្នាក់ទៀតថា ម្នាលសំឡាញ់ ចិត្តរបស់ខ្ញុំកើតប្រាកដ ដើម្បីប្រហារក្បាលសមណៈនេះ ។ កាលបើយក្ខម្នាក់ និយាយយ៉ាងនេះហើយ យក្ខនោះក៏និយាយទៅនឹងយក្ខម្នាក់ទៀតនោះថា កុំសំឡាញ់ អ្នកកុំប្រហារសមណៈឡើយ ម្នាលសំឡាញ់ សមណៈនោះ មានគុណដ៏លើសលុប មានឫទ្ធិច្រើន មានអានុភាពច្រើន ។ យក្ខម្នាក់នោះ បាននិយាយនឹងយក្ខនោះ ជាគំរប់ពីរដងទៀតថា ម្នាលសំឡាញ់ ចិត្តរបស់ខ្ញុំកើតប្រាកដ ដើម្បីប្រហារក្បាលសមណៈនេះ ។ យក្ខនោះ និយាយទៅនឹងយក្ខម្នាក់ទៀតនោះ ជាគំរប់ពីរដងទៀតថា កុំសំឡាញ់ អ្នកកុំប្រហារសមណៈឡើយ ម្នាលសំឡាញ់ សមណៈនោះ មានគុណដ៏លើសលុប មានឫទ្ធិច្រើន មានអានុភាពច្រើន ។ យក្ខម្នាក់នោះ និយាយទៅនឹងយក្ខនោះ ជាគំរប់បីដងទៀតថា ម្នាលសំឡាញ់ ចិត្តរបស់ខ្ញុំកើតប្រាកដ ដើម្បីប្រហារក្បាលសមណៈនេះ ។ យក្ខនោះ និយាយទៅនឹងយក្ខម្នាក់ទៀតនោះ ជាគំរប់បីដងទៀតថា កុំសំឡាញ់ អ្នកកុំប្រហារសមណៈឡើយ ម្នាលសំឡាញ់ សមណៈនោះមានគុណដ៏លើសលុប មានឫទ្ធិច្រើន មានអានុភាពច្រើន ។

អថ ខោ សោ យក្ខោ តំ យក្ខំ អនាទិយិត្វា អាយស្មតោ សារីបុត្តត្ថេរស្ស សីសេ បហារំ អទាសិ ។ អបិ ចេន បហារេន សត្តរតនំ វា អឌ្ឍដ្ឋរតនំ[១] វា នាគំ ឱសារេយ្យ[២] មហន្តំ វា បព្វតកូដំ បទាលេយ្យ ។ អថ ច បន សោ យក្ខោ ឌយ្ហាមីតិ[៣] វត្វា តត្ថេវ មហានិរយំ អបតាសិ ។

(៤៥) អទ្ទសា ខោ អាយស្មា មហាមោគ្គល្លានោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន តេន យក្ខេន អាយស្មតោ សារីបុត្តស្ស សីសេ បហារំ ទិយ្យមានំ ទិស្វាន យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ សារីបុត្តំ ឯតទវោច ខមនីយំ តេ អាវុសោ ខមនីយំ យាបនីយំ កច្ចិ ន កិញ្ចិ ទុក្ខន្តិ ។ ខមនីយំ មេ អាវុសោ មោគ្គល្លាន យាបនីយំ មេ អាវុសោ មោគ្គល្លាន អបិ ច មេ សីសេ ថោកំ ទុក្ខន្តិ ។ អច្ឆរិយំ អាវុសោ សារីបុត្ត អព្ភុតំ អាវុសោ សារីបុត្ត យាវ មហិទ្ធិកោ អាយស្មា សារីបុត្តោ មហានុភាវោ ។ ឥធ តេ អាវុសោ សារីបុត្ត អញ្ញតរោ យក្ខោ

១ ម.ម. ឧព្វេធេន ។ ២ ម. ឱសារេយ្យ ។ ៣ ម.ម. ឌយ្ហាមិ ឌយ្ហាមីតិ ។





លំដាប់នោះ យក្ខម្នាក់នោះ មិនអើពើនឹងយក្ខនោះឡើយ ហើយប្រហារចំព្រះសិរ្សៈ ព្រះសារីបុត្តត្ថេរដ៏មានអាយុ ។ មានសេចក្ដីដំណាលថា យក្ខនោះគប្បីគ្រវែងដំរីមានកំពស់ ៧ ហត្ថ ឬ ៨ ហត្ថ ( ឲ្យស្រុតទៅក្នុងផែនដី ) ក៏បាន គប្បីធ្វើកំពូលភ្នំធំ ឲ្យបែកខ្ទេចខ្ទីក៏បាន ដោយការប្រហារនោះ ។ លំដាប់នោះ ស្រាប់តែយក្ខនោះពោលថា ខ្ញុំក្ដៅណាស់ ៗ ហើយធ្លាក់ទៅកាន់មហានរក ត្រង់ទីនោះឯង ។

(៤៥) ព្រះមហាមោគ្គល្លានដ៏មានអាយុ បានឃើញយក្ខនោះ កំពុងប្រហារចំព្រះសិរ្សៈព្រះសារីបុត្តដ៏មានអាយុ ដោយទិព្វចក្ខុ ដ៏បរិសុទ្ធ កន្លងនូវចក្ខុរបស់មនុស្សធម្មតា លុះឃើញហើយ ក៏ចូលទៅរកព្រះសារីបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏និយាយនឹងព្រះសារីបុត្តដ៏មានអាយុថា ម្នាលអាវុសោ លោកល្មមអត់ធន់បានដែរឬ ល្មមប្រព្រឹត្តទៅបានដែរឬ មិនមានសេចក្ដីទុក្ខតិចតួចទេឬ ។ ព្រះសារីបុត្តដ៏មានអាយុ ឆ្លើយថា ម្នាលអាវុសោមោគ្គល្លាន ខ្ញុំល្មមអត់ធន់បាន ម្នាលអាវុសោមោគ្គល្លាន ខ្ញុំល្មមប្រព្រឹត្តទៅបាន តែថា មានសេចក្ដីទុក្ខបន្តិច ត្រង់ក្បាលរបស់ខ្ញុំ ។ ម្នាលអាវុសោសារីបុត្ត អស្ចារ្យណាស់ ម្នាលអាវុសោសារីបុត្ត ចំឡែកណាស់ ព្រោះថា សារីបុត្តដ៏មានអាយុ មានឫទ្ធិច្រើន មានអានុភាពច្រើន ។ ម្នាលអាវុសោ សារីបុត្ត ក្នុងទីនេះ មានយក្ខមួយ

សីសេ បហារំ អទាសិ តាវ មហាបហារោ អហោសិ អបិ តេន បហារេន សត្តរតនំ វា អឌ្ឍដ្ឋមរតនំ វា នាគំ ឱសាទេយ្យ មហន្តំ វា បព្វតកូដំ វា បទាលេយ្យាតិ ។ អថ បនាយស្មា សារីបុត្តោ ឯវមាហ ខមនីយំ មេ អាវុសោ មោគ្គល្លាន យាបនីយំ មេ អាវុសោ មោគ្គល្លាន អបិ ច មេ សីសេ ថោកំ ទុក្ខន្តិ ។ អច្ឆរិយំ អាវុសោ មោគ្គល្លាន អព្ភុតំ អាវុសោ មោគ្គល្លាន យំ[១] មហិទ្ធិកោ អាយស្មា មហាមោគ្គល្លានោ មហានុភាវោ យត្រ ហិ នាម យក្ខម្បិ បស្សិស្សតិ មយំ បនេតរហិ បំសុបិសាចកម្បិ ន បស្សាមាតិ ។

(៤៦) អស្សោសិ ខោ ភគវា ទិព្វាយ សោតធាតុយា វិសុទ្ធាយ អតិក្កន្តមានុសិកាយ តេសំ ឧភិន្នំ មហានាគានំ ឥមំ ឯវរូបំ កថាសល្លាបំ ។ អថ ខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

យស្ស សេលូបមំ[២] ចិត្តំ ឋិតំ នានុបកម្បតិ

១ ម.ឆ. យំ ត្វំ ។



ប្រហារចំព្រះសិរ្សៈនៃលោក ( ការប្រហារនោះ ) ពេញជាការប្រហារខ្លាំង ដែលគួរនោះអាចពន្លិចដំរីមានកំពស់ ៧ ហត្ថ ឬ ៨ ហត្ថ ( ឲ្យស្រុតទៅក្នុងផែនដីបាន ) អាចបំបែកកំពូលភ្នំដ៏ធំឲ្យបែកខ្ទេចបាន ដោយការប្រហារនោះ ។ លោកសារីបុត្តដ៏មានអាយុ និយាយយ៉ាងនេះថា ម្នាលអាវុសោមោគ្គល្លាន ខ្ញុំល្មមអត់ធន់បាន ម្នាលអាវុសោមោគ្គល្លាន ខ្ញុំល្មមប្រព្រឹត្តទៅបាន តែថា មានសេចក្តីទុក្ខបន្តិច ត្រង់ក្បាលរបស់ខ្ញុំ ។ ម្នាលអាវុសោមោគ្គល្លាន អស្ចារ្យណាស់ ម្នាលអាវុសោមោគ្គល្លាន ចំឡែកណាស់ ព្រោះថា មហាមោគ្គល្លានដ៏មានអាយុ មានឫទ្ធិច្រើន មានអានុភាពច្រើន មើលយក្សឃើញបាន ចំណែកខាងយើងមិនឃើញសូម្បីបិសាច ដែលអាស្រ័យនឹងកំទេចដី[១] សោះឡើយ ។

(៤៦) ព្រះមានព្រះភាគ ទ្រង់ព្រះសណ្តាប់ពាក្យចរចា មានសភាពយ៉ាងនេះ របស់ព្រះមហានាគទាំងពីរអង្គនោះ ដោយទិព្វសោតធាតុដ៏បរិសុទ្ធ កន្លងសោតធាតុ របស់មនុស្សធម្មតា ។ លុះព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់សេចក្តីនុះហើយ ទើបបន្លឺឧទាននេះ ក្នុងវេលានោះថា

ចិត្តរបស់បុគ្គលណា មានឧបមាដោយថ្មភ្នំ នៅនឹង មិនញាប់ញ័រ

១ សំដៅយកយក្សតូចៗ ដែលត្រាច់ចរ ក្នុងទីកខ្វក់ មានគំនរសម្រាមជាដើម ។

វិរត្តំ រជនីយេសុ កោបនេយ្យេ ន កុប្បតិ
យស្សេវំ ភាវិតំ ចិត្តំ កុតោ តំ ទុក្ខមេស្សតីតិ ។

ចតុត្ថំ ។

(៤៨) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ តេន ខោ បន សមយេន ភគវា អាកិណ្ណោ វិហរតិ ភិក្ខូហិ ភិក្ខុនីហិ ឧបាសកេហិ ឧបាសិកាហិ រាជូហិ រាជមហាមត្តេហិ តិត្ថិយេហិ តិត្ថិយសាវកេហិ អាកិណ្ណោ ទុក្ខំ ន ផាសុ វិហរតិ ។ អថខោ ភគវតោ ឯតទហោសិ អហំ ខោ ឯតរហិ អាកិណ្ណោ វិហរាមិ ភិក្ខូហិ ភិក្ខុនីហិ ឧបាសកេហិ ឧបាសិកាហិ រាជូហិ រាជមហាមត្តេហិ តិត្ថិយេហិ តិត្ថិយសាវកេហិ អាកិណ្ណោ ទុក្ខំ ន ផាសុ វិហរាមិ យន្នូនាហំ ឯកោ គណម្ហា វូបកដ្ឋោ វិហរេយ្យន្តិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ កោសម្ពិំ បិណ្ឌាយ បាវិសិ ។ កោសម្ពិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ សាមំ សេនាសនំ សំសាមេត្វា បត្តចីវរមាទាយ



ប្រាសចាកតម្រេក ក្នុងហេតុគួរត្រេកអរទាំងឡាយ មិនក្រោធក្នុងហេតុគួរក្រោធ ចិត្តដែលបុគ្គលណា បានចំរើនយ៉ាងនេះហើយ សេចក្ដីទុក្ខនឹងមានមក ដល់បុគ្គលនោះអំពីណាបាន ។ សូត្រ ទី ៤ ។

[៤៨] ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់នៅច្រឡូកច្រឡំដោយពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ស្ដេច អាមាត្យធំរបស់ស្ដេច តិរ្ថិយ និងពួកសាវ័ករបស់តិរ្ថិយ ព្រះមានព្រះភាគទ្រង់គង់នៅច្រឡូកច្រឡំជាទុក្ខ មិនសប្បាយឡើយ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់មានសេចក្ដីត្រិះរិះថា ឥឡូវនេះ តថាគតនៅច្រឡូកច្រឡំដោយពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ស្ដេច អាមាត្យធំរបស់ស្ដេច តិរ្ថិយ និងពួកសាវ័ករបស់តិរ្ថិយ តថាគតនៅច្រឡូកច្រឡំជាទុក្ខ មិនសប្បាយ បើដូច្នេះ គួរតែតថាគត គេចចេញអំពីពួកហើយ នៅតែម្នាក់ឯង ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅបិណ្ឌបាត ក្នុងក្រុងកោសម្ពី ។ លុះព្រះមានព្រះភាគ ត្រាច់ទៅបិណ្ឌបាតក្នុងក្រុងកោសម្ពី ត្រឡប់មកអំពីបិណ្ឌបាត ក្នុងកាលខាងក្រោយភត្ត ហើយទុកដាក់សេនាសនៈដោយព្រះអង្គឯង ហើយប្រដាប់បាត្រចីវរ

អនាមន្តេត្វា ឧបដ្ឋាកំ អនបលោកេត្វា ភិក្ខុសង្ឃំ ឯកោ អទុតិយោ យេន បាលិលេយ្យកំ តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកំ ចរមានោ យេន បាលិលេយ្យកំ តទវសរិ ។

[៤៨] តត្រ សុទំ ភគវា បាលិលេយ្យកេ វិហរតិ រក្ខិតវនសណ្ឌេ ភទ្ទសាលមូលេ ។ អញ្ញតរោបិ ខោ ហត្ថិនាគោ អាកិណ្ណោ វិហរតិ ហត្ថីហិ ហត្ថិនីហិ ហត្ថិកលភេហិ (១) ហត្ថិច្ឆាបេហិ (២) ឆិន្នគ្គានិ ចេវ តិណានិ ខាទតិ ឱភគ្គោភគ្គញ្ចស្ស សាខាភង្គំ ខាទន្តិ អាវិលានិ ច បានីយានិ បិវតិ ឱគាហា ចស្ស ឧត្តិណ្ណស្ស ហត្ថិនិយោ កាយំ ឧបនិឃំសន្តិយោ គច្ឆន្តិ អាកិណ្ណោ ទុក្ខំ ន ផាសុ វិហរតិ ។ អថ ខោ តស្ស ហត្ថិនាគស្ស ឯតទហោសិ អហំ ខោ ឯតរហិ អាកិណ្ណោ វិហរាមិ ហត្ថីហិ ហត្ថិនីហិ ហត្ថិកលភេហិ ហត្ថិច្ឆាបេហិ ឆិន្នគ្គានិ ចេវ តិណានិ ខាទាមិ

១ ម. ហត្ថិកល្លភេហិ ។ ម. ហត្ថិកល្លភកេហិ ។ ២ ម. ហត្ថិច្ឆាបកេហិ ។



មិនបានលាឧបដ្ឋាក មិនបានប្រាប់ភិក្ខុសង្ឃ តែមួយអង្គឯង ឥតមានភិក្ខុជាគំរប់ពីរ ទ្រង់យាងនៅកាន់ចារិក នៃបាលិលេយ្យកប្រទេស កាលទ្រង់យាងនៅកាន់ចារិក ដោយលំដាប់ បានដល់បាលិលេយ្យកប្រទេស ។

(៤៨) បានឮថា ព្រះមានព្រះភាគ ទ្រង់គង់នៅក្រោមម្លប់ភទ្ទសាលព្រឹក្ស ក្នុងដងព្រៃឈ្មោះរក្ខិតៈ ជិតបាលិលេយ្យកប្រទេសនោះ ។ មានដំរីជំប្រសើរមួយ នៅប្រឡូកប្រឡំដោយពួកដំរីឈ្មោល ដំរីញី ដំរីស្ទាវ និងកូនដំរី ហើយស៊ីស្មៅ ដែលពួកដំរីទាំងនោះ ស៊ីបន្ទន់ហើយផង ពួកដំរីទាំងនោះស៊ីនូវមែកឈើបាក់ ដែលដំរីជំប្រសើរនោះបំបាក់ចុះហើយផង ឯដំរីជំប្រសើរ ក៏ផឹកទឹកដែលល្អូកល្អក់ផង កាលដំរីជំប្រសើរនោះចុះឡើងកំពង់ទឹក ពួកមេដំរីក៏ដើរត្រដុសកាយផង ដំរីជំប្រសើរ នៅប្រឡូកប្រឡំដោយពួក មិនសប្បាយឡើយ ។ លំដាប់នោះ ដំរីជំប្រសើរនោះ មានសេចក្តីត្រិះរិះថា ឥឡូវនេះ អាត្មាអញនៅប្រឡូកប្រឡំដោយពួកដំរីឈ្មោល ដំរីញី ដំរីស្ទាវ និងកូនដំរី ហើយស៊ីស្មៅដែលដំរីទាំងនោះស៊ីបន្ទន់ហើយផង

ឱភគ្គោភគ្គញ្ច មេ សាខាភង្គំ ខាទន្តិ អាវិលានិ ច បានីយានិ បិវាមិ ឱគាហា ច មេ ឱតិណ្ណស្ស ហត្ថិនិយោ កាយំ ឧបនិឃំសន្តិយោ គច្ឆន្តិ អាកិណ្ណោ ទុក្ខំ ន ផាសុ វិហរាមិ យន្នូនាហំ ឯកោ គណម្ហា វូបកដ្ឋោ វិហរេយ្យន្តិ ។ អថខោ សោ ហត្ថិនាគោ យូថា អបក្កម្ម យេន បាលិលេយ្យកំ រក្ខិតវនសណ្ឌោ ភទ្ទសាលមូលំ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា អត្រ សុទំ សោ ហត្ថិនាគោ យស្មិំ បទេសេ ភគវា វិហរតិ តំ បទេសំ អប្បហរិតញ្ច[១] ករោតិ សោណ្ឌាយ ភគវតោ បានីយំ បរិភោជនីយំ ឧបដ្ឋបេតិ[២] ។

(៤៤) អថខោ ភគវតោ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ អហំ ខោ បុព្វេ អាកិណ្ណោ វិហាសិំ ភិក្ខូហិ ភិក្ខុនីហិ ឧបាសកេហិ ឧបាសិកាហិ រាជូហិ រាជមហាមត្តេហិ តិត្ថិយេហិ តិត្ថិយសាវកេហិ អាកិណ្ណោ ទុក្ខំ ន ផាសុ វិហាសិំ ។ សោហំ ឯតរហិ អនាកិណ្ណោ វិហរាមិ ភិក្ខូហិ ភិក្ខុនីហិ ឧបាសកេហិ ឧបាសិកាហិ រាជូហិ

១ ឱ. អបហរិតញ្ច ។ ២ ឱ. ម. ឧបដ្ឋបេតិ ។



ដំរីទាំងនោះស៊ីមែកឈើបាក់ ដែលអញកាច់បាក់ហើយផង អញផឹកទឹកទាំងឡាយដ៏ល្អក់ផង កាលបើអញ ដើរចុះទៅកាន់ទឹក ពួកមេដំរី ដើរត្រដុសកាយផង អញនៅច្រឡូកច្រឡំ ជាទុក្ខមិនសប្បាយ បើដូច្នោះ គួរអញគេចចេញពីហ្វូងនៅម្នាក់ឯងវិញចុះ ។ លំដាប់នោះ ដំរីប្រសើរនោះដើរគេចចេញពីហ្វូង ហើយចូលទៅរកព្រះមានព្រះភាគ ដែលទ្រង់គង់នៅក្រោមម្លប់គល់សាលព្រឹក្ស ក្នុងដែនព្រៃឈ្មោះរក្ខិតៈ ជិតបាលិលេយ្យកប្រទេស លុះចូលទៅដល់ហើយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងប្រទេសណាមួយក្តី ដំរីប្រសើរនោះ ក៏ធ្វើប្រទេសនោះ មិនឲ្យមានស្មៅស្រស់ ទាំងដងទឹកឆាន់ ទឹកប្រើ ថ្វាយព្រះមានព្រះភាគ ដោយប្រមោយ ។

(៤៤) គ្រានោះ ព្រះមានព្រះភាគ ទ្រង់យាងទៅសម្ងំ ក្នុងទីស្ងាត់ ទ្រង់មានព្រះទ័យបរិវិតក្កៈ កើតឡើងយ៉ាងនេះថា កាលមុន តថាគតបាននៅច្រឡូកច្រឡំ ដោយពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ស្តេច អមាត្យធំ របស់ស្តេច តិរ្ថិយ និងពួកសាវ័ក របស់តិរ្ថិយ តថាគតនៅច្រឡូកច្រឡំ ជាទុក្ខ មិនសប្បាយឡើយ ។ ឥឡូវនេះ តថាគត មិនបាននៅច្រឡូកច្រឡំដោយពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ស្តេច

រាជមហាមត្តេហិ តិត្ថិយេហិ តិត្ថិយសាវកេហិ អនាកិណ្ណោ សុខំ ផាសុ វិហរាមីតិ ។ តស្ស ខោ ហត្ថិនាគស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ អហំ ខោ បុព្វេ អាកិណ្ណោ វិហាសឹ ហត្ថីហិ ហត្ថិនីហិ ហត្ថិកលភេហិ ហត្ថិច្ឆាបេហិ ឆិន្នគ្គានិ ចេវ តិណានិ ខាទឹ ឱភគ្គោភគ្គញ្ច មេ សាខាភង្គំ ខាទឹសុ អាវិលានិ ច បានីយានិ បិវឹ(១) ឱគាហា ច មេ ឧត្តិណ្ណស្ស ហត្ថិនិយោ កាយំ ឧបនិឃំសន្តិយោ អគមំសុ អាកិណ្ណោ ទុក្ខំ ន ផាសុ វិហាសឹ ។ សោម្ហិ ឯតរហិ អនាកិណ្ណោ វិហរាមិ ហត្ថីហិ ហត្ថិនីហិ ហត្ថិកលភេហិ ហត្ថិច្ឆាបេហិ អច្ឆិន្នគ្គានិ ចេវ តិណានិ ខាទាមិ ឱភគ្គោភគ្គញ្ច មេ សាខាភង្គំ ន ខាទន្តិ អនាវិលានិ ច បានីយានិ បិវាមិ ឱគាហា ច មេ ឧត្តិណ្ណស្ស ន ហត្ថិនិយោ កាយំ ឧបនិឃំសន្តិយោ គច្ឆន្តិ អនាកិណ្ណោ សុខំ ផាសុ វិហរាមីតិ ។ អថខោ ភគវា អត្តនោ ច បវិវេកំ វិទិត្វា តស្ស ច ហត្ថិនាគស្ស ចេតសា ចេតោបរិវិតក្កមញ្ញាយ តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

១ ម. បិវិសំ ។ ឱ. ពិវឹ ។



អាមាត្យធំរបស់ស្ដេច តិរ្ថិយ និងពួកសាវ័ក របស់តិរ្ថិយទាំងឡាយ តថាគត មិនបាននៅប្រឡូកប្រឡំ ក៏បានសេចក្ដីសុខសប្បាយ ។ ដំរីប្រសើរនោះ មានចិត្តត្រិះរិះគិតឡើងយ៉ាងនេះថា កាលមុន អញបាននៅប្រឡូកប្រឡំ ដោយពួកដំរីឈ្មោល ដំរីញី ដំរីស្ទាវ និងកូនដំរីតូច ៗ ហើយអញបាន ស៊ីស្មៅទាំងឡាយ ដែលពួកដំរីទាំងនោះ ស៊ីចុងហើយផង ពួកដំរីទាំងនោះស៊ីមែកឈើបាក់ ដែលអញកាច់បំបាក់ហើយផង អញបានផឹកទឹកទាំងឡាយ ដ៏ល្អក់ផង កាលបើអញ ងើបចុះឡើងកំពង់ទឹក ពួកមេដំរី ដើរត្រដុសកាយផង អញនៅប្រឡូកប្រឡំជាទុក្ខ មិនសប្បាយឡើយ ។ ឥឡូវនេះ អញនោះមិននៅប្រឡូកប្រឡំ ដោយពួកដំរីឈ្មោល ដំរីញី ដំរីស្ទាវ និង កូនដំរី ហើយស៊ីស្មៅទាំងឡាយ ដែលពួកដំរីទាំងនោះ មិនបានស៊ីចុងហើយផង ពួកដំរីទាំងនោះ ក៏មិនស៊ីមែកឈើបាក់ ដែលអញកាច់បំបាក់ផង អញផឹកទឹកទាំងឡាយមិនល្អក់ផង កាលបើអញ ងើបចុះឡើងកំពង់ទឹក ពួកមេដំរី ក៏មិនដើរត្រដុសកាយផង អញមិននៅប្រឡូកប្រឡំ ក៏បានសេចក្ដីសុខសប្បាយ ។ លុះព្រះមានព្រះភាគ ទ្រង់បានជ្រាបច្បាស់សេចក្ដីស្ងប់ស្ងាត់របស់ព្រះអង្គ និងបានជ្រាបច្បាស់ បរិវិតក្កៈ គឺចិត្តរបស់ដំរីប្រសើរនោះ ដោយព្រះទ័យនៃព្រះអង្គហើយ ទើបទ្រង់បន្លឺនូវឧទាននេះ ក្នុងវេលានោះថា

ឯកំ[១] នាគស្ស នាគេន ឦសាទន្តស្ស ហត្ថិនោ សមេតិ ចិត្តំ ចិត្តេន យំ ឯកោ រមតី វនេ[២] ។ បញ្ចមំ[៣] ។

(១០០) ឯវមេ្ម សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា បិណ្ឌោលភារទ្វាជោ ភគវតោ អវិទូរេ និសិន្នោ ហោតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ អារញ្ញកោ បិណ្ឌបាតិកោ បំសុកូលិកោ តេចីវរិកោ អប្បិច្ឆោ សន្តុដ្ឋោ បវិវិត្តោ អសំសដ្ឋោ អារទ្ធវីរិយោ ធុតវាទោ អធិចិត្តមនុយុត្តោ ។ អទ្ទសា ខោ ភគវា អាយស្មន្តំ បិណ្ឌោលភារទ្វាជំ អវិទូរេ និសិន្នំ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ អារញ្ញកំ បិណ្ឌបាតិកំ បំសុកូលិកំ តេចីវរិកំ អប្បិច្ឆំ សន្តុដ្ឋំ បវិវិត្តំ អសំសដ្ឋំ អារទ្ធវីរិយំ ធុតវាទំ អធិចិត្តមនុយុត្តំ ។ អថ ខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

១ ម. ឯវំ ។ ២ ម. រមតីតិ ។ ៣ ឱ. ម. បញ្ចមំ សុត្តំ ។



ចិត្តរបស់ហត្ថីនាគ មានភ្លុកដ៏ខ្ពង់ខ្ពស់ ស្មើនឹងចិត្តរបស់ពួកនាគនេះ ព្រោះហត្ថីនាគនៅម្នាក់ឯង ត្រេកអរក្នុងព្រៃផង ។ សូត្រ ទី ៥ ។

(១០០) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះបិណ្ឌោលភារទ្វាជៈដ៏មានអាយុ ជាអ្នកប្រព្រឹត្តអារញ្ញកធុតង្គ បិណ្ឌបាតិកធុតង្គ បង្សុកូលិកធុតង្គ នឹងតេចីវរិកធុតង្គ ជាអ្នកប្រាថ្នាតិច មានសេចក្តីសន្តោស មានសេចក្តីស្ងប់ស្ងាត់ មិននៅលាយឡំដោយពួក ប្រារព្ធព្យាយាម ជាអ្នកពោលពាក្យជាគ្រឿងកំចាត់បង់កិលេស ប្រកបរឿយៗនូវអធិចិត្ត អង្គុយផ្គត់ភ្នែន តម្រង់កាយត្រង់ ក្នុងទីជិតព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញបិណ្ឌោលភារទ្វាជៈដ៏មានអាយុ ជាអ្នកប្រព្រឹត្តអារញ្ញកធុតង្គ បិណ្ឌបាតិកធុតង្គ បង្សុកូលិកធុតង្គ នឹងតេចីវរិកធុតង្គ ជាអ្នកប្រាថ្នាតិច មានសេចក្តីសន្តោស មានសេចក្តីស្ងប់ស្ងាត់ មិននៅលាយឡំដោយពួក ប្រារព្ធព្យាយាម ជាអ្នកពោលពាក្យជាគ្រឿងកំចាត់បង់កិលេស ប្រកបរឿយៗ នូវអធិចិត្ត អង្គុយផ្គត់ភ្នែន តម្រង់កាយត្រង់ ក្នុងទីជិតព្រះអង្គ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

អនូបវាទោ អនូបឃាតោ បាតិមោក្ខេ ច សំវរោ
មត្តញ្ញុតា ច ភត្តស្មឹ បន្តញ្ច(១) សយនាសនំ
អធិចិត្តេ ច អាយោគោ ឯតំ ពុទ្ធាន សាសនន្តិ ។
ឆដ្ឋំ(២) ។

(១០១) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា សារីបុត្តោ ភគវតោ អវិទូរេ និសិន្នោ ហោតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ អប្បិច្ឆោ សន្តុដ្ឋោ បវិវិត្តោ អសំសដ្ឋោ អារទ្ធវីរិយោ អធិចិត្តមនុយុត្តោ ។ អទ្ទសា ខោ ភគវា អាយស្មន្តំ សារីបុត្តំ អវិទូរេ និសិន្នំ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ អប្បិច្ឆំ សន្តុដ្ឋំ បវិវិត្តំ អសំសដ្ឋំ អារទ្ធវីរិយំ អធិចិត្តមនុយុត្តំ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

១ ម. បន្តញ្ច ។ បន្តញ្ចាតិបិ បាឋោ ។ ២ ឱ. ម. ឆដ្ឋំ ។



ការមិនចោទប្រកាន់ ១ ការមិនបៀតបៀនគេ ១ ការសង្រួមក្នុងបាតិមោក្ខ ១ ការដឹងប្រមាណក្នុងភត្តាហារ ១ ទីដេកទីអង្គុយដ៏ស្ងាត់ ១ ការប្រកបព្យាយាមក្នុងអធិចិត្ត ១ នុ៎ះជាពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។ សូត្រ ទី ៦ ។

(១០១) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះសារីបុត្តដ៏មានអាយុ ជាអ្នកមានសេចក្តីប្រាថ្នាតិច មានសេចក្តីសន្តោស មានសេចក្តីស្ងប់ស្ងាត់ មិននៅលាយឡំដោយពួក ប្រារព្ធព្យាយាម ប្រកបរឿយៗ នូវអធិចិត្ត អង្គុយផ្គត់ភ្នែន តម្រង់កាយត្រង់ ក្នុងទីជិតព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញ ព្រះសារីបុត្តដ៏មានអាយុ ជាអ្នកមានសេចក្តីប្រាថ្នាតិច មានសេចក្តីសន្តោស មានសេចក្តីស្ងប់ស្ងាត់ មិននៅលាយឡំដោយពួក ប្រារព្ធព្យាយាម ប្រកបរឿយៗនូវអធិចិត្ត អង្គុយផ្គត់ភ្នែន តម្រង់កាយត្រង់ ក្នុងទីជិតព្រះអង្គ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺនូវឧទាននេះ ក្នុងវេលានោះថា

អធិចេតសោ អប្បមជ្ជតោ មុនិនោ មោនបថេសុ សិក្ខតោ សោកា ន ភវន្តិ តាទិនោ ឧបសន្តស្ស សទា សតីមតោតិ ។

សត្តមំ[1] ។

[១០២] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភគវា សក្កតោ ហោតិ គរុកតោ មានិតោ បូជិតោ អបចិតោ លាភី ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ។ ភិក្ខុសង្ឃោបិ សក្កតោ ហោតិ គរុកតោ មានិតោ បូជិតោ អបចិតោ លាភី ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ។ អញ្ញតិត្ថិយា បន បរិព្វាជកា អសក្កតា ហោន្តិ អគរុកតា អមានិតា អបូជិតា អនបចិតា ន លាភិនោ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ។

[១០៣] អថ ខោ អញ្ញតិត្ថិយា បរិព្វាជកា ភគវតោ សក្ការំ អសហមានា ភិក្ខុសង្ឃស្ស

[1] ឱ. ម. សត្តមំ និដ្ឋិតំ ។



សេចក្តីសោកទាំងឡាយ រមែងមិនកើតមាន ដល់បុគ្គលមានអធិចិត្ត មិនប្រមាទ ជាអ្នកមុនី ជាអ្នកសិក្សា ក្នុងផ្លូវនៃការដើរទាំងឡាយ គឺអរហត្តផលញាណ មានចិត្តមិនញាប់ញ័រ ជាអ្នកនឹងធឹង ជាអ្នកស្ងប់ មានស្មារតីគ្រប់កាល ។ សូត្រទី ៧ ។

[១០២] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគ មានគេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ទ្រង់បានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ជាប្រក្រតី ។ សូម្បីភិក្ខុសង្ឃ ក៏មានគេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ជាអ្នកបានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ជាប្រក្រតីដែរ ។ ឯពួកបរិព្វាជក ជាអន្យតិរ្ថិយ មិនមានគេធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជា មិនកោតក្រែង មិនបានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ជាប្រក្រតីឡើយ ។

[១០៣] គ្រានោះ ពួកបរិព្វាជក ជាអន្យតិរ្ថិយ អត់ធន់មិនបាននូវសក្ការៈ របស់ព្រះមានព្រះភាគ នឹងភិក្ខុសង្ឃ ចូលទៅកាន់

ច យេន សុន្ទរី បរិព្វាជិកា តេនុបសង្កមឹសុ ឧបសង្ក-
មិត្វា សុន្ទរី បរិព្វាជិកំ ឯតទវោចុំ ឧស្សហសិ[១] ភគិនិ
ញាតីនំ អត្ថំ កាតុន្តិ ។ ក្យាហំ អយ្យា ករោមិ
កឹ មយា សក្កា កាតុំ ជីវិតម្បិ មេ បរិច្ចត្តំ ញាតីនំ
អត្ថាយាតិ ។ តេនហិ ភគិនិ អភិក្ខណំ ជេតវនំ
គច្ឆាហីតិ ។ ឯវំ អយ្យាតិ ខោ សុន្ទរី បរិព្វាជិកា តេសំ
អញ្ញតិត្ថិយានំ បរិព្វាជកានំ បដិស្សុត្វា អភិក្ខណំ
ជេតវនំ អគមាសិ ។ យទា អញ្ញាសុំ តេ អញ្ញតិត្ថិយា
បរិព្វាជកា វោ[២]ទិដ្ឋា ខោ សុន្ទរី បរិព្វាជិកា
ពហុជនេន អភិក្ខណំ ជេតវនំ គច្ឆតីតិ អថ នំ ជីវិតា
វោរោបេត្វា តត្ថេវ ជេតវនស្ស បរិខាកូបេ និក្ខិ-
បិត្វា យេន រាជា បសេនទិ កោសលោ តេនុប-
សង្កមឹសុ ឧបសង្កមិត្វា រាជានំ បសេនទឹ កោសលំ
ឯតទវោចុំ យា សា មហារាជ សុន្ទរី បរិព្វាជិកា សា
នោ ន ទិស្សតីតិ ។ កត្ថ បន តុម្ហេ អាសង្កថាតិ ។
ជេតវនេ មហារាជាតិ ។ តេនហិ ជេតវនេ វិចិនថាតិ ។

១ ឱ. ឧស្សហ ត្វំ ភគិ ។ ២ ម. ឱ ។



បរិព្វាជិកាឈ្មោះសុន្ទរី លុះចូលទៅដល់ហើយ ក៏និយាយនឹងនាងបរិព្វា-
ជិកាឈ្មោះសុន្ទរីថា នែប្អូនស្រី នាងអាចធ្វើប្រយោជន៍ដល់ពួកញាតិបាន
ឬទេ ។ នាងបរិព្វាជិកាឈ្មោះសុន្ទរីសួរថា បពិត្រលោកម្ចាស់ទាំងឡាយ
ខ្ញុំព្រះករុណាត្រូវធ្វើដូចម្តេច តើធ្វើដូចម្តេច ដែលខ្ញុំអាចធ្វើបាន សូម្បីជីវិត
ក៏ខ្ញុំលះបង់ ដើម្បីជាប្រយោជន៍ ដល់ពួកញាតិដែរ ។ ម្នាលប្អូនស្រី
បើដូច្នោះ នាងចូរទៅកាន់វត្តជេតពន ឲ្យញយ ៗ ។ នាងបរិព្វាជិកាឈ្មោះ
សុន្ទរី បានទទួលពាក្យបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះថា ព្រះករុណា
លោកម្ចាស់ ហើយទៅកាន់វត្តជេតពនញយ ៗ ។ កាលណាបរិព្វាជក
ជាអន្យតិរ្ថិយទាំងនោះ បានដឹងថា ជនច្រើនបានឃើញនាងបរិព្វាជិកា
ឈ្មោះសុន្ទរី ទៅកាន់វត្តជេតពនញយៗហើយ ក៏សំឡាប់នាងនោះឲ្យផុត
ចាកជីវិត ហើយកប់ក្នុងរណ្តៅស្នាមគូរ នៃវត្តជេតពននោះឯង ក្នុងកាល
ណោះ រួចចូលទៅគាល់ព្រះបាទបសេនទិកោសល លុះចូលទៅដល់ហើយ
ក៏ក្រាបទូលព្រះបាទបសេនទិកោសលថា បពិត្រមហារាជ នាងបរិព្វា-
ជិកាណាឈ្មោះសុន្ទរី នាងបរិព្វាជិកានោះ មិនប្រាកដដល់ពួកអាត្មាភាព
សោះ ។ ព្រះរាជាទ្រង់ត្រាស់ព្រះបន្ទូលសួរថា ចុះលោកទាំងឡាយ មាន
សង្ស័យក្នុងទីណាខ្លះ ។ បពិត្រមហារាជ ពួកអាត្មាភាពមានសង្ស័យ ក្នុង
វត្តជេតពន ។ បើដូច្នោះ ចូរលោកទាំងឡាយ ស្វែងរកក្នុងវត្តជេតពនចុះ ។

អថខោ តេ អញ្ញតិត្ថិយា បរិព្វាជកា ជេដ្ឋកំ វិចិនិត្វា យថាធិប្បាយំ បរិច្ចាគកថា ឧទ្ទិត្វា មព្ភុតំ អាគេហេត្វា សាវត្ថិំ បវេសេត្វា ចេតិយាយ ចេតិយំ សិង្ឃាដកោច សិង្ឃាដកំ ឧបសង្កមិត្វា មនុស្សេ ឧជ្ឈាបេសុំ ឧស្សាបេសុំ សមណានំ សក្យបុត្តិយានំ កម្មំ អលជ្ជិនោ ឥមេ សមណា សក្យបុត្តិយា ទុស្សីលា បាបធម្មា មុសាវាទិនោ អព្រហ្មចារិនោ ។ ឥមេ ហិ នាម ធម្មចារិនោ សមចារិនោ ព្រហ្មចារិនោ សច្ចវាទិនោ សីលវន្តោ កល្យាណធម្មា បដិជានិស្សន្តិ នត្ថិ ឥមេសំ សាមញ្ញំ នត្ថិ ឥមេសំ ព្រហ្មញ្ញំ[1] នដ្ឋំ ឥមេសំ សាមញ្ញំ នដ្ឋំ ឥមេសំ ព្រហ្មញ្ញំ កុតោ ឥមេសំ សាមញ្ញំ កុតោ ឥមេសំ ព្រហ្មញ្ញំ អបគតា ឥមេ សាមញ្ញា អបគតា

[1] ឧ. ព្រហ្មញ្ញំ ។



សំពត់នោះ បរិព្វាជកជាអន្យតិរ្ថិយទាំងនោះ អយកនូវបើលវត្ថុផេតគម ហើយក៏ចាស់ទ្បើង (ខ្ញុំសាកសួរ) ដែលគេបំពុះហើយ ស៊ីគ្រណ្ដាប់ ស្លាបព្រោះ ហើយលើកដាក់លើគ្រែតូច នាំចូលទៅកាន់ក្រុងសាវត្ថី ហើយ ចេញពីច្រកមួយ ចូលទៅកាន់ច្រកមួយ ចេញពីផ្លូវក្រៀវទ្បើងកែងមួយ ចូលទៅកាន់ផ្លូវក្រៀវទ្បើងកែងមួយ ហើយប្រើពួកមនុស្សឲ្យលើកទោសថា នែអ្នកទាំងទ្បាយ អ្នកទាំងទ្បាយ ចូរមើលអំពើរបស់ពួកសមណៈ ជាសក្យបុត្តិយ៍ចុះ ពួកសមណៈជាសក្យបុត្តិយ៍នេះ ជាបុគ្គលមិនអៀនខ្មាស ទ្រុស្តសីល មានធម៌លាមក ជាអ្នកនិយាយពាក្យកុហក ប្រព្រឹត្តធម៌មិន ប្រសើរ ។ មិនតែប៉ុណ្ណោះ ពួកសមណៈ ជាសក្យបុត្តិយ៍នេះ មកប្ដេជ្ញាខ្លួនថា ជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ ប្រព្រឹត្តធម៌ដ៏ប្រសើរ ពោលពាក្យពិត មាន សីល មានកល្យាណធម៌សោះ ភាពជាសមណៈគឺជាអ្នកឲ្យម៉ប់ស្ងប់ មិន មានដល់ពួកសមណៈនេះទ្បើយ ភាពជាអ្នកប្រសើរ គឺជាអ្នកបន្សាត់បាប មិនមានដល់ពួកសមណៈនេះទ្បើយ ភាពជាសមណៈ របស់ពួកសមណៈ នេះ សាបសូន្យហើយ ភាពជាអ្នកប្រសើររបស់ពួកសមណៈនេះ សាប សូន្យហើយ ភាពជាសមណៈ នឹងមានដល់ពួកសមណៈនេះ អំពីហេតុ ដូចម្ដេច ភាពជាអ្នកប្រសើរ នឹងមានដល់ពួកសមណៈ អំពីហេតុដូច ម្ដេច ពួកសមណៈនេះ ប្រាសចាកភាពជាសមណៈ ពួកសមណៈនេះ

ឥមេ ព្រហ្មញ្ញា ។ កថញ្ហិ នាម បុរិសោ បុរិសកិច្ចំ ករិត្វា ឥត្ថឹ ជីវិតា វោរោបេស្សតីតិ ។

(១០៦) តេន ខោ បន សមយេន សាវត្ថិយំ មនុស្សា ភិក្ខូ ទិស្វា អសព្ភាហិ ផរុសាហិ វាចាហិ អក្កោសន្តិ បរិភាសន្តិ រោសេន្តិ វិហេសេន្តិ អលជ្ជិនោ ឥមេ សមណា សក្យបុត្តិយា ទុស្សីលា បាបធម្មា មុសាវាទិនោ អព្រហ្មចារិនោ ឥមេ ហិ នាម ធម្មចារិនោ សមចារិនោ ព្រហ្មចារិនោ សច្ចវាទិនោ សីលវន្តោ កល្យាណធម្មា បដិជានិស្សន្តិ នត្ថិ ឥមេសំ សាមញ្ញំ នត្ថិ ឥមេសំ ព្រហ្មញ្ញំ នដ្ឋំ ឥមេសំ សាមញ្ញំ នដ្ឋំ ឥមេសំ ព្រហ្មញ្ញំ កុតោ ឥមេសំ សាមញ្ញំ កុតោ ឥមេសំ ព្រហ្មញ្ញំ អបគតា ឥមេ សាមញ្ញា អបគតា ឥមេ ព្រហ្មញ្ញា ។ កថញ្ហិ នាម បុរិសោ បុរិសកិច្ចំ ករិត្វា ឥត្ថឹ ជីវិតា វោរោបេស្សតីតិ ។



ប្រាសចាកភាពជាអ្នកប្រសើរហើយ ។ មិនគួរបើ បុរសនឹងធ្វើកិច្ចរបស់បុរស ( មេថុនកិច្ច ) ហើយមកសម្លាប់ស្រីឲ្យដាច់ចាកជីវិតសោះ ។

(១០៦) សម័យនោះឯង ពួកមនុស្សក្នុងក្រុងសាវត្ថី បានឃើញពួកភិក្ខុ ហើយតាំងជេរ ប្រទេចផ្ដាសា បៀតបៀនដោយសំដីទ្រគោះ ជារបស់អសប្បុរសថា ពួកសមណៈជាសក្យបុត្តិយ៍នេះ ជាអ្នកមិនអៀនខ្មាស ទ្រុស្តសីល មានធម៌លាមក ជាអ្នកនិយាយពាក្យកុហក ប្រព្រឹត្តធម៌មិនប្រសើរ មិនគួរបើ សមណៈទាំងនោះ មកប្ដេជ្ញាខ្លួនថា ជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ ប្រព្រឹត្តធម៌ប្រសើរ ពោលពាក្យពិត មានសីល មានកល្យាណធម៌សោះ ភាពជាសមណៈ គឺជាអ្នកស្ងប់បាប មិនមានដល់សមណៈទាំងនេះឡើយ ភាពជាអ្នកប្រសើរ គឺជាអ្នកបន្សាត់បាប មិនមានដល់សមណៈទាំងនេះឡើយ ភាពជាសមណៈ របស់សមណៈនេះ សាបសូន្យហើយ ភាពជាអ្នកប្រសើររបស់សមណៈទាំងនេះសាបសូន្យហើយ ភាពជាសមណៈ នឹងមានដល់សមណៈទាំងនេះ អំពីហេតុដូចម្ដេច ភាពជាអ្នកប្រសើរនឹងមានដល់ពួកសមណៈនេះ អំពីហេតុដូចម្ដេច សមណៈទាំងនេះ ប្រាសចាកភាពជាសមណៈហើយ សមណៈទាំងនេះប្រាសចាកភាព ជាអ្នកប្រសើរហើយ ។ មិនគួរបើបុរស នឹងធ្វើកិច្ចរបស់បុរស ( មេថុនកិច្ច ) ហើយមកសម្លាប់ស្រីឲ្យដាច់ចាកជីវិតសោះ ។

(១០៨) អថខោ សម្ពហុលា ភិក្ខូ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថិំ បិណ្ឌាយ បាវិសិំសុ ។ សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតបដិក្កន្តា យេន ភគវា តេនុបសង្កមិំសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិំសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ ឯតរហិ ភន្តេ សាវត្ថិយំ មនុស្សា ភិក្ខូ ទិស្វា អសព្ភាហិ ផរុសាហិ វាចាហិ អក្កោសន្តិ បរិភាសន្តិ រោសេន្តិ វិហេសេន្តិ អលជ្ជិនោ ឥមេ សមណា សក្យបុត្តិយា ទុស្សីលា បាបធម្មា មុសាវាទិនោ អព្រហ្មចារិនោ ឥមេ ហិ នាម ធម្មចារិនោ សមចារិនោ ព្រហ្មចារិនោ សច្ចវាទិនោ សីលវន្តោ កល្យាណធម្មា បដិជានិស្សន្តិ នត្ថិ ឥមេសំ សាមញ្ញំ នត្ថិ ឥមេសំ ព្រហ្មញ្ញំ នដ្ឋំ ឥមេសំ សាមញ្ញំ នដ្ឋំ ឥមេសំ ព្រហ្មញ្ញំ កុតោ ឥមេសំ សាមញ្ញំ



(១០៨) គ្រានោះ ពួកភិក្ខុជាច្រើនរូប បានស្លៀកស្បង់ប្រដាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត ។ លុះភិក្ខុទាំងនោះ ត្រាច់ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ហើយត្រឡប់មកអំពីបិណ្ឌបាត ក្នុងកាលខាងក្រោយភត្ត រួចចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូល ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ពួកមនុស្សក្នុងក្រុងសាវត្ថី បានឃើញពួកភិក្ខុ ហើយ ( នាំគ្នា ) ជេរប្រទេច ផ្តាសា បៀតបៀនដោយសំដីទ្រគោះគំរោះមិនសប្បុរសថា ពួកសមណៈជាសក្យបុត្តិយ៍នេះ ជាបុគ្គលមិនអៀនខ្មាស ទ្រុស្តសីល មានធម៌លាមក ពោលពាក្យកុហក ប្រព្រឹត្តធម៌មិនប្រសើរ ពួកសមណៈទាំងនេះ មិនគួរប្តេជ្ញាខ្លួនថា ជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ ប្រព្រឹត្តធម៌ប្រសើរ ពោលពាក្យពិត មានសីល មានកល្យាណធម៌សោះ ភាពជាសមណៈ គឺជាអ្នករម្ងាប់បាប មិនមានដល់សមណៈទាំងនេះ ភាពជាអ្នកប្រសើរគឺជាអ្នកបន្សាត់បាប មិនមានដល់សមណៈទាំងនេះ ភាពជាសមណៈ របស់សមណៈទាំងនេះ សាបសូន្យហើយ ភាពជាអ្នកប្រសើររបស់សមណៈទាំងនេះ សាបសូន្យហើយ ភាពជាសមណៈនឹងមានដល់សមណៈទាំងនេះ អំពីហេតុដូចម្តេច

កុតោ ឥមេសំ ព្រហ្មញ្ញំ អបគតា ឥមេ សាមញ្ញា អបគតា ឥមេ ព្រហ្មញ្ញា ។ កថញ្ហិ នាម បុរិសោ បុរិសកិច្ចំ ករិត្វា ឥត្ថឹ ជីវិតា វោរោបេស្សតីតិ ។ នេសោ ភិក្ខវេ សទ្ទោ ចិរំ ភវិស្សតិ សត្តាហមេវ ភវិស្សតិ សត្តាហស្ស អច្ចយេន អន្តរធាយិស្សតិ ។ តេនហិ ភិក្ខវេ យេ មនុស្សា ភិក្ខូ ទិស្វា អសព្ភាហិ ផរុសាហិ វាចាហិ អក្កោសន្តិ បរិភាសន្តិ រោសេន្តិ វិហេសេន្តិ តេ តុម្ហេ ឥមាយ គាថាយ បដិចោទេថ

អភូតវាទី និរយំ ឧបេតិ
យោ វាបិ កត្វា ន ករោមីតិ ចាហ
ឧភោបិ តេ បេច្ច សមា ភវន្តិ
និហីនកម្មា មនុជា បរត្ថាតិ ។

(១០៦) អថខោ តេ ភិក្ខូ ភគវតោ សន្តិកេ ឥមំ គាថំ បរិយាបុណិត្វា យេ មនុស្សា ភិក្ខូ ទិស្វា អសព្ភាហិ ផរុសាហិ វាចាហិ អក្កោសន្តិ បរិភាសន្តិ រោសេន្តិ វិហេសេន្តិ តេ ឥមាយ គាថាយ បដិចោទេន្តិ



ភាពជាអ្នកប្រសើរនឹងមានដល់សមណៈទាំងនេះ អំពីណាកុំដូចម្តេច សមណៈទាំងនេះ ប្រាសចាកភាពជាសមណៈហើយ សមណៈទាំងនេះប្រាសចាកភាព ជាអ្នកប្រសើរហើយ ។ ម្តេចក៏ បុរសនឹងធ្វើកិច្ចរបស់បុរស (មេថុនកិច្ច) ហើយមកធ្វើស្រីឲ្យឃ្លាតចាកជីវិតសោះ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សំឡេង (ពោលទោស) នុ៎ះ នឹងមិនឋិតនៅយូរឡើយ ឋិតនៅបានតែត្រឹម ៧ ថ្ងៃប៉ុណ្ណោះ លុះកន្លងហួស ៧ ថ្ងៃហើយ គង់នឹងបាត់ទៅវិញ ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ពួកមនុស្សណា បានឃើញពួកភិក្ខុហើយ ជេរប្រទេច ផ្តាសា បៀតបៀនដោយសំដីទ្រគោះ ជារបស់អសប្បុរស អ្នកទាំងឡាយ ចូរស៊ីកពួកមនុស្សទាំងនោះ ដោយគាថានេះថា

អ្នកនិយាយកុហក ឬអ្នកណាធ្វើហើយ និយាយថា ខ្ញុំមិនធ្វើទេ រមែង
ចូលទៅកាន់នរក បុគ្គលទាំងពីរនោះ ជាអ្នកកើតអំពីមនុស្សមានកម្មដ៏
ថោកទាប លុះលះលោកនេះទៅហើយ ជាអ្នកស្មើគ្នា ក្នុងលោកខាងមុខ ។

(១០៦) លំដាប់នោះ ភិក្ខុទាំងនោះ បានរៀនគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគ ពួកមនុស្សណា ដែលបានឃើញពួកភិក្ខុហើយ ជេរប្រទេច ផ្តាសា បៀតបៀនដោយសំដីទ្រគោះ ជារបស់អសប្បុរស ក៏ស៊ីកមនុស្សទាំងនោះ ដោយគាថានេះថា

អភូតវាទី និរយំ ឧបេតិ
យោ វាបិ កត្វា ន ករោមីតិ ចាហ
ឧភោបិ តេ បេច្ច សមា ភវន្តិ
និហីនកម្មា មនុជា បរត្ថាតិ ។

(១០៧) មនុស្សានំ ឯតទហោសិ អការកា(១) ឥមេ សមណា សក្យបុត្តិយា ន ឥមេហិ កតំ សបន្តិមេ(២) សមណា សក្យបុត្តិយាតិ ។ នេវ សោ សទ្ទោ ចិរំ អហោសិ សត្តាហមេវ សទ្ទោ អហោសិ សត្តាហស្ស អច្ចយេន អន្តរធាយិ ។ អថខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមិំសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិំសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យាវ សុភាសិតញ្ចិទំ ភន្តេ ភគវតា នេសោ ភិក្ខវេ សទ្ទោ ចិរំ ភវិស្សតិ សត្តាហស្ស អច្ចយេន អន្តរធាយិស្សតីតិ អន្តរហិតោ ភន្តេ សោ សទ្ទោតិ ។

១ ម. អការា ។ ២ ឱ. ម. ន ចិមេហិ កតំ សបន្តិមេ ។



បុគ្គលអ្នកនិយាយកុហក ១ បុគ្គលណាធ្វើហើយ និយាយថា ខ្ញុំមិនធ្វើទេ ក៏រមែងចូលទៅកាន់នរក បុគ្គលទាំងពីរពួកនោះ ជាអ្នកកើតអំពីមនុស្ស អ្នកមានកម្មដ៏ថោកទាប លុះលះលោកនេះទៅហើយ ជាអ្នកស្មើគ្នា ក្នុងលោកខាងមុខ ។

(១០៧) មនុស្សទាំងឡាយ ក៏មានសេចក្តីត្រិះរិះថា ពួកសមណៈជាសក្យបុត្តិយ៍នេះ ជាអ្នកមិនធ្វើទេ អំពើអាក្រក់ សមណៈទាំងនេះ មិនបានធ្វើ ពួកសមណៈនេះ ជាសក្យបុត្តិយ៍ ។ សំឡេងនោះ មិនបានឮអស់កាលយូរឡើយ សំឡេងនុ៎ះ ឮបានតែត្រឹម ៧ ថ្ងៃប៉ុណ្ណោះ លុះកន្លង ៧ ថ្ងៃហើយ ក៏សាបសូន្យទៅ ។ គ្រានោះ ពួកភិក្ខុច្រើនរូប បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូល ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចំរើន ចំឡែកណាស់ បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ បានត្រាស់ព្រះពុទ្ធដីកានេះល្អប្រពៃមែនថា ម្នាលភិក្ខុទាំងឡាយ សំឡេងនុ៎ះ នឹងមិនឮអស់កាលយូរឡើយ លុះកន្លង ៧ ថ្ងៃ ហើយ នឹងសាបសូន្យទៅ បពិត្រព្រះអង្គដ៏ចំរើន សំឡេងនោះ សូន្យបាត់ទៅហើយ ។

អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

តុទន្តិ វាចាយ ជនា អសញ្ញតា
សរេហិ[១] សង្គាមគតំវ កុញ្ជរំ
សុត្វាន វាក្យំ ផរុសំ ឧទីរិតំ
អធិវាសយេ ភិក្ខុ អទុដ្ឋចិត្តោ ។ អដ្ឋមំ ។

(១០៨) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ អថខោ អាយស្មតោ ឧបសេនស្ស វង្គន្តបុត្តស្ស រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ លាភា វត មេ សុលទ្ធំ វត មេ សត្ថា ច មេ ភគវា អរហំ សម្មាសម្ពុទ្ធោ ស្វាក្ខាតេ ចម្ហិ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជិតោ សព្រហ្មចារិនោ ច មេ សីលវន្តោ កល្យាណធម្មា សីលេសុ ចម្ហិ បរិបូរការី សុសមាហិតោ ចម្ហិ ឯកគ្គចិត្តោ អរហា ចម្ហិ ខីណាសវោ មហិទ្ធិកោ

១ អដ្ឋកថាយំ សរេហីតិ បាឋោ ទិស្សតិ ។



លុះព្រះមានព្រះភាគ ទ្រង់បានជ្រាបច្បាស់សេចក្តីនុះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

ពួកជនអ្នកមិនសង្រួម តែងចាក់ដោតគេដោយពាក្យ ដូចជា
( ទាហានតទល់ ) កាលចាក់ដំរី ដែលទៅកាន់សង្គ្រាម
ដោយសរទាំងឡាយ ភិក្ខុបានឮពាក្យអាក្រក់ ដែលពួកជន
ផ្តេរពោលហើយ ជាអ្នកមានចិត្តមិនប្រទូស្ត ហើយគប្បីអត់
ទ្រាំបាន ។ សូត្រទី ៨ ។

(១០៨) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តវេឡុវ័ន កលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ គ្រានោះឯង ព្រះឧបសេនវង្គន្តបុត្តដ៏មានអាយុ ទៅក្នុងទីស្ងាត់ ហើយសម្ងំនៅ មានចិត្តត្រិះរិះកើតឡើងយ៉ាងនេះថា ឱហ្ន៎ អញពិតជាមានលាភ ឱហ្ន៎ អញពិតជាបានល្អ ( ព្រោះ ) ព្រះមានព្រះភាគ ជាគ្រូអញ ព្រះអង្គជាព្រះអរហន្តសម្មាសម្ពុទ្ធផង អញក៏បានចេញចាកផ្ទះបួសទៅកាន់ផ្នួស ក្នុងធម្មវិន័យដែលព្រះមានព្រះភាគ ទ្រង់សំដែងដោយប្រពៃផង ពួកសព្រហ្មចារីរបស់អញ ជាអ្នកមានសីល មានកល្យាណធម៌ផង អញជាអ្នកធ្វើឲ្យពេញលេញ ក្នុងសីលទាំងឡាយផង អ្នកមានចិត្តតាំងមាំល្អ មានចិត្តមូលនឹងក្នុងអារម្មណ៍តែមួយផង ជាអរហន្តខីណាស្រពផង អ្នកមានឫទ្ធិច្រើន

ចម្ហិ មហានុភាវោ ភទ្ទកំ មេ ជីវិតំ ភទ្ទកំ មរណន្តិ ។ អថខោ ភគវា អាយស្មតោ ឧបសេនស្ស វង្គន្តបុត្តស្ស ចេតសោ(១) ចេតោបរិវិតក្កមញ្ញាយ តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

យំ ជីវិតំ ន តបតិ មរណន្តេ ន សោចតិ
សវេ ទិដ្ឋបទោ ធីរោ សោកមជ្ឈេ ន សោចតិ ។
ឧច្ឆិន្នភវតណ្ហស្ស សន្តចិត្តស្ស ភិក្ខុនោ
វិក្ខីណោ ជាតិសំសារោ នត្ថិ តស្ស បុនព្ភវោតិ ។

នវមំ ។

(១០៩) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា សារីបុត្តោ ភគវតោ អវិទូរេ និសិន្នោ ហោតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ អត្តនោ ឧបសមំ បច្ចវេក្ខមានោ ។ អទ្ទសា ខោ ភគវា អាយស្មន្តំ សារីបុត្តំ អវិទូរេ និសិន្នំ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ អត្តនោ ឧបសមំ បច្ចវេក្ខមានំ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ



មានអានុភាពច្រើនផង រស់នៅក៏ចំរើន ស្លាប់ក៏ចំរើន ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្ដីត្រិះរិះ ក្នុងចិត្តរបស់ព្រះឧបសេនវង្គន្តបុត្តដ៏មានអាយុ ដោយព្រះទ័យរបស់ព្រះអង្គហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

ជីវិតរបស់បុគ្គលណា មិនក្ដៅក្រហាយ បុគ្គលនោះ រមែងមិនសោក
ក្នុងកាលជិតស្លាប់ ប្រសិនបើ អ្នកប្រាជ្ញនោះឯង បានឃើញបទគឺ
ព្រះនិព្វាន រមែងមិនសោក ក្នុងកណ្ដាលពួកអ្នកសោកឡើយ ។
ភិក្ខុបានកាត់ផ្ដាច់តណ្ហា ក្នុងភព មានចិត្តស្ងប់ មានជាតិសង្សារ
អស់ហើយ ភពថ្មីទៀត មិនមានដល់ភិក្ខុហើយ ។ សូត្រទី ៩ ។

(១០៩) ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះសារីបុត្តដ៏មានអាយុ អង្គុយផ្គត់ភ្នែន តម្រង់កាយត្រង់ ពិចារណាការស្ងប់រម្ងាប់របស់ខ្លួន ក្នុងទីជិតនៃព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់ទតឃើញ ព្រះសារីបុត្តដ៏មានអាយុ អង្គុយផ្គត់ភ្នែន តម្រង់កាយត្រង់ ពិចារណាការស្ងប់រម្ងាប់របស់ខ្លួន ក្នុងទីជិតព្រះអង្គ ។ លុះព្រះមានព្រះភាគ ទ្រង់បានជ្រាបច្បាស់សេចក្ដីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

ឧបសន្តសន្តចិត្តស្ស[១] នេត្តិច្ឆិន្នស្ស ភិក្ខុនោ វិក្ខីណោ ជាតិសំសារោ មុត្តោ សោ មារពន្ធនា ។ ទសមំ ។

មេឃិយវគ្គោ ចតុត្ថោ ។

## តស្សុទ្ទានំ

មេឃិយោ ឧទ្ធតា គោបាលោ ជុណ្ហា[២] នាគេន បញ្ចមំ បិណ្ឌោលោ[៣] សារីបុត្តោ ច សុន្ទរី ភវតិ អដ្ឋមំ ឧបសេនោ វង្គន្តបុត្តោ សារីបុត្តោ ច តេ ទសាតិ[៤] ។

---

១ ម. ឧបសន្តស្ស ភិក្ខុស្ស ។ ២ ម. មេឃិយំ ឧទ្ធតា គោបាលំ ជុណ្ហំ ។ ៣ ម. បិណ្ឌោលោ ។ ៤ ឱ.ម. ទសាតិ ។



ភិក្ខុអ្នកមានចិត្តស្ងប់ម្ងាត់ បានកាត់ផ្តាច់តណ្ហាសម្រាប់នាំទៅ ( កាន់ភព ) មានជាតិសំសារអស់ហើយ ភិក្ខុនោះបានផុតហើយចាកចំណងនៃមារ ។ សូត្រ ទី ១០ ។

ចប់ មេឃិយវគ្គ ទី ៤ ។

## ឧទ្ទាននៃមេឃិយវគ្គនោះគឺ

និយាយអំពីរឿងព្រះមេឃិយៈ ១ ពួកភិក្ខុដែលមានចិត្តរវើរវាយ ១ នាយគោបាល ១ ព្រះសារីបុត្តអង្គុយក្នុងទីវាលក្នុងរាត្រីខែភ្លឺ ១ ពួកនាគនឹងហត្ថីនាគ ១ ជាគំរប់ប្រាំ ព្រះបិណ្ឌោលភារទ្វាជៈ ១ ព្រះសារីបុត្ត ១ នាងបរិព្វាជិកាឈ្មោះសុន្ទរី ១ ជាគំរប់ប្រាំបី ព្រះឧបសេនវង្គន្តបុត្ត ១ ព្រះសារីបុត្ត ១ រួមរឿងទាំងអស់នោះត្រូវជា ១០ ។

## ឧទានេ បញ្ចមោ សោណត្ថេរវគ្គោ

(១១០) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន រាជា បសេនទិ កោសលោ មល្លិកាយ ទេវិយា សទ្ធឹ ឧបរិបាសាទវរគតោ ហោតិ ។ អថខោ រាជា បសេនទិ កោសលោ មល្លិកំ ទេវឹ ឯតទវោច អត្ថិ នុ ខោ តេ មល្លិកេ កោចញ្ញោ អត្តនា បិយតរោតិ ។ នត្ថិ ខោ មេ មហារាជ កោចញ្ញោ អត្តនា បិយតរោ តុយ្ហំ បន មហារាជ អត្ថញ្ញោ កោចិ អត្តនា បិយតរោតិ ។ មយ្ហម្បិ(១) មល្លិកេ នត្ថញ្ញោ កោចិ អត្តនា បិយតរោតិ ។ អថខោ រាជា បសេនទិ កោសលោ បាសាទា ឱរោហិត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ រាជា បសេនទិ កោសលោ ភគវន្តំ ឯតទវោច ឥធាហំ ភន្តេ មល្លិកាយ ទេវិយា សទ្ធឹ ឧបរិបាសាទវរគតោ

១ ម. ម. មយ្ហម្បិ ខោ អត្ថិ ។



## ឧទាន សោណត្ថេរវគ្គ ទី ៥

(១១០) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះ ព្រះបាទបសេនទិកោសល គង់នៅខាងលើប្រាសាទដ៏ប្រសើរ ជាមួយនឹងព្រះនាងមល្លិកាទេវី ។ គ្រានោះ ព្រះបាទបសេនទិកោសល ទ្រង់សួរព្រះនាងមល្លិកាទេវីថា ម្នាលនាងមល្លិកា បុគ្គលដទៃណាមួយ ជាទីស្រឡាញ់ ជាងខ្លួនរបស់នាងមានដែរឬ ។ បពិត្រមហារាជ បុគ្គលដទៃណាមួយ ជាទីស្រឡាញ់ ជាងខ្លួនរបស់ខ្ញុំម្ចាស់ មិនមានទេ បពិត្រមហារាជ ចុះបុគ្គលដទៃណាមួយ ជាទីស្រឡាញ់ ជាងខ្លួនព្រះអង្គ មានដែរឬ ។ ម្នាលនាងមល្លិកា បុគ្គលដទៃណាមួយ ជាទីស្រឡាញ់ ជាងខ្លួនរបស់យើង មិនមានទេ ។ លំដាប់នោះ ព្រះបាទបសេនទិកោសល ទ្រង់យាងចុះអំពីប្រាសាទហើយ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់ក្នុងទីសមគួរ ។ លុះព្រះបាទបសេនទិកោសល គង់ក្នុងទីសមគួរហើយ ក៏ដំណាលសេចក្តីនេះទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន អម្បាញ់មិញ ខ្ញុំព្រះអង្គ នៅខាងលើប្រាសាទដ៏ប្រសើរ ជាមួយនឹងនាងមល្លិកាទេវី

មល្លិកំ ទេវឹ ឯតទវោច អត្ថិ នុ ខោ តេ មល្លិកេ កោចញ្ញោ អត្តនា បិយតរោតិ ឯវំ វុត្តេ មល្លិកា ទេវី[១] ឯតទវោច នត្ថិ ខោ មេ មហារាជ កោចញ្ញោ អត្តនា បិយតរោ តុយ្ហំ បន មហារាជ អត្ថញ្ញោ កោចិ អត្តនា បិយតរោតិ ឯវំ វុត្តោហំ[២] ភន្តេ មល្លិកំ ទេវឹ ឯតទវោចំ មយ្ហម្បិ ខោ មល្លិកេ នត្ថញ្ញោ កោចិ អត្តនា បិយតរោតិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

សព្វា ទិសា អនុបរិគម្ម ចេតសា
នេវជ្ឈគា បិយតរមត្តនា ក្វចិ
ឯវម្បិ សោ[៣] បុថុ អត្តា បរេសំ
តស្មា ន ហឹសេ បរំ អត្តកាមោតិ ។ សុត្តំ បឋមំ ។[៤]

[១១១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អាយស្មា អានន្ទោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា

១ ឱ.ម. ទិន្នន្តុ មល្លិ អត្ថិ ។ ២ ឱ.ម. វុត្តាហំ ។ ៣ ម. ឯវំបិ យោ ។ ឯវំបិ យោតិ អដ្ឋកថា ។ ៤ ឱ.ម. សុត្តំ បឋមំ ។ បញ្ចមំ ។



ហើយសួរនាងមល្លិកាទេវីថា ម្នាលនាងមល្លិកា ចុះបុគ្គលដទៃណាមួយ ជាទីស្រឡាញ់ជាងខ្លួនរបស់នាង មានដែរឬ លុះខ្ញុំព្រះអង្គ សួរយ៉ាងនេះហើយ ទើបនាងមល្លិកាទេវីតបថា បពិត្រមហារាជ បុគ្គលដទៃណាមួយ ជាទីស្រឡាញ់ជាងខ្លួនខ្ញុំម្ចាស់ មិនមានទេ បពិត្រមហារាជ បុគ្គលដទៃណាមួយ ជាទីស្រឡាញ់ជាងខ្លួនព្រះអង្គ មានដែរឬ បពិត្រព្រះអង្គដ៏ចំរើន លុះនាងមល្លិកាទេវី សួរយ៉ាងនេះហើយ ខ្ញុំព្រះអង្គឆ្លើយនឹងនាងមល្លិកាទេវីថា ម្នាលនាងមល្លិកា បុគ្គលដទៃណាមួយ ជាទីស្រឡាញ់ជាងខ្លួនរបស់យើង មិនមានទេ ។ គ្រានោះ ព្រះមានព្រះភាគ ជ្រាបសេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

បុគ្គលមានចិត្តគិតរក គ្រប់ទិស ក៏មិនបានបុគ្គលជាទីស្រឡាញ់
ជាងខ្លួន ក្នុងទីណាមួយឡើយ ចំណែកខ្លួននោះ ទើបជាទីស្រឡាញ់
ច្រើនជាងបុគ្គលដទៃ យ៉ាងនេះ ព្រោះហេតុនោះ បុគ្គលអ្នក
ស្រឡាញ់ខ្លួន មិនត្រូវបៀតបៀនបុគ្គលដទៃឡើយ ។ សូត្រទី ១ ។

[១១១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចេញអំពីទីសម្ងំ ក្នុងសាយណ្ហសម័យ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ

ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យាវ អប្បាយុកា ហិ ភន្តេ ភគវតោ មាតា អហោសិ សត្តាហជាតេ ភគវតិ ភគវតោ មាតា កាលមកាសិ តុសិតំ កាយំ(១) ឧបបជ្ជីតិ ។ ឯវមេតំ អានន្ទ ឯវមេតំ អានន្ទ អប្បាយុកា ហិ អានន្ទ ពោធិសត្តមាតរោ ហោន្តិ សត្តាហជាតេសុ ពោធិសត្តេសុ ពោធិសត្តមាតរោ កាលំ ករោន្តិ តុសិតំ កាយំ ឧបបជ្ជន្តិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

យេ កេចិ ភូតា ភវិស្សន្តិ យេ វាបិ
សព្វេ គមិស្សន្តិ បហាយ ទេហំ
តំ សព្វជានិ កុសលោ វិទិត្វា
អាតាបិយោ ព្រហ្មចរិយំ ចរេយ្យាតិ ។ ទុតិយំ ។





ថ្វាយបង្គំព្រះមានព្រះភាគ អង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចំរើន ចំឡែកណាស់ បពិត្រព្រះអង្គដ៏ចំរើន ព្រោះថា ព្រះមាតារបស់ព្រះមានព្រះភាគ មានព្រះជន្មាយុតិចណាស់ កាលព្រះមានព្រះភាគ ប្រសូតបាន ៧ ថ្ងៃ ព្រះមាតារបស់ព្រះអង្គ ទ្រង់សោយព្រះពិរាល័យ ទៅកើតក្នុងទេវនិកាយ ឯស្ថានតុសិត ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអានន្ទ ដំណើរនុ៎ះមែនហើយ ម្នាលអានន្ទ ដំណើរនុ៎ះមែនហើយ ម្នាលអានន្ទ ព្រោះថា ព្រះមាតារបស់ពោធិសត្វទាំងឡាយ តែងមានព្រះជន្មាយុតិច កាលព្រះពោធិសត្វទាំងឡាយ ទ្រង់ប្រសូតបាន ៧ ថ្ងៃ ព្រះមាតារបស់ពោធិសត្វទាំងឡាយ គំសោយព្រះពិរាល័យ ហើយទៅកើត ក្នុងទេវនិកាយ ឯស្ថានតុសិត ( ជាធម្មតា ) ។ គ្រានោះ ព្រះមានព្រះភាគ ជ្រាបសេចក្ដីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

ពួកសត្វណាមួយ ដែលកើតហើយក្ដី នឹងកើត (ក្នុងអនាគត) ក្ដី ពួក
សត្វទាំងអស់នោះ នឹងលះបង់នូវរាងកាយ ទៅកាន់ (បរលោក) ដូចគ្នា
បណ្ឌិតអ្នកឈ្លាស ដឹងច្បាស់សេចក្ដីសាបសូន្យ ទាំងអស់នោះហើយ
គួរជាអ្នកមានព្យាយាម ប្រព្រឹត្តព្រហ្មចរិយធម៌ ។ សូត្រទី ២ ។

(១១២) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន រាជគហេ សុប្បពុទ្ធោ នាម កុដ្ឋី មនុស្សទលិទ្ទោ អហោសិ មនុស្សកបណោ មនុស្សវរាកោ ។ តេន ខោ បន សមយេន ភគវា មហតិយា បរិសាយ បរិវុតោ ធម្មំ ទេសេន្តោ និសិន្នោ ហោតិ ។ អទ្ទសា ខោ សុប្បពុទ្ធោ កុដ្ឋី(១) មហាជនកាយំ ទូរតោវ សន្និបតិតំ ទិស្វានស្ស ឯតទហោសិ និស្សំសយំ ខោ ឯត្ថ កិញ្ចិ ខាទនីយំ វា ភោជនីយំ វា ភាជីយតិ(២) យន្នូនាហំ យេន សោ មហាជនកាយោ តេនុបសង្កមេយ្យំ អប្បេវ នាមេត្ថ កិញ្ចិ ខាទនីយំ វា ភោជនីយំ វា លភេយ្យន្តិ ។ អថខោ សុប្បពុទ្ធោ កុដ្ឋី យេន សោ មហាជនកាយោ តេនុបសង្កមិ អទ្ទសា ខោ សុប្បពុទ្ធោ កុដ្ឋី ភគវន្តំ មហតិយា បរិសាយ បរិវុតំ ធម្មំ ទេសេន្តំ និសិន្នំ ទិស្វានស្ស ឯតទហោសិ ន ខោ ឯត្ថ កិញ្ចិ ខាទនីយំ វា ភោជនីយំ វា ភាជីយតិ

១ ម. ខ្មុំ កុដ្ឋី ។ ២ ម. ភាជិយ្យតិ ។



(១០៦) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង មនុស្សឃ្លង់ម្នាក់ ជាមនុស្សកំសត់ មនុស្សកំព្រា មនុស្សថោកទាបឈ្មោះសុប្បពុទ្ធ នៅក្នុងក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះមានព្រះភាគមានបរិស័ទច្រើនចោមរោមហើយ គង់សំដែងធម៌ ។ សុប្បពុទ្ធកុដ្ឋិ បានឃើញនូវពួកមហាជនប្រជុំគ្នា លុះឃើញហើយ គាត់មានសេចក្តីត្រិះរិះថា គេពិតជាចែកខាទនីយៈឬភោជនីយាហារណាមួយ ក្នុងទីនេះជាមិនសង្ស័យ បើដូច្នោះ អាត្មាអញគួរទៅរកពួកមហាជនដោយពិត ថា ធ្វើម្តេចទៅហ្ន៎ អាត្មាអញនឹងបានខាទនីយៈឬភោជនីយាហារណាមួយ ក្នុងទីនុ៎ះ ។ លំដាប់នោះ សុប្បពុទ្ធកុដ្ឋិ ចូលសំដៅទៅរកពួកមហាជន សុប្បពុទ្ធកុដ្ឋិ បានឃើញព្រះមានព្រះភាគ ដែលបរិស័ទជាច្រើន ចោមរោម គង់សំដែងធម៌ លុះឃើញហើយ គាត់ក៏មានសេចក្តីត្រិះរិះ ដូច្នេះថា ចុះហ្ន៎ គេមិនចែកខាទនីយៈ ឬភោជនីយាហារណាមួយ ក្នុងទីនេះទេ

សមណោ អយំ គោតមោ បរិសតិ[១] ធម្មំ ទេសេតិ យន្នូនាហម្បិ ធម្មំ សុណេយ្យន្តិ តត្ថេវ ឯកមន្តំ និសីទិ អហម្បិ ធម្មំ សោស្សាមីតិ ។ អថខោ ភគវា សព្វាវន្តំ បរិសំ ចេតសា ចេតោ បរិច្ច មនសាកាសិ កោ នុ ខោ ឥធ ភព្វោ ធម្មំ វិញ្ញាតុន្តិ ។ អទ្ទសា ខោ ភគវា សុប្បពុទ្ធំ កុដ្ឋឹ តស្សំ បរិសាយំ និសិន្នំ ទិស្វានស្ស ឯតទហោសិ អយំ ខោ ឥធ ភព្វោ ធម្មំ វិញ្ញាតុន្តិ សុប្បពុទ្ធំ កុដ្ឋឹ អារព្ភ អនុបុព្វីកថំ កថេសិ សេយ្យថីទំ ទានកថំ សី-លកថំ សគ្គកថំ កាមានំ អាទីនវំ ឱការំ សង្កិលេសំ នេក្ខម្មេ ច[២] អានិសំសំ បកាសេសិ[៣] ។ យទា ភគវា អញ្ញាសិ សុប្បពុទ្ធំ កុដ្ឋឹ កល្លចិត្តំ មុទុចិត្តំ វិនីវរណចិត្តំ ឧទគ្គចិត្តំ បសន្នចិត្តំ អថ យា ពុទ្ធានំ សាមុក្កំសិកា ធម្មទេសនា តំ បកាសេសិ ទុក្ខំ សមុទយំ និរោធំ មគ្គំ ។ សេយ្យថាបិ នាម សុទ្ធំ វត្ថំ អបគតកាឡកំ សម្មទេវ រជនំ បដិគ្គណ្ហេយ្យ ឯវមេវ សុប្បពុទ្ធស្ស កុដ្ឋិស្ស តស្មិំយេវ អាសនេ វិរជំ វីតមលំ ធម្មចក្ខុំ[៤] ឧទបាទិ យំ កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ។

១ ម. បរិសតិ ។ ២ ម. នេក្ខម្មេ ច ។ ៣ ម. បកាសេតិ ។ ៤ ម. ធម្មចក្ខុ ។



ព្រះសមណគោតមនេះ ទ្រង់សំដែងធម៌ ក្នុងកណ្ដាលបរិស័ទ បើដូច្នោះ គួរតែអាត្មាអញស្ដាប់ធម៌ដែរ គាត់ក៏អង្គុយក្នុងទីសមគួរ ក្នុងទីនោះដោយគិតថា អាត្មាអញនឹងស្ដាប់ធម៌ដែរ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ធ្វើទុកក្នុងព្រះទ័យកំណត់ចិត្តបរិស័ទទាំងអស់ ដោយព្រះហឫទ័យថា តើណាហ្ន៎ គួរត្រាស់ដឹងនូវធម៌ក្នុងទីនេះបាន ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញសុប្ប-ពុទ្ធកុដ្ឋិ ដែលអង្គុយក្នុងបរិស័ទនោះ លុះទ្រង់ទតឃើញហើយ ព្រះមានព្រះ-ភាគត្រិះរិះថា សុប្បពុទ្ធកុដ្ឋិនេះឯង គួរនឹងដឹងនូវធម៌បានក្នុងទីនេះ ទើបទ្រង់សំដែងអនុបុព្វីកថា ប្រារព្ធសុប្បពុទ្ធកុដ្ឋិ គឺទ្រង់ប្រកាសទានកថា សីលកថា សគ្គកថា ទោសដ៏លាមកសៅហ្មងនៃកាមគុណ និងអានិសង្សក្នុងការចេញបួស ។ ព្រះមានព្រះភាគបានជ្រាបថា សុប្បពុទ្ធកុដ្ឋិ មានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តខ្ពស់ឡើង មានចិត្តជ្រះថ្លា ក្នុងកាលណាហើយ ទ្រង់ប្រកាសធម្មទេសនា ដែលព្រះពុទ្ធទាំងឡាយ ទ្រង់លើកឡើងសំដែងដោយព្រះអង្គឯង គឺសំដែងទុក្ខ សមុទ័យ និរោធ និងមគ្គ ក្នុងកា-លនោះ ។ ធម្មចក្ខុប្រាសចាកធូលី ប្រាសចាកមន្ទិល កើតឡើងដល់សុប្បពុទ្ធកុដ្ឋិក្នុងទីអង្គុយនោះថា ធម្មជាតណាមួយ ដែលកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ តែងរលត់ទៅវិញជាធម្មតាដូច្នោះ ដូចសំពត់ស ស្អាតប្រាសចាកពណ៌ខ្មៅ គួរទទួលគ្រឿងជ្រលក់បានដោយប្រពៃ យ៉ាងដូច្នោះឯង ។

(១១៣) អថខោ សុប្បពុទ្ធោ កុដ្ឋី ទិដ្ឋធម្មោ បត្តធម្មោ វិទិតធម្មោ បរិយោគាឡ្ហធម្មោ តិណ្ណវិចិកិច្ឆោ វិគតកថំកថោ វេសារជ្ជប្បត្តោ អបរប្បច្ចយោ សត្ថុសាសនេ ឧដ្ឋាយាសនា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សុប្បពុទ្ធោ កុដ្ឋី ភគវន្តំ ឯតទវោច អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ សេយ្យថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវំ ភគវតា អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។ អថខោ សុប្បពុទ្ធោ កុដ្ឋី ភគវតា ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ សម្បហំសិតោ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា



(១១៣) គ្រានោះ សុប្បពុទ្ធកុដ្ឋិ ឃើញធម៌ហើយ បានធម៌ហើយ ដឹងធម៌ហើយ ចុះកាន់ធម៌ស៊ប់ហើយ ឆ្លងសេចក្ដីសង្ស័យ ប្រាសចាកសេចក្ដីចចើងចចូល ដល់នូវភាពក្លៀវក្លា មិនជឿបុគ្គលដទៃ ក្នុងសាសនា នៃព្រះសាស្ដាហើយក្រោកចាកទីអង្គុយ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះសុប្បពុទ្ធកុដ្ឋិ អង្គុយក្នុងទីសមគួរហើយ សរសើរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ច្បាស់ណាស់ បពិត្រព្រះអង្គដ៏ចំរើន ច្បាស់ណាស់ បពិត្រព្រះអង្គដ៏ចំរើន ធម៌ទេសនាដែលព្រះមានព្រះភាគ សំដែងហើយ ដោយអនេកបរិយាយ ដូចបុរសផ្ងារ របស់ដែលផ្កាប់ឬបើករបស់ដែលបិទបាំង ពុំនោះសោតដូចគេប្រាប់ផ្លូវដល់អ្នកវង្វេង ពុំនោះសោតដូចគេទ្រោលប្រទីបប្រេង ក្នុងទីងងឹត ដោយគិតថា ពួកអ្នកមានភ្នែកឃើញរូបទាំងឡាយ ដូច្នោះឯង បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនុ៎ះ សូមដល់ព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង សូមព្រះមានព្រះភាគ ចាំទុកខ្ញុំព្រះអង្គថាជាឧបាសក ដល់សរណៈស្មើដោយជីវិត តាំងពីថ្ងៃនេះរៀងទៅ ។ គ្រានោះ សុប្បពុទ្ធកុដ្ឋិ ដែលព្រះមានព្រះភាគ ទ្រង់ពន្យល់ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ត្រេកអររីករាយនឹងភាសិតរបស់ព្រះមានព្រះភាគ ទើបក្រោកចាកទីអង្គុយ ថ្វាយបង្គំលាព្រះមានព្រះភាគ

បទក្ខិណំ កត្វា បក្កាមិ ។ អថខោ អចិរបក្កន្តំ សុប្បពុទ្ធំ កុដ្ឋឹ គាវី តរុណវច្ឆា អធិបតិត្វា ជីវិតា វោរោបេសិ ។ អថខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ យោ សោ ភន្តេ សុប្បពុទ្ធោ នាម កុដ្ឋី ភគវតា ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ សម្បហំសិតោ សោ កាលង្កតោ តស្ស កា គតិ កោ អភិសម្បរាយោតិ ។ បណ្ឌិតោ ភិក្ខវេ សុប្បពុទ្ធោ កុដ្ឋី បច្ចបាទិ ធម្មស្សានុធម្មំ ន ច មំ ធម្មាធិករណំ វិហេសេសិ សុប្បពុទ្ធោ ភិក្ខវេ កុដ្ឋី តិណ្ណំ សញ្ញោជនានំ បរិក្ខយា សោតាបន្នោ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ ។

(១១៤) ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន សុប្បពុទ្ធោ កុដ្ឋី មនុស្សទលិទ្ទោ អហោសិ មនុស្សកបណោ មនុស្សវរាកោតិ ។ ភូតបុព្វំ ភិក្ខវេ



ធ្វើប្រទក្សិណ ចៀសចេញទៅ ។ គ្រានោះ មេគោមានកូនខ្ចី មកប៉ុះសុប្បពុទ្ធកុដ្ឋិ ដែលទើបនឹងចេញទៅមិនយូរប៉ុន្មាន ឲ្យដាច់ជាតជីវិត ។ គ្រានោះ ភិក្ខុច្រើនរូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ អង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ ទូលសួរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សុប្បពុទ្ធកុដ្ឋិ ដែលព្រះមានព្រះភាគ ទ្រង់ពន្យល់ ឲ្យកាន់យក ឲ្យអង់អាច ឲ្យរីករាយដោយធម្មីកថា ( ទេសនា ) សុប្បពុទ្ធកុដ្ឋិនោះស្លាប់ហើយ គតិរបស់គាត់ តើដូចម្តេច បរលោករបស់គាត់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សុប្បពុទ្ធកុដ្ឋិ ជាបណ្ឌិត បានដឹងធម៌សមគួរតាមធម៌ហើយ មិនបៀតបៀនតថាគត ព្រោះហេតុនៃការសំដែងធម៌ទៀតទេ ម្នាលភិក្ខុទាំងឡាយ សុប្បពុទ្ធកុដ្ឋិ ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ចុះ មានគតិទៀងទាត់ មានសម្ពោធិធម៌ប្រព្រឹត្តទៅខាងមុខ ព្រោះអស់ទៅនៃសញ្ញោជនធម៌ ៣ ប្រការ ។

(១១៤) កាលដែលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះ ភិក្ខុ ១ រូប ទូលសួរព្រះមានព្រះភាគទៀតថា បពិត្រព្រះអង្គដ៏ចំរើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យ សុប្បពុទ្ធកុដ្ឋិ ជាមនុស្សកំសត់ ជាមនុស្សកំព្រា ជាមនុស្សថោកទាប ។ ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយ

សុប្បពុទ្ធោ កុដ្ឋី ឥមស្មឹយេវ រាជគហេ សេដ្ឋិបុត្តោ អហោសិ សោ ឧយ្យានភូមឹ និយ្យន្តោ អទ្ទស[១] តគរសិខឹ បច្ចេកពុទ្ធំ នគរេ[២] បិណ្ឌាយ ចរន្តំ[៣] ទិស្វានស្ស ឯតទហោសិ ក្វាយំ កុដ្ឋី វិចរតីតិ និដ្ឋុភិត្វា អបព្យាមតោ[៤] ករិត្វា បក្កាមិ ។ សោ តស្ស កម្មស្ស វិបាកេន ពហូនិ វស្សានិ ពហូនិ វស្សសតានិ ពហូនិ វស្សសហស្សានិ ពហូនិ វស្សសតសហស្សានិ និរយេ បច្ចិត្ថ តស្សេវ កម្មស្ស វិបាកាវសេសេន ឥមស្មឹយេវ រាជគហេ មនុស្សទលិទ្ទោ អហោសិ មនុស្សកបណោ មនុស្សវរាកោ សោ តថាគតប្បវេទិតំ ធម្មវិនយំ អាគម្ម សទ្ធំ សមាទិយិ សីលំ សមាទិយិ សុតំ សមាទិយិ ចាគំ សមាទិយិ បញ្ញំ សមាទិយិ សោ តថាគតប្បវេទិតំ ធម្មវិនយំ អាគម្ម សទ្ធំ សមាទិយិត្វា សីលំ សមាទិយិត្វា សុតំ សមាទិយិត្វា ចាគំ សមាទិយិត្វា បញ្ញំ សមាទិយិត្វា

១ ម. អទ្ទសា ។ ២ ម. យ. នគរំ ។ ៣ ម. យ. បវិសន្តំ ។ ៤ ម. និដ្ឋុភិត្វា អបសព្យាមតោ ។ យ. និដ្ឋុភិត្វា អបសព្យតោ ។



សុប្បពុទ្ធកុដ្ឋិ កើតជាសេដ្ឋីបុត្រ ក្នុងក្រុងរាជគ្រឹះនេះឯង សេដ្ឋីបុត្រនោះ ចេញទៅកាន់ទីឧទ្យានក្ដី បានឃើញព្រះតគរសិខីបច្ចេកពុទ្ធ ដែលកំពុងត្រាច់ទៅបិណ្ឌបាតក្នុងក្រុង លុះឃើញហើយ ទើបសេដ្ឋីបុត្រនោះគិតថា សមណៈគំលង់នេះ ដើរធ្វើអ្វី ហើយស្ដោះទឹកមាត់ ធ្វើជាយកការគោរពជ្រាយ ហើយចៀសចេញទៅ ។ ដោយផលនៃកម្មនោះ សេដ្ឋីបុត្រនោះ ក៏ទៅកើតនៅក្នុងនរក អស់ឆ្នាំជាច្រើន គឺអស់រយនៃឆ្នាំជាច្រើន អស់ពាន់នៃឆ្នាំនឹងសែននៃឆ្នាំជាច្រើន ដោយសំណល់នៃផលកម្មនោះ ទើបគាត់កើតមកជាមនុស្សកំសត់ មនុស្សកំព្រា មនុស្សថោកទាប ក្នុងក្រុងរាជគ្រឹះនេះឯង សុប្បពុទ្ធកុដ្ឋិនោះ បានអាស្រ័យធម្មវិន័យ ដែលព្រះតថាគតសំដែងហើយ កាន់យកសទ្ធាដោយប្រពៃ កាន់យកសីលដោយប្រពៃ កាន់យកសុតៈដោយប្រពៃ កាន់យកចាគៈដោយប្រពៃ កាន់យកបញ្ញាដោយប្រពៃ សុប្បពុទ្ធកុដ្ឋិនោះ លុះអាស្រ័យធម្មវិន័យ ដែលតថាគតសំដែងហើយ ក៏កាន់យកសទ្ធាដោយប្រពៃ កាន់យកសីលដោយប្រពៃ កាន់យកសុតៈដោយប្រពៃ កាន់យកចាគៈដោយប្រពៃ កាន់យកបញ្ញាដោយប្រពៃ

កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបប-
ន្នោ ទេវានំ តាវត្តឹសានំ សហព្យតំ គតោ អញ្ញេ ទេវេ
អភិភវិត្វា វណ្ណេន ចេវ យសសា ចាតិ ។ អថខោ ភគវា
ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

ចក្ខុមា វិសមានីវ វិជ្ជមានេ បរក្កមេ
បណ្ឌិតោ ជីវលោកស្មឹ បាបានិ បរិវជ្ជយេតិ ។

តតិយំ(១) ។

[១១៩] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សម្ពហុលា កុមារកា អន្តរា ច សាវត្ថឹ អន្តរា ច ជេតវនំ មច្ឆកេ ពាធេន្តិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បាវិសិ ។ អទ្ទសា ខោ ភគវា តេ សម្ពហុលេ កុមារកេ អន្តរា ច សាវត្ថឹ អន្តរា ច ជេតវនំ មច្ឆកេ ពាធេន្តេ ទិស្វាន យេន(២) តេ កុមារកា តេនុបសង្កមិ ឧបសង្កមិត្វា តេ កុមារកេ ឯតទវោច ភាយថ នោ តុម្ហេ កុមារកា ទុក្ខស្ស អប្បិយំ វោ ទុក្ខន្តិ ។

១ ឱ. ប. តតិយំ សុត្តំ ។ ២ ឱ. ម. ទិស្វាន យេន តេ ។



លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតឯសុគតិសួគ៌ទេវលោក ជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស ទៅឫគ្គនោះ ក៏ផ្សើរឡើងគ្របសង្កត់ពួកទេវតាដទៃទៀត គឺដោយពណ៌សម្បុរផង ដោយយសបរិវារផង ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបសេចក្តីនុះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

បណ្ឌិតគប្បីវៀរស្រឡះនូវអំពើលាមក ក្នុងជីវលោកនេះ ដូចបុរសមាន
ចក្ខុ វៀរស្រឡះទីមិនស្មើ ក្នុងកាលដែលរស់នៅ ។ សូត្រ ទី ៣ ។

[១១៩] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ពួកកុមារច្រើននាក់ចាប់ត្រី ក្នុងចន្លោះក្រុងសាវត្ថីនឹងវត្តជេតពន ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រចីវរ ក្នុងវេលាព្រឹក ហើយចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញ នូវពួកកុមារច្រើននាក់ទាំងនោះ កំពុងចាប់ត្រី ក្នុងចន្លោះក្រុងសាវត្ថីនឹងវត្តជេតពន លុះឃើញហើយ ទើបទ្រង់ចៀសចូលទៅរក ពួកកុមារទាំងនោះ លុះចូលទៅដល់ហើយ ទ្រង់សួរពួកកុមារទាំងនោះថា ម្នាលកុមារទាំងឡាយ អ្នកទាំងឡាយ ខ្លាចសេចក្តីទុក្ខ សេចក្តីទុក្ខ មិនជាទីស្រឡាញ់ របស់អ្នកទាំងឡាយទេឬ ។

ឯវំ ភន្តេ ភាយាម មយំ ភន្តេ ទុក្ខស្ស អប្បិយំ នោ ទុក្ខន្តិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

សចេ ភាយថ ទុក្ខស្ស សចេ វោ ទុក្ខមប្បិយំ
មាកត្ថ បាបកំ កម្មំ អាវិ វា យទិ វា រហោ
សចេ ច បាបកំ កម្មំ ករិស្សថ ករោថ វា
ន វោ[១] ទុក្ខា បមុត្យត្ថិ ឧបេច្ចាបិ បលាយតន្តិ ។

ចតុត្ថំ[២] ។

[១១៦] ឯវំមេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ បុព្វារាមេ មិគារមាតុបាសាទេ ។ តេន ខោ បន សមយេន ភគវា តទហុបោសថេ ភិក្ខុសង្ឃបរិវុតោ និសិន្នោ ហោតិ ។ អថខោ អាយស្មា អានន្ទោ អភិក្កន្តាយ រត្តិយា និក្ខន្តេ បឋមេ យាមេ ឧដ្ឋាយាសនា ឯកំសំ ចីវរំ កត្វា យេន ភគវា តេនញ្ជលិំ បណាមេត្វា ភគវន្តំ ឯតទវោច អភិក្កន្តា ភន្តេ រត្តិ និក្ខន្តោ បឋមោ យាមោ ចិរនិសិន្នោ ភិក្ខុសង្ឃោ ឧទ្ទិសតុ ភន្តេ ភគវា ភិក្ខូនំ បាតិមោក្ខន្តិ ។

១ ម. ឆ. ។ ២ ឱ. ម. ចតុត្ថំ ។



ព្រះករុណាព្រះអង្គ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គទាំងឡាយ ខ្លាចសេចក្ដីទុក្ខមែន សេចក្ដីទុក្ខ មិនជាទីស្រឡាញ់ របស់ខ្ញុំព្រះអង្គទាំងឡាយទេ ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបសេចក្ដីនុ៎ះហើយ ទើបទ្រង់បន្លឺនូវឧទាននេះ ក្នុងវេលានោះថា

បើ អ្នកទាំងឡាយ ខ្លាចសេចក្ដីទុក្ខ បើសេចក្ដីទុក្ខ មិនជាទីស្រឡាញ់
របស់អ្នកទាំងឡាយទេ អ្នកទាំងឡាយ កុំធ្វើបាបកម្ម ក្នុងទីកំបាំងមុខ
ទីចំពោះមុខឡើយ ប្រសិនបើ អ្នកទាំងឡាយនឹងធ្វើ ឬ កំពុងធ្វើបាបកម្ម
សូម្បីអ្នកទាំងឡាយគេចរត់ទៅ ក៏មិនរួចចាកទុក្ខឡើយ ។ សូត្រទី ៤ ។

[១១៦] ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងប្រាសាទមិគារមាតា ក្នុងបុព្វារាម ទៀបក្រុងសាវត្ថី ។ សម័យនោះឯង គាប់ជួនថ្ងៃឧបោសថនោះ ព្រះមានព្រះភាគ មានភិក្ខុសង្ឃចោមរោម ទ្រង់គង់ក្នុងថ្ងៃឧបោសថនោះ ។ លុះវេលាកន្លងបឋមយាម កន្លងទៅហើយ ព្រះអានន្ទដ៏មានអាយុ ក្រោកចាកអាសនៈធ្វើចីវរឆៀងស្មាម្ខាង ប្រណម្យអញ្ជលី ចំពោះព្រះមានព្រះភាគ ហើយក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន វេលាកន្លងបឋមយាម កន្លងទៅហើយ ភិក្ខុសង្ឃអង្គុយយូរហើយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទ្រង់សំដែងបាតិមោក្ខ ដល់ពួកភិក្ខុ ។

ឯវំ វុត្តេ ភគវា តុណ្ហី អហោសិ ។ ទុតិយម្បិ ខោ អាយស្មា អានន្ទោ អភិក្កន្តាយ រត្តិយា និក្ខន្តេ មជ្ឈិមេ យាមេ ឧដ្ឋាយាសនា ឯកំសំ ចីវរំ កត្វា យេន ភគវា តេនញ្ជលិំ បណាមេត្វា ភគវន្តំ ឯតទវោច អភិក្កន្តា ភន្តេ រត្តិ និក្ខន្តោ មជ្ឈិមោ យាមោ ចិរនិសិន្នោ ភិក្ខុសង្ឃោ ទេសេតុ ភន្តេ ភគវា ភិក្ខូនំ បាតិមោក្ខន្តិ ។ ទុតិយម្បិ ខោ ភគវា តុណ្ហី អហោសិ ។ តតិយម្បិ ខោ អាយស្មា អានន្ទោ អភិក្កន្តាយ រត្តិយា និក្ខន្តេ បច្ឆិមេ យាមេ ឧទ្ធស្តេ អរុណេ នន្ទិមុខិយា រត្តិយា ឧដ្ឋាយាសនា ឯកំសំ ចីវរំ កត្វា យេន ភគវា តេនញ្ជលិំ បណាមេត្វា ភគវន្តំ ឯតទវោច អភិក្កន្តា ភន្តេ រត្តិ និក្ខន្តោ បច្ឆិមោ យាមោ ឧទ្ធស្តោ អរុណោ នន្ទិមុខី រត្តិ ចិរនិសិន្នោ ភិក្ខុសង្ឃោ ទេសេតុ ភន្តេ ភគវា ភិក្ខូនំ បាតិមោក្ខន្តិ ។ អបរិសុទ្ធា អានន្ទ បរិសាតិ ។ អថខោ អាយស្មតោ មហាមោគ្គល្លានស្ស ឯតទហោសិ កំ នុ(១) ខោ ភគវា បុគ្គលំ សន្ធាយ

១ ម. ម. ចូឡ ១ ៤ ១. កំ នុ ។ ម. កិំ នុ ។



កាលព្រះអានន្ទ ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះមានព្រះភាគក៏គង់ស្ងៀម ។ កាលមជ្ឈិមយាម កន្លងហើយ ព្រះអានន្ទដ៏មានអាយុក៏ក្រោកចាកអាសនៈ ធ្វើចីវរឆៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះព្រះមានព្រះភាគ ហើយក្រាបបង្គំទូលសេចក្តីនុះ ចំពោះព្រះមានព្រះភាគ អស់វារៈពីរដងទៀតថា បពិត្រព្រះអង្គដ៏ចំរើន វេលាមជ្ឈិមយាម កន្លងហើយ ភិក្ខុសង្ឃអង្គុយយូរហើយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ សំដែងបាតិមោក្ខដល់ពួកភិក្ខុទាំងឡាយ ។ ព្រះមានព្រះភាគ ក៏ទ្រង់គង់ស្ងៀម អស់វារៈពីរដង ។ លុះវេលាបច្ឆិមយាម កន្លងហើយ ពន្លឺក្រហមដូចជាមាត់ស្រស់ ក្នុងវេលាដែលអរុណរះឡើង ព្រះអានន្ទដ៏មានអាយុ ក៏ក្រោកចាកអាសនៈធ្វើចីវរឆៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះព្រះមានព្រះភាគ ហើយក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះមានព្រះភាគ ជាគំរប់បីដងទៀតថា បពិត្រព្រះអង្គដ៏ចំរើន វេលានេះបច្ឆិមយាមកន្លងហើយ អរុណរះហើយ ពន្លឺក្រហមដូចមាត់ស្រស់ហើយ ភិក្ខុសង្ឃអង្គុយអស់យូរហើយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ សំដែងបាតិមោក្ខដល់ពួកភិក្ខុ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ បរិស័ទមិនបរិសុទ្ធទេ ។ គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុត្រិះរិះថា ព្រះមានព្រះភាគទ្រង់សំដៅបុគ្គលណាហ្ន៎

ឯវមាហ អបរិសុទ្ធា អានន្ទ បរិសាតិ ។ អថខោ អាយស្មា មហាមោគ្គល្លានោ សព្វាវន្តំ ភិក្ខុសង្ឃំ ចេតសា ចេតោ បរិច្ច មនសាកាសិ ។ អទ្ទសា ខោ អាយស្មា មហាមោគ្គល្លានោ តំ បុគ្គលំ ទុស្សីលំ បាបធម្មំ អសុចិសង្កស្សរសមាចារំ បដិច្ឆន្នកម្មន្តំ អស្សមណំ សមណបដិញ្ញំ អព្រហ្មចារឹ ព្រហ្មចារិបដិញ្ញំ អន្តោបូតឹ អវស្សុតំ កសម្ពុកជាតំ[1] មជ្ឈេ ភិក្ខុសង្ឃស្ស និសិន្នំ ទិស្វាន ឧដ្ឋាយាសនា យេន សោ បុគ្គលោ តេនុបសង្កមិ ឧបសង្កមិត្វា តំ បុគ្គលំ ឯតទវោច ឧដ្ឋេហាវុសោ ទិដ្ឋោសិ ភគវតា នត្ថិ តេ ភិក្ខូហិ សទ្ធឹ សំវាសោតិ ។ អថខោ សោ បុគ្គលោ តុណ្ហី អហោសិ ។ ទុតិយម្បិ ខោ សោ អាយស្មា មហាមោគ្គល្លានោ តំ បុគ្គលំ ឯតទវោច ឧដ្ឋេហាវុសោ ទិដ្ឋោសិ ភគវតា នត្ថិ តេ ភិក្ខូហិ សទ្ធឹ សំវាសោតិ ។ ទុតិយម្បិ ខោ សោ បុគ្គលោ តុណ្ហី អហោសិ ។ តតិយម្បិ ខោ អាយស្មា មហាមោគ្គល្លានោ តំ បុគ្គលំ ឯតទវោច ឧដ្ឋេហាវុសោ ទិដ្ឋោសិ ភគវតា

---

១. ម. កសម្ពុជាតំ ។



បានជាទ្រង់ត្រាស់ថា ម្នាលអានន្ទ បរិស័ទមិនបរិសុទ្ធយ៉ាងនេះ ។ ទើបព្រះមហាមោគ្គល្លានដ៏មានអាយុ ស្ទង់មើលចិត្ត ដោយចិត្តរបស់លោក ហើយធ្វើទុកក្នុងចិត្តចំពោះភិក្ខុសង្ឃទាំងអស់ ។ លុះព្រះមហាមោគ្គល្លានដ៏មានអាយុ បានឃើញបុគ្គលទ្រុស្តសីលនោះ មានធម៌លាមក មានមារយាទមិនស្អាតគួរឲ្យរង្កៀស មានអំពើលាក់បិទបាំងទុក មិនមែនជាសមណៈ តែប្តេជ្ញាថា ខ្លួនជាសមណៈ មិនប្រព្រឹត្តធម៌ដ៏ប្រសើរ តែប្តេជ្ញាថា ខ្លួនជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ស្អុយខាងក្នុង មានចិត្តជោគជាំដោយរាគៈ កខ្វក់ដូចសម្រាម អង្គុយក្នុងកណ្តាលភិក្ខុសង្ឃ ។ លុះឃើញហើយក្រោកចាកអាសនៈ ចូលទៅរកបុគ្គលនោះ លុះចូលទៅដល់ហើយ ក៏និយាយនឹងបុគ្គលនោះថា នែអាវុសោ អ្នកចូរក្រោកចេញ ដ្បិតព្រះមានព្រះភាគ ទ្រង់ឃើញអ្នកហើយ អ្នកលែងបាននៅរួមជាមួយនឹងពួកភិក្ខុហើយ ។ លំដាប់នោះ បុគ្គលនោះក៏នៅស្ងៀម ។ ព្រះមហាមោគ្គល្លានដ៏មានអាយុនោះ បាននិយាយនឹងបុគ្គលនោះ ជាគំរប់ពីរដងថា នែអាវុសោ អ្នកចូរក្រោកចេញ ដ្បិតព្រះមានព្រះភាគ ទ្រង់ឃើញអ្នកហើយ អ្នកលែងបាននៅរួមជាមួយនឹងពួកភិក្ខុហើយ ។ បុគ្គលនោះ នៅស្ងៀមអស់វារៈពីរដងទៀត ។ ព្រះមហាមោគ្គល្លានដ៏មានអាយុ បាននិយាយនឹងបុគ្គលនោះ ជាគំរប់បីដងថា នែអាវុសោ អ្នកចូរក្រោកចេញ ដ្បិតព្រះមានព្រះភាគទ្រង់ឃើញអ្នកហើយ

នត្ថិ តេ ភិក្ខូហិ សទ្ធឹ សំវាសោតិ ។ តតិយម្បិ ខោ សោ បុគ្គលោ តុណ្ហី អហោសិ ។ អថខោ អាយស្មា មហាមោគ្គល្លានោ តំ បុគ្គលំ ពាហាយំ គហេត្វា ពហិ-ទ្វារកោដ្ឋកា និក្ខាមេត្វា(១) សូចិឃដិកំ ទត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ ឯតទវោច និក្ខាមិតោ ភន្តេ សោ បុគ្គលោ មយា បរិសុទ្ធា បរិសា ឧទ្ទិសតុ ភន្តេ ភគវា ភិក្ខូនំ បាតិមោក្ខន្តិ ។ អច្ឆរិយំ មោគ្គល្លាន អព្ភុតំ មោគ្គល្លាន យាវ ពាហាគហណាបិ នាម សោ មោឃបុរិសោ អាគមិស្សតីតិ ។ អថខោ ភគវា ភិក្ខូ អាមន្តេសិ ន ទានាហំ ភិក្ខវេ ឥតោ បរំ ឧបោសថំ ករិស្សាមិ បាតិមោក្ខំ ឧទ្ទិសិស្សាមិ តុម្ហេ-យេវ(២) ភិក្ខវេ ឥតោ បរំ ឧបោសថំ ករេយ្យាថ បាតិមោក្ខំ ឧទ្ទិសេយ្យាថ ។ អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ តថាគតោ អបរិសុទ្ធាយ បរិសាយ ឧបោសថំ ករេយ្យ បាតិមោក្ខំ ឧទ្ទិសេយ្យាតិ ។

១ ម. និក្ខមិត្វា ។ ២ ឱ. ម. តុម្ហេវ ទានិ ។



អ្នកលែងបានសំវាសជាមួយនឹងពួកភិក្ខុហើយ ។ បុគ្គលនោះក៏នៅស្ងៀម អស់វារៈជាគំរប់បីដង ។ គ្រានោះឯង ព្រះមហាមោគ្គល្លាន ដ៏មានអាយុ ចាប់ដើមដៃបុគ្គលនោះ ទាញចេញទៅខាងក្រៅស៊ុំទ្វារ ហើយសិកខ្ទាស់គន្លឹះនឹងរនុកទ្វារ រួចចូលមកកាន់ព្រះមានព្រះភាគវិញ លុះចូលទៅដល់ហើយ បានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន បុគ្គលនោះ ខ្ញុំព្រះអង្គបានបណ្តេញ ឲ្យចេញទៅហើយ ឥឡូវនេះ បរិស័ទបរិសុទ្ធហើយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទ្រង់សំដែងបាតិមោក្ខ ដល់ពួកភិក្ខុឲ្យបាន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលមោគ្គល្លាន គួរអស្ចារ្យណាស់ ម្នាលមោគ្គល្លាន ចំឡែកណាស់ មោឃបុរសនោះ មិនសមបើនឹងក្រញាញនៅចង្អេត ទាល់តែគេចាប់ទាញដៃសោះ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតនឹងលែងធ្វើឧបោសថ សំដែងបាតិមោក្ខ តាំងពីកាលនេះ ម្នាលភិក្ខុទាំងឡាយ លំដាប់អំពីនេះ អ្នកទាំងឡាយ ធ្វើឧបោសថសំដែងបាតិមោក្ខចុះ ។ ម្នាលភិក្ខុទាំងឡាយ តថាគត ធ្វើឧបោសថ សំដែងបាតិមោក្ខ ដល់បរិស័ទដែលមិនបរិសុទ្ធ ដោយហេតុណា ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យទេ ។

[១០៧] អដ្ឋិមេ ភិក្ខវេ មហាសមុទ្ទេ អច្ឆរិយា អព្ភុតធម្មា(១) យេ ទិស្វា ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ។ កតមេ អដ្ឋ ។

មហាសមុទ្ទោ ភិក្ខវេ អនុបុព្វនិន្នោ អនុបុព្វពោណោ អនុបុព្វបព្ភារោ នាយតកេនេវ បបាតោ យំ(២) ភិក្ខវេ មហាសមុទ្ទោ អនុបុព្វនិន្នោ អនុបុព្វពោណោ អនុបុព្វបព្ភារោ នាយតកេនេវ បបាតោ អយំ(៣) ភិក្ខវេ មហាសមុទ្ទេ បឋមោ អច្ឆរិយោ អព្ភុតធម្មោ យំ ទិ-ស្វា ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ។

បុន ចបរំ ភិក្ខវេ មហាសមុទ្ទោ ឋិតធម្មោ វេលំ នាតិវត្តតិ(៤) យំ ភិក្ខវេ មហាសមុទ្ទោ ឋិតធម្មោ វេលំ នាតិវត្តតិ អយម្បិ ភិក្ខវេ មហាសមុទ្ទេ ទុតិយោ អច្ឆរិយោ អព្ភុតធម្មោ យំ ទិស្វា ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ។

---

១ ម. អព្ភុតា ធម្មា ។ ២ ម. យម្បិ ។ ៣ ម. អយម្បិ ។ ៤ ម. នាតិវត្តតិ ។



(១០៧) ម្នាលភិក្ខុទាំងឡាយ ក្នុងមហាសមុទ្រ មានធម្មតាដែលអស្ចារ្យ កើតមិនធ្លាប់មាន ៨ យ៉ាងនេះ ដែលពួកអសុរឃើញហើយត្រេកអរ ក្នុងមហាសមុទ្រ ។ ធម្មតាអស្ចារ្យ ៨ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រមានទំនាបដោយលំដាប់ មានទីជម្រាលដោយលំដាប់ មានទីជ្រេតដោយលំដាប់ មិនមែនចោតជ្រៅស្រឡូន ទៅតែម្ដង ដូចជាអណ្ដូងទេ ម្នាលភិក្ខុទាំងឡាយ ឯមហាសមុទ្រ ដែលមានទំនាបដោយលំដាប់ មានទីជម្រាលដោយលំដាប់ មានទីជ្រេតដោយលំដាប់ មិនមែនចោតជ្រៅស្រឡូន ទៅតែម្ដង ដូចជាអណ្ដូងដោយធម្មតាណា ម្នាលភិក្ខុទាំងឡាយ នេះជាធម្មតា អស្ចារ្យ កើតមិនធ្លាប់មានទី ១ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយ ត្រេកអរ ក្នុងមហាសមុទ្រ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត មហាសមុទ្រមានទឹកតាំងនៅនឹងជាធម្មតា មិនដែលឡើង ឬ ជោរហួសច្រាំងទៅឡើយទេ ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រ ដែលមានទឹកតាំងនៅនឹងជាធម្មតា មិនដែលឡើង ឬជោរហួសច្រាំងទៅបាន ដោយធម្មតាណា ម្នាលភិក្ខុ ទាំងនេះជាធម្មតា អស្ចារ្យ កើតមិនធ្លាប់មាន ទី ២ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយ ត្រេកអរ ក្នុងមហាសមុទ្រ ។

បុន ចបរំ ភិក្ខវេ មហាសមុទ្ទោ ន មតេន កុណបេន សំវសតិ យំ ហោតិ មហាសមុទ្ទេ មតំ កុណបំ តំ ខិប្បមេវ តីរំ វាហេតិ ថលំ ឧស្សារេតិ[១] យម្បិ ភិក្ខវេ មហាសមុទ្ទោ ន មតេន កុណបេន សំវសតិ យំ មហាសមុទ្ទេ មតំ កុណបំ តំ ខិប្បមេវ តីរំ វាហេតិ ថលំ ឧស្សារេតិ អយម្បិ ភិក្ខវេ មហាសមុទ្ទេ ចតុត្ថោ អច្ឆរិយោ អព្ភុតធម្មោ យំ ទិស្វា ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ។

បុន ចបរំ ភិក្ខវេ យា កាចិ មហានទិយោ សេយ្យថីទំ គង្គា យមុនា អចិរវតី សរភូ មហី តា មហាសមុទ្ទំ បត្វា ជហន្តិ បុរិមានិ នាមគោត្តានិ មហាសមុទ្ទោត្វេវ សង្ខ្យំ គច្ឆន្តិ ។ យំ ភិក្ខវេ យា កាចិ មហានទិយោ សេយ្យថីទំ គង្គា យមុនា អចិរវតី សរភូ មហី តា មហាសមុទ្ទំ បត្វា ជហន្តិ បុរិមានិ នាមគោត្តានិ មហាសមុទ្ទោត្វេវ សង្ខ្យំ គច្ឆន្តិ អយម្បិ ភិក្ខវេ មហាសមុទ្ទេ

១ ឱ.ម. ថលេ ឧស្សរេតិ ។





ម្នាលភិក្ខុទាំងឡាយ មួយទៀត មហាសមុទ្រមិនដែលមានសាកសព ស្លាប់នៅរួមបានទេ បើសាកសពស្លាប់ណា មានក្នុងមហាសមុទ្រ រលក តែងបក់សាកសពស្លាប់នោះ ទៅកាន់ត្រើយ ច្រាំងឡើងទៅ លើគោក មួយរំពេច ម្នាលភិក្ខុទាំងឡាយ ឯមហាសមុទ្រមិនដែលមានសាកសព ស្លាប់នៅរួមបាន បើសាកសពស្លាប់ណា មានក្នុងមហាសមុទ្រ រលក តែងបក់សាកសពស្លាប់នោះ ទៅកាន់ត្រើយ ច្រាំងឡើងទៅលើគោក មួយរំពេច ដោយធម្មតាណា ម្នាលភិក្ខុទាំងឡាយ នេះជាធម្មតា អស្ចារ្យ ចំឡែកទី ៤ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយ តែង រីករាយ ក្នុងមហាសមុទ្រ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ទន្លេធំ ៗ ទាំងឡាយណាមួយ ដូច ទន្លេគង្គា យមុនា អចិរវតី សរភូ មហី ទន្លេទាំងនោះ កាលបើហូរទៅ ដល់មហាសមុទ្រហើយ តែងលះបង់នាមនិងគោត្រដើម ( របស់ខ្លួន ) ដល់នូវការរាប់ថា មហាសមុទ្រតែម្យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ទន្លេធំ ៗ ទាំងឡាយណាមួយ ដូចជាទន្លេគង្គា យមុនា អចិរវតី សរភូ មហី ទន្លេទាំងនោះ កាលបើហូរទៅដល់មហាសមុទ្រហើយ តែងលះបង់នាម និងគោត្រដើម (របស់ខ្លួន) ដល់នូវការរាប់ថា មហាសមុទ្រ តែម្យ៉ាងដោយធម្មតាណា ម្នាលភិក្ខុទាំងឡាយ នេះជាធម្មតា អស្ចារ្យ

ចតុត្ថោ អច្ឆរិយោ អព្ភុតធម្មោ យំ ទិស្វា ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ។

បុន ចបរំ ភិក្ខវេ យា[១] លោកេ សវន្តិយោ មហាសមុទ្ទំ អប្បេន្តិ យា ច អន្តលិក្ខា ធារា បបតន្តិ ន តេន មហាសមុទ្ទស្ស ឩនត្តំ វា បូរត្តំ វា បញ្ញាយតិ យម្បិ ភិក្ខវេ យា ច លោកេ សវន្តិយោ មហាសមុទ្ទំ អប្បេន្តិ យា ច អន្តលិក្ខា ធារា បបតន្តិ ន តេន មហាសមុទ្ទស្ស ឩនត្តំ វា បូរត្តំ វា បញ្ញាយតិ អយម្បិ ភិក្ខវេ មហាសមុទ្ទេ បញ្ចមោ អច្ឆរិយោ អព្ភុតធម្មោ យំ ទិស្វា ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ។

បុន ចបរំ ភិក្ខវេ មហាសមុទ្ទោ ឯករសោ លោណរសោ យម្បិ ភិក្ខវេ មហាសមុទ្ទោ ឯករសោ លោណរសោ អយម្បិ ភិក្ខវេ មហាសមុទ្ទេ ឆដ្ឋោ អច្ឆរិយោ អព្ភុតធម្មោ យំ ទិស្វា ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ។

---

១ ម.ឆ. យា ច ។ ក្នុងទី យា កាពីពី ក ឈាយ ទីស្យូម ។



កើតចំឡែក ទី ៤ ក្នុងមហាសមុទ្រ ដែលពួកអសុរាឃើញហើយ តែងរីករាយ ក្នុងមហាសមុទ្រ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ទឹកទន្លេទាំងឡាយណាមួយ ក្នុងលោក ដែលហូរតាម ទៅកាន់មហាសមុទ្រក្តី ធារទឹកភ្លៀងទាំងឡាយណា ដែលធ្លាក់ចុះមកពីអាកាសក្តី មហាសមុទ្រ ក៏មិនប្រាកដជាស្រកឬពេញ ដោយទឹកទន្លេនិងធារទឹកភ្លៀងនោះឡើយ ម្នាលភិក្ខុទាំងឡាយ ទឹកទន្លេទាំងឡាយណាមួយ ក្នុងលោក ដែលហូរទៅកាន់មហាសមុទ្រក្តី ធារទឹកភ្លៀងទាំងឡាយណា ដែលហូរធ្លាក់ចុះមកពីអាកាសក្តី មហាសមុទ្រក៏មិនប្រាកដជាស្រកឬពេញ ដោយទឹកទន្លេនិងធារទឹកភ្លៀងទាំងនោះ ដោយហេតុណា ម្នាលភិក្ខុទាំងឡាយ នេះជាធម្មតា អស្ចារ្យ កើតចំឡែកទី ៥ ក្នុងមហាសមុទ្រ ដែលពួកអសុរាឃើញហើយ តែងរីករាយ ក្នុងមហាសមុទ្រ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត មហាសមុទ្រមានរសតែមួយ គឺរសប្រៃ ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រមានរសតែមួយគឺរសប្រៃ ដោយហេតុណា ម្នាលភិក្ខុទាំងឡាយ នេះជាធម្មតា អស្ចារ្យ កើតចំឡែកទី ៦ ក្នុងមហាសមុទ្រ ដែលពួកអសុរាឃើញហើយៗ តែងរីករាយ ក្នុងមហាសមុទ្រ ។

បុន ចបរំ ភិក្ខវេ មហាសមុទ្ទោ ពហុរតនោ អនេករតនោ តត្រិមានិ រតនានិ សេយ្យថីទំ មុត្តា មណិ វេឡុរិយោ សង្ខោ សិលា បវាឡំ រជតំ ជាតរូបំ លោហិតង្កោ មសារគល្លោ[១] យំ ភិក្ខវេ មហាសមុទ្ទោ ពហុរតនោ អនេករតនោ តត្រិមានិ រតនានិ សេយ្យថីទំ មុត្តា មណិ វេឡុរិយោ សង្ខោ សិលា បវាឡំ រជតំ ជាតរូបំ លោហិតង្កោ មសារគល្លោ អយម្បិ ភិក្ខវេ មហាសមុទ្ទេ សត្តមោ អច្ឆរិយោ អព្ភុតធម្មោ យំ ទិស្វា ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ។

បុន ចបរំ ភិក្ខវេ មហាសមុទ្ទោ មហតំ ភូតានំ អាវាសោ តត្រិមេ ភូតា តិមិ តិមិង្គលោ តិមិតិមិង្គលោ[២] អសុរា នាគា គន្ធព្វា សន្តិ មហាសមុទ្ទេ យោជនសតិកាបិ អត្តភាវា ទ្វិយោជនសតិកាបិ អត្តភាវា តិយោជនសតិកាបិ អត្តភាវា ចតុយោជនសតិកាបិ អត្តភាវា

១ ម. មសារគល្លំ ។ ២ តិមិរពិង្គលោ ។ ថៃយ៉ាងនេះ បុគ្គលគ្គ តិមិតិមិង្គលោ មហាតិមិង្គលោតិ បាឋា ទិស្សន្តិ ។ អដ្ឋកថាយំ បន តិមិ តិមិង្គលា តិមិតិមិង្គលាតិ ទិស្សន្តិ ។



ម្នាលភិក្ខុទាំងឡាយ មួយទៀត មហាសមុទ្រ មានរតនៈច្រើនយ៉ាង មិនមែនមានរតនៈតែមួយប្រការទេ ឯរតនៈទាំងនេះដែលមាន ក្នុងមហាសមុទ្រនោះ គឺកែវមុក្តា កែវមណី កែវពិទូរ្យ ស័ង្ខ សិលា កែវប្រពាឡ ប្រាក់ មាស កែវក្រហម ( ត្បូងទទឹម ) និងកែវមរកត ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រ មានរតនៈច្រើនយ៉ាង មិនមែនមានរតនៈតែមួយប្រការទេ ឯរតនៈទាំងនេះ ដែលមាននៅ ក្នុងមហាសមុទ្រនោះគឺ កែវមុក្តា កែវមណី កែវពិទូរ្យ ស័ង្ខ សិលា កែវប្រពាឡ ប្រាក់ មាស កែវក្រហម និងកែវមរកត ដោយប្រការណា ម្នាលភិក្ខុទាំងឡាយ នេះជាធម្មតា អស្ចារ្យ ដែលចំឡែក ទី ៧ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយ តែងរីករាយ ក្នុងមហាសមុទ្រ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត មហាសមុទ្រជាទីនៅអាស្រ័យនៃពួកសត្វធំ ៗ ជាច្រើន ពួកសត្វធំ ៗ ទាំងនេះ ក្នុងមហាសមុទ្រនោះគឺ ត្រីឈ្មោះតិមិ ឈ្មោះតិមិង្គល ឈ្មោះតិមិរមិង្គល និងពួកអសុរ នាគ គន្ធព្វ ដែលមានអត្តភាព ១ រយយោជន៍ខ្លះ មានអត្តភាព ២ រយយោជន៍ខ្លះ មានអត្តភាព ៣ រយយោជន៍ខ្លះ មានអត្តភាព ៤ រយយោជន៍ខ្លះ

បញ្ចយោជនសតិកាបិ អត្តភាវា យម្បិ ភិក្ខវេ មហា-
សមុទ្ទោ មហតំ ភូតានំ អាវាសោ តត្រិមេ ភូតា តិមិ
តិមិង្គលោ តិមិរបិង្គលោ អសុរា នាគា គន្ធព្វា សន្តិ
មហាសមុទ្ទេ យោជនសតិកាបិ អត្តភាវា ទ្វិយោជន
សតិកាបិ អត្តភាវា តិយោជនសតិកាបិ អត្តភាវា
ចតុយោជនសតិកាបិ អត្តភាវា បញ្ចយោជនសតិកាបិ
អត្តភាវា អយម្បិ ភិក្ខវេ មហាសមុទ្ទេ អដ្ឋមោ អច្ឆរិ-
យោ អព្ភុតោ ធម្មោ យំ ទិស្វា ទិស្វា អសុរា មហាស-
មុទ្ទេ អភិរមន្តិ ។ ឥមេ ខោ ភិក្ខវេ មហាសមុទ្ទេ អដ្ឋ
អច្ឆរិយា អព្ភុតា ធម្មា យេ ទិស្វា ទិស្វា អសុរា មហា-
សមុទ្ទេ អភិរមន្តិ ។

[១១៤] ឯវមេវ ខោ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ
អដ្ឋ អច្ឆរិយា អព្ភុតា ធម្មា យេ ទិស្វា ទិស្វា ភិក្ខូ
ឥមស្មឹ ធម្មវិនយេ អភិរមន្តិ ។ កតមេ អដ្ឋ ។



មានអត្តភាព ៥ រយយោជន៍ខ្លះ ក៏មាននៅ ក្នុងមហាសមុទ្រ ម្នាលភិក្ខុ
ទាំងឡាយ មហាសមុទ្រជាទីនៅអាស្រ័យ នៃពួកសត្វធំ ៗ ជាច្រើន
ពួកសត្វធំទាំងនេះ ក្នុងមហាសមុទ្រនោះ គឺត្រីឈ្មោះតិមិ ឈ្មោះតិមិង្គល
ឈ្មោះតិមិរបិង្គលនិងពួកអសុរនាគ គន្ធព្វ ដែលមានអត្តភាព ១ រយ
យោជន៍ខ្លះ មានអត្តភាព ២ រយយោជន៍ខ្លះ មានអត្តភាព ៣ រយយោជន៍
ខ្លះ មានអត្តភាព ៤ រយយោជន៍ខ្លះ មានអត្តភាព ៥ រយយោជន៍ខ្លះ
ក៏មាននៅ ក្នុងមហាសមុទ្រ ដោយធម្មការណ៍ ម្នាលភិក្ខុទាំងឡាយ នេះ
ជាធម្ម អស្ចារ្យ ដែលកើតចំឡែក ទី ៨ ក្នុងមហាសមុទ្រ ដែលពួក
អសុរឃើញហើយ ក៏ត្រេកអរក្នុងមហាសមុទ្រ ។ ម្នាលភិក្ខុទាំងឡាយ
ធម្ម អស្ចារ្យ ដែលកើតចំឡែកទាំង៨ ប្រការនេះ ក៏មាន ក្នុងមហា-
សមុទ្រ ដែលពួកអសុរឃើញហើយ ក៏ត្រេកអរ ក្នុងមហាសមុទ្រ ។

[១១៤] ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យនេះ មានសភាពជាធម៌
អស្ចារ្យ ដែលកើតចំឡែក ៨ ប្រការ ដែលភិក្ខុទាំងឡាយ ឃើញហើយ
ក៏ត្រេកអរ ក្នុងធម្មវិន័យនេះ ដូចមហាសមុទ្រដែរ ។
សភាពអស្ចារ្យ ដែលកើតចំឡែក ៨ ប្រការ តើដូចម្ដេច ។

សេយ្យថាបិ ភិក្ខវេ មហាសមុទ្ទោ អនុបុព្វនិន្នោ អនុបុព្វបោណោ អនុបុព្វបព្ភារោ នាយតកេនេវ បបាតោ ឯវមេវ ខោ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ អនុបុព្វសិក្ខា អនុបុព្វកិរិយា អនុបុព្វប្បដិបទា នាយតកេនេវ អញ្ញាបដិវេធោ យំ[១] ភិក្ខវេ ឥមស្មឹ ធម្មវិនយេ អនុបុព្វសិក្ខា អនុបុព្វកិរិយា អនុបុព្វប្បដិបទា នាយតកេនេវ អញ្ញាបដិវេធោ អយំ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ បឋមោ អច្ឆរិយោ អព្ភុតធម្មោ យំ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តិ ។

សេយ្យថាបិ ភិក្ខវេ មហាសមុទ្ទោ ឋិតធម្មោ វេលំ នាតិវត្តតិ ឯវមេវ ខោ ភិក្ខវេ យំ មយា សាវកានំ សិក្ខាបទំ បញ្ញត្តំ តំ មម សាវកា ជីវិតហេតុបិ នាតិក្កមន្តិ យម្បិ ភិក្ខវេ មម សាវកានំ សិក្ខាបទំ បញ្ញត្តំ តំ មម សាវកា ជីវិតហេតុបិ នាតិក្កមន្តិ

១ ឱ. យម្បិ ។



ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យនេះ មានការសិក្សាដោយលំដាប់ មានកិច្ចដែលត្រូវធ្វើដោយលំដាប់ មានសេចក្តីប្រតិបត្តិដោយលំដាប់ មិនមែនបានត្រាស់ដឹងអរហត្តផល តែម្តងទេ ដូចជាមហាសមុទ្រ ដែលមានទីទំនាបដោយលំដាប់ មានទីជម្រាលដោយលំដាប់ មានទីជ្រៅដោយលំដាប់ មិនមែនជាការជ្រៅស្រឡូន ឡើងតែម្តង ដូចអណ្តូងទេ ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យនេះ តែងមានការសិក្សាដោយលំដាប់ មានកិច្ចដែលត្រូវធ្វើដោយលំដាប់ មានសេចក្តីប្រតិបត្តិដោយលំដាប់ មិនមែនបានត្រាស់ដឹងអរហត្តផល តែម្តង- ដោយសារហេតុណា ម្នាលភិក្ខុទាំងឡាយ នេះជាសភាព អស្ចារ្យ ដែលកើតចំឡែកទី ១ ក្នុងធម្មវិន័យនេះ ដែលភិក្ខុទាំងឡាយ ឃើញហើយ តែងត្រេកអរ ក្នុងធម្មវិន័យនេះ ។

ម្នាលភិក្ខុទាំងឡាយ សិក្ខាបទណា ដែលតថាគត បានបញ្ញត្ត ដល់សាវ័កទាំងឡាយហើយ ពួកសាវ័កនៃតថាគត សូម្បីមានហេតុដល់ជីវិត ក៏មិនហ៊ានប្រព្រឹត្តកន្លងសិក្ខាបទនោះឡើយ ដូចមហាសមុទ្រ ដែលមានទឹកនៅនឹង ជាធម្មតា មិនដែលឡើង ឬ ជោរហួសច្រាំងទៅបាន ដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ សិក្ខាបទណា ដែលតថាគត បានបញ្ញត្ត ដល់សាវ័កទាំងឡាយហើយ ពួកសាវ័កនៃតថាគត សូម្បីមានហេតុដល់ជីវិត ក៏មិនហ៊ានប្រព្រឹត្តកន្លងសិក្ខាបទនោះ ដោយសារហេតុណា

អយម្បិ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ ឆដ្ឋោ អច្ឆរិយោ អព្ភូតធម្មោ យំ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តិ ។

សេយ្យថាបិ ភិក្ខវេ មហាសមុទ្ទោ ន មតេន កុណបេន សំវសតិ យំ ហោតិ មហាសមុទ្ទេ មតំ កុណបំ តំ ខិប្បមេវ តីរំ វាហេតិ ថលំ ឧស្សារេតិ ឯវមេវ ខោ ភិក្ខវេ យោ សោ បុគ្គលោ ទុស្សីលោ បាបធម្មោ អសុចិសង្កស្សរសមាចារោ បដិច្ឆន្នកម្មន្តោ អស្សមណោ សមណបដិញ្ញោ អព្រហ្មចារី ព្រហ្មចារិបដិញ្ញោ អន្តោបូតិ អវស្សុតោ កសម្ពុជាតោ ន តេន សង្ឃោ សំវសតិ អថខោ[១] ខិប្បមេវ សន្និបតិត្វា ឧក្ខិបតិ កិញ្ចាបិ សោ ហោតិ មជ្ឈេ ភិក្ខុសង្ឃស្ស និសិន្នោ អថខោ សោ អារកា ច សង្ឃម្ហា សង្ឃោ ច តេន យម្បិ ភិក្ខវេ យោ សោ បុគ្គលោ ទុស្សីលោ បាបធម្មោ អសុចិសង្កស្សរសមាចារោ បដិច្ឆន្នកម្មន្តោ អស្សមណោ សមណបដិញ្ញោ អព្រហ្មចារី ព្រហ្មចារិបដិញ្ញោ អន្តោបូតិ អវស្សុតោ កសម្ពុជាតោ

១ ឱ. ម. ខិប្បមេវ នំ ។



នេះជាសភាព អស្ចារ្យ ដែលជាគំរប់ទី ៦ ក្នុងធម្មវិន័យនេះ ដែលពួកភិក្ខុឃើញៗហើយ តែងត្រេកអរ ក្នុងធម្មវិន័យនេះ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលណា ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ មានអាចារៈមិនស្អាតគួរឲ្យរង្កៀស មានអំពើអាក្រក់បិទបាំងទុក មិនមែនជាសមណៈ តែប្តេជ្ញាខ្លួនថាជាសមណៈ មិនមែនជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ តែប្តេជ្ញាខ្លួនថាជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ស្អុយខាងក្នុង មានចិត្តជោគជាំដោយរាគៈ កខ្វក់ដូចសំរាម សង្ឃមិននៅរួមជាមួយបុគ្គលនោះទេ សង្ឃប្រជុំគ្នាលើកបុគ្គលនោះចេញមួយរំពេច បុគ្គលនោះបើទុកជាអង្គុយនៅក្នុងកណ្តាលភិក្ខុសង្ឃក៏ពិតមែន ប៉ុន្តែបុគ្គលនោះ ឈ្មោះថា នៅឆ្ងាយអំពីសង្ឃ ចំណែកសង្ឃក៏ឈ្មោះថា នៅឆ្ងាយអំពីបុគ្គលនោះ ដូចមហាសមុទ្រមិននៅរួមជាមួយសាកសពសត្វស្លាប់ ។ បើសាកសពសត្វស្លាប់ណាមួយ ដែលមានក្នុងមហាសមុទ្រ មហាសមុទ្រតែងបណ្តែតសាកសពនោះ ទៅកាន់ត្រើយ ដាក់ឡើងលើគោកមួយរំពេច ដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ បុគ្គលណា ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ មានអាចារៈមិនស្អាត គួរឲ្យរង្កៀស បិទបាំងនូវអំពើអាក្រក់ទុក មិនមែនជាសមណៈ តែប្តេជ្ញាខ្លួនថាជាសមណៈ មិនមែនជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ តែប្តេជ្ញាខ្លួនថាជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ស្អុយខាងក្នុង មានចិត្តជោគជាំដោយរាគៈ កខ្វក់ដូចសំរាម

ន តេន សង្ឃោ សំវសតិ អថខោ ខិប្បមេវ សន្និបតិត្វា ឧក្ខិបតិ កិញ្ចាបិ សោ ហោតិ មជ្ឈេ ភិក្ខុសង្ឃស្ស និសិន្នោ អថខោ សោ អារកាវ សង្ឃម្ហា សង្ឃោ ច តេន អយម្បិ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ តតិយោ អច្ឆរិយោ អព្ភុតធម្មោ យំ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តិ ។

សេយ្យថាបិ ភិក្ខវេ យា កាចិ មហានទិយោ សេយ្យថីទំ គង្គា យមុនា អចិរវតី សរភូ មហី តា មហាសមុទ្ទំ បត្វា ជហន្តិ បុរិមានិ នាមគោត្តានិ មហាសមុទ្ទោត្វេវ សង្ខ្យំ គច្ឆន្តិ ឯវមេវ ខោ ភិក្ខវេ ចត្តារោមេ វណ្ណា ខត្តិយា ព្រាហ្មណា វេស្សា សុទ្ទា តេ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជិត្វា ជហន្តិ បុរិមានិ នាមគោត្តានិ សមណា សក្យបុត្តិយាត្វេវ សង្ខ្យំ គច្ឆន្តិ យម្បិ ភិក្ខវេ ចត្តារោ វណ្ណា ខត្តិយា ព្រាហ្មណា វេស្សា សុទ្ទា តេ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជិត្វា ជហន្តិ បុរិមានិ នាមគោត្តានិ សមណា សក្យបុត្តិយាត្វេវ សង្ខ្យំ គច្ឆន្តិ



សង្ឃមិនដែលនៅរួមជាមួយបុគ្គលនោះ សង្ឃតែងប្រជុំគ្នា នាំយកបុគ្គលនោះចេញមួយរំពេច បុគ្គលនោះ បើទុកជាអង្គុយនៅ ក្នុងកណ្តាលភិក្ខុសង្ឃក៏ពិតមែន ប៉ុន្តែបុគ្គលនោះ ឈ្មោះថា នៅឆ្ងាយអំពីសង្ឃ ចំណែកខាងសង្ឃក៏ឈ្មោះថា នៅឆ្ងាយអំពីបុគ្គលនោះ ដោយសភាពណា ម្នាលភិក្ខុទាំងឡាយ នេះជាសភាព អស្ចារ្យ ដែលកើតចំឡែកទី ៣ ក្នុងធម្មវិន័យនេះ ដែលភិក្ខុទាំងឡាយ ឃើញហើយ តែងត្រេកអរ ក្នុងធម្មវិន័យនេះ ។

ម្នាលភិក្ខុទាំងឡាយ វណ្ណៈ ៤ ពួកនេះ គឺខត្តិយៈ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ វណ្ណៈទាំងនោះ ចេញចាកផ្ទះមកបួស ក្នុងធម្មវិន័យ ដែលតថាគតសំដែងហើយ រមែងលះបង់នាមនឹងគោត្រដើម (របស់ខ្លួន) ហើយដល់នូវការរាប់ថាជាសមណសក្យបុត្តិយ៍ តែម្យ៉ាង ដូចមហានទី ៗ ទាំងឡាយគឺ ទន្លេគង្គា យមុនា អចិរវតី សរភូ មហី ទន្លេទាំងនោះកាលបើហូរទៅ ដល់មហាសមុទ្រហើយ តែងលះបង់នាមនឹងគោត្រដើម (របស់ខ្លួន) ហើយដល់នូវការរាប់ថាជាមហាសមុទ្រ តែម្យ៉ាង ដូច្នេះឯង ម្នាលភិក្ខុទាំងឡាយ វណ្ណៈទាំង ៤ ពួកគឺ ខត្តិយៈ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ វណ្ណៈទាំងនោះ ចេញចាកផ្ទះមកបួស ក្នុងធម្មវិន័យ ដែលតថាគតសំដែងហើយ ក៏រមែងលះបង់នាមនឹងគោត្រដើម (របស់ខ្លួន) ហើយដល់នូវការរាប់ថាជាសមណសក្យបុត្តិយ៍តែម្យ៉ាង ដោយសភាពណា

អយម្បិ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ ចតុត្ថោ អច្ឆរិយោ អព្ភុតធម្មោ យំ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តិ។

សេយ្យថាបិ ភិក្ខវេ យា ច លោកេ សវន្តិយោ មហាសមុទ្ទំ អប្បេន្តិ យា ច អន្តលិក្ខា ធារា បបតន្តិ ន តេន មហាសមុទ្ទស្ស ឩនត្តំ វា បូរត្តំ វា បញ្ញាយតិ ឯវមេវ ខោ ភិក្ខវេ ពហូចេបិ[១] ភិក្ខូ អនុបាទិសេសាយ និព្វានធាតុយា បរិនិព្វាយន្តិ ន តេន និព្វានធាតុយា ឩនត្តំ វា បូរត្តំ វា បញ្ញាយតិ យម្បិ ភិក្ខវេ ពហូបិ ភិក្ខូ អនុបាទិសេសាយ និព្វានធាតុយា បរិនិព្វាយន្តិ ន តេន និព្វានធាតុយា ឩនត្តំ វា បូរត្តំ វា បញ្ញាយតិ អយម្បិ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ បញ្ចមោ អច្ឆរិយោ អព្ភុតធម្មោ យំ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តិ ។

សេយ្យថាបិ ភិក្ខវេ មហាសមុទ្ទោ ឯករសោ លោណរសោ ឯវមេវ ខោ ភិក្ខវេ អយំ ធម្មវិនយោ ឯករសោ វិមុត្តិរសោ យម្បិ ភិក្ខវេ អយំ ធម្មវិនយោ ឯករសោ វិមុត្តិរសោ អយម្បិ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ ឆដ្ឋោ អច្ឆរិយោ អព្ភុតធម្មោ

១. ឱ.ម. ពហូ យទិ ។



ម្នាលភិក្ខុទាំងឡាយ នេះជាសភាព អស្ចារ្យ ដែលកើតចំឡែកទី ៤ ក្នុងធម្មវិន័យនេះ ដែលពួកភិក្ខុឃើញហើយ តែងត្រេកអរ ក្នុងធម្មវិន័យនេះ ។

ម្នាលភិក្ខុទាំងឡាយ ទោះបីពួកភិក្ខុច្រើនរូប បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ និព្វានធាតុក៏មិនប្រាកដជា ខ្វះ ឬពេញ ដោយភិក្ខុទាំងនោះឡើយ ម្នាលភិក្ខុទាំងឡាយ ដូចជាទឹកទន្លេទាំងឡាយណាមួយ ក្នុងលោក ហូរស្រោចចុះទៅកាន់មហាសមុទ្រក្តី ធារទឹកភ្លៀងទាំងឡាយណា ដែលធ្លាក់ចុះមកពីអាកាសក្តី មហាសមុទ្រក៏មិនប្រាកដជាស្រក ឬពេញដោយទឹកនោះ ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ទុកជាពួកភិក្ខុច្រើនរូបបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ និព្វានធាតុក៏មិនប្រាកដជា ខ្វះ ឬពេញ ដោយភិក្ខុទាំងនោះ ដោយសភាពណា ម្នាលភិក្ខុទាំងឡាយ នេះជាសភាព អស្ចារ្យ ដែលកើតចំឡែកទី ៥ ក្នុងធម្មវិន័យនេះ ដែលពួកភិក្ខុឃើញហើយ តែងត្រេកអរ ក្នុងធម្មវិន័យនេះ ។

ម្នាលភិក្ខុទាំងឡាយ ធម្មវិន័យនេះ មានរសតែមួយគឺវិមុត្តិរស ដូចមហាសមុទ្រ មានរសតែមួយគឺរសប្រៃ ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ធម្មវិន័យនេះ មានរសតែមួយគឺវិមុត្តិរស ដោយសភាពណា ម្នាលភិក្ខុទាំងឡាយ នេះជាសភាព អស្ចារ្យ ដែលកើតចំឡែកទី ៦ ក្នុងធម្មវិន័យនេះ

យំ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តិ ។

សេយ្យថាបិ ភិក្ខវេ មហាសមុទ្ទោ ពហុរតនោ អនេករតនោ តត្រិមានិ រតនានិ សេយ្យថីទំ មុត្តា មណិ វេឡុរិយោ សង្ខោ សិលា បវាឡំ រជតំ ជាតរូបំ លោហិតង្គោ មសារគល្លោ ឯវមេវ ខោ ភិក្ខវេ អយំ ធម្មវិនយោ ពហុរតនោ អនេករតនោ តត្រិមានិ រតនានិ សេយ្យថីទំ ចត្តារោ សតិបដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ យម្បិ ភិក្ខវេ អយំ ធម្មវិនយោ ពហុរតនោ អនេករតនោ តត្រិមានិ រតនានិ សេយ្យថីទំ ចត្តារោ សតិបដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ អយម្បិ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ សត្តមោ អច្ឆរិយោ អព្ភុតធម្មោ យំ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តិ ។

សេយ្យថាបិ ភិក្ខវេ មហាសមុទ្ទោ មហតំ ភូតានំ អាវាសោ តត្រិមេ ភូតា តិមិ តិមិង្គលោ តិមិតិមិង្គលោ



ដែលពួកភិក្ខុឃើញហើយ តែងត្រេកអរ ក្នុងធម្មវិន័យនេះ ។

ម្នាលភិក្ខុទាំងឡាយ ធម្មវិន័យនេះ មានរតនៈច្រើនយ៉ាង មិនមែនមានតែមួយប៉ុណ្ណោះទេ រតនៈនេះ ក្នុងធម្មវិន័យនោះគឺ សតិបដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ និងមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដូចមហាសមុទ្រ ដែលមានរតនៈច្រើនយ៉ាង មិនមែនមានតែមួយទេ រតនៈទាំងនេះ ក្នុងមហាសមុទ្រនោះគឺ កែវមុក្តា កែវមណី កែវពិទូរ្យ ស័ង្ខ សិលា កែវប្រពាឡ ប្រាក់ មាស កែវក្រហមនិងកែវមរកត ដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ ធម្មវិន័យនេះ មានរតនៈ ច្រើនយ៉ាង មិនមែនមានតែមួយទេ រតនៈទាំងនេះ ក្នុងធម្មវិន័យនោះគឺ សតិបដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ និងមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដោយសភាពណា នេះជាសភាព អស្ចារ្យ ដែលកើតចំឡែកទី៧ ក្នុងធម្មវិន័យនេះ ដែលពួកភិក្ខុឃើញហើយ តែងត្រេកអរ ក្នុងធម្មវិន័យនេះ ។

ម្នាលភិក្ខុទាំងឡាយ ធម្មវិន័យនេះជាទីនៅអាស្រ័យ នៃពួកបុគ្គលធំៗ ជាច្រើន បុគ្គលទាំងនេះ ក្នុងធម្មវិន័យនោះគឺ សោតាបន្នបុគ្គល និងបុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់សោតាបត្តិផល សកទាគាមិបុគ្គលនិងបុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ សកទាគាមិផល អនាគាមិបុគ្គល

អសុរា នាគា គន្ធព្វា សន្តិ មហាសមុទ្ទេ យោជនសតិកាបិ អត្តភាវា ទ្វិយោជនសតិកាបិ អត្តភាវា តិយោជនសតិកាបិ អត្តភាវា ចតុយោជនសតិកាបិ អត្តភាវា បញ្ចយោជនសតិកាបិ អត្តភាវា ឯវមេវ ខោ ភិក្ខវេ អយំ ធម្មវិនយោ មហតំ ភូតានំ អាវាសោ តត្រិមេ ភូតា សោតាបន្នោ សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នោ សកទាគាមី សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ អនាគាមី អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ អរហា អរហត្តាយ បដិបន្នោ យម្បិ ភិក្ខវេ អយំ ធម្មវិនយោ មហតំ ភូតានំ អាវាសោ តត្រិមេ ភូតា សោតាបន្នោ សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នោ សកទាគាមី សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ អនាគាមី អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ អរហា អរហត្តាយ បដិបន្នោ អយម្បិ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ អដ្ឋមោ អច្ឆរិយោ អព្ភុតធម្មោ យំ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តិ ។



និងបុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ព្រះអរហ និងបុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ដូចជាមហាសមុទ្រ ជាទីនៅអាស្រ័យ នៃពួកសត្វធំៗ ជាច្រើន ឯពួកសត្វទាំងនេះ ក្នុងមហាសមុទ្រនោះគឺ ត្រីឈ្មោះតិមិ ឈ្មោះតិមិង្គល ឈ្មោះ តិមិតិមិង្គល និងពួកអសុរ នាគ គន្ធព្វ ដែលមានអត្តភាព ១ រយយោជន៍ខ្លះ មានអត្តភាព ២ រយយោជន៍ខ្លះ មានអត្តភាព ៣ រយយោជន៍ខ្លះ មានអត្តភាព ៤ រយយោជន៍ខ្លះ មានអត្តភាព ៥ រយយោជន៍ខ្លះ ដែលមាននៅក្នុងមហាសមុទ្រដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ ធម្មវិន័យនេះ ជាទីនៅអាស្រ័យនៃពួកបុគ្គលធំៗ ជាច្រើន បុគ្គលទាំងនេះ ក្នុងធម្មវិន័យនោះគឺ សោតាបន្នបុគ្គល និងបុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល សកទាគាមិបុគ្គល និងបុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់សកទាគាមិផល អនាគាមិបុគ្គល និងបុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ព្រះអរហន្ត និងបុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ដោយសភាពណា ម្នាលភិក្ខុទាំងឡាយ នេះជាសភាព អស្ចារ្យ ដែលកើតមិនទៀតទី ៨ ក្នុងធម្មវិន័យនេះ ដែលពួកភិក្ខុឃើញហើយ តែងត្រេកអរ ក្នុងធម្មវិន័យនេះ ។

ឯវមេវ ខោ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ អដ្ឋ អច្ឆរិយា អព្ភុតធម្មា យេ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តីតិ ។ អថ ខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

ឆន្នមតិវស្សតិ[1] វិវដំ នាតិវស្សតិ
តស្មា ឆន្នំ វិវរេថ ឯវន្តំ នាតិវស្សតីតិ ។

បញ្ចមំ[2] ។

(១១៥) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា មហាកច្ចានោ អវន្តីសុ វិហរតិ កុររឃរេ[3] បវត្តេ បព្ពតេ ។ តេន ខោ បន សមយេន សោណោ ឧបាសកោ កោដិកណ្ណោ[4] អាយស្មតោ មហាកច្ចានស្ស ឧបដ្ឋាកោ ហោតិ ។ អថ ខោ សោណស្ស ឧបាសកស្ស កោដិកណ្ណស្ស រហោគតស្ស

១ ម. ឆន្នមតិវស្សតិ ។ ២ ឱ.ម. បញ្ចមំ ។ ៣ ម. កុររឃរេ ។ ម. កុលឃរេ ។ ៤ ម. កុដិកណ្ណោ ។



ម្នាលភិក្ខុទាំងឡាយ នេះឯងហើយដែលហៅថា សភាពអស្ចារ្យ ដែលកើតចំឡែក ៨ ប្រការ ក្នុងធម្មវិន័យនេះ ដែលពួកភិក្ខុឃើញហើយ តែងត្រេកអរ ក្នុងធម្មវិន័យនេះ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបសេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

ភិក្ខុត្រូវអាបត្តិហើយបិទបាំងអាបត្តិទុក រមែងត្រូវអាបត្តិថ្មីដទៃទៀត
ភិក្ខុត្រូវអាបត្តិហើយ បើកអាបត្តិ មិនត្រូវអាបត្តិដទៃទៀត ព្រោះ
ហេតុនោះ ភិក្ខុ( ណាមួយ ) ត្រូវអាបត្តិ ដែលបិទបាំងហើយ ភិក្ខុ
(នោះ) ត្រូវតែបើកអាបត្តិចេញ កាលបើយ៉ាងនេះ ទើបមិនត្រូវ
អាបត្តិតទៅទៀត ។ សូត្រទី ៥ ។

(១១៥) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមហាកច្ចានៈដ៏មានអាយុ គង់នៅលើភ្នំឈ្មោះបវត្តៈ ទៀបក្រុងឈ្មោះកុររឃរៈ ក្នុងអវន្តីជនបទ ។ សម័យនោះ ឧបាសកឈ្មោះសោណកុដិកណ្ណៈ[1] ជាឧបដ្ឋាក របស់ព្រះមហាកច្ចានៈ ដ៏មានអាយុ ។ វេលានោះ ឧបាសកឈ្មោះសោណកុដិកណ្ណៈ នៅក្នុងទីស្ងាត់

១ ព្រោះលោកពាក់គ្រឿងប្រដាប់ត្រចៀកមានតម្លៃមួយកោដិ ទើបគេហៅថា កុដិកណ្ណៈ ។ អដ្ឋកថា ។

បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ យថា យថា ខោ អយ្យោ មហាកច្ចានោ ធម្មំ ទេសេតិ នយិទំ សុករំ អគារំ អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្តបរិសុទ្ធំ សង្ខលិខិតំ ព្រហ្មចរិយំ ចរិតុំ យន្នូនាហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជេយ្យន្តិ ។ អថខោ សោណោ ឧបាសកោ កោដិកណ្ណោ យេនាយស្មា មហាកច្ចានោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ មហាកច្ចានំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោណោ ឧបាសកោ កោដិកណ្ណោ អាយស្មន្តំ មហាកច្ចានំ ឯតទវោច ឥធ មយ្ហំ ភន្តេ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ យថា យថា ខោ អយ្យោ មហាកច្ចានោ ធម្មំ ទេសេតិ នយិទំ សុករំ អគារំ[១] អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្តបរិសុទ្ធំ សង្ខលិខិតំ ព្រហ្មចរិយំ ចរិតុំ យន្នូនាហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជេយ្យន្តិ បព្វាជេតុ មំ ភន្តេ អយ្យោ មហាកច្ចានោតិ ។

១ ម. អគារ ។



ពួនសម្ងំ កើតសេចក្ដីត្រិះរិះ ក្នុងចិត្តយ៉ាងនេះថា លោកម្ចាស់មហាកច្ចានៈ សំដែងធម៌ ដោយអាការណា បុគ្គលដែលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌នោះ ឲ្យបរិបូណ៌ បរិសុទ្ធពេញលេញ ដូចជាស័ង្ខ ដែលដុសខាត់ហើយ (ដោយអាការនោះ) បានឡើយ បើដូច្នោះ មានតែអញ កោរសក់នឹងពុកមាត់ ហើយស្លៀកដណ្ដប់សំពត់កាសាយៈចេញចាកផ្ទះចូលទៅកាន់ផ្នួស ។ គ្រានោះ ឧបាសកឈ្មោះសោណកុដិកណ្ណៈ ចូលទៅរកព្រះមហាកច្ចានៈដ៏មានអាយុ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមហាកច្ចានៈ ដ៏មានអាយុ ហើយអង្គុយក្នុងទីសមគួរ ។ លុះឧបាសកឈ្មោះសោណកុដិកណ្ណៈ អង្គុយក្នុងទីសមគួរហើយ បាននិយាយពាក្យនេះ នឹងព្រះមហាកច្ចានៈដ៏មានអាយុថា បពិត្រលោកម្ចាស់ដ៏ចំរើន ក្នុងទីនេះ ខ្ញុំព្រះករុណានៅ ក្នុងទីស្ងាត់ពួនសម្ងំ កើតសេចក្ដីត្រិះរិះ ក្នុងចិត្តយ៉ាងនេះថា លោកម្ចាស់មហាកច្ចានៈ តែងសំដែងធម៌ ដោយអាការណា បុគ្គលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌នេះ ឲ្យបរិបូណ៌ បរិសុទ្ធពេញលេញ ដូចជាស័ង្ខ ដែលដុសខាត់ហើយ ( ដោយអាការនោះ ) បានឡើយ បើដូច្នោះ មានតែអញ កោរសក់នឹងពុកមាត់ ហើយស្លៀកដណ្ដប់សំពត់កាសាយៈ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់មហាកច្ចានៈ បំបួសខ្ញុំឲ្យបាន ។

(១៦០) ឯវំ វុត្តេ អាយស្មា មហាកច្ចានោ សោណំ ឧបាសកំ កោដិកណ្ណំ ឯតទវោច ទុក្ករំ ខោ សោណ យាវជីវំ ឯកភត្តំ ឯកសេយ្យំ ព្រហ្មចរិយំ ឥង្ឃ ត្វំ សោណ តត្ថេវ អគារិកភូតោ សមានោ ពុទ្ធានំ សាសនំ អនុយុញ្ជ កាលយុត្តំ ឯកភត្តំ ឯកសេយ្យំ ព្រហ្មចរិយន្តិ ។ អថខោ សោណស្ស ឧបាសកស្ស កោដិកណ្ណស្ស យោ អហោសិ បព្វជ្ជាភិសង្ខារោ សោ បដិប្បស្សម្ភិ ។ ទុតិយម្បិ ខោ សោណស្ស ឧបាសកស្ស កោដិកណ្ណស្ស រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ យថា យថា ខោ អយ្យោ មហាកច្ចានោ ធម្មំ ទេសេតិ នយិទំ សុករំ អគារំ អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្តបរិសុទ្ធំ សង្ខលិខិតំ ព្រហ្មចរិយំ ចរិតុំ យន្នូនាហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជេយ្យន្តិ ។



(១៦០) លុះឧបាសក និយាយយ៉ាងនេះហើយ ទើបមហាកច្ចានៈមានអាយុ ពោលនឹងឧបាសក ឈ្មោះសោណកុដិកណ្ណៈដូច្នេះថា នែសោណៈ ព្រហ្មចរិយៈ មានការបរិភោគភត្ត តែមួយពេល មានការដេកនៅតែម្នាក់ឯង ដរាបដល់អស់មួយជីវិត កម្រក្រលនឹងធ្វើបាន នែសោណៈ ម្ល៉ោះហើយចុះ អ្នកនៅជាគ្រហស្ថ ក្នុងទីនោះឯណោះសិនចុះ ចូរប្រកបតាមពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធទាំងឡាយ នូវព្រហ្មចរិយៈ មានការបរិភោគភត្ត តែមួយពេល មានការដេកនៅ តែម្នាក់ឯង សមគួរតាមកាលចុះ ។ លំដាប់នោះ ការប្រុងប្រៀបនឹងបួសរបស់ឧបាសកឈ្មោះសោណកុដិកណ្ណៈ ក៏ស្ងប់ទៅ ។ ឧបាសកសោណកុដិកណ្ណៈ នៅក្នុងទីស្ងាត់ ចូលសម្ងំ កើតសេចក្ដីត្រិះរិះ ក្នុងចិត្តអស់វារៈពីរដងថា លោកម្ចាស់មហាកច្ចានៈ សំដែងធម៌ ដោយអាការណា បុគ្គលដែលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌នេះ ឲ្យបរិបូណ៌ បរិសុទ្ធ ពេញលេញ ដូចជាសង្ខ ដែលខាត់ហើយ (ដោយអាការនោះ) បានឡើយ បើដូច្នោះ មានតែអញ កោរសក់នឹងពុកមាត់ ហើយស្លៀកដណ្ដប់សំពត់កាសាវៈ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ។

ទុតិយម្បិ ខោ សោណោ ឧបាសកោ កោដិកណ្ណោ យេនាយស្មា មហាកច្ចានោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ មហាកច្ចានំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោណោ ឧបាសកោ កោដិកណ្ណោ អាយស្មន្តំ មហាកច្ចានំ ឯតទវោច ឥធ មយ្ហំ ភន្តេ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ យថា យថា ខោ អយ្យោ មហាកច្ចានោ ធម្មំ ទេសេតិ នយិទំ សុករំ អគារំ អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្តបរិសុទ្ធំ សង្ខលិខិតំ ព្រហ្មចរិយំ ចរិតុំ យន្នូនាហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជេយ្យន្តិ បព្វាជេតុ មំ ភន្តេ អយ្យោ មហាកច្ចានោតិ ។ ទុតិយម្បិ ខោ អាយស្មា មហាកច្ចានោ សោណំ ឧបាសកំ កោដិកណ្ណំ ឯតទវោច ទុក្ករំ ខោ សោណ យាវជីវំ ឯកភត្តំ ឯកសេយ្យំ ព្រហ្មចរិយំ ឥង្ឃ ត្វំ សោណ តត្ថេវ អគារិកភូតោ សមានោ ពុទ្ធានំ សាសនំ អនុយុញ្ជ កាលយុត្តំ ឯកភត្តំ ឯកសេយ្យំ ព្រហ្មចរិយន្តិ ។



ឧបាសកឈ្មោះសោណកុដិកណ្ណៈ ចូលទៅរកមហាកច្ចានៈ ដ៏មានអាយុ លុះចូលទៅដល់ហើយ ថ្វាយបង្គំមហាកច្ចានៈ ដ៏មានអាយុ ហើយអង្គុយក្នុងទីសមគួរ អស់វារៈពីរដង ។ លុះឧបាសកឈ្មោះសោណកុដិកណ្ណៈ អង្គុយក្នុងទីសមគួរហើយ ក៏ពោលពាក្យនឹងមហាកច្ចានៈដ៏មានអាយុ ដូច្នេះថា បពិត្រលោកម្ចាស់ដ៏ចំរើន អម្បាញ់មិញនេះ ខ្ញុំនៅក្នុងទីស្ងាត់ ពួនសម្ងំ កើតសេចក្តីត្រិះរិះក្នុងចិត្តយ៉ាងនេះថា លោកម្ចាស់មហាកច្ចានៈ សំដែងធម៌ដោយអាការណា បុគ្គលដែលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌នេះ ឲ្យបរិបូណ៌ ឲ្យបរិសុទ្ធពេញលេញ ( ដោយអាការនោះ ) បានឡើយ បើដូច្នោះ មានតែអញ កោរសក់នឹងពុកមាត់ ស្លៀកដណ្តប់សំពត់កាសាយៈ ហើយចេញចាកផ្ទះចូលទៅកាន់ផ្នួស បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់មហាកច្ចានៈ បំបួសខ្ញុំឲ្យបាន ។ ព្រះមហាកច្ចានៈដ៏មានអាយុ និយាយប្រាប់ឧបាសកឈ្មោះសោណកុដិកណ្ណៈ អស់វារៈពីរដងថា នែសោណៈ ព្រហ្មចរិយៈមានការបរិភោគភត្ត តែមួយពេល មានការដេកទៅតែម្នាក់ឯង ដរាបដល់អស់ជីវិត ក្រែងបុគ្គលធ្វើបាន នែសោណៈ ណ្ហើយចុះ អ្នកនៅជាគ្រហស្ថក្នុងទីនេះបណ្តើរសិនចុះ ចូរប្រកបតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គឺព្រហ្មចរិយៈមានការបរិភោគភត្តតែមួយពេល មានការដេកនៅតែម្នាក់ឯង សមគួរដល់កាលចុះ ។

ទុតិយម្បិ ខោ សោណស្ស ឧបាសកស្ស កោដិ-កណ្ណស្ស យោ អហោសិ បព្វជ្ជាភិសង្ខារោ សោ បដិប្បស្សទ្ធោ ។ តតិយម្បិ ខោ សោណស្ស ឧបាស-កស្ស កោដិកណ្ណស្ស រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ យថា យថា ខោ អយ្យោ មហាកច្ចានោ ធម្មំ ទេសេតិ នយិទំ សុករំ អគារំ អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្តបរិសុទ្ធំ សង្ខលិខិតំ ព្រហ្មចរិយំ ចរិតុំ យន្នូនាហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អន-គារិយំ បព្វជេយ្យន្តិ ។ អថខោ សោណោ ឧបា-សកោ កោដិកណ្ណោ យេនាយស្មា មហាកច្ចានោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ មហាកច្ចានំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោណោ ឧបាសកោ កោដិកណ្ណោ អាយស្មន្តំ មហាកច្ចានំ ឯតទវោច ឥធ មយ្ហំ ភន្តេ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ យថា យថា ខោ អយ្យោ មហាកច្ចានោ ធម្មំ ទេសេតិ



ការប្រុងប្រៀបដើម្បីបួសរបស់ឧបាសកឈ្មោះសោណកុដិកណ្ណៈ ក៏ស្ងប់ខានទៅអស់វារៈពីរដង ។ ឧបាសកឈ្មោះសោណកុដិកណ្ណៈ នៅក្នុងទីស្ងាត់ ក្នុងសម្ងំ កើតសេចក្តីត្រិះរិះ ក្នុងចិត្តយ៉ាងនេះ អស់វារៈ ៣ ដងថា លោកម្ចាស់មហាកច្ចានៈ សំដែងធម៌ ដោយអាការណា បុគ្គលដែលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌នេះ ឲ្យបរិបូណ៌ បរិសុទ្ធ-តែម្យ៉ាង ដូចជាសង្ខ័ដែលដុសខាត់ហើយ (ដោយអាការនោះ) បានឡើយ បើដូច្នោះ គួរតែអាត្មាអញ កោរសក់និងពុកមាត់ ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ។ ឧបាសកឈ្មោះសោណកុដិកណ្ណៈ ចូលទៅរកមហាកច្ចានៈដ៏មានអាយុ លុះចូលទៅដល់ហើយថ្វាយបង្គំមហាកច្ចានៈដ៏មានអាយុ ហើយអង្គុយ ក្នុងទីសមគួរ ជាគំរប់ ៣ ដង ។ លុះឧបាសកឈ្មោះសោណកុដិកណ្ណៈ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាប-ទូលមហាកច្ចានៈដ៏មានអាយុដូច្នេះថា បពិត្រលោកម្ចាស់ដ៏ចំរើន អម្បាញ់មិញនេះ ខ្ញុំនៅក្នុងទីស្ងាត់ ក្នុងសម្ងំ កើតសេចក្តីត្រិះរិះ ក្នុងចិត្ត យ៉ាងនេះថា លោកម្ចាស់មហាកច្ចានៈ សំដែងធម៌ ដោយអាការណា

នយិទំ សុករំ អគារំ អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្តបរិសុទ្ធំ សង្ខលិខិតំ ព្រហ្មចរិយំ ចរិតុំ យន្នូនាហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជេយ្យន្តិ បព្វាជេតុ មំ ភន្តេ អយ្យោ មហាកច្ចានោតិ ។ អថខោ អាយស្មា មហាកច្ចានោ សោណំ ឧបាសកំ កោដិកណ្ណំ បព្វាជេសិ ។

(១៦១) តេន ខោ បន សមយេន អវន្តីទក្ខិណាបថោ អប្បភិក្ខុកោ ហោតិ ។ អថខោ អាយស្មា មហាកច្ចានោ តិណ្ណំ វស្សានំ អច្ចយេន កិច្ឆេន កសិរេន តតោ តតោ ទសវគ្គំ ភិក្ខុសង្ឃំ សន្និបាតេត្វា អាយស្មន្តំ សោណំ ឧបសម្បាទេសិ ។ អថខោ អាយស្មតោ សោណស្ស វស្សំ វុដ្ឋស្ស រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ ន ខោ មេ សោ ភគវា សម្មុខា ទិដ្ឋោ អបិ ច សុតោយេវ មេ សោ ភគវា ឦទិសោ ច ឦទិសោ ចាតិ សចេ មំ ឧបជ្ឈាយោ អនុជានេយ្យ គច្ឆេយ្យាហំ តំ ភគវន្តំ ទស្សនាយ អរហន្តំ សម្មាសម្ពុទ្ធន្តិ ។



បុគ្គលដែលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌នេះឲ្យបរិបូណ៌ បរិសុទ្ធពេញលេញ ដូចជាស័ង្ខដែលគេខាត់ហើយ (ដោយការនោះ) បានឡើយ បើដូច្នោះ មានតែអញ កោរសក់និងពុកមាត់ ស្លៀកដណ្ដប់សំពត់កាសាយៈ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់មហាកច្ចានៈ បំបួសខ្ញុំឲ្យបាន ។ លំដាប់នោះ ព្រះមហាកច្ចានៈដ៏មានអាយុ ក៏បំបួសឧបាសក ឈ្មោះសោណកុដិកណ្ណៈ (ក្នុងកាលនោះ) ។

(១៦១) សម័យនោះឯង អវន្តីទក្ខិណាបថជនបទ មានភិក្ខុតិច ។ វេលានោះ ព្រះមហាកច្ចានៈដ៏មានអាយុ ក៏ប្រជុំភិក្ខុសង្ឃ ទសវគ្គ អំពីតាមនិគមនោះៗ ដោយកាលកន្លងទៅ ៣ ឆ្នាំ ដោយក្រលំបាក ហើយឲ្យសោណៈដ៏មានអាយុបានឧបសម្បទា ។ គ្រានោះ ព្រះសោណៈដ៏មានអាយុ នៅចាំវស្សារួចហើយ នៅក្នុងទីស្ងាត់ ពួនសម្ងំ កើតសេចក្ដីត្រិះរិះ ក្នុងចិត្តយ៉ាងនេះថា អញមិនដែលឃើញព្រះមានព្រះភាគព្រះអង្គនោះ ក្នុងទីចំពោះមុខសោះ អញគ្រាន់តែឮថា ព្រះមានព្រះភាគ ព្រះអង្គនោះប្រកបដោយគុណយ៉ាងនេះៗ ប្រសិនបើ ព្រះឧបជ្ឈាយ៍អនុញ្ញាតអញ ។ អញគួរតែទៅគាល់ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។

អថខោ អាយស្មា សោណោ សាយណ្ហសមយំ បដិស-
ល្លានា វុដ្ឋិតោ យេនាយស្មា មហាកច្ចានោ តេនុប-
សង្កមិ ឧបសង្កមិត្វា អាយស្មន្តំ មហាកច្ចានំ អភិវាទេ-
ត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយ-
ស្មា សោណោ អាយស្មន្តំ មហាកច្ចានំ ឯតទវោច
ឥធ មយ្ហំ ភន្តេ រហោគតស្ស បដិសល្លីនស្ស ឯវំ
ចេតសោ បរិវិតក្កោ ឧទបាទិ ន ខោ មេ សោ
ភគវា សម្មុខា ទិដ្ឋោ អបិ ច សុតោយេវ មេ
សោ ភគវា ឯទិសោ ច ឯទិសោ ចាតិ សចេ មំ
ឧបជ្ឈាយោ អនុជានេយ្យ គច្ឆេយ្យាហំ តំ ភគវន្តំ
ទស្សនាយ អរហន្តំ សម្មាសម្ពុទ្ធន្តិ ។ សាធុ សាធុ
សោណ គច្ឆ ត្វំ សោណ តំ ភគវន្តំ ទស្សនាយ
អរហន្តំ សម្មាសម្ពុទ្ធំ ទក្ខិស្សសិ ត្វំ សោណ តំ
ភគវន្តំ បាសាទិកំ បសាទនីយំ សន្តិន្ទ្រិយំ សន្តមា-
នសំ ឧត្តមទមថសមថមនុប្បត្តំ ទន្តំ គុត្តំ យតិន្ទ្រិយំ
នាគំ ទិស្វា មម វចនេន ភគវតោ បាទេ សិរសា វន្ទាហិ



លំដាប់នោះ ព្រះសោណៈដ៏មានអាយុ ចេញអំពីទីសម្ងំក្នុងសាយណ្ហសម័យ ចូលទៅរកព្រះមហាកច្ចានៈដ៏មានអាយុ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមហាកច្ចានៈដ៏មានអាយុ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះសោណៈដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ និយាយពាក្យនេះនឹងមហាកច្ចានៈដ៏មានអាយុថា បពិត្រលោកម្ចាស់ដ៏ចំរើន អម្បាញ់មិញនេះ ខ្ញុំព្រះករុណានៅក្នុងទីស្ងាត់ ពួនសម្ងំ កើតសេចក្ដីត្រិះរិះក្នុងចិត្តយ៉ាងនេះថា អញមិនដែលឃើញព្រះមានព្រះភាគ ព្រះអង្គនោះក្នុងទីចំពោះមុខសោះ អញគ្រាន់តែឮថា ព្រះមានព្រះភាគព្រះអង្គនោះ មានសភាពដូច្នេះៗ ប្រសិនបើ ព្រះឧបជ្ឈាយ៍អនុញ្ញាត អញនឹងទៅគាល់ ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។ ព្រះមហាកច្ចានៈដ៏មានអាយុតបថា នែសោណៈ ប្រពៃណាស់ ប្រពៃណាស់ ម្នាលសោណៈ លោកចូរទៅគាល់ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះចុះ ម្នាលសោណៈ លោកនឹងឃើញព្រះមានព្រះភាគនោះជាទីជ្រះថ្លា គួរឲ្យជ្រះថ្លា មានឥន្ទ្រិយស្ងប់មានព្រះទ័យស្ងប់ ដល់នូវការស្ងប់នឹងការទូន្មានដ៏ឧត្តម ឈ្នះខ្លួនបាន គ្រប់គ្រងមានឥន្ទ្រិយសង្រួមហើយ ជាព្រះពុទ្ធដ៏ប្រសើរ លុះឃើញហើយ ចូរថ្វាយបង្គំព្រះបាទារបស់ព្រះមានព្រះភាគ ដោយត្បូង តាមពាក្យបណ្ដាំរបស់ខ្ញុំ

អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ ពុច្ឆាតិ[១] ។ ឯវំ អាវុសោតិ ខោ អាយស្មា សោណោ អាយស្មតោ មហាកច្ចានស្ស ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា អាយស្មន្តំ មហាកច្ចានំ អភិវាទេត្វា បទក្ខិណំ កត្វា សេនាសនំ សំសាមេត្វា បត្តចីវរមាទាយ យេន សាវត្ថី តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកញ្ចរមានោ យេន សាវត្ថី ជេតវនំ អនាថបិណ្ឌិកស្ស អារាមោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សោណោ ភគវន្តំ ឯតទវោច ឧបជ្ឈាយោ មេ ភន្តេ អាយស្មា មហា- កច្ចានោ ភគវតោ បាទេ សិរសា វន្ទតិ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆតីតិ ។ កច្ចិ ភិក្ខុ ខមនីយំ កច្ចិ យាបនីយំ កច្ចិសិ អប្បកិលមថេន អទ្ធានំ អាគតោ ន ច បិណ្ឌកេន កិលន្តោសីតិ ។

១. ម. ផាសុវិហារំ បុច្ឆ ឧបជ្ឈាយោ មេ ភន្តេ អាយស្មា មហាកច្ចានោ ភគវតោ បាទេ សិរសា វន្ទតិ អប្បាពាធំ ។ បេ ។ ផាសុវិហារំ បុច្ឆតីតិ ឥតិ បាឋោ ទិស្សតិ ។ ម. ច. ក. យុត្តតរោ ។



លោកឲ្យសួរសេចក្ដីមិនមានអាពាធ មិនមានទុក្ខ ការក្រោកឡើងដោយរហ័សរហួន កម្លាំងកាយ និងការនៅជាសុខស្រួលផង ។ សោណភិក្ខុដ៏មានអាយុ ទទួលថា ព្រះករុណាលោកម្ចាស់ ហើយត្រេកអរ រីករាយនឹងភាសិតរបស់មហាកច្ចានៈដ៏មានអាយុ ហើយក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមហាកច្ចានៈ ដ៏មានអាយុ ធ្វើប្រទក្សិណ ទុកដាក់សេនាសនៈ កាន់យកបាត្រនិងចីវរហើយ ចេញទៅកាន់ចារិកក្នុងក្រុងសាវត្ថី កាលត្រាច់ទៅកាន់ចារិកតាមលំដាប់ សំដៅទៅក្រុងសាវត្ថី វត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយ ក្នុងទីសមគួរ ។ លុះសោណភិក្ខុដ៏មានអាយុ អង្គុយ ក្នុងទីសមគួរហើយ ក៏ក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមហាកច្ចានៈដ៏មានអាយុ ជាឧបជ្ឈាយ៍នៃខ្ញុំព្រះអង្គ ថ្វាយបង្គំព្រះបាទនៃព្រះមានព្រះភាគ ដោយត្បូង សួរសេចក្ដីមិនមានអាពាធ មិនមានទុក្ខ ការក្រោកឡើងរហ័សរហួន កម្លាំងកាយ និងការនៅជាសុខស្រួលផង ។ ព្រះមានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ អ្នកគួរអត់ធន់បានដែរឬ គួរឲ្យប្រព្រឹត្តទៅបានដែរឬ អ្នកមកតាមផ្លូវ កាន់ឆ្ងាយ មិនលំបាកទេឬ ទាំងមិនលំបាកដោយបិណ្ឌបាតទេឬ ។

ខមនីយំ ភគវា យាបនីយំ ភគវា អប្បកិលមថេន ចាហំ ភន្តេ មគ្គេន អាគតោ ន ច បិណ្ឌកេន កិលន្តោម្ហីតិ ។

(១៦៦) អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ ឥមស្សានន្ទ អាគន្តុកស្ស ភិក្ខុនោ សេនាសនំ បញ្ញាបេហីតិ ។ អថ ខោ អាយស្មតោ អានន្ទស្ស ឯតទហោសិ យស្ស ខោ មំ ភគវា អាណាបេតិ ឥមស្ស អានន្ទ អាគន្តុកស្ស ភិក្ខុនោ សេនាសនំ បញ្ញាបេហីតិ ឥច្ឆតិ ភគវា តេន ភិក្ខុនា សទ្ធឹ ឯកវិហារេ វត្ថុំ ឥច្ឆតិ ភគវា អាយស្មតា សោណេន សទ្ធឹ ឯកវិហារេ វត្ថុន្តិ ។ យស្មឹ វិហារេ ភគវា វិហរតិ តស្មឹ វិហារេ អាយស្មតោ សោណស្ស សេនាសនំ បញ្ញាបេសិ ។ អថខោ ពហុទេវ រត្តឹ អជ្ឈោកាសេ និសជ្ជាយ[១] វីតិនាមេត្វា វិហារំ បាវិសិ ។ អាយស្មាបិ ខោ សោណោ ពហុទេវ រត្តឹ អជ្ឈោកាសេ និសជ្ជាយ វីតិនាមេត្វា វិហារំ បាវិសិ ។

១ ម.ឆ. និសជ្ជាយ ។



បពិត្រព្រះមានព្រះភាគ ខ្ញុំអត់ធន់បាន បពិត្រព្រះមានព្រះភាគ ខ្ញុំប្រព្រឹត្តទៅបាន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមកតាមផ្លូវកាត់ផ្លូវឆ្ងាយ មិនលំបាកទេ ទាំងមិនលំបាកដោយចង្អត់បិណ្ឌបាតទៀតឡើយ ។

(១៦៦) គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុ មកថា ម្នាលអានន្ទ អ្នកចូរក្រាលសេនាសនៈ សម្រាប់អាគន្តុកភិក្ខុនេះផង ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ មានសេចក្តីត្រិះរិះថា ព្រះមានព្រះភាគទ្រង់បង្គាប់អញ ឲ្យក្រាលសេនាសនៈសម្រាប់ភិក្ខុណា ដោយព្រះពុទ្ធដីកាថា អ្នកចូរក្រាលសេនាសនៈ សម្រាប់អាគន្តុកភិក្ខុនេះផង ព្រះមានព្រះភាគ ចង់គង់នៅក្នុងលំនៅមួយ ជាមួយនឹងភិក្ខុនោះ ព្រះមានព្រះភាគ ទ្រង់ចង់គង់នៅក្នុងលំនៅមួយ ជាមួយនឹងសោណភិក្ខុដ៏មានអាយុ ។ ព្រះមានព្រះភាគទ្រង់ប្រថាប់ក្នុងលំនៅណា គាត់ក៏ក្រាលសេនាសនៈ សម្រាប់សោណភិក្ខុដ៏មានអាយុ ក្នុងលំនៅនោះដែរ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងទីវាល អស់វេលាយប់ជ្រៅ លុះកន្លងវេលាហើយ ក៏លាងព្រះបាទហើយចូលទៅកាន់វិហារ ។ ចំណែកសោណភិក្ខុដ៏មានអាយុ ក៏អង្គុយក្នុងទីវាល អស់វេលាយប់ជ្រៅ លុះកន្លងវេលាទៅហើយ ក៏លាងជើង ហើយចូលទៅកាន់វិហារដែរ ។ លំដាប់នោះ

អថខោ ភគវា រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ អាយស្មន្តំ មហាសោណំ អជ្ឈេសិ បដិភាតុ តំ ភិក្ខុ ធម្មោ(១) ភាសិតុន្តិ ។ ឯវំ ភន្តេតិ ខោ អាយស្មា សោណោ ភគវតោ បដិស្សុត្វា សោឡស អដ្ឋកវគ្គិកានិ សព្វានេវ សរេន អភណិ ។ អថខោ ភគវា អាយស្មតោ សោណស្ស សរភញ្ញបរិយោសានេ អព្ភនុមោទិ សាធុ សាធុ ភិក្ខុ សុគ្គហិតានិ តេ ភិក្ខុ អដ្ឋកវគ្គិកានិ(២) សុមនសិកតានិ សូបធារិតានិ កល្យាណិយាសិ វាចាយ សមន្នាគតោ វិសដ្ឋាយ អនេលាយ អត្ថស្ស វិញ្ញាបនិយា កតិវស្សោសិ ត្វំ ភិក្ខូតិ ។ ឯកវស្សោ អហំ ភគវាតិ ។ កិស្ស បន ត្វំ ភិក្ខុ ឯវំ ចិរំ អកាសីតិ ។ ចិរំ ទិដ្ឋោ មេ ភន្តេ កាមេសុ អាទីនវោ អបិ ច សម្ពាធោ ឃរាវាសោ ពហុកិច្ចោ ពហុករណីយោតិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

១ ម. ឱភាតុ ។ បដិភាតុ តំ ភិក្ខុ ធម្មោតិ ឯវមេវ អដ្ឋកថា ទិស្សតិ ។ ២ ឧ. សោឡស អដ្ឋកវគ្គិកានិ ហោតិ នត្ថិ ។



ព្រះមានព្រះភាគទ្រង់តើនឡើងក្នុងបច្ចូសសម័យនៃរាត្រី ត្រាស់បង្គាប់ព្រះសោណៈដ៏មានអាយុថា ម្នាលភិក្ខុ ការសំដែងធម៌ចូរភ្លឺច្បាស់ដល់លោក ។ ព្រះសោណៈដ៏មានអាយុ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយសំដែងព្រះសូត្រ ១៦ ក្នុងអដ្ឋកវគ្គទាំងអស់ ដោយសំឡេង ( បទសរភញ្ញ ) ។ គ្រានោះ ព្រះមានព្រះភាគទ្រង់អនុមោទនាព្រះសោណភិក្ខុដ៏មានអាយុ ក្នុងទីបំផុតនៃការសំដែង ដោយសំឡេងថា ម្នាលភិក្ខុ ពីរោះណាស់ ម្នាលភិក្ខុ សូត្រដែលមានក្នុងអដ្ឋកវគ្គ អ្នករៀនល្អហើយ យកចិត្តទុកដាក់ល្អហើយ ចាំស្ទាត់ហើយ អ្នកជាភិក្ខុប្រកបដោយវាចាដ៏ពីរោះ ស្អាតស្អំ ជាវាចាមិនមានទោស ការញុំាងបុគ្គលដទៃ ឱ្យដឹងច្បាស់សេចក្តីបាន ម្នាលភិក្ខុ អ្នកមានវស្សាប៉ុន្មាន ។ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទើបនឹងបានមួយវស្សា ។ ម្នាលភិក្ខុ ហេតុអ្វីក៏អ្នកធ្វើឱ្យយូរយ៉ាងនេះ ។ បពិត្រព្រះអង្គដ៏ចំរើន ទោសក្នុងកាមគុណ ខ្ញុំព្រះអង្គឃើញយូរហើយដែរ តែថា ឃរាវាស ជាទីចង្អៀត មានកិច្ចច្រើន មានការកិច្ចច្រើន ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបសេចក្តីនុះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

ទិស្វា អាទីនវំ លោកេ ញត្វា ធម្មំ និរុបធិំ

អរិយោ ន រមតី បាបេ បាបេ ន រមតី សុចីតិ ។

ឆដ្ឋំ(១) ។

(១៨៣) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា កង្ខារេវតោ ភគវតោ អវិទូរេ និសិន្នោ ហោតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ អត្តនោ កង្ខាវិតរណវិសុទ្ធិំ បច្ចវេក្ខមានោ ។ អទ្ទសា ខោ ភគវា អាយស្មន្តំ កង្ខារេវតំ អវិទូរេ និសិន្នំ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ អត្តនោ កង្ខាវិតរណវិសុទ្ធិំ បច្ចវេក្ខមានំ ។ អថ ខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

យា កាចិ កង្ខា ឥធ វា ហុរំ វា

សកវេទិយា វា បរវេទិយា វា

យេ ឈាយិនោ តា បជហន្តិ សព្វា

អាតាបិនោ ព្រហ្មចរិយំ ចរន្តាតិ ។ សត្តមំ(២) ។

១. ម. ឆ. ឆដ្ឋំ ។ ២. ម. ឆ. សត្តមំ ។



ព្រោះឃើញទោស ក្នុងសង្ខារលោក ដឹងនូវនិព្វានជាធម៌មិនមានឧបធិហើយ រមែងមិនត្រេកអរ ក្នុងបាប ( ទេ ) បុគ្គលស្អាត មិនត្រេកអរ ក្នុងបាបទេ ។ សូត្រទី ៦ ។

( ១៨៤ ) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះកង្ខារេវតៈដ៏មានអាយុ អង្គុយពែនភ្នែន តម្រង់កាយឲ្យត្រង់ហើយ ពិចារណានូវកង្ខាវិតរណវិសុទ្ធិ ( សេចក្តីបរិសុទ្ធិ ព្រោះឆ្លងនូវសេចក្តីសង្ស័យ ) របស់ខ្លួន ក្នុងទីជិតនៃព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញព្រះកង្ខារេវតៈដ៏មានអាយុ កំពុងអង្គុយពែនភ្នែន តម្រង់កាយឲ្យត្រង់ហើយ ពិចារណានូវកង្ខាវិតរណវិសុទ្ធិរបស់ខ្លួន ក្នុងទីជិតនៃព្រះមានព្រះភាគ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

សេចក្តីសង្ស័យទាំងឡាយណាមួយ ក្នុងលោកនេះក្តី ក្នុងលោកខាងមុខក្តី ដែលបុគ្គលគប្បីដឹង ក្នុងអត្តភាពរបស់ខ្លួនឬ គប្បីដឹង ក្នុងអត្តភាពរបស់បុគ្គលដទៃ បុគ្គលអ្នកមានឈាន មានព្យាយាម កាលប្រព្រឹត្តព្រហ្មចរិយធម៌ រមែងលះបង់ នូវសេចក្តីសង្ស័យទាំងអស់នោះបាន ។ សូត្រទី ៧ ។

(១៦៦) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អាយស្មា អានន្ទោ តទហុបោសថេ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ រាជគហំ បិណ្ឌាយ បាវិសិ ។ អទ្ទសា ខោ ទេវទត្តោ អាយស្មន្តំ អានន្ទំ រាជគហេ បិណ្ឌាយ ចរន្តំ ទិស្វាន យេន អា-យស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ ឯតទវោច អជ្ជតគ្គេទានាហំ អាវុសោ អានន្ទ អញ្ញត្រេវ ភគវតា អញ្ញត្រ ភិក្ខុសង្ឃា ឧបោសថំ ករិស្សាមិ សង្ឃកម្មានិ ចាតិ ។ អថខោ អាយស្មា អានន្ទោ រាជគហេ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាត-បដិក្កន្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ឥធាហំ ភន្តេ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ រាជ-គហំ បិណ្ឌាយ បាវិសឹ អទ្ទសា ខោ មំ ភន្តេ ទេវទត្តោ





(១៦៦) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះអានន្ទដ៏មានអាយុ ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ចូលទៅកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត្រ ក្នុងវេលាបុព្វណ្ហសម័យ ក្នុងឧបោសថថ្ងៃនោះ ។ ទេវទត្តបានឃើញនូវព្រះអានន្ទដ៏មានអាយុ កំពុងត្រាច់ទៅបិណ្ឌបាត្រ ក្នុងក្រុងរាជគ្រឹះ លុះឃើញហើយ ចូលសំដៅមករកព្រះអានន្ទដ៏មានអាយុ លុះចូលមកដល់ហើយ ក៏និយាយនឹងព្រះអានន្ទដ៏មានអាយុយ៉ាងនេះថា នែអាវុសោ អានន្ទ តាំងពីថ្ងៃនេះជាដើមទៅ ខ្ញុំវៀរព្រះមានព្រះភាគ វៀរភិក្ខុសង្ឃហើយ នឹងធ្វើឧបោសថនិងសង្ឃកម្មទាំងឡាយ ( ដាច់ដោយឡែក ) ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ ត្រាច់ទៅបិណ្ឌបាត្រ ក្នុងក្រុងរាជគ្រឹះ លុះត្រឡប់អំពីបិណ្ឌបាត្រក្នុងវេលាក្រោយភត្ត ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន អម្បាញ់មិញនេះ ខ្ញុំព្រះអង្គស្លៀកស្បង់ប្រដាប់បាត្រចីវរ ចូលទៅកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត្រ ក្នុងបុព្វណ្ហសម័យ បពិត្រព្រះអង្គដ៏ចំរើន ទេវទត្ត ក៏បានឃើញខ្ញុំព្រះអង្គ

រាជគហេ បិណ្ឌាយ ចរន្តំ ទិស្វាន យេនាហំ តេនុប-
សង្កមិ ឧបសង្កមិត្វា មំ ឯតទវោច អជ្ជតគ្គេទានាហំ
អាវុសោ អានន្ទ អញ្ញត្រេវ ភគវតា អញ្ញត្រ ភិក្ខុសង្ឃា
ឧបោសថំ ករិស្សាមិ សង្ឃកម្មានិ ចាតិ អជ្ជ ភន្តេ
ទេវទត្តោ សង្ឃំ ភិន្ទិស្សតិ ឧបោសថញ្ច ករិស្សតិ
សង្ឃកម្មានិ ចាតិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា
តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

សុករំ សាធុនា សាធុ សាធុ បាបេន ទុក្ករំ (១)
បាបំ បាបេន សុករំ បាបមរិយេហិ ទុក្ករន្តិ ។ អដ្ឋមំ ។

(១៦៨) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កោស-
លេសុ ចារិកំ ចរតិ មហតា ភិក្ខុសង្ឃេន សទ្ធឹ ។
តេន ខោ បន សមយេន សម្ពហុលា មាណវកា
ភគវតោ អវិទូរេ សទ្ធាយមានរូបា(២) អតិក្កមន្តិ ។
អទ្ទសា ខោ ភគវា សម្ពហុលេ មាណវកេ អវិទូរេ
(៣) សទ្ធាយមានរូបេ អតិក្កមន្តេ ។ អថខោ ភគវា ឯតមត្ថំ
វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

១ ឱ.ម. [illegible] ទុក្ករន្តិ ។ ២ ម. ឧបាយមានរូបា ។ ៣ ម. អតិក្កមេ ។



កំពុងត្រាច់ទៅកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត្រ លុះឃើញហើយក៏
ដើរចូលមករកខ្ញុំព្រះអង្គ លុះចូលមកហើយ និយាយនឹងខ្ញុំព្រះអង្គថា
នែអាវុសោអានន្ទ តាំងពីថ្ងៃនេះតទៅ ខ្ញុំវៀរព្រះមានព្រះភាគ វៀរ
ភិក្ខុសង្ឃហើយ នឹងធ្វើឧបោសថធ្វើសង្ឃកម្មទាំងឡាយ (ដាច់ដោយខ្លួន)
បពិត្រព្រះអង្គដ៏ចំរើន ទេវទត្តនឹងបំបែកសង្ឃក្នុងថ្ងៃនេះ នឹងធ្វើឧបោសថ
ធ្វើសង្ឃកម្មទាំងឡាយ ( ដាច់ដោយខ្លួន) ។ លុះព្រះមានព្រះភាគ ទ្រង់
ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

អំពើល្អ មនុស្សល្អ ធ្វើបានដោយងាយ អំពើល្អ មនុស្សអាក្រក់ ធ្វើ
បានដោយកម្រ អំពើអាក្រក់ មនុស្សអាក្រក់ ធ្វើបានដោយងាយ
អំពើអាក្រក់ ពួកព្រះអរិយៈធ្វើបានដោយកម្រ ។ សូត្រទី ៨ ។

(១៦៨) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ
ទ្រង់ពុទ្ធដំណើរ ទៅកាន់ចារិក ក្នុងដែនកោសល ជាមួយភិក្ខុសង្ឃ
ច្រើនរូប ។ សម័យនោះ មាណពច្រើននាក់ ( ក្មេង ៗ ) មានសភាព
ជាអ្នកនិយាយលេងកាក ដើរកន្លងទីជិតនៃព្រះមានព្រះភាគ ។ ព្រះ
មានព្រះភាគបានឃើញពួកមាណព ច្រើននាក់ដែលកំពុងនិយាយលេង
កាក ដើរកន្លងព្រះអង្គ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបសេចក្តី
នុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

បរិមុដ្ឋា បណ្ឌិតាភាសា វាចាគោចរភាណិនោ

យាវិច្ឆន្តិ មុខាយាមំ យេន នីតា ន តំ វិទូតិ ។ នវមំ ។

(១៦៦) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា ចូឡបន្ថកោ ភគវតោ អវិទូរេ និសិន្នោ ហោតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតិំ ឧបដ្ឋបេត្វា ។ អទ្ទសា ខោ ភគវា អាយស្មន្តំ ចូឡបន្ថកំ អវិទូរេ និសិន្នំ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតិំ ឧបដ្ឋបេត្វា ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

ឋិតេន កាយេន ឋិតេន ចេតសា
តិដ្ឋំ និសិន្នោ ឧទ វា សយានោ
ឯតំ សតិំ ភិក្ខុ អធិដ្ឋហានោ
លភេថ បុព្ពាបរិយំ វិសេសំ
លទ្ធាន បុព្ពាបរិយំ វិសេសំ
អទស្សនំ មច្ចុរាជស្ស គច្ឆេតិ ។ ទសមំ ។

សោណត្ថេរវគ្គោ បញ្ចមោ ។



បុគ្គលល្ងង់ខ្លៅ មានសំដីគ្រាតគ្រាតដូចជាសំដីបណ្ឌិត ពោលពាក្យ ជាវិស័យ ( នៃពាក្យព្រហើនៈ ) ប្រាថ្នានូវការហើបមាត់និយាយ តាមប៉ុណ្ណាយ ដរាបណា (តែហាមាត់និយាយ ដរាបនោះ) ពាក្យ ដែលបុគ្គលល្ងង់ខ្លៅណា នាំមកនិយាយ បុគ្គលល្ងង់ខ្លៅនោះ មិន ដឹងច្បាស់ពាក្យនោះទេ ។ សូត្រ ទី ៩ ។

(១៦៦) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះ ព្រះចូឡបន្ថកៈដ៏មានអាយុ អង្គុយផ្គត់ភ្នែន តម្រង់កាយ ឲ្យត្រង់ តាំងសតិ ( ចំពោះកម្មដ្ឋាន ) ក្នុងទីជិតនៃព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ បានឃើញចូឡបន្ថកៈដ៏មានអាយុ កំពុងអង្គុយផ្គត់ភ្នែន តម្រង់កាយឲ្យត្រង់តាំងសតិ ក្នុងទីជិតនៃព្រះមានព្រះភាគ ។ លុះព្រះមាន ព្រះភាគទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

ភិក្ខុមានកាយខ្ជាប់ខ្ជួន មានចិត្តខ្ជាប់ខ្ជួន ទោះឈរ អង្គុយ ឬ ដេក តែងដំកល់សតិនុ៎ះ ភិក្ខុនោះគប្បីបានគុណវិសេសមានទីបំផុត ខាងដើម លុះបានគុណវិសេសមានទីបំផុតខាងដើមហើយ គប្បីដល់ នូវការមិនជួបប្រទះមច្ចុរាជ ។ សូត្រទី ១០ ។

ចប់ សោណត្ថេរវគ្គ ទី ៥ ។

## ឧទ្ទានំ

ភជា អបរាយុតា ពាជ្ជី ពាមារកា ច ទុបោសថោ
សោឃោ ច បោកោ នត្ថោ សត្ថាយមាហា បន្តកោឧ ពាស៊ីៗ





## ឧទ្ទាន នៃសោណត្ថេរវគ្គនោះគឺ

និយាយអំពីព្រះបាទបសេនទិកោសល ១ គុម្ពារាមាតព្រះផ្គួយពិច ១ សុប្បវាសាកោលិយធីតា ១ ពួកកុមារ ១ ឧបោសថ ១ សោណកុដិកណ្ណៈ ១ កង្ខារេវតៈ ១ ព្រះអានន្ទ ១ មាសោតព្រើនពាក់ មាតកំបាគោពកាព ១ ចូឡបន្ថកភិក្ខុ ១ ។

## ឧទានេ ឆដ្ឋោ ជច្ចន្ធវគ្គោ

(១៤៧) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ វេសាលឹ បិណ្ឌាយ បាវិសិ វេសាលិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ អាយស្មន្តំ អានន្ទំ អាមន្តេសិ គណ្ហាហិ អានន្ទ និសីទនំ យេន ចាបាលំ ចេតិយំ តេនុបសង្កមិស្សាម[1] ទិវាវិហារាយាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុត្វា និសីទនំ អាទាយ ភគវន្តំ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធិ ។ អថខោ ភគវា យេន ចាបាលំ ចេតិយំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ និសជ្ជ ខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ រមណីយា អានន្ទ វេសាលី រមណីយំ ឧទេនំ ចេតិយំ[2]

១ ម. ឧ. ចាបាលំ ចេតិយំ តេនុបសង្កមិស្សាមិ ។ ២ ម. ឧទេនចេតិយំ ។



## ឧទាន ជច្ចន្ធវគ្គ ទី ៦

(១៤៧) ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារសាលា ជិតមហាវ័ន ទៀបក្រុងវេសាលី ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រចីវរ ចូលទៅកាន់ក្រុងវេសាលី ដើម្បីបិណ្ឌបាត ក្នុងបុព្វណ្ហសម័យ ព្រះអង្គកាលត្រាច់ទៅបិណ្ឌបាត ក្នុងក្រុងវេសាលី ត្រឡប់អំពីបិណ្ឌបាត ក្នុងកាលជាខាងក្រោយភត្ត ក៏ត្រាស់ហៅព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ អ្នកចូរយកនិសីទនៈ យើងនឹងចូលទៅឯចាបាលចេតិយ ដើម្បីសម្រាកក្នុងវេលាថ្ងៃ ។ ព្រះអានន្ទដ៏មានអាយុទទួលស្ដាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយកាន់យកនិសីទនៈទៅតាមក្រោយ នៃព្រះមានព្រះភាគ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់យាងចូលទៅឯចាបាលចេតិយ លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈ ដែលព្រះអានន្ទក្រាល លុះព្រះមានព្រះភាគទ្រង់គង់ស្រេចហើយ ទើបទ្រង់ត្រាស់នឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ ទីក្រុងវេសាលី គួរជាទីត្រេកអរ ឧទេនចេតិយ[1] គួរជាទីត្រេកអរ

១ ទីគោរពបូជារបស់ អារក្សឈ្មោះឧទេន [illegible] ទើបហៅថា ឧទេនចេតិយ តមក ។

រមណីយំ គោតមកំ ចេតិយំ[១] រមណីយំ សត្តម្ពំ ចេតិយំ[២] រមណីយំ ពហុបុត្តំ ចេតិយំ[៣] រមណីយំ សារន្ទទំ[៤] ចេតិយំ រមណីយំ ចាបាលំ[៥] ចេតិយំ យស្ស កស្សចិ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា សោ អាកង្ខមានោ[៦] កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វា[៧] តថាគតស្ស ខោ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា សោ អាកង្ខមានោ អានន្ទ តថាគតោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វាតិ ។

---

១ ម. គោតមកចេតិយំ ។ ២ ម. សត្តម្ពចេតិយំ ។ ៣ ម. ពហុបុត្តចេតិយំ ។ ៤ ម. សារន្ទទំ ។ ម. អានន្ទ ។ ៥ ម. ចាបាលំ ។ ម. ចាបាល- ។ ៦ ម. អាកង្ខមានោ អន្តិ ។ ៧ ម. វាតិ ។



គោតមកចេតិយ[១] ជាទីរីករាយ សត្តម្ពចេតិយ[២] ជាទីរីករាយ ពហុបុត្តចេតិយ[៣] ជាទីរីករាយ សារន្ទទចេតិយ[៤] ជាទីរីករាយ ចាបាលចេតិយ[៥] ជាទីរីករាយ ម្នាលអានន្ទ ឥទ្ធិបាទទាំង៤យ៉ាង ដែលបុគ្គលណាមួយ ចំរើនហើយ ធ្វើឲ្យច្រើនហើយ ធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យជាទីតាំងហើយ អធិដ្ឋានហើយ សន្សំហើយ ប្រារព្ធល្អហើយ បុគ្គលនោះ កាលបើប្រាថ្នា គឺនឹងឋិតនៅអស់អាយុកប្ប[៦] ឬលើសពីអាយុកប្បទៅក៏បាន ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ តថាគត ចំរើនហើយ ធ្វើឲ្យច្រើនហើយ ធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យជាទីតាំងហើយ អធិដ្ឋានហើយ សន្សំហើយ ប្រារព្ធល្អហើយ ម្នាលអានន្ទ ព្រះតថាគតនោះ កាលប្រាថ្នា គឺនឹងឋិតនៅអស់អាយុកប្ប ឬលើសអំពីអាយុកប្បទៅក៏បាន ។

---

១ ហៅតាមឈ្មោះយក្សនោះ ។ ២ ហៅតាមព្រះរាជធីតាទាំង ៧ អង្គ របស់ស្តេចក្នុងដែនកាសី ព្រះនាមកិកិស្សរៈ នាំគ្នាមានសេចក្តីសង្វេគ ទើបចេញពីក្រុងពារាណសី ទៅតាំងព្យាយាមប្រឹងប្រែងទីនោះ ទើបហៅថា សត្តម្ពចេតិយ តមក ។ ៣ ត្រង់ទីនោះមានដើមជ្រៃមួយដើម មានមែកច្រើនគួរជាទីគាប់ចិត្ត មានទេវតារក្សាដើមជ្រៃនោះ មនុស្សប្រាថ្នាកូនប្រុសស្រី តែងទៅបួងសួងត្រង់ដើមជ្រៃនោះ ទើបហៅថា ពហុបុត្តចេតិយ ។ ៤-៥ ហៅតាមឈ្មោះយក្សនោះ ។ អដ្ឋកថា ។ ៦ ពាក្យថា អាយុកប្បនេះ សំដៅយកកំណត់អាយុរបស់មនុស្ស តាមចំណត់នៃអាយុច្រើនដើម ។ អដ្ឋកថា ។

(១៦៨) អថខោ អាយស្មា អានន្ទោ ភគវតា ឱឡារិកេ និមិត្តេ កយិរមានេ ឱឡារិកេ ឱភាសេ កយិរមានេ នាសក្ខិ បដិវិជ្ឈិតុំ ន ភគវន្តំ យាចិ តិដ្ឋតុ ភន្តេ ភគវា កប្បំ តិដ្ឋតុ សុគតោ កប្បំ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ យថាតំ មារេន បរិយុដ្ឋិតចិត្តោ ។ ទុតិយម្បិ ខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ រមណីយា អានន្ទ វេសាលី រមណីយំ ឧទេនំ ចេតិយំ រមណីយំ គោតមកំ ចេតិយំ រមណីយំ សត្តម្ពំ ចេតិយំ រមណីយំ ពហុបុត្តំ ចេតិយំ រមណីយំ សារន្ទទំ ចេតិយំ រមណីយំ ចាបាលំ ចេតិយំ យស្ស កស្សចិ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា សោ អាកង្ខមានោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វា តថាគតស្ស ខោ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា សោ អាកង្ខមានោ អានន្ទ តថាគតោ



(១៦៨) កាលដែលព្រះមានព្រះភាគ ធ្វើនិមិត្តដ៏ឱឡារិក ធ្វើឱភាសដ៏ឱឡារិកយ៉ាងនេះ ព្រះអានន្ទដ៏មានអាយុមិនអាចនឹងយល់បាន ទាំងមិនបានអារាធនា នូវព្រះមានព្រះភាគថា បពិត្រព្រះមានព្រះភាគ សូមព្រះអង្គ ឋិតនៅអស់អាយុកប្ប សូមព្រះសុគតឋិតនៅអស់អាយុកប្ប ដើម្បីប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចំរើន ដើម្បីប្រយោជន៍និងសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ ដូច្នេះឡើយ ព្រោះត្រូវមារគ្របសង្កត់ចិត្ត ។ ព្រះមានព្រះភាគត្រាស់នឹងព្រះអានន្ទដ៏មានអាយុ ជាគំរប់ពីរដងថា ម្នាលអានន្ទ ក្រុងវេសាលី គួរជាទីត្រេកអរ ឧទេនចេតិយ ជាទីត្រេកអរ គោតមកចេតិយ ជាទីត្រេកអរ សត្តម្ពចេតិយ ជាទីត្រេកអរ ពហុបុត្តកចេតិយ ជាទីត្រេកអរ សារន្ទទចេតិយ ជាទីត្រេកអរ ចាបាលចេតិយ ជាទីត្រេកអរ ម្នាលអានន្ទ ឥទ្ធិបាទ ៤ ដែលបុគ្គលណា ចំរើនហើយ ធ្វើឲ្យរឿយ ៗ ហើយ ធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យជាទីតាំងហើយ អធិដ្ឋានហើយ សន្សំហើយ ប្រារព្ធល្អហើយ បុគ្គលនោះ កាលប្រាថ្នានឹងឋិតនៅអស់អាយុកប្បក្តី លើសអំពីអាយុកប្បក្តីបាន ម្នាលអានន្ទ ឥទ្ធិបាទ ៤ ដែលព្រះតថាគត ចំរើនហើយ ធ្វើឲ្យរឿយ ៗ ហើយ ធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យជាទីតាំងហើយ អធិដ្ឋានហើយ សន្សំហើយ ប្រារព្ធល្អហើយ ម្នាលអានន្ទ ព្រះតថាគតនោះ

កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វាតិ ។ ឯវម្បិ ខោ អាយស្មា អានន្ទោ ភគវតា ឱឡារិកេ និមិត្តេ ករិយ-មានេ ឱឡារិកេ ឱភាសេ ករិយមានេ នាសក្ខិ បដិវិជ្ឈិតុំ ន ភគវន្តំ យាចិ តិដ្ឋតុ ភន្តេ ភគវា កប្បំ តិដ្ឋតុ សុគតោ កប្បំ ពហុជនហិតាយ ពហុជនសុ-ខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ យថាតំ មារេន បរិយុដ្ឋិតចិត្តោ ។ តតិយម្បិ ខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ រមណីយា អានន្ទ វេសាលី រមណីយំ ឧទេនំ ចេតិយំ រមណីយំ គោតមកំ ចេតិយំ រមណីយំ សត្តម្ពំ ចេតិយំ រមណីយំ ពហុបុត្តំ ចេតិយំ រមណីយំ សារន្ទទំ ចេតិយំ រមណីយំ ចាបាលំ ចេតិយំ យស្ស កស្សចិ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានី-កតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា សោ អាកង្ខមានោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វា តថាគតស្ស ខោ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា



កាលប្រាថ្នានឹងឋិតនៅ អស់អាយុកប្ប ឬលើសពីអាយុកប្បទៅទៀតបាន ។ កាលព្រះមានព្រះភាគ ធ្វើនិមិត្តដ៏ឱឡារិក ធ្វើឱភាសដ៏ឱឡារិកយ៉ាងនេះ ព្រះអានន្ទដ៏មានអាយុ មិនអាចយល់បាន ទាំងមិនបានអារាធនា ព្រះមានព្រះភាគថា បពិត្រព្រះមានព្រះភាគ សូមព្រះអង្គឋិតនៅ អស់អាយុកប្ប សូមព្រះសុគតឋិតនៅ អស់អាយុកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ និងសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ ឲ្យបានដូច្នោះឡើយ ព្រោះត្រូវមារគ្របសង្កត់ចិត្ត ។ ព្រះមានព្រះភាគត្រាស់នឹងព្រះអានន្ទដ៏មានអាយុ ជាគំរប់ ៣ ដងថា ម្នាលអានន្ទ ក្រុងវេសាលី គួរជាទីត្រេកអរ ឧទេនចេតិយ ជាទីត្រេកអរ គោតមកចេតិយ ជាទីត្រេក-អរ សត្តម្ពចេតិយ ជាទីត្រេកអរ ពហុបុត្តកចេតិយ ជាទីត្រេកអរ សារន្ទ-ទចេតិយ ជាទីត្រេកអរ ចាបាលចេតិយ ជាទីត្រេកអរ ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ ដែលបុគ្គលណា ចំរើនហើយ ធ្វើឲ្យរឿយៗហើយ ធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យជាទីតាំងហើយ តាំងផ្គងហើយ សន្សំហើយ ប្រារព្ធល្អហើយ បុគ្គលនោះ កាលប្រាថ្នានឹងឋិតនៅអស់អាយុកប្ប ឬ លើសពីអាយុកប្បទៅទៀតបាន ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ ដែលព្រះតថាគត ចំរើនហើយធ្វើឲ្យរឿយៗហើយ ធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យជាទីតាំងហើយ

អនុដ្ឋិតា បរិចិតា សុសមារទ្ធា សោ អាកង្ខមានោ អានន្ទ តថាគតោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វាតិ ។ ឯវម្បិ ខោ អាយស្មា អានន្ទោ ភគវតា ឱឡារិកេ និមិត្តេ កយិរមានេ ឱឡារិកេ ឱភាសេ កយិរមានេ នាសក្ខិ បដិវិជ្ឈិតុំ ន ភគវន្តំ យាចិ តិដ្ឋតុ ភន្តេ ភគវា កប្បំ តិដ្ឋតុ សុគតោ កប្បំ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ យថា តំ មារេន បរិយុដ្ឋិតចិត្តោ ។

(១៤៨) អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ គច្ឆ ត្វំ អានន្ទ យស្សទានិ កាលំ មញ្ញសីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា អវិទូរេ អញ្ញតរស្មឹ រុក្ខមូលេ និសីទិ ។



អធិដ្ឋានហើយ សន្សំហើយ ប្រារព្ធល្អហើយ ម្នាលអានន្ទ ព្រះតថាគតនោះ កាលប្រាថ្នានឹងឋិតនៅ អស់អាយុកប្បមួយ លើសអំពីអាយុកប្បទៅក៏បាន ។ លុះព្រះមានព្រះភាគ ធ្វើនិមិត្តដ៏ឧឡារិក ធ្វើឱភាសដ៏ឧឡារិកយ៉ាងនេះ ព្រះអានន្ទដ៏មានអាយុ មិនអាចយល់បាន ក៏មិនបានអារាធនាព្រះមានព្រះភាគថា បពិត្រព្រះមានព្រះភាគ សូមព្រះអង្គ ឋិតនៅអស់អាយុកប្ប សូមព្រះសុគត ឋិតនៅអស់អាយុកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍និងសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ឲ្យគង់នៅឡើយ ព្រោះត្រូវមារគ្របសង្កត់ចិត្ត ។

(១៤៨) គ្រានោះ ព្រះមានព្រះភាគ ត្រាស់នឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ អ្នកចូរទៅ អ្នកចូរសំគាល់កាលដែលគួរទៅ ក្នុងកាលឥឡូវនេះចុះ ។ ព្រះអានន្ទដ៏មានអាយុ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក្រោកចាកអាសនៈ ថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយ អង្គុយទៀបគល់ឈើ ១ ដើមជិតព្រះមានព្រះភាគ ។

(១៣០) អថខោ មារោ បាបិមា អចិរបក្កន្តេ អាយស្មន្តេ អានន្ទេ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ មារោ បាបិមា ភគវន្តំ ឯតទវោច បរិនិព្វាតុទានិ ភន្តេ ភគវា បរិនិព្វាតុ សុគតោ បរិនិព្វានកាលោទានិ ភន្តេ ភគវតោ ភាសិតា ខោ បនេសា ភន្តេ ភគវតា វាចា ន តាវាហំ បាបិម បរិនិព្វាយិស្សាមិ យាវ មេ ភិក្ខូ ន សាវកា ភវិស្សន្តិ វិយត្តា វិនីតា វិសារទប្បត្តា យោគក្ខេមកាមា[១] ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនោ[២] សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខិស្សន្តិ ទេសិស្សន្តិ បញ្ញបេស្សន្តិ បដ្ឋបេស្សន្តិ វិវរិស្សន្តិ វិភជិស្សន្តិ ឧត្តានីករិស្សន្តិ[៣] ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសិស្សន្តីតិ ឯតរហិ ខោ បន ភន្តេ[៤] ភិក្ខូ ភគវតោ សាវកា វិយត្តា វិនីតា វិសារទប្បត្តា យោគក្ខេមកាមា ពហុស្សុតា ធម្មធរា

១ ឱ.ម. យោគក្ខេមា ។ ២ ម. អនុធម្មចារិនោ នត្ថិ ។ ៣ ឱ. ឧត្តានីករិស្សន្តិ ។ ម. ឧត្តានីករិស្សន្តិ ។ ៤ ឱ. សន្តិ ភោ បន ភន្តេ ឯតរហិ ទិស្សន្តិ ។



(១៣០) គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចេញទៅមិនយូរប៉ុន្មាន មារមានចិត្តបាប ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ឋិតនៅក្នុងទីដ៏សមគួរ ។ លុះមារមានចិត្តបាប ឋិតនៅក្នុងទីដ៏សមគួរហើយ ទើបពោលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទ្រង់បរិនិព្វាន ក្នុងកាលឥឡូវនេះ សូមព្រះសុគតបរិនិព្វាន បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ កាលនេះ ជាកាលគួរបរិនិព្វាន របស់ព្រះមានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចំរើន ព្រោះថា ព្រះមានព្រះភាគ បានត្រាស់វាចានេះហើយថា នែ មារមានចិត្តបាប ពួកភិក្ខុជាសាវ័ករបស់តថាគត ដែលឈ្លាសវៃចេះចប់ ទៀតក្លា ប្រាថ្នាការក្សេមចាកយោគៈ ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌ សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីគោរពក្រែង ប្រព្រឹត្តតាមធម៌ដ៏សមគួរ រៀនយកវាទៈនៃអាចារ្យរបស់ខ្លួន ហើយនឹងប្រាប់ សំដែង បញ្ញត្ត តាំងទុក បើកបែក ធ្វើឲ្យរាក់ បាននូវសេចក្តីសង្កត់សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលខ្លួនសង្កត់សង្កិនដោយល្អ សំដែងធម៌ប្រកបដោយបាដិហារ្យ (គ្រឿងនាំ) ទៅមិនមានដរាបណាទេ តថាគតនឹងមិនទាន់បរិនិព្វានដរាបនោះ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ពួកភិក្ខុជាសាវ័ក របស់ព្រះមានព្រះភាគ ឈ្លាសវៃ ចេះចប់ ទៀតក្លា ប្រាថ្នាសេចក្តីក្សេមចាកយោគៈ ជាពហុស្សូត ទ្រទ្រង់ធម៌

ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខន្តិ ទេសេន្តិ បញ្ញបេន្តិ បដ្ឋបេន្តិ វិវរន្តិ វិភជន្តិ ឧត្តានីករោន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេន្តិ បរិនិព្វាតុទានិ ភន្តេ ភគវា បរិនិព្វាតុ សុគតោ បរិនិព្វានកាលោ ទានិ ភន្តេ ភគវតោ ភាសិតា ខោ បនេសា ភន្តេ ភគវតា វាចា ន តាវាហំ បាបិម បរិនិព្វាយិស្សាមិ យាវ មេ ភិក្ខុនិយោ ន សាវិកា ភវិស្សន្តិ វិយត្តា វិនីតា វិសារទប្បត្តា យោគក្ខេមកាមិនិយោ ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនិយោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខិស្សន្តិ ទេសិស្សន្តិ បញ្ញបេស្សន្តិ បដ្ឋបេស្សន្តិ វិវរិស្សន្តិ វិភជិស្សន្តិ ឧត្តានីករិស្សន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសិស្សន្តីតិ ឯតរហិ ខោ បន ភន្តេ[១] ភិក្ខុនិយោ ភគវតោ សាវិកា វិយត្តា វិនីតា វិសារទប្បត្តា

១ ម. សន្តិ ខោ បន ភន្តេ ឯតរហិ ទិស្សន្តិ ។



ប្រតិបត្តិធម៌ ដ៏សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីគោរពក្រែង ប្រព្រឹត្តតាមធម៌ដ៏សមគួរ រៀនយកវាទៈនៃអាចារ្យរបស់ខ្លួនហើយ ប្រាប់ សំដែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ ផ្ចាញសង្កត់សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ច ដែលខ្លួនសង្កត់សង្កិនដោយល្អ ហើយសំដែងធម៌ប្រកបដោយបាដិហារ្យ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគទ្រង់បរិនិព្វាន ក្នុងកាលឥឡូវនេះ សូមព្រះសុគតបរិនិព្វាន បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ កាលនេះជាកាលគួរបរិនិព្វានរបស់ព្រះមានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចំរើន ព្រោះថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ពាក្យនេះហើយថា ម្នាលមារមានបាប ភិក្ខុនីជាសាវិការបស់តថាគត ឈ្លាសវៃ មានបេច ក្លៀវក្លា ប្រាថ្នាសេចក្តីក្សេមចាកយោគៈ ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌ ដ៏សមគួរដល់ធម៌ ប្រតិបត្តិ ដោយសេចក្តីគោរពក្រែង ប្រព្រឹត្តតាមធម៌ដ៏សមគួរ រៀនយកវាទៈនៃអាចារ្យរបស់ខ្លួនហើយនឹងប្រាប់ សំដែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ ផ្ចាញសង្កត់សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលខ្លួន គួរសង្កត់សង្កិនដោយល្អ សំដែងធម៌ប្រកបដោយបាដិហារ្យ នៅមិនទាន់មាន ដរាបណា តថាគតនឹងមិនទាន់បរិនិព្វានដរាបនោះ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ភិក្ខុនី ជាសាវិកា របស់ព្រះមានព្រះភាគ ឈ្លាសវៃ មានបេច ក្លៀវក្លា

យោគក្ខេមកាមិនិយោ ពហុស្សុតា ធម្មធរា ធម្មានុធម្ម-ប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនិយោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខន្តិ ទេសេន្តិ បញ្ញបេន្តិ បដ្ឋបេន្តិ វិវរន្តិ វិភជន្តិ ឧត្តានីករោន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេន្តិ បរិនិព្វាតុទានិ ភន្តេ ភគវា បរិនិព្វាតុ សុគតោ បរិនិព្វានកាលោទានិ ភន្តេ ភគវតោ ភាសិតា ខោ បនេសា ភន្តេ ភគវតា វាចា ន តាវាហំ បាបិម បរិនិព្វា-យិស្សាមិ យាវ មេ ឧបាសកា ន សាវកា ភវិស្សន្តិ វិយត្តា វិនីតា វិសារទប្បត្តា យោគក្ខេមកាមា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចា-រិនោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខិស្សន្តិ ទេសិ-ស្សន្តិ បញ្ញបេស្សន្តិ បដ្ឋបេស្សន្តិ វិវរិស្សន្តិ វិភជិស្សន្តិ ឧត្តានីករិស្សន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គ-ហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសិស្សន្តីតិ សន្តិ ខោ បន ភន្តេ ឧបាសកា ភគវតោ សាវកា



ប្រាថ្នាសេចក្តីក្សេមចាកយោគៈ ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីគោរពក្រែង ប្រព្រឹត្តតាមធម៌ដ៏សមគួរ រៀនយកវាទៈនៃអាចារ្យរបស់ខ្លួនហើយប្រាប់ សំដែង បញ្ញត្ត តាំងទុក បើកបែក ធ្វើឲ្យរាក់ ចាប់សង្កត់សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលខ្លួនសង្កត់សង្កិនដោយល្អ ហើយសំដែងធម៌ ប្រកបដោយបាដិហារ្យ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទ្រង់បរិនិព្វាន ក្នុងកាលឥឡូវនេះ សូមព្រះសុគតបរិនិព្វាន បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ កាលនេះជាកាលគួរបរិនិព្វានរបស់ព្រះមានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចំរើន ព្រោះថា ព្រះមានព្រះភាគទ្រង់ត្រាស់វាចានេះហើយថា នែមារចិត្តបាប ពួកឧ-បាសកជាសាវ័ក របស់តថាគត ឈ្លាសវៃ បានទូន្មាន ក្លៀវក្លា ប្រាថ្នាសេចក្តីក្សេមចាកយោគៈ ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីគោរពក្រែង ប្រព្រឹត្តតាមធម៌ដ៏សមគួរ បានរៀនយកវាទៈនៃអាចារ្យរបស់ខ្លួន ហើយនឹងប្រាប់ សំដែង បញ្ញត្ត តាំងទុក បើកបែក ធ្វើឲ្យរាក់ ចាប់សង្កត់សង្កិនបរប្បវាទដែលកើតឡើងហើយ ឲ្យជាកិច្ចដែលខ្លួនសង្កត់សង្កិនបានដោយល្អ សំដែងធម៌ប្រកបដោយបាដិហារ្យ នៅមិនទាន់មានដរាបណា តថាគតនឹងមិនទាន់បរិនិព្វាន ដរាបនោះ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ពួកឧបាសកជាសាវ័ក របស់ព្រះមានព្រះភាគ

វិយត្តា វិនីតា វិសារទប្បត្តា យោគក្ខេមកាមា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខន្តិ ទេសេន្តិ បញ្ញបេន្តិ បដ្ឋបេន្តិ វិវរន្តិ វិភជន្តិ ឧត្តានីករោន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេន្តិ បរិនិព្វាតុ ទានិ ភន្តេ ភគវា បរិនិព្វាតុ សុគតោ បរិនិព្វានកាលោ ទានិ ភន្តេ ភគវតោ ភាសិតា ខោ បនេសា ភន្តេ ភគវតា វាចា ន តាវាហំ បាបិម បរិនិព្វាយិស្សាមិ យាវ មេ ឧបាសិកា ន សាវិកា ភវិស្សន្តិ វិយត្តា វិនីតា វិសារទប្បត្តា យោគក្ខេមកាមិនិយោ ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនិយោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខិស្សន្តិ ទេសិស្សន្តិ បញ្ញបេស្សន្តិ បដ្ឋបេស្សន្តិ វិវរិស្សន្តិ វិភជិស្សន្តិ ឧត្តានីករិស្សន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេស្សន្តីតិ



ឈ្លាសវៃ បានរបៀប ក្លៀវក្លា ប្រាជ្ញាសេចក្ដីក្សេមចាកយោគៈ ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌ ដ៏សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្ដីគោរពក្រែង ប្រព្រឹត្តតាមធម៌ដ៏សមគួរ បានរៀនយកវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សំដែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ បានសង្កត់សង្កិនបរប្បវាទដែលកើតឡើងហើយ ឲ្យជាកិច្ច ដែលខ្លួនសង្កត់សង្កិនបានដោយល្អ សំដែងធម៌ប្រកបដោយបាដិហារ្យ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ បរិនិព្វានក្នុងកាលឥឡូវនេះ សូមព្រះសុគតបរិនិព្វាន បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ កាលនេះជាកាលគួរបរិនិព្វានរបស់ព្រះមានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចំរើន ព្រោះថាព្រះមានព្រះភាគ ទ្រង់ត្រាស់វាចានេះហើយថា ម្នាលមារចិត្តបាប ពួកឧបាសិកា ជាសាវិការបស់តថាគត ឈ្លាសវៃ បានរបៀប ក្លៀវក្លា ប្រាជ្ញសេចក្ដីក្សេមចាកយោគៈ ទ្រទ្រង់ធម៌ ជាពហុស្សូត ប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្ដីគោរពក្រែង ប្រព្រឹត្តតាមធម៌ដ៏សមគួររៀនយកវាទៈនៃអាចារ្យរបស់ខ្លួន ហើយនឹងប្រាប់ សំដែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ បានសង្កត់សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ច ដែលខ្លួនសង្កត់សង្កិនបានដោយល្អ សំដែងធម៌ប្រកបដោយបាដិហារ្យ ដរាបណា តថាគតនឹងមិនទាន់បរិនិព្វាន ដរាបនោះ

ឯតរហិ ខោ បន ភន្តេ ឧបាសិកា ភគវតោ សាវិកា វិយត្តា វិនីតា វិសារទប្បត្តា យោគក្ខេមកាមិនិយោ ធម្មធរា ពហុស្សុតា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនិយោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខន្តិ ទេសេន្តិ បញ្ញបេន្តិ បដ្ឋបេន្តិ វិវរន្តិ វិភជន្តិ ឧត្តានីករោន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេន្តិ បរិនិព្វាតុទានិ ភន្តេ ភគវា បរិនិព្វាតុ សុគតោ បរិនិព្វានកាលោទានិ ភន្តេ ភគវតោ ភាសិតា ខោ បនេសា ភន្តេ ភគវតា វាចា ន តាវាហំ បាបិម បរិនិព្វាយិស្សាមិ យាវ មេ ឥទំ ព្រហ្មចរិយំ ន ឥទ្ធញ្ច ភវិស្សតិ ផីតញ្ច វិត្ថារិកំ ពាហុជញ្ញំ បុថុភូតំ យាវ ទេវមនុស្សេហិ សុប្បកាសិតន្តិ ឯតរហិ ខោ បន ភន្តេ ភគវតោ ព្រហ្មចរិយំ ឥទ្ធញ្ច ផីតញ្ច វិត្ថារិកំ ពាហុជញ្ញំ បុថុភូតំ យាវ ទេវមនុស្សេហិ សុប្បកាសិតំ(១) បរិនិព្វាតុទានិ ភន្តេ ភគវា

១ ឱ. សុប្បកាសិតន្តិ ។



បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះពួកឧបាសិកាជាសាវិការបស់ព្រះមានព្រះភាគ ឈ្លាសវៃ បានទទួល ទូន្មាន ប្រាជ្ញាសេចក្ដីក្សេមចាកយោគៈ ចេះច្រើន ទ្រទ្រង់ធម៌ ជាពហុស្សូត ប្រព្រឹត្តធម៌ដ៏សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្ដីគោរពក្រែង ប្រតិបត្តិតាមធម៌ដ៏សមគួរ រៀនយកវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សំដែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ បានសង្កត់សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលខ្លួនសង្កត់សង្កិនបានដោយល្អ ហើយសំដែងធម៌ប្រកបដោយបាដិហារ្យ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគបរិនិព្វានក្នុងកាលឥឡូវនេះ សូមព្រះសុគតបរិនិព្វាន បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ កាលនេះ ជាកាលគួរបរិនិព្វានរបស់ព្រះមានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចំរើន ព្រោះថាព្រះមានព្រះភាគទ្រង់ត្រាស់ពាក្យនេះហើយថា ម្នាលមារមានបាប ព្រហ្មចរិយធម៌ របស់តថាគតនេះនៅមិនទាន់ខ្ជាប់ខ្ជួន ផ្សព្វផ្សាយ ទូលាយ ដឹងច្រើនគ្នា ក្រាស់ក្រៃល ដរាបណា តាំងក្នុងទេវតានិងមនុស្ស សំដែងបានដោយប្រពៃ ដរាបណា តថាគតនឹងមិនទាន់បរិនិព្វាន ដរាបនោះ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ព្រហ្មចរិយធម៌ របស់ព្រះមានព្រះភាគ ខ្ជាប់ខ្ជួន ផ្សព្វផ្សាយ ទូលាយ ដឹងច្រើនគ្នា ក្រាស់ក្រៃលហើយ តាំងក្នុងទេវតានិងមនុស្សក៏សំដែងបានដោយប្រពៃ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ សូមព្រះមានព្រះភាគ បរិនិព្វាន

បរិនិព្វាតុ សុគតោ បរិនិព្វានកាលោ ទានិ ភន្តេ ភគវតោតិ ។

(១៣១) ឯវំ វុត្តេ ភគវា មារំ បាបិមន្តំ ឯតទវោច អប្បោស្សុក្កោ ត្វំ បាបិម ហោហិ ន ចិរំ តថាគតស្ស បរិនិព្វានំ ភវិស្សតិ ឥតោ តិណ្ណំ មាសានំ អច្ចយេន តថាគតោ បរិនិព្វាយិស្សតីតិ ។ អថ ខោ ភគវា ចាបាលេ ចេតិយេ[១] សតោ សម្បជានោ អាយុសង្ខារំ ឱស្សជ្ជិ ។ ឱស្សដ្ឋេ ច ភគវតា អាយុសង្ខារេ មហាភូមិចាលោ អហោសិ ភឹសនកោ លោមហំសោ ទេវទុន្ទុភិយោ[២] ច ផលឹសុ ។ អថ ខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

តុលមតុលញ្ច សម្ភវំ
ភវសង្ខារមវស្សជ្ជិ មុនិ
អជ្ឈត្តរតោ សមាហិតោ
អភិន្ទិ កវចមិវត្តសម្ភវន្តិ ។ [៣] សុត្តំ បឋមំ ។

(១៣២) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា

១ ឧ.ម. ចាបាលេ ចេតិយេ ។ ២ ម. ទេវទុន្ទុភិយោ ។ ៣ ឧ.ម. សុត្តំ បឋមំ ។



សូមព្រះសុគត បរិនិព្វាន បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ កាលនេះ ជាកាលគួរបរិនិព្វាន របស់ព្រះមានព្រះភាគហើយ ។

(១៣១) កាលបើមារ ទូលយ៉ាងនេះហើយ ព្រះមានព្រះភាគទ្រង់ត្រាស់តបនឹងមារមានចិត្តបាបថា ម្នាលមារមានចិត្តបាប ចូរអ្នកកុំមានសេចក្តីខ្វល់ខ្វាយចុះ ការបរិនិព្វាន របស់តថាគតមិនយូរប៉ុន្មានទេ អំពីនេះទៅ លុះ ៣ ខែ ទៀតកន្លងទៅនេះ តថាគតនឹងបរិនិព្វាន ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់មានសតិសម្បជញ្ញៈ ដាក់អាយុសង្ខារ នាចាបាលចេតិយ ។ លុះព្រះមានព្រះភាគ ទ្រង់ដាក់អាយុសង្ខារហើយ មហាប្រថពី កក្រើក គួរខ្លាច ព្រឺព្រួចរោម ទាំងស្គរទេវតាលាន់ឮឡើង ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុះហើយ ទើបទ្រង់បន្លឺនូវឧទាននេះ ក្នុងវេលានោះថា

ព្រះពុទ្ធ ជាអ្នកប្រាជ្ញ បានលះបង់កុសលចិត្តដែលគួរថ្លឹងបាននឹងថ្លឹងមិនបានផង កិលេស ជាដែនកើតផង សង្ខារប្រព្រឹត្តទៅ ក្នុងភពផង ទ្រង់ត្រេកអរក្នុងខាងក្នុង មានព្រះហឫទ័យតាំងមាំហើយ បានទំលាយបណ្តាញ គឺកិលេសដែលមានខ្លួន ជាដែនកើត ដូចជាគ្រឿងក្រោះ (របស់ទាហាន) ។ សូត្រទី ១ ។

(១៣២) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ

សាវត្ថិយំ វិហរតិ បុព្វារាមេ មិគារមាតុ បាសាទេ ។ តេន ខោ បន សមយេន ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ ពហិទ្វារកោដ្ឋកេ និសិន្នោ ហោតិ ។ អថ ខោ រាជា បសេនទិ កោសលោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ តេន ខោ បន សមយេន សត្ត ច ជដិលា សត្ត ច និគណ្ឋា សត្ត ច អចេលា សត្ត ច ឯកសាដា សត្ត ច បរិព្វាជកា បរូឡ្ហកច្ឆនខលោមា ខារិវិវិធមាទាយ(១) ភគវតោ អវិទូរេ អតិក្កមន្តិ(២) ។ អទ្ទសា ខោ រាជា បសេនទិ កោសលោ តេ សត្ត ច ជដិលេ សត្ត ច និគណ្ឋេ សត្ត ច អចេលេ សត្ត ច ឯកសាដេ សត្ត ច បរិព្វាជកេ បរូឡ្ហកច្ឆនខលោមេ ខារិវិវិធមាទាយ ភគវតោ អវិទូរេ អតិក្កមន្តេ ទិស្វាន ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា ទក្ខិណជាណុមណ្ឌលំ បឋវិយំ និហន្ត្វា

១ ម. ខារិវិធមាទាយ ។ ២ ឱ. ម. អតិក្កមន្តិ ។



គង់ ក្នុងមិគារមាតុប្រាសាទ ក្នុងបុព្វារាម ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគ ចេញអំពីទីសម្ងំ ក្នុងសាយណ្ហសម័យ ហើយទ្រង់គង់ក្នុងទីខាងក្រៅក្លោងទ្វារ ។ គ្រានោះ ព្រះបាទបសេនទិកោសល ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅគាល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ គង់នៅ ក្នុងទីសមគួរ ។ សម័យនោះឯង ពួកជដិល(១) ៧ នាក់ ពួកនិគ្រន្ថ ៧ នាក់(២) ពួកអចេល ៧ នាក់(៣) ពួកឯកសាដក ៧ នាក់(៤) ពួកបរិព្វាជក ៧ នាក់(៥) សុទ្ធតែមានរោម ក្លៀក ព្រុបព្រុលនឹងក្រចកវែង ៗ នាំយកនូវគ្រឿងបរិក្ខារផ្សេង ៗ ដើរចូលមកក្នុងទីជិតនៃព្រះមានព្រះភាគ ។ ព្រះបាទបសេនទិកោសល ទ្រង់ទតឃើញពួកអ្នកបួសទាំងនោះគឺ ជដិល ៧ នាក់ និគ្រន្ថ ៧ នាក់ អចេល ៧ នាក់ ឯកសាដក ៧ នាក់ បរិព្វាជក ៧ នាក់ សុទ្ធតែមានរោម ក្លៀក ព្រុបព្រុលនឹងក្រចកវែង ៗ នាំយកនូវ គ្រឿងបរិក្ខារផ្សេង ៗ ហើយដើរចូលមកក្នុងទីជិតនៃព្រះមានព្រះភាគ លុះទ្រង់ទតឃើញហើយ ទើបក្រោកចាកអាសនៈ ធ្វើសំពត់ឆៀងស្មាម្ខាង ហើយលុតមណ្ឌលជង្គង់ខាងស្តាំចុះ លើប្រថពី

១ អ្នកបួសក្រងសក់ ធ្វើជាជដា ។ ២ សាវកជាតិនិគ្រន្ថប្រើប្រាស់សំលៀកបំពាក់តិចតួច ។ ៣ អាក្រាតឥតគ្រឿងស្លៀកបំពាក់សោះឡើយ ។ ៤ បុគ្គលកាត់សំពត់ត្រង់ៗ ហើយនឹងបិទបាំង (ខ្លួន) តាមខាងមុខ: ខ្លួនត្រូវមានសំពត់សាដកតែមួយ ។ ៥ ឈ្មោះអ្នកបួសក្រៅពុទ្ធសាសនាដទៃ ។ អដ្ឋកថា ។

យេន តេ សត្ត ច ជដិលា សត្ត ច និគណ្ឋា សត្ត ច អចេលា សត្ត ច ឯកសាដកា សត្ត ច បរិព្វាជកា តេនញ្ជលឹ បណាមេត្វា តិក្ខត្តុំ នាមំ សាវេសិ រាជាហំ ភន្តេ បសេនទិ កោសលោ រាជាហំ ភន្តេ បសេនទិ កោសលោតិ ។ អថ ខោ រាជា បសេនទិ កោសលោ អចិរបក្កន្តេសុ តេសុ សត្តសុ ច ជដិលេសុ សត្តសុ ច និគណ្ឋេសុ សត្តសុ ច អចេលេសុ សត្តសុ ច ឯកសាដកេសុ សត្តសុ ច បរិព្វាជកេសុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ រាជា បសេនទិ កោសលោ ភគវន្តំ ឯតទវោច យេ ច តេ ភន្តេ(១) លោកេ អរហន្តោ វា អរហត្តមគ្គំ វា សមាបន្នា ឯតេ តេសំ អញ្ញតរេតិ ។

[១៣៣] ទុជ្ជានំ ខោ ឯតំ មហារាជ តយា គិហិនា កាមភោគិនា បុត្តសម្ពាធសយនំ អជ្ឈាវសន្តេន កាសិកចន្ទនំ បច្ចនុភោន្តេន មាលាគន្ធវិលេបនំ ធារយន្តេន ជាតរូបរជតំ សាទិយន្តេន ឥមេ វា អរហន្តោ ឥមេ វា អរហត្តមគ្គំ សមាបន្នាតិ ។

១ ឱ. យេ នុ ខោ កេចិ ភន្តេ ។ ម. យេ តេ ភន្តេ ។



ប្រណមអញ្ជលី ចំពោះពួកអ្នកបួសទាំងនោះគឺជដិល ៧ នាក់ និគ្រន្ថ ៧ នាក់ អចេល ៧ នាក់ ឯកសាដក ៧ នាក់ បរិព្វាជក ៧ នាក់នោះ ហើយប្រកាសនាម ( របស់ព្រះអង្គ ) អស់វារៈ ៣ ដងថា បពិត្រលោកដ៏ចំរើន ខ្ញុំជាស្តេចឈ្មោះបសេនទិកោសល បពិត្រលោកដ៏ចំរើន ខ្ញុំជាស្តេចឈ្មោះបសេនទិកោសល ។ គ្រានោះ កាលពួកអ្នកបួសទាំងនោះគឺជដិល ៧ នាក់ និគ្រន្ថ ៧ នាក់ អចេល ៧ នាក់ ឯកសាដក ៧ នាក់បរិព្វាជក ៧ នាក់ ចេញទៅមិនយូរប៉ុន្មាន ទើបព្រះបាទបសេនទិកោសល ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចគង់ក្នុងទីសមគួរ ។ លុះព្រះបាទបសេនទិកោសល ស្តេចគង់នៅក្នុងទីសមគួរហើយ ទើបក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ពួកអ្នកបួសណា ជាព្រះអរហន្ត ឬបានសម្រេចអរហត្តមគ្គក្នុងលោក បណ្តាអ្នកបួសទាំងនោះ ជាព្រះអរហន្តមួយដែរឬ ។

[១៣៣] បពិត្រមហារាជ ដំណើរដែលថា បុគ្គលនេះជាព្រះអរហន្ត ឬបុគ្គលនេះ បានសម្រេចអរហត្តមគ្គនោះ ព្រះអង្គជាគ្រហស្ថ ជាអ្នកបរិភោគកាម គ្រប់គ្រងសយនៈដែលចង្អៀតដោយបុត្រ ប្រើប្រាស់កាសិកព័ស្ត្រ និងលំអិតខ្លឹមចន្ទន៍ ទ្រទ្រង់កម្រងផ្កានិងគ្រឿងក្រអូប គ្រឿងលាបផ្សេងៗ ត្រេកអរចំពោះមាសប្រាក់ នឹងដឹងបាន ដោយក្រលំបាក ។

សំវាសេន ខោ មហារាជ សីលំ វេទិតព្វំ តញ្ច ខោ ទីឃេន អទ្ធុនា ន ឥត្តរេន(១) មនសិការោតា នោ អមនសិការោតា(២) បញ្ញវតា នោ ទុប្បញ្ញេន ។ សំវោហារេន ខោ(៣) មហារាជ សោចេយ្យំ វេទិតព្វំ តញ្ច ខោ ទីឃេន អទ្ធុនា ន ឥត្តរេន មនសិការោតា នោ អមនសិការោតា បញ្ញវតា នោ ទុប្បញ្ញេន ។ អាបទាសុ ខោ មហារាជ ថាមោ វេទិតព្វោ សោ ច ខោ ទីឃេន អទ្ធុនា ន ឥត្តរេន មនសិការោតា នោ អមនសិការោតា បញ្ញវតា នោ ទុប្បញ្ញេន ។ សាកច្ឆាយ ខោ មហារាជ បញ្ញា វេទិតព្វា សា ច ខោ ទីឃេន អទ្ធុនា ន ឥត្តរេន មនសិការោតា នោ អមនសិការោតា បញ្ញវតា នោ ទុប្បញ្ញេនាតិ ។

១ ម.ម. ឥត្តរំ ។ ២ ម.ម. អមនសិការា ។ ៣ ម.ម. សព្វោហារេន ។



បពិត្រមហារាជ សីល ត្រូវបុគ្គលដឹង ដោយការនៅរួមគ្នា សីលនោះឯងតែដឹងបាន ដោយកាលវែង មិនមែនដឹងបាន ដោយកាលបន្តិចបន្តួចទេ កាលធ្វើទុកក្នុងចិត្ត ទើបអាចដឹងបាន កាលបើមិនបានធ្វើទុកក្នុងចិត្ត មិនអាចដឹងបាន អ្នកជាបណ្ឌិត ទើបអាចដឹងបាន ជនពាលមិនអាចដឹងបានទេ ។ បពិត្រមហារាជ សេចក្តីស្អាត ត្រូវបុគ្គលដឹងបាន ដោយការនិយាយទៅរួមគ្នា ទាំងសេចក្តីស្អាតនោះឯង គេដឹងបាន ដោយកាលវែង មិនមែនដឹងដោយកាលបន្តិចបន្តួចទេ កាលធ្វើទុកក្នុងចិត្ត ទើបអាចដឹងបាន កាលបើមិនបានធ្វើទុកក្នុងចិត្ត មិនអាចដឹងបានទេ អ្នកជាបណ្ឌិត ទើបអាចដឹងបាន ជនពាលមិនអាចដឹងបានទេ ។ បពិត្រមហារាជ កំឡាំងញាណ ត្រូវបុគ្គលដឹងបាន ក្នុងវេលាមានអន្តរាយ ទាំងកំឡាំងញាណនោះឯង ត្រូវដឹងដោយកាលវែង មិនមែនដឹងដោយកាលបន្តិចបន្តួចទេ កាលធ្វើទុកក្នុងចិត្ត ទើបអាចដឹងបាន កាលបើមិនបានធ្វើទុកក្នុងចិត្ត មិនអាចដឹងបានទេ អ្នកជាបណ្ឌិត ទើបអាចដឹងបាន ជនពាលមិនអាចដឹងបានទេ ។ បពិត្រមហារាជ បញ្ញា ត្រូវបុគ្គលដឹងបាន ដោយការសាកសួរ ទាំងបញ្ញានោះឯង ត្រូវដឹង ដោយកាលវែង មិនមែនដឹង ដោយកាលបន្តិចបន្តួចទេ កាលធ្វើទុកក្នុងចិត្ត ទើបអាចដឹងបាន កាលបើមិនបានធ្វើទុកក្នុងចិត្ត មិនអាចដឹងបានទេ អ្នកជាបណ្ឌិតទើបអាចដឹងបាន ជនពាលមិនអាចដឹងបានទេ ។

(១៣៦) អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យាវ សុភាសិតមិទំ ភគវតា ទុជ្ជានំ ខោ មហារាជ តយា គិហិនា កាមភោគិនា បុត្តសម្ពាធសយនំ អជ្ឈាវសន្តេន កាសិកចន្ទនំ បច្ចនុភោន្តេន មាលាគន្ធវិលេបនំ ធារយន្តេន ជាតរូបរជតំ សាទិយន្តេន ឥមេ វា អរហន្តោ ឥមេ វា អរហត្តមគ្គំ សមាបន្នាតិ ។ សំវាសេន ខោ មហារាជ សីលំ វេទិតព្វំ តញ្ច ខោ ទីឃេន អទ្ធុនា ន ឥត្តរេន មនសិករោតា នោ អមនសិករោតា បញ្ញវតា នោ ទុប្បញ្ញេន ។ សំវោហារេន ខោ មហារាជ សោចេយ្យំ វេទិតព្វំ តញ្ច ខោ ទីឃេន អទ្ធុនា ន ឥត្តរេន មនសិករោតា នោ អមនសិករោតា បញ្ញវតា នោ ទុប្បញ្ញេន ។ អាបទាសុ ខោ មហារាជ ថាមោ វេទិតព្វោ



(១៣៦) បពិត្រព្រះអង្គដ៏ចំរើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចំរើន ចំឡែកណាស់ ត្រង់ដែលព្រះមានព្រះភាគ សំដែងដោយប្រពៃថា បពិត្រមហារាជ ដំណើរដែលថា បុគ្គលនេះ ជាព្រះអរហន្ត ឬបុគ្គលនេះ បានសម្រេចអរហត្តមគ្គនោះ ព្រះអង្គជាគ្រហស្ថ ជាអ្នកបរិភោគកាមគ្រប់គ្រងសយនៈ ដែលចង្អៀតដោយបុត្រ ប្រើប្រាស់កាសិកពស្ត្រ និងលំអិតខ្លឹមចន្ទន៍ ប្រដាប់កម្រងផ្កា គ្រឿងក្រអូបគ្រឿងលាបផ្សេងៗ ត្រេកអរចំពោះមាស ប្រាក់ ដឹងបានដោយក្រណាស់ ។ បពិត្រមហារាជ សីលត្រូវបុគ្គលដឹងបាន ដោយការនៅរួមគ្នា តាំងសីលនោះឯង គេដឹងបាន ដោយកាលវែង មិនមែនដឹង ដោយកាលបន្តិចបន្តួចទេ កាលកំណត់ក្នុងចិត្ត ទើបដឹងបាន កាលបើមិនកំណត់ក្នុងចិត្ត មិនអាចដឹងបានទេ អ្នកជាបណ្ឌិតទើបអាចដឹងបាន ឯអ្នកពាលមិនអាចដឹងបានទេ ។ បពិត្រមហារាជ សេចក្តីស្អាតត្រូវបុគ្គលដឹងបាន ដោយការនិយាយរឿយៗ តាំងសេចក្តីស្អាតនោះឯង គេដឹង ដោយកាលវែង មិនមែនដឹង ដោយកាលបន្តិចបន្តួចទេ កាលកំណត់ក្នុងចិត្ត ទើបអាចដឹងបាន កាលបើមិនកំណត់ក្នុងចិត្ត មិនអាចដឹងបានទេ អ្នកជាបណ្ឌិត ទើបអាចដឹងបាន ឯអ្នកពាលមិនអាចដឹងបានទេ ។ បពិត្រមហារាជ កំឡាំងញាណ ត្រូវបុគ្គលដឹងបាន ក្នុងវេលាមានអន្តរាយ

សោ ច ហោ ធីយេន អត្ថេន ច ឥន្ទ្រិយេន មនសិការ-
កោតោ ហោ អមនសិការកោតោ បញ្ញាតោ ហោ ទុព្បញ្ញោ ។
សាកច្ឆាយ ហោ មហាភដ បញ្ញា វេមតា សោ ច ហោ
ធីយេន អត្ថេន ច ឥន្ទ្រិយេន មនសិការកោតោ ហោ អមន-
សិការកោតោ បញ្ញាតោ ហោ ទុព្បញ្ញោ ហោតិ ។ ឯវេ ករន្ត
មម បុរិសា ហោក និចរកា ជនបទំ និគមា អាគន្តុ
គេហំ បវេសំ និតិណ្ណំ អហំ បញ្ញា និគមស្សាទំ ឥតានិ
គេ ករន្ត ធំ រជាផល្គំ បកហោត្វា សុគ្គតា សុវិលីត្តា
កាបរិតកោសមស្ស និតាកត្វាសោតា បតាហំ តាម
ក្បាលហិ សមប្បិតា សមន្នាគតា បរិចារិយន្តិ[១] ។
អថខោ គហក ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ
ឧទានំ ឧទានេសិ

ន ភយមេយ្យ សព្ពញ្ញុស្ស បុរិសោ សិយា
ញាត្វា និស្សាយ ធីរេយ្យ ជម្មេន ន វិណ្ណំ ចរេតិ[២] ។
ទុតិយំ[៣] ។

---

១ ឱ.ម. បរិចារិយន្តិ ។ ចារិយន្តិ អន្នុកាយំ កន្សេតិ ។ ២ ម. ជម្មេន វិណ្ណំ ចរតិ ។ ៣ ឱ.ម. ទុតិយន្តិ នត្ថិ ។



ទាំងពីរព្យាករណ៍នោះឯង ត្រូវដឹង ដោយការរំពឹង មិនមែនដឹង ដោយ
ការបន្តិចបន្តួចទេ ការកំណត់ក្នុងចិត្ត ទើបអាចដឹងបាន ការបើមិន
កំណត់ក្នុងចិត្ត មិនងាយដឹងបានទេ ។ បពិត្រមហារាជ បញ្ញា ត្រូវបុគ្គល
ដឹងបាន ដោយការសាកសួរ ទាំងបញ្ញានោះឯង ត្រូវដឹង ដោយការ
រំពឹង មិនមែនដឹង ដោយការបន្តិចបន្តួចទេ ការកំណត់ក្នុងចិត្ត ទើប
អាចដឹងបាន ការបើមិនកំណត់ក្នុងចិត្ត មិនងាយដឹងបានទេ អ្នកជា
បណ្ឌិត ទើបអាចដឹងបាន ជនពាលមិនងាយដឹងបានទេ ។ បពិត្រព្រះ
អង្គដ៏ចំរើន ពួកបុរសរបស់ខ្ញុំព្រះអង្គ ទាំងនុ៎ះស្លៀកដណ្តប់ ដើរត្រាច់ ត្រាច់
ត្រាចរទេស ពួកបុរសទាំងនោះមកក្នុងក្រោយ ខ្ញុំព្រះអង្គនឹងមកត្រូវក្រោ
ពាក់ក្រោយ បពិត្រព្រះអង្គដ៏ចំរើន ម្យ៉ាងទៀត ពួកបុរសទាំងនោះ
យាំប្រាក់បន្សាត់បង់នូវធូលីនិងមន្ទិលនោះចេញ ហើយងូតទឹក លាបស្រ
ឡាបដោយល្អ កោរសក់និងពុកមាត់ ស្លៀកពាក់សំពត់ពណ៌ស ក៏ឆ្អែត
ស្កប់ស្កល់ បម្រើខ្លួនដោយកាមគុណ ៥ ក្រោយនោះ ព្រះមានព្រះ
ភាគ ទ្រង់ជ្រាបសេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា
បុគ្គលមិនគប្បីប្រឹងប្រែង ក្នុងការងារក្នុងទីទាំងពួង បុគ្គលមិនគប្បី
ជាបុរសនៃបុគ្គលដទៃ មិនគប្បីរស់នៅព្រោះអាស្រ័យអ្នកដទៃ មិន
គប្បីប្រព្រឹត្តធម៌ (ដើម្បីលាភ) ដូចការជួញប្រែទេ ។ សូត្រទី ២ ។

[១៣៥] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភគវា អត្តនោ អនេកេ បាបកេ អកុសលេ ធម្មេ បហីនេ បច្ចវេក្ខមានោ និសិន្នោ ហោតិ អនេកេ ច កុសលេ ធម្មេ ភាវនាយ[១] ពារិបូរិគតេ ។ អថខោ ភគវា អត្តនោ អនេកេ បាបកេ អកុសលេ ធម្មេ បហីនេ វិទិត្វា អនេកេ ច កុសលេ ធម្មេ ភាវនាយ ពារិបូរិគតេ តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

អហុ បុព្វេ តទា នាហុ  នាហុ បុព្វេ តទា អហុ
ន ចាហុ ន ច ភវិស្សតិ ន ចេតរហិ វិជ្ជតីតិ ។

តតិយំ[២] ។

[១៣៦] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។

១ ម. ភាវនា ។ ២ ឱ.ម. តតិយសុត្តំ ។



(១៣៥) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគ កំពុងគង់ពិចារណា ពួកអកុសលធម៌ដ៏លាមក ច្រើនប្រការ ដែលទ្រង់លះហើយផង ពួកកុសលធម៌ ច្រើនប្រការ ដែលបរិបូណ៌ដោយការចំរើនផង ។ លុះព្រះមានព្រះភាគ ជ្រាបពួកអកុសល-ធម៌ដ៏លាមក ច្រើនប្រការ ដែលព្រះអង្គ លះហើយផង ពួកកុសលធម៌ច្រើនប្រការ ដែលបរិបូណ៌ ដោយការចំរើនផង ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

ពួកកិលេសមានរាគៈជាដើម ធ្លាប់មានហើយ ក្នុងកាលមុន ពួកកិលេសណាមួយ របស់តថាគត មិនបានមានហើយ ក្នុងខណៈនៃមគ្គញាណនោះទេ អរិយមគ្គមិនធ្លាប់មានហើយ ក្នុងកាលមុន អរិយមគ្គក៏បានមានហើយ ក្នុងកាលនោះ ពួកកិលេសមិនបានមាន ក្នុងកាល (ជាអតីត) ផង មិនមាន ក្នុងកាល ( ជាអនាគត ) ផង មិនមាន ក្នុងកាលជាបច្ចុប្បន្នផង ( ដល់តថាគត ) ។ សូត្រទី ៣ ។

(១៣៦) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។

តេន ខោ បន សមយេន សម្ពហុលា នានាតិត្ថិយា សមណព្រាហ្មណា បរិព្វាជកា សាវត្ថិយំ បដិវសន្តិ(១) នានាទិដ្ឋិកា នានាខន្តិកា នានារុចិកា នានាទិដ្ឋិនិស្សយនិស្សិតា ។ សន្តេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អសស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អន្តវា លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អនន្តវា លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ តំ ជីវំ តំ សរីរំ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អញ្ញំ ជីវំ អញ្ញំ សរីរំ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។

១ ម. សាវត្ថឹ ឧបនិស្សាយ វសន្តិ ។



សម័យនោះឯង ពួកសមណព្រាហ្មណ៍ បរិព្វាជក(១) ច្រើនគ្នា អាស្រ័យនៅក្នុងក្រុងសាវត្ថី មានលទ្ធិផ្សេង ៗ មានទិដ្ឋិផ្សេង ៗ មានសេចក្តីគាប់ចិត្តផ្សេង ៗ មានសេចក្តីចូលចិត្តផ្សេង ៗ អាស្រ័យទិដ្ឋិនិស្ស័យផ្សេង ៗ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា លោកទៀង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា លោកមិនទៀង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា លោកមានទីបំផុត ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា លោកមិនមានទីបំផុត ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ជីវៈនោះ គឺសរីរៈនោះ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ជីវៈដទៃ សរីរៈដទៃ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។

១ សំដៅយកពួកសមណៈមានទិដ្ឋិផ្សេងៗ ដែលប្រព្រឹត្តក្រៅពុទ្ធសាសនា ។ ពួកព្រាហ្មណ៍ មាន [illegible] ។ [illegible] ។ អដ្ឋកថា ។

សន្តេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ
ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃ-
មញ្ញន្តិ ។ សន្តិ បនេកេ សមណព្រាហ្មណា ឯវំ-
វាទិនោ ឯវំទិដ្ឋិនោ ន ហោតិ តថាគតោ បរម្មរណា
ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តេកេ សមណព្រាហ្ម-
ណា ឯវំវាទិនោ ឯវំទិដ្ឋិនោ ហោតិ ច ន ច ហោតិ
តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។
សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិ-
នោ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទ-
មេវ សច្ចំ មោឃមញ្ញន្តិ ។ តេ ភណ្ឌនជាតា កលហ-
ជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា
វិហរន្តិ ឯទិសោ ធម្មោ នេទិសោ ធម្មោ នេទិសោ
ធម្មោ ឯទិសោ ធម្មោតិ ។

(១៣៧) អថខោ សម្ពហុលា ភិក្ខូ បុព្វណ្ហសមយំ និវា-
សេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បាវិសិំសុ ។
សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្ប-
ដិក្កន្តា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា



សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា សត្វ
ស្លាប់ទៅកើតទៀត ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទេ ។
សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា
សត្វស្លាប់ទៅ មិនកើតទៀត ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះ
សូន្យទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាង
នេះថា សត្វស្លាប់ទៅ កើតទៀតក៏មាន មិនកើតទៀតក៏មាន ពាក្យនេះ
ពិត ពាក្យដទៃ ជាពាក្យសោះសូន្យទេ ។ សមណព្រាហ្មណ៍មួយពួក
ទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា សត្វស្លាប់ទៅ កើតទៀត
ក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះពិត ពាក្យដទៃ ជាពាក្យ
សោះសូន្យទេ ។ សមណព្រាហ្មណ៍ទាំងនោះ មានសេចក្តីប្រកួត
ប្រកាន់ ជម្លោះ ទាស់ទែង ចាក់ដោតគ្នានឹងគ្នា ដោយលំពែង គឺមាត់ថា
យ៉ាងនេះជាធម៌ យ៉ាងនេះមិនមែនជាធម៌ យ៉ាងនេះមិនមែនជាធម៌ យ៉ាងនេះជាធម៌ ។

(១៣៧) គ្រានោះ ពួកភិក្ខុច្រើនរូប ស្លៀកស្បង់ប្រដាប់បាត្រចីវរ ក្នុង
បុព្វណ្ហសម័យ ហើយចូលទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថី ។ លុះត្រាច់ទៅ
បិណ្ឌបាត ក្នុងក្រុងសាវត្ថីហើយ ត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលា
ខាងក្រោយភត្ត ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់

ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ ឥធ ភន្តេ សម្ព-ហុលា នានាតិត្ថិយា សមណព្រាហ្មណា បរិព្វាជកា សាវត្ថិយំ បដិវសន្តិ នានាទិដ្ឋិកា នានាខន្តិកា នានារុចិកា នានាទិដ្ឋិនិស្សយនិស្សិតា ។ សន្តេកេ សម-ណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អសស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អន្តវា លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំ-ទិដ្ឋិនោ អនន្តវា លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ តំ ជីវំ តំ សរីរំ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អញ្ញំ ជីវំ អញ្ញំ សរីរំ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។



ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងទីនេះ ពួកសមណព្រាហ្មណ៍បរិព្វាជកច្រើនគ្នា អាស្រ័យនៅ ក្នុងក្រុងសាវត្ថី មានលទ្ធិផ្សេងៗ មានទិដ្ឋិផ្សេងៗ មានសេចក្តីគាប់ចិត្តផ្សេងៗ មានសេចក្តីចូលចិត្តផ្សេងៗ អាស្រ័យទិដ្ឋិនិស្ស័យផ្សេងៗ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា លោកទៀង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា លោកមិនទៀង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា លោកមានទីបំផុត ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា លោកមិនមានទីបំផុត ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ជីវិតនោះ គឺសរីរៈនោះ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ជីវិតដទៃ សរីរៈដទៃ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។

សន្តេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ តេ ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរន្តិ ឯទិសោ ធម្មោ នេទិសោ ធម្មោ នេទិសោ ធម្មោ ឯទិសោ ធម្មោតិ ។ អញ្ញតិត្ថិយា ភិក្ខវេ អន្ធា អចក្ខុកា អត្ថំ ន ជានន្តិ អនត្ថំ ន ជានន្តិ ធម្មំ ន ជានន្តិ អធម្មំ ន ជានន្តិ ។ តេ អត្ថំ អជានន្តា អនត្ថំ អជានន្តា ធម្មំ អជានន្តា អធម្មំ អជានន្តា ភណ្ឌនជាតា កលហជាតា វិវាទាបន្នា



សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា សត្វស្លាប់ទៅ កើតទៀត ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា សត្វស្លាប់ទៅ មិនកើតទៀត ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា សត្វស្លាប់ទៅ កើតទៀតក៏មាន មិនកើតទៀតក៏មាន ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនេះពិត ពាក្យដទៃជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍ទាំងនោះ មានសេចក្ដីប្រកួតប្រកាន់ ជម្លោះ ទាស់ទែង ចាក់ដោតគ្នានឹងគ្នា ដោយលំពែងគឺមាត់ថា យ៉ាងនេះធម៌ យ៉ាងនេះមិនមែនធម៌ យ៉ាងនេះមិនមែនធម៌ យ៉ាងនេះធម៌ ។ ម្នាលភិក្ខុទាំងឡាយ ពួកអន្យតិរ្ថិយបរិព្វាជក ដូចជាមនុស្សខ្វាក់ មើលមិនឃើញ មិនស្គាល់ប្រយោជន៍ មិនស្គាល់សភាវៈមិនមែនប្រយោជន៍ មិនស្គាល់ធម៌ មិនស្គាល់អធម៌ ។ អន្យតិរ្ថិយបរិព្វាជកទាំងនោះ កាលបើមិនស្គាល់ប្រយោជន៍ មិនស្គាល់សភាវៈមិនមែនប្រយោជន៍ មិនស្គាល់ធម៌ មិនស្គាល់អធម៌ ហើយក៏មានសេចក្ដីប្រកួតប្រកាន់ ជម្លោះ ទាស់ទែង

អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរន្តិ ឯទិសោ ធម្មោ នេទិសោ ធម្មោ នេទិសោ ធម្មោ ឯទិសោ ធម្មោតិ ។

(១៣៨) ភូតបុព្វំ ភិក្ខវេ ឥមិស្សា យេវ សាវត្ថិយា[១] អញ្ញតរោ រាជា អហោសិ ។ អថខោ ភិក្ខវេ សោ រាជា អញ្ញតរំ បុរិសំ អាមន្តេសិ ឯហិ ត្វំ អម្ភោ បុរិស យាវតិកា សាវត្ថិយា[២] ជច្ចន្ធា តេ សព្វេ ឯកជ្ឈំ សន្និបាតេហីតិ ។ ឯវំ ទេវាតិ ខោ ភិក្ខវេ សោ បុរិសោ តស្ស រញ្ញោ បដិស្សុត្វា យាវតិកា សាវត្ថិយា[៣] ជច្ចន្ធា តេ សព្វេ គហេត្វា យេន សោ រាជា តេនុបសង្កមិ ឧបសង្កមិត្វា តំ រាជានំ ឯតទវោច សន្និបាតិតា ខោ តេ ទេវ យាវតិកា សាវត្ថិយា[៤] ជច្ចន្ធាតិ ។ តេនហិ ភណេ ជច្ចន្ធានំ ហត្ថឹ ទស្សេហីតិ ។ ឯវំ ទេវាតិ ខោ ភិក្ខវេ សោ បុរិសោ តស្ស រញ្ញោ បដិស្សុត្វា ជច្ចន្ធានំ ហត្ថឹ ទស្សេសិ[៥] ឯកច្ចានំ ជច្ចន្ធានំ ហត្ថិស្ស សីសំ ទស្សេសិ ឯទិសោ ជច្ចន្ធា ហត្ថីតិ ។

១-២-៣-៤ ឱ. សាវត្ថិយំ ។ ៥ ម. ធម្មវេ ទិស្សោ ស. ហត្ថឹ បាណិ ទស្សេតិ ។



ចាក់ដោតគ្នានឹងគ្នា ដោយលំពែងគឺមាត់ថា យ៉ាងនេះជាធម៌ យ៉ាងនេះមិនមែនធម៌ យ៉ាងនេះមិនមែនធម៌ យ៉ាងនេះជាធម៌ ។

(១៣៨) ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយ មានព្រះរាជាអង្គមួយក្នុងក្រុងសាវត្ថីនេះ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះរាជានោះ ត្រាស់ហៅបុរសម្នាក់មកត្រាស់បង្គាប់ថា នែបុរសដ៏ចំរើន ចូរអ្នកមកនាយ ចូរអ្នកទៅប្រមូលពួកមនុស្សខ្វាក់ ពីកំណើត ដែលមាន ក្នុងក្រុងសាវត្ថីទាំងប៉ុន្មាន ឲ្យមកជួបជុំគ្នាទាំងអស់ ក្នុងទីជាមួយគ្នា ។ ម្នាលភិក្ខុទាំងឡាយ បុរសនោះទទួលព្រះរាជបញ្ជា របស់ព្រះរាជានោះថា ព្រះករុណាថ្លៃវិសេសហើយ ប្រមូលពួកមនុស្សខ្វាក់ ពីកំណើត ដែលមាន ក្នុងក្រុងសាវត្ថី ទាំងប៉ុន្មាន មកទាំងអស់ ហើយចូលគាល់ព្រះរាជាអង្គនោះ លុះចូលទៅដល់ក្រាបបង្គំទូលព្រះរាជាអង្គនោះថា បពិត្រព្រះសម្មតិទេព ពួកមនុស្សខ្វាក់ពីកំណើត ដែលមានក្នុងក្រុងសាវត្ថីទាំងប៉ុន្មាន ខ្ញុំព្រះអង្គបានឲ្យមកជួបជុំគ្នាទាំងអស់ហើយ ។ ព្រះរាជាត្រាស់ថា ម្នាលនាយ បើដូច្នោះ ចូរអ្នកបង្ហាញដំរីដល់ពួកមនុស្សខ្វាក់ពីកំណើត ។ ម្នាលភិក្ខុទាំងឡាយ បុរសនោះទទួលព្រះរាជបញ្ជារបស់ព្រះរាជានោះថា ព្រះករុណាថ្លៃវិសេស ហើយក៏បង្ហាញដំរីដល់មនុស្សខ្វាក់ ពីកំណើតទាំងឡាយនឹងបង្ហាញក្បាលដំរី ដល់ពួកមនុស្សខ្វាក់ពីកំណើតខ្លះថា នែមនុស្សខ្វាក់ ពីកំណើតទាំងឡាយ ដំរីបែបនេះ ។

ឯកច្ចានំ ជច្ចន្ធានំ ហត្ថិស្ស កណ្ណំ ទស្សេសិ ឯទិសោ ជច្ចន្ធា ហត្ថីតិ ។ ឯកច្ចានំ ជច្ចន្ធានំ ហត្ថិស្ស ទន្តំ ទស្សេសិ ឯទិសោ ជច្ចន្ធា ហត្ថីតិ ។ ឯកច្ចានំ ជច្ចន្ធានំ ហត្ថិស្ស សោណ្ឌំ ទស្សេសិ ឯទិសោ ជច្ចន្ធា ហត្ថីតិ ។ ឯកច្ចានំ ជច្ចន្ធានំ ហត្ថិស្ស កាយំ ទស្សេសិ ឯទិសោ ជច្ចន្ធា ហត្ថីតិ ។ ឯកច្ចានំ ជច្ចន្ធានំ ហត្ថិស្ស បាទំ ទស្សេសិ ឯទិសោ ជច្ចន្ធា ហត្ថីតិ ។ ឯកច្ចានំ ជច្ចន្ធានំ ហត្ថិស្ស បិដ្ឋឹ ទស្សេសិ ឯទិសោ ជច្ចន្ធា ហត្ថីតិ ។ ឯកច្ចានំ ជច្ចន្ធានំ ហត្ថិស្ស នង្គុដ្ឋំ ទស្សេសិ ឯទិសោ ជច្ចន្ធា ហត្ថីតិ ។ ឯកច្ចានំ ជច្ចន្ធានំ ហត្ថិស្ស វាលធឹ ទស្សេសិ ឯទិសោ ជច្ចន្ធា ហត្ថីតិ ។ អថខោ ភិក្ខវេ សោ បុរិសោ ជច្ចន្ធានំ ហត្ថឹ ទស្សេត្វា យេន សោ រាជា តេនុបសង្កមិ ឧបសង្កមិត្វា តំ រាជានំ ឯតទវោច ទិដ្ឋោ ខោ តេហិ ទេវ ជច្ចន្ធេហិ ហត្ថី យស្សទានិ កាលំ មញ្ញសីតិ[1] ។ អថខោ ភិក្ខវេ សោ រាជា

[1] ម. ម. មញ្ញសីតិ ។



បង្ហាញត្រចៀកដំរី ដល់ពួកមនុស្សខ្វាក់ ពីកំណើតខ្លះថា នែមនុស្សខ្វាក់ពីកំណើតទាំងឡាយ ដំរីបែបនេះ ។ បង្ហាញភ្លុកដំរី ដល់ពួកមនុស្សខ្វាក់ពីកំណើតខ្លះថា នែមនុស្សខ្វាក់ ពីកំណើតទាំងឡាយ ដំរីបែបនេះ ។ បង្ហាញប្រមោយដំរី ដល់ពួកមនុស្សខ្វាក់ ពីកំណើតខ្លះថា នែមនុស្សខ្វាក់ ពីកំណើតទាំងឡាយ ដំរីបែបនេះ ។ បង្ហាញខ្លួនដំរី ដល់ពួកមនុស្សខ្វាក់ ពីកំណើតខ្លះថា នែមនុស្សខ្វាក់ ពីកំណើតទាំងឡាយ ដំរីបែបនេះ ។ បង្ហាញជើងដំរី ដល់ពួកមនុស្សខ្វាក់ ពីកំណើតខ្លះថា នែមនុស្សខ្វាក់ ពីកំណើតទាំងឡាយ ដំរីបែបនេះ ។ បង្ហាញខ្នងដំរី ដល់ពួកមនុស្សខ្វាក់ ពីកំណើតខ្លះថា នែមនុស្សខ្វាក់ ពីកំណើតទាំងឡាយ ដំរីបែបនេះ ។ បង្ហាញកន្ទុយដំរី ដល់ពួកមនុស្សខ្វាក់ពីកំណើតខ្លះថា នែមនុស្សខ្វាក់ ពីកំណើតទាំងឡាយ ដំរីបែបនេះ ។ បង្ហាញរោមកន្ទុយដំរី ដល់ពួកមនុស្សខ្វាក់ ពីកំណើតខ្លះថា នែមនុស្សខ្វាក់ ពីកំណើតទាំងឡាយ ដំរីបែបនេះ ។ ម្នាលភិក្ខុទាំងឡាយ លុះបុរសនោះបង្ហាញដំរី ដល់ពួកមនុស្សខ្វាក់ ពីកំណើតរួចហើយ ក៏ចូលទៅគាល់ព្រះរាជាអង្គនោះ លុះចូលទៅដល់ ក្រាបបង្គំទូលព្រះរាជាអង្គនោះថា បពិត្រព្រះសម្មតិទេព មនុស្សខ្វាក់ ពីកំណើតទាំងនោះ បានឃើញដំរីច្បាស់លាស់ហើយ សូមព្រះអង្គសំគាល់កាលគួរនឹងស្តេចទៅ ក្នុងកាលឥឡូវនេះចុះ ។ ម្នាលភិក្ខុទាំងឡាយ ឯព្រះរាជាអង្គនោះ

យេន តេ ជច្ចន្ធា តេនុបសង្កមិ ឧបសង្កមិត្វា តេ ជច្ចន្ធេ ឯតទវោច ទិដ្ឋោ ភោ ជច្ចន្ធា ហត្ថីតិ ។ ឯវំ ទេវាតិ ។ ទិដ្ឋោ ទេវ ហត្ថីតិ វទេថ ជច្ចន្ធា កីទិសោ ហត្ថីតិ ។ យេហិ ភិក្ខវេ ជច្ចន្ធេហិ ហត្ថិស្ស សីសំ ទិដ្ឋំ អហោសិ តេ ឯវមាហំសុ ឯទិសោ ទេវ ហត្ថី សេយ្យថាបិ កុម្ភោតិ ។ យេហិ ភិក្ខវេ ជច្ចន្ធេហិ ហត្ថិស្ស កណ្ណោ ទិដ្ឋោ អហោសិ តេ ឯវមាហំសុ ឯទិសោ ទេវ ហត្ថី សេយ្យថាបិ សុប្បោតិ ។ យេហិ ភិក្ខវេ ជច្ចន្ធេហិ ហត្ថិស្ស ទន្តោ ទិដ្ឋោ អហោសិ តេ ឯវមាហំសុ ឯទិសោ ទេវ ហត្ថី សេយ្យថាបិ ផាលោតិ ។ យេហិ ភិក្ខវេ ជច្ចន្ធេហិ ហត្ថិស្ស សោណ្ឌោ ទិដ្ឋោ អហោសិ តេ ឯវមាហំសុ ឯទិសោ ទេវ ហត្ថី សេយ្យថាបិ នង្គលីសាតិ ។



ទ្រង់ចូលទៅរកមនុស្សខ្វាក់ ពីកំណើតទាំងនោះ លុះចូលទៅដល់ ត្រាស់ព្រះរាជឱង្ការទៅនឹងមនុស្សខ្វាក់ ពីកំណើតទាំងនោះថា នែមនុស្សខ្វាក់ពីកំណើតទាំងឡាយ អ្នកទាំងឡាយ បានឃើញដំរីហើយឬ ។ ពួកមនុស្សខ្វាក់ពីកំណើត ទើបតបព្រះរាជឱង្ការថា ព្រះករុណាវិសេស ។ ព្រះរាជាត្រាស់ថា នែមនុស្សខ្វាក់ ពីកំណើតទាំងឡាយ អ្នកទាំងឡាយ និយាយថា ដំរី អ្នកទាំងឡាយបានឃើញហើយ តើដំរីដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សខ្វាក់ពីកំណើតណា ដែលបានឃើញក្បាលដំរី មនុស្សទាំងនោះ និយាយយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ដំរីនេះដូចក្អម ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សខ្វាក់ ពីកំណើតណា ដែលបានឃើញស្លឹកត្រចៀកដំរី មនុស្សទាំងនោះ និយាយយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ដំរីនេះដូចចង្អេរ ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សខ្វាក់ពីកំណើតណា ដែលបានឃើញភ្លុកដំរី មនុស្សទាំងនោះនិយាយយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ដំរីនេះដូចផាល(១) ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សខ្វាក់ ពីកំណើតណា ដែលបានឃើញប្រមោយដំរី មនុស្សទាំងនោះនិយាយយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ដំរីនេះដូចយាមនង្គ័ល ។

១ ត្រង់នេះ អ្នកប្រាជ្ញខ្លះប្រែ ថាចបកាប់ ឬ គ្រឿងសម្រាប់ភ្ជួរដី តាមលំនាំព្រៀប ធ្វើផាល ។

យេហិ ភិក្ខវេ ជច្ចន្ធេហិ ហត្ថិស្ស កាយោ ទិដ្ឋោ អហោសិ តេ ឯវមាហំសុ ឯទិសោ ទេវ ហត្ថី សេយ្យថាបិ កោដ្ឋោតិ ។ យេហិ ភិក្ខវេ ជច្ចន្ធេហិ ហត្ថិស្ស បាទោ ទិដ្ឋោ អហោសិ តេ ឯវមាហំសុ ឯទិសោ ទេវ ហត្ថី សេយ្យថាបិ ថូណោតិ ។ យេហិ ភិក្ខវេ ជច្ចន្ធេហិ ហត្ថិស្ស បិដ្ឋិ ទិដ្ឋា អហោសិ តេ ឯវមាហំសុ ឯទិសោ ទេវ ហត្ថី សេយ្យថាបិ ឧទុក្ខលោតិ ។ យេហិ ភិក្ខវេ ជច្ចន្ធេហិ ហត្ថិស្ស នង្គុដ្ឋំ ទិដ្ឋំ អហោសិ តេ ឯវមាហំសុ ឯទិសោ ទេវ ហត្ថី សេយ្យថាបិ មុសលោតិ ។ យេហិ ភិក្ខវេ ជច្ចន្ធេហិ ហត្ថិស្ស វាលធិ ទិដ្ឋោ អហោសិ តេ ឯវមាហំសុ ឯទិសោ ទេវ ហត្ថី សេយ្យថាបិ សម្មជ្ជនីតិ ។ តេ ឯទិសោ ហត្ថី នេទិសោ ហត្ថី នេទិសោ ហត្ថី ឯទិសោ ហត្ថីតិ អញ្ញមញ្ញំ មុដ្ឋីហិ សំយុជ្ឈឹសុ(១) ។ តេន ច បន ភិក្ខវេ សោ រាជា អត្តមនោ អហោសិ ។ ឯវមេវ ខោ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា អន្ធា អចក្ខុកា អត្ថំ ន ជានន្តិ អនត្ថំ ន ជានន្តិ ធម្មំ ន ជានន្តិ អធម្មំ ន ជានន្តិ

១ ម. សំយុជ្ជឹសុ ។



ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សខ្វាក់ ពីកំណើតណា ដែលបានឃើញខ្លួនដំរី មនុស្សទាំងនោះ និយាយយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ដំរីនេះ ដូចជាកញ្ច្រែ ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សខ្វាក់ ពីកំណើតណា ដែលបានឃើញជើងដំរី មនុស្សទាំងនោះ និយាយយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ដំរីនេះ ដូចសសរ ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សខ្វាក់ ពីកំណើតណា ដែលបានឃើញខ្នងដំរី មនុស្សទាំងនោះនិយាយយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ដំរីនេះដូចត្បាល់ក្ដឿង ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សខ្វាក់ ពីកំណើតណា ដែលបានឃើញកន្ទុយដំរី មនុស្សទាំងនោះ និយាយយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ដំរីនេះ ដូចអង្រែ ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សខ្វាក់ ពីកំណើតណា ដែលបានឃើញរោមកន្ទុយដំរី មនុស្សទាំងនោះនិយាយយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ដំរីនេះ ដូចអំបោស ។ មនុស្សខ្វាក់ពីកំណើតទាំងនោះ ក៏ដាល់គប់គ្នានឹងក្ដាប់ថា បែបនេះដំរី បែបនេះមិនមែនដំរីទេ បែបនេះមិនមែនដំរីបែបនេះទើបហៅថា ដំរី ។ ម្នាលភិក្ខុទាំងឡាយ ព្រះរាជាអង្គនោះ មានព្រះរាជហឫទ័យត្រេកអរដោយហេតុនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកអន្យតិរ្ថិយបរិព្វាជក ដូចជាមនុស្សខ្វាក់ មើលមិនឃើញ មិនស្គាល់ប្រយោជន៍ មិនស្គាល់សភាវៈមិនមែនប្រយោជន៍ មិនស្គាល់ធម៌ មិនស្គាល់អធម៌យ៉ាងនេះ

តេ អញ្ញំ អជានន្តា អនត្ថំ អជានន្តា ធម្មំ អជានន្តា អធម្មំ អជានន្តា ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរន្តិ ឯទិសោ ធម្មោ នេទិសោ ធម្មោ នេទិសោ ធម្មោ ឯទិសោ ធម្មោតិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

ឥមេសុ កិរ សជ្ជន្តិ ឯកេ សមណព្រាហ្មណា
វិគ្គយ្ហ នំ វិវទន្តិ ជនា ឯកង្គទស្សិនោតិ(១) ។

ចតុត្ថំ(២) ។

(១៣៩) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សម្ពហុលា នានាតិត្ថិយា សមណព្រាហ្មណា បរិព្វាជកា សាវត្ថិយំ បដិវសន្តិ នានាទិដ្ឋិកា នានាខន្តិកា នានារុចិកា នានាទិដ្ឋិនិស្សយនិស្សិតា ។ សន្តេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សស្សតោ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។



កាលបើ អន្ធទាំងឡាយ បរិព្វាជកទាំងនោះ មិនស្គាល់ប្រយោជន៍ មិនស្គាល់សភាវៈមិនមែនប្រយោជន៍ មិនស្គាល់ធម៌ មិនស្គាល់អធម៌ ហើយក៏មានសេចក្ដីប្រកួតប្រកាន់ជម្លោះទាស់ទែង ចាក់ដោតគ្នានឹងគ្នា ដោយលំពែងគឺមាត់ថា យ៉ាងនេះជាធម៌ យ៉ាងនេះ មិនមែនធម៌ យ៉ាងនេះ មិនមែនធម៌ យ៉ាងនេះជាធម៌ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្ដីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

សមណព្រាហ្មណ៍មួយពួក តែងជាប់ក្នុងទិដ្ឋិ ដែលជាគ្រឿងអាស្រ័យទាំងនេះ ពួកជនអ្នកឃើញនូវអង្គៈតែមួយ ៗ ទើបទាស់ទែង ជជែកគ្នា ព្រោះអាស្រ័យនូវទិដ្ឋិនិស្ស័យនោះ ។ សូត្រទី ៤ ។

(១៣៩) ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ពួកសមណព្រាហ្មណ៍ បរិព្វាជក ច្រើនគ្នា អាស្រ័យនៅក្នុងក្រុងសាវត្ថី មានលទ្ធិផ្សេង ៗ មានទិដ្ឋិផ្សេង ៗ មានសេចក្ដីគាប់ចិត្តផ្សេង ៗ មានសេចក្ដីចូលចិត្តផ្សេង ៗ អាស្រ័យទិដ្ឋិនិស្ស័យផ្សេង ៗ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្ដី លោកក្ដី ទៀង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។

សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អសស្សតោ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សស្សតោ ច អសស្សតោ ច អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ នេវ សស្សតោ នាសស្សតោ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សយង្កតោ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ បរង្កតោ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សយង្កតោ ច បរង្កតោ ច អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អសយង្ការោ ច អបរង្ការោ ច អធិច្ចសមុប្បន្នោ អត្តា ច លោកោ ច



សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មិនទៀង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី ទៀងខ្លះ មិនទៀងខ្លះ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី ទៀងក៏មិនមែន មិនទៀងក៏មិនមែន ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណមួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី ធ្វើដោយខ្លួនឯង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី អ្នកដទៃធ្វើ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី ធ្វើដោយខ្លួនឯងខ្លះ អ្នកដទៃធ្វើខ្លះ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី ធ្វើដោយខ្លួនឯងក៏មិនមែន អ្នកដទៃធ្វើក៏មិនមែន អាស្រ័យបច្ច័យកើតឡើង

ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តេកេ សមណ-
ព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សស្សតំ សុខទុក្ខំ
អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។
សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ
អសស្សតំ សុខទុក្ខំ អត្តា ច លោកោ ច ឥទមេវ សច្ចំ
មោឃមញ្ញន្តិ ។ សន្តេកេ សមណព្រាហ្មណា ឯវំវាទិ-
នោ ឯវំទិដ្ឋិនោ សស្សតញ្ច អសស្សតញ្ច សុខទុក្ខំ អត្តា
ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តិ បនេ-
កេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ នេវ
សស្សតំ នាសស្សតំ សុខទុក្ខំ អត្តា ច លោកោ ច ឥទ-
មេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តេកេ សមណព្រាហ្មណា
ឯវំវាទិនោ ឯវំទិដ្ឋិនោ សយំកតំ សុខទុក្ខំ អត្តា ច
លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តិ បនេកេ
សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ បរំកតំ សុខ-
ទុក្ខំ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។



ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍
មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី
មានសុខនិងទុក្ខ ទៀង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យ
ទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិ
យ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខនិងទុក្ខ មិនទៀងទេ ពាក្យនេះពិត
ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មាន
វាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខនិងទុក្ខ
ទៀងផង មិនទៀងផង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។
សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា
ខ្លួនក្តី លោកក្តី មានសុខនិងទុក្ខ ទៀងក៏មិនមែន មិនទៀងក៏មិនមែន
ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណ-
ព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី
លោកក្តី មានសុខនិងទុក្ខ ធ្វើដោយខ្លួនឯង ពាក្យនេះពិត ពាក្យដទៃ
ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មាន
វាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខនិងទុក្ខ
ព្រោះអ្នកដទៃធ្វើ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។

សន្តេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សយង្កតញ្ច បរង្កតញ្ច សុខទុក្ខំ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អសយង្ការំ ច អបរង្ការំ ច អធិច្ចសមុប្បន្នំ សុខទុក្ខំ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ តេ ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរន្តិ ឯទិសោ ធម្មោ នេទិសោ ធម្មោ នេទិសោ ធម្មោ ឯទិសោ ធម្មោតិ ។

(១៦០) អថខោ សម្ពហុលា ភិក្ខូ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បាវិសិំសុ ។ សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តា យេន ភគវា តេនុបសង្កមិំសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិំសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ ឥធ ភន្តេ សម្ពហុលា នានាតិត្ថិយា សមណព្រាហ្មណា បរិព្វាជកា សាវត្ថិយំ បដិវសន្តិ នានាទិដ្ឋិកា



សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខនិងទុក្ខ ធ្វើដោយខ្លួនឯងខ្លះ អ្នកដទៃធ្វើខ្លះ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខនិងទុក្ខ ធ្វើដោយខ្លួនឯងក៏មិនមែន អ្នកដទៃធ្វើក៏មិនមែន អាស្រ័យបច្ច័យកើតឡើង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍ទាំងនោះ មានសេចក្តីប្រកួតប្រកាន់ ជាឈ្លោះ ទាស់ទែង ចាក់ដោតគ្នានឹងគ្នា ដោយលំពែងគឺមាត់ថា យ៉ាងនេះ ធម៌ យ៉ាងនេះ មិនមែនធម៌ យ៉ាងនេះ មិនមែនធម៌ យ៉ាងនេះ ធម៌ ។

(១៦០) គ្រានោះ ពួកភិក្ខុច្រើនរូប ស្លៀកស្បង់ប្រដាប់បាត្រចីវរ ក្នុងវេលាបុព្វណ្ហសម័យ ហើយចូលទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថី ។ លុះភិក្ខុទាំងនោះ ត្រាច់ទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថី ត្រឡប់អំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្ត ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងទីនេះ ពួកសមណព្រាហ្មណ៍បរិព្វាជកច្រើនគ្នា អាស្រ័យនៅ ក្នុងក្រុងសាវត្ថី មានលទ្ធិផ្សេងៗ មានទិដ្ឋិផ្សេង ៗ

នានាទិដ្ឋិកា នានាខន្តិកា នានារុចិកា នានាទិដ្ឋិនិស្សយនិស្សិតា ។ សន្តេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សស្សតោ លោកោ(១) ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ បេ ។ តេ ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរន្តិ ឯទិសោ ធម្មោ នេទិសោ ធម្មោ នេទិសោ ធម្មោ ឯទិសោ ធម្មោតិ ។ អញ្ញតិត្ថិយា ភិក្ខវេ បរិព្វាជកា អន្ធា អចក្ខុកា អត្ថំ ន ជានន្តិ អនត្ថំ ន ជានន្តិ ធម្មំ ន ជានន្តិ អធម្មំ ន ជានន្តិ ។ តេ អត្ថំ អជានន្តា អនត្ថំ អជានន្តា ធម្មំ អជានន្តា អធម្មំ អជានន្តា ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរន្តិ ឯទិសោ ធម្មោ នេទិសោ ធម្មោ នេទិសោ ធម្មោ ឯទិសោ ធម្មោតិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

ឥមេសុ កិរ សជ្ជន្តិ ឯកេ សមណព្រាហ្មណា
អន្តរា(២) វ វិសីទន្តិ អប្បត្វាវ តមោគធន្តិ ។ បញ្ចមំ ។(៣)

១ ម. សស្សតោ អត្តា ច លោកោ ច ។ ២ ម. អ ។ ៣ ម.ឧ. បញ្ចមំ សុត្តំ ។



មានសេចក្តីគាប់ចិត្តផ្សេងៗ មានសេចក្តីចូលចិត្តផ្សេងៗ អាស្រ័យទិដ្ឋិនិស្ស័យផ្សេងៗ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា លោកទៀង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ បេ ។ សមណព្រាហ្មណ៍ទាំងនោះ មានសេចក្តីប្រកួតប្រកាន់ ជម្លោះ ទាស់ទែង ពាក់ដោតគ្នានឹងគ្នា ដោយលំពែងគឺមាត់ថា យ៉ាងនេះជាធម៌ យ៉ាងនេះមិនមែនធម៌ យ៉ាងនេះមិនមែនធម៌ យ៉ាងនេះជាធម៌ ។ ម្នាលភិក្ខុទាំងឡាយ ពួកអន្យតិរ្ថិយ បរិព្វាជក ដូចជាមនុស្សខ្វាក់ មើលមិនឃើញ មិនស្គាល់ប្រយោជន៍ មិនស្គាល់សភាវៈមិនមែនប្រយោជន៍ មិនស្គាល់ធម៌ មិនស្គាល់អធម៌ កាលបើ អន្យតិរ្ថិយទាំងនោះ មិនស្គាល់ប្រយោជន៍ មិនស្គាល់សភាវៈ មិនមែនប្រយោជន៍ មិនស្គាល់ធម៌ មិនស្គាល់អធម៌ ហើយក៏មានសេចក្តីប្រកួតប្រកាន់ ជម្លោះ ទាស់ទែង ពាក់ដោតគ្នានឹងគ្នា ដោយលំពែងគឺមាត់ថា យ៉ាងនេះជាធម៌ យ៉ាងនេះមិនមែនធម៌ យ៉ាងនេះមិនមែនធម៌ យ៉ាងនេះជាធម៌ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

សមណព្រាហ្មណ៍ទាំងឡាយ មួយពួក តែងជាប់ចំពាក់ ក្នុងទិដ្ឋិ
និស្ស័យទាំងនេះ មិនទាន់ដល់ព្រះនិព្វាន ជាទីពឹងនោះទេ
រមែងលិចចុះ ក្នុងកណ្តាលនៃអន្លង់គឺសង្សារ ។ សូត្រ ទី ៥ ។

(១៤០) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សម្ពហុលា នានាតិត្ថិយា សមណព្រាហ្មណា បរិព្វាជកា សាវត្ថិយំ បដិវសន្តិ នានាទិដ្ឋិកា នានាខន្តិកា នានារុចិកា នានាទិដ្ឋិនិស្សយនិស្សិតា ។ សន្តេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សស្សតោ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អសស្សតោ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សស្សតោ ច អសស្សតោ ច អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ នេវសស្សតោ នាសស្សតោ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សយំកតោ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។



(១៤០) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ពួកសមណព្រាហ្មណ៍បរិព្វាជក ច្រើនគ្នា អាស្រ័យនៅ ក្នុងក្រុងសាវត្ថី មានលទ្ធិផ្សេងៗ មានទិដ្ឋិផ្សេងៗ មានសេចក្តីគាប់ចិត្តផ្សេងៗ មានសេចក្តីចូលចិត្តផ្សេងៗ អាស្រ័យទិដ្ឋិនិស្ស័យផ្សេងៗ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី ទៀង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មិនទៀងទេ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី ទៀងផង មិនទៀងផង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី ទៀងក៏មិនមែន មិនទៀងក៏មិនមែន ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី ធ្វើដោយខ្លួនឯង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។

សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ បរង្កតោ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សយង្កតោ ច បរង្កតោ ច អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អសយង្ការោ ច អបរង្ការោ ច អធិច្ចសមុប្បន្នោ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សស្សតំ សុខទុក្ខំ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អសស្សតំ សុខទុក្ខំ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សស្សតំ ច អសស្សតំ ច សុខទុក្ខំ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ



សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី អ្នកដទៃធ្វើ ពាក្យនេះពិត ពាក្យដទៃជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី ធ្វើដោយខ្លួនឯងខ្លះ អ្នកដទៃធ្វើខ្លះ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី ធ្វើខ្លួនឯងក៏មិនមែន អ្នកដទៃធ្វើក៏មិនមែន អាស្រ័យបច្ច័យកើតឡើង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខនឹងទុក្ខទៀង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខនឹងទុក្ខមិនទៀង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខនឹងទុក្ខទៀងខ្លះ មិនទៀងខ្លះ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ

ឯវំទិដ្ឋិនោ នេវ សស្សតំ នាសស្សតំ សុខទុក្ខំ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សយង្កតំ សុខទុក្ខំ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃ-មញ្ញន្តិ ។ សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ បរង្កតំ សុខទុក្ខំ អត្តា ច លោកោ-ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តេកេ សមណ-ព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សយង្កតំ ច បរង្កតំ ច សុខទុក្ខំ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អសយង្ការំ ច អបរង្ការំ ច អធិ-ច្ចសមុប្បន្នំ សុខទុក្ខំ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ តេ ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរន្តិ ឯទិសោ ធម្មោ នេទិសោ ធម្មោ នេទិសោ ធម្មោ ឯទិសោ ធម្មោតិ ។



មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខនិងទុក្ខ ទៀងក៏មិនមែន មិនទៀងក៏មិនមែន ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខនិងទុក្ខ ធ្វើដោយខ្លួនឯង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខនិងទុក្ខ អ្នកដទៃធ្វើ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខនិងទុក្ខ ធ្វើដោយខ្លួនឯងខ្លះ អ្នកដទៃធ្វើខ្លះ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខនិងទុក្ខ ធ្វើដោយខ្លួនឯងក៏មិនមែន អ្នកដទៃធ្វើក៏មិនមែន អាស្រ័យបច្ច័យកើតឡើង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍ទាំងនោះ មានសេចក្តីប្រកួតប្រកាន់ ជម្លោះ ទាស់ទែង ចាក់ដោតគ្នានឹងគ្នា ដោយលំពែងគឺមាត់ថា យ៉ាងនេះជាធម៌ យ៉ាងនេះមិនមែនជាធម៌ យ៉ាងនេះមិនមែនជាធម៌ យ៉ាងនេះជាធម៌ ។

(១៦៦) អថខោ សម្ពហុលា ភិក្ខូ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បាវិសឹសុ ។ សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតបដិក្កន្តា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ ឥធ ភន្តេ សម្ពហុលា នានាតិត្ថិយា សមណព្រាហ្មណា បរិព្វាជកា សាវត្ថិយំ បដិវសន្តិ នានាទិដ្ឋិកា នានាខន្តិកា នានារុចិកា នានាទិដ្ឋិនិស្សយនិស្សិតា ។ សន្តេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សស្សតោ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អសស្សតោ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សស្សតោ ច អសស្សតោ ច អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ



(១៦៦) គ្រានោះ ភិក្ខុច្រើនរូប ស្លៀកស្បង់ប្រដាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថី ។ លុះត្រាច់ទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថី ត្រឡប់អំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្តហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយ ក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះអង្គុយ ក្នុងទីសមគួរហើយ ទើបក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងទីឯណោះ ពួកសមណព្រាហ្មណ៍បរិព្វាជក ច្រើនគ្នា អាស្រ័យនៅ ក្នុងក្រុងសាវត្ថី មានលទ្ធិផ្សេង ៗ មានទិដ្ឋិផ្សេង ៗ មានសេចក្តីគាប់ចិត្តផ្សេង ៗ មានសេចក្តីចូលចិត្តផ្សេង ៗ អាស្រ័យទិដ្ឋិនិស្ស័យផ្សេង ៗ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី ទៀង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មិនទៀង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី ទៀងផង មិនទៀងផង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា

នេវ សស្សតោ នាសស្សតោ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សយង្កតោ បរង្កតោ សយង្កតោ ច បរង្កតោ ច អសយង្ការោ ច អបរង្ការោ ច អធិច្ចសមុប្បន្នោ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សស្សតំ សុខទុក្ខំ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អសស្សតំ សុខទុក្ខំ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សស្សតំ ច អសស្សតំ ច សុខទុក្ខំ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ នេវ សស្សតំ នាសស្សតំ សុខទុក្ខំ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ



ខ្លួនក្តី លោកក្តី ទៀងក៏មិនមែន មិនទៀងក៏មិនមែន ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី ធ្វើដោយខ្លួនឯង អ្នកដទៃធ្វើ ធ្វើដោយខ្លួនឯងផង អ្នកដទៃធ្វើផង មិនធ្វើដោយខ្លួនឯងផង អ្នកដទៃមិនធ្វើផង អាស្រ័យបច្ច័យកើតឡើង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខនិងទុក្ខ ទៀង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខនិងទុក្ខ មិនទៀង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខនិងទុក្ខ ទៀងផង មិនទៀងផង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខនិងទុក្ខ ទៀងក៏មិនមែន មិនទៀងក៏មិនមែន ពាក្យនេះពិត ពាក្យដទៃជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា

សយង្កតំ សុខទុក្ខំ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ បរង្កតំ សុខទុក្ខំ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សយង្កតំ ច បរង្កតំ ច សុខទុក្ខំ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តិ បនេកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សយង្ការំ ច បរង្ការំ ច អធិច្ចស-មុប្បន្នំ សុខទុក្ខំ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ តេ ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរន្តិ ឯទិសោ ធម្មោ នេទិសោ ធម្មោ នេទិសោ ធម្មោ ឯទិសោ ធម្មោតិ ។ អញ្ញតិត្ថិយា ភិក្ខវេ បរិព្វាជកា អន្ធា អចក្ខុកា អត្ថំ ន ជានន្តិ អនត្ថំ ន ជានន្តិ ធម្មំ ន ជានន្តិ អធម្មំ ន ជានន្តិ ។ តេ អត្ថំ អជានន្តា អនត្ថំ អជានន្តា ធម្មំ អជានន្តា អធម្មំ អជានន្តា ភណ្ឌនជាតា



ខ្លួនក្តី លោកក្តី មានសុខនឹងទុក្ខ ធ្វើដោយខ្លួនឯង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខនឹងទុក្ខ អ្នកដទៃធ្វើ ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណ-ព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខនឹងទុក្ខ ធ្វើដោយខ្លួនឯងផង អ្នកដទៃធ្វើផង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនក្តី លោកក្តី មានសុខនឹងទុក្ខ ធ្វើដោយខ្លួនឯងក៏មិន អ្នកដទៃធ្វើក៏មិន ឥតស្រ័យបច្ច័យកើតឡើង ពាក្យនេះពិត ពាក្យដទៃ ជាពាក្យសោះសូន្យទទេ ។ សមណព្រាហ្មណ៍ទាំងនោះ មានសេចក្តីប្រកួតប្រកាន់ ជម្លោះ ទាស់ទែង ចាក់ដោតគ្នានឹងគ្នា ដោយលំពែងគឺមាត់ថា យ៉ាងនេះជាធម៌ យ៉ាងនេះមិនមែនធម៌ យ៉ាងនេះមិនមែនធម៌ យ៉ាងនេះជាធម៌ ។ ម្នាលភិក្ខុទាំងឡាយ ពួកអន្យតិរ្ថិយ បរិព្វាជក ជាមនុស្សខ្វាក់ មើលមិនឃើញ មិនស្គាល់ប្រយោជន៍ មិនស្គាល់សភាវៈមិនមែនប្រយោជន៍ មិនស្គាល់ធម៌ មិនស្គាល់អធម៌ កាលពួកសមណ-ព្រាហ្មណ៍ទាំងនោះ មិនស្គាល់ប្រយោជន៍ មិនស្គាល់សភាវៈមិនមែនប្រ-យោជន៍ មិនស្គាល់ធម៌ មិនស្គាល់អធម៌ហើយ មានសេចក្តីប្រកួតប្រកាន់

កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរន្តិ ឯទិសោ ធម្មោ នេទិសោ ធម្មោ នេទិសោ ធម្មោ ឯទិសោ ធម្មោតិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

អហង្ការបសុតាយំ បជា បរង្ការូបសំហិតា
ឯតទេកេ នាព្ភញ្ញំសុ ន នំ សល្លន្តិ អទ្ទសុំ(១)
ឯតញ្ច សល្លំ បដិកច្ច(២) បស្សតោ
អហំ ករោមីតិ ន តស្ស ហោតិ
បរោ ករោតីតិ ន តស្ស ហោតិ ។
មានុបេតា អយំ បជា មានគន្ថា(៣) មានវិនិពទ្ធា
ទិដ្ឋីសុ សារម្ភកថា(៤) សំសារំ នាតិវត្តតីតិ ។ ឆដ្ឋំ(៥) ។

(១៤៣) ឯវមេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា សុភូតិ ភគវតោ អវិទូរេ និសិន្នោ ហោតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ អវិតក្កំ សមាធិំ សមាបជ្ជិត្វា ។

១ ម. អទ្ទសំ ។ ២ ម. បដិកច្ច ។ ៣ ម. មានគន្ថា ។ ៤ ម.ម. ទិដ្ឋិសារម្ភកថា ។ ៥ ម.ម. ឆដ្ឋំ សុត្តំ ។



ជម្លោះ ទាស់ទែង ចាក់ដោតគ្នានឹងគ្នា ដោយលំពែងគឺមាត់ថា ធម៌យ៉ាងនេះជាធម៌ ធម៌យ៉ាងនេះមិនមែនធម៌ ធម៌យ៉ាងនេះមិនមែនធម៌ ធម៌យ៉ាងនេះជាធម៌ ។ លុះព្រះមានព្រះភាគ ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

ពួកសមណព្រាហ្មណ៍មួយពួក មិនបានស្គាល់ប្រជុំគឺ នៃទិដ្ឋិនេះថា ពួកសត្វនេះ ខ្វល់ខ្វាយ ដោយអហង្ការទិដ្ឋិ ប្រកបដោយបរង្ការទិដ្ឋិ តាំងមិនឃើញទិដ្ឋិនោះ ថាជាព្រួញ ។ កាលបុគ្គលកាស្រយព្រួញគឺទិដ្ឋិនុ៎ះ ហើយពិចារណាថា អាត្មាអញធ្វើ (ឬអាត្មាយេមក) ដូច្នេះក៏ ទៅវិញ កាលបុគ្គលនោះ កាស្រយព្រួញគឺទិដ្ឋិនុ៎ះ ពិចារណាឃើញថា អ្នកដទៃធ្វើ (ឬអាត្មាយេមក) ដូច្នេះក៏ទៅវិញ ។ ពួកសត្វនេះ ប្រកបដោយមានះ ជាប់ស្រេះដោយមានះ ចងភ្ជាប់ដោយមានះ ធ្វើការផ្គុំញ្ញើមក្នុងទិដ្ឋិទាំងឡាយ មិនអាចកន្លងនូវសង្សារបានឡើយ ។ សូត្រទី៦ ។

(១៤៣) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះសុភូតិដ៏មានអាយុ អង្គុយពែនភ្នែន តាំងកាយត្រង់ ចូលកាន់សមាធិ ដែលមិនមានវិតក្កៈ ក្នុងទីជិតនៃព្រះមានព្រះភាគ ។

អទ្ទសា ខោ ភគវា អាយស្មន្តំ សុភូតឹ អវិទូរេ និសិន្នំ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ អវិតក្កំ សមាធឹ សមាបន្នំ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

យស្ស វិតក្កា វិធូបិតា
អជ្ឈត្តំ សុវិកប្បិតា អសេសា
តំ សង្គមតិច្ច អរូបសញ្ញី
ចតុយោគាតិគតោ ន ជាតឹ[១]មេតីតិ ។ សត្តមំ[២] ។

[១៦៦] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន រាជគហេ ទ្វេ បូគា អញ្ញតរិស្សា គណិកាយ សារត្តា ហោន្តិ បដិពទ្ធចិត្តា ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ បាណីហិបិ ឧបក្កមន្តិ លេឌ្ឌូហិបិ ឧបក្កមន្តិ ទណ្ឌេហិបិ ឧបក្កមន្តិ សត្ថេហិបិ ឧបក្កមន្តិ តេ តត្ថ មរណម្បិ និគច្ឆន្តិ មរណមត្តម្បិ ទុក្ខំ ។ អថខោ សម្ពហុលា ភិក្ខូ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ រាជគហំ បិណ្ឌាយ បាវិសិំសុ

១ ម. ជាតុមេតីតិ ។ ២ ឱ.ម. សត្តមំ ខន្ធំ ។



ព្រះមានព្រះភាគ បានទតឃើញព្រះសុភូតិដ៏មានអាយុ គង់ពែនភ្នែន តាំងកាយត្រង់ ចូលកាន់សមាធិ ដែលមិនមានវិតក្កៈ ក្នុងទីជិត ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្ដីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

វិតក្កៈទាំងឡាយ ដែលបុគ្គលណា កំចាត់បង់ហើយ សម្រេចហើយដោយប្រពៃ ក្នុងសន្ដានឥតមានសេសសល់ មិនសំគាល់រូប ព្រោះកន្លងការជាប់ជំពាក់នោះ បុគ្គលនោះ មិនដល់នូវជាតិ ព្រោះបានកន្លងយោគៈទាំង ៤ ហើយ ។ សូត្រទី ៧ ។

[១៦៦] ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង មានមនុស្សពីរពួក ជាអ្នកមានគណៈប្រាកដ មានចិត្តប្រតិព័ទ្ធនឹងស្រីផ្កាមាសម្នាក់ មានសេចក្ដីប្រកួតប្រកាន់ ជាឈ្លោះ ទាស់ទែង ប្រហារគ្នានឹងគ្នា ដោយដៃទាំងឡាយខ្លះ ប្រហារដោយដុំដីទាំងឡាយខ្លះ ប្រហារដោយដំបងទាំងឡាយខ្លះ ប្រហារដោយគ្រឿងសស្ត្រាទាំងឡាយខ្លះ ក្នុងទីនោះ មនុស្សទាំងនោះ ដល់សេចក្ដីស្លាប់ខ្លះ ដល់សេចក្ដីទុក្ខស្មើស្លាប់ខ្លះ ។ លំដាប់នោះ ពួកភិក្ខុច្រើនរូប ស្លៀកស្បង់ប្រដាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅបិណ្ឌបាត ក្នុងក្រុងរាជគ្រឹះ

រាជគហេ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ ឥធ ភន្តេ រាជគហេ ទ្វេ បូគា អញ្ញតរិស្សា គណិកាយ សារត្តា បដិពទ្ធចិត្តា ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ បាណីហិបិ ឧបក្កមន្តិ លេឌ្ឌូហិបិ ឧបក្កមន្តិ ទណ្ឌេហិបិ ឧបក្កមន្តិ សត្ថេហិបិ ឧបក្កមន្តិ តេ តត្ថ មរណម្បិ និគច្ឆន្តិ មរណមត្តម្បិ ទុក្ខន្តិ ។ អថ ខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

យញ្ច បត្តំ យញ្ច បត្តព្វំ ឧភយមេតំ រជានុកិណ្ណំ
អាតុរស្សានុសិក្ខតោ[១]

យេ ច[២] សិក្ខាសារា សីលព្វតំ ជីវិតំ ព្រហ្មចរិយំ ឧបដ្ឋានសារា[៣] អយមេកោ អន្តោ ។ យេ ច ឯវំវាទិនោ នត្ថិ កាមេសុ ទោសោតិ អយំ ទុតិយោ អន្តោ ។

១ ឱ. អាតុរស្សានុសិក្ខិតោ ។ ២ ឱ. ក ។ ៣ ឱ. សីលព្វតជីវិតព្រហ្មចរិយុបដ្ឋានសារា ។



លុះត្រាច់ទៅបិណ្ឌបាត ក្នុងក្រុងរាជគ្រឹះ ហើយត្រឡប់ពីបិណ្ឌបាតវិញ ក្នុងវេលាខាងក្រោយភត្ត ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគហើយអង្គុយ ក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះអង្គុយ ក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងក្រុងរាជគ្រឹះនេះ មានមនុស្សពីរពួក មានតម្រេក មានចិត្តប្រតិពទ្ធនឹងស្រីពេស្យាម្នាក់ មានសេចក្ដីប្រកួតប្រកាន់ ជំលោះទាស់ទែង ប្រហារគ្នានឹងគ្នា ដោយដៃទាំងឡាយខ្លះ ប្រហារដោយដុំដីទាំងឡាយខ្លះ ប្រហារដោយដំបងទាំងឡាយខ្លះ ប្រហារដោយគ្រឿងសស្ត្រាទាំងឡាយខ្លះ ក្នុងទីនោះ មនុស្សទាំងនោះ ដល់សេចក្ដីស្លាប់ខ្លះ ដល់សេចក្ដីទុក្ខស្មើស្លាប់ខ្លះ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្ដីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

ការណ៍ណា ដែលបុគ្គលដល់ហើយក្ដី ការណ៍ណា ដែលបុគ្គលនឹងដល់ក្ដី ការណ៍ទាំងពីរនុ៎ះ រាយពាយ ដោយធូលីគឺរាគាទិក្កិលេស របស់បុគ្គលអ្នកក្ដៅក្រហាយ កាលសិក្សារឿយ ៗ ជនទាំងឡាយណា មានការសិក្សាជាខ្លឹម សីលព្វត ជីវិត ព្រហ្មចរិយៈ គឺការបម្រើជាខ្លឹម នេះជាផ្លូវលាមកទី ១ ។ ជនទាំងឡាយណា មានវាទៈយ៉ាងនេះថា ទោសក្នុងកាមទាំងឡាយមិនមានទេ នេះជាផ្លូវលាមក ទី ២ ។

ឥច្ចេតេ ឧភោ អន្តា កដសិវឌ្ឍនា កដសិយោ ទិដ្ឋឹ វឌ្ឍន្តិ ។ ឯតេ តេ ឧភោ អន្តេ អនភិញ្ញាយ ឱលីយន្តិ ឯកេ អតិធាវន្តិ ឯកេ ។ យេ ច ខោ តេ អភិញ្ញាយ តត្រ ច នាហេសុំ តេន ច ន អមញ្ញិំសុ វដ្ដំ តេសំ នត្ថិ បញ្ញាបនាយាតិ ។ អដ្ឋមំ(១) ។

[១៦៨] ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភគវា រត្តន្ធការតិមិសាយំ អព្ភោកាសេ និសិន្នោ ហោតិ តេលបជ្ជោតេសុ ឈាយមានេសុ ។ តេន ខោ បន សមយេន សម្ពហុលា អធិបាតកា តេសុ តេលបជ្ជោតេសុ អាបាតបរិបាតំ អនយំ អាបជ្ជន្តិ ព្យសនំ អាបជ្ជន្តិ អនយព្យសនំ អាបជ្ជន្តិ ។ អទ្ទសា ខោ ភគវា តេ សម្ពហុលេ អធិបាតកេ តេសុ តេលបជ្ជោតេសុ អាបាតបរិបាតំ អនយំ អាបជ្ជមានេ ព្យសនំ អាបជ្ជមានេ អនយព្យសនំ អាបជ្ជមានេ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

១ ឱ.ម. អដ្ឋមំ សុត្តំ ។



ផ្លូវលាមកទាំងពីរនុ៎ះ តែងចំរើន ដោយព្រៃស្មសាន គឺតណ្ហា និងអវិជ្ជា
ព្រៃស្មសានគឺតណ្ហានិងអវិជ្ជា តែងធ្វើទិដ្ឋិឲ្យចំរើន ដោយប្រការដូច្នេះ ៗ
សមណព្រាហ្មណ៍មួយពួក តែងរួញរា មួយពួកតែងស្ទុះទៅក្រៃលែង
ព្រោះមិនដឹងនូវផ្លូវលាមកទាំងពីរនុ៎ះ ៗ ពួកបុគ្គលទាំងឡាយណា ដឹងច្បាស់នូវផ្លូវលា-
មកទាំងពីរហើយ ពួកបុគ្គលទាំងនោះ មិនធ្លាក់ចុះក្នុងផ្លូវលាមកទាំង
ពីរនុ៎ះ ទាំងមិនសំគាល់ខ្លួន ដោយការលះផ្លូវលាមកនោះឡើយ
វដ្ដៈរបស់ពួកបុគ្គលទាំងនោះ មិនមានដើម្បីបញ្ញត្តិទេ ៗ សូត្រទី ៨ ៗ

[១៦៨] ខ្ញុំបានស្តាប់មកយ៉ាងនេះ ៗ សម័យមួយ ព្រះមានព្រះភាគ
ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ៗ
សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់ក្នុងទីវាល ក្នុងរាត្រីងងឹតទឹក
ភ្លៀង មានគេអុជប្រទីបប្រេងថ្វាយ ៗ សម័យនោះឯង សត្វមមាចជាច្រើន
ហើរធ្លាក់ ក្នុងប្រទីបប្រេងទាំងនោះ ដល់សេចក្តីមិនចំរើនក៏មាន ដល់
សេចក្តីវិនាសក៏មាន ដល់សេចក្តីមិនចំរើន និងសេចក្តីវិនាស ៗ ព្រះ
មានព្រះភាគ ទ្រង់បានឃើញសត្វមមាចច្រើនទាំងនោះ ហើរធ្លាក់
ក្នុងប្រទីបប្រេងទាំងនោះ ដល់សេចក្តីមិនចំរើន ដល់សេចក្តីវិនាស ដល់
សេចក្តីមិនចំរើន និងសេចក្តីវិនាស ៗ លុះព្រះមានព្រះភាគ បានជ្រាប
ច្បាស់ សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺ ឧទាននេះ ក្នុងវេលានោះថា

ឧបាតិធាវន្តិ ន សារមេន្តិ

នវំ នវំ ពន្ធនំ ព្រូហយន្តិ

បតន្តិ បជ្ជោតមិវាធិបាតា

ទិដ្ឋេ សុតេ ឥតិហេកេ និវិដ្ឋាតិ (១) ។

(១៦៦) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច យាវកីវញ្ច ភន្តេ តថាគតា លោកេ នុប្បជ្ជន្តិ អរហន្តោ សម្មាសម្ពុទ្ធា តាវ អញ្ញតិត្ថិយា បរិព្វាជកា សក្កតា ហោន្តិ គរុកតា មានិតា បូជិតា អបចិតា លាភិនោ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ យតោ ច ខោ ភន្តេ តថាគតា លោកេ ឧប្បជ្ជន្តិ អរហន្តោ សម្មាសម្ពុទ្ធា អថខោ អញ្ញតិត្ថិយា បរិព្វាជកា អសក្កតា ហោន្តិ អគរុកតា អមានិតា

១ ម.ម. សាមន្តំ ។



សមណព្រាហ្មណ៍ពួកខ្លះ មិនចាត់បាននូវធម៌ដ៏ជាសារធម៌ តែងរំលងហួស ហើយប្រកាន់ខ្ជាប់ តែងញ៉ាំងចំណងថ្មីៗ គឺតណ្ហានិងទិដ្ឋិ ឲ្យចំរើន ហើយធ្លាក់(ក្នុងភ្លើងគឺកិលេស) ដូចជាសត្វមមាច ដែលធ្លាក់ចូល ក្នុងអណ្តាតភ្លើង សមណព្រាហ្មណ៍មួយពួក ប្រកាន់ចាំ ក្នុងរបស់ដែលឃើញ និងសំឡេងដែលខ្លួនឮហើយ ។ សូត្រទី ៩ ។

(១៦៦) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយ ក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយ ក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះតថាគតទាំងឡាយ ជាអរហន្តសម្មាសម្ពុទ្ធ មិនទាន់កើត ក្នុងលោក ដរាបណា ពួកអន្យតិរ្ថិយ បរិព្វាជក មានគេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ជាអ្នកបានចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ដរាបនោះ បពិត្រព្រះអង្គដ៏ចម្រើន កាលណាបើ ព្រះតថាគតទាំងឡាយ ជាអរហន្តសម្មាសម្ពុទ្ធ កើតឡើង ក្នុងលោក ពួកអន្យតិរ្ថិយ បរិព្វាជក ក៏លែងមិនមានគេធ្វើសក្ការៈ មិនមានគេគោរព មិនមានគេរាប់អាន

អបូជិតា អនបចិតា ន លាភិនោ ចីវរបិណ្ឌបាតសេនា-
សនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ភគវា ចេទានិ[១]
ភន្តេ សក្កតោ ហោតិ គរុកតោ មានិតោ បូជិតោ
អបចិតោ លាភី ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ច-
យភេសជ្ជបរិក្ខារានំ ភិក្ខុសង្ឃោ ចាតិ ។ ឯវមេតំ
អានន្ទ ឯវមេតំ អានន្ទ យាវកីវញ្ច អានន្ទ តថាគតា
លោកេ នុប្បជ្ជន្តិ អរហន្តោ សម្មាសម្ពុទ្ធា តាវ អញ្ញ-
តិត្ថិយា បរិព្វាជកា សក្កតា ហោន្តិ គរុកតា មានិតា
បូជិតា អបចិតា លាភិនោ ចីវរបិណ្ឌបាតសេនាសនគិ-
លានប្បច្ចយភេសជ្ជបរិក្ខារានំ យតោ ច ខោ អានន្ទ
តថាគតា លោកេ ឧប្បជ្ជន្តិ អរហន្តោ សម្មាសម្ពុទ្ធា
អថ ខោ អញ្ញតិត្ថិយា បរិព្វាជកា អសក្កតា ហោន្តិ
អគរុកតា អមានិតា អបូជិតា អនបចិតា ន លាភិនោ
ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខា-
រានំ តថាគតោ ចេទានិ សក្កតោ ហោតិ គរុ-
កតោ មានិតោ បូជិតោ អបចិតោ លាភី ចីវរ-
បិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ



មិនមានគេបូជា មិនមានគេកោតក្រែង ជាទីមិនបានចីវរ បិណ្ឌបាត សេ-
នាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ក្នុងកាលនោះឯង បពិត្រព្រះអង្គ
ដ៏ចំរើន ឥឡូវនេះ ព្រះមានព្រះភាគ ព្រះអង្គមានគេធ្វើសក្ការៈ គោរព
រាប់អាន បូជា កោតក្រែង បានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្ប-
ច្ចយភេសជ្ជបរិក្ខារ ទាំងភិក្ខុសង្ឃ (ក៏ដូច្នោះដែរ) ។ ម្នាលអានន្ទ ដំណើរ
នុ៎ះយ៉ាងនេះហើយ ម្នាលអានន្ទ ដំណើរនុ៎ះយ៉ាងនេះហើយ ម្នាលអានន្ទ
ព្រះតថាគតទាំងឡាយ ជាអរហន្តសម្មាសម្ពុទ្ធ មិនទាន់កើតឡើង ក្នុង
លោក ដរាបណា ពួកអន្យតិរ្ថិយ បរិព្វាជកទាំងឡាយ ដែលគេធ្វើសក្ការៈ
គោរព រាប់អាន បូជា កោតក្រែង ជាអ្នកបានចីវរ បិណ្ឌបាត សេនា-
សនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ដរាបនោះដែរ ម្នាលអានន្ទ កាលណា
បើ ព្រះតថាគតទាំងឡាយ ជាអរហន្តសម្មាសម្ពុទ្ធ កើតឡើង ក្នុងលោក
ពួកអន្យតិរ្ថិយ បរិព្វាជក មិនមានគេធ្វើសក្ការៈ មិនមានគេគោរព មិន
មានគេរាប់អាន មិនមានគេបូជា មិនមានគេកោតក្រែង ជាទីមិនបានចីវរ
បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ក្នុងកាលនោះឡើយ
ឥឡូវនេះ តថាគត ដែលគេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង
ជាអ្នកបានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ

ភិក្ខុសង្ឃោ ចាតិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

ឱភាសតិ តាវ សោ កិមិ យាវ ន ឧណ្ណមតិ[1] បភង្ករោ
[2]
វេរោចនម្ហិ ឧគ្គតេ ហតប្បភោ ហោតិ ន ចាបិ ភាសតិ ។
ឯវំ ឱភាសិតមេវ តក្កិកានំ[3]
យាវ សម្មាសម្ពុទ្ធា លោកេ នុប្បជ្ជន្តិ
ន តក្កិកា[4] សុជ្ឈន្តិ ន ចាបិ សាវកា
ទុទ្ទិដ្ឋី ន ទុក្ខា បមុច្ចរេតិ[5] ។ ទសមំ[6] ។

ជច្ចន្ធវគ្គោ ឆដ្ឋោ ។

## តស្សុទ្ទានំ

អាយុសមោស្សជ្ជនំ បដិសល្លា
អាហុ តយោ ច តិត្ថិយា
[7]
សត្តមមាហុ សុភូតិ
គណិកា ឧបាតិ ធាវេ
ឧប្បជ្ជន្តិ ច តេ ទសាតិ ។

---

១ ឱ. ឧម្មតិ ។ ម. ឧណ្ណមេ ។ ២ ឱ. សព្វរោចនម្ហិ ។ ៣ ឱ. តក្កិកានំ ។ ៤ ឱ. ... ៥ ឱ.ម. បមុច្ចរេ ។ ៦ ... ៧ ម. ...



តាំងកំពុងសន្ស ( កំពុងភ្លឺដែរ ) ។ លុះព្រះអាទិត្យព្រះការ ចុះព្រោប ច្បាស់សេចក្តីនុះហើយ ទើបប្រេតីដទុំទាំងនេះ គួរលោះចោះចាំ ព្រះតថាគតមិនទាន់កើតឡើងដរាបណា សត្វអ្នកកណ្តាលកិតតែតោះ ភ្លឺរៀង ដរាបនោះ កាលបើព្រះតថាគតកើតឡើង សត្វអ្នកកណ្តាលតែតែក គំណាបសូត្រ ភាគ្គី មិនភ្លឺរៀងទេ ។ ព្រះសម្មាសម្ពុទ្ធទាំងឡាយ មិនទាន់កើតឡើងក្នុងលោក ដរាបណា សេចក្តីភ្លឺរៀងរបស់ពួកតក្កិយ (តក្កិក) ដរាបនោះ តក្កិយទាំងឡាយ ហៅថាមិនស្អាត ទាំងពួកសាវ័ក ក៏មានទិដ្ឋិអាក្រក់ មិនស្អាត មិនរួចចាកទុក្ខបានឡើយ ។ សូត្រទី ១០ ។

ចប់ ជច្ចន្ធវគ្គ ទី ៦ ។

## ឧទ្ទានក្នុងវគ្គនោះគឺ

និយាយអំពីការដាក់អាយុសង្ខារ ១ អំពីព្រះមានព្រះភាគទ្រង់ចេញអំពីទីស្ងាត់ ១ អំពីការពិចារណាសោះហើយ ១ អំពីពួកសមណព្រាហ្មណ៍រាល់សាសន៍ដទៃ ការស្រែកយំ ១ អំពីពួកសមណព្រាហ្មណ៍ មានលទ្ធិផ្សេងៗ ១ អំពីការជាប់នៅក្នុងទិដ្ឋិទាំងនោះ ១ អំពីសុភូតិ ជាគំរប់ប្រាំពីរ ១ អំពីការប្រកែកអរ ក្នុងស្រីផ្កាមាស ១ អំពីសត្វមមាច តំបងព្រៃចូល ១ អំពីព្រះតថាគតទាំងឡាយ កើតឡើងក្នុងលោក ជាគំរប់ដប់ ។

# ឧទានេ សត្តមោ ចូឡវគ្គោ

(១៤៧) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា សារីបុត្តោ អាយស្មន្តំ លកុណ្ឌកភទ្ទិយំ[១] អនេកបរិយាយេន ធម្មិយា កថាយ សន្ទស្សេតិ សមាទបេតិ សមុត្តេជេតិ សម្បហំសេតិ ។ អថខោ អាយស្មតោ លកុណ្ឌកភទ្ទិយស្ស អាយស្មតា សារីបុត្តេន អនេកបរិយាយេន ធម្មិយា កថាយ សន្ទស្សិយមានស្ស សមាទបិយមានស្ស សមុត្តេជិយមានស្ស សម្បហំសិយមានស្ស អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចិ ។ អទ្ទសា ខោ ភគវា អាយស្មន្តំ លកុណ្ឌកភទ្ទិយំ អាយស្មតា សារីបុត្តេន អនេកបរិយាយេន ធម្មិយា កថាយ សន្ទស្សិយមានំ សមាទបិយមានំ សមុត្តេជិយមានំ សម្បហំសិយមានំ អនុបាទាយ អាសវេហិ ចិត្តំ វិមុត្តំ[២] ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

១ ម. លកុណ្ឋកភទ្ទិយំ ។ ២ ម. វិមុច្ចមានំ ។



# ឧទាន ចូឡវគ្គទី ៧

(១៤៧) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះសារីបុត្តដ៏មានអាយុ បានពន្យល់ព្រះលកុណ្ឌកភទ្ទិយៈដ៏មានអាយុ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាច្រើនប្រការ ។ លំដាប់នោះ ព្រះលកុណ្ឌកភទ្ទិយៈដ៏មានអាយុ ដែលព្រះសារីបុត្តដ៏មានអាយុ ពន្យល ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ច្រើនប្រការហើយ ចិត្តក៏រួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញព្រះលកុណ្ឌកភទ្ទិយៈដ៏មានអាយុ ដែលព្រះសារីបុត្តដ៏មានអាយុ ពន្យល់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាច្រើនប្រការ ចិត្តក៏រួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំហើយ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

ឧទ្ធំ អធោ[១] សព្វធិ វិប្បមុត្តោ
អយមហមស្មីតិ អនានុបស្សី
ឯវំ វិមុត្តោ ឧទតារិ ឱឃំ
អតិណ្ណបុព្វំ អបុនព្ភវាយាតិ ។ សុត្តំ បឋមំ ។[២]

(១៦៨) ឯវមេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា[៣] សារិបុត្តោ អាយស្មន្តំ លកុណ្ដកភទ្ទិយំ សេក្ខោតិ មញ្ញមានោ[៤] ភិយ្យោសោ មត្តាយ អនេកបរិយាយេន ធម្មិយា កថាយ សន្ទស្សេតិ សមាទបេតិ សមុត្តេជេតិ សម្បហំសេតិ ។ អទ្ទសា ខោ ភគវា អាយស្មន្តំ សារិបុត្តំ អាយស្មន្តំ លកុណ្ដកភទ្ទិយំ សេក្ខោតិ មញ្ញមានំ ភិយ្យោសោ មត្តាយ អនេកបរិយាយេន ធម្មិយា កថាយ សន្ទស្សេន្តំ សមាទបេន្តំ សមុត្តេជេន្តំ សម្បហំសេន្តំ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

១ ម. អធោ ។ ២ ឱ.ម. សុត្តំ បឋមំ នត្ថិ ។ ៣ ឱ. អថខោ អាយស្មា ។ ៤ ម. សេក្ខោតិមញ្ញមានោ ។



បុគ្គលរួចស្រឡះចាកសង្ខារទាំងពួង ក្នុងទីណាកកាងលើគឺរូបធាតុ និង អរូបធាតុ ក្នុងទីណាកកាងក្រោម គឺ កាមធាតុ មិនឃើញថា នេះជា អាត្មាអញ លុះរួចស្រឡះយ៉ាងនេះហើយ ក៏ឆ្លងនូវឱឃៈ(ទាំង៤)ដែល ខ្លួនមិនធ្លាប់ឆ្លង មិនប្រព្រឹត្តទៅ ដើម្បីកកើតទៀតឡើយ ។ សូត្រទី ១ ។

(១៦៨) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះសារីបុត្តដ៏មានអាយុ សំគាល់ព្រះលកុណ្ដកភទ្ទិយៈ ដ៏មានអាយុ ថាជាសេក្ខៈ ក៏ពន្យល់ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យ អាចហាន ឲ្យរីករាយ ដោយធម្មីកថា ច្រើនប្រការ ខានប្រមាណដ៏ក្រៃលែង ។ កាលព្រះមានព្រះភាគ ទ្រង់បានឃើញ ព្រះសារីបុត្តដ៏មាន អាយុ សំគាល់ព្រះលកុណ្ដកភទ្ទិយៈដ៏មានអាយុ ថាជាសេក្ខៈ ក៏ពន្យល់ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ច្រើនប្រការ ខានប្រមាណដ៏ក្រៃលែង ។ លុះព្រះមានព្រះភាគ បាន ជ្រាបច្បាស់សេចក្ដីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

អច្ឆេច្ឆិ វដ្ដំ ព្យគា និរាសំ
វិសុក្ខា សរិតា ន សន្ទតិ
ឆិន្នំ វដ្ដំ ន វត្តតិ
ឯសេវន្តោ ទុក្ខស្សាតិ ។ ទុតិយំ[១] ។

(១២៩) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សាវត្ថិយំ មនុស្សា យេភុយ្យេន កាមេសុ អតិវេលំ សត្តា រត្តា គិទ្ធា គធិតា មុច្ឆិតា អជ្ឈោបន្នា សម្មត្តកជាតា[២] កាមេសុ វិហរន្តិ ។ អថខោ សម្ពហុលា ភិក្ខូ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បាវិសិំសុ ។ សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តា យេន ភគវា តេនុបសង្កមិំសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិំសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ ឥធ ភន្តេ សាវត្ថិយំ មនុស្សា យេភុយ្យេន កាមេសុ អតិវេលំ សត្តា រត្តា គិទ្ធា គធិតា មុច្ឆិតា អជ្ឈោបន្នា សម្មត្តកជាតា កាមេសុ វិហរន្តីតិ ។

១ ម.ឆ. ទុតិយំ ន ។ ២ ម. សម្មត្តកជាតា ។ ឱ. សម្មត្តកជាតា ។



បុគ្គលបានកាត់ផ្ដាច់វដ្ដៈ បានដល់ព្រះនិព្វាន មិនមានតណ្ហា ស្ទឹងដែលស្ងួត មិនហូរទៅ យ៉ាងណា គឺវដ្ដៈ ដែលបុគ្គលកាត់ហើយ រមែងមិនប្រព្រឹត្តទៅ(យ៉ាងនោះដែរ)នេះជាទីបំផុតទុក្ខ ។ សូត្រទី ២ ។

(១២៩) ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ពួកមនុស្ស ក្នុងក្រុងសាវត្ថី ជាប់ជំពាក់ ក្នុងកាមទាំងឡាយ ហួសវេលាដោយច្រើន ជាអ្នកត្រេកអរ ជាប់ចិត្ត រងើង ងប់ងល់ ស្រវឹងស្រាំង ក្នុងកាមទាំងឡាយ ។ លំដាប់នោះ ពួកភិក្ខុ ជាច្រើនរូប ស្លៀកស្បង់ ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថី ។ លុះត្រាច់ទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថីរួចហើយ ត្រឡប់អំពីបិណ្ឌបាតវិញ ក្នុងវេលាខាងក្រោយភត្ត ក៏ចូលទៅគាល់ ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំ ព្រះមានព្រះភាគ ហើយក៏អង្គុយ ក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយ ក្នុងទីសមគួរហើយ បានក្រាបបង្គំទូល ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ពួកមនុស្ស ក្នុងក្រុងសាវត្ថីនេះ ជាប់ជំពាក់ ក្នុងកាមទាំងឡាយ ហួសវេលា ដោយច្រើន ជាអ្នកត្រេកអរ ជាប់ចិត្ត រងើង ងប់ងល់ ស្រវឹងស្រាំង ក្នុងកាមទាំងឡាយ ។

អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

> កាមេសុ សត្តា កាមសង្គសត្តា[១]
> សំយោជនេ វជ្ជមបស្សមានា
> ន ហិ ជាតុ សំយោជនសង្គសត្តា
> ឱឃំ តរេយ្យុំ វិបុលំ មហន្តំ ។ តតិយំ[២] ។

[១៩០] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សាវត្ថិយំ មនុស្សា យេភុយ្យេន កាមេសុ សត្តា ហោន្តិ រត្តា គិទ្ធា គធិតា មុច្ឆិតា អជ្ឈោបន្នា អន្ធីកតា សម្មត្តកជាតា កាមេសុ វិហរន្តិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថិំ បិណ្ឌាយ បាវិសិ ។ អទ្ទសា ខោ ភគវា តេ សាវត្ថិយំ មនុស្សេ យេភុយ្យេន កាមេសុ សត្តេ រត្តេ គិទ្ធេ គធិតេ មុច្ឆិតេ អជ្ឈោបន្នេ អន្ធីកតេ សម្មត្តកជាតេ កាមេសុ វិហរន្តេ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

១ ឱ. កាមសង្គសត្តា ។ ២ ម.ឱ. តតិយសុត្តំ ។



លុះព្រះមានព្រះភាគ ទ្រង់ជ្រាបសេចក្តីនុះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

> ពួកបុគ្គលជាប់នៅ ក្នុងកាមទាំងឡាយ ឈ្មោះថា អ្នកជាប់នៅ ក្នុង
> គ្រឿងជាប់ជំពាក់ គឺកាម កាលបើមិនឃើញទោស ក្នុងសំយោជនៈ
> ឈ្មោះថា អ្នកជាប់នៅ ក្នុងគ្រឿងជាប់ជំពាក់ គឺ សំយោជនៈ ឆ្លង
> នូវឱឃៈធំទូលាយ មិនបានដោយពិត ។ សូត្រទី ៣ ។

[១៩០] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ពួកមនុស្ស ក្នុងក្រុងសាវត្ថី ជាប់នៅ ក្នុងកាមទាំងឡាយ ដោយច្រើន ជាអ្នកត្រេកអរ ចង់បាន ជាប់ចិត្ត វង្វេង ង៉ប់ងល់ ងងឹត ស្រវឹងខ្លាំង ក្នុងកាមទាំងឡាយ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ ប្រដាប់បាត្រនិងចីវរហើយ ស្តេចចូលទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថី ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញ មនុស្សទាំងនោះ ក្នុងក្រុងសាវត្ថី ជាប់នៅ ក្នុងកាមទាំងឡាយ ជាច្រើន ចង់បាន ជាប់ចិត្ត វង្វេង ង៉ប់ ងងឹត ស្រវឹងខ្លាំង ក្នុងកាមទាំងឡាយ ។ លុះព្រះមានព្រះភាគ ជ្រាបច្បាស់សេចក្តីនុះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

កាមន្ធា ជាលសញ្ឆន្នា តណ្ហាឆទនឆាទិតា
បមត្តពន្ធុនា ពទ្ធា មច្ឆាវ កុមិនាមុខេ
ជរាមរណំ[១] អន្វេន្តិ វច្ឆោ ខីរបកោវ មាតរន្តិ ។
ចតុត្ថំ[២] ។

(១៨១) ឯវំមេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា លកុណ្ឌកភទ្ទិយោ សម្ពហុលានំ ភិក្ខូនំ បិដ្ឋិតោ បិដ្ឋិតោ យេន ភគវា តេនុបសង្កមតិ ។ អទ្ទសា ខោ ភគវា អាយស្មន្តំ លកុណ្ឌកភទ្ទិយំ ទូរតោវ សម្ពហុលានំ ភិក្ខូនំ បិដ្ឋិតោ បិដ្ឋិតោ អាគច្ឆន្តំ ទុព្វណ្ណំ ទុទ្ទសិកំ ឱកោដិមកំ យេភុយ្យេន ភិក្ខូនំ បរិភូតរូបំ ទិស្វាន ភិក្ខូ អាមន្តេសិ បស្សថ នោ តុម្ហេ ភិក្ខវេ ឯតំ ភិក្ខុំ ទូរតោវ សម្ពហុលានំ ភិក្ខូនំ បិដ្ឋិតោ បិដ្ឋិតោ អាគច្ឆន្តំ ទុព្វណ្ណំ ទុទ្ទសិកំ ឱកោដិមកំ យេភុយ្យេន ភិក្ខូនំ បរិភូតរូបន្តិ ។ ឯវំ ភន្តេតិ ។ ឯសោ ភិក្ខវេ ភិក្ខុ មហិទ្ធិកោ មហានុភាវោ

១ ម. ជរាមរណមន្វេន្តិ ។ ២ ឱ.ម. ចតុត្ថំ [illegible] ។



ជនទាំងឡាយ ដែលងងឹត ព្រោះកាម ដែលបណ្ដាញ គឺតណ្ហា រួបរឹត ត្រូវផ្សាល គឺតណ្ហាបិទបាំង ជាប់នៅ ដោយកិលេសមារ ដូចជាត្រីជាប់នៅ ក្នុងលប រមែងដល់នូវជរានិងមរណៈ ដូចជាកូនគោ នៅបៅដោះ រមែងចូលទៅរកមេ ។ សូត្រ ទី ៤ ។

(១៨១) ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះលកុណ្ឌកភទ្ទិយៈដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ អំពីខាងក្រោយ ៗ នៃពួកភិក្ខុជាច្រើន ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញ ព្រះលកុណ្ឌកភទ្ទិយៈដ៏មានអាយុ មានរូបថោក មិនគួរជ្រះថ្លា តាបកន្ទួញ មានរូបគួរឲ្យភិក្ខុ ជាច្រើន ចាប់ពាល់លេង កំពុងដើរមកអំពីខាងក្រោយ ៗ នៃពួកភិក្ខុជាច្រើន អំពីចម្ងាយ លុះឃើញហើយ ទ្រង់ត្រាស់នឹងពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ឃើញភិក្ខុនុ៎ះដែលមានរូបថោក មិនគួរជ្រះថ្លា តាបកន្ទួញ មានរូបគួរឲ្យពួកភិក្ខុ ជាច្រើន ចាប់ពាល់លេង កំពុងដើរមក អំពីខាងក្រោយ ៗ នៃពួកភិក្ខុជាច្រើន អំពីចម្ងាយដែរឬ ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនុ៎ះមានឫទ្ធិច្រើន មានអានុភាពច្រើន

ន ច សា សមាបត្តិ សុលភរូបា យា តេន ភិក្ខុនា
អសមាបន្នបុព្វា យស្ស ចត្ថាយ កុលបុត្តា សម្មទេវ
អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយ-
បរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា
ឧបសម្បជ្ជ វិហរតីតិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា
តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

នេលង្គោ សេតបច្ឆាទោ ឯការោ វត្តតី រថោ
អនីឃំ បស្ស អាយន្តំ ឆិន្នសោតំ អពន្ធនំ ។

បញ្ចមំ(១) ។

(១៩៦) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន
ខោ បន សមយេន អាយស្មា អញ្ញាកោណ្ឌញ្ញោ
ភគវតោ អវិទូរេ និសិន្នោ ហោតិ បល្លង្កំ អាភុជិត្វា
ឧជុំ កាយំ បណិធាយ តណ្ហាសង្ខយវិមុត្តិំ បច្ច-
វេក្ខមានោ ។ អទ្ទសា ខោ ភគវា អាយស្មន្តំ អញ្ញា-
កោណ្ឌញ្ញំ អវិទូរេ និសិន្នំ បល្លង្កំ អាភុជិត្វា ឧជុំ
កាយំ បណិធាយ តណ្ហាសង្ខយវិមុត្តិំ បច្ចវេក្ខមានំ ។

១ ឱ.ម. បញ្ចមំ ឆដ្ឋំ ។



សមាបត្តិណា ដែលភិក្ខុនោះមិនធ្លាប់បាន សមាបត្តិនោះ មិនមែនបុគ្គល
បានដោយងាយទេ កុលបុត្តទាំងឡាយ ចេញចាកផ្ទះ ទៅបួសក្នុង
ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ ដល់គុណធម៌ណា ភិក្ខុនោះ បាន
ព្រោះដឹង ធ្វើឲ្យជាក់ច្បាស់ បានដល់គុណធម៌នោះ ជាព្រហ្មចរិយៈ
ជាទីបំផុត ដោយខ្លួនឯង ក្នុងបច្ចុប្បន្ននៃរ ។ លុះព្រះមានព្រះភាគ
ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

រថគឺអត្តភាព មានអវយវៈឥតទោស មានដំបូលស មានកង់តែមួយ
រមែងប្រព្រឹត្តទៅបាន អ្នកចូរមើលអត្តភាព (នោះ) មានខ្សែគឺតណ្ហា
ដាច់ហើយ មិនមានចំណង មិនមានទុក្ខ កំពុងដើរមក ។ សូត្រទី៥ ។

(១៩៦) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ
ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។
សម័យនោះឯង ព្រះអញ្ញាកោណ្ឌញ្ញ ដ៏មានអាយុ អង្គុយពែនភ្នែន
តម្រង់កាយត្រង់ ក្នុងទីជិតនៃព្រះមានព្រះភាគ ហើយពិចារណា តណ្ហា
សង្ខយវិមុត្តិ គឺនិព្វាន ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញ ព្រះ
អញ្ញាកោណ្ឌញ្ញដ៏មានអាយុ អង្គុយពែនភ្នែន តម្រង់កាយត្រង់ ក្នុងទី
ជិតហើយពិចារណា តណ្ហាសង្ខយវិមុត្តិ ។

អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

យស្ស មូលំ ឆមា នត្ថិ បណ្ណា នត្ថិ កុតោ លតា
តំ ធីរំ ពន្ធនា មុត្តំ កោ តំ និន្ទិតុមរហតិ
ទេវាបិ នំ បសំសន្តិ ព្រហ្មុនាបិ បសំសិតោតិ ។

ឆដ្ឋំ(១) ។

(១៩៣) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភគវា អត្តនោ បបញ្ចសញ្ញាសង្ខា-បហានំ បច្ចវេក្ខមានោ និសិន្នោ ហោតិ ។ អថខោ ភគវា អត្តនោ បបញ្ចសញ្ញាសង្ខាបហានំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

យស្ស បបញ្ចា ឋិតិ ច(២) នត្ថិ
សន្ទានំ បលិឃំ ច វីតិវត្តោ
ត(៣) តំ និត្តណ្ហំ មុនឹ ចរន្តំ
នាវជានាតិ សទេវកោបិ លោកោតិ ។

សត្តមំ(៤) ។

---

១. ឱ. ម. ឆដ្ឋំ ឆដ្ឋំ ។ ២. ឱ. ឋិតិ ។ ៣. ម. តតិ ឆដ្ឋំ ។ ៤. ឱ. ម. សត្តមំ សត្តំ ។





លុះព្រះមានព្រះភាគ ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺនូវឧទាននេះ ក្នុងវេលានោះថា

ឫស គឺអវិជ្ជា និងផែនដី គឺមានៈ មិនមាន ដល់អរិយបុគ្គលណា
ស្លឹក គឺសេចក្តីស្រើប ក៏មិនមាន វល្លិ គឺមានៈ នឹងមានមក អំពីណា
បុគ្គលណា នឹងគួរតិះដៀល នូវអរិយបុគ្គលនោះ ដែលជាអ្នកប្រាជ្ញ
ផុតចាកចំណងបាន សូម្បីពួកទេវតា ក៏សរសើរបុគ្គលនោះ ទាំង
ព្រហ្មក៏សរសើរដែរ ។ សូត្រទី ៦ ។

[១៩៣] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់ពិចារណាការលះបង់នូវការពិចារណាបបញ្ចសញ្ញា (សញ្ញាជាគ្រឿងយឺតយូរ) របស់ព្រះអង្គ ។ លុះព្រះមានព្រះភាគ ជ្រាបការលះបង់នូវការពិចារណា បបញ្ចសញ្ញា របស់ព្រះអង្គហើយ ទើបទ្រង់បន្លឺនូវឧទាននេះ ក្នុងវេលានោះថា

បបញ្ចសញ្ញាក្តី ការតាំងនៅក្តី មិនមានដល់បុគ្គលណា បុគ្គលនោះឈ្មោះ
ថា បានកន្លងនូវកិលេសជាតំណរគ្រឿងកងផង និងគល់គឺអវិជ្ជាផង មនុស្ស
លោកព្រមទាំងទេវលោក ក៏មិនមើលងាយអ្នកប្រាជ្ញ ដែលគ្មានតណ្ហា
ហើយប្រព្រឹត្តទៅ ដោយញាណនោះបានឡើយ ។ សូត្រទី ៧ ។

(១៨៦) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវ-ត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា មហាកច្ចានោ ភគវតោ អវិទូរេ និសិន្នោ ហោតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ កាយគតាយ សតិយា អជ្ឈត្តំ បរិមុខំ សូបដ្ឋិតាយ ។ អទ្ទសា ខោ ភគវា អាយ-ស្មន្តំ មហាកច្ចានំ អវិទូរេ និសិន្នំ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ កាយគតាយ សតិយា អជ្ឈត្តំ បរិមុខំ សូបដ្ឋិតាយ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

យស្ស សិយា សព្វទា សតិ សតតំ កាយគតា ឧបដ្ឋិតា
នោ ចស្ស នោ ច មេ សិយា ន ភវិស្សតិ ន ច មេ ភវិស្សតិ
អនុបុព្វវិហារី តត្ថ សោ កាលេនេវ តរេ វិសត្តិកន្តិ ។

អដ្ឋមំ[១] ។

(១៨៧) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា មល្លេ-សុ ចារិកំ ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធិំ

១ ឱ.ម. អដ្ឋមំ សុត្តំ ។



(១៨៦) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមហាកច្ចានៈដ៏មានអាយុ អង្គុយពែនភ្នែន តម្រង់កាយត្រង់ ដំកល់ចិត្តទៅរកកាយគតាសតិ ឲ្យមានមុខរក្សានៅ ក្នុងខាងក្នុង ជិតព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញព្រះមហាកច្ចានៈដ៏មានអាយុ អង្គុយពែនភ្នែន តម្រង់កាយត្រង់ ដំកល់ចិត្តទៅរកកាយគតាសតិ ឲ្យមានមុខរក្សានៅ ក្នុងខាងក្នុង ក្នុងទីជិតហើយ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

កាយគតាសតិ ដែលបុគ្គលណា ផ្ចង់រឿយៗគ្រប់កាល ( កាយគតាសតិនោះ)មិនមាន ដល់បុគ្គលនោះផង មិនមាន ដល់អាត្មាអញ ( ក្នុងអតីតកាលផង ) នឹងមិនមាន ដល់អាត្មាអញ ( ក្នុងអនាគតផង ) មិនមាន ដល់អាត្មាអញ ( ក្នុងកាលឥឡូវនេះ ) ផង បុគ្គលនោះ ឈ្មោះថា នៅដោយអនុបុព្វវិហារធម៌ គប្បីឆ្លងនូវតណ្ហា ជាគំស ក្នុងកាល ( តាំង៣ ) ក្នុងកាលតាំង ៣ នោះបាន ។ សូត្រទី៨ ។

(១៨៧) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ស្តេចទៅកាន់ចារិក ក្នុងដែនមល្លៈ ជាមួយនឹងភិក្ខុសង្ឃ ជាច្រើនរូប

យេន ថូណំ នាម មល្លានំ ព្រាហ្មណគាមោ តទវសរិ ។ អស្សោសុំ ខោ ថូណេយ្យកា ព្រាហ្មណគហបតិកា សមណោ ខលុ ភោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ មល្លេសុ ចារិកញ្ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ ថូណំ អនុប្បត្តោតិ ឧទបានំ តិណស្ស ច ភុសស្ស ច យាវ មុខតោ បូរេសុំ មា តេ មុណ្ឌកា សមណកា បានីយំ អបំសូតិ ។

(១៨៦) អថខោ ភគវា មគ្គា ឱក្កម្ម យេន អញ្ញតរំ រុក្ខមូលំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ ឥង្ឃ មេ ត្វំ អានន្ទ ឯតស្មា ឧទបានា បានីយំ អាហរាតិ ។ ឯវំ វុត្តេ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ឥទានិ សោ ភន្តេ ឧទបានោ ថូណេយ្យកេហិ ព្រាហ្មណគហបតិកេហិ តិណស្ស ច ភុសស្ស ច យាវ មុខតោ បូរិតោ មា តេ មុណ្ឌកា សមណកា បានីយំ អបំសូតិ ។ ទុតិយម្បិ ខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ ឥង្ឃ មេ ត្វំ អានន្ទ ឯតស្មា ឧទបានា បានីយំ អាហរាតិ ។



ទ្រង់ចូលទៅដល់ព្រាហ្មណគ្រាមឈ្មោះថូនៈ របស់ពួកមល្លជន ។ ពួកព្រាហ្មណ៍និងគហបតី អ្នកស្រុកថូនៈ បានឮហើយ (ក៏ប្រកាសប្រាប់គ្នា) ថា ម្នាលគ្នាយើង ឮថា សមណគោតម ជាសក្យបុត្រ ចេញចាកសក្យត្រកូល មកបួស ហើយស្តេចមកកាន់ចារិក ក្នុងដែនមល្លៈ ជាមួយនឹងភិក្ខុសង្ឃជាច្រើន បានមកដល់ថូនព្រាហ្មណគ្រាមហើយ ក៏នាំគ្នាយកស្មៅនិងអង្កាម ចាក់បំពេញអណ្តូងដរាបដល់មាត់ ដោយគិតថា កុំឲ្យសមណៈត្រងោលទាំងនោះ ផឹកទឹកបាន ។

(១៨៦) គ្រានោះ ព្រះមានព្រះភាគ ទ្រង់ចៀសចេញអំពីផ្លូវ ស្តេចទៅរកដើមឈើ១ដើម លុះចូលទៅដល់ ទ្រង់គង់លើអាសនៈ ដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគ ទ្រង់គង់ហើយ ទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ អ្នកចូរទៅដងទឹក អំពីអណ្តូងនុ៎ះ មកឲ្យតថាគត ។ កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះអានន្ទដ៏មានអាយុ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ អណ្តូងនោះ ពួកព្រាហ្មណ៍ និងគហបតី អ្នកស្រុកថូនៈ យកស្មៅនិងអង្កាម ចាក់បំពេញដរាបដល់មាត់ ដោយគិតថា កុំឲ្យសមណៈត្រងោលទាំងនោះផឹកទឹកបាន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុ ជាគំរប់ពីរដងទៀតថា ម្នាលអានន្ទ អ្នកចូរទៅដងទឹក អំពីអណ្តូងនុ៎ះមកឲ្យតថាគត ។

ទុតិយម្បិ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ឥទានិ សោ ភន្តេ ឧទបានោ ថូណេយ្យកេហិ ព្រាហ្មណគហបតិកេហិ តិណស្ស ច ភុសស្ស ច យាវ មុខតោ បូរិតោ មា តេ មុណ្ឌកា សមណកា បានីយំ អបំសូតិ ។ តតិយម្បិ ខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ ឥង្ឃ មេ ត្វំ អានន្ទ ឯតស្មា ឧទបានា បានីយំ អាហរាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុត្វា បត្តំ គហេត្វា យេន សោ ឧទបានោ តេនុបសង្កមិ ។ អថខោ ឧទបានោ អាយស្មន្តេ អានន្ទេ ឧបសង្កមន្តេ សព្វន្តំ តិណញ្ច ភុសញ្ច មុខតោ ឧគ្គិរិត្វា អច្ឆស្ស ឧទកស្ស អនាវិលស្ស វិប្បសន្នស្ស យាវ មុខតោ បូរិតោ វិស្សន្ទន្តោ[១] មញ្ញេ អដ្ឋាសិ ។ អថខោ អាយស្មតោ អានន្ទស្ស ឯតទហោសិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ តថាគតស្ស មហិទ្ធិកតា មហានុភាវតា[២] អយញ្ហិ សោ ឧទបានោ មយិ ឧបសង្កមន្តេ សព្វន្តំ តិណញ្ច ភុសញ្ច មុខតោ ឧគ្គិរិត្វា អច្ឆស្ស ឧទកស្ស

១ ។ វិស្សន្ទន្តោ ។ ម. វិស្សន្តោ ។ ២ ឱ.ម. មហានុភាវតោ ។



ព្រះអានន្ទដ៏មានអាយុ ក្រាបបង្គំទូលព្រះមានព្រះភាគ ជាគំរប់ពីរដងថា បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ អណ្ដូងនោះ ពួកព្រាហ្មណ៍និងគហបតី អ្នកស្រុកថូណៈ យកស្មៅនិងអង្កាម ចាក់បំពេញ ដរាបដល់មាត់ ដោយគិតថា កុំឲ្យសមណៈក្បាលត្រងោលទាំងនោះផឹកទឹកបាន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ប្រើព្រះអានន្ទដ៏មានអាយុ ជាគំរប់បីដងទៀតថា ម្នាលអានន្ទ អ្នកចូរទៅដងទឹក អំពីអណ្ដូងនុ៎ះ មកឲ្យតថាគត ។ ព្រះអានន្ទដ៏មានអាយុ ទទួលព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏កាន់បាត្រ ដើរចូលទៅរកអណ្ដូងនោះ ។ កាលបើព្រះអានន្ទដ៏មានអាយុ ចូលទៅ ក៏ស្រាប់តែ អណ្ដូងខ្ជាក់ស្មៅនិងអង្កាមទាំងអស់នោះ ចេញអំពីមាត់ ពេញពោរពេញដោយទឹកថ្លាមិនល្អក់ ស្អាតដរាបដល់មាត់វិញ ។ សំដាប់នោះ ព្រះអានន្ទដ៏មានអាយុ មានសេចក្ដីត្រិះរិះយ៉ាងនេះថា អើអស្ចារ្យណាស់ហ្ន៎ អើចំឡែកណាស់ហ្ន៎ ព្រះតថាគតមានឫទ្ធិច្រើន មានអានុភាពច្រើន ព្រោះថា អណ្ដូងនេះ កាលអាត្មាអញ ចូលទៅជិត ក៏ស្រាប់តែខ្ជាក់ស្មៅនិងអង្កាមទាំងអស់នោះ ចេញអំពីមាត់ ទៅជាពេញពោរពេញដោយទឹកថ្លា

អនាវិលស្ស វិប្បសន្នស្ស យាវ មុខតោ បូរោ វិសន្ទន្តោ មញ្ញេ ឋិតោតិ ។ បត្តេន បានីយំ អាទាយ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ ឯតទវោច អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ តថាគតស្ស មហិទ្ធិកតា មហានុភាវតា អយញ្ហិ សោ ភន្តេ ឧទបានោ មយិ ឧបសង្កមន្តេ សព្វំ តិណភុសំ មុខតោ ឧវមិត្វា អច្ឆស្ស ឧទកស្ស អនាវិលស្ស វិប្បសន្នស្ស យាវ មុខតោ បូរោ វិសន្ទន្តោ មញ្ញេ អដ្ឋាសិ បិវតុ ភគវា បានីយំ បិវតុ សុគតោ បានីយន្តិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

កឹ កយិរា ឧទបានេន អាបា ចេ សព្វទា សិយុំ
តណ្ហាយ មូលតោ ឆេត្វា កិស្ស បរិយេសនញ្ចរេតិ ។

នវមំ(១) ។

(១៨៨) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ តេន ខោ បន សមយេន រញ្ញោ ឧទេនស្ស ឧយ្យានគតស្ស អន្តេបុរំ ទឌ្ឍំ ហោតិ

១ ឱ.ម. ស៊ែន្ធ ៥ បញ្ចមំ ។



មិនល្អក់ ស្អាត ជន់ឡើងដល់មាត់ទៅវិញ ។ ព្រះអានន្ទដ៏មានអាយុ ក៏ដងទឹក ដោយបាត្រ ហើយយកចូលទៅ ថ្វាយព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបបង្គំទូល ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចំរើន ចំឡែកណាស់ ព្រោះព្រះតថាគត មានឫទ្ធិច្រើនមែន មានអានុភាពច្រើនមែន បពិត្រព្រះអង្គដ៏ចំរើន ព្រោះថា អណ្តូងនោះ កាលខ្ញុំព្រះអង្គ ចូលទៅជិត ក៏ស្រាប់តែខ្ជាក់ស្មៅ និងអង្កាមទាំងអស់នោះ ចេញអំពីមាត់ រញ្ជួរតោរ ដោយទឹកថ្លា មិនល្អក់ ស្អាតជន់ឡើងដល់មាត់ទៅវិញ សូមព្រះមានព្រះភាគ សោយទឹក សូមព្រះសុគត សោយទឹក ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

បុគ្គលគប្បីធ្វើអណ្តូងប្រយោជន៍អ្វី បើទឹកមាននៅ គ្រប់កាល
ហើយ តថាគត កាត់តណ្ហាអំពីឫសគល់ហើយ គប្បីត្រាច់
ទៅស្វែងរកទឹក ដូចម្តេចទៀត ។ សូត្រទី ៩ ។

(១៨៨) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។ សម័យនោះឯង កាលព្រះបាទឧទេន ស្តេចទៅកាន់ឧទ្យាន មានភ្លើងឆេះខាងក្នុងព្រះរាជវាំង

បញ្ច ឥត្ថីសតានិ កាលង្កតានិ ហោន្តិ សាមាវតីប-មុខានិ ។ អថខោ សម្ពហុលា ភិក្ខូ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ កោសម្ពឹ បិណ្ឌាយ បាវិសឹសុ ។ កោសម្ពិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ ឥធ ភន្តេ រញ្ញោ ឧទេនស្ស ឧយ្យានគតស្ស អន្តេបុរំ ទឌ្ឍំ បញ្ច ឥត្ថីសតានិ កាលង្កតានិ ហោន្តិ សាមាវ-តីបមុខានិ តាសំ ភន្តេ ឧបាសិកានំ កា គតិ កោ អភិសម្បរាយោតិ ។ សន្តេត្ថ ភិក្ខវេ ឧបាសិកាយោ សោតាបន្នា សន្តិ សកទាគាមិនិយោ សន្តិ អនាគាមិ-និយោ សព្វា តា ភិក្ខវេ ឧបាសិកាយោ អនិប្ផលា កាលង្កតាតិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

មោហសម្ពន្ធនោ លោកោ ភព្វរូបោវ ទិស្សតិ
ឧបធិពន្ធនោ ពាលោ តមសា បរិវារិតោ



ស្ត្រីទាំង ៥០០ នាក់ មាននាងសាមាវតីជាប្រធាន ធ្វើមរណកាលទាំងអស់ ។ គ្រានោះ ភិក្ខុទាំងឡាយច្រើនរូប ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅបិណ្ឌបាត ក្នុងក្រុងកោសម្ពី ។ លុះត្រាច់បិណ្ឌបាតក្នុងក្រុងកោសម្ពីហើយ ត្រឡប់អំពីបិណ្ឌបាតវិញ ក្នុងវេលាខាងក្រោយភត្ត ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយ ក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ បានក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងទីឯណោះ កាលព្រះបាទឧទេន ទ្រង់ស្តេចទៅកាន់ឧទ្យាន មានភ្លើងឆេះរោងក្នុងព្រះរាជវាំង ស្ត្រីទាំង ៥០០ នាក់ មាននាងសាមាវតីជាប្រធាន ធ្វើមរណកាលទាំងអស់ បពិត្រព្រះអង្គដ៏ចំរើន គតិរបស់ឧបា-សិកាទាំងនោះ តើដូចម្តេច លោកខាងមុខ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បណ្តាឧបាសិកាទាំងនុ៎ះ ឧបាសិកាជាសោតាបន្នក៏មាន ជាសក-ទាគាមិនីក៏មាន ជាអនាគាមិនីក៏មាន ម្នាលភិក្ខុទាំងឡាយ ឧបាសិកាទាំងអស់នោះ ដែលធ្វើកាលកិរិយា មិនមែនឥតផលទេ ។ លុះព្រះមានព្រះភាគ ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

សត្វលោក មានមោហៈជាចំណង ប្រាកដដូចជាមានរូបចំរើន បុគ្គល
ពាល មានឧបធិក្កិលេសជាចំណង ត្រូវងងឹតគ្របចោមរោមហើយ

សស្សតោ ហិ[1] ទាយតិ ឋស្សតោ ឧទ្ធំ ការញ្ជង្គិ ។ ចសមំ[2] ។

ឧទ្ទេសោ សត្តមោ ។

## តស្សុទ្ទានំ

ហោន្តិ ឆុព្វ ឥជា កន្ទិយា ហោន្តិ ឆុព្វ កាមេសុ

សត្តា សញ្ញោ តណ្ហាខយោ ច បបញ្ចខយោ ច

កប្បោ នជាតំ ខនេយាតិ ។

1 ឱ. សស្សតោ ។ 2 ឱ.ម. សេមុត្តំ ១បញ្ញាយតិ ។



ព្រោះផ្លូវជាទៀងទាត់ សេចក្ដីកន្ទល់មានគេះជាដើម របស់បុគ្គលអ្នកពិចារណា ឃើញច្បាស់ មិនមានទេ ។ សូត្រទី ១០ ។

ចប់ ឧទ្ទេស ទី ៨ ។

## ឧទ្ទាននៃឧទ្ទេសនោះគឺ

និយាយ អំពីព្រះលក្ខណកម្មិយៈ មាន ៦ លើក អំពីក្ដួចផល ជាប់ក្នុងកាម មាន ៦ លើក អំពីព្រះលក្ខណកម្មិយៈ ១ អំពីការផេស់តណ្ហា ១ អំពីការផេស់បបញ្ចសញ្ញា ១ អំពីព្រះកប្បៈ ១ អំពីសណ្ឋិ ១ អំពីព្រះធុតធម្មនេ ១ ។

## ឧទានេ អដ្ឋមោ បាដលិគាមិយវគ្គោ

[១៦៨] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភគវា ភិក្ខូ និព្វានបដិសំយុត្តាយ ធម្មិយា កថាយ សន្ទស្សេតិ សមាទបេតិ សមុត្តេជេតិ សម្បហំសេតិ ។ តេ ច ភិក្ខូ អដ្ឋិំកត្វា មនសិកត្វា សព្វំ ចេតសោ សមន្នាហរិត្វា ឱហិតសោតា ធម្មំ សុណន្តិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

អត្ថិ ភិក្ខវេ តទាយតនំ យត្ថ នេវ បថវី ន
អាបោ ន តេជោ ន វាយោ ន អាកាសានញ្ចា-
យតនំ ន វិញ្ញាណញ្ចាយតនំ ន អាកិញ្ចញ្ញា-
យតនំ ន នេវសញ្ញានាសញ្ញាយតនំ នាយំ
លោកោ ន បរលោកោ ន ឧភោ ចន្ទិមសុ-
រិយា តមហំ ភិក្ខវេ នេវ អាគតឹ វទាមិ ន គតឹ



## ឧទាន បាដលិគាមិយវគ្គ ទី ៨

[១៦៨] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់ពន្យល់ភិក្ខុទាំងឡាយ ឲ្យយល់ច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ប្រកបដោយព្រះនិព្វាន ភិក្ខុទាំងនោះធ្វើឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត ប្រមូលមកនូវធម្មទេសនាទាំងអស់ ដោយចិត្ត ផ្ទៀងត្រចៀកស្តាប់ធម៌ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

ម្នាលភិក្ខុទាំងឡាយ អាយតនៈ (*) នោះ រមែងមានពិត ដីមិនមាន ទឹកមិនមាន ភ្លើងមិនមាន ខ្យល់មិនមាន អាកាសានញ្ចាយតនៈមិនមាន វិញ្ញាណញ្ចាយតនៈមិនមាន អាកិញ្ចញ្ញាយតនៈមិនមាន នេវសញ្ញានាសញ្ញាយតនៈមិនមាន លោកនេះមិនមាន លោកដទៃមិនមាន ព្រះចន្ទនិងព្រះអាទិត្យទាំងពីរក៏មិនមាន ក្នុងព្រះនិព្វានណា ម្នាលភិក្ខុទាំងឡាយ តថាគត ពោលព្រះនិព្វាននោះថា មិនមានដំណើរមក មិនមានដំណើរទៅ

* បាលីថា អាយតនៈ ក្នុងទីនេះសំដៅយកនិព្វាន ដែលជាហេតុរបស់ញាណ ។ អដ្ឋកថា ។

ន ឋិតឹ ន ចុតឹ ន ឧបបត្តឹ អប្បតិដ្ឋំ អប្បវត្តំ អនារម្មណមេវេតំ ឯសេវន្តោ ទុក្ខស្សាតិ ។ សុត្តំ បឋមំ(១) ។

(១៥៩) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភគវា ភិក្ខូ និព្វានបដិសំយុត្តាយ ធម្មិយា កថាយ សន្ទស្សេតិ សមាទបេតិ សមុត្តេជេតិ សម្បហំសេតិ ។ តេ ច ភិក្ខូ អដ្ឋិកត្វា មនសិកត្វា សព្វចេតសា សមន្នាហរិត្វា ឱហិតសោតា ធម្មំ សុណន្តិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

ទុទ្ទសំ អនត្តំ នាម ន ហិ សច្ចំ សុទស្សនំ
បដិវិទ្ធា តណ្ហា ជានតោ បស្សតោ នត្ថិ កិញ្ចនន្តិ ។

ទុតិយំ(២) ។

(១៦០) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។

១ ម.ឆ. សុត្តំ បឋមំ នត្ថិ ។ ២ ម.ឆ. ទុតិយំ នត្ថិ ។



មិនមានការតាំងនៅ មិនមានការច្យុតិ មិនមានការកើត
មិនមានទី ជាទីតាំង មិនប្រព្រឹត្តទៅ មិនមានអារម្មណ៍
ព្រះនិព្វាននោះ ជាទីបំផុតនៃទុក្ខតែម្យ៉ាង ។ សូត្រទី ១ ។

(១៥៩) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់ពន្យល់ភិក្ខុទាំងឡាយ ឲ្យយល់ច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ប្រកបដោយព្រះនិព្វាន ។ ភិក្ខុទាំងនោះ ធ្វើឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត ប្រមូលមកនូវធម្មទេសនាទាំងអស់ ដោយចិត្ត ផ្ទៀងត្រចៀកស្តាប់ធម៌ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

ធម្មតាព្រះនិព្វាន បុគ្គលឃើញបានដោយក្រ ព្រោះសច្ចៈ មិន
មែនសម្រាប់ឃើញបាន ដោយងាយទេ តណ្ហា ជាគ្រឿង
កង្វល់ រមែងមិនមាន ដល់បុគ្គល កាលដឹង កាលឃើញតណ្ហា
ព្រោះត្រាស់ដឹង ( នូវសច្ចៈ ) ។ សូត្រទី ២ ។

(១៦០) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។

តេន ខោ បន សមយេន ភគវា ភិក្ខូនំ និព្វានប្បដិសំយុត្តាយ ធម្មិយា កថាយ សន្ទស្សេតិ សមាទបេតិ សមុត្តេជេតិ សម្បហំសេតិ ។ តេ ច ភិក្ខូ អដ្ឋិកត្វា មនសិកត្វា សព្វចេតសោ សមន្នាហរិត្វា ឱហិតសោតា ធម្មំ សុណន្តិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

អត្ថិ ភិក្ខវេ អជាតំ អភូតំ អកតំ អសង្ខតំ នោ ចេ តំ ភិក្ខវេ អភវិស្ស អជាតំ អភូតំ អកតំ អសង្ខតំ នយិធ ជាតស្ស ភូតស្ស កតស្ស សង្ខតស្ស និស្សរណំ បញ្ញាយេថ ។ យស្មា ច ខោ ភិក្ខវេ អត្ថិ អជាតំ អភូតំ អកតំ អសង្ខតំ



សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់ពន្យល់ពួកភិក្ខុ ឲ្យយល់ច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ប្រកបដោយព្រះនិព្វាន ។ ភិក្ខុទាំងនោះ ធ្វើឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត ប្រមូលមកនូវចិត្តទាំងអស់ ដោយចិត្ត ផ្ទៀងត្រចៀកស្ដាប់ធម៌ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្ដីនុ៎ះ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

ម្នាលភិក្ខុទាំងឡាយ ព្រះនិព្វានឈ្មោះថា អជាតៈ ឈ្មោះថា អភូតៈ ឈ្មោះថា អកតៈ ឈ្មោះថា អសង្ខតៈ[១] មានប្រាកដ ម្នាលភិក្ខុទាំងឡាយ ប្រសិនណាបើ ព្រះនិព្វាននោះឈ្មោះថា អជាតៈ ឈ្មោះថា អភូតៈ ឈ្មោះថា អកតៈ ឈ្មោះថា អសង្ខតៈ មិនមានទេ ការរលាស់ចេញនូវកិលេស ដែលនាំឲ្យកើតមហាភូតរូប ដែលប្រាកដនូវហេតុ ដែលធ្វើ នូវបច្ច័យដែលតាក់តែង ក្នុងលោកនេះក៏មិនប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះនិព្វាន ឈ្មោះថា អជាតៈ ឈ្មោះថា អភូតៈ ឈ្មោះថា អកតៈ ឈ្មោះថា អសង្ខតៈ រមែងមានប្រាកដ ព្រោះហេតុណា

១ ព្រះនិព្វានដែលឈ្មោះថា អជាតៈ នោះ ព្រោះមិនមានសេចក្ដីកើតឡើង ដោយហេតុទាំងឡាយដទៃទៀត ។ ដែលឈ្មោះថា អភូតៈ នោះព្រោះតែមិនប្រាកដ ដូចមហាភូតរូប ។ ដែលឈ្មោះថា អកតៈនោះ ពីព្រោះមិនមានហេតុណាមួយ ធ្វើឲ្យកើតឡើងទេ ។ ដែលឈ្មោះថា អសង្ខតៈ នោះ ពីព្រោះមិនមានបច្ច័យតាក់តែងប្រជុំគ្នាឲ្យកើត ។ អដ្ឋកថា ។

តស្មា ជាតស្ស ភូតស្ស កតស្ស សង្ខតស្ស និស្សរណំ បញ្ញាយតីតិ ។ តតិយំ[១] ។

[១៦១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភគវា ភិក្ខូ និព្វានប្បដិសំយុត្តាយ ធម្មិយា កថាយ សន្ទស្សេតិ សមាទបេតិ សមុត្តេជេតិ សម្បហំសេតិ ។ តេ ច ភិក្ខូ អដ្ឋិកត្វា មនសិកត្វា សព្វំ ចេតសា សមន្នាហរិត្វា ឱហិតសោតា ធម្មំ សុណន្តិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

និស្សិតស្ស ចលិតំ អនិស្សិតស្ស ចលិតំ នត្ថិ ចលិតេ អសតិ បស្សទ្ធិ បស្សទ្ធិយា សតិ រតិ[២] ន ហោតិ រតិយា[៣] អសតិ អាគតិគតិ ន ហោតិ អាគតិគតិយា អសតិ ចុតូបបាតោ ន ហោតិ

១ ឱ.ម. តតិយន្តិ ន បញ្ញាយតិ ។ ២ ម. នតិ ។ ៣ ម. នតិយា ។



ហេតុនោះ ការរលាស់ចេញនូវកិលេស សរដែលនាំឲ្យកើតមហាភូតរូបដ៏ប្រាកដ នូវហេតុដែលតាក់តែង នូវបច្ច័យតាក់តែង ក៏រមែងប្រាកដ ។ សូត្រ ទី ៣ ។

(១៦១) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់ពន្យល់ពួកភិក្ខុ ឲ្យយល់ច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ប្រកបដោយព្រះនិព្វាន ។ ភិក្ខុទាំងនោះ ធ្វើនូវធម៌ឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត ប្រមូលមកនូវធម្មទេសនាទាំងអស់ ដោយចិត្ត ផ្ចង់ត្រចៀកស្តាប់ធម៌ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះ ទើបទ្រង់បន្លឺនូវឧទាននេះ ក្នុងវេលានោះថា

ការញាប់ញ័រ របស់បុគ្គលអ្នកអាស្រ័យ (ដោយតណ្ហានិងទិដ្ឋិ) រមែងមាន ការញាប់ញ័រ របស់បុគ្គលអ្នកមិនអាស្រ័យ ( ដោយតណ្ហានិងទិដ្ឋិ) មិនមាន កាលបើសេចក្តីញាប់ញ័រ មិនមាន បស្សទ្ធិ (សេចក្តីស្ងប់) ក៏កើតមានឡើង កាលបើបស្សទ្ធិ មាន តម្រេកក៏រមែងមិនមាន កាលបើតម្រេកមិនមាន ដំណើរមកនិងដំណើរទៅ ក៏មិនមាន កាលបើដំណើរមក ដំណើរទៅ មិនមាន ការច្យុតិនិងការកើត ក៏មិនមាន

ចុតូបបាតោ អសតិ នេវិធ ន ហុរំ ន ឧភយមន្តរេន ឯសេវន្តោ ទុក្ខស្សាតិ ។ ចតុត្ថំ[១] ។

(១៦៩) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា មល្លេសុ ចារិកំ ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ យេន បាវា តទវសរិ ។ តត្រ សុទំ ភគវា បាវាយំ វិហរតិ ចុន្ទស្ស កម្មារបុត្តស្ស អម្ពវនេ ។ អស្សោសិ ខោ ចុន្ទោ កម្មារបុត្តោ ភគវា កិរ មល្លេសុ ចារិកញ្ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ បាវំ អនុប្បត្តោ[២] បាវាយំ វិហរតិ មយ្ហំ អម្ពវនេតិ ។ អថខោ ចុន្ទោ កម្មារបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ ចុន្ទំ កម្មារបុត្តំ ភគវា ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ ចុន្ទោ កម្មារបុត្តោ ភគវតា ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ សម្បហំសិតោ ភគវន្តំ ឯតទវោច

១ ម.ឆ. ចតុត្ថំ ៖ បញ្ចមំ ។ ២ ម. បាវាយំ អនុប្បត្តោ ។



កាលបើការច្យុតិនិងការកើត មិនមាន ដំណើរទៅមក ក្នុងផងលោកនេះបរលោក ក៏មិនមាន ទាំងមិនមាន ក្នុងកណ្ដាលនៃលោកទាំងពីរ នេះជាទីបំផុតនៃទុក្ខ ។ សូត្រទី ៤ ។

(១៦៩) ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ត្រាច់ទៅកាន់ចារិក ក្នុងជនបទឈ្មោះមល្លៈ ជាមួយភិក្ខុសង្ឃច្រើនរូប បានដល់ក្រុងបាវា ។ បានឮថា ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់គង់ក្នុងស្វនស្វាយរបស់ចុន្ទកម្មារបុត្ត (កូនជាងមាស) ទៀបក្រុងបាវា ។ ចុន្ទកម្មារបុត្ត បានឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់ត្រាច់មកកាន់ចារិក ក្នុងមល្លជនបទ ជាមួយភិក្ខុសង្ឃច្រើនរូប បានដល់ក្រុងបាវា ឥឡូវនេះ ទ្រង់គង់នៅក្នុងស្វនស្វាយរបស់អញ ទៀបក្រុងបាវា ។ គ្រានោះឯង ចុន្ទកម្មារបុត្ត ចូលទៅរក ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំ ព្រះមានព្រះភាគ ហើយអង្គុយ ក្នុងទីសមគួរ ។ លុះចុន្ទកម្មារបុត្ត អង្គុយ ក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ក៏ទ្រង់ពន្យល់ ឲ្យយល់ច្បាស់ ឲ្យកាន់យក ឲ្យក្លាហាន ឲ្យរីករាយ ដោយធម្មីកថា ។ លំដាប់នោះ ចុន្ទកម្មារបុត្ត ដែលព្រះមានព្រះភាគ ឲ្យយល់ច្បាស់ ឲ្យកាន់យក ឲ្យក្លាហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏បានក្រាបបង្គំទូល ព្រះមានព្រះភាគ

អធិវាសេតុ មេ[១] ភន្តេ ភគវា ស្វាតនាយ ភត្តំ សទ្ធិំ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ ចុន្ទោ កម្មារបុត្តោ ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ ចុន្ទោ កម្មារបុត្តោ តស្សា រត្តិយា អច្ចយេន សកេ និវេសនេ បណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេត្វា បហូតញ្ច សូករមទ្ទវំ ភគវតោ កាលំ អារោចេសិ[២] កាលោ ភន្តេ និដ្ឋិតំ ភត្តន្តិ ។ អថខោ ភគវា

---

១ ម. ម៉ុ ។ ២ ម. អារោចាបេសិ ។



បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគព្រមទាំងភិក្ខុសង្ឃ ទទួលភត្ត របស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ ក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគ ទ្រង់ទទួល និមន្តដោយតុណ្ហីភាព ។ គ្រានោះ ចុន្ទកម្មារបុត្ត ដឹងច្បាស់ថា ព្រះមានព្រះភាគទ្រង់ទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណ ចៀសចេញទៅ ។ គ្រានោះ កាលកន្លងរាត្រីនោះហើយ ចុន្ទកម្មារបុត្ត ឲ្យគេតាក់តែងខាទនីយភោជនីយាហារ មានរសដ៏ឆ្ងាញ់ពិសា ព្រមទាំងសូករមទ្ទវៈ[១]ដ៏ច្រើន ក្នុងផ្ទះរបស់ខ្លួន ហើយ ឲ្យគេទៅក្រាបបង្គំទូលកាលវេលា ដល់ព្រះមានព្រះភាគថា បពិត្រព្រះអង្គ ដ៏ចំរើន កាលគួរហើយ ភត្តសម្រេចហើយ ។ គ្រានោះ ព្រះមានព្រះភាគ

---

១ ពាក្យថា សូករមទ្ទវៈនេះ លោកពោលទុក ក្នុងអដ្ឋកថា ជា ឈ្មោះសាច់ជ្រូក ដែលស្លាប់ស្រាប់ ដែលជាសាច់ជ្រូកទន់ល្មម ។

អាចារ្យមួយពួកទៀត ពោលថា ពាក្យថា សូករមទ្ទវៈនេះ មិនមែនសាច់ជ្រូកទេ គឺជា ទំពាំងឫស្សី ដែលជ្រូកឈ្លីស ។ អាចារ្យដទៃទៀតពោលថា ផ្សិតដែលដុះត្រង់ប្រទេសដែលជ្រូកឈ្លីស ។ មួយទៀត អាចារ្យដទៃ បានពោលថា ម្ហូបនេះ ជាភោជនមានរសមួយបែប មានឈ្មោះថា សូករមទ្ទវៈ ព្រោះថា នាយចុន្ទកម្មារបុត្ត បានប្រគេនសូករមទ្ទវៈនោះ ដើម្បីឲ្យព្រះសាស្តា គង់ព្រះជន្មនៅបានយូរ ព្រោះឮថា ព្រះមានព្រះភាគ នឹងបរិនិព្វាន ក្នុងថ្ងៃនេះហើយគិតថា ធ្វើម្ដេចហ្ន៎ ព្រះមានព្រះភាគ សោយសូករមទ្ទវៈនោះហើយ គប្បីគង់ព្រះជន្មនៅបានយូរនេះ ។ អដ្ឋកថា ។

ពុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ ភិក្ខុសង្ឃេន សទ្ធឹ យេន ចុន្ទស្ស កម្មារបុត្តស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ។ និសជ្ជ ខោ ភគវា ចុន្ទំ កម្មារបុត្តំ អាមន្តេសិ យំ តេ ចុន្ទ សូករមទ្ទវំ បដិយត្តំ តេន មំ បរិវិស[១] យំ បនញ្ញំ ខាទនីយំ ភោជនីយំ បដិយត្តំ តេន ភិក្ខុសង្ឃំ បរិវិសាតិ។ ឯវំ ភន្តេតិ ខោ ចុន្ទោ កម្មារបុត្តោ ភគវតោ បដិស្សុត្វា យំ អហោសិ សូករមទ្ទវំ បដិយត្តំ តេន ភគវន្តំ បរិវិសិ យំ បនញ្ញំ ខាទនីយំ ភោជនីយំ បដិយត្តំ តេន ភិក្ខុសង្ឃំ បរិវិសតិ។ អថខោ ភគវា ចុន្ទំ កម្មារបុត្តំ អាមន្តេសិ យំ តេ ចុន្ទ សូករមទ្ទវំ អវសិដ្ឋំ តំ សោព្ភេ និខណាហិ[២] នាហំ តំ ចុន្ទ បស្សាមិ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ យស្ស តំ បរិភុត្តំ សម្មា បរិណាមំ គច្ឆេយ្យ អញ្ញត្រ តថាគតស្សាតិ។

១ ឱ.ម. បរិវិស ។ ២ ម. និក្ខណាហិ ។



ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយស្ដេចចូលទៅកាន់លំនៅនៃចុន្ទកម្មារបុត្ត ព្រមដោយភិក្ខុសង្ឃ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈ ដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគ ទ្រង់គង់ស្រេចហើយ ក៏ត្រាស់នឹងចុន្ទកម្មារបុត្តថា ម្នាលចុន្ទ សូករមទ្ទវៈណា ដែលអ្នកតាក់តែងហើយ ចូរអ្នកអង្គាសតថាគត ដោយសូករមទ្ទវៈនោះចុះ ឯខាទនីយភោជនីយាហារណា ក្រៅពីនេះ ដែលអ្នកតាក់តែងហើយ ចូរអ្នកអង្គាសចំពោះភិក្ខុសង្ឃ ដោយខាទនីយភោជនីយាហារនោះចុះ ។ ចុន្ទកម្មារបុត្ត ទទួលព្រះពុទ្ធដីកា ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយអង្គាស ព្រះមានព្រះភាគ ដោយសូករមទ្ទវៈ ដែលខ្លួនតាក់តែងហើយ អង្គាសភិក្ខុសង្ឃ ដោយខាទនីយភោជនីយាហារដទៃ ដែលខ្លួនតាក់តែងហើយ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងចុន្ទកម្មារបុត្តថា ម្នាលចុន្ទ សូករមទ្ទវៈណា របស់អ្នកដែលនៅសល់ អ្នកចូរកប់សូករមទ្ទវៈនោះ ក្នុងរណ្ដៅចុះ ម្នាលចុន្ទ ក្នុងលោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្ស ជាសម្មតិទេព និងមនុស្សដ៏សេស តថាគត មិនឃើញបុគ្គលណាមួយ ដែលបរិភោគនូវសូករមទ្ទវៈនោះ ហើយសូករមទ្ទវៈនោះ ដល់នូវការរលួយទៅដោយល្អឡើយ វៀរលែងតែព្រះតថាគតចេញ ។

ឯវំ ភន្តេតិ ខោ ចុន្ទោ កម្មារបុត្តោ ភគវតោ បដិស្សុត្វា យំ អហោសិ សូករមទ្ទវំ អវសិដ្ឋំ(១) សោព្ភេ និខណិត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ ចុន្ទំ កម្មារបុត្តំ ភគវា ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧដ្ឋាយាសនា បក្កាមិ ។

(១៦៣) អថ ខោ ភគវតោ ចុន្ទស្ស កម្មារបុត្តស្ស ភត្តំ ភុត្តាវិស្ស ខរោ អាពាធោ ឧប្បជ្ជិ លោហិតបក្ខន្ទិកា ពាឡ្ហា(២) វេទនា វត្តន្តិ មារណន្តិកា(៣) ។ តត្រ សុទំ ភគវា សតោ សម្បជានោ អធិវាសេតិ(៤) អវិហញ្ញមានោ ។ អថ ខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ អាយាមានន្ទ យេន កុសិនារា តេនុបសង្កមិស្សាមាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។

ចុន្ទស្ស ភត្តំ ភុញ្ជិត្វា កម្មារស្សាតិ មេ សុតំ
អាពាធំ សម្ផុសី ធីរោ(៥) បពាឡ្ហំ មារណន្តិកំ(៦) ។

១ ស.ម. អវសិដ្ឋំ តំ អត្ថិ ។ ២ ម. បពាឡ្ហា ។ ៣ ឱ. មារណន្តិកា ។ ៤ ឱ. អធិវាសេសិ ។ ៥ ម. វីរោ ។ ៦ ម. មារណន្តិកំ ។

ចុន្ទកម្មារបុត្ត ទូលព្រះពុទ្ធដីកា ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គស្រេចហើយ ក៏កប់សូករមទ្ទវៈ ដែលសល់នៅ ទៅក្នុងរណ្តៅ ហើយចូលទៅគាល់ ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំ ព្រះមានព្រះភាគ អង្គុយក្នុងទីសមគួរ ។ លុះចុន្ទកម្មារបុត្ត អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ក៏ទ្រង់ពន្យល់ ឲ្យយល់ច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ហើយក្រោកចាកអាសនៈ ស្តេចចៀសចេញទៅ ។

(១៦៣) គ្រានោះ កាលព្រះមានព្រះភាគ ឆាន់ភត្តរបស់ចុន្ទកម្មារបុត្ត រួចហើយ ព្រះអាពាធដ៏ខ្លាំង ក៏កើតឡើង វេទនាដ៏ក្លៀវក្លា កើតអំពី លោហិតបក្ខន្ទិកាពាធ ( អាពាធចុះព្រះលោហិត ) ជិតដល់មរណៈក៏ ប្រព្រឹត្តទៅ ។ បានឮថា ក្នុងទីនោះ ព្រះមានព្រះភាគ មានព្រះសតិនិង សម្បជញ្ញៈ មិនបានលំបាក ដោយទ្រង់អត់សង្កត់វេទនានោះបាន ។ វេលានោះឯង ព្រះមានព្រះភាគ ត្រាស់នឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ មកយើងនឹងទៅឯនគរកុសិនារា ។ ព្រះអានន្ទដ៏មាន អាយុ ទូលព្រះពុទ្ធដីកា ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

ខ្ញុំបានឮថា ព្រះពុទ្ធជាអ្នកប្រាជ្ញ ទ្រង់សោយភត្តរបស់ចុន្ទកម្មារ-
បុត្តហើយ ទ្រង់មានព្រះអាពាធ ជាទម្ងន់ជិតនឹងមរណៈ ។

ភុត្តស្ស ច សូករមទ្ទវេន
ព្យាធិ បពាឡ្ហោ ឧទបាទិ សត្ថុនោ
វិរិច្ចមានោ ភគវា អវោច
គច្ឆាមហំ កុសិនារំ នគរន្តិ ។

[១៦៦] អថខោ ភគវា មគ្គា ឱក្កម្ម យេនញ្ញតរំ(១) រុក្ខមូលំ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ អាមន្តេសិ ឥង្ឃ មេ ត្វំ អានន្ទ ចតុគ្គុណំ សង្ឃាដិំ បញ្ញាបេហិ កិលន្តោស្មិ និសីទិស្សាមីតិ(២) ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុត្វា ចតុគ្គុណំ សង្ឃាដិំ បញ្ញាបេតិ(៣) ។ និសីទិ ភគវា បញ្ញត្តេ អាសនេ ។ និសជ្ជ ខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ ឥង្ឃ មេ ត្វំ អានន្ទ បានីយំ អាហរ បិបាសិតោស្មិ អានន្ទ បិវិស្សាមីតិ ។ ឯវំ វុត្តេ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ឥទានិ ភន្តេ បញ្ចមត្តានិ សកដសតានិ អតិក្កន្តានិ តំ ចក្កច្ឆិន្នំ ឧទកំ បរិត្តំ លុឡិតំ អាវិលំ សន្ទតិ អយំ ភន្តេ កកុធា នទី អវិទូរេ អច្ឆោទកា

១. ឱ. យេន អញ្ញតរំ ។ ២. ឱ. កិលន្តោស្មិ អានន្ទ និសីទិស្សាមីតិ ។ ៣. ឱ. បញ្ញាបេសិ ។



ព្យាធិដ៏ខ្លាំងក្លា កើតដល់ព្រះសាស្ដា ដែលសោយសូករមទ្ទវៈ ព្រះមានព្រះភាគ ទ្រង់ព្រះអាពាធចុះព្រះលោហិតរឿយ ៗ ហើយមានព្រះពុទ្ធដីកាថា តថាគតនឹងទៅកាន់ក្រុងកុសិនារា ។

[១៦៦] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ចៀសចេញអំពីផ្លូវ ទ្រង់ចូលទៅកាន់គល់ឈើមួយដើម លុះចូលទៅដល់ហើយ ទ្រង់ប្រើព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ ចូរអ្នកក្រាលសង្ឃាដិមានជាន់ ៤ ឲ្យតថាគត ព្រោះថា តថាគតល្ហិតល្ហៃណាស់ តថាគតនឹងអង្គុយសិន ។ ព្រះអានន្ទដ៏មានអាយុ ទទួលស្ដាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក្រាលសង្ឃាដិមានជាន់ ៤ ថ្វាយ ។ ព្រះមានព្រះភាគ គង់នឹងលើអាសនៈ ដែលព្រះអានន្ទក្រាលថ្វាយ ។ លុះព្រះមានព្រះភាគ គង់ស្រេចហើយ ទ្រង់ប្រើព្រះអានន្ទថា ម្នាលអានន្ទ ចូរអ្នកទៅដងទឹក មកឲ្យតថាគត ព្រោះថា ម្នាលអានន្ទ តថាគត ស្រេកទឹកណាស់ តថាគតនឹងផឹកទឹកបន្តិច ។ កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះអានន្ទដ៏មានអាយុ ក៏ក្រាបថ្វាយបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន អម្បាញ់មិញនេះ រទេះចំនួន ៥០០ បរឆ្លងទៅហើយ ទឹកនោះតិច កង់រទេះ កិនកល់ល្អក់កករហូរមក បពិត្រព្រះអង្គដ៏ចំរើន កកុធានទី ជិតនៅនេះ មានទឹកថ្លា

សាតោទកា សីតោទកា សេតោទកា សុបតិត្ថា រមណីយា ឯត្ថ ភគវា បានីយញ្ច បិវិស្សតិ គត្តានិ ច សីតំ ករិស្សតីតិ ។ ទុតិយម្បិ ខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ ឥង្ឃ មេ ត្វំ អានន្ទ បានីយំ អាហរ បិបាសិតោស្មិ អានន្ទ បិវិស្សាមីតិ ។ ទុតិយម្បិ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ឥទានិ ភន្តេ បញ្ចមត្តានិ សកដសតានិ អតិក្កន្តានិ តំ ចក្កច្ឆិន្នំ ឧទកំ បរិត្តំ លុឡិតំ អាវិលំ សន្ទតិ អយំ ភន្តេ កកុធា នទី អវិទូរេ អច្ឆោទកា សាតោទកា សីតោទកា សេតោទកា សុបតិត្ថា រមណីយា ឯត្ថ ភគវា បានីយញ្ច បិវិស្សតិ គត្តានិ ច សីតំ ករិស្សតីតិ ។ តតិយម្បិ ខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ ឥង្ឃ មេ ត្វំ អានន្ទ បានីយំ អាហរ បិបាសិតោស្មិ អានន្ទ បិវិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុត្វា បត្តំ គហេត្វា យេន សា នទី តេនុបសង្កមិ ។



មានរសជាតស្រួល មានទឹកត្រជាក់ មានទឹកថ្លា មានកំពង់រាបទាប គួរជាទីរីករាយ ក្នុងស្ទឹងនោះ ព្រះមានព្រះភាគ នឹងសោយទឹក ក៏បាន នឹងស្រង់ព្រះកាយឲ្យត្រជាក់ស្រួល ក៏បាន ។ ព្រះមានព្រះភាគ ត្រាស់ប្រើព្រះអានន្ទដ៏មានអាយុ ជាគំរប់ពីរដងទៀតថា ម្នាលអានន្ទ ចូរអ្នកដងទឹក មកឲ្យតថាគត ដោយឆាប់ ម្នាលអានន្ទ តថាគតស្រេកទឹកណាស់ តថាគតនឹងឆាន់ ។ ព្រះអានន្ទដ៏មានអាយុ ក៏ក្រាបបង្គំទូល ព្រះមានព្រះភាគ ជាគំរប់ពីរដងទៀតថា បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ រទេះចំនួន ៥០០ បររំលងទៅហើយ ទឹកនោះតិច កង់រទេះកិន ល្អក់កករហូរមក បពិត្រព្រះអង្គដ៏ចំរើន ស្ទឹងកកុធានទី នៅជិតនេះ មានទឹកថ្លា មានរសជាតស្រួល មានទឹកត្រជាក់ មានទឹកថ្លា មានកំពង់រាបទាប គួរជាទីរីករាយ ក្នុងស្ទឹងនោះ ព្រះមានព្រះភាគ នឹងសោយ ក៏បាន នឹងស្រង់ព្រះកាយឲ្យត្រជាក់ ក៏បាន ។ ព្រះមានព្រះភាគ ត្រាស់ប្រើព្រះអានន្ទដ៏មានអាយុ ជាគំរប់បីដងទៀតថា ម្នាលអានន្ទ ចូរអ្នកទៅដងទឹកមកឲ្យតថាគត ដោយឆាប់ ម្នាលអានន្ទ តថាគតស្រេក តថាគតនឹងឆាន់ ។ ព្រះអានន្ទដ៏មានអាយុ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏កាន់យកបាត្រ ដើរចូលទៅឯស្ទឹងនោះ ។

[១៦៥] អថ ខោ សា នទី ចក្កច្ឆិន្នា បរិត្តា លុឡិតា អាវិលា សន្ទមានា អាយស្មន្តេ អានន្ទេ ឧបសង្កមន្តេ អច្ឆា វិប្បសន្នា អនាវិលា សន្ទិត្ថ ។ អថ ខោ អាយស្មតោ អានន្ទស្ស ឯតទហោសិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ តថាគតស្ស មហិទ្ធិកតា មហានុភាវតា ។ អយញ្ហិ សា នទី ចក្កច្ឆិន្នា បរិត្តា លុឡិតា អាវិលា សន្ទមានា មយិ ឧបសង្កមន្តេ អច្ឆា វិប្បសន្នា អនាវិលា សន្ទតីតិ ។ បត្តេន បានីយំ អាទាយ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ ឯតទវោច អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ តថាគតស្ស មហិទ្ធិកតា មហានុភាវតា ។ អយញ្ហិ ភន្តេ សា នទី ចក្កច្ឆិន្នា បរិត្តា លុឡិតា អាវិលា សន្ទមានា មយិ ឧបសង្កមន្តេ អច្ឆា វិប្បសន្នា អនាវិលា សន្ទតិ ។ បិវតុ ភគវា បានីយំ បិវតុ សុគតោ បានីយន្តិ ។ អថ ខោ ភគវា បានីយំ អបាសិ(១) ។

[១៦៦] អថ ខោ ភគវា មហតា ភិក្ខុសង្ឃេន សទ្ធិំ យេន កកុធា នទី តេនុបសង្កមិ ឧបសង្កមិត្វា កកុធំ នទី

១ ម. អបាយិ ។



(១៦៥) គ្រានោះ ស្ទឹងដែលកង់រទេះបុកកាត់ មានទឹកតិច ល្អក់កករ ហូរមកនោះ កាលដែលព្រះអានន្ទដ៏មានអាយុ ចូលទៅដល់ ទឹកស្ទឹងក៏ថ្លាប្រែក្រឡប់ជាថ្លាស្អាត មិនល្អក់កករហូរមក ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ មានសេចក្តីត្រិះរិះថា យើអើ អស្ចារ្យណាស់ យើអើ ចំឡែកណាស់ ព្រះតថាគត មានឫទ្ធិច្រើន មានអានុភាពច្រើន ។ អម្បាញ់មិញ ស្ទឹងដែលកង់រទេះបុកកាត់ មានទឹកតិច ល្អក់កករហូរមកនេះ លុះដល់អាត្មាអញ ចូលមកដល់ ទឹកស្ទឹងក៏ថ្លាប្រែក្រឡប់ជាថ្លាស្អាត មិនល្អក់កករហូរមកវិញ ។ ព្រះអានន្ទ យកបាត្រទៅដងទឹក ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចំរើន ចំឡែកណាស់ ព្រះតថាគត មានឫទ្ធិច្រើន មានអានុភាពច្រើន ។ បពិត្រព្រះអង្គដ៏ចំរើន ស្ទឹងនោះ កង់រទេះបុកកាត់ មានទឹកតិច ល្អក់កករហូរមក កាលបើខ្ញុំព្រះអង្គ ចូលទៅដល់ ស្ទឹងក៏ថ្លាប្រែក្រឡប់ជាថ្លា ស្អាត មិនល្អក់កករទៅវិញ ។ សូមព្រះមានព្រះភាគ សោយទឹក សូមព្រះសុគត សោយទឹកចុះ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សោយទឹកនោះឯង ។

(១៦៦) គ្រានោះ ព្រះមានព្រះភាគ ទ្រង់យាងស្ដេចទៅឯកកុធានទីជាមួយនឹងភិក្ខុសង្ឃច្រើនរូប លុះចូលទៅដល់ហើយ ក៏យាងចុះកាន់កកុធានទី

អជ្ឈោគាហេត្វា ន្ហត្វា ច បិវិត្វា ច បច្ចុត្តរិត្វា យេន អម្ពវនំ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ចុន្ទកំ អាមន្តេសិ ឥង្ឃ មេ ត្វំ ចុន្ទក ចតុគ្គុណំ សង្ឃាដឹ បញ្ញាបេហិ កិលន្តោស្មិ ចុន្ទក និបជ្ជិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា ចុន្ទកោ ភគវតោ បដិស្សុត្វា ចតុគ្គុណំ សង្ឃាដឹ បញ្ញាបេសិ ។ អថខោ ភគវា ទក្ខិណេន បស្សេន សីហសេយ្យំ កប្បេសិ បាទេ បាទំ អច្ចាធាយ សតោ សម្បជានោ ឧដ្ឋានសញ្ញំ មនសិករិត្វា ។ អាយស្មា បន ចុន្ទកោ តត្ថេវ ភគវតោ បុរតោ និសីទិ ។

(១៦៧) គន្ត្វាន ពុទ្ធោ នទិកំ កកុធំ(១)
អច្ឆោទកំ សាតោទកំ វិប្បសន្នំ
ឱគាហិ សត្ថា សុកិលន្តរូបោ
តថាគតោ អប្បដិមោ ច លោកេ
ន្ហត្វា បិវិត្វា ច ឧត្តារិ សត្ថា
បុរក្ខតោ ភិក្ខុគណស្ស មជ្ឈេ ។
សត្ថា បវត្តា ភគវា ឥធ ធម្មេ
ឧបាគមិ អម្ពវនំ មហេសី ។



ទ្រង់ស្រង់ទឹកសោយស្រេចហើយ ទ្រង់ឡើងមក ហើយយាងចូលទៅកាន់អម្ពវ័ន លុះចូលទៅដល់ហើយ ទ្រង់ត្រាស់នឹងចុន្ទកៈដ៏មានអាយុ ថា ម្នាលចុន្ទកៈ អ្នកចូរក្រាលសង្ឃាដីមានជាន់ ៤ ឲ្យតថាគត ម្នាលចុន្ទកៈ តថាគតល្ហិតល្ហៃណាស់ តថាគតនឹងសឹង ។ ចុន្ទកភិក្ខុដ៏មានអាយុ ទទួលស្ដាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក្រាលសង្ឃាដីមានជាន់ ៤ ថ្វាយ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សម្រេចឱសីហសេយ្យា ផ្ទៀងទៅខាងស្ដាំ ទ្រង់យកព្រះបាទ (ខាងឆ្វេង) តម្រួតលើព្រះបាទ (ខាងស្ដាំ) ទ្រង់មានសតិសម្បជញ្ញៈ ធ្វើទុកក្នុងព្រះហឫទ័យ នូវឧដ្ឋានសញ្ញា ។ ចំណែកខាងចុន្ទកៈដ៏មានអាយុ ក៏អង្គុយនៅចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគ ក្នុងទីនោះឯង ។

(១៦៧) ព្រះពុទ្ធ ទ្រង់យាងចុះទៅកាន់ស្ទឹងកុកុធា ដែលមានទឹកថ្លាល្អ មានទឹកត្រជាក់ រីឯព្រះតថាគត ជាសាស្ដាឥតមានបុគ្គលប្រៀបផ្ទឹមបាន ក្នុងលោក ព្រះអង្គមានសេចក្ដីលំបាកព្រះកាយ ទ្រង់ស្រង់ ស្រោចស្រពហើយ ទើបយាងឡើងមក ព្រះសាស្ដា មានភិក្ខុសង្ឃជាបរិវារ គង់នៅត្រង់កណ្ដាល ។ ព្រះមានព្រះភាគ ជាសាស្ដាស្វែងរកគុណធំ ញុំាងធម៌ទាំងឡាយឲ្យប្រព្រឹត្តទៅ ក្នុងលោកនេះ ហើយយាងមកកាន់អម្ពវ័ន ។

អាមន្តយិ ចុន្ទកំ នាម ភិក្ខុំ
ចតុគ្គុណំ សន្ថរ[១] មេ និបជ្ជំ[២] ។
សោ ចោទិតោ ភាវិតត្តេន ចុន្ទោ
ចតុគ្គុណំ សន្ថរិ ខិប្បមេវ ។
និបជ្ជិ សត្ថា អកិលន្តរូបោ
ចុន្ទោបិ តត្ថ បមុខេ [៣] និសីទីតិ ។

[១៦៨] អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ សិយា ខោ បនានន្ទ ចុន្ទស្ស កម្មារបុត្តស្ស កោចិ វិប្បដិសារំ ឧប្បាទេយ្យ[៤] តស្ស តេ អាវុសោ ចុន្ទ អលាភា តស្ស តេ ទុល្លទ្ធំ យស្ស តេ តថាគតោ បច្ឆិមំ បិណ្ឌបាតំ បរិភុញ្ជិត្វា បរិនិព្វុតោតិ ។ ចុន្ទស្ស អានន្ទ កម្មារបុត្តស្ស ឯវំ វិប្បដិសារោ បដិវិនោទេតព្វោ តស្ស តេ អាវុសោ ចុន្ទ លាភា តស្ស តេ សុលទ្ធំ យស្ស តេ តថាគតោ បច្ឆិមំ បិណ្ឌបាតំ បរិភុញ្ជិត្វា បរិនិព្វុតោ ។ សម្មុខា មេ តំ អាវុសោ ចុន្ទ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ

១ ឱ.ម. សន្ថរ ។ ២ ម. និសជ្ជំ ។ ៣ ម. តស្ស សម្មុខេ ។ ៤ ឱ. ឧប្បាទេយ្យ ។



ត្រាស់ហៅភិក្ខុ ឈ្មោះចុន្ទកៈថា អ្នកចូរក្រាលសង្ឃាដិ ៤ ជាន់ ឲ្យតថាគតចុះ តថាគតនឹងសិង ។ ចុន្ទកភិក្ខុនោះ កាលបើព្រះសាស្តា ព្រះអង្គមានព្រះហឫទ័យអប់រំ ទ្រង់ដាស់តឿនហើយ ក្រាលសង្ឃាដិ៤ ជាន់ ដោយឆាប់រហ័ស ។ ព្រះសាស្តា មានព្រះកាយលំបាកក្រៃលែង ទ្រង់ផ្ទំ ចំណែកចុន្ទកភិក្ខុ ក៏អង្គុយចំពោះព្រះភក្ត្រ ក្នុងទីនោះដែរ ។

[១៦៨] គ្រានោះ ព្រះមានព្រះភាគ ត្រាស់ហៅព្រះអានន្ទដ៏មានអាយុ មកថា ម្នាលអានន្ទ បើមានបុគ្គលណាមួយ ញុំាងសេចក្តីក្តៅក្រហាយ ឲ្យកើតឡើង ដល់ចុន្ទកម្មារបុត្តថា ម្នាលអាវុសោចុន្ទ អ្នកឥតលាភ អ្នកបានផលអាក្រក់ ព្រោះថា ព្រះតថាគត ទ្រង់សោយបិណ្ឌបាត របស់អ្នកជាទីបំផុត ហើយបរិនិព្វាន ។ ម្នាលអានន្ទ អ្នកត្រូវបន្ទោបង់ នូវសេចក្តីក្តៅក្រហាយ នៃចុន្ទកម្មារបុត្ត យ៉ាងនេះថា ម្នាលអាវុសោចុន្ទៈ លាភរបស់អ្នកហើយ អ្នកបានល្អហើយ ព្រោះថា ព្រះតថាគត ទ្រង់សោយបិណ្ឌបាត របស់អ្នកជាទីបំផុត ហើយបរិនិព្វាន ។ ម្នាលអាវុសោចុន្ទៈ ពាក្យនុ៎ះ ខ្ញុំបានស្តាប់ ចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគ បានទទួលចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគថា

ទ្វេមេ បិណ្ឌបាតា សមសមផលា សមសមវិបាកា(១) អតិវិយ អញ្ញេហិ បិណ្ឌបាតេហិ មហប្ផលតរា ច មហានិសំសតរា ច ។ កតមេ ទ្វេ ។ យញ្ច បិណ្ឌបាតំ បរិភុញ្ជិត្វា តថាគតោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុជ្ឈតិ យញ្ច បិណ្ឌបាតំ បរិភុញ្ជិត្វា អនុបាទិសេសាយ និព្ពានធាតុយា បរិនិព្ពាយតិ ឥមេ ទ្វេ បិណ្ឌបាតា សមសមផលា សមសមវិបាកា អតិវិយ អញ្ញេហិ បិណ្ឌបាតេហិ មហប្ផលតរា ច មហានិសំសតរា ច ។ អាយុសំវត្តនិកំ អាយស្មតា ចុន្ទេន កម្មារបុត្តេន កម្មំ ឧបចិតំ វណ្ណសំវត្តនិកំ អាយស្មតា ចុន្ទេន កម្មារបុត្តេន កម្មំ ឧបចិតំ សុខសំវត្តនិកំ អាយស្មតា ចុន្ទេន កម្មារបុត្តេន កម្មំ ឧបចិតំ សគ្គសំវត្តនិកំ អាយស្មតា ចុន្ទេន កម្មារបុត្តេន កម្មំ ឧបចិតំ យសសំវត្តនិកំ អាយស្មតា ចុន្ទេន កម្មារបុត្តេន កម្មំ ឧបចិតំ អាធិបតេយ្យសំវត្តនិកំ អាយស្មតា ចុន្ទេន កម្មារបុត្តេន កម្មំ ឧបចិតន្តិ ។ ចុន្ទស្ស អានន្ទ កម្មារបុត្តស្ស ឯវំ វិប្បដិសារោ បដិវិនោទេតព្វោតិ ។ អថខោ ភគវា

១ ម. សមសមផលា សមសមវិបាកា ។





បិណ្ឌបាតពីរនេះ មានផលស្មើ ៗ គ្នា មានវិបាកស្មើ ៗ គ្នា មានផលច្រើនផង មានអានិសង្សច្រើនផង ជាងបិណ្ឌបាតឯទៀត ៗ បិណ្ឌបាតពីរ តើដូចម្តេចខ្លះ ។ គឺបិណ្ឌបាត ដែលតថាគត ទ្រង់សោយហើយ ត្រាស់ដឹងអនុត្តរសម្មាសម្ពោធិ ១ បិណ្ឌបាត ដែលតថាគត សោយហើយបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ១ បិណ្ឌបាតទាំងពីរនេះ មានផលស្មើៗគ្នា មានវិបាកស្មើ ៗ គ្នា មានផលច្រើនផង មានអានិសង្សច្រើនផង ជាងបិណ្ឌបាតឯទៀត ៗ កម្មដែលចុន្ទកម្មារបុត្តដ៏មានអាយុ សន្សំហើយ ជាកម្មប្រព្រឹត្តទៅ ដើម្បីអាយុ កម្មដែលចុន្ទកម្មារបុត្តដ៏មានអាយុ សន្សំហើយ ជាកម្មប្រព្រឹត្តទៅ ដើម្បីវណ្ណសម្បទា កម្មដែលចុន្ទកម្មារបុត្តដ៏មានអាយុ សន្សំហើយ ជាកម្មប្រព្រឹត្តទៅ ដើម្បីសេចក្តីសុខ កម្មដែលចុន្ទកម្មារបុត្តដ៏មានអាយុ សន្សំហើយ ជាកម្មប្រព្រឹត្តទៅ ដើម្បីសួគ៌ កម្មដែលចុន្ទកម្មារបុត្តដ៏មានអាយុ សន្សំហើយ ជាកម្មប្រព្រឹត្តទៅ ដើម្បីយស កម្មដែលចុន្ទកម្មារបុត្តដ៏មានអាយុ សន្សំហើយ ជាកម្មប្រព្រឹត្តទៅ ដើម្បីភាពៈជាធំ ។ ម្នាលអានន្ទ អ្នកត្រូវបន្ទោបង់នូវសេចក្តីក្តៅក្រហាយ របស់ចុន្ទកម្មារបុត្ត ចេញយ៉ាងនេះឯង ។ លំដាប់នោះ ព្រះមានព្រះភាគ

ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

ទទតោ បុញ្ញំ បវឌ្ឍតិ សញ្ញមតោ វេរំ ន ចីយតិ

កុសលោ ច ជហាតិ បាបកំ រាគទោសមោហក្ខយា

សនិព្វុតោតិ ។ បញ្ចមំ(១) ។

(១៦៨) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា មគធេសុ ចារិកញ្ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ យេន បាដលិគាមោ តទវសរិ ។ អស្សោសុំ ខោ បាដលិគាមិយា ឧបាសកា ភគវា កិរ មគធេសុ ចារិកញ្ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ បាដលិគាមំ អនុប្បត្តោតិ ។ អថ ខោ បាដលិគាមិយា ឧបាសកា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ បាដលិគាមិយា ឧបាសកា ភគវន្តំ ឯតទវោចុំ អធិវាសេតុ នោ ភន្តេ ភគវា អាវសថាគារន្តិ ។ អធិវាសេតិ(២) ភគវា តុណ្ហីភាវេន ។ អថ ខោ បាដលិគាមិយា ឧបាសកា ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា

១ ម. បញ្ចមំ នត្ថិ ។ ២ ម. អធិវាសេសិ ។



ក្រាបទូលសេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

បុណ្យ រមែងចំរើន ដល់បុគ្គលអ្នកឱ្យ បុគ្គលអ្នកសង្រួម រមែងមិនសន្សំទុកនូវពៀរ អ្នកឈ្លាស រមែងលះបង់កម្មដ៏លាមក បុគ្គលបរិនិព្វាន ព្រោះអស់ទៅនៃរាគៈ ទោសៈ មោហៈ ។ សូត្រទី ៥ ។

(១៦៨) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ត្រាច់ទៅកាន់ចារិក ក្នុងដែនមគធៈ ជាមួយនឹងភិក្ខុសង្ឃ ច្រើនរូប បានទៅដល់បាដលិគ្រាម ។ ពួកឧបាសកឧបាសិកាអ្នកបាដលិគ្រាមបានឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់យាងទៅកាន់ចារិក ក្នុងដែនមគធៈ ជាមួយនឹងភិក្ខុសង្ឃច្រើនរូប ឥឡូវនេះ យាងមកដល់បាដលិគ្រាមហើយ ។ គ្រានោះឯង ពួកឧបាសកឧបាសិកា អ្នកបាដលិគ្រាម ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះពួកឧបាសកឧបាសិកា អ្នកបាដលិគ្រាម អង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទទួលរោងសំណាក់ នៃពួកខ្ញុំព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ទទួលដោយតុណ្ហីភាព ។ គ្រានោះឯង ពួកឧបាសកឧបាសិកាអ្នកបាដលិគ្រាមដឹងច្បាស់ថា ព្រះមានព្រះភាគទ្រង់ទទួលហើយ ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណ

យេន អាវសថាគារំ តេនុបសង្កមឹសុ ឧបសង្កមិត្វា សព្វសន្ថរិំ អាវសថាគារំ សន្ថរិត្វា អាសនានិ បញ្ញាបេត្វា ឧទកមណិកំ បតិដ្ឋាបេត្វា តេលប្បទីបំ អារោបេត្វា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ បាដលិគាមិយា ឧបាសកា ភគវន្តំ ឯតទវោចុំ សព្វសន្ថរិំ សន្ថតំ ភន្តេ អាវសថាគារំ អាសនានិ បញ្ញត្តានិ ឧទកមណិកោ បតិដ្ឋាបិតោ តេលប្បទីបោ អារោបិតោ យស្សទានិ ភន្តេ ភគវា កាលំ មញ្ញតីតិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សទ្ធិំ ភិក្ខុសង្ឃេន យេន អាវសថាគារំ តេនុបសង្កមិ ឧបសង្កមិត្វា បាទេ បក្ខាលេត្វា អាវសថាគារំ បវិសិត្វា មជ្ឈិមំ ថម្ភំ និស្សាយ បុរត្ថាភិមុខោ និសីទិ ។ ភិក្ខុសង្ឃោបិ ខោ បាទេ បក្ខាលេត្វា អាវសថាគារំ បវិសិត្វា បច្ឆិមំ ភិត្តិំ និស្សាយ បុរត្ថាភិមុខោ និសីទិ ភគវន្តំយេវ បុរក្ខត្វា ។ បាដលិគាមិយាបិ ខោ ឧបាសកា បាទេ បក្ខាលេត្វា



ហើយចូលទៅឯរោងសំណាក់ លុះចូលទៅដល់ហើយ ក៏ក្រាលកម្រាលពេញក្នុងរោងសំណាក់ តាក់តែងអាសនៈ ដម្កល់ក្អមទឹក លើកឡើងនូវប្រទីបប្រេងហើយ ចូលមកគាល់ព្រះមានព្រះភាគ លុះចូលមកដល់ក្រាបថ្វាយបង្គំ ព្រះមានព្រះភាគ ហើយឋិតនៅ ក្នុងទីសមគួរ ។ លុះពួកឧបាសកឧបាសិកា អ្នកបាដលិគ្រាម ឋិតនៅ ក្នុងទីសមគួរហើយ ក្រាបបង្គំទូល ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន រោងសំណាក់នៃពួកខ្ញុំព្រះអង្គ បានក្រាលកម្រាលពេញហើយ អាសនៈបានតាក់តែងហើយ ក្អមទឹកបានដម្កល់ទុកហើយ ចង្កៀងប្រេង ក៏បានលើកឡើងហើយ បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ទ្រង់សំគាល់កាលគួរ ក្នុងកាលឥឡូវនេះ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ជាមួយភិក្ខុសង្ឃ យាងទៅកាន់រោងសំណាក់ លុះចូលទៅដល់ហើយ ក៏លាងព្រះបាទ រួចចូលទៅកាន់រោងសំណាក់ ទ្រង់គង់បែរព្រះភក្ត្រទៅទិសខាងកើត ផ្អែកនឹងសសរកណ្ដាល ។ ចំណែកខាងភិក្ខុសង្ឃ លាងជើងរួចហើយ ចូលទៅឯរោងសំណាក់ អង្គុយបែរមុខទៅទិសខាងកើត ផ្អែកនឹងជញ្ជាំងខាងក្រោយ មានព្រះមានព្រះភាគគង់ខាងមុខ ។ ពួកឧបាសកឧបាសិកា អ្នកបាដលិគ្រាម លាងជើងរួចហើយ

អាវសថាគារំ បវិសិត្វា បុរត្ថិមំ ភិត្តិំ និស្សាយ បច្ចិមា-ភិមុខា និសីទិំសុ ភគវន្តំយេវ បុរក្ខត្វា ។

(១៧០) អថខោ ភគវា បាដលិគាមិយេ ឧបាសកេ អាមន្តេសិ បញ្ចិមេ គហបតយោ អាទីនវា ទុស្សីលស្ស សីលវិបត្តិយា ។ កតមេ បញ្ច ។ ឥធ គហបតយោ ទុស្សីលោ សីលវិបន្នោ បមាទាធិករណំ មហតិំ ភោគ-ជានិំ និគច្ឆតិ អយំ បឋមោ អាទីនវោ ទុស្សីលស្ស សីលវិបត្តិយា ។ បុន ច បរំ គហបតយោ ទុស្សីលស្ស សីលវិបន្នស្ស បាបកោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ អយំ ទុតិយោ អាទីនវោ ទុស្សីលស្ស សីលវិបត្តិយា ។ បុន ច បរំ គហបតយោ ទុស្សីលោ សីលវិបន្នោ យញ្ញទេវ(១) បរិសំ ឧបសង្កមតិ យទិ ខត្តិយបរិសំ យទិ ព្រាហ្មណបរិសំ យទិ គហបតិបរិសំ យទិ សមណបរិសំ អវិសារទោ ឧបសង្កមតិ មង្កុភូតោ អយំ តតិយោ អាទីនវោ ទុស្សីលស្ស សីលវិបត្តិយា ។ បុន ច បរំ គហបតយោ ទុស្សីលោ សីលវិបន្នោ សម្មូឡ្ហោ កាលំ ករោតិ អយំ ចតុត្ថោ អាទីនវោ ទុស្សីលស្ស សីលវិបត្តិយា ។

១ ម. យំ យទេវ ។



ចូលទៅកាន់រោងសំណាក់ អង្គុយបែរមុខ ទៅទិសខាងលិច ផ្អែកនឹងជញ្ជាំងខាងមុខ ធ្វើព្រះមានព្រះភាគ ពីខាងមុខដែរ ។

(១៧០) គ្រានោះឯង ព្រះមានព្រះភាគ ត្រាស់ហៅពួកឧបាសក ឧបាសិកា អ្នកបាដលិគ្រាមមកថា ម្នាលគហបតីទាំងឡាយ ទោសនៃសីលវិបត្តិ របស់បុគ្គលទ្រុស្តសីលមាន ៥ យ៉ាង ។ ទោស ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលគហបតីទាំងឡាយ បុគ្គលក្នុងលោកនេះ ជាអ្នកទ្រុស្តសីល វិបត្តិចាកសីល តែងដល់នូវសេចក្តីសាបសូន្យភោគៈច្រើន ព្រោះមានសេចក្តីប្រមាទ ជាហេតុ នេះជាទោសនៃសីលវិបត្តិ របស់បុគ្គលទ្រុស្តសីល ទី ១ ។ ម្នាលគហបតីទាំងឡាយ មួយទៀត កិត្តិសព្ទដ៏អាក្រក់ របស់បុគ្គលទ្រុស្តសីល វិបត្តិចាកសីល ផ្សាយទៅ នេះជាទោសនៃសីលវិបត្តិ របស់បុគ្គលទ្រុស្តសីល ទី ២ ។ ម្នាលគហបតីទាំងឡាយ មួយទៀត បុគ្គលទ្រុស្តសីល វិបត្តិចាកសីល ចូលទៅកាន់បរិស័ទណា ៗ ទោះខត្តិយបរិស័ទក្តី ព្រាហ្មណបរិស័ទក្តី គហបតិបរិស័ទក្តី សមណ-បរិស័ទក្តី រមែងមិនក្លៀវក្លា មានមុខខងចុះ នេះជាទោសនៃសីលវិបត្តិ របស់បុគ្គលទ្រុស្តសីល ទី ៣ ។ ម្នាលគហបតីទាំងឡាយ មួយទៀត បុគ្គលទ្រុស្តសីល វិបត្តិចាកសីល តែងធ្វើមរណកាលទាំងវង្វេង នេះជាទោសនៃសីលវិបត្តិ របស់បុគ្គលទ្រុស្តសីល ទី ៤ ។

បុន ច បរំ គហបតយោ ទុស្សីលោ សីលវិបន្នោ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ អយំ បញ្ចមោ អាទីនវោ ទុស្សីលស្ស សីលវិបត្តិយា ។ ឥមេ ខោ គហបតយោ បញ្ច អាទីនវា ទុស្សីលស្ស សីលវិបត្តិយា ។ បញ្ចិមេ គហបតយោ អានិសំសា សីលវតោ សីលសម្បទាយ ។ កតមេ បញ្ច ។ ឥធ គហបតយោ សីលវា សីលសម្បន្នោ អប្បមាទាធិករណំ មហន្តំ ភោគក្ខន្ធំ អធិគច្ឆតិ អយំ បឋមោ អានិសំសោ សីលវតោ សីលសម្បទាយ ។ បុន ច បរំ គហបតយោ សីលវតោ សីលសម្បន្នស្ស កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ អយំ ទុតិយោ អានិសំសោ សីលវតោ សីលសម្បទាយ ។ បុន ច បរំ គហបតយោ សីលវា សីលសម្បន្នោ យញ្ញទេវ បរិសំ ឧបសង្កមតិ យទិ ខត្តិយបរិសំ យទិ ព្រាហ្មណបរិសំ យទិ គហបតិបរិសំ យទិ សមណបរិសំ វិសារទោ ឧបសង្កមតិ អមង្កុភូតោ អយំ តតិយោ អានិសំសោ សីលវតោ សីលសម្បទាយ ។ បុន ច បរំ គហបតយោ សីលវា



ម្នាលគហបតីទាំងឡាយ មួយទៀត បុគ្គលទ្រុស្តសីល វិបត្តិចាកសីល លុះបែកធ្លាយរាងកាយ ស្លាប់ទៅ រមែងទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាតនរក នេះជាទោសនៃសីលវិបត្តិ របស់បុគ្គលទ្រុស្តសីលទី ៥ ។ ម្នាលគហបតីទាំងឡាយ ទោសនៃសីលវិបត្តិ របស់បុគ្គលទ្រុស្តសីល មាន ៥ យ៉ាងនេះឯង ។ ម្នាលគហបតីទាំងឡាយ អានិសង្ស នៃសីលសម្បទា របស់បុគ្គលអ្នកមានសីល នេះមាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលគហបតីទាំងឡាយ ក្នុងលោកនេះ បុគ្គលមានសីល បរិបូណ៌ដោយសីល តែងបានគំនរទ្រព្យច្រើន មានសេចក្តីមិនប្រមាទ ជាហេតុ នេះជាអានិសង្ស នៃសីលសម្បទា របស់បុគ្គលមានសីលទី ១ ។ ម្នាលគហបតីទាំងឡាយ មួយទៀត កិត្តិសព្ទដ៏ពីរោះ របស់បុគ្គលមានសីល បរិបូណ៌ដោយសីល តែងខ្ចរខ្ចាយទៅ នេះជាអានិសង្ស នៃសីលសម្បទារបស់បុគ្គលមានសីលទី ២ ។ ម្នាលគហបតីទាំងឡាយ មួយទៀត បុគ្គលមានសីល បរិបូណ៌ដោយសីល ចូលទៅកាន់បរិស័ទណា ៗ ទោះជាខត្តិយបរិស័ទក្តី ព្រាហ្មណបរិស័ទក្តី គហបតិបរិស័ទក្តី សមណបរិស័ទក្តី រមែងក្លៀវក្លា មិនមានមុខងងុះ នេះជាអានិសង្សនៃសីលសម្បទា របស់បុគ្គលមានសីលទី ៣ ។ ម្នាលគហបតីទាំងឡាយ មួយទៀត បុគ្គលមាន

សីលសម្បន្នោ អសម្មូឡ្ហោ កាលំ ករោតិ អយំ ចតុត្ថោ អានិសំសោ សីលវតោ សីលសម្បទាយ ។ បុន ច បរំ គហបតយោ សីលវា សីលសម្បន្នោ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ អយំ បញ្ចមោ អានិសំសោ សីលវតោ សីល-សម្បទាយ ។ ឥមេ ខោ គហបតយោ បញ្ច អានិសំសា សីលវតោ សីលសម្បទាយាតិ ។

(១៩១) អថខោ ភគវា បាដលិគាមិយេ ឧបាសកេ ពហុទេវ រត្តិយា[១] ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧយ្យោជេសិ អភិក្កន្តា ខោ គហបតយោ រត្តិ យស្សទានិ កាលំ មញ្ញថាតិ ។ អថខោ បាដលិគាមិយា ឧបាសកា ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កមឹសុ ។ អថខោ ភគវា អចិរបក្កន្តេសុ បាដលិគាមិយេសុ ឧបាសកេសុ សុញ្ញាគារំ បាវិសិ ។

១ ម. ម. រត្តឹ ។



សីល បរិបូណ៌ដោយសីល រមែងមិនធ្វើមរណកាល ទាំងវង្វេង នេះជាអានិសង្ស នៃសីលសម្បទា របស់បុគ្គលមានសីលទី ៤ ។ ម្នាលគហបតីទាំងឡាយ មួយវិញទៀត បុគ្គលមានសីល បរិបូណ៌ដោយសីល លុះបែកធ្លាយរាងកាយ ស្លាប់ទៅ រមែងទៅកើត ក្នុងសុគតិ សួគ៌ទេវលោក នេះជាអានិសង្ស នៃសីលសម្បទា របស់បុគ្គលមានសីលទី ៥ ។ ម្នាលគហបតីទាំងឡាយ អានិសង្ស នៃសីលសម្បទា របស់បុគ្គលមានសីល មាន ៥ យ៉ាងនេះឯង ។

(១៩១) គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ញ៉ាំងពួកឧបាសកបាដលិគាម អ្នកបាដលិគ្រាម ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា អស់រាត្រីច្រើន ហើយទ្រង់បញ្ជូនថា ម្នាលគហបតីទាំងឡាយ រាត្រីជ្រៅហើយ អ្នកទាំងឡាយ ចូរសំគាល់កាលគួរនឹងទៅ ក្នុងកាលឥឡូវនេះចុះ ។ គ្រានោះឯង ពួកឧបាសកបាដលិគាម អ្នកបាដលិគ្រាម ត្រេកអរ រីករាយ ចំពោះភាសិត នៃព្រះមានព្រះភាគ ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ចៀសចេញទៅ ។ លំដាប់នោះឯង ព្រះមានព្រះភាគ កាលពួកឧបាសកបាដលិគាម អ្នកបាដលិគ្រាម ចៀសចេញទៅ មិនយូរប៉ុន្មាន ក៏យាងចូលទៅកាន់សុញ្ញាគារស្ងាត់ ។

(១៧៦) តេន ខោ បន សមយេន សុនីធវស្សការា មគធមហាមត្តា បាដលិគាមេ នគរំ មាបេន្តិ វជ្ជីនំ បដិពាហាយ ។ តេន ខោ បន សមយេន សម្ពហុលា ទេវតាយោ សហស្សេវ(១) បាដលិគាមេ វត្ថូនិ បរិគ្គណ្ហន្តិ ។ យស្មឹ បទេសេ មហេសក្ខា ទេវតា វត្ថូនិ បរិគ្គណ្ហន្តិ មហេសក្ខានំ តត្ថ រញ្ញំ រាជមហាមត្តានំ ចិត្តានិ នមន្តិ និវេសនានិ មាបេតុំ ។ យស្មឹ បទេសេ មជ្ឈិមា ទេវតា វត្ថូនិ បរិគ្គណ្ហន្តិ មជ្ឈិមានំ តត្ថ រញ្ញំ រាជមហាមត្តានំ ចិត្តានិ នមន្តិ និវេសនានិ មាបេតុំ ។ យស្មឹ បទេសេ នីចា ទេវតា វត្ថូនិ បរិគ្គណ្ហន្តិ នីចានំ តត្ថ រញ្ញំ រាជមហាមត្តានំ ចិត្តានិ នមន្តិ និវេសនានិ មាបេតុំ ។ អទ្ទសា ខោ ភគវា ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន តា ទេវតាយោ សហស្សេវ បាដលិគាមេ វត្ថូនិ បរិគ្គណ្ហន្តិយោ ។ យស្មឹ បទេសេ មហេសក្ខា ទេវតា វត្ថូនិ បរិគ្គណ្ហន្តិ មហេសក្ខានំ តត្ថ រញ្ញំ រាជមហាមត្តានំ ចិត្តានិ នមន្តិ និវេសនានិ មាបេតុំ ។

១ ម. សហស្សស្សេ ។





[១៧៦] សម័យនោះឯង មហាមាត្យ ក្នុងដែនមគធៈ ឈ្មោះសុនីធៈនិងវស្សការៈ កំពុងកសាងក្រុង ក្នុងប្រទេសបាដលិគ្រាម ដើម្បីការពារពួកស្ដេចវជ្ជី នៅ ក្នុងដែនវជ្ជី ។ សម័យនោះឯង ពួកទេវតាជាច្រើនពាន់ពាន់ កំណត់យកទីទាំងឡាយ ក្នុងបាដលិគ្រាម ។ ពួកទេវតាមានស័ក្ដិធំ កំណត់យកទីទាំងឡាយ ក្នុងប្រទេសណា ចិត្តរបស់ព្រះរាជានឹងរាជមហាមាត្យទាំងឡាយ មានស័ក្ដិធំ រមែងឱនទៅ ដើម្បីកសាងនិវេសនដ្ឋាន ក្នុងប្រទេសនោះៗ ពួកទេវតាមានស័ក្ដិ ជាកណ្ដាល កំណត់យកទីទាំងឡាយ ក្នុងប្រទេសណា ចិត្តរបស់ព្រះរាជានឹងរាជមហាមាត្យទាំងឡាយ មានស័ក្ដិ ជាកណ្ដាល ក៏ឱនទៅ ដើម្បីកសាងនិវេសនដ្ឋាន ក្នុងប្រទេសនោះផង ។ ពួកទេវតាមានស័ក្ដិតូច កំណត់យកទីទាំងឡាយ ក្នុងប្រទេសណា ចិត្តរបស់ព្រះរាជានឹងរាជមហាមាត្យទាំងឡាយមានស័ក្ដិតូច ក៏ឱនទៅ ដើម្បីកសាងនិវេសនដ្ឋាន ក្នុងប្រទេសនោះផង ។ ព្រះមានព្រះភាគ មានទិព្វចក្ខុ ដ៏បរិសុទ្ធ កន្លងបង់ចក្ខុរបស់មនុស្សសាមញ្ញ បានទ្រង់ឃើញពួកទេវតា ពាន់នោះ ដែលកំពុងកំណត់យកទីទាំងឡាយ ក្នុងបាដលិគ្រាម ពួកទេវតាមានស័ក្ដិធំ កំណត់យកទីទាំងឡាយ ក្នុងប្រទេសណា ចិត្តរបស់ព្រះរាជានឹងរាជមហាមាត្យទាំងឡាយ មានស័ក្ដិធំ ក៏ឱនទៅ ដើម្បីកសាងនិវេសនដ្ឋាន ក្នុងប្រទេសនោះផង ។

យស្មឹ បទេសេ មជ្ឈិមា ទេវតា វិហរន្តិ បរិគ្គណ្ហន្តិ មជ្ឈិមានំ តត្ថ រញ្ញោ រាជមហាមត្តានំ ចិត្តានិ នមន្តិ និវេសនានិ មាបេតុំ ។ យស្មឹ បទេសេ នីចា ទេវតា វត្ថូនិ បរិគ្គណ្ហន្តិ នីចានំ តត្ថ រញ្ញោ រាជមហាមត្តានំ ចិត្តានិ នមន្តិ និវេសនានិ មាបេតុំ ។ អថខោ ភគវា តស្សា រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ អាយស្មន្តំ អានន្ទំ អាមន្តេសិ កេ នុ ខោ អានន្ទ បាដលិគាមេ នគរំ មាបេន្តីតិ ។ សុនីធវស្សការា ភន្តេ មគធមហាមត្តា បាដលិគាមេ នគរំ មាបេន្តិ វជ្ជីនំ បដិពាហាយាតិ ។ សេយ្យថាបិ អានន្ទ ទេវេហិ តាវតឹសេហិ សទ្ធឹ មន្តេត្វា ឯវមេវ ខោ អានន្ទ សុនីធវស្សការា មគធមហាមត្តា បាដលិគាមេ នគរំ មាបេន្តិ វជ្ជីនំ បដិពាហាយ ។ ឥធាហំ អានន្ទ អទ្ទសំ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សម្ពហុលា ទេវតាយោ សហស្សេវ បាដលិគាមេ វត្ថូនិ បរិគ្គណ្ហន្តិយោ ។



ពួកទេវតាមានស័ក្តិជាកណ្តាល កំណត់យកទីតាំងឡាយ ក្នុងប្រទេសណា ចិត្តរបស់ព្រះរាជានិងរាជមហាមាត្យទាំងឡាយ មានស័ក្តិជាកណ្តាល ក៏ទនទៅ ដើម្បីកសាងនិវេសនដ្ឋាន ក្នុងប្រទេសនោះដែរ ។ ពួកទេវតាមានស័ក្តិទាប កំណត់យកទីតាំងឡាយ ក្នុងប្រទេសណា ចិត្តរបស់ព្រះរាជានិងរាជមហាមាត្យទាំងឡាយ មានស័ក្តិទាប ក៏ទនទៅ ដើម្បីកសាងនិវេសនដ្ឋាន ក្នុងប្រទេសនោះដែរ ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់តើនឡើង ក្នុងបច្ចូសសម័យ នៃរាត្រីនោះហើយ ត្រាស់សួរព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ អ្នកណាខ្លះ កំពុងកសាងក្រុង ក្នុងប្រទេសបាដលិគ្រាម ។ បពិត្រព្រះអង្គដ៏ចំរើន មហាមាត្យ ក្នុងដែនមគធៈ ឈ្មោះសុនីធៈ និងវស្សការៈ កសាងក្រុង ក្នុងបាដលិគ្រាម ដើម្បីការពារពួកស្តេចលិច្ឆវី ក្នុងដែនវជ្ជី ។ ម្នាលអានន្ទ មហាមាត្យ ក្នុងដែនមគធៈ ឈ្មោះសុនីធៈ និងវស្សការៈ ហាក់ដូចជាបានប្រឹក្សា ជាមួយនឹងពួកទេវតា ក្នុងឋានតាវត្តឹង្សហើយណាមិញ ។ ម្នាលអានន្ទ មហាមាត្យ ក្នុងដែនមគធៈឈ្មោះសុនីធៈនិងវស្សការៈ កសាងក្រុងបាដលិគ្រាម ដើម្បីការពារពួកស្តេចលិច្ឆវី ក្នុងដែនវជ្ជី ក៏យ៉ាងនោះដែរ ។ ម្នាលអានន្ទ អម្បាញ់មិញនេះ តថាគតបាន ទិព្វចក្ខុដ៏បរិសុទ្ធ កន្លងបង់ចក្ខុរបស់មនុស្សសាមញ្ញ បានឃើញពួកទេវតាជាច្រើន ពាន់នាក់ កំពុងកំណត់យកទីតាំងឡាយ ក្នុងបាដលិគ្រាម ។

យស្មឹ បទេសេ មហេសក្ខា ទេវតា វត្ថូនិ បរិគ្គណ្ហន្តិ មហេសក្ខានំ តត្ថ រញ្ញំ រាជមហាមត្តានំ ចិត្តានិ នមន្តិ និវេសនានិ មាបេតុំ ។ យស្មឹ បទេសេ មជ្ឈិមា ទេវតា វត្ថូនិ បរិគ្គណ្ហន្តិ មជ្ឈិមានំ តត្ថ រញ្ញំ រាជមហាមត្តានំ ចិត្តានិ នមន្តិ និវេសនានិ មាបេតុំ ។ យស្មឹ បទេសេ នីចា ទេវតា វត្ថូនិ បរិគ្គណ្ហន្តិ នីចានំ តត្ថ រញ្ញំ រាជមហាមត្តានំ ចិត្តានិ នមន្តិ និវេសនានិ មាបេតុំ ។ យាវតា អានន្ទ អរិយំ អាយតនំ យាវតា វណិប្បថោ ឥទំ អគ្គនគរំ ភវិស្សតិ បុដភេទនំ ។ បាដលិបុត្តស្ស ខោ អានន្ទ តយោ អន្តរាយា ភវិស្សន្តិ អគ្គិតោ វា ឧទកតោ វា មិថុភេទតោ វាតិ ។

(១៧៣) អថខោ សុនីធវស្សការា មគធមហាមត្តា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ អដ្ឋំសុ ។



ពួកទេវតាមានស័ក្តិធំ កំណត់យកទីតាំងឡាយ ក្នុងប្រទេសណា ចិត្តរបស់ព្រះរាជានឹងរាជមហាមាត្យមានស័ក្តិធំ ក៏ឱនទៅ ដើម្បីកសាងនិវេសនដ្ឋាន ក្នុងប្រទេសនោះដែរ ។ ពួកទេវតាមានស័ក្តិ ជាកណ្តាល កំណត់យកទីតាំងឡាយ ក្នុងប្រទេសណា ចិត្តរបស់ព្រះរាជានឹងរាជមហាមាត្យ មានស័ក្តិ ជាកណ្តាល ក៏ឱនទៅ ដើម្បីកសាងនិវេសនដ្ឋាន ក្នុងប្រទេសនោះដែរ ។ ពួកទេវតាមានស័ក្តិទាប កំណត់យកទីតាំងឡាយ ក្នុងប្រទេសណា ចិត្តរបស់ព្រះរាជានឹងរាជមហាមាត្យមានស័ក្តិទាប ក៏ឱនទៅ ដើម្បីកសាងនិវេសនដ្ឋាន ក្នុងប្រទេសនោះដែរ ។ ម្នាលអានន្ទ ទីប្រជុំរបស់អរិយបុគ្គល ដែលមានតាំងប៉ុន្មាន ផ្លូវជំនួញ ដែលមានតាំងប៉ុន្មាន ក្រុងបាដលិបុត្តនេះ ជានគរដ៏ប្រសើរ នឹងជាកន្លែងស្រាយបង្វិចទ្រព្យ[1] ។ ម្នាលអានន្ទ ក្រុងបាដលិបុត្ត មុខជានឹងមានសេចក្តីអន្តរាយ ៣ យ៉ាង គឺអន្តរាយអំពីភ្លើង ១ អំពីទឹក ១ អំពីការបែកបាក់គ្នានឹងគ្នា ១ ។

(១៧៣) គ្រានោះ មហាមាត្យ ក្នុងដែនមគធៈ ឈ្មោះសុនីធៈនឹងវស្សការៈ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យ ដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ទើបឋិតនៅ ក្នុងទីសមគួរ ។

១ ពោលគឺបាដលិបុត្តនោះ ជាកន្លែងសម្រាប់ស្រាយបង្វិចទ្រព្យ របស់បុគ្គលអ្នកមានទ្រព្យ និងជាទីសម្បូណ៌ហូរហៀរ ដោយទ្រព្យសម្បត្តិ ។

ឯកមន្តំ ឋិតា ខោ សុនីធវស្សការា មគធមហាមត្តា ភគវន្តំ ឯតទវោចុំ អធិវាសេតុ នោ ភវំ គោតមោ អជ្ជតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ សុនីធវស្សការា មគធមហាមត្តា ភគវតោ អធិវាសនំ វិទិត្វា យេន សកោ អាវសថោ តេនុបសង្កមឹសុ ឧបសង្កមិត្វា សកេ អាវសថេ បណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេត្វា ភគវតោ កាលំ អារោចាបេសុំ កាលោ ភោ គោតម និដ្ឋិតំ ភត្តន្តិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សទ្ធឹ ភិក្ខុសង្ឃេន យេន សុនីធវស្សការានំ មគធមហាមត្តានំ អាវសថោ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ សុនីធវស្សការា មគធមហាមត្តា ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេត្វា សម្បវារេសុំ[*] ។ អថខោ សុនីធវស្សការា មគធមហាមត្តា ភគវន្តំ ភុត្តាវឹ ឱនីតបត្តបាណឹ អញ្ញតរំ នីចំ អាសនំ គហេត្វា ឯកមន្តំ និសីទឹសុ ។

* ឧ. សន្តប្បេសុំ សម្បវារេសុំ ។



លុះមហាមាត្យ ក្នុងដែនមគធៈ ឈ្មោះសុនីធៈនិងវស្សការៈឋិតនៅ ក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូល ព្រះមានព្រះភាគថា សូមព្រះគោតមដ៏ចំរើន ទទួលភត្តរបស់ខ្ញុំព្រះអង្គទាំងឡាយ ដើម្បីឆាន់ ក្នុងថ្ងៃនេះ ជាមួយនឹងភិក្ខុសង្ឃ ។ ព្រះមានព្រះភាគ ទ្រង់ទទួលដោយការនៅស្ងៀម ។ លំដាប់នោះ មហាមាត្យ ក្នុងដែនមគធៈ ឈ្មោះសុនីធៈនិងវស្សការៈដឹងច្បាស់ថា ព្រះមានព្រះភាគ ទទួលនិមន្តហើយ ក៏ចូលទៅកាន់លំនៅរបស់ខ្លួន លុះចូលទៅដល់ហើយ ក៏តាក់តែងខាទនីយភោជនីយាហារ ដ៏ឧត្ដម ក្នុងលំនៅរបស់ខ្លួន ហើយក្រាបទូល នូវកាលចំពោះព្រះមានព្រះភាគ ថា បពិត្រព្រះគោតមដ៏ចំរើន កាលនេះ ជាកាលគួរ ភត្តសម្រេចហើយ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ យាងចូលទៅក្នុងលំនៅ របស់មហាមាត្យ ក្នុងដែនមគធៈ ឈ្មោះសុនីធៈនិងវស្សការៈ ជាមួយនឹងភិក្ខុសង្ឃ លុះយាងចូលទៅដល់ហើយ គង់លើអាសនៈ ដែលគេក្រាលថ្វាយ ។ លំដាប់នោះ មហាមាត្យ ក្នុងដែនមគធៈ ឈ្មោះសុនីធៈនិងវស្សការៈ ក៏អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយខាទនីយភោជនីយាហារដ៏ឧត្ដម ឲ្យឆ្អែតស្កប់ស្កល់ដោយដៃខ្លួនឯង លុះគ្រាន់តែហាមឃាត់ ។ លំដាប់នោះ មហាមាត្យ ក្នុងដែនមគធៈ ឈ្មោះសុនីធៈនិងវស្សការៈ ដឹងថា ព្រះមានព្រះភាគ ទ្រង់ឆាន់រួចហើយ

ឯកមន្តំ និសិន្នេ ខោ សុនីធវស្សការេ មគធមហា-
មត្តេ ភគវា ឥមាហិ គាថាហិ អនុមោទិ

យស្មិំ បទេសេ កប្បេតិ វាសំ បណ្ឌិតជាតិយោ
សីលវន្តេត្ថ ភោជេត្វា សញ្ញតេ ព្រហ្មចារយោ[១]
យា តត្ថ ទេវតា អាសុំ តាសំ ទក្ខិណមាទិសេ
តា បូជិតា បូជយន្តិ មានិតា មានយន្តិ នំ
តតោ នំ អនុកម្បន្តិ មាតា បុត្តំវ ឱរសំ
ទេវតានុកម្បិតោ បោសោ សទា ភទ្រានិ បស្សតីតិ ។

(១៧៤) អថខោ ភគវា សុនីធវស្សការេ មគធមហា-
មត្តេ ឥមាហិ គាថាហិ អនុមោទិត្វា ឧដ្ឋាយាសនា
បក្កាមិ ។ តេន ខោ បន សមយេន សុនីធវស្សការា
មគធមហាមត្តា ភគវន្តំ បិដ្ឋិតោ បិដ្ឋិតោ អនុពទ្ធា
ហោន្តិ យេនជ្ជ សមណោ គោតមោ ទ្វារេន និក្ខ-
មិស្សតិ តំ គោតមទ្វារំ នាម ភវិស្សតិ ។ យេន តិត្ថេន
គង្គំ នទឹ តរិស្សតិ តំ គោតមតិត្ថំ នាម ភវិស្សតីតិ ។

១ ឱ. ម. ព្រហ្មចារិយេ ។



វេលាដែលលូកព្រះហស្តទៅក្នុងបាត្រ ក៏កាន់យកអាសនៈទាបមួយ ហើយអង្គុយ ក្នុងទីសមគួរ ។ កាលដែលមហាមាត្យ ក្នុងដែនមគធៈ ឈ្មោះសុនីធៈនិងវស្សការៈ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ទ្រង់អនុមោទនា ដោយគាថាទាំងនេះថា

មនុស្សជាបណ្ឌិតជាតិ សម្រេចការនៅក្នុងប្រទេសណា រមែងញុំាង
ពួកបុគ្គលអ្នកមានសីល សង្រួម ប្រព្រឹត្តធម៌ប្រសើរ ឲ្យបរិភោគ
ក្នុងប្រទេសនោះ ហើយឧទ្ទិសផលទក្ខិណាទាន ចំពោះពួក
ទេវតាដែលនៅ ក្នុងប្រទេសនោះ ទេវតាទាំងនោះ ដែលបណ្ឌិត
នោះ បូជាហើយ រមែងបូជាតបវិញ ដែលរាប់អានហើយ រមែងរាប់
អានវិញ តែងអនុគ្រោះបណ្ឌិតនោះ ព្រោះទក្ខិណានុប្បទាន
នោះ ដូចមាតាអនុគ្រោះបុត្រ ដែលកើតអំពីទ្រូង បុរសដែល
ទេវតាអនុគ្រោះហើយ តែងឃើញសេចក្តីចំរើន សព្វកាល ។

(១៧៤) គ្រានោះ ព្រះមានព្រះភាគ ទ្រង់អនុមោទនាដោយគាថាទាំងនេះ ចំពោះមហាមាត្យ ក្នុងដែនមគធៈ ឈ្មោះសុនីធៈនិងវស្សការៈរួចហើយ ទ្រង់ក្រោកចាកអាសនៈ យាងចេញទៅ ។ សម័យនោះឯង មហាមាត្យ ក្នុងដែនមគធៈ ឈ្មោះសុនីធៈនិងវស្សការៈ ដើរតាមក្រោយ ៗ នៃព្រះមានព្រះភាគ ហើយគិតថា ក្នុងថ្ងៃនេះ ព្រះសមណគោតម នឹងយាងចេញទៅ

អថ ខោ ភគវា យេន ទ្វារេន និក្ខមិ តំ គោតមទ្វារំ នាម អហោសិ ។ អថ ខោ ភគវា យេន គង្គា នទី តេនុបសង្កមិ ។ តេន ខោ បន សមយេន គង្គា នទី បូរា ហោតិ សមតិត្តិកា កាកបេយ្យា ។ អប្បេកច្ចេ មនុស្សា នាវំ បរិយេសន្តិ អប្បេកច្ចេ ឧឡុម្បំ បរិយេសន្តិ អប្បេកច្ចេ កុល្លំ ពន្ធន្តិ អបារា បារំ គន្តុកាមា ។ អថ ខោ ភគវា សេយ្យថាបិ នាម ពលវា បុរិសោ សមិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សមិញ្ជេយ្យ ឯវមេវ គង្គាយ នទិយា ឱរិមតីរេ អន្តរហិតោ បារិមតីរេ បច្ចុដ្ឋាសិ សទ្ធឹ ភិក្ខុសង្ឃេន ។ អទ្ទសា ខោ ភគវា តេ មនុស្សេ អប្បេកច្ចេ នាវំ បរិយេសន្តេ អប្បេកច្ចេ ឧឡុម្បំ បរិយេសន្តេ អប្បេកច្ចេ កុល្លំ ពន្ធន្តេ អបារា បារំ គន្តុកាមេ ។ អថ ខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

យេ តរន្តិ អណ្ណវំ សរំ
សេតុំ កត្វាន វិសជ្ជ បល្លលានិ



តាមទ្វារណា ទ្វារនោះនឹងមានឈ្មោះថា គោតមទ្វារ ។ ព្រះអង្គនឹងឆ្លងទន្លេគង្គា តាមកំពង់ណា កំពង់នោះនឹងមានឈ្មោះថា គោតមតិត្ថៈ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់យាងចេញទៅ តាមទ្វារណា ទ្វារនោះ មានឈ្មោះថា គោតមទ្វារ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់យាងចូលទៅកាន់ទន្លេគង្គា ។ សម័យនោះឯង ទន្លេគង្គាមានទឹកពេញត្រៀបត្រាស្មើនឹងមាត់ច្រាំង ល្មមក្អែកទំនឹកផឹកបាន ។ ពួកមនុស្សខ្លះ ស្វែងរកទូក ខ្លះស្វែងរកផែ ខ្លះចងក្បូន ប្រាថ្នាដើម្បីឆ្លង ពីត្រើយខាងអាយ ទៅកាន់ត្រើយខាងនាយ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់បាត់ក្នុងត្រើយខាងអាយនៃទន្លេគង្គា ទៅប្រាកដនៅត្រើយខាងនាយ ជាមួយនឹងភិក្ខុសង្ឃ ដូចបុរសមានកំឡាំង លាដៃ ដែលបត់ចូល ឬបត់ចូលនូវដៃ ដែលលាចេញ ដូច្នោះឯង ។ ព្រះមានព្រះភាគ បានឃើញពួកមនុស្សទាំងនោះ ខ្លះកំពុងស្វែងរកទូក ខ្លះកំពុងស្វែងរកផែ ខ្លះកំពុងចងក្បូន ប្រាថ្នាដើម្បីឆ្លង ពីត្រើយខាងអាយ ទៅកាន់ត្រើយខាងនាយ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់ សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

ពួកជនណា ឆ្លងទន្លេធំជ្រៅឆ្ងាយបាន ពួកជន
នោះឯង ធ្វើស្ពាន វៀរចាកបឹងទាំងឡាយ

បុញ្ញំ ឯតោ បវឌ្ឍតិ

ទិដ្ឋា[1] មេធាវិនោ ជនា ។ ឆន្ទំ[2] ។

(១៧៨) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កោសលេសុ អទ្ធានមគ្គប្បដិបន្នោ ហោតិ អាយស្មតា អានន្ទេន បច្ឆាសមណេន ។ អទ្ទសា ខោ អាយស្មា អានន្ទោ អន្តរាមគ្គេ ទ្វិធាបថំ ទិស្វាន ភគវន្តំ ឯតទវោច អយំ ភន្តេ ភគវា បន្ថោ ឥមិនា គច្ឆាមាតិ ។ ឯវំ វុត្តេ ភគវា អាយស្មន្តំ អានន្ទំ ឯតទវោច អយំ អានន្ទ បន្ថោ ឥមិនា គច្ឆាមាតិ ។ ទុតិយម្បិ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច អយំ ភន្តេ ភគវា បន្ថោ ឥមិនា គច្ឆាមាតិ ។ ទុតិយម្បិ ខោ ភគវា អាយស្មន្តំ អានន្ទំ ឯតទវោច អយំ អានន្ទ បន្ថោ ឥមិនា គច្ឆាមាតិ ។ តតិយម្បិ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច អយំ ភន្តេ ភគវា បន្ថោ ឥមិនា គច្ឆាមាតិ ។ តតិយម្បិ ខោ ភគវា អាយស្មន្តំ អានន្ទំ ឯតទវោច អយំ អានន្ទ បន្ថោ

[1] ម. ទិស្វា ។ [2] ម. ឆន្ទំ ឆន្ទំ ។



សេចក្តីពិតថា ជនណាម្នាក់ ដែលជាបណ្ឌិត រមែងដើរទៅក្នុងផ្លូវ ចំណែកជន ជាអ្នកប្រាជ្ញដ៏ពីរោះ (មិនចាប់ក្បួន) ក៏ដើរទៅខាង ។ សូត្រទី ៦ ។

(១៧៨) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់យាងទៅកាន់ផ្លូវឆ្ងាយ ក្នុងដែនកោសល មានព្រះអានន្ទមានអាយុ ជាបច្ឆាសមណៈ ។ ព្រះអានន្ទមានអាយុ បានឃើញផ្លូវបែកជាពីរ ត្រង់ពាក់កណ្តាលផ្លូវ លុះបានឃើញហើយ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះមានព្រះភាគដ៏ចំរើន នេះផ្លូវ យើងទៅតាមផ្លូវនេះ ។ កាលព្រះអានន្ទមានអាយុ ក្រាបទូលយ៉ាងនេះហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ នេះផ្លូវ យើងទៅតាមផ្លូវនេះវិញ ។ ព្រះអានន្ទមានអាយុ ក្រាបបង្គំទូលព្រះមានព្រះភាគ អស់វារៈពីរដងថា បពិត្រព្រះមានព្រះភាគ ដ៏ចំរើន នេះផ្លូវ យើងទៅតាមផ្លូវនេះ ។ ព្រះមានព្រះភាគ ទ្រង់ ត្រាស់នឹងព្រះអានន្ទមានអាយុ អស់វារៈពីរដងថា ម្នាលអានន្ទ នេះផ្លូវ យើងទៅតាមផ្លូវនេះវិញ ។ ព្រះអានន្ទមានអាយុ ក្រាបបង្គំទូលព្រះមានព្រះភាគ អស់វារៈបីដងថា បពិត្រព្រះមានព្រះភាគ ដ៏ចំរើន នេះផ្លូវ យើងទៅតាមផ្លូវនេះ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះ អានន្ទមានអាយុ អស់វារៈបីដងថា ម្នាលអានន្ទ នេះផ្លូវ

ឥមិនា គច្ឆាមាតិ ។ អថខោ អាយស្មា នាគសមាលោ ភគវតោ បត្តចីវរំ ឆមាយំ និក្ខិបិត្វា បក្កាមិ ឥទំ ភន្តេ ភគវា បត្តចីវរន្តិ ។ អថខោ អាយស្មតោ នាគសមាលស្ស តេន មគ្គេន គច្ឆន្តស្ស អន្តរាមគ្គេ ចោរា និក្ខមិត្វា ហត្ថេហិ ច បាទេហិ ច អាកោដេសុំ បត្តញ្ច ភិន្ទឹសុ សង្ឃាដិញ្ច វិប្ផាលេសុំ ។ អថខោ អាយស្មា នាគសមាលោ ភិន្នេន បត្តេន វិប្ផាលិតាយ សង្ឃាដិយា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា នាគសមាលោ[១] ភគវន្តំ ឯតទវោច ឥធ មយ្ហំ ភន្តេ តេន មគ្គេន គច្ឆន្តស្ស អន្តរាមគ្គេ ចោរា និក្ខមិត្វា ហត្ថេហិ ច បាទេហិ ច អាកោដេសុំ បត្តញ្ច ភិន្ទឹសុ សង្ឃាដិញ្ច វិប្ផាលេសុន្តិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

សទ្ធិំ ចរមេកតោ វសំ មិស្សោ អញ្ញជនេហិ វេទគូ
វិទ្វា បជហាតិ បាបកំ កោញ្ចោ ខីរបកោវ និន្នកន្តិ ។

សត្តមំ[២] ។

១ ឱ.ម. [illegible] ។ ២ ឱ.ម. [illegible] ។



យើងទៅតាមផ្លូវនេះវិញ ។ គ្រានោះ ព្រះនាគសមាល ដ៏មានអាយុ ដាក់បាត្រនិងចីវរ របស់ព្រះមានព្រះភាគ លើផែនដី ក្នុងផ្លូវនោះឯង ហើយចេញទៅ ដោយពាក្យថា បពិត្រព្រះមានព្រះភាគ ដ៏ចំរើន នេះបាត្រនិងចីវរ ។ លំដាប់នោះ កាលព្រះនាគសមាល ដ៏មានអាយុ ដើរទៅតាមផ្លូវនោះ ពួកចោរ ក្រឡឹបផ្លូវ ចេញមក វាយតប់ដោយដៃខ្លះ ជើងខ្លះ ហើយបំបែកបាត្រ ហែកចាំងសង្ឃាដិទាល ។ លំដាប់នោះ ព្រះនាគសមាលដ៏មានអាយុ កាលបើបាត្របែក រហែកសង្ឃាដិហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់ ក្នុងទីសមគួរ ។ លុះព្រះនាគសមាល ដ៏មានអាយុ គង់ក្នុងទីសមគួរហើយ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គ ដើរទៅតាមផ្លូវនោះ ពួកចោរក្រឡឹបផ្លូវ ស្រាប់តែចេញមក វាយតប់ដោយដៃខ្លះ ជើងខ្លះ បំបែកបាត្រ ហែកចាំងសង្ឃាដិទាលអស់ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

បុគ្គលអ្នកដល់ នូវវេទ គឺមគ្គផល ជាអ្នកប្រាជ្ញ កាលត្រាច់ទៅជាមួយ
(នឹងជនពាល) ឬនៅច្រឡំដោយជនដទៃ រមែងលះបង់នូវបាបកម្មបាន
ដូចសត្វក្រៀលផឹកនូវទឹកដោះស្រស់លះបង់ទឹកស្អុយ ។ សូត្រទី ៧ ។

(១៨៦) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ បុព្វារាមេ មិគារមាតុ បាសាទេ ។ តេន ខោ បន សមយេន វិសាខាយ មិគារមាតុយា នត្តា កាលកតា ហោតិ បិយា មនាបា ។ អថខោ វិសាខា មិគារមាតា អល្លវត្ថា អល្លកេសា ទិវាទិវស្ស យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ វិសាខំ មិគារមាតរំ ភគវា ឯតទវោច ហន្ទ កុតោ នុ ត្វំ វិសាខេ អាគច្ឆសិ អល្លវត្ថា អល្លកេសា ឥធូបសង្កន្តា ទិវាទិវស្សាតិ ។ នត្តា មេ ភន្តេ បិយា មនាបា កាលកតា តេនាហំ អល្លវត្ថា អល្លកេសា ឥធូបសង្កន្តា ទិវាទិវស្សាតិ ។ ឥច្ឆេយ្យាសិ ត្វំ វិសាខេ យាវតិកា សាវត្ថិយា មនុស្សា តាវតិកេ បុត្តេ ច នត្តារោ ចាតិ ។ ឥច្ឆេយ្យាហំ ភគវា យាវតិកា សាវត្ថិយា មនុស្សា តាវតិកេ បុត្តេ ច នត្តារោ ចាតិ ។ កីវពហុកា បន វិសាខេ សាវត្ថិយា មនុស្សា ទេវសិកំ កាលំ ករោន្តីតិ ។ ទសបិ ភន្តេ សាវត្ថិយា មនុស្សា ទេវសិកំ កាលំ ករោន្តិ



[១៨៦] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅលើប្រាសាទរបស់មិគារមាតា ក្នុងបុព្វារាម ជិតក្រុងសាវត្ថី ។ សម័យនោះឯង ចៅស្រីជាទីស្រឡាញ់គាប់ចិត្ត របស់នាងវិសាខាមិគារមាតា ធ្វើមរណកាល ។ គ្រានោះ វិសាខាមិគារមាតា មានសំពត់សើម សក់សើម ចូលទៅគាល់ព្រះមានព្រះភាគ ក្នុងវេលាថ្ងៃត្រង់ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយ ក្នុងទីសមគួរ ។ លុះនាងវិសាខាមិគារមាតា អង្គុយ ក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលវិសាខា ឥឡូវនេះ នាងមកពីណា មានសំពត់សើម សក់សើម ចូលមកក្នុងទីនេះ ទាំងថ្ងៃត្រង់ ។ បពិត្រព្រះអង្គដ៏ចំរើន ចៅស្រីជាទីស្រឡាញ់ គាប់ចិត្តរបស់ខ្ញុំព្រះអង្គ ធ្វើមរណកាល ព្រោះហេតុនោះ បានជាខ្ញុំព្រះអង្គ មានសំពត់សើម សក់សើម ចូលមកក្នុងទីនេះ ទាំងថ្ងៃត្រង់ ។ ម្នាលវិសាខា មនុស្សក្នុងក្រុងសាវត្ថី មានចំនួនប៉ុន្មាន នាងចង់បានកូននិងចៅចំនួនប៉ុណ្ណោះឬ ។ បពិត្រព្រះមានព្រះភាគដ៏ចំរើន មនុស្សក្នុងក្រុងសាវត្ថីមានចំនួនប៉ុន្មាន ខ្ញុំព្រះអង្គចង់បានកូននិងចៅចំនួនប៉ុណ្ណោះ ។ ម្នាលវិសាខា ចុះមនុស្សទាំងឡាយ ក្នុងក្រុងសាវត្ថីជាច្រើន តែងធ្វើមរណកាលរាល់ ៗ ថ្ងៃប៉ុន្មាននាក់ ។ បពិត្រព្រះអង្គដ៏ចំរើន មនុស្សក្នុងក្រុងសាវត្ថី ធ្វើមរណកាលរាល់ៗ ថ្ងៃ ១០ នាក់ខ្លះ

នវបិ ភន្តេ សាវត្ថិយា មនុស្សា ទេវសិកំ កាលំ ករោន្តិ អដ្ឋបិ ភន្តេ សាវត្ថិយា មនុស្សា ទេវសិកំ កាលំ ករោន្តិ សត្តបិ ភន្តេ សាវត្ថិយា មនុស្សា ទេវសិកំ កាលំ ករោន្តិ ឆបិ ភន្តេ សាវត្ថិយា មនុស្សា ទេវសិកំ កាលំ ករោន្តិ បញ្ចបិ ភន្តេ សាវត្ថិយា មនុស្សា ទេវសិកំ កាលំ ករោន្តិ ចត្តារោបិ ភន្តេ សាវត្ថិយា មនុស្សា ទេវសិកំ កាលំ ករោន្តិ តយោបិ ភន្តេ សាវត្ថិយា មនុស្សា ទេវសិកំ កាលំ ករោន្តិ ទ្វេបិ ភន្តេ សាវត្ថិយា មនុស្សា ទេវសិកំ កាលំ ករោន្តិ ឯកោបិ ភន្តេ សាវត្ថិយា មនុស្សា ទេវសិកំ កាលំ ករោតិ អវិវិត្តា ភន្តេ សាវត្ថី មនុស្សេហិ កាលំ ករោន្តេហីតិ ។ តំ កិំ មញ្ញសិ វិសាខេ អបិ នុ ត្វំ កទាចិ ករហចិ អល្លវត្ថា[១] វា អល្លកេសា[២] វាតិ ។ នោ ហេតំ ភន្តេ អលំ មេ ភន្តេ តាវ ពហុកេហិ បុត្តេហិ ច នត្តារេហិ ចាតិ ។ យេសំ ខោ វិសាខេ

១ ម.ម. អនល្លវត្ថា ។ ២ ម.ម. អនល្លកេសា ។



បពិត្រព្រះអង្គដ៏ចំរើន មនុស្សក្នុងក្រុងសាវត្ថី ធ្វើមរណកាលរាល់ៗថ្ងៃ ៩ នាក់ខ្លះ បពិត្រព្រះអង្គដ៏ចំរើន មនុស្សក្នុងក្រុងសាវត្ថី ធ្វើមរណកាលរាល់ៗថ្ងៃ ៨ នាក់ខ្លះ បពិត្រព្រះអង្គដ៏ចំរើន មនុស្សក្នុងក្រុងសាវត្ថី ធ្វើមរណកាលរាល់ៗថ្ងៃ ៧ នាក់ខ្លះ បពិត្រព្រះអង្គដ៏ចំរើន មនុស្សក្នុងក្រុងសាវត្ថី ធ្វើមរណកាលរាល់ៗថ្ងៃ ៦ នាក់ខ្លះ បពិត្រព្រះអង្គដ៏ចំរើន មនុស្សក្នុងក្រុងសាវត្ថី ធ្វើមរណកាលរាល់ៗថ្ងៃ ៥ នាក់ខ្លះ បពិត្រព្រះអង្គដ៏ចំរើន មនុស្សក្នុងក្រុងសាវត្ថី ធ្វើមរណកាលរាល់ៗថ្ងៃ ៤ នាក់ខ្លះ បពិត្រព្រះអង្គដ៏ចំរើន មនុស្សក្នុងក្រុងសាវត្ថី ធ្វើមរណកាលរាល់ៗថ្ងៃ ៣ នាក់ខ្លះ បពិត្រព្រះអង្គដ៏ចំរើន មនុស្សក្នុងក្រុងសាវត្ថី ធ្វើមរណកាលរាល់ៗថ្ងៃ ២ នាក់ខ្លះ បពិត្រព្រះអង្គដ៏ចំរើន មនុស្សក្នុងក្រុងសាវត្ថី ធ្វើមរណកាលរាល់ៗថ្ងៃ តែម្នាក់ខ្លះ បពិត្រព្រះអង្គដ៏ចំរើន ពួកមនុស្សក្នុងក្រុងសាវត្ថី រមែងធ្វើមរណកាលមិនដែលស្ងាត់ទេ ។ ម្នាលវិសាខា នាងសំគាល់ហេតុនោះដូចម្តេច ចុះនាងជាអ្នកមានសំពត់សើម សក់សើម ក្នុងកាលខ្លះរឺទេ ។ បពិត្រព្រះអង្គដ៏ចំរើន ដំណើរនុ៎ះ មិនមែនដូច្នោះទេ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ លុះត្រឹមតែកូននឹងចៅច្រើនប៉ុណ្ណោះ ។ ម្នាលវិសាខា បុគ្គលណា

សតំ បិយានិ សតំ តេសំ ទុក្ខានិ យេសំ នវុតិ បិយានិ នវុតិ តេសំ ទុក្ខានិ យេសំ អសីតិ បិយានិ អសីតិ តេសំ ទុក្ខានិ យេសំ សត្តតិ បិយានិ សត្តតិ តេសំ ទុក្ខានិ យេសំ សដ្ឋី បិយានិ សដ្ឋី តេសំ ទុក្ខានិ យេសំ បញ្ញាសំ បិយានិ បញ្ញាសំ តេសំ ទុក្ខានិ យេសំ ចត្តាឡីសំ បិយានិ ចត្តាឡីសំ តេសំ ទុក្ខានិ យេសំ តឹសំ បិយានិ តឹសំ តេសំ ទុក្ខានិ យេសំ វីសំ[១] បិយានិ វីសំ[១] តេសំ ទុក្ខានិ យេសំ ទស បិយានិ ទស តេសំ ទុក្ខានិ យេសំ នវ បិយានិ នវ តេសំ ទុក្ខានិ យេសំ អដ្ឋ បិយានិ អដ្ឋ តេសំ ទុក្ខានិ យេសំ សត្ត បិយានិ សត្ត តេសំ ទុក្ខានិ យេសំ ឆ បិយានិ ឆ តេសំ ទុក្ខានិ យេសំ បញ្ច បិយានិ បញ្ច តេសំ ទុក្ខានិ យេសំ ចត្តារិ បិយានិ ចត្តារិ តេសំ ទុក្ខានិ យេសំ តីណិ បិយានិ តីណិ តេសំ ទុក្ខានិ យេសំ

---
១-១ ម. វីសតិ ។





មានវត្ថុជាទីស្រឡាញ់ ១០០ បុគ្គលនោះ មានសេចក្តីទុក្ខ ១០០ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ៩០ បុគ្គលនោះ មានសេចក្តីទុក្ខ ៩០ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ៨០ បុគ្គលនោះ មានសេចក្តីទុក្ខ ៨០ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ៧០ បុគ្គលនោះ មានសេចក្តីទុក្ខ ៧០ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ៦០ បុគ្គលនោះ មានសេចក្តីទុក្ខ ៦០ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ៥០ បុគ្គលនោះ មានសេចក្តីទុក្ខ ៥០ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ៤០ បុគ្គលនោះ មានសេចក្តីទុក្ខ ៤០ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ៣០ បុគ្គលនោះ មានសេចក្តីទុក្ខ ៣០ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ២០ បុគ្គលនោះ មានសេចក្តីទុក្ខ ២០ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ១០ បុគ្គលនោះ មានសេចក្តីទុក្ខ ១០ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ៩ បុគ្គលនោះ មានសេចក្តីទុក្ខ ៩ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ៨ បុគ្គលនោះ មានសេចក្តីទុក្ខ ៨ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ៧ បុគ្គលនោះ មានសេចក្តីទុក្ខ ៧ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ៦ បុគ្គលនោះ មានសេចក្តីទុក្ខ ៦ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ៥ បុគ្គលនោះ មានសេចក្តីទុក្ខ ៥ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ៤ បុគ្គលនោះ មានសេចក្តីទុក្ខ ៤ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ៣ បុគ្គលនោះ មានសេចក្តីទុក្ខ ៣ បុគ្គលណា

ទ្វេ បិយានិ ទ្វេ តេសំ ទុក្ខានិ យេសំ ឯកំ បិយំ ឯកំ តេសំ ទុក្ខំ យេសំ នត្ថិ បិយំ នត្ថិ តេសំ ទុក្ខំ អសោកា តេ វិរជា អនុបាយាសាតិ វទាមីតិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

យេ កេចិ សោកា បរិទេវិតា វា
ទុក្ខា ច លោកស្មឹ អនេករូបា
បិយំ បដិច្ច បភវន្តិ ឯតេ
បិយេ អសន្តេ ន ភវន្តិ ឯតេ ។
តស្មា ហិ តេ សុខិនោ វីតសោកា
យេសំ បិយំ នត្ថិ កុហិញ្ចិ លោកេ
តស្មា អសោកំ វិរជំ បត្ថយានោ
បិយំ ន កយិរាថ កុហិញ្ចិ លោកេតិ ។

អដ្ឋមំ(១) ។

[១៩៧] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជ-គហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ អថខោ

១ ឧ.ម. អដ្ឋមំ នត្ថិ ។



មានវត្ថុជាទីស្រឡាញ់ ២ បុគ្គលនោះ មានសេចក្តីទុក្ខ ២ បុគ្គលណា មានវត្ថុជាទីស្រឡាញ់ ១ បុគ្គលនោះ មានសេចក្តីទុក្ខ ១ បុគ្គលណា មិនមានវត្ថុជាទីស្រឡាញ់ បុគ្គលនោះ ក៏មិនមានសេចក្តីទុក្ខសោះឡើយ តថាគត ទើបពោលថា បុគ្គលទាំងនោះ ជាអ្នកមិនមានសោក ជាបុគ្គលប្រាសចាកធូលីគឺកិលេស ជាអ្នកមិនមានសេចក្តីចង្អៀតចង្អល់ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

សេចក្តីសោកក្តី សេចក្តីខ្សឹកខ្សួលក្តី ណាមួយ ឬសេចក្តីទុក្ខ ជាច្រើនយ៉ាង ក្នុងលោក ធម៌ទាំងនុ៎ះ រមែងកើតឡើង ព្រោះអាស្រ័យសត្វនិងសង្ខារជាទីស្រឡាញ់ កាលបើមិនមានសត្វនិងសង្ខារ ជាទីស្រឡាញ់ ធម៌ទាំងនុ៎ះ ក៏រមែងមិនមាន ។ ព្រោះហេតុនោះឯង បុគ្គលណា មិនមានសត្វនិងសង្ខារ ជាទីស្រឡាញ់ ក្នុងលោកណាមួយទេ បុគ្គលនោះ ទើបមានសេចក្តីសុខ ប្រាសចាកសេចក្តីសោក ព្រោះថា បុគ្គលប្រាថ្នាសេចក្តីមិនសោក និងការប្រាសចាកធូលីគឺកិលេស មិនគប្បីធ្វើសត្វនិងសង្ខារ ឲ្យជាទីស្រឡាញ់ ក្នុងលោកណាមួយឡើយ ។ សូត្រទី ៨ ។

(១៩៧) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ គ្រានោះឯង

អាយស្មា ទព្វោ មល្លបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា ទព្វោ មល្លបុត្តោ ភគវន្តំ ឯតទវោច បរិនិព្វានកាលោ មេ ទានិ សុគ-តាតិ ។ យស្សទានិ ត្វំ ទព្វ កាលំ មញ្ញសីតិ ។ អថខោ អាយស្មា ទព្វោ មល្លបុត្តោ ឧដ្ឋាយាសនា ភគវន្តំ អភិ-វាទេត្វា បទក្ខិណំ កត្វា វេហាសំ អព្ភុគ្គន្ត្វា អាកាសេ អន្តលិក្ខេ បល្លង្កេន និសីទិត្វា តេជោធាតុំ សមាបជ្ជិ-ត្វា វុដ្ឋហិត្វា បរិនិព្វាយិ ។ អថខោ អាយស្មតោ ទព្វ-ស្ស មល្លបុត្តស្ស វេហាសំ អព្ភុគ្គន្ត្វា អាកាសេ អន្ត-លិក្ខេ បល្លង្កេន និសីទិត្វា តេជោធាតុំ សមាបជ្ជិត្វា វុដ្ឋហិត្វា បរិនិព្វុតស្ស សរីរស្ស ឈាយមានស្ស ឌយ្ហ-មានស្ស នេវ ឆារិកា បញ្ញាយតិ(១) ន មសិ(២) ។ សេយ្យថាបិ នាម សប្បិស្ស វា តេលស្ស វា ឈាយមា-នស្ស ឌយ្ហមានស្ស នេវ ឆារិកា បញ្ញាយតិ ន មសិ ឯវមេវ អាយស្មតោ ទព្វស្ស មល្លបុត្តស្ស វេហាសំ អព្ភុគ្គន្ត្វា អាកាសេ អន្តលិក្ខេ បល្លង្កេន និសីទិត្វា

១ ម.ម. បញ្ញាយិត្ថ ។ ២ ម. មសិ ។



ព្រះទព្វមល្លបុត្តដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយ ក្នុងទីសមគួរ ។ លុះព្រះទព្វមល្លបុត្តដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះសុគត ឥឡូវនេះ ជាកាលគួរបរិនិព្វាន របស់ខ្ញុំព្រះអង្គ ។ ម្នាលទព្វៈ អ្នកសំគាល់កាលគួរនឹងបរិនិព្វាន ក្នុងកាលឥឡូវនេះចុះ ។ គ្រានោះ ព្រះទព្វមល្លបុត្តដ៏មានអាយុ ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហោះទៅឯអាកាស អង្គុយពែនភ្នែន ក្នុងអាកាសដ៏ស្រឡះ ចូលកាន់តេជោធាតុ ចេញហើយទើបបរិនិព្វាន ។ កាលព្រះទព្វមល្លបុត្តដ៏មានអាយុ ហោះទៅឯអាកាស អង្គុយពែនភ្នែន ក្នុងអាកាសដ៏ស្រឡះ ចូលកាន់តេជោធាតុ ចេញហើយ បរិនិព្វាន សរីរៈ បណ្តាលភ្លើងឆាបឆេះ ផេះក៏មិនប្រាកដ ធ្យូងក៏មិនប្រាកដ ។ ដូចសប្បិឬប្រេង កាលបើភ្លើងឆាបឆេះ ផេះក៏មិនប្រាកដ ធ្យូងក៏មិនប្រាកដ យ៉ាងណា កាលព្រះទព្វមល្លបុត្តដ៏មានអាយុ ហោះទៅឯអាកាស អង្គុយពែនភ្នែន ក្នុងអាកាសដ៏ស្រឡះ

តេជោធាតុំ សមាបជ្ជិត្វា វុដ្ឋហិត្វា បរិនិព្វុតស្ស សរីរស្ស ឈាយមានស្ស ទយ្ហមានស្ស នេវ ឆារិកា បញ្ញាយិត្ថ ន មសិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

អភេជ្ជិ កាយោ និរោធិ សញ្ញា វេទនា បីតិទហំសុ[១] សព្វា
វូបសមឹសុ សង្ខារា វិញ្ញាណំ អត្ថមាគមាតិ ។ នវមំ[២] ។

(១៧៨) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច ទព្វស្ស ភិក្ខវេ មល្លបុត្តស្ស វេហាសំ អព្ភុគ្គន្ត្វា អាកាសេ អន្តលិក្ខេ បល្លង្កេន និសីទិត្វា តេជោធាតុំ សមាបជ្ជិត្វា វុដ្ឋហិត្វា បរិនិព្វុតស្ស សរីរស្ស ឈាយមានស្ស ទយ្ហមានស្ស នេវ ឆារិកា បញ្ញាយិត្ថ ន មសិ សេយ្យថាបិ នាម សប្បិស្ស វា តេលស្ស វា ឈាយមានស្ស ទយ្ហមានស្ស នេវ ឆារិកា បញ្ញាយតិ ន មសិ ឯវមេវ ភិក្ខវេ ទព្វស្ស មល្លបុត្តស្ស វេហាសំ អព្ភុគ្គន្ត្វា

១ បរាតសីកាបុត្ថកេ ទព្វកាយំ ។ ២ ម.ម. នវមំ សុត្តំ ។



ចូលកាន់តេជោធាតុ ចេញហើយបរិនិព្វាន សរីរៈ ក៏បណ្ដាលភ្លើង ឆាបឆេះ ផេះផង់ក៏មិនប្រាកដ កំទេចធាតុ ក៏មិនប្រាកដ យ៉ាងនោះដែរ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្ដីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

រីឯកាយ ( របស់ទព្វមល្លបុត្ត ) បែកធ្លាយហើយ សញ្ញាក៏
រលត់ វេទនាទាំងអស់ ក៏ត្រជាក់ សង្ខារទាំងឡាយ ក៏
ស្ងប់រម្ងាប់ វិញ្ញាណក៏ដល់នូវសេចក្ដីវិនាស ។ សូត្រទី៩ ។

(១៧៨) ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលស្ដាប់ព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលទព្វមល្លបុត្ត ហោះទៅឯអាកាស អង្គុយពែនភ្នែន ក្នុងអាកាសដ៏ប្រឡះ ចូលកាន់តេជោធាតុ ចេញហើយបរិនិព្វាន សរីរៈ បណ្ដាលភ្លើងឆាបឆេះ ផេះក៏មិនប្រាកដ កំទេចធាតុក៏មិនប្រាកដ ដូចសប្បិប្រេង កាលបើភ្លើងឆាបឆេះផេះក៏មិនប្រាកដ កំទេចក៏មិនប្រាកដ យ៉ាងណា ម្នាលភិក្ខុទាំងឡាយ កាលទព្វមល្លបុត្ត ហោះទៅឯអាកាស

អាកាសេ អន្តលិក្ខេ បល្លង្កេន និសីទិត្វា តេជោធាតុំ សមាបជ្ជិត្វា បរិនិព្វុតស្ស សរីរស្ស ឈាយមានស្ស ឌយ្ហមានស្ស នេវ ឆារិកា បញ្ញាយិត្ថ ន មសិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

អយោឃនហតស្សេវ ជលតោ ជាតវេទស្ស
អនុបុព្វូបសន្តស្ស យថា ន ញាយតេ គតិ
ឯវំ សម្មាវិមុត្តានំ កាមពន្ធោឃតារិនំ
បញ្ញាបេតុំ គតិ នត្ថិ បត្តានំ អចលំ សុខន្តិ ។

ទសមំ[1] ។

បាដលិគាមិយវគ្គោ អដ្ឋមោ ។

## តស្សុទ្ទានំ

និព្វាណា ចតុរោ វុត្តា ចុន្ទោ បាដលិគាមិយា
ទ្វិធាបថោ វិសាខា ច ទព្វេន ច សហ តេ ទសាតិ ។

១ ម.ឆ. សោឡសមំ? ។



អង្គុយក្នុងអាកាសដ៏ស្រឡះ ចូលកាន់តេជោធាតុ ចេញហើយ បរិនិព្វាន សរីរៈ កំពុងកាលភ្លើងឆាបឆេះ ទាំងផេះ ក៏មិនប្រាកដ កំទេចធាតុ ក៏មិនប្រាកដ យ៉ាងនោះឯង ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបសេចក្ដីនុ៎ះហើយ ទើបបន្លឺឧទាននេះ ក្នុងវេលានោះថា

បុគ្គល រមែងមិនដឹងគតិ របស់ភ្លើងកំពុងឆេះ គឺដុំដែកដែលគេដំ ហើយ ដែលរលត់ទៅ ដោយលំដាប់ យ៉ាងណាមិញ គតិរបស់ ពួកលោក អ្នករួចស្រឡះចាកកិលេស ដោយប្រពៃ អ្នកឆ្លងចាក ចំណងគឺកាម និងឱឃៈគឺកាម ដល់នូវសេចក្ដីសុខ មិនញាប់ញ័រ រមែង មិនគួរបញ្ញត្ត ក៏យ៉ាងនោះដែរ ។ សូត្រ ទី ១០ ។

ចប់ បាដលិគាមិយវគ្គ ទី ៨ ។

## ឧទ្ទាននៃវគ្គនោះ គឺ

ពោលអំពីព្រះនិព្វាន ៤ លើក អំពីចុន្ទកម្មារបុត្ត ១ អំពីពួកឧបាសក បាដលិគាម អ្នកធ្វើសក្ការៈ ១ អំពីផ្លូវបែកជាពីរ ១ អំពីនាងវិសាខា ១ ព្រមទាំងព្រះទព្វមល្លបុត្ត ២ លើក រួមជា ១០ ។

វគ្គមិទំ បឋមំ វរំ ពោធិ
វគ្គមិទំ ទុតិយោ(១) មុចលិន្ទោ
នន្ទកវគ្គវរោ តតិយោ
មេឃិយវគ្គវរោ(២) ចតុត្ថោ
បញ្ចមវគ្គវរន្តិ សោណោ
ឆដ្ឋមវគ្គវរន្តិ ជច្ចន្ធោ
សត្តមវគ្គវរន្តិ ច ចូឡោ
បាដលិគាមិយវរដ្ឋមវគ្គោ(៣) ។
អសីតិមនូនកសុត្តំ(៤)
វគ្គមិទដ្ឋមំ សុវិភត្តំ
ទស្សិតំ ចក្ខុមតា វិមលេន
សទ្ធា ហិ តំ ឧទានមិតិទមាហុ(៥) ។

ឧទានំ សមត្តំ ។

១ ម. មុចលិន្ទ ចតុត្ថោ ។ ២ ម. ច សោណោ ឆដ្ឋមវគ្គវរំ ជច្ចន្ធោ ។ ៣ ម. បាដលិគាមិយវគ្គោ ។ ៤ ម. អសីតិមនូនកសុត្តំ វគ្គមិទដ្ឋមំ ។ ៥ ម. សញ្ញិតំ ឧទានមិតិទមាហុ ។



ពោធិវគ្គដ៏ប្រសើរ ជាវគ្គទី ១ មុចលិន្ទវគ្គ ជាវគ្គទី ២ នន្ទវគ្គដ៏ប្រសើរ ជាវគ្គទី ៣ មេឃិយវគ្គដ៏ប្រសើរ ជាវគ្គទី ៤ សោណត្ថេរវគ្គ ដ៏ប្រសើរ ជាវគ្គទី ៥ ជច្ចន្ធវគ្គដ៏ប្រសើរ ជាវគ្គទី ៦ ចូឡវគ្គ ដ៏ប្រសើរ ជាវគ្គទី ៧ បាដលិគាមិយវគ្គ ដ៏ប្រសើរ ជាវគ្គទី ៨ ។ វគ្គទាំង ៨ នេះមានសូត្រ ដ៏ប្រសើរ ៨០ មិនខ្វះ ដែលលោកលើកទុកហើយ ដោយប្រពៃមែនពិត ព្រះសូត្រណា ដែលព្រះសម្ពុទ្ធ ប្រាសចាកមន្ទិល មានចក្ខុ ទ្រង់សំដែងហើយ បណ្ឌិតទាំងឡាយ អ្នកមានសញ្ញា ចុន ពោលព្រះសូត្រនោះ ថាជាឧទាន ។

ចប់ ឧទាន ។